# អដ្ឋកថា ព្រះសុត្តន្តបិដក

## ធម្មបទដ្ឋកថា
## តតិយភាគ

## ភាគ ៥២

ពុទ្ធសករាជ ២៥៥៩

# អដ្ឋកថា ព្រះសុត្តន្តបិដក

## ខុទ្ទកនិកាយ គាថាធម្មបទ

ឈ្មោះ

## ធម្មបទដ្ឋកថា

## តតិយភាគ

## ភាគ ៥២

ពុទ្ធសករាជ ២៥៥៥

អធិប្បាយ

គាថាធម្មបទ មាន៩វគ្គ

បាបវគ្គ ទណ្ឌវគ្គ ជរាវគ្គ អត្តវគ្គ លោកវគ្គ ពុទ្ធវគ្គ

សុខវគ្គ បិយវគ្គ កោធវគ្គ

# គាថាធម្មបទ

## តតិយភាគ រួមមាន ៩ វគ្គ

### ១-បាបវគ្គ មាន ១២ រឿង


១. រឿងចូឡេកសាដកព្រាហ្មណ៍ ២. រឿងព្រះសេយ្យសកត្ថេរ
៣. រឿងនាងលាជធីតា ៤. រឿងអនាថបិណ្ឌិកសេដ្ឋី
៥. រឿងភិក្ខុមិនចេះទុកដាក់បរិក្ខារ ៦. រឿងសេដ្ឋីជើងឆ្មា
៧. រឿងមហាធនពាណិជ្ជ ៨. រឿងព្រាហ្មណ៍កុក្កុដមិត្រ
៩. រឿងព្រាហ្មណ៍សុនខឈ្មោះកោកៈ ១០. រឿងព្រះតិស្សៈចូលកាន់ត្រកូលជាងកែវមណី
១១. រឿងជន ៣ នាក់ ១២. រឿងព្រះចាទសុប្បពុទ្ធសក្យៈ


### ២-ទណ្ឌវគ្គ មាន ១១ រឿង


១. រឿងភិក្ខុឆព្វគ្គិយៈ ២. រឿងភិក្ខុឆព្វគ្គិយៈ
៣. រឿងក្មេងច្រើននាក់ ៤. រឿងព្រះកោណ្ឌធានត្ថេរ
៥. រឿងឧបោសថកម្ម ៦. រឿងអជគរប្រេត
៧. រឿងព្រះមហាមោគ្គល្លាន ៨. រឿងភិក្ខុមានភណ្ឌៈច្រើន
៩. រឿងសន្តតិមហាមាត្យ ១០. រឿងព្រះលោតិកត្ថេរ
១១. រឿងសុខសាមណេរ


### ៣-ជរាវគ្គ មាន ០៩ រឿង


១. រឿងស្ត្រីសំឡាញ់នាងវិសាខា ២. រឿងនាងសិរិមា
៣. រឿងព្រះនាងឧត្តរាថេរី ៤. រឿងព្រះអធិមានិកភិក្ខុ
៥. រឿងព្រះនាងរូបនន្ទាថេរី ៦. រឿងព្រះនាងមល្លិកាទេវី
៧. រឿងព្រលោឡុទាយី ៨. រឿងបឋមពោធិកាល
៩. រឿងបុត្តសេដ្ឋីមានទ្រព្យច្រើន

## **៤-អត្តវគ្គ** មាន ១០ រឿង

១.រឿងពោធិរាជកុមារ
២.រឿងព្រះឧបនន្ទសក្យបុត្ត
៣.រឿងព្រះបធានិកតិស្សត្ថេរ
៤.រឿងមាតារបស់ព្រះកុមារកស្សបៈ
៥.រឿងមហាកាលឧបាសក
៦.រឿងព្រះទេវទត្ត
៧.រឿងការបំបែកសង្ឃ
៨.រឿងព្រះកាលត្ថេរ
៩.រឿងចុល្លកាលឧបាសក
១០.រឿងព្រះអត្តទត្ថត្ថេរ

## **៥-លោកវគ្គ** មាន ១១ រឿង

១.រឿង ភិក្ខុកំលោះ
២.រឿង ព្រះបាទសុទ្ធោទនៈ
៣.រឿង ភិក្ខុអ្នកចម្រើនវិបស្សនា
៤.រឿង អភយរាជកុមារ
៥.រឿង ព្រះសម្មជ្ជនត្ថេរ:
៦.រឿង ព្រះអង្គុលិមាល
៧.រឿង ធីតានាយជាងតម្បាញ
៨.រឿង ភិក្ខុ ៣០ រូប
៩.រឿង នាងចិញ្ចាមាណវិកា
១០.រឿង អសទិសទាន
១១.រឿង នាយកាលៈបុត្តអនាថបិណ្ឌិកសេដ្ឋី

## **៦-ពុទ្ធវគ្គ** មាន ០៩ រឿង

១.រឿងមារធីតា
២.រឿងយមកបាដិហារីយ៍
៣.រឿងឯរកបត្តនាគរាជ
៤.រឿងបញ្ហារបស់ព្រះអានន្ទ
៥.រឿងភិក្ខុអ្នកមិនត្រេកអរ
៦.រឿងអគ្គិទត្តបុរោហិត
៧.រឿងបញ្ហាព្រះអានន្ទ
៨.រឿងសម្ពហុលភិក្ខុ
៩.រឿងព្រះចេតិយមាសព្រះមហាកស្សបទសពល

## ៧-សុខវគ្គ មាន ០៨ រឿង


១. រឿងការរំងាប់ជម្លោះនៃពួកព្រះញាតិ
២. រឿងមារ
៣. រឿងបរាជ័យរបស់ព្រះបាទកោសល
៤. រឿងក្មេងស្រីនៃត្រកូលមួយ
៥. រឿងឧបាសកម្នាក់
៦. រឿងព្រះបាទបសេនទិកោសល
៧. រឿងព្រះតិស្សត្ថេរ
៨. រឿងសក្កទេវរាជ


## ៨-បិយវគ្គ មាន ០៩ រឿង


១. រឿងបព្វជិត ៣ រូប
២. រឿងកុដិម្ពីក៍ម្នាក់
៣. រឿងនាងវិសាខាឧបាសិកា
៤. រឿងស្តេចលិច្ឆវី
៥. រឿងអនត្ថិគន្ធកុមារ
៦. រឿងព្រាហ្មណ៍ម្នាក់
៧. រឿងក្មេង ៥០០ នាក់
៨. រឿងព្រះអនាគាមិត្ថេរ
៩. រឿងនាយនន្ទិយៈ


## ៩-កោធវគ្គ មាន ០៨ រឿង


១. រឿងនាងរោហិណី
២. រឿងភិក្ខុមួយរូប
៣. រឿងឧត្តរាឧបាសិកា
៤. រឿងបញ្ហាព្រះមហាមោគ្គល្លាន
៥. រឿងបញ្ហាដែលភិក្ខុទូលសួរ
៦. រឿងនាងបុណ្ណទាសី
៧. រឿងអតុលឧបាសក
៨. រឿងភិក្ខុឆព្វគ្គីយ៍

# ស្រៈនិងស្រៀយ

# Signes et accents:



# ស្រះពេញតួ
# *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រ៉ូម Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien |  | | | | | | | |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

## *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក | ខ | គ | ឃ | ង |
| ឡូប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| សង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| ឡូប Romain | ṭ | ṭh | ḍ | ḍh | ṇ |
| សៀម Siamois | ฎ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ᨭ | ᨮ | ᨯ | ᨰ | ᨱ |
| លង្កា Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| [illegible] | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ᨲ | ᨳ | ᨴ | ᨵ | ᨶ |
| សិង្ហល Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| [illegible] Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ᨸ | ᨹ | ᨻ | ᨽ | ᨾ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | យ | រ | ល | វ | ស | ហ | ឡ | ំ | ។ |
| ឥរ៉ូប Romain | y | r | l | v | s | h | ḷ | ṃ | ·/. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| លង្កា Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | । |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ။ |

# ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេងៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធៗ ដែលមិនមានឈ្មោះ ពោលដល់ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តក** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ ដែលមានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភុតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភុតធម៌ទាំងអស់ ។

**វេទល្ល** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដីរីករាយ និងសួរជាបន្តៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹង នូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេងៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាម នឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថាការបានស្ដាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេងៗ គ្នា មានសីល និងទិដ្ឋិផ្សេងៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធវចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងមានឧស្សាហៈដ៏ខ្លាំង-ក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្ដីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ អាចរិយវាទ វាទៈរបស់អាចារ្យផ្សេងៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង

បុព្វាចារ្យជំនាន់ក្រោយៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទុន្មានទុកជាមួយអត្តនោមតិទៅតាមមតិរបស់ខ្លួនឯងដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនាដែលមានគោលសំខាន់ គឺ ព្រះត្រៃ-បិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយលំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។ ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះមានឱកាសដែលយល់ខុស និយាយខុស និងបដិបត្តិខុស ។

ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋ-ធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាស-និកជនដែលល្អប្រកាន់ថា ធ្វើមិនបានដូចគ្នា ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ

-៥-

សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់

ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

\

## និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណា ប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្ដាប់វត្ថុ ១០ ប្រការនោះហើយ បានកាន់យកព្រះចៅអសោករាជដែលជាព្រះឱរសរបស់ព្រះចៅសុសុនាគៈធ្វើជាសម្ងាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ (ដប់ពីរសែន) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ តិះដៀលហើយ ទើបស្វែងរកពួកគណៈ លុះបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀត ឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះៗ ឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈ ដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជាប្រាំមួយ

ត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និង វជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធ-សករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈ កើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈ ផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយនោះ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយនោះឯង ។ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

## តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




*ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្ត ជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបណ្ដេញចេញហើយ បានពួកដទៃ ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។*

*(ស្រង់ចេញពីអដ្ឋកថាបរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ)*

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងគម្ពីរនេះឡើង (គម្ពីរអដ្ឋសាលិនី) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈ អារាធនាឲ្យព្រះពុទ្ធឃោសៈតែងគម្ពីរនេះ ជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្បសាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេងៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់របួតអស់ទាំងសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្សំមកដល់វត្តមួយ ដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតៈដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមក ដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេងៗ ក្នុងគម្ពីរត្រៃវេទ ដែលខ្លួននៅមានការសង្ស័យមិនយល់ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមក ព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា ពុទ្ធមន្ត ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជា ឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្តនាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ ញាណោទ័យ ទុកក្នុងវត្ត ហើយផ្ដើមរចនាគម្ពីរអដ្ឋកថា ឈ្មោះ អដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈបានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីប មានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែនៅក្នុងលង្កាទ្វីបនៅមាន ព្រោះព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក) ជាដើមបានរចនាទុក និងតមក ព្រះមហិន្ទត្ថេរបានត្រួតពិនិត្យ ហើយរចនាទុកជា

ភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរដែលបាននិមន្តជួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះគឺ ជាកាលរបស់ក្សត្រិយ៍លង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា (សិរិនិវាស) ខ្វះ (សិរិកុឋៈ) ខ្វះ (សិរិកូដ្ឋៈ) ខ្វះ ក្នុងពុទ្ធសករាជ (៩៥២-៩៧៤) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថា ឲ្យលោករចនាជាមុន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ

ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយបាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តងទៀត គម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀប គ្នាហើយ មិនមានការខុសគ្នា ទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយ ព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬដោយព្រះបាលីទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយក៏បានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារ បានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរសោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះ ជាព្រះមេត្តេយ្យពោធិ-សត្វពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរពីភាសាសីហឡៈ មកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះមហានាមក្សត្រិយ៍នៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា ព្រះមហិន្ទត្ថេរនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ: ឈ្មោះ **មហា-អដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ (ផុះទឹក) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរីយ: ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុ-វិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡ: ដែលព្រះពុទ្ធឃោស:បានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធ: មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្ម ទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេងៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យដ៏សំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុជាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

| | |
|---|---|
| ឧបាសក ក្អាត ហ៊ន | ឧបាសក ណាក់ ម៉ៅ |
| ឧបាសក ធុំ ធួន | ឧបាសក ហុក សីងហួត |
| ឧបាសក ជីម ជំនិត | ឧបាសក កើត និត្យ |
| ឧបាសក សន ម៉ារឌី | ឧបាសក ហាយ ចំរើន |
| ឧបាសក អ៊ឹម វ៉ៃយ៉ា | ឧបាសក សុក្រ ហ៊ត |
| ឧបាសក សោម រតនៈ | ឧបាសក សំ ឆាយ |
| ឧបាសក ម៉ៅ ផុន | ឧបាសក ជា ស៊ីថាន |
| ឧបាសិកា ថាប់ លឿម | ឧបាសិកា ហាយ សារ៉ាត់ |
| ឧបាសិកា ប៊ុត សុម៉ាលី | ឧបាសិកា យស សម្បត្តិ |
| ឧបាសិកា តូ ហ៊ាង | ឧបាសិកា ប៊ុត សេដាដួង |
| ឧបាសិកា ប៉ែន រមណី | |

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គធិន្នោ | នូវ ប៉ូ | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ជុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ដុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុតេជធរោ | ជាវ ជាន | ធម្មាចារ្យ |

សាមណេរ កោវិទោ ឡោះស្វៀត សមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជឹម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បី
បូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ-

ឧទ្ទិសថ្វាយ និងគោរពជូនៈ

-ព្រះមហាវរក្សត្រិយ៍ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រិយ៍នៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុជាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកគ្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ៕.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

**ឈ្មោះធម៌** **ទំព័រ**

## បាបវគ្គទី ៩


| | |
|---|---|
| ១-រឿងព្រាហ្មណ៍ឈ្មោះចូឡសាដក | ១ |
| -ព្រាហ្មណ៍ និងព្រាហ្មណីផ្លាស់ប្តូរគ្នាស្តាប់ធម៌ | ១ |
| -ទានរបស់ព្រាហ្មណ៍ ឱ្យផលទាន់ភ្នែក | ៣ |
| -ប្រញាប់ធ្វើបុណ្យឱ្យរហ័ស | ៥ |
| -អធិប្បាយគាថា | ៦ |
| ២-រឿងព្រះសេយ្យសកត្ថេរ | ៨ |
| -កម្មអាក្រក់ឱ្យទុក្ខក្នុងភពទាំងពីរ | ៨ |
| -អធិប្បាយគាថា | ៩ |
| ៣-រឿងនាងលាជទេវធីតា | ១០ |
| -ស្ត្រីថ្វាយលាជដល់ព្រះមហាកស្សបៈ | ១០ |
| -ចិត្តជ្រះថ្លាក្នុងទាន នាំកើតក្នុងសួគ៌ | ១១ |
| -ការធ្វើទិព្វសម្បត្តិឱ្យជាថាវរៈ | ១១ |
| -បុណ្យឱ្យកើតសុខក្នុងភពទាំងពីរ | ១៤ |
| -អធិប្បាយគាថា | ១៥ |
| ៤-រឿងអនាថបិណ្ឌិកសេដ្ឋី | ១៧ |
| -លោកសេដ្ឋីធំនុកបម្រុកភិក្ខុសាមណេរជានិច្ច | ១៧ |
| -បើមានចិត្តជ្រះថ្លា ទានដែលថ្វាយមិនជា... | ១៨ |
| -ទេវតាដាស់តឿនលោកសេដ្ឋី | ១៩ |
| -សក្កទេវរាជប្រាប់ឧបាយដល់ទេវតា | ២១ |
| -សេដ្ឋីបានទ្រព្យដូចដើម | ២២ |

-កាលកម្មឱ្យលបុគ្គលល្ងង់ទើបយល់ត្រូវ ២៣
-អធិប្បាយគាថា ២៤
៥-រឿងភិក្ខុមិនរក្សាបរិក្ខារ ២៧
-ត្រូវរក្សារបស់សង្ឃដែលបានប្រើហើយ ២៧
-កុំមើលងាយបាបថាតិចតួច ២៨
-អធិប្បាយគាថា ២៩
៦-រឿងពិឡាលបទកសេដ្ឋី ៣០
-ឱ្យទានខ្លួនឯង និងបបួលគេ បានសម្បត្តិពីរយ៉ាង ៣០
-បណ្ឌិតប្រកាសសេចក្ដីនៃបុណ្យ ៣១
-សេដ្ឋីឱ្យគេតាមមើលការធ្វើរបស់បុរសវៃអង្គាស ៣២
-កុំមើលងាយបុណ្យថាមានប្រមាណតិច ៣៤
-អធិប្បាយគាថា ៣៥
៧-រឿងមហាធនពាណិជ្ជ ៣៦
-ឈ្មួញនិមន្តភិក្ខុ ៥០០ ដើរផ្លូវ ៣៦
-ឈ្មួញត្រូវពួកចោរស្កាត់ផ្លូវ... ៣៧
-វត្ថុដែលគួរវៀរ ៣៩
-អធិប្បាយគាថា ៤០
៨-រឿងនាយព្រានកុក្កុដមិត្ត ៤១
-ធីតាសេដ្ឋីស្រឡាញ់ព្រានកុក្កុដមិត្ត ៤១
-កុក្កុដមិត្តអាឃាតក្នុងព្រះសម្ពុទ្ធ ៤៣
-កុក្កុដមិត្តលើកអាឃាត ៤៤
-ព្រះសោតាបន្នមិនធ្វើបាប ៤៦
-អធិប្បាយគាថា ៤៧
-បុព្វកម្មរបស់ព្រាន និងកូន កូនប្រសា ៤៨
-គតិអ្នកមិនឃើញសច្ចៈ មិនពិតប្រាកដ ៥០

៩-រឿងព្រានសុនខឈ្មោះកោកៈ ៥២

-ព្រានសម្គាល់ភិក្ខុថាជាកាឡកណ្ណី ៥២

-សុនខខាំព្រាន ៥៤

-ព្រះថេរៈសង្ស័យក្នុងសីល និងសមណធម៌ ៥៤

-បុព្វកម្មរបស់ព្រាន ៥៥

-អធិប្បាយគាថា ៥៦

១០-រឿងព្រះតិស្សៈចូលកាន់ត្រកូលជាងកែវ ៥៨

-ព្រះបាទបសេនទិកោសលបញ្ជូនកែវឱ្យជាងច្នៃ ៥៨

-ជាងកែវធ្វើទោសព្រះថេរៈព្រោះយល់ខុស ៦០

-ព្រះថេរៈឃើញទោសនៃការចូលកាន់ត្រកូល ៦១

-អធិប្បាយគាថា ៦២

១១-រឿងជន ៣ នាក់ ៦៤

-ការត្រូវភ្លើងឆេះក្នុងអាកាសស្លាប់ ៦៤

-ភរិយានាយសំពៅត្រូវទម្លាក់ទឹក ៦៥

-ភិក្ខុ ៧ រូប អត់អាហារ ៧ ថ្ងៃ ក្នុងល្អាង ៦៦

-បុព្វកម្មរបស់សត្វក្អែក ៦៧

-បុព្វកម្មរបស់ភរិយានាយសំពៅ ៦៨

-បុព្វកម្មរបស់ភិក្ខុ ៧ រូប ៧០

-បុគ្គលនៅទីណា ៗ ក៏មិនរួចចាកកម្មអាក្រក់ ៧២

-អធិប្បាយគាថា ៧២

១២-រឿងសុប្បពុទ្ធសក្យៈ ៧៤

-សុប្បពុទ្ធៈក្រែងបិទផ្លូវព្រះសាស្តា ៧៤

-សុប្បពុទ្ធៈធ្វើកម្មធ្ងន់ត្រូវដែនដីស្រូប ៧៥

-គេចផលកម្មអាក្រក់មិនរួច ៧៧

-អធិប្បាយគាថា ៧៨

-ព្រះរាជាត្រូវដែនដីស្រូបទៅកើតក្នុងអវចី ៧៨

## ទណ្ឌវគ្គទី ១០

១-រឿងភិក្ខុឆព្វគ្គីយ៍ ៨០
-ហេតុឱ្យទ្រង់បញ្ញត្តិប្បហារទានសិក្ខាបទ ៨០
-អធិប្បាយគាថា ៨១
២-រឿងភិក្ខុឆព្វគ្គីយ៍ ៨៣
-ហេតុឱ្យទ្រង់បញ្ញត្តិតលសត្តិកសិក្ខាបទ ៨៣
-អធិប្បាយគាថា ៨៤
៣-រឿងក្មេងច្រើននាក់ ៨៥
-ព្រះសាស្ដាជួបពួកក្មេងវាយពស់ ៨៥
-អធិប្បាយគាថា ៨៦
៤-រឿងព្រះកោណ្ឌធានត្ថេរៈ ៨៨
-រូបស្ត្រីជាប់តាមព្រះថេរៈគ្រប់កន្លែង ៨៨
-ទេវតាក្លែងធ្វើឱ្យព្រះថេរៈបែកគ្នា ៨៩
-រង្គាសគ្នាដោយសីល ៨៩
-ទេវតាមកកើតជាព្រះកោណ្ឌធាន ៩១
-ពួកភិក្ខុប្រាប់គ្រហស្ថឱ្យបណ្ដេញលោក ៩១
-ព្រះរាជាសាកសួរលោក ៩២
-ព្រះរាជាសន្និដ្ឋានថាជារូបស្រមោល ៩៤
-ព្រះសាស្ដាទ្រង់សាកសួរទាំងពីរខាង ៩៥
-អធិប្បាយគាថា ៩៧
៥-រឿងឧបោសថកម្ម ៩៩
-ស្ត្រីរក្សាឧបោសថបំណាច់ផលផ្សេងៗគ្នា ៩៩
-សត្វសត្វត្រូវបញ្ជូនទៅបណ្ដើរ ១០០

| | |
|---|---|
| -អធិប្បាយគាថា | ១០០ |
| ៦-រឿងអជគរប្រេត | ១០២ |
| -ព្រះមហាមោគ្គល្លានឃើញប្រេត | ១០២ |
| -ព្រះសាស្តាទ្រង់ក៏ធ្លាប់ឃើញប្រេតនោះ | ១០៣ |
| -បុព្វកម្មរបស់អជគរប្រេត | ១០៣ |
| -អធិប្បាយគាថា | ១០៨ |
| ៧-រឿងព្រះមហាមោគ្គល្លាន | ១០៩ |
| -ពួកតិរត្ថីយ៍រកឧបាយសម្លាប់លោក | ១០៩ |
| -ពួកតិរត្ថីយ៍ជួលចោរឱ្យសម្លាប់ព្រះថេរៈ | ១១០ |
| -ព្រះថេរៈប្រមូលឫទ្ធិហើយនៅគាល់ព្រះសាស្តា | ១១១ |
| -ពួកចោរត្រូវចារបុរសចាប់បាន | ១១២ |
| -បុព្វកម្មរបស់ព្រះមហាមោគ្គល្លាន | ១១៣ |
| -ផលកម្មអាក្រក់តាមឱ្យផល | ១១៥ |
| -អធិប្បាយគាថា | ១១៧ |
| ៨-រឿងភិក្ខុមានភណ្ឌៈច្រើន | ១២០ |
| -កុដុម្ពីក៏ត្រៀមវត្ថុប្រើប្រាស់មុនបួស | ១២០ |
| -ព្រះសាស្តាទ្រង់សម្តែងឱ្យមានហិរិ និងឱត្តប្បៈ | ១២១ |
| -បុព្វកម្មរបស់ភិក្ខុនោះ | ១២២ |
| -ព្រះសាស្តាប្រជុំជាតក | ១២៨ |
| -អធិប្បាយគាថា | ១២៩ |
| ៩-រឿងព្រះសន្តតិមហាមាត្យ | ១៣០ |
| -ព្រះសាស្តាព្យាករណ៍សន្តតិមហាមាត្យ | ១៣០ |
| -សន្តតិមហាមាត្យសម្រេចព្រះអរហន្ត | ១៣២ |
| -បុព្វកម្មសន្តតិមហាមាត្យ | ១៣៤ |
| -ផលនៃការដឹកនាំមហាជនបំពេញកុសល | ១៣៤ |

-សន្តតិមហាមាត្យក្រុងហៅថា... ១៣៦
-អធិប្បាយគាថា ១៣៧
១០-រឿងព្រះលោតិកត្ថេរ ១៣៩
-ព្រះអានន្ទឱ្យបិលោតិកៈបួស ១៣៩
-ព្រះបិលោតិកៈសម្រេចព្រះអរហត្ត ១៤០
-អធិប្បាយគាថា ១៤២
១១-រឿងសុខសាមណេរ ១៤៥
-គន្ធសេដ្ឋី ១៤៥
-សេដ្ឋីចំណាយទ្រព្យសាងវត្ថុផ្សេងៗ ១៤៦
-បុរសម្នាក់ឃ្លានក្នុងភត្តសេដ្ឋី ១៤៧
-បុរសនោះធ្វើការបម្រើសេដ្ឋីព្រោះភត្ត ១៤៩
-នាយភត្តភតិកៈត្រៀមបរិភោគអាហារ ១៥១
-នាយភត្តភតិកៈថ្វាយទានដល់ព្រះបច្ចេកពុទ្ធ ១៥២
-ទានដែលថ្វាយទាំងអស់មានផលច្រើន ១៥៣
-គន្ធសេដ្ឋីបែងចែកទ្រព្យឱ្យភត្តភតិកបុរស ១៥៤
-សម្បទា ៤ យ៉ាង ១៥៥
-នាយភត្តភតិកៈនៅកើតក្នុងក្រុងសាវត្ថី ១៥៧
-សាមណេរទូន្មានខ្លួន ១៥៩
-សុខសាមណេរសម្រេចព្រះអរហន្ត ១៦១
-អធិប្បាយគាថា ១៦៣

## ជរាវគ្គទី ១១

១-រឿងស្ត្រីសំឡាញ់នាងវិសាខា ១៦៥
-ស្វាមីប្រគល់ភរិយារបស់ខ្លួនឱ្យនាងវិសាខា ១៦៥
-ស្ត្រីទាំងនោះគិតរកឧបាយផឹកស្រា ១៦៦

-ទេវបុត្តមារសម្តែងកាយវិការតែមិនសម្រេច ១៦៨
-អធិប្បាយគាថា ១៦៩
-នាងវិសាខាបង្ហាញទោសសុរាដោយ..... ១៧០
២-រឿងនាងសិរិមា ១៧១
-នាងសិរិមាសម្រេចសោតាបត្តិផល ១៧១
-ភិក្ខុពណ៌នាលំអរបស់នាងសិរិមា ១៧២
-នាងសិរិមាធ្វើកាលកិរិយា ១៧៤
-សពនាងសិរិមាដាក់លក់តែមិនទាន់ថ្ងៃ ១៧៦
-អធិប្បាយគាថា ១៧៨
៣-រឿងព្រះនាងឧត្តរាថេរី ១៨០
-ព្រះនាងអត់អាហារព្រោះសេចក្តីករុណា ១៨០
-អធិប្បាយគាថា ១៨១
៤-រឿងព្រះអធិមានិកភិក្ខុ ១៨២
-ពួកភិក្ខុសម្គាល់ខុស ១៨២
-អធិប្បាយគាថា ១៨៣
២-រឿងព្រះនាងរូបនន្ទាថេរី ១៨៥
-ព្រះនាងរូបនន្ទាបួស ១៨៥
-អ្នកនគរនិយមស្តាប់ព្រះធម៌ ១៨៦
-សេចក្តីជ្រះថ្លារបស់បុគ្គល ៤ ជំពូក ១៨៦
-រូប្បមាណិកា ១៨៦
-ឃោសប្បមាណិកា ១៨៦
-លូខប្បមាណិកា ១៨៧
-ធម្មប្បមាណិកា ១៨៧
-ព្រះនាងរូបនន្ទាស្តាប់ព្រះធម៌ ១៨៧
-ព្រះសាស្តាទ្រង់សម្តែងវិបស្សនា ១៩១

-អធិប្បាយគាថា ១៩២
៦-រឿងព្រះនាងមល្លិកាទេវី ១៩៤
-ព្រះនាងធ្វើសន្ទនៈជាមួយសុនខ ១៩៤
-ព្រះនាងកើតក្នុងអវិចី ១៩៦
-ធម៌របស់សប្បុរសមិនចាស់គ្រាំគ្រាដូចរបស់ដទៃ ១៩៨
-អធិប្បាយគាថា ២០០
៧-រឿងព្រះលោឡុទាយី ២០១
-ព្រះថេរៈពោលធម៌មិនគួរ ២០១
-បុព្វកម្មរបស់ព្រះថេរៈ ២០២
-សោមទត្តនាំឪពុកចូលគាល់ព្រះរាជា ២០៣
-អ្នកមានការស្តាប់តិចដូចគោចាស់ ២០៤
-អធិប្បាយគាថា ២០៥
៨-រឿងបឋមពោធិកាល ២០៨
-ព្រះសាស្តាកម្ចាត់មារ ទ្រង់បន្លឺឧទាន ២០៨
-អធិប្បាយគាថា ២០៩
៩-រឿងសេដ្ឋីបុត្តមានទ្រព្យច្រើន ២១២
-ពួកអ្នកលេងបបួលសេដ្ឋីផឹកស្រា ២១២
-សេដ្ឋីបុត្តធ្លាក់ខ្លួនព្រោះប្រព្រឹត្តអបាយមុខ ២១៣
-សេដ្ឋីបុត្តដើរសូមទានគេ ២១៤
-អធិប្បាយគាថា ២១៦

## អត្តវគ្គទី ១២

១-រឿងពោធិរាជកុមារ ២១៩
-ពោធិរាជកុមារសាងប្រាសាទហើយគិតសម្លាប់.. ២១៩
-ជាងធ្វើគ្រុឌគេចអំពីភ័យ ២២០
-ព្រះសាស្តាមិនជាន់សំពត់ដែលក្រាល ២២១

| | |
|---|---|
| -ព្រះសាស្ដាត្រាស់ហេតុដែលទ្រង់មិនជាន់ | ២២២ |
| -បុព្វកម្មរបស់ពោធិរាជកុមារ | ២២៤ |
| -គប្បីរក្សាខ្លួនឱ្យល្អក្នុងវ័យទាំង ៣ | ២២៤ |
| -អធិប្បាយគាថា | ២២៥ |
| ២-រឿងព្រះឧបនន្ទសក្យបុត្ត | ២២៨ |
| -ព្រះថេរៈច្រាប់ឧបាយរកលាភ | ២២៨ |
| -ព្រះឧបនន្ទកាត់ក្ដីរឿងវិវាទ | ២២៩ |
| -បុព្វកម្មរបស់ព្រះឧបនន្ទ | ២៣០ |
| -អធិប្បាយគាថា | ២៣២ |
| ៣-រឿងព្រះបធានិកតិស្សត្ថេរ | ២៣៤ |
| -ព្រះបធានប្រដៅអ្នកដទៃ តែខ្លួនមិនធ្វើ | ២៣៤ |
| -រឿងមាន់រងាវមិនពេលវេលា | ២៣៥ |
| -អធិប្បាយគាថា | ២៣៦ |
| ៤-រឿងមាតារបស់ព្រះកុមារកស្សបៈ | ២៣៨ |
| -មាតារបស់ព្រះកុមារកស្សបៈបួស | ២៣៨ |
| -ព្រះកុមារកស្សបៈកើត | ២៣៩ |
| -ព្រះកុមារកស្សបៈបួសសម្រេចព្រះអរហន្ត | ២៤១ |
| -មាតាព្រះកុមារកស្សបៈសម្រេចព្រះអរហន្ត | ២៤១ |
| -ពួកភិក្ខុសរសើរគុណព្រះសាស្ដា | ២៤២ |
| -អធិប្បាយគាថា | ២៤៤ |
| ៥-រឿងមហាកាលឧបាសក | ២៤៦ |
| -មហាកាលត្រូវចោទថាចោរ និងត្រូវវាយស្លាប់ | ២៤៦ |
| -បុព្វកម្មរបស់មហាកាល | ២៤៧ |
| -ចាបរមែងញាំញីដល់អ្នកធ្វើ | ២៤៩ |
| -អធិប្បាយគាថា | ២៤៩ |

៦–រឿងព្រះទេវទត្ត ២៥១
–សន្ទនារឿងលាមករបស់ព្រះទេវទត្ត ២៥១
–អធិប្បាយគាថា ២៥២
៧–រឿងការបំបែកសង្ឃ ២៥៤
–ព្រះទេវទត្តព្យាយាមបំបែកសង្ឃ ២៥៤
–អំពើល្អមនុស្សធ្វើបានងាយ ២៥៤
–អធិប្បាយគាថា ២៥៥
៨–រឿងព្រះកាលត្ថេរ ២៥៧
–ព្រះថេរៈមិនឱ្យឧបដ្ឋាយិកាទៅស្តាប់ធម៌ ២៥៧
–សក្ការៈមែនសម្រាប់បុគ្គលល្ងង់ ២៥៨
–អធិប្បាយគាថា ២៥៩
៩–រឿងចុល្លកាលឧបាសក ២៦១
–ចុល្លកាលត្រូវចោទថាជាចោរ ២៦១
–សេចក្តីសៅហ្មង ឬផូរផង់ព្រោះខ្លួនឯង ២៦២
–អធិប្បាយគាថា ២៦២
១០–រឿងព្រះអត្តទត្ថត្ថេរ ២៦៤
–ព្រះថេរៈព្យាយាមបំពេញប្រយោជន៍ ២៦៤
–អ្នកបដិបត្តិធម៌ឈ្មោះថាបូជាព្រះសាស្តា ២៦៥
–អធិប្បាយគាថា ២៦៥

## លោកវគ្គទី ១៣

១–រឿងភិក្ខុកំលោះ ២៦៨
–ភិក្ខុឈ្មោះជាមួយចៅនាងវិសាខា ២៦៨
–ព្រះសាស្តាប្រទានឱវាទដល់ភិក្ខុកំលោះ ២៧០
–អធិប្បាយគាថា ២៧០

២-រឿងព្រះថានសុទ្ធោទនៈ ២៧២

-ព្រះសាស្ដាទៅកាន់ក្រុងកបិលភស្ដុជាដំបូង ២៧២

-ការបិណ្ឌបាតជាវង្សរបស់ព្រះពុទ្ធ ២៧៣

-អធិប្បាយគាថា ២៧៤

៣-រឿងភិក្ខុចម្រើនវិបស្សនា ២៧៧

-ភិក្ខុកាន់យកថ្ងៃបណ្ដើរក្លូនជាអារម្មណ៍ ២៧៧

-អធិប្បាយគាថា ២៧៨

៤-រឿងអភយរាជកុមារ ២៧៩

-រាជកុមារទទួលរាជសម្បត្តិ ២៧៩

-ឧចាយរម្យាប់សេចក្ដីសោក ២៨០

-អធិប្បាយគាថា ២៨០

៥-រឿងព្រះសម្មជ្ជនត្ថេរ ២៨២

-អ្នកមិនប្រមាទញ៉ាំងលោកនេះឲ្យភ្លឺស្វាង ២៨២

-អធិប្បាយគាថា ២៨៤

៦-រឿងព្រះអង្គុលិមាល ២៨៥

-ដើមវៀចចុងត្រង់ប្រើការបាន ២៨៥

-អធិប្បាយគាថា ២៨៦

៧-រឿងធីតាជាងតម្បាញ ២៨៨

-អ្នកចម្រើនមរណស្សតិមិនខ្លាចស្លាប់ ២៨៨

-ព្រះសាស្ដាត្រាស់បញ្ហាជាមួយនឹងធីតា... ២៩២

-បុគ្គលមានបញ្ញា ឈ្មោះថា មានចក្ខុ ២៩៤

-អធិប្បាយគាថា ២៩៥

-ធីតាជាងតម្បាញទៅកើតក្នុងឋានតុសិត ២៩៦

៨-រឿងភិក្ខុ៣០រូប ២៩៨

-អ្នកចម្រើនឥទ្ធិបាទរមែងហោះបាន ២៩៨
-អធិប្បាយគាថា ២៩៩
៩-រឿងនាងបិញ្ចមាណវិកា ៣០១
-ពួកតិរត្ថីយ៍ច្រណែនព្រះពុទ្ធសាសនា ៣០១
-នាងបិញ្ចាធានាជួយពួកតិរត្ថីយ៍ ៣០២
-នាងបិញ្ចាត្រូវផែនដីស្រូប ៣០៥
-ព្រះពោធិសត្វត្រូវទម្លាក់ក្នុងជ្រោះតែមិនស្លាប់ ៣០៦
-ព្រះពោធិសត្វថ្វាយឱវាទដល់ព្រះរាជា ៣០៧
-អធិប្បាយគាថា ៣០៨
១០-រឿងអសទិសទាន ៣១០
-ព្រះរាជថ្វាយទានប្រជែងជាមួយរាស្ត្រ ៣១០
-ព្រះនាងមល្លិកាចាត់ចែងទាន ៣១១
-ទានព្រះនាងមល្លិកាឈ្មោះថាអសទិសទាន ៣១៣
-ត្រាស់សរសើរព្រះអង្គុលិមាល ៣១៥
-ព្រះរាជទ្រង់និរទេសអាមាត្យអាក្រក់ ៣១៧
-បុគ្គលកំណាញ់មិនទៅកាន់ទេវលោក ៣១៧
-អធិប្បាយគាថា ៣១៨
១១-រឿងនាយកាលៈបុត្ររបស់អនាថបិណ្ឌិកសេដ្ឋី ៣២០
-បិតាជួលបុត្តឱ្យទៅស្តាប់ធម៌ ៣២០
-សោបត្តិផលប្រសើជាងសម្បត្តិក្នុងលោក ៣២៣
-អធិប្បាយគាថា ៣២៤

## ពុទ្ធវគ្គទី ១៤

១-រឿងមារធីតា ៣២៦
-ព្រាហ្មណ៍រកស្វាមីឱ្យកូនក្រមុំ ៣២៦

-ស្នាមជើងជាគ្រឿងសម្តែងនូវលក្ខណៈបុគ្គល ៣២៨
-មារតាមចាប់កំហុសព្រះពោធិសត្វមិនបាន ៣៣០
-ធីតាមារប្រលោមព្រះសាស្តា ៣៣១
-អធិប្បាយគាថា ៣៣៣
២-រឿងយមកប្បាដិហារ្យ ៣៣៧
-សេដ្ឋីប្រើឈើច័ន្ទធ្វើបាត្រ ៣៣៧
-គ្រូទាំង ៦ ចង់បានបាត្រខ្លឹមច័ន្ទ ៣៣៨
-ព្រះបិណ្ឌោលភារទ្វាជៈសម្តែងបាដិហារ្យ ៣៤០
-ព្រះសាស្តាហាមភិក្ខុមិនឱ្យធ្វើបាដិហារ្យ ៣៤២
-ប្រវត្តិគណ្ឌាមព្រឹក្ស ៣៤៧
-សាវកសាវិកាទទួលធ្វើបាដិហារ្យជំនួស ៣៥១
-ព្រះសាស្តាត្រាស់ហេតុមិនឱ្យសាវកធ្វើបាដិហារ្យ ៣៥៦
-លក្ខណៈយមកប្បាដិហារ្យ ៣៥៨
-ព្រះសាស្តាចាំវស្សានៅតាវតិង្ស ៣៦២
-ព្រះសាស្តារុងរោចន៍ជាងពួកទេវតា ៣៦៥
-ព្រះសាស្តាត្រាស់ឱ្យព្រួដល់មនុស្សលោក ៣៦៧
-ទានឱ្យដល់ទក្ខិណេយ្យបុគ្គលមានផលច្រើន ៣៦៩
-ព្រះសាស្តានៅប្រោសព្រះមាតានៅជាន់តាវតិង្ស ៣៧១
-ព្រះមោគ្គល្លានទូលសួរពីការស្តេចយាងចុះ ៣៧២
-ព្រះសាស្តាទ្រង់បើកលោក ៣៧៤
-អធិប្បាយគាថា ៣៧៦
-សង្កស្សនគរជាទីស្តេចចុះចាកតាវតិង្ស ៣៧៧
-ព្រះសារីបុត្រមានបញ្ញាច្រើន ៣៧៨
៣-រឿងឯរកបត្តនាគរាជ ៣៨២
-អាបត្តិតិចតួចមិនសម្តែងចេញក៏ឱ្យទោស ៣៨២

| | |
|---|---|
| -ស្តេចនាគមានឧបាយដើម្បីដឹងការឧប្បត្តិ... | ៣៨៣ |
| -ព្រះសាស្តាចងបទចម្រៀង.ត | ៣៨៤ |
| -ឧត្តរមាណពរៀនចម្រៀង.តពីព្រះសាស្តា | ៣៨៥ |
| -នាគរាជជ្រាបការឧបត្តិរបស់ព្រះពុទ្ធ | ៣៨៨ |
| -អធិប្បាយគាថា | ៣៩០ |
| -នាគរាជមិនបានត្រាស់ដឹង | ៣៩០ |
| ៤-រឿងបញ្ហារបស់ព្រះអានន្ទ | ៣៩២ |
| -កាលនៃព្រះពុទ្ធផ្សេងគ្នា តែពាក្យទូន្មានដូចគ្នា | ៣៩២ |
| -អធិប្បាយគាថា | ៣៩៤ |
| ៥-រឿងភិក្ខុអ្នកមិនត្រេកអរ | ៣៩៧ |
| -ភិក្ខុកំលោះអផ្សុកចង់សឹក | ៣៩៧ |
| -អធិប្បាយគាថា | ៤០០ |
| ៦-រឿងអគ្គិទត្តបុរោហិត | ៤០៣ |
| -អគ្គិទត្តៈទូលសូមបួស | ៤០៣ |
| -ព្រះមហាមោគ្គល្លានទូន្មានអគ្គិទត្តៈ | ៤០៥ |
| -ព្រះថេរៈផ្ចាញ់នាគរាជ | ៤០៧ |
| -នាគរាជចាញ់ព្រះថេរៈ | ៤០៨ |
| -ពួកឥសីសរសើរព្រះសាស្តា | ៤០៩ |
| -សរណៈដែលក្សេម និងមិនក្សេម | ៤១០ |
| -អធិប្បាយគាថា | ៤១១ |
| -អ្នកនគរយល់ថាអគ្គិទត្តៈធំជាងព្រះសាស្តា | ៤១៣ |
| ៧-រឿងបញ្ហាព្រះអានន្ទ | ៤១៥ |
| -ព្រះថេរៈរំពឹងដល់ទីកើតរបស់បុរសអាជានេយ្យ | ៤១៥ |
| -អធិប្បាយគាថា | ៤១៦ |
| ៨-រឿងសម្ពហុលភិក្ខុ | ៤១៨ |

-ការយល់ឃើញក្នុងបញ្ហាផ្សេងៗគ្នា ៤១៨
-ព្រះសាស្តាដោះស្រាយបញ្ហានោះ ៤១៨
-អធិប្បាយគាថា ៤១៩
៩-រឿងព្រះចេតិយមាស ៤២១
-អធិប្បាយគាថា ៤២៣

## សុខវគ្គទី ១៥

១-រឿងរំងាប់ជំលោះរបស់ពួកព្រះញាតិ ៤២៧
-វិវាទព្រោះទឹក ៤២៧
-ព្រះសាស្តាឃាមពួកព្រះញាតិ ៤២៩
-អធិប្បាយគាថា ៤៣១
២-រឿងមារ ៤៣៣
-ក្មេងស្រី ៥០០ នាក់ លេងនក្ខត្តឫក្ស ៤៣៣
-អ្នកមិនកង្វល់សោយបីតិជាអាហារ ៤៣៤
-អធិប្បាយគាថា ៤៣៤
៣-រឿងបរាជ័យរបស់ព្រះបាទកោសល ៤៣៦
-មាចាញ់ក្មួយ ៤៣៦
-អធិប្បាយគាថា ៤៣៧
៤-រឿងក្មេងស្រីក្នុងត្រកូលមួយ ៤៣៩
-ព្រះសាស្តាយាងក្នុងពិធីអាវាហមង្គល ៤៣៩
-អធិប្បាយគាថា ៤៤០
៥-រឿងឧបាសកម្នាក់ ៤៤២
-ព្រះសាស្តាប្រោសបុគ្គលឆាល់ក្រ ៤៤២
-ព្រះសាស្តាត្រូវគេនិន្ទា ៤៤៣
-អធិប្បាយគាថា ៤៤៥

៦-រឿងព្រះបាទបសេនទិកោសល ៤៤៧

-ព្រះរាជាសោយព្រះក្រយាហារច្រើន ៤៤៧

-ព្រះរាជាបន្ថយព្រះក្រយាហារបាន ៤៤៩

-អធិប្បាយគាថា ៤៥០

៧-រឿងព្រះតិស្សត្ថេរៈ ៤៥២

-បានដឹងការបរិនិព្វាន ក៏ព្យាយាមបំពេញ... ៤៥២

-អធិប្បាយគាថា ៤៥៣

៨-រឿងសក្កទេវរាជ ៤៥៥

-ភិក្ខុសរសើរសក្កទេវរាជ ៤៥៦

-អធិប្បាយគាថា ៤៥៩

## បិយវគ្គទី ១៦

១-រឿងបព្វជិត ៣ រូប ៤៦២

-ត្រកូលមានកូនប្រុសម្នាក់រត់ទៅបួស ៤៦២

-ព្រះសាស្តាទ្រង់ជាស់តឿន ៤៦៤

-អធិប្បាយគាថា ៤៦៥

២-រឿងកុដុម្ពិកម្នាក់ ៤៦៩

-ព្រះសាស្តាទ្រង់រម្ងាប់សេចក្តីរបស់កុដុម្ពិក ៤៦៩

-អធិប្បាយគាថា ៤៧១

៣-រឿងឧបាសិកាវិសាខា ៤៧៣

-ព្រះសាស្តាត្រាស់ឱបាយរម្ងាប់សេចក្តីសោក ៤៧៣

-អធិប្បាយគាថា ៤៧៥

៤-រឿងស្តេចលិច្ឆវី ៤៧៦

-ព្រះសាស្តាត្រាស់ទោសនៃសេចក្តីត្រេកអរ ៤៧៦

-អធិប្បាយគាថា ៤៧៧

៥-រឿងអនិត្ថិគន្ធកុមារ ៤៧៨

-កុមារឱ្យជាន់ស្ងួនប្រុសស្ត្រី ៤៧៨

-ព្រាហ្មណ៍ជួបស្ត្រីមានរូបដូចរូបដែលសួន ៤៧៩

-គ្រួគ្រងរបស់អនិត្ថិកុមារស្លាប់ក្នុងចន្លោះផ្លូវ ៤៨០

-ព្រះសាស្តាសម្តែងឧទាយរម្ងាប់សេចក្តីសោក ៤៨១

-អធិប្បាយគាថា ៤៨២

៦-រឿងព្រាហ្មណ៍ម្នាក់ ៤៨៤

-ព្រះសាស្តាទ្រង់ប្រោសព្រាហ្មណ៍មិច្ឆាទិដ្ឋិ ៤៨៤

-អធិប្បាយគាថា ៤៨៧

៧-រឿងក្មេង ៥០០ នាក់ ៤៨៨

-ក្មេង ៥០០ នាក់ ថ្វាយនំដល់ព្រះមហាកស្សបៈ ៤៨៨

-អធិប្បាយគាថា ៤៩០

៨-រឿងអនាគាមិត្ថេរៈ ៤៩២

-ព្រះថេរៈសម្រេចព្រះអនាគាមិផល ៤៩២

-អធិប្បាយគាថា ៤៩៤

៩-រឿងនាយនន្ទិយៈ ៤៩៦

-នន្ទិយៈជាអនុជាតបុត្ត ៤៩៦

-ព្រះមហាមោគ្គល្លានទៅកាន់ស្ថានសួគ៌ ៤៩៨

-ទិព្វសម្បត្តិកើតរង់ចាំអ្នកមានបុណ្យ ៤៩៨

-អធិប្បាយគាថា ៥០០

## កោធវគ្គទី ១៧

១-រឿងព្រះនាងរោហិណី ៥០៣

-សាងរោងឆាន់វិនាសរោគសើស្បែក ៥០៣

-បុព្វកម្មរបស់ព្រះនាងរោហិណី ៥០៦

| | |
|---|---|
| -អធិប្បាយគាថា | ៥០៨ |
| ២-រឿងភិក្ខុមួយរូប | ៥១១ |
| -ភិក្ខុកាត់ដើមឈើដែលទេវតាស្ថិតនៅ | ៥១១ |
| -អធិប្បាយគាថា | ៥១៣ |
| ៣-រឿងឧត្តរាឧបាសិកា | ៥១៥ |
| -នាយបុណ្ណៈអ្នកបម្រើសមនសេដ្ឋី | ៥១៥ |
| -ព្រះសារីបុត្រនៅសង្គ្រោះនាយបុណ្ណៈ | ៥១៦ |
| -ភរិយានាយបុណ្ណៈថ្វាយភត្តដល់ព្រះថេរៈ | ៥១៧ |
| -ទានរបស់ភរិយាស្វាមីឱ្យផលទាន់ភ្នែក | ៥១៩ |
| -នាយបុណ្ណៈទទួលតំណែងសេដ្ឋី | ៥២១ |
| -ធីតាបុណ្ណៈបានជាភរិយារបស់បុត្តសមនសេដ្ឋី | ៥២២ |
| -នាងឧត្តរាបានឱកាសធ្វើបុណ្យ | ៥២៤ |
| -នាងសិរិមាយកទឹកដោះក្ដៅចាក់លើ... | ៥២៥ |
| -នាងសិរិមាដឹងខ្លួនខុស សូមទោសនាងឧត្តរា | ៥២៦ |
| -នាងសិរិមាសូមឱ្យព្រះសាស្ដាអត់ទោស | ៥២៧ |
| -អធិប្បាយគាថា | ៥៣០ |
| ៤-រឿងបញ្ហារបស់ព្រះមហាមោគ្គល្លាន | ៥៣១ |
| -ព្រះមោគ្គល្លានទៅកាន់ទេវលោក | ៥៣១ |
| -ពោលពាក្យសច្ចៈក៏ទៅសួគ៌បាន | ៥៣២ |
| -អធិប្បាយគាថា | ៥៣៣ |
| ៥-រឿងបញ្ហាភិក្ខុទូលសួរ | ៥៣៥ |
| -ប្តីប្រពន្ធពីរនាក់ថាខ្លួនជាពុទ្ធបិតាពុទ្ធមាតា | ៥៣៥ |
| -ព្រះសាស្ដាត្រាស់ប្រវត្តិរបស់ព្រាហ្មណ៍ | ៥៣៧ |
| -ព្រះសាស្ដាត្រាស់ជរាសូត្រ | ៥៣៨ |
| -ព្រះអសេក្ខមុនីទៅកាន់ឋានៈមិនចុតិ | ៥៣៩ |

-អធិប្បាយគាថា ៥៤០
៦-រឿងនាងបុណ្ណទាសី ៥៤១
-នាងបុណ្ណាថ្វាយនំកន្ទក់ដល់ព្រះសាស្ដា ៥៤១
-ព្រះសាស្ដាសោយនំរបស់នាងបុណ្ណា ៥៤២
-សាវករបស់ព្រះពុទ្ធភ្ញាក់រឿយ ៗ ៥៤៤
-អធិប្បាយគាថា ៥៤៤
-ពួកភិក្ខុសរសើរព្រះសាស្ដា ៥៤៥
៧-រឿងអតុលឧបាសក ៥៤៧
-អតុលៈក្រោធនឹងព្រះរេវតៈដែលមិននិយាយ ៥៤៧
-អតុលៈក្រោធនឹងអ្នកនិយាយច្រើន ៥៤៨
-អតុលៈក្រោធនឹងអ្នកនិយាយតិច ៥៤៩
-ការនិន្ទា ការសរសើរជារបស់បុរាណ ៥៤៩
-អធិប្បាយគាថា ៥៥១
៨-រឿងភិក្ខុឆព្វគ្គីយ៍ ៥៥៤
-មូលបញ្ញត្តិនៃការពាក់ទ្រនាប់ជើង ៥៥៤
-អធិប្បាយគាថា ៥៥៥

# ខុទ្ទកនិកាយ គាថាធម្មបទ

## បាបវគ្គ ទី ៩

"ពោលអំពីបុណ្យ និងបាប"

## ១. រឿងព្រាហ្មណ៍ឈ្មោះចូឡេកសាដក

[១៩] *ព្រះសាស្តា កាលទ្រង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ឈ្មោះចូឡេកសាដក បានត្រាស់ព្រះធម្មទេសនានេះថា* ***អភិត្ថរេថ កល្យាណេ*** *(បុគ្គលប្រញាប់រួសរាន់ធ្វើបុណ្យ) ជាដើម ។*

### ព្រាហ្មណ៍ និងព្រាហ្មណីផ្លាស់វេនគ្នាទៅស្តាប់ធម៌

*សេចក្តីពិស្តារថា ក្នុងកាលនៃព្រះវិបស្សីទសពល មានព្រាហ្មណ៍ម្នាក់ឈ្មោះមហាឯកសាដក ។ តែក្នុងកាលនៃព្រះសម្មាសម្ពុទ្ធនៃយើង គេបានឈ្មោះថា ចូឡេកសាដក នៅក្នុងក្រុងសាវត្ថី ។ ក៏សំពត់សាដកសម្រាប់ស្លៀករបស់ព្រាហ្មណ៍នោះ មានតែមួយផ្ទាំង ។ សូម្បីនាងព្រាហ្មណី ក៏មានតែមួយផ្ទាំងដែរ ។ ទាំងពីរនាក់ប្តីប្រពន្ធមានសំពត់ដណ្តប់តែមួយផ្ទាំងប៉ុណ្ណោះ ។ ថ្ងៃមួយ កាលគេប្រកាសការស្តាប់ធម៌ក្នុងវិហារ ព្រាហ្មណ៍បានពោលថា "នាងគេប្រកាសការស្តាប់ធម៌ នាងនឹងទៅស្តាប់ព្រះធម៌ក្នុងវេលាថ្ងៃ ឬក៏វេលាយប់ ព្រោះយើងទាំងពីរនាក់មិនអាចទៅព្រមគ្នាបានទេ ព្រោះមិនមានសំពត់ស្លៀកដណ្តប់" ព្រាហ្មណីតបថា "នាយ ខ្ញុំនឹងទៅក្នុងវេលាថ្ងៃ" លុះពោលដូច្នេះហើយ*

ក៏ដណ្តប់សំពត់សាដកទៅ ។ ព្រាហ្មណ៍នៅចាំផ្ទះរហូតអស់មួយថ្ងៃ ដល់វេលាយប់ ទើបបានទៅអង្គុយស្តាប់ធម៌ខាងមុខព្រះភក្ត្រព្រះសាស្តា ។ គ្រានោះបីតិ ៥ យ៉ាង បានកើតឡើងផ្សព្វផ្សាយទូទៅសរីរៈរបស់ព្រាហ្មណ៍នោះ ។ គេមានសេចក្តីប្រាថ្នានឹងបូជាចំពោះព្រះសាស្តា ក៏គិតថា "បើយើងនឹងថ្វាយសំពត់សាដកនេះ ភរិយារបស់យើងនឹងមិនមានសំពត់ដណ្តប់ សូម្បីយើងក៏មិនមាន ខណៈនោះ មច្ឆេរចិត្ត (ចិត្តប្រកបដោយសេចក្តីកំណាញ់) ១.០០០ ដួង ក៏បានកើតឡើងដល់គេ ចិត្តប្រកបដោយសទ្ធា ១ ដួង ក៏បានកើតឡើងទៀត ។ មច្ឆេរចិត្តមួយពាន់ដួង ក៏បានកើតឡើងគ្របសង្កត់ចិត្តដែលប្រកបដោយសទ្ធានោះទៀត ។ សេចក្តីកំណាញ់ដ៏មានកម្លាំងរបស់គេ ក៏បានកើតឡើងរារាំងចិត្តដែលប្រកបដោយសទ្ធាមិនឲ្យកើតឡើង ដូចជាចាប់ចងទុកយ៉ាងមាំ ដូច្នេះ ។ កាលគេកំពុងគិតថា "នឹងថ្វាយ ឬមិនថ្វាយ" ដូច្នេះនោះ បឋមយាមនៃរាត្រីក៏បានកន្លងទៅ ។ សូម្បីមជ្ឈិមយាមចូលមកដល់ ក៏គេមិនអាចថ្វាយសំពត់សាដកចំពោះព្រះសាស្តាបានទៀត ។ លុះដល់បច្ឆិមយាម គេក៏គិតថា "កាលយើងច្បាំងជាមួយនឹងមច្ឆេរចិត្តដោយសទ្ធាចិត្តនោះឯង ២ យាមក៏បានកន្លងផុតទៅហើយ ។ មច្ឆេរចិត្តរបស់យើងនេះកាលចម្រើនឡើងហើយនឹងមិនឲ្យយើងងើបសីសៈឡើងអំពីអបាយទាំង ៤ បាន យើងនឹងថ្វាយសំពត់សាដកនេះ" ។ គេគ្របសង្កត់សេចក្តីកំណាញ់ទាំង ១.០០០ ដួងបានហើយធ្វើសទ្ធាចិត្តឲ្យជាបុរេចារិក (នាំមុខ) ហើយកាន់យកសំពត់សាដកទៅដាក់ល់

ទៀបបាទមូលរបស់ព្រះសាស្តា បានបន្លឺសំឡេងខ្លាំងៗ ៣ ដង ថា "យើងឈ្នះហើយ យើងឈ្នះហើយ" ជាដើម ។

## ទានរបស់ព្រាហ្មណ៍ឱ្យផលទាន់ភ្នែក

ព្រះបាទបសេនទិកោសល ទ្រង់កំពុងតែស្តាប់ព្រះធម៌ បានឮសំឡេងនោះហើយ ត្រាស់ថា "អ្នកទាំងឡាយ ចូរសួរព្រាហ្មណ៍នោះមើល តើគេមានឈ្នះអ្វី?" ។

ព្រាហ្មណ៍នោះ ត្រូវពួករាជបុរសសួរ ក៏បានឆ្លើយប្រាប់នូវសេចក្តីនោះដល់ពួករាជបុរស ។ ព្រះរាជាទ្រង់ស្តាប់នូវសេចក្តីនោះហើយ ក៏ទ្រង់ត្រិះរិះថា ព្រាហ្មណ៍នោះបានធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ យើងនឹងធ្វើការសង្គ្រោះគេ លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់ត្រាស់បង្គាប់ឲ្យព្រះរាជទានសំពត់សាដកមួយគូ ។ គេបានថ្វាយសំពត់មួយគូនោះចំពោះព្រះតថាគតទៀត ព្រះរាជាក៏ត្រាស់បង្គាប់ឲ្យព្រះរាជទានជាទ្វេគុណទៀត គឺ ២ គូ ៤ គូ ៨ គូ ១៦ គូ ។ ព្រាហ្មណ៍ក៏បានថ្វាយសំពត់ទាំងនោះចំពោះព្រះតថាគតអស់ទៀត ។ តមក ព្រះរាជាត្រាស់បង្គាប់ឲ្យព្រះរាជទានសំពត់ ៣២ គូ ដល់គេ ។ ព្រាហ្មណ៍ដើម្បីការពារវាទៈថា "ព្រាហ្មណ៍មិនកាន់យកដើម្បីខ្លួន លះបង់សំពត់ដែលបានហើយៗ ទាំងអស់" ទើបកាន់យកសំពត់ ២ គូ អំពីសំពត់ ៣២ គូនោះ ដើម្បីខ្លួន ១ គូ ដើម្បីនាងព្រាហ្មណី ១ គូ ហើយថ្វាយសំពត់ ៣០ គូ ចំពោះព្រះ

តថាគត ។ ចំណែកព្រះរាជា កាលព្រាហ្មណ៍នោះថ្វាយដល់ ៧ ដង ទ្រង់មានព្រះរាជបំណងចង់ព្រះរាជទានទៀត ។ ក្នុងកាលមុន ព្រាហ្មណ៍ឈ្មោះ មហាឯកសាដក បានកាន់យកសំពត់សាដក ២ គូ អំពីសំពត់សាដក ៦៤ គូ ។ ចំណែកព្រាហ្មណ៍ឈ្មោះ ចូឡេកសាដកនោះ បានកាន់យកសំពត់សាដក ២ គូ ក្នុងវេលាដែលខ្លួនបានសំពត់សាដក ៣២ គូ ។

ព្រះរាជាទ្រង់បង្គាប់ពួករាជបុរសថា "អ្នកទាំងឡាយ ព្រាហ្មណ៍ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ អ្នកទាំងឡាយ គប្បីឲ្យគេនាំយកសំពត់កម្ពល ២ ផ្ទាំងខាងក្នុងព្រះរាជវាំងរបស់យើងមក ។ ពួករាជបុរសក៏បានធ្វើយ៉ាងនោះ ព្រះរាជាទ្រង់ព្រះរាជទានសំពត់កម្ពល ២ ផ្ទាំង ដែលមានតំលៃ ១ សែនដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍គិតថា សំពត់កម្ពលទាំងនោះ មិនសមគួរប៉ះពាល់ដល់សរីរៈរបស់យើងទេ សំពត់ទាំងនោះសមគួរតែព្រះពុទ្ធសាសនាប៉ុណ្ណោះ ទើបយកសំពត់កម្ពល ១ ផ្ទាំង ទៅចងធ្វើជាពិដានខាងលើគ្រែផ្ទំរបស់ព្រះសាស្ដាខាងក្នុងព្រះគន្ធកុដិ ។ ១ ផ្ទាំងទៀត ទៅចងធ្វើជាពិដានខាងលើទីធ្វើភត្តកិច្ចរបស់ភិក្ខុទាំងឡាយដែលឆាន់ជាប្រចាំ ក្នុងផ្ទះរបស់ខ្លួន ។ ក្នុងវេលារសៀលព្រះរាជាស្ដេចយាងទៅកាន់សម្នាក់របស់ព្រះសាស្ដា ទ្រង់ចាំសំពត់កម្ពលបានក៏ទូលសួរព្រះសាស្ដាថា "បពិត្រព្រះអង្គដ៏ចម្រើន នរណាបូជាសំពត់កម្ពលនោះដល់ព្រះអង្គ?" កាលព្រះសាស្ដាត្រាស់តបថា "ព្រាហ្មណ៍ឈ្មោះឯកសាដក"

ដូច្នេះហើយ ទ្រង់ព្រះតម្រិះថា "ព្រាហ្មណ៍ជ្រះថ្លាក្នុងឋាន: ដែលយើងជ្រះថ្លាដែរ" ទ្រង់ក៏ត្រាស់បង្គាប់ឲ្យព្រះរាជទានពួក ៤ នៃវត្ថុគ្រប់យ៉ាង រហូតដល់វត្ថុទាំងអស់ ១០០ ទ្រង់ធ្វើវត្ថុមួយមុខៗ ៤ ដល់ព្រាហ្មណ៍នោះ យ៉ាងនេះគឺ ដំរី ៤ សេះ ៤ កហាបណៈ ៤.០០០ ស្ត្រី ៤ ទាសី ៤ បុរស ៤ ស្រុកសួយ ៤ ។

## ប្រញាប់ធ្វើកុសលឱ្យច្រើនជាងអកុសល

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា "សូម្បី កម្មរបស់ព្រាហ្មណ៍ឈ្មោះចូឡេកសាដក គួរឲ្យអស្ចារ្យណាស់ តែមួយរំពេចប៉ុណ្ណោះ គេបានទូវពួក ៤ នៃវត្ថុគ្រប់យ៉ាង កម្មជាកុសលគេធ្វើហើយក្នុងស្រែបុណ្យដ៏ប្រសើរ ក្នុងពេលនេះ ក៏ឲ្យផលក្នុងថ្ងៃនោះឯង" ។

ព្រះសាស្ដាស្ដេចយាងមក ហើយត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរកថាអ្វី?" កាលពួកភិក្ខុទាំងឡាយក្រាបទូលថា "ដោយកថាឈ្មោះនេះ ព្រះអង្គ" ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ប្រសិនបើឯកសាដក ថ្វាយសំពត់សាដកចំពោះតថាគតក្នុងបឋមយាម គេនឹងបាននូវសព្វវត្ថុមួយយ៉ាង ១៦ បើគេបានថ្វាយក្នុងមជ្ឈិមយាម គេនឹងបាននូវសព្វវត្ថុមួយយ៉ាង ៨ ប៉ុន្តែព្រោះគេថ្វាយក្នុងវេលាជិតភ្លឺ ទើបគេបាននូវសព្វវត្ថុមួយយ៉ាង ៤ ដូច្នេះ ។ ពិតហើយ បុគ្គលកាលបើកុសលកម្ម មិនឲ្យ

ចិត្តជាកុសលកើតឡើងវិនាសទៅវិញទេ គប្បីធ្វើនូវអំពើជាកុសលភ្លាមៗ ព្រោះថា កុសលដែលបុគ្គលធ្វើយឺតយូរ កាលឲ្យសម្បត្តិរមែងឲ្យផលយូរដូចគ្នា ព្រោះដូច្នោះ គប្បីធ្វើកុសលក្នុងលំដាប់ដែលកើតការគិតនោះឯង” កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសំដែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

១.អភិត្ថរេថ កល្យាណេ ចាចា ចិត្តំ និវារយេ

ទន្ធំ ហិ ករតោ បុញ្ញំ ចាបស្មឹ រមតី មនោ។

បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប

ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរ

ក្នុងបាប ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អភិត្ថរេថ** (គប្បីប្រញាប់ខ្វល់ខ្វាយ) សេចក្តីថា គប្បីធ្វើភ្លាមៗ គឺថា ឲ្យឆាប់ៗ ។ ពិតណាស់ គ្រហស្ថកាលបើចិត្តកើតឡើងថា “នឹងធ្វើកុសលណាមួយ ក្នុងកុសលទានទាំងឡាយ មានថ្វាយសលាកភត្តជាដើម” គួរធ្វើភ្លាមៗ ដោយគិតថា “យើងនឹងធ្វើមុន យើងនឹងធ្វើមុន” កុំឲ្យជនដទៃបានឱកាស ។ ឬបើបព្វជិត កាលបើធ្វើវត្តទាំងឡាយ មានឧបជ្ឈាយវត្តជាដើម មិនឲ្យឱកាសដល់បព្វជិតដទៃ គួរធ្វើឲ្យឆាប់ៗ ដោយគិត

ថា "យើងនឹងធ្វើមុន យើងនឹងធ្វើមុន" ។

*បទថា **បាបា ចិត្តំ** (ចិត្តចាកអំពីបាប) សេចក្តីថា បុគ្គលគប្បីហាម ចិត្តចាកបាបកម្ម មានកាយទុច្ចរិតជាដើម ឬចាកអកុសលចិត្តប្បាទក្នុងទីទាំងពួង ។*

*បទថា **ទន្ធំ ហិ ករតោ** (ព្រោះថា បើបុគ្គលធ្វើបុណ្យយឺតយូរ) សេចក្តីថា បុគ្គលណានៅគិតយ៉ាងនោះថា "យើងនឹងឲ្យទាន នឹងយើងធ្វើបុណ្យ ផលនេះនឹងសម្រេចដល់យើងឬទេ" ឈ្មោះថា ធ្វើបុណ្យយឺតយូរ ដូចជាបុគ្គលដើរផ្លូវរអិល បាបរបស់បុគ្គលនោះ រមែងបានឱកាស ដូចមច្ឆរចិត្ត ១.០០០ ដួងរបស់ព្រាហ្មណ៍ ឈ្មោះឯកសាដកដូច្នោះ ដូច្នោះឯង ចិត្តរបស់បុគ្គលនោះ រមែងត្រេកអរក្នុងបាប ព្រោះថា ក្នុងវេលាដែលធ្វើកុសលកម្មប៉ុណ្ណោះ ចិត្តរមែងត្រេកអរក្នុងកុសលកម្ម ផុតអំពីនោះហើយ រមែងបង្អោនទៅកាន់បាបដោយពិត ។*

*ក្នុងវេលាចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ដូច្នេះឯង ។*

ចប់ រឿងព្រាហ្មណ៍ឈ្មោះចូឡេកសាដក

# ២. រឿងព្រះសេយ្យកត្ថេរ

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសេយ្យកៈ ត្រាស់ព្រះធម្មទេសនានោះថា **បាបញ្ចេ បុរិសោ កយិរា (បើបុគ្គលគប្បីធ្វើនូវបាប)** ជាដើម ។

## កម្មអាក្រក់ឱ្យទុក្ខក្នុងភពទាំងពីរ

ដូចបានស្តាប់មក ព្រះសេយ្យកៈនោះ ជាសទ្ធិវិហារិករបស់ព្រះលោឡុទាយី បានប្រាប់សេចក្តីមិនត្រេកអររបស់ខ្លួនដល់ព្រះលោឡុទាយី ត្រូវលោកបបួលឲ្យធ្វើបឋមសង្ឃាទិសេស ក្នុងកាលសេចក្តីមិនត្រេកអរ កើតឡើង លោកក៏បានប្រព្រឹត្តកម្មនោះ ។

ព្រះសាស្តា ទ្រង់ស្តាប់នូវកិរិយារបស់លោកហើយ ទ្រង់ត្រាស់ឲ្យហៅលោកមក ទ្រង់ត្រាស់សួរថា "ម្នាលសេយ្យកៈ អ្នកបានធ្វើយ៉ាងនោះពិតឬ?" កាលលោកទូលថា "បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែន" ទើបទ្រង់ត្រាស់ថា "នែមោឃបុរស ព្រោះហេតុអ្វី បានជាអ្នកធ្វើកម្មដ៏ធ្ងន់ ជាកម្មមិនសមគួរយ៉ាងនោះ?" ទ្រង់តិះដៀលដោយប្រការផ្សេងៗ ទ្រង់បញ្ញត្តិសិក្ខាបទ ហើយទ្រង់ត្រាស់ថា "កម្មបែបនោះ ជាកម្មញ៉ាំងសត្វឲ្យប្រព្រឹត្តទៅដើម្បីសេចក្តីទុក្ខតែម្យ៉ាងប៉ុណ្ណោះ ទាំងក្នុងភពនេះ ទាំងក្នុងភពខាងមុខ" កាលនឹងទ្រង់បន្ត

អនុសន្ធិដើម្បីសម្ដែងព្រះធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

២.បាបញ្ចេ បុរិសោ កយិរា   ន នំ កយិរា បុនប្បុនំ

ន តម្ហិ ឆន្ទំ កយិរាថ   ទុក្ខោ បាបស្ស ឧច្ចយោ ។

បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយៗ ឡើយ កុំគប្បីធ្វើសេចក្ដី ពេញចិត្តក្នុងបាបនោះ (ព្រោះថា) ការសន្សំបាប តែងនាំសេចក្ដី ទុក្ខមកឲ្យ ។

## អធិប្បាយគាថា

ខ្លឹមសារនៃព្រះគាថានោះថា "បើបុគ្គលធ្វើកម្មលាមកមួយគ្រា គប្បីពិចារណាក្នុងខណៈនោះឯងថា កម្មនេះមិនសមគួរ ជាកម្មគ្រោតគ្រាត មិនគួរធ្វើកម្មនោះរឿយៗ ឡើយ ។ គប្បីបន្ទោបង់ចេញ មិនគួរធ្វើសេចក្ដីពេញចិត្ត ឬសេចក្ដីត្រេកអរក្នុងបាបនោះឡើយ" ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះថា ការសន្សំ គឺ ការកពូនទូវបាប ជាហេតុឲ្យកើតទុក្ខ គឺ រមែងនាំតែទុក្ខមកឲ្យ ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។

ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចប់ រឿងព្រះសេយ្យកត្ថេរ

# ៣. រឿងនាងលាជទេពធីតា

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ នាងលាជទេពធីតា ត្រាស់ព្រះធម្មទេសនានោះថា **បុញ្ញញ្ចេ បុរិសោ កយិរា** (បើបុគ្គលគប្បីធ្វើបុណ្យ) ជាដើម ។ រឿងកើតឡើងនៅក្នុងក្រុងរាជគ្រឹះ ។*

## ស្ត្រីថ្វាយលាជដល់ព្រះមហាកស្សបៈ

*សេចក្តីពិស្តារថា ព្រះមហាកស្សបៈ កាលដែលលោកគង់នៅបិប្ផលិគូហា លោកបានចូលនិរោធសមាបត្តិ ហើយចេញក្នុងថ្ងៃទី ៧ បានពិចារណាមើលនូវទីត្រាច់ទៅដើម្បីភិក្ខាដោយទិព្វចក្ខុ ឃើញស្ត្រីថែរក្សាស្រែស្រូវសាលីម្នាក់ដែលកំពុងក្តិចកួរស្រូវសាលីលីងធ្វើជាលាជ លុះឃើញហើយ ក៏បានពិចារណាទៀតថា "ស្ត្រីនោះមានសទ្ធា ឬក៏មិនមានហ្ន៎?" ដឹងថា មានសទ្ធា ក៏ពិចារណាទៀតថា "នាងនឹងអាចសង្គ្រោះយើង ឬក៏មិនអាច" ដឹងថា កុលធីតានោះជាស្ត្រីឈ្លាសវៃ នឹងសង្គ្រោះយើង លុះធ្វើហើយ នឹងបានសម្បត្តិជាច្រើន ទើបឃ្លុំចីវរប្រដាប់បាត្រ និមន្តទៅឈរនៅជិតស្រែស្រូវសាលីនោះ ។ កុលធីតានោះ គ្រាន់តែបានឃើញព្រះថេរៈភ្លាម ក៏មានចិត្តជ្រះថ្លា មានសរីរៈដែលបីតិ ៥ ប្រការពាល់ត្រូវហើយ បានពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ឈប់សិន" ហើយកាន់លាជដើរចូលទៅដោយរហ័ស លុះចូល*

ទៅដល់ព្រះថេរៈ ចាក់លាជទៅក្នុងបាត្ររបស់ព្រះថេរៈ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ធ្វើសេចក្ដីប្រាថ្នាថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមឲ្យនាងខ្ញុំម្ចាស់ជាអ្នកមានទូវចំណែកនៃធម៌ ដែលលោកម្ចាស់ឃើញហើយ" ។

## ចិត្តជ្រះថ្លាក្នុងទាន នាំកើតក្នុងសួគ៌

ព្រះថេរៈបានធ្វើអនុមោទនាថា "សេចក្ដីជ្រះថ្លាដែលនាងប្រាថ្នាហើយចូរសម្រេចចុះ" ។ ចំណែកនាងថ្វាយបង្គំព្រះថេរៈហើយ ត្រឡប់ទៅវិញ នឹកដល់ទានដែលខ្លួនថ្វាយហើយ ។ ក៏ក្នុងផ្លូវដែលនាងដើរទៅ លើភ្លឺស្រែមួយកន្លែង មានអាសិរពិសកាចដេកនៅក្នុងរន្ធមួយ ។ វាមិនអាចខាំព្រះថេរៈដែលបិទបាំងដោយសំពត់កាសាយៈបាន ។ នាងដើរបណ្ដើរនឹកដល់ទានបណ្ដើរធ្វើដំណើរទៅដល់ទីនោះ ពស់ក៏លូនចេញអំពីរន្ធ ខាំនាងឲ្យដួលដេកនៅក្នុងទីនោះឯង នាងមានចិត្តជ្រះថ្លាធ្វើមរណកាលហើយ ទៅកើតនៅក្នុងវិមានមាសកំពស់ប្រមាណ ៣០ យោជន៍ ក្នុងឋានតាវត្តិង្ស មានអត្តភាព ៣ គាវុត ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ហាក់ដូចជាភ្ញាក់ឡើងអំពីការដេកលក់ដូច្នោះ ។

## វិធីធ្វើទិព្វសម្បត្តិឱ្យមាំមួន

នាងស្លៀកសំពត់ទិព្វប្រមាណ ១២ ហត្ថ មួយផ្ទាំង ដណ្ដប់មួយផ្ទាំង មាននាងទេពអប្សរ ១.០០០ ជាបរិវារ ដើម្បីប្រកាសបុព្វកម្ម ទើបឈរនៅត្រង់ទ្វារវិមាន ដែលប្រដាប់ដោយផ្តិលមាស ពេញដោយលាជមាសព្យួរយោង

ក្រឡេកមើលសម្បត្តិរបស់ខ្លួនហើយ ពិចារណាដោយទិព្វចក្ខុថា "យើងបាន ធ្វើកម្មអ្វីហ្ន៎ ទើបបានសម្បត្តិនេះ" បានដឹងថា "សម្បត្តិនេះ យើងបានដោយ សារផលនៃលាជ ដែលយើងបានថ្វាយចំពោះលោកម្ចាស់មហាកស្សបៈ" ។ នាងគិតថា "យើងបានសម្បត្តិបែបនេះ ព្រោះអាស្រ័យកម្មបន្តិចបន្តួច ដូច្នេះ ឥឡូវនេះ យើងមិនគួរប្រមាទទេ យើងគួរតែធ្វើវត្តបដិបត្តិបម្រើលោក ដើម្បី ធ្វើសម្បត្តិនេះឲ្យមាំមួន" លុះគិតដូច្នេះហើយ ក៏បានកាន់យកអំបោស និង កញ្ច្រែងសម្រាប់ចាក់សំរាមដែលធ្វើអំពីមាស ទៅបោសបរិវេណរបស់ព្រះថេរៈ ដម្កល់ទឹកឆាន់ និងទឹកប្រើប្រាស់ទុកអំពីព្រលឹម ។ ព្រះថេរៈឃើញដូច្នេះ ក៏ សម្គាល់ថា ជាវត្តរបស់ភិក្ខុកំលោះ ឬសាមណេររូបណាមួយ ។ សូម្បីថ្ងៃទី ២ នាងក៏បានធ្វើដូច្នោះទៀត ។ ចំណែកព្រះថេរៈ ក៏សម្គាល់ដូច្នោះទៀត ។ តែក្នុងថ្ងៃទី ៣ ព្រះថេរៈបានឮសំឡេងអំបោសដែលនាងបោស និងឃើញពន្លឺ ផ្សាយចេញពីសរីរៈរបស់នាង ចាំងចូលទៅក្នុងតាមប្រហោងសោរ ក៏បើក ទ្វារ (ចេញមក) សួរថា "នរណា បោសបរិវេណនេះ?" ។

នាងលាជ. លោកម្ចាស់ ខ្ញុំនេះឯង ជាឧបដ្ឋាយិការបស់លោកម្ចាស់ ឈ្មោះ លាជទេពធីតា ។

ព្រះថេរៈ. ឧបដ្ឋាយិការបស់អាត្មា មានឈ្មោះយ៉ាងនោះ មើលទៅដូច ជាមិនមាន ។

នាងលាជ. លោកម្ចាស់ ខ្ញុំព្រះករុណាជាអ្នកថែរក្សាស្រែស្រូវសាលី បានថ្វាយលាជចំពោះលោកម្ចាស់ហើយ មានចិត្តជ្រះថ្លា កំពុងតែធ្វើដំណើរត្រឡប់ទៅវិញ ត្រូវពស់ចឹក ធ្វើមរណកាលហើយក៏កើតក្នុងទេវលោកជាន់តាវត្តិង្ស លោកម្ចាស់ដ៏ចម្រើន នាងខ្ញុំគិតថា "សម្បត្តិនេះ យើងបានព្រោះអាស្រ័យលោកម្ចាស់ សូម្បីក្នុងពេលនេះ យើងនឹងធ្វើវត្តបដិបត្តិចំពោះលោកម្ចាស់ ដើម្បីធ្វើសម្បត្តិឲ្យឋិតថេរ ទើបបានមក" ។

ព្រះថេរៈ. ទាំងថ្ងៃម្សិលមិញ ទាំងម្សិលម៉្ងៃ នាងបោសទីនេះ នាងតែម្នាក់ប៉ុណ្ណោះឬ ដម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ ។

នាងលាជ. យ៉ាងនោះឯង លោកម្ចាស់ ។

ព្រះថេរៈ. ម្នាលនាងទេពធីតា នាងចូរចៀសចេញទៅ វត្តដែលនាងធ្វើហើយ ក៏ចាត់ទុកថានាងបានធ្វើហើយចុះ ចាប់ពីពេលនេះតទៅ នាងកុំមកកាន់ទីនេះទៀត ។

នាងលាជ. លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំញ៉ាំងនាងខ្ញុំឲ្យវិនាសឡើយ សូមលោកម្ចាស់មេត្តាឲ្យនាងខ្ញុំធ្វើវត្តបម្រើលោកម្ចាស់ ដើម្បីធ្វើសម្បត្តិរបស់នាងខ្ញុំឲ្យគង់វង់ចុះ ។

ព្រះថេរៈ. ម្នាលនាងទេពធីតា នាងចូរចៀសចេញ នាងកុំធ្វើឲ្យអត្ថាត្រូវព្រះធម្មកថិកទាំងឡាយ ដែលអង្គុយលើធម្មាសនៈចាប់ផ្លិតដ៏វិចិត្រពោល

ក្នុងអនាគតថា បានឮថា មាននាងទេពធីតាម្នាក់មកធ្វើវត្តបដិបត្តិ ដម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ដើម្បីព្រះមហាកស្សបត្ថេរ ចាប់អំពីពេលនេះតទៅ នាងកុំមកកាន់ទីនេះ នាងចូរត្រឡប់ទៅវិញចុះ” ។

នាងនៅតែអង្វរព្រះថេរៈដដែលៗ ទៀតថា សូមលោកម្ចាស់កុំឲ្យនាងខ្ញុំ វិនាសឡើយ ។

ព្រះថេរៈគិតថា “នាងទេពធីតានេះ មិនស្តាប់ពាក្យរបស់យើង” ទើបទះដៃ ហើយពោលថា “នាងមិនស្គាល់ប្រមាណខ្លួន” ។ នាងមិនអាចឋិតនៅទីនោះបាន ក៏ហោះឡើងកាន់អាកាស ផ្គងអញ្ជលីឈរស្រែកយំខ្សឹកខ្សួលក្នុងអាកាសថា “លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំឲ្យសម្បត្តិដែលនាងខ្ញុំបានហើយវិនាសឡើយ សូមឲ្យនាងខ្ញុំធ្វើសម្បត្តិឲ្យមាំមួនផងចុះ” ។

## បុណ្យឱ្យកើតសេចក្តីសុខក្នុងភពទាំងពីរ

ព្រះសាស្តា ទ្រង់ប្រថាប់នៅក្នុងព្រះគន្ធកុដិ ទ្រង់បានឮសំឡេងទេពធីតានោះស្រែកយំ ទ្រង់ផ្សាយព្រះរស្មីទៅ ហាក់ដូចជាទ្រង់ប្រថាប់នៅក្នុងទីចំពោះមុខនាងទេពធីតា ទ្រង់ត្រាស់ថា “ម្នាលទេពធីតា ការសង្រួមជាការៈរបស់កស្សបៈបុត្ររបស់តថាគត ប៉ុន្តែការកំណត់ដឹងថា នោះជាប្រយោជន៍របស់យើង ហើយប្រាថ្នាធ្វើបុណ្យជាការៈរបស់អ្នកត្រូវការបុណ្យ ព្រោះថាការធ្វើបុណ្យ ជាហេតុឲ្យកើតសុខទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ

លុះទ្រង់ត្រាស់ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ បាន ត្រាស់ព្រះគាថានេះថា ៖

៣.បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ
តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ។

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឲ្យរឿយៗ គួរធ្វើសេចក្ដី
ពេញចិត្តក្នុងបុណ្យនោះ (ព្រោះថា) ការសន្សំបុណ្យ តែងនាំ
សេចក្ដីសុខមកឲ្យ ។

## អធិប្បាយគាថា

សេចក្ដីនៃព្រះគាថានោះថា ប្រសិនបើបុគ្គលគប្បីធ្វើបុណ្យ មិនគប្បី លះបង់ដោយយល់ថា "យើងធ្វើបុណ្យម្ដងហើយ ល្មមហើយ ដោយបុណ្យ ប៉ុណ្ណេះ គប្បីធ្វើឲ្យរឿយៗ សូម្បីក្នុងខណៈធ្វើបុណ្យនោះ គប្បីធ្វើសេចក្ដី ពេញចិត្ត គឺ សេចក្ដីពេញចិត្ត បានដល់ កើតឧស្សាហៈក្នុងបុណ្យនោះឯង ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះការសន្សំបុណ្យឲ្យកើតសុខ អធិប្បាយថា ព្រោះថា ការសន្សំ គឺ ការចម្រើនបុណ្យ ឈ្មោះថា ឲ្យកើតសុខ ព្រោះជាហេតុនាំ សេចក្ដីសុខមកឲ្យ ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។

ក្នុងវេលាចប់ទេសនា ទេពធីតាឈរនៅក្នុងទីបំផុតផ្លូវ ៤៥ យោជន៍

នុ៎ះឯង ក៏បានសម្រេចសោតាបត្តិផលហើយ ដូច្នេះឯង ។

ចប់ រឿងលាជទេពធីតា

# ៤. រឿងអនាថបិណ្ឌិកសេដ្ឋី

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធលោកអនាថ-បិណ្ឌិកសេដ្ឋី ត្រាស់ព្រះធម្មទេសនានោះថា **បាបោបិ បស្សតី ភទ្រំ (សូម្បីបុគ្គលអ្នកធ្វើបាប រមែងឃើញបាបថាល្អ)** ជាដើម ។

សេដ្ឋីធំនុកបម្រុងភិក្ខុសាមណេរជានិច្ច

សេចក្តីពិស្តារថា អនាថបិណ្ឌិកសេដ្ឋី ចំណាយទ្រព្យ ៥៤ កោដិ កសាងវិហារ កាលព្រះសាស្តាទ្រង់ប្រថាប់នៅក្នុងវត្តជេតពន លោកទៅកាន់វត្តមួយថ្ងៃ ៣ ដង រាល់ៗ ថ្ងៃ មុននឹងគេធ្វើដំណើរទៅកាន់វត្ត គេបានគិតថា "សាមណេរក្តី ភិក្ខុកំលោះក្តី គប្បីក្រឡេកមើលដៃរបស់យើង ដោយគិតថា សេដ្ឋីនោះកាន់វត្ថុអ្វីមកខ្លះ ដូច្នេះ ទើបគាត់មិនមានឈ្មោះថា មានដៃទទេទៅឡើយ កាលទៅវេលាព្រឹកឲ្យមនុស្សកាន់បបរទៅ បរិភោគអាហារព្រឹកហើយ ឲ្យមនុស្សកាន់ភេសជ្ជៈទាំងឡាយ មានទឹកដោះថ្លា ទឹកដោះខាប់ជាដើមទៅ ក្នុងពេលរសៀលឲ្យអ្នកបម្រើកាន់វត្ថុផ្សេងៗ មានកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាបនិងសំពត់ជាដើមទៅកាន់វិហារ ថ្វាយទាន រក្សាសីល យ៉ាងនេះរាល់ៗ ថ្ងៃអស់កាលជានិច្ច ។ ក្នុងកាលតមក លោកសេដ្ឋីក៏ដល់នូវការអស់ទ្រព្យ ទាំងពួកពាណិជ្ជ ក៏បានចងការទ្រព្យអំពីគាត់ ១៨ កោដិទៀត ។ ប្រាក់ ១៨ កោដិ

ដែលជាសម្បត្តិនៃត្រកូលរបស់គាត់ ដែលកប់ទុកនៅត្រង់ឆ្នេរស្ទឹងនោះ កាលច្រាំងបាក់ដោយសារទឹក ក៏ហូរចូលទៅកាន់មហាសមុទ្រ ។ ទ្រព្យរបស់លោកសេដ្ឋី បានដល់នូវការអស់ទៅដោយលំដាប់ ដោយប្រការយ៉ាងនេះឯង ។

សេដ្ឋីសូម្បីគាត់ធ្លាក់ខ្លួនក្រយ៉ាងនោះហើយក៏ដោយ ក៏គាត់នៅតែថ្វាយទានចំពោះសង្ឃជានិច្ច គ្រាន់តែទេយ្យវត្ថុដែលថ្វាយចំពោះសង្ឃនោះមិនបានប្រណីត ។ ក្នុងថ្ងៃមួយ ត្រូវព្រះសាស្តាត្រាស់សួរថា "ម្នាលគហបតី ទានក្នុងត្រកូលអ្នកនៅតែឲ្យទេឬ" ក៏ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ទានក្នុងត្រកូលខ្ញុំព្រះអង្គនៅតែឲ្យ គ្រាន់តែទាននោះ មានបាយចុងអង្ករ និងទឹកជ្រក់ជាគម្រប់ពីរ" ។

## កាលចិត្តជ្រះថ្លា ទានដែលថ្វាយហើយមិនមែន ជារបស់សៅហ្មងឡើយ

គ្រានោះ ព្រះសាស្តាត្រាស់នឹងលោកសេដ្ឋីថា "ម្នាលគហបតី អ្នកកុំគិតឡើយថា ទានរបស់យើងសៅហ្មង ព្រោះថា កាលចិត្តប្រណីតហើយ ទានដែលបុគ្គលបានថ្វាយចំពោះព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើម ក៏មិនឈ្មោះថា សៅហ្មងឡើយ ម្នាលគហបតី ម្យ៉ាងទៀត អ្នកបានថ្វាយទានចំពោះព្រះអរិយបុគ្គល ៨ ពួកហើយ ចំណែកតថាគត ក្នុងកាលជាវេលាមព្រាហ្មណ៍នោះ ធ្វើមនុស្សក្នុងជម្ពូទ្វីបទាំងអស់ឲ្យសម្រាកការភ្ជួរស្រែ ញ៉ាំងមហាទាន

ឲ្យប្រព្រឹត្តទៅហើយ មិនបានទក្ខិណេយ្យបុគ្គលណានីមួយ សូម្បីអ្នកដល់ត្រៃ-សរណៈ ឈ្មោះថា ទក្ខិណេយ្យបុគ្គលទាំងឡាយ បុគ្គលរកបានដោយលំបាក ដូច្នេះ ព្រោះហេតុនោះ អ្នកកុំគិតឡើយថា ទានរបស់យើងសៅហ្មង” ដូច្នេះហើយ ទ្រង់ក៏ត្រាស់វេលាមសូត្រឲ្យលោកសេដ្ឋីស្ដាប់ ។

## ទេវតាដាស់តឿនសេដ្ឋីឱ្យឈប់បរិច្ចាគ

គ្រានោះ ទេវតាដែលអាស្រ័យនៅត្រង់ខ្លោងទ្វារផ្ទះរបស់លោកសេដ្ឋី កាលព្រះសាស្ដា និងសាវកទាំងឡាយចូលទៅកាន់ផ្ទះ មិនអាចនឹងនៅខាងលើខ្លោងទ្វារបាន ដោយតេជៈនៃព្រះសាស្ដា និងសាវកទាំងឡាយ បានគិតថា “ព្រះសាស្ដា និងពួកសាវក មិនអាចចូលទៅកាន់ផ្ទះនោះបានដោយប្រការណា យើងនិងញុះញង់លោកសេដ្ឋីដោយប្រការនោះ” សូម្បីបំណងនឹងពោលដែរ ក៏មិនអាចពោលពាក្យអ្វីៗ បាន ក្នុងកាលដែលសេដ្ឋីនៅជាឥស្សរៈ” បានគិត “ឥឡូវនេះ សេដ្ឋីបានធ្លាក់ខ្លួនក្រហើយ គង់នឹងជឿពាក្យរបស់យើង” លុះដល់វេលារាត្រី បានចូលទៅកាន់បន្ទប់ដ៏មានសិរីរបស់លោកសេដ្ឋី ហើយឈរក្នុងអាកាស ។

គ្រានោះ លោកសេដ្ឋីឃើញទេវតានោះហើយ សួរថា នរណា?

ទេវតា. មហាសេដ្ឋី ខ្ញុំជាទេវតាអាស្រ័យនៅត្រង់ខ្លោងទ្វារទី ៤ របស់លោក មកនេះដើម្បីដាស់តឿនលោក ។

សេដ្ឋី. បើដូច្នោះ អញ្ជើញអ្នកនិយាយមកចុះ ។

ទេវតា. មហាសេដ្ឋី លោកមិនក្រឡេកមើលដល់កាលជាខាងក្រោយទេឬ លោកចំណាយទ្រព្យយ៉ាងច្រើន ក្នុងសាសនារបស់ព្រះសមណគោតម ឥឡូវនេះ លោកធ្លាក់ខ្លួនក្រហើយ នៅតែមិនលះបង់ការចំណាយទ្រព្យទៀត ប្រសិនបើលោកនៅតែប្រព្រឹត្តយ៉ាងនេះ តែ ២-៣ ថ្ងៃទៀត លោកប្រាកដជារកអាហារបរិភោគ និងគ្រឿងស្លៀកពាក់មិនបាន លោកចូរបញ្ឈប់ការបរិច្ចាគហួសកំលាំង ហើយប្រកបការងារទាំងឡាយ ដើម្បីប្រមូលទ្រព្យសម្បត្តិទុកចុះ ។

សេដ្ឋី. នេះជាឱវាទ ដែលអ្នកឲ្យដល់ខ្ញុំឬ ?

ទេវតា. ត្រូវហើយ មហាសេដ្ឋី ។

សេដ្ឋី. ម្នាលទេវតា អ្នកចូរអញ្ជើញទៅវិញចុះ ខ្ញុំ ដែលបុគ្គលដូចជាអ្នក សូម្បីទាំងរយទាំងពាន់ទាំងសែននាក់ ក៏មិនអាចធ្វើឲ្យខ្ញុំញាប់ញ័របានដែរ អ្នកបានពោលពាក្យមិនសមគួរ ដូច្នេះ អ្នកក៏មិនគួរនឹងនៅក្នុងផ្ទះរបស់ខ្ញុំដែរ អ្នកចូរចេញអំពីផ្ទះរបស់ខ្ញុំឲ្យឆាប់ៗ ។

ទេវតានោះ ស្តាប់ពាក្យរបស់លោកសេដ្ឋីដែលជាសោតាបន្ន ជាអរិយសាវក មិនអាចតាំងនៅបាន ទើបនាំទារកទាំងឡាយចេញទៅ គ្រាចេញទៅហើយ មិនបានទីអាស្រ័យក្នុងទីដទៃ ក៏គិតថា "យើងនឹងឲ្យលោកសេដ្ឋីអត់

ទោស ហើយនឹងនៅក្នុងទីដដែលនោះវិញ" ក៏បានចូលទៅរកទេវបុត្រដែលរក្សាព្រះនគរ ប្រាប់នូវកំហុសដែលខ្លួនបានធ្វើហើយ ហើយពោលថា "មកចុះលោក សូមលោកនាំខ្ញុំទៅកាន់សម្នាក់របស់លោកសេដ្ឋី ឲ្យលោកសេដ្ឋីអត់ទោស ហើយឲ្យទីនៅដល់ខ្ញុំ" ។ ទេវបុត្រហាមទេវតានោះថា ដោយពោលថា "នាងពោលពាក្យមិនសមគួរ ខ្ញុំមិនអាចទៅកាន់សម្នាក់របស់លោកសេដ្ឋីនោះបានទេ" ។ ទេវតានោះ ទៅកាន់សម្នាក់របស់មហារាជទាំង ៤ ក៏ត្រូវមហារាជទាំង ៤ ប្រកែកមិនព្រមជូនទៅកាន់សម្នាក់សេដ្ឋី ទើបចូលទៅគាល់សក្កទេវរាជ ក្រាបទូលរឿងនោះឲ្យទ្រង់បានជ្រាប "ហើយទូលអង្វរគួរឲ្យអាណិតថា បពិត្រព្រះឧប្បត្តិទេព ខ្ញុំព្រះអង្គមិនមានទីនៅ ត្រូវដឹកដៃទារកទាំងឡាយដើរដោយលំបាក គ្មានទីពឹង សូមមហារាជទ្រង់ប្រោសញ៉ាំងសេដ្ឋីឲ្យនូវទីនៅដល់ខ្ញុំព្រះអង្គផងចុះ" ។

## សក្កទេវរាជទ្រង់ប្រាប់ឧបាយដល់ទេវតា

គ្រានោះ សក្កទេវរាជត្រាស់នឹងទេវតានោះថា សូម្បីយើងក៏មិនហ៊ានពោលពាក្យអ្វីៗ នឹងសេដ្ឋី ព្រោះហេតុនៃអ្នកដែរ តែយើងនឹងប្រាប់ឧបាយមួយដល់អ្នក ។

ទេវតា. បពិត្រព្រះឧប្បត្តិទេព ប្រពៃណាស់ សូមព្រះអង្គទ្រង់ត្រាស់ប្រាប់មកចុះ ។

សក្កៈ. ម្នាលទេវតា អ្នកចូរទៅចុះ អ្នកចូរក្លែងភេទជាស្មៀនរបស់សេដ្ឋី ហើយឲ្យបុគ្គលម្នាក់នាំសៀវភៅ (បញ្ជីប្រាក់) អំពីដៃលោកសេដ្ឋីមក ហើយយកទៅទារបំណុលដែលមានទ្រព្យ ១៨ កោដិ ដែលពួកឈ្មួញខ្ចីយកទៅ ដោយអានុភាពរបស់ខ្លួន ហើយនាំមកដាក់ឲ្យពេញក្នុងឃ្លាំងទទេ ទ្រព្យ ១៨ កោដិ ដែលលិចចូលកាន់មហាសមុទ្រក្តី ទ្រព្យ ១៨ កោដិ ចំណែកដទៃដែលមិនមានម្ចាស់ មាននៅក្នុងទីនោះក្តី ចូរប្រមូលទ្រព្យទាំងអស់នោះ មកដាក់ឲ្យពេញក្នុងឃ្លាំងទទេរបស់សេដ្ឋី លុះធ្វើកម្មបែបនោះឲ្យជាទណ្ឌកម្មហើយ សូមខមាទោសលោកសេដ្ឋីចុះ ។

## សេដ្ឋីត្រឡប់ជាមានទ្រព្យដូចដើម

ទេវតានោះ ទទួលព្រមដោយពាក្យថា "ប្រពៃហើយ ព្រះឧប្បត្តិទេព" ហើយធ្វើកម្មគ្រប់យ៉ាងតាមន័យដែលសក្កទេវរាជត្រាស់ប្រាប់នោះឯង ញ៉ាំងឃ្លាំងដ៏មានសិរីរបស់លោកសេដ្ឋីឲ្យភ្លឺស្វាងហើយ ឋិតនៅឰដ៏អាកាស កាលលោកសេដ្ឋីសួរថា "នរណានុ៎ះ" ក៏ប្រាប់ថា "មហាសេដ្ឋី ខ្ញុំជាទេវតាអន្ធពាលដែលស្ថិតនៅទីឯខ្លោងទ្វារទី ៤ របស់លោក ពាក្យណាដែលខ្ញុំបានពោលហើយក្នុងសម្នាក់របស់លោក ដោយភាពល្ងង់ខ្លៅរបស់ខ្ញុំ សូមលោកអត់ទោសនោះ ដល់ខ្ញុំផងចុះ ព្រោះខ្ញុំបានធ្វើទណ្ឌកម្ម ដោយការប្រមូលទ្រព្យ ៥៤ កោដិមកដាក់ទុកពេញឃ្លាំងទទេ តាមបញ្ជារបស់សក្កទេវរាជហើយ ខ្ញុំកាលមិនមាន

ទីនៅ រមែងលំបាក” ។ អនាថបិណ្ឌិកសេដ្ឋីគិតថា “ទេវតានេះ ពោលថា ទណ្ឌកម្មដែលខ្លួនធ្វើហើយ និងដឹងទោសកំហុសរបស់ខ្លួន យើងនឹងនាំទេវតានេះទៅគាល់ព្រះសម្មាសម្ពុទ្ធ” ។ សេដ្ឋីនាំទេវតានោះ ទៅកាន់សម្នាក់របស់ព្រះសាស្តា ក្រាបទូលនូវអំពើដែលទេវតានោះបានធ្វើហើយទាំងអស់ ។ ទេ-វតាក្រាបចុះទៀបព្រះយុគលបាទនៃព្រះសាស្តា ហើយក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនជ្រាបព្រះគុណទាំងឡាយរបស់ព្រះអង្គ បានពោលពាក្យដ៏អាក្រក់គ្រោតគ្រាត ព្រោះភាពជាបុគ្គលអន្ធពាល សូមព្រះអង្គទ្រង់អត់នូវទោសនោះដល់ខ្ញុំព្រះអង្គផងចុះ (ទេវតា) សូមខមាទោសព្រះសាស្តាហើយ ទើបសូមខមាទោសមហាសេដ្ឋីជាក្រោយ ។

## កាលកម្មឱ្យផល បុគ្គលល្ងង់ទើបឃើញត្រូវ

ព្រះសាស្តា មុននឹងទ្រង់ឲ្យឱវាទសេដ្ឋី និងទេវតា ដោយអំណាចវិបាកនៃកម្មល្អ និងកម្មអាក្រក់នោះឯង ទើបត្រាស់ថា “ម្នាលគហបតី បុគ្គលអ្នកធ្វើបាបក្នុងលោកនេះ ដរាបណាដែលបាបមិនទាន់ឲ្យផល ដរាបនោះ បុគ្គលរមែងឃើញបាបថា ល្អ តែកាលណាបាបរបស់គេឲ្យផល ក្នុងកាលនោះ គេរមែងឃើញបាបថា អាក្រក់ពិតៗ ចំណែកបុគ្គលអ្នកធ្វើបុណ្យ រមែងឃើញបុណ្យថាអាក្រក់ ដរាបណាដែលបុណ្យមិនទាន់ឲ្យផល តែកាលណាបុណ្យរបស់គេឲ្យផល កាលនោះ គេរមែងឃើញបុណ្យថា ល្អពិតៗ ដូច្នេះហើយ

កាលទីងទ្រងបន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបបានភាសិតព្រះគាថាទាំងនេះថា ៖

៤.បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ (បាបោ) បាបានិ បស្សតិ ។
ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតី ភទ្រំ អថ (ភទ្រោ) ភទ្រានិ បស្សតិ ។

បាប មិនទាន់ឲ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែសេចក្តីចម្រើនត្រឹមនោះ លុះកាលណាបាបឲ្យផល មនុស្សបាប ទើបឃើញបាប ក្នុងកាលនោះ ។

អំពើល្អ មិនទាន់ឲ្យផលត្រឹមណា មនុស្សល្អ នៅឃើញតែត្រឹមបាបនោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អ ទើបឃើញល្អក្នុងកាលនោះ ។

## អធិប្បាយគាថា

បុគ្គលអ្នកប្រកបដោយបាបកម្ម មានទុច្ចរិតផ្លូវកាយជាដើម ឈ្មោះថា មនុស្សបាប ក្នុងព្រះគាថានេះ ។ ក៏មនុស្សបាបនោះ កាលនៅសោយសុខដែលកើតឡើង ដោយអានុភាពនៃសុចរិតកម្មក្នុងកាលមុន រមែងឃើញបាបថាល្អ ។

បទថា យាវ បាបំ ន បច្ចតិ (ដរាបណាបាបមិនទាន់ឲ្យផល) ជាដើម

សេចក្តីថា បាបកម្មរបស់បុគ្គលនោះ នៅមិនទាន់ឲ្យផលក្នុងបច្ចុប្បន្នភព ឬ សម្បរាយភព (អ្នកធ្វើបាប រមែងឃើញបាបថាល្អ ដរាបនោះ) ។ តែកាលណា បាបកម្មរបស់គេនោះ ឲ្យផលក្នុងបច្ចុប្បន្នភព ឬសម្បរាយភព កាលនោះ អ្នកធ្វើបាបនោះ កាលសោយកម្មករណ៍ផ្សេងៗ ក្នុងបច្ចុប្បន្ន និងទុក្ខក្នុងអបាយ ក្នុងសម្បរាយភព រមែងឃើញបាបថា អាក្រក់ដោយពិត ។

ក្នុងព្រះគាថាទី ២ (គប្បីជ្រាបន័យដូចតទៅនេះ) បុគ្គលអ្នកប្រកបកម្មល្អ មានកាយសុចរិតជាដើម ឈ្មោះថា មនុស្សល្អ មនុស្សល្អនោះ កាលបើសោយទុក្ខ ដែលកើតឡើងដោយអានុភាពនៃទុច្ចរិតក្នុងកាលមុន រមែងឃើញអំពើល្អថា អាក្រក់ ។ បទថា **យាវ ភទ្រំ ន បច្ចតិ (ដរាបណាដែលកម្មល្អមិនទាន់ឲ្យផល)** ជាដើម សេចក្តីថា អំពើល្អរបស់គេនោះ នៅមិនទាន់ឲ្យផល ក្នុងបច្ចុប្បន្នភព ឬសម្បរាយភពត្រឹមណា (មនុស្សធ្វើល្អ រមែងឃើញអំពើល្អ ថាអាក្រក់ត្រឹមនោះ) ។ តែកាលណាកម្មល្អនោះឲ្យផល កាលនោះ បុគ្គលធ្វើកម្មល្អនោះ កាលសោយសុខដែលអាស្រ័យអាមិស មានលាភ និងសក្ការៈជាដើម ក្នុងបច្ចុប្បន្នភព និងសុខដែលអាស្រ័យសម្បត្តិដែលជាទិព្វ ក្នុងសម្បរាយភព រមែងឃើញកម្មល្អថា ល្អពិតៗ ដូច្នេះ ។

លុះចប់ព្រះធម៌ទេសនា ទេវតានោះ បានតាំងនៅក្នុងសោតាបត្តិផល

ព្រះធម្មទេសនា មានប្រយោជន៍ដល់បរិស័ទដែលមកប្រជុំគ្នា ដូច្នេះឯង ។

ចប់ រឿងអនាថបិណ្ឌិកសេដ្ឋី

# ៥. រឿងភិក្ខុមិនចេះទុកដាក់បរិក្ខារ

*ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ដែលមិនចេះទុកដាក់បរិក្ខារ ត្រាស់ព្រះធម្មទេសនានេះថា* ***មាវមញ្ញេថ បាបស្ស (បុគ្គលមិនគប្បីមើលងាយបាប)*** *ជាដើម ។*

### របស់សង្ឃប្រើហើយគួរប្រញាប់រក្សាទុកដាក់វិញ

*បានឮថា ភិក្ខុនោះប្រើប្រាស់បរិក្ខារ មានគ្រែ និងតាំងជាដើមណាមួយ នៅទីខាងក្រៅហើយ ទុកចោលនៅក្នុងទីនោះៗ ឯង ។ បរិក្ខាររមែងវិនាសទៅ ព្រោះភ្លៀងខ្លះ កំដៅថ្ងៃខ្លះ ពួកសត្វមានកណ្ដៀរជាដើមខ្លះ ។ ភិក្ខុនោះ កាលពួកភិក្ខុដាស់តឿនថា "អ្នកមានអាយុ ធម្មតាបរិក្ខារ ភិក្ខុគួររក្សាទុកមិនមែនឬ" ត្រឡប់ជាពោលថា "អាវុសោ កម្មដែលខ្ញុំធ្វើនោះតិចតួចណាស់ បរិក្ខារនោះមិនមានចិត្ត ការវិចិត្រក៏មិនមាន" ដូច្នេះហើយ ក៏នៅតែធ្វើដូច្នោះទៀត ។ ភិក្ខុទាំងឡាយក្រាបទូលអំពើរបស់លោកចំពោះព្រះសាស្ដា ។ ព្រះសាស្ដាត្រាស់ឲ្យហៅភិក្ខុនោះមក ហើយត្រាស់សួរថា "ម្នាលភិក្ខុ អ្នកបានធ្វើយ៉ាងនោះពិតមែនឬ" សូម្បីត្រូវព្រះសាស្ដាត្រាស់សួរ ក៏ក្រាបទូលរបៀបមើលងាយយ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចម្រើន កម្មបន្តិចបន្តួចនោះនឹងជាអ្វី កម្មដែលខ្ញុំព្រះអង្គធ្វើហើយនោះ មិនចាត់ថាជាកម្មដែលខ្ញុំព្រះអង្គបានធ្វើទេ បរិក្ខារនោះមិន*

មានចិត្ត ការវិចិត្រក៏មិនមាន" ។

## កុំមើលងាយកម្មអាក្រក់ថាតិចតួច

គ្រានោះ ព្រះសាស្តាត្រាស់នឹងលោកថា "ម្នាលភិក្ខុ ការដែលភិក្ខុទាំងឡាយធ្វើយ៉ាងនោះ រមែងមិនគួរ ដែលឈ្មោះថា បាបកម្ម នរណាៗ មិនគួរមើលងាយថា តិចតួចឡើយ ដូចជា ភាជនៈដែលគេបើកគម្របតាំងទុកកណ្តាលវាល កាលភ្លៀងធ្លាក់មក រមែងមិនពេញដោយដំណក់ទឹកមួយដំណក់ ក៏ពិតតែថា កាលភ្លៀងធ្លាក់មករឿយៗ ភាជនៈនោះរមែងពេញដោយពិតៗ យ៉ាងណាមិញ បុគ្គលអ្នកធ្វើបាបកម្ម រមែងធ្វើគំនរបាបឲ្យចម្រើនឡើងដោយលំដាប់បានដោយពិត ដូច្នោះដូចគ្នា" កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

៥.មាវមញ្ញេថ បាបស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
អាបូរតិ ពាលោ បាបស្ស ថោកំ ថោកំបិ អាចិនំ ។

បុគ្គលមិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឲ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយដំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា បុគ្គលពាល កាលសន្សំបាប សូម្បីបន្តិចម្តងៗ គង់ពេញបានដោយបាប យ៉ាងនោះ

ដែរ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **មាវមញ្ញេថ** (មិនគួរមើលងាយ) សេចក្ដីថា បុគ្គលមិនគប្បីមើលងាយ ។ បទថា **បាបស្ស** (បាប) បានដល់ នូវបាប ។

បទថា **ន មត្តំ អាគមិស្សតិ** (បាបមានប្រមាណតិចនឹងមកមិនដល់) ន័យថា បុគ្គលមិនគួរមើលងាយបាបយ៉ាងនេះថា "យើងធ្វើបាប មានប្រមាណតិចតួច កាលណាបាបនោះនឹងមកឲ្យផល" ។ បទថា **ឧទកុម្ភោបិ** (សូម្បីក្អមទឹក) សេចក្ដីថា ភាជនៈដីប្រភេទណាមួយ ដែលគេបើកគម្របទុកចោលក្នុងវេលាភ្លៀងធ្លាក់ រមែងពេញដោយដំណក់ទឹកដែលធ្លាក់ចុះសូម្បីម្ដងមួយដំណក់ៗដោយលំដាប់បាន យ៉ាងណា បុគ្គលពាល កាលសន្សំ គឺ កាលកពូនបាបសូម្បីម្ដងបន្តិចៗ រមែងពេញដោយបាបបានដូច្នោះដូចគ្នា ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើន ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ សូម្បីព្រះសាស្ដា ក៏ទ្រង់បញ្ញត្តិសិក្ខាបទទុកថា "ភិក្ខុយកកម្រាលរបស់សង្ឃក្រាលក្នុងទីវាលហើយ មិនយកមកទុកដាក់ដូចដើមវិញ ត្រូវអាបត្តិឈ្មោះនេះ" ដូច្នេះឯង ។

ចប់ រឿងភិក្ខុមិនចេះរក្សាទុកបរិក្ខារ

# ៦. រឿងសេដ្ឋីឈ្មោះពិឡាលបទកៈ

*ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះពិឡាលបទកៈ (សេដ្ឋីជើងឆ្មា) ទ្រង់ត្រាស់ព្រះធម្មទេសនានេះថា* ***មាវមញ្ញេថ បុញ្ញស្ស (បុគ្គលមិនគួរមើលងាយបុណ្យ)*** *ជាដើម ។*

## ឱ្យទានខ្លួនឯង និងបបួលអ្នកអ្នកដទៃបានសម្បត្តិពីរយ៉ាង

*សេចក្ដីពិស្ដារថា សម័យមួយអ្នកក្រុងសាវត្ថីរួមគ្នាជាពួក នាំគ្នាថ្វាយទានចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ថ្ងៃមួយ ព្រះសាស្ដាមុននឹងទ្រង់ធ្វើអនុមោទនា បានត្រាស់យ៉ាងនោះថា "ឧបាសក ឧបាសិកាទាំងឡាយ បុគ្គលខ្លះក្នុងលោកនោះ ឲ្យទានដោយខ្លួនឯង (ប៉ុន្តែ) មិនបបួលអ្នកដទៃ គេនោះ រមែងបានភោគសម្បត្តិ (តែ) មិនមាននូវបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយៗ បុគ្គលខ្លះមិនឲ្យទានដោយខ្លួនឯង បបួលតែអ្នកដទៃឲ្យធ្វើ គេនោះ រមែងបានបរិវារសម្បត្តិ (តែ) មិនមាននូវភោគសម្បត្តិក្នុងទីនៃខ្លួនកើតហើយៗ បុគ្គលខ្លះ មិនឲ្យទានដោយខ្លួនឯងផង មិនបបួលអ្នកដទៃផង បុគ្គលនោះ រមែងមិនមានទាំងភោគសម្បត្តិ ទាំងបរិវារសម្បត្តិក្នុងទីដែលខ្លួនកើតហើយ ជាមនុស្សស៊ីដែលគេ បុគ្គលខ្លះទៀត ឲ្យទានដោយខ្លួនឯងផង បបួលអ្នកដទៃផង បុគ្គលនោះ រមែងបានទាំងភោគសម្បត្តិ និងបរិវារសម្បត្តិក្នុងទី*

ដែលខ្លួនកើតហើយៗ ។

## បណ្ឌិតអំពាវនាវសូមរបស់ធ្វើបុណ្យ

គ្រានោះ បុរសជាបណ្ឌិតម្នាក់ ស្ដាប់ព្រះធម៌ទេសនានោះហើយ គិតថា ឱ! ហេតុនេះគួរឲ្យអស្ចារ្យណាស់ ឥឡូវនេះ យើងនឹងធ្វើកម្មដែលប្រព្រឹត្តទៅ ដើម្បីបាននូវសម្បត្តិទាំងពីរ ទើបក្រាបទូលព្រះសាស្ដា ក្នុងវេលាដែលស្ដេចក្រោកទៅថា "បពិត្រព្រះអង្គដ៏ចម្រើន ស្អែកនេះ សូមព្រះអង្គទ្រង់ទទួលភិក្ខារបស់ពួកខ្ញុំព្រះអង្គ" ។

ព្រះសាស្ដា. ម្នាលឧបាសក អ្នកត្រូវការភិក្ខុប៉ុន្មានរូប ?

បុរសបណ្ឌិត. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គត្រូវការភិក្ខុទាំងអស់ ។

ព្រះសាស្ដាទ្រង់ទទួលហើយ បុរសជាបណ្ឌិតនោះ ក៏ចូលទៅកាន់ស្រុកឃោសនាថា "ម្នាលអ្នកទាំងឡាយ ខ្ញុំបាននិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដើម្បីឆាន់កត្ដាហារក្នុងថ្ងៃស្អែកនេះ អ្នកណាអាចថ្វាយដល់ភិក្ខុប៉ុន្មានរូប អ្នកនោះចូរឲ្យវត្ថុផ្សេងៗ មានអង្ករជាដើម ដើម្បីប្រយោជនដល់អាហារ មានយាគូជាដើម ដើម្បីភិក្ខុប៉ុណ្ណោះរូប ពួកយើងនឹងឲ្យគេដាំស្ល់ក្នុងទីមួយ ហើយថ្វាយទាន" ។ គ្រានោះ សេដ្ឋីម្នាក់ ឃើញបុរសនោះមកដល់ទ្វារផ្សាររបស់ខ្លួន ក៏ខឹងថា "អ្នកនេះ មិននិមន្តភិក្ខុឲ្យល្មមកំលាំងរបស់ខ្លួន ចាំបាច់មកដើរបបួលអ្នកស្រុកទាំងអស់ធ្វើអ្វីទៀត" ទើបប្រាប់ថា "អ្នកចូរយកភាជនៈដែលអ្នកកាន់

*មក” ដូច្នេះ ហើយក៏យកម្រាមដៃ ៣ ច្បិចអង្ករបន្តិច សណ្តែកខៀវបន្តិច សណ្តែករាជមាសបន្តិចឲ្យទៅបុរសនោះ ។ តាំងពីពេលនោះមក សេដ្ឋីនោះមានឈ្មោះថា* ***ពិឡាលបទកសេដ្ឋី*** *(សេដ្ឋីជើងឆ្មា) ។ សូម្បីកាលឲ្យគេសដ្ឋ: មានទឹកដោះថ្លា និងទឹកអំពៅជាដើម ក៏ផ្អៀងចំពួយកំសៀវចូលទៅក្នុងក្អម ធ្វើចំពួយកំសៀវនោះឲ្យជាប់ជាមួយនឹងមាត់ក្អម ឲ្យគេសដ្ឋ: មានទឹកដោះថ្លា និងទឹកអំពៅជាដើម ហូរចុះទៅម្តងមួយដំណក់ៗ បានឲ្យត្រឹមបន្តិចបន្តួចប៉ុណ្ណោះ ។ ឧបាសកនោះ ដាក់វត្ថុទានដែលមនុស្សឲ្យរួមគ្នា (តែ) ដាក់របស់ដែលលោកសេដ្ឋីឲ្យ ដោយឡែកផ្សេងអំពីគេ ។*

## សេដ្ឋីឱ្យមនុស្សជិតស្និទ្ធទៅស៊ើបមើល
## ការធ្វើរបស់បុរសអ្នកត្រែអង្គាស

*សេដ្ឋីនោះ ឃើញអំពើរបស់ឧបាសកនោះហើយ គិតថា “ហេតុអ្វីបានជាបុរសនោះ ចាំបាច់យករបស់ដែលយើងឲ្យ ទុកដោយឡែក” ទើបប្រើអ្នកបម្រើម្នាក់ឲ្យទៅតាមក្រោយបុរសនោះ ដោយពោលថា “ឯងចូរទៅ ចូរដឹងនូវកម្មដែលគេធ្វើនោះ” ។ ឧបាសកនោះទៅដល់រោងទានហើយ ពោលថា “សូមផលដ៏ធំ ចូរកើតមានដល់សេដ្ឋី” ដូច្នេះហើយ ដាក់អង្ករ ១-២ គ្រាប់ ដើម្បីប្រយោជន៍ដល់យាគូ កត្ត និងនំ ដាក់សណ្តែកខៀវខ្លះ សណ្តែករាជមាសខ្លះ ប្រេងមួយតក់ និងទឹកអំពៅមួយតក់ទៅក្នុងភាជន:គ្រប់ៗ ភាជន: ។ អ្នកបម្រើ*

នោះ បានទៅស៊ើបដឹងរឿងមកប្រាប់លោកសេដ្ឋី ។ សេដ្ឋីបានស្តាប់ពាក្យនោះហើយ គិតថា "ប្រសិនបើបុរសនោះពោលទោសយើងកណ្តាលបរិស័ទ មែននោះ បើវានិយាយដល់ឈ្មោះរបស់យើងក្លាម យើងនឹងប្រហារវាឲ្យស្លាប់" ។ ក្នុងថ្ងៃស្អែកឡើង សេដ្ឋីសៀតកូនកាំបិតក្នុងជាយសំពត់ស្លៀក ហើយដើរទៅឈរនៅក្បែររោងទាន ។

បុរសនោះ អញ្ចាសកិច្ចសង្ឃ មានព្រះពុទ្ធជាប្រធានហើយ បានក្រាបទូលព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានដើរបបួលមហាជនឲ្យថ្វាយទាននេះ ពួកមនុស្សដែលខ្ញុំព្រះអង្គបបួលហើយ បានឲ្យអង្ករជាដើមច្រើនខ្លះ តិចខ្លះតាមកំលាំងរបស់ខ្លួន សូមផលដ៏វិសាល (ដ៏ច្រើន) ចូរកើតមានដល់មហាជនទាំងអស់នោះចុះ" ។

សេដ្ឋីបានឮពាក្យនោះហើយ គិតថា "យើងមកដោយតាំងចិត្តថា បើវាលើកឈ្មោះរបស់យើងឡើងថា សេដ្ឋីឈ្មោះឯណោះកាន់យកអង្ករជាដើមដោយម្រាមដៃបីឲ្យ យើងនឹងសម្លាប់បុរសនោះ តែបុរសនោះបានធ្វើទានទាំងអស់រួមគ្នា ហើយពោលថា "ទានដែលជនទាំងឡាយណា វាល់ដោយនាឡិជាដើមហើយឲ្យក្តី ទានដែលជនទាំងឡាយណា កាន់យកដោយម្រាមដៃហើយឲ្យក្តី សូមផលដ៏វិសាល ចូរកើតមានដល់ជនទាំងអស់នោះចុះ" បើយើងមិនឲ្យបុរសរូបនោះអត់ទោសឲ្យទេ ទេវទណ្ឌនឹងធ្លាក់ចុះមកលើក្បាលរបស់យើង

មិនខាន ។ សេដ្ឋីនោះ ក្រាបចុះទៀបជើងរបស់ឧបាសកនោះ ហើយពោលថា "បពិត្រនាយ សូមលោកអត់ទោសឲ្យខ្ញុំផង" ឧបាសកនោះសួរថា "លោកសេដ្ឋី តើមានរឿងអ្វី?" ទើបប្រាប់រឿងនោះទាំងអស់ ។ ព្រះសាស្តាទ្រង់ជ្រាបកិរិយានោះហើយ ត្រាស់សួរអ្នកខ្វល់ខ្វាយក្នុងទាននោះថា "ឧបាសក តើមានរឿងអ្វី?" គេក្រាបទូលរឿងនោះទាំងអស់ តាំងអំពីថ្ងៃដែលកន្លងទៅហើយចំពោះព្រះសាស្តា ។

## កុំមើលងាយបុណ្យថាតិចតួច

គ្រានោះ ព្រះសាស្តាត្រាស់សួរសេដ្ឋីនោះថា "ម្នាលសេដ្ឋី តើរឿងនោះយ៉ាងនោះពិតមែនឬ?" កាលលោកសេដ្ឋីក្រាបទូលថា "ព្រះករុណាព្រះអង្គ" ទ្រង់ត្រាស់ថា "ម្នាលឧបាសក ដែលឈ្មោះថា បុណ្យ នរណាៗ មិនគួរមើលងាយថា មានប្រមាណតិចតួច បុគ្គលថ្វាយទានចំពោះភិក្ខុសង្ឃហើយ មិនគួរមើលងាយថា ជារបស់តិចតួច ព្រោះថា បុរសជាបណ្ឌិត ធ្វើបុណ្យរមែងពេញទៅដោយបុណ្យដោយលំដាប់ ប្រៀបដូចភាជនៈដែលចំហមាត់ រមែងពេញទៅដោយទឹក ដូច្នោះ" ដូច្នេះហើយ កាលទឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបបានត្រាស់ព្រះគាថានេះថា ៖

៦.មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ

អាបូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។

បុគ្គល មិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិនឲ្យផល ដូច្នេះឡើយ ប្រៀបដូចជាក្អមទឹក រមែងពេញបានដោយដំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្តងៗ គង់ពេញបានដោយបុណ្យយ៉ាងនោះដែរ ។

អធិប្បាយគាថា

ខ្លឹមសារនៃព្រះគាថានោះថា "បុរសជាបណ្ឌិត ធ្វើបុណ្យហើយ កុំមើលងាយ គឺ មិនគួរមើលងាយបុណ្យ យ៉ាងនេះថា យើងធ្វើបុណ្យមានប្រមាណតិច បុណ្យមានប្រមាណតិចនឹងមិនឲ្យផល បើដូច្នេះ កម្មតិចតួចនឹងឃើញយើងបានយ៉ាងណា ឬថា យើងនឹងឃើញកម្មនោះយ៉ាងណា កាលណាបុណ្យនោះនឹងឲ្យផល ដូចជា ភាជនៈដីដែលគេបើកគ្របចំហមាត់ទុកកណ្តាលវាល រមែងពេញដោយដំណក់ទឹកដែលធ្លាក់ចុះមក (ម្តងមួយដំណក់ៗ) មិនដាច់ខ្សែ យ៉ាងណា ធីរជន គឺ ជនជាបណ្ឌិត កាលសន្សំបុណ្យបន្តិចម្តងៗ ឈ្មោះថាពេញដោយបុណ្យបាន ក៏ដូច្នោះ" ។

ក្នុងកាលចប់ព្រះធម៌ទេសនា សេដ្ឋីនោះ បានសម្រេចសោតាបត្តិផល ព្រះធម្មទេសនា មានប្រយោជន៍ដល់បរិស័ទដែលមកប្រជុំគ្នា ដូច្នេះឯង ។

ចប់ រឿងសេដ្ឋីឈ្មោះពិឡាលបទកៈ

# ៧. រឿងមហាធនពាណិជ្ជ

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពាណិជ្ជអ្នកមានទ្រព្យច្រើន បានត្រាស់ព្រះធម្មទេសនានេះថា *វាណិជោវ ភយំ មគ្គំ (ដូចឈ្មួញ... វៀរផ្លូវដែលគួរខ្លាច)* ជាដើម ។

## ពាណិជ្ជនិមន្តភិក្ខុ ៥០០ រូប រួមដំណើរជាមួយគ្នា

ដូចបានស្តាប់មក ពួកចោរ ៥០០ នាក់ ស្វែងរកឱកាសដើម្បីប្លន់ទ្រព្យសម្បត្តិក្នុងផ្ទះរបស់ពាណិជ្ជនោះ តែមិនបានឱកាស ។ សម័យក្រោយមក ពាណិជ្ជនោះផ្ទុកទំនិញ ៥០០ រទេះ ពេញដោយរបស់របរហើយ ឲ្យគេប្រាប់ភិក្ខុទាំងឡាយថា "យើងនឹងទៅកាន់ទីឯណោះដើម្បីជួញ លោកម្ចាស់អង្គណាមានបំណងនិមន្តទៅកាន់ទីនោះ សូមលោកម្ចាស់ទាំងនោះនិមន្តចេញទៅ នឹងមិនលំបាកដោយភិក្ខាក្នុងដំណើរផ្លូវ" ។ ភិក្ខុ ៥០០ រូប ស្តាប់ដំណឹងនោះហើយ បាននិមន្តទៅជាមួយនឹងពាណិជ្ជនោះ ។ ឯចោរទាំងនោះ បានដឹងពត៌មានថា "ពាណិជ្ជនោះចេញដំណើរទៅហើយ" បានទៅពួនស្ទាក់ចាំប្លន់ត្រង់ដងព្រៃក្រាស់មួយ ។ ចំណែកពាណិជ្ជទៅហើយ ឈប់សម្រាកក្នុងស្រុកមួយក្បែរមាត់ព្រៃ ចាត់ចែងនូវពាហនៈទាំងឡាយ មានគោ និងរទេះជាដើមរួចហើយ ថ្វាយភិក្ខាដល់ភិក្ខុទាំងនោះជាប់មិនដាច់ អស់២-៣ ថ្ងៃ ។

ពួកចោរ កាលចាំឈ្លបយូរពេក ក៏ប្រើបុរសម្នាក់ឲ្យទៅ ដោយពាក្យថា "ឯងចូរទៅ ចូរដឹងនូវថ្ងៃដែលចេញដំណើររបស់ពាណិជ្ជនោះ ហើយចូរមកវិញ" ។ បុរសនោះធ្វើដំណើរទៅដល់ស្រុកនោះហើយ សួរបុរសជាសំឡាញ់ម្នាក់ថា "ម្នាលសំឡាញ់ កាលណាទើបពាណិជ្ជចេញដំណើរ" សំឡាញ់នោះឆ្លើយថា "២-៣ ថ្ងៃទៀត" ឆ្លើយដូច្នេះហើយ សួរថា "ចុះអ្នកឯងសួរដើម្បីអ្វី" គ្រានោះ បុរសនោះប្រាប់សំឡាញ់នោះថា "ពួកខ្ញុំជាចោរ ៥០០ ពួននៅក្នុងព្រៃមួយដើម្បីប្លន់ពាណិជ្ជនោះ" ។ ចំណែកសំឡាញ់ពោលថា "បើដូច្នោះ អ្នកចូរទៅចុះ ពាណិជ្ជនឹងចេញទៅឆាប់ៗ ឥឡូវនេះហើយ" បញ្ជូនបុរសនោះទៅហើយ គិតថា "តើយើងគួរហាមឃាត់ពួកចោរ ឬក៏ពាណិជ្ជ" សម្រេចចិត្តថា "តើមានប្រយោជន៍អ្វីដល់យើងដោយការប្រាប់ដំណឹងដល់ចោរទាំងនោះ ភិក្ខុ ៥០០ រូបចិញ្ចឹមជីវិតអាស្រ័យពាណិជ្ជ យើងនឹងឲ្យដំណឹងដល់ពាណិជ្ជ ហើយបានទៅកាន់សម្នាក់ពាណិជ្ជនោះ សួរថា "កាលណាលោកនឹងចេញដំណើរទៅ" ពាណិជ្ជប្រាប់ថា "៣ ថ្ងៃទៀត" ក៏ពោលថា "លោកចូរធ្វើតាមពាក្យរបស់ខ្ញុំបានឮថា ពួកចោរ ៥០០ ពួនចាំប្លន់លោកនៅក្នុងដងព្រៃមួយ ដូច្នេះ លោកកុំអាលធ្វើដំណើរទៅអី" ។

## ពាណិជ្ជត្រូវចោរស្ទាត់ ក៏ស្នាក់នៅក្នុងរវាងផ្លូវ

ពាណិជ្ជ. ហេតុអ្វី បានជាអ្នកដឹង?

បុរសជាសំឡាញ់. ខ្ញុំមានសំឡាញ់ម្នាក់នៅក្នុងក្រុមចោរទាំងនោះ ខ្ញុំដឹងព្រោះអាស្រ័យគេនិយាយប្រាប់ ។

ពាណិជ្ជ. បើដូច្នោះ តើមានប្រយោជន៍អ្វីដល់យើងដោយការចេញទៅអំពីទីនេះ ។ យើងនឹងត្រឡប់ទៅផ្ទះវិញ ។ កាលចាំពាណិជ្ជនោះយូរពេក ចោរទាំងនោះ ក៏បញ្ជូនបុរសនោះមកម្តងទៀត បុរសនោះមកដល់ទីនោះហើយ សួរសំឡាញ់នោះ បានដឹងដំណឹងនោះហើយ ទៅប្រាប់ពួកចោរថា "បានឮថាពាណិជ្ជត្រឡប់ទៅផ្ទះវិញ" ។ ពួកចោរស្តាប់ពាក្យនោះហើយ បានចេញអំពីដងព្រៃនោះទៅស្ទាក់នៅក្បែរផ្លូវដទៃទៀត ។ កាលស្ទាក់ចាំពាណិជ្ជយូរពេក ក៏ប្រើបុរសនោះឲ្យទៅក្នុងសម្នាក់របស់សំឡាញ់នោះម្តងទៀត ។ សំឡាញ់នោះដឹងថាពួកចោរស្ទាក់នៅក្នុងទីនោះហើយ ក៏ប្រាប់ពាណិជ្ជទៀត ។ ឈ្មួញគិតថា "សូម្បីយើងនៅទីនេះ ក៏មិនមានការខ្វះខាតអ្វីដែរ បើដូច្នោះ យើងមិនទៅណាទាំងអស់" យើងនឹងនៅទីនេះឯង" លុះគិតដូច្នេះហើយ ក៏ទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ ហើយប្រាប់ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន បានឮថាពួកចោរមានបំណងនឹងប្ចន់ខ្ញុំព្រះករុណា បានទៅពួនស្ទាក់នៅក្បែរផ្លូវមួយ លុះបានដឹងថា ឥឡូវនេះខ្ញុំព្រះករុណាត្រឡប់ទៅផ្ទះវិញ ក៏ទៅពួនស្ទាក់នៅក្បែរផ្លូវមួយទៀត ខ្ញុំព្រះករុណានឹងមិនទៅណាទាំងអស់ ខ្ញុំព្រះករុណានឹងសម្រាកនៅទីនេះសិន លោកម្ចាស់ទាំងឡាយមានបំណងនឹងនៅទីនេះ ក៏នៅចុះ មានបំណង

នឹងនិមន្តទៅ ក៏និមន្តទៅតាមសេចក្តីពេញចិត្តរបស់លោកម្ចាស់” ។ ពួកភិក្ខុពោលថា “បើដូច្នោះ ពួកអាត្មានឹងត្រឡប់” លុះព្រឹកឡើង លាពាណិជ្ជ និមន្តទៅកាន់ក្រុងសាវត្ថី ទៅដល់វត្តជេតពនថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីដ៏សមគួរ ។

## វត្ថុដែលគួរវៀរ

ព្រះសាស្តាត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនទៅជាមួយពាណិជ្ជដែលជាអ្នកមានទ្រព្យច្រើនទេឬ” កាលពួកភិក្ខុទាំងនោះក្រាបទូលថា “ព្រះករុណាព្រះអង្គ ពួកចោរពួនស្ទាក់នៅក្បែរផ្លូវទាំងសងខាងដើម្បីប្លន់ពាណិជ្ជដែលមានទ្រព្យច្រើន ព្រោះហេតុនោះ ទើបពាណិជ្ជគេស្នាក់នៅទីនោះឯង ចំណែកពួកខ្ញុំព្រះអង្គលាគេត្រឡប់មកវិញ” ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ពាណិជ្ជដែលមានទ្រព្យច្រើន រមែងវៀរផ្លូវដែលមានភ័យ ព្រោះមានពួកចោរ សូម្បីបុរសដែលជាអ្នកប្រាថ្នានឹងរស់នៅ ក៏រមែងវៀរថ្នាំពិសដ៏ខ្លាំងក្លាដែរ សូម្បីភិក្ខុជ្រាបថា ភព ៣ ដូចជាផ្លូវដែលពួកចោរចាំស្ទាក់ គួរតែវៀរអំពើអាក្រក់ចេញ” ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

៧.វាណិជោវ ភយំ មគ្គំ អប្បសត្ថោ មហទ្ធនោ
វិសំ ជីវិតុកាមោវ បាបានិ បរិវជ្ជយេ ។

បុគ្គលគួរចៀសវាងបាបទាំងឡាយ ឲ្យដូចពាណិជ្ជ ដែលមាន
ទ្រព្យច្រើន តែមានគ្នាតិច ចៀសវាងផ្លូវគួរខ្លាច ឬដូចជាបុរស
ប្រាថ្នារស់នៅ ចៀសវាងថ្នាំពិសដូច្នោះដែរ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ភយំ បានដល់ ផ្លូវដែលគួរខ្លាច អធិ-ប្បាយថា ឈ្មោះថា មានភ័យចំពោះមុខ ព្រោះជាផ្លូវដែលពួកចោរពួនស្ទាក់ ។ លោកអធិប្បាយពាក្យនោះទុកថា ពាណិជ្ជដែលមានទ្រព្យច្រើន តែមានគ្នាតិច ចៀសវាងផ្លូវដែលមានភ័យនៅចំពោះមុខ យ៉ាងណា អ្នកត្រូវការនឹងរស់នៅ រមែងវៀរថ្នាំពិស យ៉ាងណា បណ្ឌិតគួរវៀរចាកកម្មអាក្រក់ទាំងឡាយ សូម្បីមានប្រមាណតិចចេញ ដូច្នោះដែរ ។

លុះចប់ព្រះធម៌ទេសនា ភិក្ខុទាំងនោះ បានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទាទាំងឡាយ ។ ព្រះធម្មទេសនា មានប្រយោជន៍ដល់មហាជនដែលមកប្រជុំគ្នា ដូច្នេះឯង ។

ចប់ រឿងពាណិជ្ជអ្នកមានទ្រព្យច្រើន

# ៨. រឿងនាយព្រានកុក្កុដមិត្ត

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់បានប្រារព្ធព្រានម្នាក់ឈ្មោះកុក្កុដមិត្ត បានត្រាស់ព្រះធម្មទេសនានោះថា* ***បាណិម្ហិ ចេ វណោ នាស្ស (បើដំបៅមិនគប្បីមានត្រង់បាតដៃ)*** *ជាដើម ។*

## ធីតាសេដ្ឋីស្រឡាញ់នាយព្រានកុក្កុដមិត្ត

*បានឮថា នៅក្នុងក្រុងរាជគ្រឹះ មានធីតាសេដ្ឋីម្នាក់ ចម្រើនវ័យហើយ ដើម្បីប្រយោជន៍ដល់ការរក្សា មាតាបិតាទើបប្រគល់ស្រីបម្រើម្នាក់ ហើយឲ្យនៅក្នុងបន្ទប់ឮដ៏ខាងលើនៃប្រាសាទ ៧ ជាន់ នៅវេលារសៀលថ្ងៃមួយ នាងបានក្រឡេកមើលទៅថ្នល់តាមបង្អួច បានឃើញព្រានម្រឹគម្នាក់ឈ្មោះកុក្កុដមិត្ត ដៃកាន់អន្ទាក់ ៥០០ និងស្នួ ៥០០ សម្លាប់ម្រឹគទាំងឡាយចិញ្ចឹមជីវិត សម្លាប់ម្រឹគ ៥០០ ហើយ លើកដាក់លើរទេះបរចូលទៅកាន់ព្រះនគរ ដើម្បីលក់សាច់ ក៏មានចិត្តប្រតិព័ទ្ធព្រានម្រឹគនោះ បានឲ្យបណ្ណាការទៅស្ត្រីបម្រើ ហើយបញ្ជូនទៅដោយពាក្យថា "នាងចូរនាំយកបណ្ណាការនេះ ទៅឲ្យបុរសនោះ ហើយសួរឲ្យដឹងថា គេនឹងត្រឡប់ទៅវិញអង្កាល់ ហើយសឹមមក" ។ ស្ត្រីបម្រើនោះទៅដល់ទីនោះហើយ ឲ្យបណ្ណាការដល់ព្រានម្រឹគនោះ ហើយសួរថា "កាលណាលោកនឹងត្រឡប់ទៅវិញ" នាយព្រានឆ្លើយតបថា ថ្ងៃនេះយើងលក់សាច់អស់*

ហើយ នឹងចេញទៅតាមទ្វារឈ្មោះឯណោះអំពីព្រលឹម ។ ស្ត្រីបម្រើស្តាប់ពាក្យដែលនាយព្រាននោះប្រាប់ហើយ ក៏ត្រឡប់មកប្រាប់សេដ្ឋីធីតា ។ សេដ្ឋីធីតាប្រមូលសំពត់ និងអាភរណៈដែលខ្លួនអាចកាន់យកបាន ស្លៀកសំពត់ចាស់កណ្តៀតក្អមចេញអំពីផ្ទះតាំងពីព្រលឹម ធ្វើដូចជាទៅកាន់កំពង់ទឹកជាមួយនឹងពួកនាងទាសី ដល់ទីនោះហើយ បានឈរចាំដំណើរមករបស់នាយព្រាន ។ ចំណែកនាយព្រាន ក៏បររទេះចេញទៅអំពីព្រលឹមដែរ ។ ចំណែកនាងក៏ដើរតាមក្រោយនាយព្រាននោះ ។ គេឃើញនាងទើបនិយាយថា "ខ្ញុំមិនស្គាល់ថា នាងជាធីតារបស់អ្នកណា នែនាង កុំមកតាមខ្ញុំ" ។ នាងឆ្លើយថា "លោកមិនបានហៅខ្ញុំមក ខ្ញុំមកតាមធម្មតារបស់ខ្លួន លោកចូរនៅស្ងៀមចុះ ហើយគិតតែបររទេះរបស់ខ្លួនទៅ" ។ គេបានហាមនាងហើយហាមទៀត លុះនាងនិយាយនឹងខ្លួនថា "ការហាមសិរីដែលមកកាន់សម្នាក់របស់ខ្លួនមិនសមគួរឡើយ" ។ ទើបដឹងថាការដែលនាងមកនោះ គឺ មកដើម្បីខ្លួនដោយឥតសង្ស័យ ហើយក៏បានបីនាងឡើងកាន់រទេះបរទៅ ។ មាតាបិតារបស់នាង ឲ្យមនុស្សស្វែងរកសព្វទីកន្លែងមិនឃើញ ក៏សម្គាល់ថា នាងស្លាប់ហើយ ក៏ផ្តើមធ្វើកត្តដើម្បីអ្នកស្លាប់ (មតកកត្ត) ។ សូម្បីនាងអាស្រ័យការរស់នៅរួមជាមួយនាយព្រាននោះ រហូតបានបុត្រ ៧ នាក់ដោយលំដាប់ ក្នុងកាលដែលបុត្រទាំងនោះចម្រើនវ័យហើយ នាងបានចងបុត្រទាំងនោះដោយគ្រឿងចង គឺ ផ្ទះ ។

## កុក្កុដមិត្តអាឃាតក្នុងព្រះសម្ពុទ្ធ

ថ្ងៃមួយ ព្រះសាស្តាទ្រង់ប្រមើលមើលនូវសត្វលោក ក្នុងវេលាជិតភ្លឺ ទ្រង់ឃើញព្រានកុក្កុដមិត្ត ព្រមទាំងបុត្រ និងកូនប្រសារចូលទៅក្នុងសំណាញ់ គឺ ព្រះញាណរបស់ព្រះអង្គ ទ្រង់ពិចារណាទៅទៀតថា "តើមានហេតុអ្វីហ្ន៎" ទ្រង់ឃើញឧបនិស្ស័យនៃជនទាំងនោះហើយ ទ្រង់ប្រដាប់បាត្រ និងចីវរយាង ទៅកាន់ទីដាក់អន្ទាក់របស់នាយព្រាននោះ តាំងអំពីព្រលឹម ។ ថ្ងៃនោះ ម្រឹគ សូម្បីតែមួយក៏មិនបានជាប់អន្ទាក់ ។ ព្រះសាស្តា ទ្រង់សម្តែងស្នាមព្រះបាទ ទុកជិតអន្ទាក់របស់ព្រាន ហើយទ្រង់គង់ក្រោមម្លប់ឈើមួយដើមខាងមុខ ។ នាយព្រានកុក្កុដមិត្តកាន់ធ្នូទៅកន្លែងអន្ទាក់អំពីព្រលឹម ពិនិត្យមើលអន្ទាក់តាំងពីដើម មិនឃើញម្រឹគជាប់អន្ទាក់សូម្បីត្រឹមតែ ១ បានឃើញតែស្នាមព្រះបាទរបស់ព្រះសាស្តា ក៏ត្រិះរិះដូច្នេះថា "នរណាដើរស្រាយម្រឹគដែលជាប់អន្ទាក់របស់យើង" ។ គេចងអាឃាតនឹងព្រះសាស្តា ដើរទៅមុខបន្តិច ក៏ឃើញព្រះសាស្តាដែលទ្រង់ប្រថាប់គង់ក្រោមដើមឈើ គិតថា "សមណៈនេះព្រលែងម្រឹគដែលជាប់អន្ទាក់របស់យើង យើងនឹងសម្លាប់សមណៈនេះ ហើយក៏បានយឹតធ្នូតម្រង់ទៅរកព្រះសាស្តា ។ ព្រះសាស្តា ទ្រង់ឲ្យយឹតធ្នូបាន តែទ្រង់មិនឲ្យព្រលែងធ្នូទៅបាន ។ គេមិនអាចព្រលែងកូនសរទៅ ទាំងមិនអាចដាក់ចុះ គេមានអាការហាក់ដូចជាបែកឆ្អឹងជំនីទាំងពីរ មានទឹកមាត់ហូរចេញអំពីមាត់ ឈរ

នៅដោយលំបាកកាយ ។ គ្រានោះ ពួកបុត្ររបស់គេទៅផ្ទះនិយាយគ្នាថា “បិតារបស់យើងទៅយូរម្លេះ តើមានហេតុអ្វីហ្ន៎?” កាលមាតារបស់គេបញ្ជូនទៅថា “កូនទាំងឡាយ កូនចូរទៅកាន់សម្នាក់របស់បិតាកូនមើល” ម្នាក់ៗ ក៏នាំគ្នាកាន់យកធ្នូចេញទៅ ឃើញបិតាឈរដោយអាការដូច្នោះ ក៏គិតថា “បុរសនេះ ពិតជាបច្ចាមិត្តរបស់បិតាពួកយើង” ទាំង ៧ នាក់យឹតធ្នូតម្រង់ទៅរកព្រះសម្មាសម្ពុទ្ធ ក៏បានឈរទ្រឹងដូចបិតារបស់ពួកគេ ដោយអានុភាពរបស់ព្រះសម្ពុទ្ធ ។

## កុក្កុដមិត្តឈប់ចងអាឃាតជាមួយព្រះសម្ពុទ្ធ

គ្រានោះ មាតារបស់ពួកគេ គិតថា “ព្រោះហេតុអ្វីហ្ន៎ បិតា និងបុត្រទៅយូរម្លេះ” ក៏នាំកូនប្រសារ ៧ នាក់ទៅកាន់ទីនោះ លុះទៅដល់ទីនោះ ឃើញជនទាំងនោះឈរសំកាំងដូច្នោះ គិតថា “ជនទាំងនេះឈរយឹតធ្នូតម្រង់រកបុគ្គលណាហ្ន៎” ក្រឡេកទៅក៏ឃើញព្រះសាស្ដា ទើបលើកដៃទាំងពីរស្រែកឡើងយ៉ាងខ្លាំងៗ ថា “អ្នកទាំងឡាយកុំញ៉ាំងបិតារបស់យើងឲ្យវិនាសឡើយ ពួកអ្នករាល់គ្នាកុំញ៉ាំងបិតារបស់យើងឲ្យវិនាស” ។ នាយព្រានកុក្កុដមិត្ត បានឮសំឡេងនោះហើយ ក៏គិតថា “យើងវិនាសហើយ ព្រោះបុរសនេះជាឪពុកក្មេករបស់យើង ស្លាប់ហើយយើង យើងបានធ្វើកម្មធ្ងន់ណាស់” សូម្បីពួកបុត្ររបស់គេក៏គិតថា “វិនាសហើយពួកយើង ព្រោះបុរសនេះជាជីតារបស់យើង ពួកយើងបានធ្វើកម្មធ្ងន់ណាស់” នាយព្រានចូលទៅ ដោយតាំងមេត្តាចិត្តទុកថា “អ្នក

នេះជាឪពុកក្មេករបស់យើង" ។ សូម្បីពួកបុត្ររបស់គេ ក៏ញុំាងមេត្តាចិត្តឲ្យកើតឡើងថា "អ្នកនេះជាជីតារបស់ពួកយើង" ។ គ្រានោះ សេដ្ឋីធីតាដែលជាមាតារបស់ពួកគេ បាននិយាយថា "ពួកអ្នកបោះធ្នូចោលហើយ សូមទោសបិតារបស់ខ្ញុំដើម្បីឲ្យបិតាខ្ញុំអត់ទោសឲ្យ ឲ្យឆាប់" ។ ព្រះសាស្ដាទ្រង់ជ្រាបចិត្តរបស់ជនទាំងនោះទន់ហើយ ទើបឲ្យដាក់ធ្នូចុះបាន ។ ជនទាំងអស់នោះ ថ្វាយបង្គំព្រះសាស្ដាហើយ សូមឲ្យព្រះអង្គអត់ទោសឲ្យថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គអត់ទោសឲ្យខ្ញុំព្រះអង្គទាំងឡាយផង ដូច្នេះហើយ អង្គុយនៅទីដ៏សមគួរ ។ លំដាប់នោះ ព្រះសាស្ដាត្រាស់អនុបុព្វីកថាដល់ពួកគេ ។ ក្នុងវេលាចប់ទេសនា ព្រានកុក្កុដមិត្តព្រមទាំងបុត្រ និងកូនប្រសារ មានខ្លួនឯងជាទី ១៥ ក៏បានសម្រេចសោតាបត្តិផល ។ ព្រះសាស្ដាត្រាច់ទៅបិណ្ឌបាត សម្រេចកត្តកិច្ចហើយ ទើបស្ដេចយាងទៅកាន់វិហារវិញ ។ គ្រានោះ ព្រះអានន្ទត្ថេរទូលសួរព្រះអង្គថា "បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះព្រះអង្គស្ដេចយាងទៅកាន់ទីណា"

ព្រះសាស្ដា. ម្នាលអានន្ទ ថ្ងៃនេះ តថាគតទៅកាន់សម្នាក់របស់កុក្កុ-ដមិត្ត ។

អានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ព្រានកុក្កុដមិត្តនោះ ត្រូវព្រះអង្គធ្វើឲ្យជាអ្នកឈប់ធ្វើកម្ម គឺ បាណាតិបាតហើយឬ ។

ព្រះសាស្ដា. អើ អានន្ទ ព្រានកុក្កុដមិត្តនោះ មានខ្លួនជាគម្រប់ ១៥

បានតាំងនៅក្នុងសទ្ធាដែលមិនញាប់ញ័រ ជាអ្នកអស់សេចក្តីសង្ស័យក្នុងរតនៈ ៣ ជាអ្នកមិនធ្វើកម្មគឺ បាណាតិបាតទៀតហើយ ។

ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រានទោះមានភរិយាមិនមែនឬ? ព្រះសាស្តាត្រាស់ថា "ពិតមែនហើយ ភិក្ខុទាំងឡាយ នាងជាកុមារិកាក្នុងត្រកូលសេដ្ឋី សម្រេចសោតបត្តិផលហើយ" ។

## ព្រះសោតាបន្នមិនធ្វើបាប

ពួកភិក្ខុសន្ទនាគ្នាថា "ភរិយារបស់នាយព្រានកុក្កុដមិត្ត បានសម្រេចសោតាបត្តិផលក្នុងកាលដែលខ្លួននៅជាក្មេងតូចម្ល៉េះ ហើយទៅកាន់ផ្ទះរបស់នាយព្រានទោះ បានបុត្រ ៧ នាក់ ហើយនាងត្រូវស្វាមីប្រើអស់កាលប៉ុណ្ណោះថា "នាងចូរនាំធ្នូមក នាំកូនសរមក នាំលំពែងមក នាំស្នមក យកអន្ទាក់មក បានឲ្យវត្ថុទាំងនោះទៅព្រាន នាយព្រានទោះ កាន់គ្រឿងប្រហារដែលនាងឲ្យហើយទៅធ្វើបាណាតិបាត សូម្បីព្រះសោតាបន្នទាំងឡាយ ក៏នៅធ្វើបាណា-តិបាតដែរឬ" ។ ព្រះសាស្តាស្តេចយាងមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ តើអ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាអំពីរឿងអ្វី" កាលភិក្ខុទាំងនោះក្រាបទូលថា អំពីរឿងឈ្មោះនេះ ទ្រង់ក៏ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រះសោតាបន្ន រមែងមិនធ្វើបាណាតិបាតឡើយ តែការដែលនាងបានធ្វើដូច្នោះ ព្រោះបានគិតថា "យើងនឹងធ្វើតាមពាក្យស្វាមី" ចិត្តរបស់នាងមិនមានឡើយថា

ស្វាមីនោះចូរកាន់យកគ្រឿងប្រហារនេះទៅធ្វើបាណាតិបាតចុះ ពិតហើយ កាលបាតដៃមិនមានដំបៅ ថ្នាំពិសក៏មិនអាចនឹងឲ្យទោសដល់អ្នកកាន់ថ្នាំពិសនោះបាន យ៉ាងណា ឈ្មោះថា បាប រមែងមិនមានដល់អ្នកមិនធ្វើបាប សូម្បីនាំគ្រឿងប្រហារទាំងឡាយមានធ្នូជាដើមឲ្យ មិនមានអកុសលចេតនា ដូច្នោះដែរ" ដូច្នេះហើយ កាលនឹងបន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបត្រាស់ធម្មទេសនានេះថា ៖

៨.បាណិម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ
នាព្វណំ វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ ។

បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំយកថ្នាំពិសដោយបាតដៃ ថ្នាំពិសតែងមិនជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាបរមែងមិនមាន ដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះដែរ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា នាស្ស បានដល់ មិនមាន ។

បទថា ហរេយ្យ (គប្បីនាំទៅ) ប្រែថា អាចនាំទៅបាន ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះថ្នាំពិសមិនអាចជ្រាបចូលទៅកាន់បាតដៃដែលមិនមាន

ដំបៅ ពិតហើយ ថ្នាំពិស រមែងមិនអាចជ្រាបចូលបាតដៃដែលមិនមានដំបៅ យ៉ាងណា ឈ្មោះថា បាប រមែងមិនមានដល់អ្នកមិនធ្វើបាប សូម្បីនាំគ្រឿងប្រហារទាំងឡាយមានធ្នូជាដើមឲ្យ ព្រោះមិនមានអកុសលចេតនា ដូច្នោះដូចគ្នា ការពិត បាបរមែងមិនជាប់តាមចិត្តរបស់បុគ្គលនោះ ដូចថ្នាំពិសមិនជ្រាបចូលបាតដៃដែលមិនមានដំបៅដូច្នោះ ដូច្នេះឯង ។

ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។

## បុព្វកម្មរបស់កុក្កុដមិត្ត ព្រមទាំងបុត្រ និងកូនប្រសារ

សម័យខាងក្រោយមក ពួកភិក្ខុសន្ទនាគ្នាថា "អ្វីហ្ន៎ ដែលជាឧបនិស្ស័យនៃសោតាបត្តិមគ្គរបស់ព្រានកុក្កុដមិត្ត ព្រមទាំងបុត្រ និងកូនប្រសារ ព្រាននេះកើតក្នុងត្រកូលព្រានម្រឹគ ព្រោះហេតុអ្វី?" ។

ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយសន្ទនាគ្នាអំពីរឿងអ្វី?" កាលភិក្ខុទាំងនោះក្រាបទូលថា "អំពីរឿងឈ្មោះនេះ" ក៏ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ជនទាំងឡាយ ចាត់ចែងកសាងចេតិយ បញ្ចុះព្រះធាតុរបស់ព្រះកស្សបទសពល ក៏បានប្រឹក្សាគ្នាយ៉ាងនេះថា "បានអ្វីធ្វើជាដីស្អិត បានអ្វីធ្វើជាទឹក (លាយ) នូវចេតិយនេះ?" ។

គ្រានោះ ពួកជនទាំងនោះសម្រេចថា “ហរតាល និងមនោសិលាធ្វើជាដីស្អិត យកប្រេងល្ងធ្វើជាទឹក (លាយ)” ។ ពួកគេបុកហរតាល និងមនោ-សិលានោះ ផ្សំជាមួយប្រេងល្ង ក.ដោយឥដ្ឋ បិទដោយមាស ហើយឆ្លាក់ក្បាច់ខាងក្នុង ។ អំពីខាងក្រៅខាងមុខមានឥដ្ឋមាសទាំងដុំៗ ។ ឥដ្ឋមួយដុំៗ មានតំលៃមួយសែន ។ លុះចេតិយសម្រេចហើយ ក៏ប្រឹក្សាគ្នាថា “ក្នុងកាលបញ្ចុះព្រះធាតុត្រូវការទ្រព្យច្រើន តើពួកយើងលើកបុគ្គលណាឲ្យធ្វើជាប្រធាន” ។ គ្រានោះ សេដ្ឋីស្រុកក្រៅម្នាក់ ពោលថា “ខ្ញុំនឹងធ្វើជាប្រធាន” លុះពោលដូច្នេះហើយ ក៏បានដាក់ប្រាក់មួយកោដិក្នុងទីបញ្ចុះព្រះសារីរិកធាតុ ។ ពួកអ្នកនគរឃើញកិរិយានោះ តិះដៀលថា “សេដ្ឋីក្នុងក្រុងនេះ ក៏មានទ្រព្យ មិនអាចធ្វើជាប្រធានក្នុងព្រះចេតិយនេះបាន ចំណែកសេដ្ឋីស្រុកក្រៅ ដាក់ទ្រព្យមួយកោដិទើបសមធ្វើជាប្រធានឬ” ។

សេដ្ឋីក្នុងក្រុងនោះ បានស្តាប់ពាក្យរបស់ជនទាំងនោះហើយ ពោលថា “យើងនឹងធ្វើជាប្រធាន” បានឲ្យទ្រព្យពីរកោដិហើយ ។

សេដ្ឋីស្រុកក្រៅ គិតថា “យើងនឹងធ្វើជាប្រធាន” បានឲ្យទ្រព្យបីកោដិ ។ កាលសេដ្ឋីទាំងពីរនាក់នោះ បន្ថែមទ្រព្យដោយអាការយ៉ាងនោះ សេដ្ឋីក្នុងក្រុងបានឲ្យទ្រព្យ ៨ កោដិ ។

ចំណែកសេដ្ឋីស្រុកក្រៅគិតថា ក្នុងផ្ទះមានទ្រព្យ ៩ កោដិប៉ុណ្ណោះ ។

សេដ្ឋីក្នុងក្រុងមានទ្រព្យ ៨០ កោដិ ព្រោះដូច្នោះសេដ្ឋីស្រុកក្រៅ ទើបគិតថា "បើយើងឲ្យទ្រព្យ ៩ កោដិ សេដ្ឋីនេះនឹងពោលថា យើងនឹងឲ្យ ១០ កោដិ បើដូច្នោះ ទ្រព្យរបស់យើងនឹងអស់ជាប្រាកដ" ទើបបានពោលយ៉ាងនោះថា "យើងនឹងឲ្យទ្រព្យប្រមាណប៉ុណ្ណេះ ឯយើង ព្រមទាំងកូន និងប្រពន្ធសូមធ្វើជាទាសៈរបស់ចេតិយ" ដូច្នេះហើយ ក៏នាំបុត្រទាំង ៧ នាក់ កូនប្រសារទាំង ៧ នាក់ និងភរិយា ប្រគល់ចំពោះព្រះចេតិយព្រមទាំងខ្លួនឯង ។

អ្នកនគរក៏បានធ្វើសេដ្ឋីក្រៅស្រុកឲ្យជាប្រធាន ដោយអាងថា ឈ្មោះថាទ្រព្យសម្បត្តិ នរណាៗ ក៏អាចឲ្យកើតឡើងបាន តែសេដ្ឋីស្រុកក្រៅនេះ ព្រមទាំងបុត្រ និងភរិយា បានប្រគល់ខ្លួន (ចំពោះព្រះចេតិយ) សេដ្ឋីនេះឯង ចូរធ្វើជាប្រធាន ។ ជនទាំង ១៦ នាក់ បានធ្វើជាទាសៈរបស់ព្រះចេតិយ ដោយប្រការដូច្នេះ ។ តែពួកអ្នកនគរបានធ្វើពួកគេឲ្យជាអ្នកជា ។ សូម្បីបានទៅជាអ្នកជាហើយក៏ដោយ ពួកគេនៅតែបដិបត្តិព្រះចេតិយរហូតអស់ជីវិត ចុតិចាកអត្តភាពនោះហើយ បានបដិសន្ធិក្នុងទេវលោក កាលជនទាំងនោះនៅក្នុងទេវលោកអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទនេះ ភរិយាចុតិចាកទេវលោកនោះ ក៏កើតជាធីតាសេដ្ឋីក្នុងក្រុងរាជគ្រឹះ ។

## គតិរបស់អ្នកមិនឃើញសច្ចៈ មិនទៀងទាត់

នាងបានសម្រេចសោតាបត្តិផល តាំងពីនៅជាកុមារិកាម៉្លេះ ។ ដែល

ឈ្មោះថា បដិសន្ធិរបស់សត្វដែលមិនបានឃើញសច្ចៈ ជាការៈដ៏ធ្ងន់ ព្រោះដូច្នោះ ទើបស្វាមីរបស់នាងវិលត្រឡប់ទៅកើតក្នុងត្រកូលព្រានម្រឹគ ។ សេចក្តីស្នេហាក្នុងកាលមុន បានគ្របសង្កត់សេដ្ឋីធីតាព្រមគ្នានឹងការបានឃើញនាយព្រានកុក្កុដមិត្តនោះឯង ។ ពិតណាស់ សូម្បីព្រះមានព្រះភាគ ក៏បានត្រាស់ពាក្យនោះទុកថា ៖

> សេចក្តីស្រឡាញ់នោះ រមែងកើតឡើង ព្រោះអាស្រ័យហេតុ ២ ប្រការ គឺ ព្រោះការនៅរួមគ្នាក្នុងកាលមុន ១ ដោយការប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់គ្នានឹងគ្នាក្នុងបច្ចុប្បន្ន ១ ដូចផ្កាឈូកកើតក្នុងទឹក (ព្រោះអាស្រ័យភក់ និងទឹក) ដូច្នោះ ។

ធីតារបស់សេដ្ឋីនោះ បានទៅកាន់ត្រកូលរបស់ព្រានម្រឹគ ព្រោះសេចក្តីស្នេហាក្នុងកាលមុន សូម្បីពួកបុត្ររបស់នាង ក៏ចុតិចាកទេវលោក មកបដិសន្ធិក្នុងផ្ទៃរបស់នាងនោះឯង ។ សូម្បីកូនប្រសាររបស់នាង ក៏កើតក្នុងទីនោះៗ លុះចម្រើនវ័យហើយ ក៏បានធ្វើជាកូនប្រសាររបស់នាង ។ ជនទាំងអស់នោះ បដិបត្តិព្រះចេតិយក្នុងកាលនោះ ដោយប្រការដូច្នេះ ទើបបានសម្រេចសោតាបត្តិផលដោយអានុភាពនៃកម្មនោះ ដូច្នេះឯង ។

ចប់ រឿងព្រានឈ្មោះកុក្កុដមិត្ត

# ៩. រឿងព្រានសុនខឈ្មោះកោកៈ

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធនាយព្រានសុនខឈ្មោះ កោកៈ ត្រាស់ព្រះធម្មទេសនានេះថា*

***យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ** (បុគ្គលណា ប្រទូស្តចំពោះអ្នកមិនប្រទូស្តតប) ជាដើម ។*

## ព្រានសម្គាល់ភិក្ខុជាមនុស្សកាឡកណ្ណី

*បានឮថា វេលាព្រឹកនាថ្ងៃមួយ នាយព្រាននោះកាន់ធ្នូ និងមានសុនខចោមរោម ចេញទៅព្រៃ បានជួបភិក្ខុអ្នកមានបិណ្ឌបាតជាវត្តមួយរូប កំពុងតែត្រាច់បិណ្ឌបាតក្នុងចន្លោះផ្លូវ ក៏ក្រោធ ហើយគិតថា "យើងបានជួបមនុស្សកាឡកណ្ណី ថ្ងៃនេះនឹងមិនបានអ្វីៗ ឡើយ ហើយក៏ចៀសចេញទៅ ។ ចំណែកព្រះថេរៈ ត្រាច់ទៅបិណ្ឌបាតក្នុងស្រុក ធ្វើភត្តកិច្ចហើយ ក៏ត្រឡប់ទៅវិហារវិញ ។*

*ចំណែកព្រានរូបនោះ ត្រាច់ទៅក្នុងព្រៃមិនបានអ្វីៗ កាលត្រឡប់មកវិញ បានជួបព្រះថេរៈម្តងទៀត ទើបគិតថា "ថ្ងៃនេះ ព្រោះតែយើងបានជួបមនុស្សកាឡកណ្ណីនេះហើយ ទើបយើងទៅព្រៃមិនបានអ្វីៗ ឥឡូវនេះ លោកបានមកប្រាកដចំពោះមុខយើងម្តងទៀត យើងនឹងឲ្យសុនខទាំងឡាយខាំភិក្ខុនេះ" ដូច្នេះ*

ទើបក៏ឲ្យសញ្ញាលែងសុនខទៅ ។

ព្រះថេរៈអង្វរថា “ឧបាសក អ្នកកុំធ្វើដូច្នេះឡើយ” ។ គេស្រែកប្រាប់ព្រះថេរៈថា “ថ្ងៃនេះ ខ្ញុំមិនបានអ្វី ព្រោះតែបានជួបលោក ឯលោកក៏មកជួបខ្ញុំម្តងទៀត ខ្ញុំនឹងឲ្យសុនខខាំលោក” ដូច្នេះហើយ ទើបឲ្យសុនខខាំ ។ ព្រះថេរៈរត់ឡើងដើមឈើមួយដើមយ៉ាងរហ័ស អង្គុយនៅត្រង់ទីខ្ពស់មួយជួរបុរស ។ សុនខទាំងឡាយ ក៏នាំគ្នាចោមរោមដើមឈើនោះ ។

នាយកោកៈទៅទីនោះ ហើយស្រែកប្រាប់ថា សូម្បីលោកឡើងដើមឈើ ក៏មិនផុតអំពីកណ្តាប់ដៃរបស់យើងដែរ លុះពោលដូច្នេះហើយ ក៏ចាក់បាតជើងព្រះថេរៈដោយចុងព្រួញ ។ ព្រះថេរៈបានត្រឹមតែអង្វរថា “ម្នាលឧបាសក សូមអ្នកកុំធ្វើដូច្នេះឡើយ” ។ នាយកោកៈ មិនបានអើពើនឹងពាក្យអង្វររបស់ព្រះថេរៈឡើយ កាន់តែចាក់ខ្លាំងឡើងៗ ។ ចំណែកព្រះថេរៈ កាលត្រូវព្រានចាក់បាតជើងម្ខាង ក៏លើកជើងម្ខាងនោះឡើង ទម្លាក់ជើងម្ខាងទៀតចុះ កាលព្រានចាក់ជើងម្ខាងនោះទៀត ក៏លើកជើងនោះឡើងវិញ នាយកោកៈមិនស្តាប់ពាក្យអង្វររបស់ព្រះថេរៈឡើយ ចាក់បាតជើងទាំងពីររបស់ព្រះថេរៈដោយអាការយ៉ាងនោះឯង ។ សរីរៈរបស់ព្រះថេរៈ ដូចជាត្រូវឆេះរោលដោយគប់ភ្លើង ។ ដោយសារតែទុក្ខវេទនាគ្របសង្កត់ខ្លាំងពេក ទើបលោកមិនអាចគ្រប់គ្រងសតិបាន សូម្បីចីវរដែលលោកដណ្តប់ របូតធ្លាក់ចុះក៏មិនដឹង ។ ចីវរនោះធ្លាក់ចុះ

ទៅគ្របនាយកោកៈនោះ តាំងអំពីក្បាល ។

## សុនខចោមរោមខាំនាយព្រាន

ហ្វូងសុនខនាំគ្នាចូលទៅក្នុងចន្លោះនៃចីវរ ដោយសម្គាល់ថា ព្រះថេរៈធ្លាក់ចុះមក ហើយក៏នាំគ្នាខាំម្ចាស់របស់ខ្លួន អង្កៀមស៊ីបន្សល់ទុកតែឆ្អឹង ។ សុនខទាំងឡាយចេញមកអំពីចន្លោះនៃចីវរហើយ ឈរនៅខាងក្រៅ ។ ខណៈនោះ ព្រះថេរៈកាច់មែកឈើស្ងួតមួយ គ្រវែងបង្អើលសុនខទាំងនោះ ។ ហ្វូងសុនខឃើញព្រះថេរៈហើយ ដឹងថា ពួកខ្លួនខាំស៊ីម្ចាស់របស់ខ្លួនឯង ក៏នាំគ្នាបោលចូលព្រៃ ។

## ព្រះថេរៈសង្ស័យក្នុងសីល និងសមណភាពរបស់ខ្លួន

ព្រះថេរៈកើតសេចក្ដីសង្ស័យថា បុរសនោះដល់នូវសេចក្ដីវិនាសខ្លួន ព្រោះតែចូលមកកាន់ចន្លោះនៃចីវររបស់យើង សីលរបស់យើងមិនដាច់ទេឬ លោកចុះពីដើមឈើហើយ ទៅកាន់សម្នាក់របស់ព្រះសាស្ដា ក្រាបទូលរឿងទាំងអស់នោះតាំងអំពីដើម ហើយទូលសួរថា "បពិត្រព្រះអង្គ ឧបាសកនោះវិនាសខ្លួន ព្រោះអាស្រ័យចីវររបស់ខ្ញុំព្រះអង្គ សីលរបស់ខ្ញុំព្រះអង្គមិនដាច់ធុះធ្លាយទេឬ? សមណភាពរបស់ខ្ញុំព្រះអង្គនៅមានដែរឬ?" ។

ព្រះសាស្ដា ទ្រង់ស្ដាប់ពាក្យរបស់ព្រះថេរៈនោះហើយ ត្រាស់ថា "ម្នាលភិក្ខុ សីលរបស់អ្នកមិនដាច់ទេ សមណភាពរបស់អ្នកនៅមាន បុរសនោះដែល

ប្រទូស្តចំពោះអ្នកដែលជាអ្នកមិនប្រទូស្តតប ទើបដល់នូវសេចក្ដីវិនាសយ៉ាង នេះ បុរសនោះមិនមែនទើបតែប្រទូស្តចំពោះអ្នកក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងអតីតកាល ក៏ធ្លាប់ប្រទូស្តចំពោះអ្នកដែលមិនប្រទូស្តតប និងដល់នូវសេចក្ដីវិនាសដែរ ដូច្នេះហើយ កាលនឹងទ្រង់ប្រកាសនូវរឿងនោះ ទើបទ្រង់នាំអតីតនិទានមក (ត្រាស់ថា) ៖

## បុព្វកម្មរបស់នាយព្រាន

ដូចបានស្ដាប់មក ក្នុងអតីតកាល មានពេទ្យម្នាក់ត្រាច់ទៅកាន់ស្រុក ដើម្បីប្រកបវេជ្ជកម្ម មិនបាននូវកម្មអ្វីៗ ត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ ក៏ចេញមកវិញ បានជួបក្មេងៗ ជាច្រើនកំពុងតែលេងនៅក្បែរទ្វារស្រុក គិតថា "យើងនឹងឲ្យពស់ចឹកក្មេងទាំងនោះ ហើយរក្សា (ព្យាបាល) នឹងបានអាហារបរិភោគ ដូច្នេះហើយ ក៏សម្ដែងពស់ដែលដេកចេញតែក្បាលក្នុងរន្ធឈើមួយប្រាប់ថា នែ ក្មេងៗ ទាំងឡាយ នុ៎ះកូនសារិកា ពួកឯងចូរចាប់វាមក" ។ គ្រានោះ ក្មេងម្នាក់ចាប់ពស់ត្រង់.កយ៉ាងមាំទាញចេញមក ដឹងថា វាជាពស់ ក៏ស្រែកឡើងហើយ គ្រវែងពស់នោះទៅលើក្បាលពេទ្យដែលឈរនៅជិតនោះ ។ ពស់រិតរុំបំពង់.ករបស់ពេទ្យ ចឹកយ៉ាងដំណំ ឲ្យអស់ជីវិតក្នុងទីនោះឯង នាយកោក:ព្រានសុនខនេះ សូម្បីក្នុងកាលមុន ក៏ប្រទូស្តចំពោះអ្នកដែលមិនប្រទូស្តតប ហើយដល់នូវសេចក្ដីវិនាសយ៉ាងនោះដូចគ្នា ។

ព្រះសាស្តា លុះទ្រង់នាំអតីតនិទាននោះមកហើយ កាលនឹងទ្រង់បន្ត អនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់គាថានេះថា ៖

៩.យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ
សុទ្ធស្ស បោសស្ស អនង្គណស្ស
តមេវ ពាលំ បច្ចេតិ បាបំ
សុខុមោ រជោ បដិវាតំវ ខិត្តោ ។

បុគ្គលណា ប្រទូស្តចំពោះអ្នកមិនប្រទូស្តតប ជាសត្វស្អាត មិនមានកិលេសដូចជាទីទួល បាប រមែងត្រឡប់មករកបុគ្គល ពាលនោះវិញ ដូចធូលីល្អិត ដែលបុគ្គលបាចទៅកាន់ទីច្រាស់ ខ្យល់ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អប្បទុដ្ឋស្ស** (អ្នកមិនប្រទូស្ត) គឺ អ្នកមិនប្រទូស្តចំពោះខ្លួន ឬចំពោះសព្វសត្វ ។ បទថា **នរស្ស** (នរជន) បានដល់សត្វ ។ បទថា **ទុស្សតិ** (ប្រទូស្ត) បានដល់ រមែងប្រព្រឹត្តខុស ។ បទថា **សុទ្ធស្ស** (អ្នកបរិសុទ្ធ) គឺ អ្នកមិនមានកំហុស ។ សូម្បីបទថា **បោសស្ស** នេះ ក៏ជាឈ្មោះរបស់សត្វនោះឯង ដោយអាការដទៃ។ បទថា **អនង្គណស្ស** (មិនមានកិលេស) គឺ អ្នកមិនមានកិលេស ។ បទថា **បច្ចេតិ** កាត់បទជា **បដិឯតិ**

(ប្រែថា រមែងត្រឡប់មករក) ។ បទថា **បដិវាតំ (ច្រាសខ្យល់)** ជាដើម មានន័យថា ធូលីដ៏ល្អិត ដែលបុរសម្នាក់បាចទៅ ដោយបំណងប្រហារមនុស្សម្នាក់ ដែលឈរនៅក្នុងទីខាងលើខ្យល់ រមែងត្រឡប់មករកបុរសនោះវិញ គឺ ធ្លាក់មកលើបុគ្គលអ្នកបាចនោះឯង យ៉ាងណា បុគ្គលណា កាលប្រហារដោយបាតដៃជាដើម ឈ្មោះថា រមែងប្រទូស្តចំពោះបុរសអ្នកមិនប្រទូស្តតប បាបនោះកាលឲ្យផលក្នុងបច្ចុប្បន្ននោះ ឬក្នុងអបាយទាំងឡាយ មាននរកជាដើមក្នុងភពខាងមុខ ឈ្មោះថា រមែងត្រឡប់មករកបុគ្គលពាលនោះវិញ ដោយអំណាចទុក្ខវិបាក ដូច្នេះដូចគ្នា ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះតាំងនៅក្នុងព្រះអរហត្តផល ។ ព្រះធម្មទេសនា បានជាប្រយោជន៍ដល់បរិស័ទដែលមកប្រជុំគ្នាហើយ ដូច្នេះឯង ។

ចប់ រឿងព្រានសុនខឈ្មោះកោកៈ

# ១០. រឿងព្រះតិស្សត្ថេរចូលទៅកាន់ត្រកូលជាងកែវមណី

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះតិស្សៈ អ្នកចូលទៅកាន់ត្រកូលជាងកែវមណី ត្រាស់ព្រះធម្មទេសនានេះថា **គព្ភមេកេ ឧប្បជ្ជន្តិ** (ជនទាំងឡាយពួកខ្លះរមែងចូលទៅកាន់គភ៌) ជាដើម ។*

## ព្រះបាទបសេនទិកោសលបញ្ជូនកែវមណីឱ្យជាងច្នៃ

*បានឮថា ព្រះថេរៈនោះ ឆាន់នៅក្នុងត្រកូលរបស់ជាងកែវមណីនោះអស់ ១២ ឆ្នាំ ។ ជាងកែវមណី និងភរិយារបស់គេតាំងនៅក្នុងឋានៈដូចជាមាតានិងបិតារបស់ព្រះថេរៈ ទំនុកបម្រុងព្រះថេរៈដោយសេចក្តីគោរព ។ ថ្ងៃមួយជាងកែវមណីកំពុងអង្គុយហាន់សាច់ខាងមុខព្រះថេរៈ ។ ក្នុងខណៈនោះ ព្រះបាទបសេនទិកោសលទ្រង់បញ្ជូនកែវមណីមួយទៅ ដោយព្រះត្រាស់បង្គាប់ថា "សូមជាង ចូរខាត់ និងច្នៃកែវមណីនេះឲ្យល្អ ហើយបញ្ជូនមកឲ្យយើងវិញ" ។ ជាងកែវមណីទទួលយកកែវនោះ ទាំងដៃប្រឡាក់ឈាម យកមកដាក់លើជ្រញ់ ហើយក៏ចូលទៅខាងក្នុងដើម្បីលាងដៃ ។ ក៏ក្នុងផ្ទះនោះ មានចិញ្ចឹមសត្វក្រៀលមួយក្បាល ។ ក្នុងកាលដែលព្រះថេរៈកំពុងតែក្រឡេកមើលនូវកែវមណីនោះ*

សត្វក្រៀលនោះ ក៏បានលេបនូវកែវមណីនោះដោយសម្គាល់ថា ជាដុំសាច់ ព្រោះចុំក្លិនឈាម ។ ជាងកែវមណីមកហើយ មិនឃើញកែវមណី ក៏សួរ ភរិយា ធីតា និងបុត្រដោយលំដាប់ថា "អ្នកទាំងឡាយយកកែវមណីឬ" កាល ជនទាំងនោះឆ្លើយថា "មិនបានយកទេ" ក៏គិតថា ប្រាកដជាព្រះថេរៈកាន់យក ហើយ ទើបប្រឹក្សានឹងភរិយាថា "កែវមណីប្រាកដជាព្រះថេរៈជាអ្នកយក" ឯ ភរិយារបស់គេប្រាប់ថា "នាយ អ្នកកុំពោលដូច្នោះឡើយ រហូតអស់កាលមក ប្រមាណប៉ុណ្ណេះ ខ្ញុំមិនធ្លាប់បានឃើញទោសអ្វីៗ របស់ព្រះថេរៈឡើយ ព្រះថេរៈ ពិតជាមិនបានកាន់យកឡើយ" ។ ជាងកែវមណីសួរព្រះថេរៈថា "លោកម្ចាស់ យកកែវមណី ក្នុងទីឯណោះឬ" ។

ព្រះថេរៈ. ឧបាសក អាត្មាមិនបានកាន់យកទេ ។

ជាង. លោកម្ចាស់ ក្នុងទីនេះមិនមានមនុស្សដទៃទេ លោកម្ចាស់ជាអ្នក យកដោយពិត សូមលោកម្ចាស់ឲ្យកែវមណីមកខ្ញុំព្រះករុណាវិញ ។

កាលព្រះថេរៈបដិសេធ ទើបគេនិយាយនឹងភរិយាថា "កែវរបស់យើង ពិតជាព្រះថេរៈជាអ្នកយក យើងនឹងគាបសួរលោក ។

ភរិយារបស់គេអង្វរថា "នាយ អ្នកកុំញុំាងយើងទាំងឡាយឲ្យវិនាស ឡើយ បើពួកយើងចូលដល់ភាពជាទាសៈប្រសើរជាង ឯការពោលទៅកាន់ ព្រះថេរៈបែបនេះ មិនប្រសើរឡើយ" ។

## ជាងកែវធ្វើទោសព្រះថេរៈ ព្រោះយល់ខុស

ជាងកែវនោះពោលថា "ពួកយើងទាំងអស់គ្នា សូម្បីចូលដល់ភាពជាទាសៈ ក៏នៅតែមិនស្មើនឹងតម្លៃកែវមណីនោះដែរ" លុះពោលដូច្នេះហើយ ក៏បានយកខ្សែរុំសីសៈរបស់ព្រះថេរៈ មួលរឹតដោយកំណាត់ឈើ ។ លោហិតហូរចេញអំពីសីសៈ ត្រចៀក និងច្រមុះរបស់ព្រះថេរៈ គ្រាប់ភ្នែកទាំងពីរលៀនចេញមកក្រៅ លោកឈឺចាប់ខ្លាំងពេក ក៏ដួលចុះលើផែនដី ។ សត្វក្រៀលនោះធុំក្លិនឈាម ក៏បានមកផឹកឈាមនោះ ។

ខណៈនោះ នាយមណីការទាត់សត្វក្រៀលដោយជើង ហើយកៀសចេញទៅ ដោយពោលពាក្យថា "ឯងមកធ្វើអ្វី" ដោយកម្លាំងនៃសេចក្តីក្រោធដែលកើតឡើងចំពោះព្រះថេរៈ ។ សត្វក្រៀលនោះដួលប្រកាច់ស្លាប់ ដោយការទាត់តែមួយជើងប៉ុណ្ណោះ ។ ព្រះថេរៈ ឃើញនូវអាការរបស់សត្វក្រៀលនោះហើយក៏ពោលថា "ឧបាសក លោកចូរបន្ធូរចំណងសីសៈអាត្មាឲ្យធូរសិនហើយ ចូរមើលនូវសត្វក្រៀលនោះថា វាស្លាប់ហើយឬនៅ" លំដាប់នោះ ជាងកែវពោលនឹងព្រះថេរៈថា "សូម្បីលោកឯងក៏នឹងស្លាប់ដូចវាដែរ" ។ ព្រះថេរៈប្រាប់ជាងកែវមណីថា "ឧបាសក កែវមណីនោះ គឺ សត្វក្រៀលនោះឯងជាអ្នកលេប ប្រសិនបើសត្វក្រៀលនោះមិនស្លាប់ទេ សូម្បីអាត្មាស្លាប់ក៏មិនប្រាប់ដល់លោកដែរ" ។

គេវះពោះសត្វក្រៀលនោះ បានឃើញកែវមណីហើយ ញ័ររន្ធត់ មានចិត្តតក់ស្លុត ក្រាបចុះទៀបព្រះបាទរបស់ព្រះថេរៈ ហើយពោលថា "សូមលោកម្ចាស់អត់ទោសនោះដល់ខ្ញុំ ខ្ញុំមិនដឹង បានធ្វើហើយ" ។

ព្រះថេរៈ. ឧបាសក ទោសរបស់លោកក៏មិនមាន ទោសរបស់អាត្មាក៏មិនមាន មានតែទោសរបស់វដ្ដៈប៉ុណ្ណោះ អាត្មាអត់ទោសដល់លោក ។

ជាងកែវ. លោកម្ចាស់ បើលោកម្ចាស់អត់ទោសដល់ខ្ញុំ សូមលោកម្ចាស់និមន្តទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំដូចដើមចុះ ។

## ព្រះថេរៈឃើញទោសនៃការចូលកាន់ត្រកូល

ព្រះថេរៈពោលថា "ឧបាសក តាំងអំពីថ្ងៃនេះទៅ អាត្មានឹងមិនចូលកាន់ត្រកូលទៀតទេ ព្រោះថា នេះជាទោសនៃការចូលកាន់ត្រកូលដោយត្រង់ តាំងពីពេលនេះទៅ បើជើងទាំងពីរនៅដើរបាន អាត្មានឹងឈរក្បែរទ្វារផ្ទះតែម្យ៉ាង ទទួលភិក្ខា" លុះពោលដូច្នេះហើយ ព្រះថេរៈក៏បានសមាទានធុតង្គ ហើយពោលគាថានេះថា ៖

កត្តគ្រប់ៗ ត្រកូល សូម្បីតិចតួច ដែលគេចម្អិនទុកដើម្បីមុនី
អាត្មានឹងត្រាច់ទៅដោយកម្លាំងស្មង (ព្រោះ) កម្លាំងស្មងរបស់
អាត្មានៅមាន ។

ព្រះថេរៈ លុះពោលគាថានោះចប់ហើយ មិនយូរប៉ុន្មាន ក៏បរិនិព្វាន

ដោយព្យាធិទុំះឯង ។ សត្វក្រៀល បានបដិសន្ធិ ក្នុងផ្ទៃនៃភរិយារបស់ជាងកែវមណី ។ ជាងកែវមណីស្លាប់ទៅហើយ ក៏ទៅកើតក្នុងនរក ។ ភរិយារបស់ជាងកែវមណីស្លាប់ទៅកើតក្នុងទេវលោក ព្រោះជាអ្នកមានចិត្តទន់ភ្លន់ចំពោះព្រះថេរៈ ។ ភិក្ខុទាំងឡាយទូលសួរអភិសម្បរាយភពរបស់ជនទាំងនោះចំពោះព្រះសាស្តា ។

ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ រមែងកើតក្នុងគភ៌ ពួកខ្លះធ្វើកម្មអាក្រក់ រមែងកើតក្នុងនរក ពួកខ្លះធ្វើកម្មល្អហើយ រមែងកើតក្នុងទេវលោក ចំណែកអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

១០.គព្ភមេកេ ឧប្បជ្ជន្តិ និរយំ បាបកម្មិនោ
សគ្គំ សុគតិនោ យន្តិ បរិនិព្វន្តិ អនាសវា ។

ជនពួកខ្លះ កើតក្នុងគភ៌មនុស្ស ពួកអ្នកធ្វើអំពើអាក្រក់ ទៅកាន់នរក ពួកអ្នកមានគតិល្អ ទៅកាន់ឋានសួគ៌ ពួកអ្នកមិនមានអាសវៈ បរិនិព្វាន ។

## អធិប្បាយគាថា

ក្នុងបទទាំងនោះ គភ៌របស់មនុស្សប៉ុណ្ណោះ ព្រះសាស្តាទ្រង់បំណងយក

*ក្នុងបទថា **គត្តិំ** (គតិ) នោះ ។ ពាក្យដ៏សេសក្នុងគាថានោះ មានអត្ថងាយហើយ ដូច្នេះឯង ។*

*ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។*

ចប់ រឿងព្រះតិស្សត្ថេរ អ្នកចូលកាន់ត្រកូលជាងកែវមណី

# ១១. រឿងជន ៣ នាក់

ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធជន ៣ នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ (ក្នុងអាកាស... ក្នុងកណ្ដាលមហាសមុទ្ទ ក៏មិនគប្បីរួចផុតចាកកម្មអាក្រក់បាន)** ជាដើម ។

## ក្អែកត្រូវភ្លើងឆេះស្លាប់ក្នុងអាកាស

បានឮថា កាលព្រះសាស្ដាប្រថាប់នៅក្នុងវត្តជេតពន ភិក្ខុច្រើនរូបមក ដើម្បីគាល់ព្រះសាស្ដា បានចូលទៅកាន់ស្រុកមួយដើម្បីបិណ្ឌបាត ។ ពួកអ្នកស្រុកទទួលបាត្ររបស់ភិក្ខុទាំងនោះហើយ និមន្តឲ្យគង់ក្នុងរោងឆាន់ ប្រគេនយាគូ និងបង្អែមដល់ភិក្ខុទាំងនោះឆាន់ហើយ អង្គុយស្ដាប់ព្រះធម៌ដើម្បីរង់ចាំនូវភត្តកាល ។ ក្នុងខណៈនោះ អណ្ដាតភ្លើងតាំងឡើងអំពីចង្ក្រានរបស់ស្ត្រីម្នាក់ដែលចំអិនភត្ត ចំអិនម្ហូបទឹក និងម្ហូបក្រៀម ឆាបឆេះដល់ដំបូល ។ រង្វេលឆ្នាំងដែលធ្វើអំពីស្មៅមួយ តាំងឡើងអំពីដំបូលនោះ ដែលត្រូវភ្លើងឆេះហើយក៏អណ្ដែតឡើងទៅកាន់អាកាស ។ ក្នុងខណៈនោះឯង មានក្អែកមួយហើរមកតាមអាកាស ក៏ស៊ក.កចូលទៅក្នុងរង្វេលឆ្នាំងនោះ ត្រូវស្មៅរង្វេលឆ្នាំងនោះឆេះធ្លាក់ចុះមកចំកណ្ដាលស្រុក ។ ពួកភិក្ខុឃើញនូវហេតុនោះហើយ គិតថា "ឱ! កម្មនេះធ្ងន់ណាស់ អ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរមើលនូវ

អាការដ៏ប្លែករបស់ក្អែកនោះចុះ វៀរចាកព្រះសាស្តាហើយ អ្នកដទៃណាហ្ន៎ នឹងដឹងនូវកម្មដែលក្អែកនោះបានធ្វើហើយ ពួកយើងនឹងទូលសួរកម្មរបស់ក្អែកនោះចំពោះព្រះសាស្តា” ដូច្នេះហើយ ក៏នាំគ្នាគេចចេញទៅ ។

## កិរិយានាយសំពៅត្រូវបណ្ដែតទឹក

កិត្តុមួយពួកទៀត ឡើងកាន់សំពៅទៅដើម្បីគាល់ព្រះសាស្តា សំពៅនោះកឿងនៅកណ្តាលសមុទ្រ ពួកមនុស្សដែលជិះនៅក្នុងសំពៅនោះ ប្រឹក្សាគ្នាថា “ប្រហែលជាមានមនុស្សកាឡកណ្ណីនៅក្នុងសំពៅនេះទេដឹង?” លុះប្រឹក្សាគ្នាដូច្នេះហើយ ក៏ចែកស្លាកឲ្យចាប់ ។ ក៏កិរិយារបស់នាយសំពៅនោះ តាំងនៅក្នុងបឋមវ័យ ជាស្ត្រីមានរូបល្អគួរដល់ការមើល ចាប់បានស្លាកកាឡកណ្ណីនោះ ។ ពួកមនុស្សដែលជិះនៅក្នុងសំពៅនោះ នាំគ្នាពោលថា “ចូរចែកស្លាកម្តងទៀត ហើយឲ្យចែកដល់ទៅ ៣ ដង ។ ស្លាកបានធ្លាក់ទៅលើកិរិយារបស់នាយសំពៅនោះ ដល់ទៅ ៣ ដង ។ អ្នកដែលជិះនៅក្នុងសំពៅនោះ បានក្រឡេកមើលមុខនាយសំពៅដោយពោលថា “ដូចម្តេចដែរនាយ?” នាយសំពៅពោលថា “ខ្ញុំមិនអាចឲ្យមហាជនវិនាស ព្រោះតែនាងនោះទេ ពួកលោកចូរបោះនាងទៅក្នុងទឹកចុះ” ។ កិរិយារបស់នាយសំពៅនោះ កាលត្រូវពួកមនុស្សចាប់ប្រុងនឹងបោះទៅក្នុងទឹក ត្រូវមរណភ័យគ្របសង្កត់ ក៏ស្រែកឡើងយ៉ាងខ្លាំង ។ នាយសំពៅបានឮនូវសម្រែកនោះហើយ ក៏ពោលថា “ប្រយោជន៍អ្វីដោយអាភរណៈ

ដែលនាងប្រដាប់នោះ វានឹងវិនាសទៅទទេៗ ពួកលោកចូរដោះគ្រឿងអាក-រណៈទាំងអស់ ឲ្យនាងស្លៀកសំពត់ចាស់មួយផ្ទាំង ហើយបោះនាងទៅក្នុងទឹកចុះ ខ្ញុំមិនអាចសម្លឹងមើលនាងដែលអណ្តែតនៅលើខ្នងទឹកបានទេ ព្រោះហេតុដូច្នោះ ពួកលោកចូរយកក្អមដែលពេញដោយដីខ្សាច់ចងត្រង់.កហើយ បោះទៅក្នុងសមុទ្ទចុះ ។ ពួកមនុស្សទាំងនោះ ក៏បានធ្វើដូច្នោះ ។ ត្រី និងអណ្តើកប្រញាយស៊ីនាងក្នុងទីដែលធ្លាក់នុ៎ះឯង ។ ពួកភិក្ខុបានស្តាប់នូវរឿងនោះហើយក៏គិតថា "វៀរព្រះសាស្តាចេញហើយ គ្មាននរណាដឹងនូវកម្មរបស់ស្ត្រីនោះទេ ពួកយើងនឹងទូលសួរនូវកម្មរបស់ស្ត្រីនោះ ចំពោះព្រះសាស្តា ។ ទៅដល់ទីកន្លែងដែលប្រាថ្នាហើយ ក៏នាំគ្នាចុះចាកសំពៅចៀសចេញទៅ ។

## ភិក្ខុ ៧ រូប អត់អាហារ ៧ ថ្ងៃ ក្នុងល្អាងភ្នំ

ភិក្ខុ ៧ រូប ដទៃទៀត និមន្តចេញអំពីបច្ចន្តជនបទ ដើម្បីនឹងមកគាល់ព្រះសាស្តាដែរ វេលាល្ងាចចូលទៅកាន់វត្តមួយ ហើយសួររកកន្លែងសម្រាក ។ ក្នុងវត្តនោះ មានល្អាងមួយ មានគ្រែ ៧ ភិក្ខុដែលជាចៅអាវាសក៏បានប្រគល់ល្អាងនោះឲ្យ ភិក្ខុទាំង ៧ នោះ កាលបានល្អាងនោះហើយ ក៏នាំគ្នាដេកលើគ្រែនៅក្នុងល្អាងនោះ លុះដល់ពាក់កណ្តាលអធ្រាត (មាន) ផែនថ្មមួយដុំប៉ុនផ្ទះកំពូលរមៀលមកបិទទ្វារល្អាងជិត ពួកភិក្ខុម្ចាស់កន្លែងពោលថា "ពួកយើងបានប្រគល់ល្អាងនោះឲ្យដល់ពួកភិក្ខុអាគន្តុកៈ ឥឡូវនេះ ស្រាប់តែមានផែនថ្មមួយ

ផ្ទាំងធំ រមៀលមកបិទទ្វារល្អាងជិត ពួកយើងត្រូវជួយគ្នា នាំយកផែនថ្មនោះចេញ" លុះពោលដូច្នេះហើយ ក៏ឲ្យប្រជុំពួកមនុស្សទាំង ៧ ស្រុក ដែលនៅជុំវិញវត្តនោះ ដើម្បីនាំយកដុំថ្មនោះចេញ សូម្បីពួកភិក្ខុ និងពួកមនុស្សទាំង ៧ ស្រុកនោះ ខំប្រឹងព្យាយាមយ៉ាងណាក៏ដោយ ក៏មិនអាចធ្វើផែនថ្មនោះឲ្យរមៀលចេញទៅបាន ។ សូម្បីពួកភិក្ខុដែលនៅខាងក្នុងល្អាងនោះ ក៏ព្យាយាមដូចគ្នា ។ សូម្បីនាំគ្នាព្យាយាមយ៉ាងនោះក៏ដោយ ក៏មិនអាចរំកិលដុំថ្មនោះបានរហូត ៧ ថ្ងៃ ។ ពួកភិក្ខុអាគន្តុកៈត្រូវសេចក្តីឃ្លានគ្របសង្កត់អស់ ៧ ថ្ងៃ បានរងទុក្ខដ៏ធំក្នុងល្អាងនោះ ។ ក្នុងថ្ងៃទី ៧ ផែនថ្មនោះ ក៏បានរមៀលចេញឯងពួកភិក្ខុចេញអំពីល្អាងនោះហើយ គិតថា "បាបរបស់ពួកយើងនេះ វៀរលែងព្រះសាស្តាចេញហើយ នរណាទៅហ្ន៎នឹងដឹងនូវបាបនោះ ពួកយើងនឹងទូលសួរព្រះសាស្តា" ហើយក៏នាំគ្នាចៀសចេញទៅ ។ ពួកភិក្ខុទាំងនោះ បានមកជួបពួកភិក្ខុមុនៗ នៅពាក់កណ្តាលផ្លូវ ទាំងអស់គ្នាចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរមួយ ដែលព្រះសាស្តាបដិសណ្ឋារៈហើយ ក៏ទូលសួរនូវហេតុដែលខ្លួនបានឃើញ និងបានសោយហើយដោយលំដាប់ ។ សូម្បីព្រះសាស្តាក៏ទ្រង់ព្យាករណ៍ប្រាប់ភិក្ខុទាំងនោះ ដោយលំដាប់យ៉ាងនេះ ។

## បុព្វកម្មរបស់សត្វក្អែក

"ម្នាលភិក្ខុទាំងឡាយ ក្អែកនោះសោយនូវកម្មដែលខ្លួនបានធ្វើហើយនោះ

ឯង ។ ក៏ក្នុងអតីតកាល អ្នកស្រែម្នាក់ដែលមានប្រក្រតីនៅក្នុងក្រុងពារាណសី បានបង្ហាត់គោរបស់ខ្លួន តែមិនអាចបង្ហាត់បាន ។ ព្រោះថា គោរបស់គេនោះ ដើរទៅបានបន្តិចក៏ដេក សូម្បីគេវាយឲ្យក្រោកឡើងហើយ ដើរទៅបានបន្តិច ក៏ដេកទៀត ។ អ្នកស្រែនោះ សូម្បីព្យាយាមយ៉ាងណាក៏ដោយ ក៏មិនអាចបង្ហាត់ គោនោះបាន ត្រូវសេចក្តីក្រោធគ្របសង្កត់ ក៏ពោលថា "ឥឡូវនេះ យើងនឹង ឲ្យឯងដេកជាសុខតាំងអំពីថ្ងៃនេះទៅ" លុះពោលដូច្នេះហើយ ក៏ក្រងចំបើងធ្វើ ជាគប់មួយយ៉ាងធំ យកមកចងរុំនឹង.កគោនោះ ហើយដុតភ្លើងដុត ។ គោ នោះត្រូវភ្លើងឆេះ ក៏ស្លាប់នៅទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្អែកនោះបាន នូវធ្វើបាបកម្មក្នុងកាលដែលខ្លួននៅជាកសិករនោះឯង ។ គេឆេះនៅក្នុងនរក អស់កាលដ៏យូរ ព្រោះវិបាករបស់កម្មដែលជាបាបនោះ កើតហើយក្នុងកំណើត ក្អែក ត្រូវភ្លើងឆេះស្លាប់អស់ ៧ ដង ក្នុងកណ្តាលអាកាសយ៉ាងនេះឯង" ។

## បុព្វកម្មរបស់ភរិយានាយសំពៅ

ម្នាលភិក្ខុទាំងឡាយ សូម្បីស្ត្រីនោះ ក៏បានសោយបាបកម្មដែលខ្លួនបាន ធ្វើហើយដែរ ។ ក្នុងអតីតកាល ស្ត្រីនោះជាភរិយានៃគហបតីម្នាក់ នៅក្នុងក្រុង ពារាណសី បានធ្វើកិច្ចគ្រប់យ៉ាង មានដងទឹក បុកអង្ករ ចំអិនអាហារជាដើម ដោយដៃរបស់ខ្លួន ។ នៅក្នុងផ្ទះរបស់គហបតីនោះ មានសុនខមួយក្បាល សុនខនោះ តែងតែអង្គុយមើលនាង ដែលធ្វើកិច្ចគ្រប់យ៉ាងនៅក្នុងផ្ទះនោះ ។

ពេលនាងនាំកត្តទៅជូនស្វាមីរបស់នាងនៅឯស្រែក្តី ពេលទៅព្រៃដើម្បីរកវត្ថុផ្សេងៗ មានឧស និងបន្លែជាដើមក្តី សុនខនោះតែងតែទៅតាមនាងជានិច្ច ។ ពួកបុរសកំលោះៗ ឃើញដូច្នោះ តែងតែនិយាយចំអកឲ្យនាងថា "ម្នាលអ្នកទាំងឡាយ ព្រានសុនខចេញទៅព្រៃហើយវើយ ថ្ងៃនេះ ពួកយើងនឹងបានបរិភោគបាយជាមួយសាច់ហើយ" នាងអៀនខ្មាសនឹងពាក្យចំអកចំអន់របស់ពួកមនុស្សទាំងនោះ ទើបប្រហារសុនខនោះដោយដុំដី និងដំបងជាដើមឲ្យត្រឡប់ ។ សុនខនោះត្រឡប់ក្រោយបានបន្តិច ក៏រត់ទៅតាមនាងទៀត ។ បានឮមកថា សុនខនោះ ធ្លាប់ជាស្វាមីរបស់នាងកាលពី ៣ ជាតិមុន ព្រោះដូច្នោះ ទើបវាមិនអាចកាត់នូវសេចក្តីស្រឡាញ់ដែលកើតមានចំពោះនាងបាន ។ ពិតណាស់ បុគ្គលណាៗ ដែលឈ្មោះថា មិនធ្លាប់ជាភរិយា ឬជាស្វាមីនឹងគ្នាក្នុងសង្សារវដ្ត ដែលមានទីបំផុតខាងដើម និងខាងចុង ដែលបុគ្គលតាមដឹងមិនបាននោះ រមែងមិនមានឡើយ ព្រោះហេតុនោះ សេចក្តីស្រឡាញ់ដែលមានប្រមាណដ៏ក្រៃលែង រមែងមានក្នុងបុគ្គលដែលជាញាតិក្នុងអត្តភាពជិតៗ ព្រោះដូច្នោះ ទើបសុនខនោះ មិនអាចលះបង់សេចក្តីស្រឡាញ់ដែលកើតមានចំពោះនាងនោះបាន ។ នាងក៏ក្រោធខឹងនឹងសុនខនោះ ពេលដែលនាំយកបបរទៅជូនស្វាមីដែលនៅឯស្រែនោះ នាងបានយកខ្សែទុកក្នុងជាយសំពត់ ទើបធ្វើដំណើរទៅ ។ សុនខនោះក៏បានរត់ទៅតាមនាងដែរ លុះនាងធ្វើដំណើរទៅដល់ស្រែ ក៏បានយក

បបរជូនស្វាមីរបស់នាង រួចហើយក៏កាន់ក្អមទទេ ទៅកាន់កំពង់ទឹកមួយ ដាក់ខ្សាច់ឲ្យពេញក្អមនោះហើយ បានធ្វើសំឡេង (ជាសញ្ញា) ហៅសុនខដែលកំពុងឈរមើលនាងនៅក្នុងទីជិតនោះ ។ សុនខសប្បាយចិត្តខ្លាំងណាស់ ដោយគិតថា "យូរណាស់ហើយ យើងមិនដែលបានទទួលពាក្យដ៏ពីរោះយ៉ាងនេះទេ ទើបបានទទួលក្នុងថ្ងៃនេះឯង ទើបបក់កន្ទុយដើរចូលទៅរកនាង ។ នាងចាប់.កន្ត្រៃនោះយ៉ាងមាំហើយ យកចុងខ្សែម្ខាងចងក្អម យកចុងខ្សែម្ខាងទៀតចង.កសុនខហើយប្រានក្អមនោះឲ្យរមៀលចុះទឹក ។ សុនខនោះជាប់តាមក្អមធ្លាក់ទៅក្នុងទឹក ហើយស្លាប់នៅក្នុងទឹកនោះឯង ។ នាងនោះឆេះក្នុងនរកអស់កាលដ៏យូរព្រោះវិបាករបស់កម្មនោះ ។ ចំណែកវិបាកដ៏សេស ទើបត្រូវគេយកក្អមពេញដោយដីខ្សាច់ចង.កទម្លាក់ចុះក្នុងទឹក ស្លាប់ក្នុងទឹកអស់ ១០០ អត្តភាព ។

## បុព្វកម្មរបស់ភិក្ខុ ៧ រូប

ម្នាលភិក្ខុទាំងឡាយ សូម្បីអ្នកទាំងឡាយ ក៏សោយនូវបាបកម្មដែលខ្លួនបានធ្វើហើយដូចគ្នា ។ ក្នុងអតីតកាល មានក្មេងឃ្វាលគោ ៧ នាក់ នៅក្នុងក្រុងពារាណសី ដើរឃ្វាលគោតាមដងព្រៃ ក្នុងមួយកន្លែង ៧ ថ្ងៃ ។ ថ្ងៃមួយត្រឡប់មកអំពីឃ្វាលគោវិញ បានឃើញមេទន្សងមួយក្បាល ក៏នាំគ្នាដេញចាប់ ។ មេទន្សងនោះ ក៏រត់ចូលទៅក្នុងដំបូកកណ្តៀរមួយ ។ ក៏ដំបូកនោះមានរន្ធ ៧ ។ ក្មេងៗ ទាំងនោះប្រឹក្សាគ្នាថា "ថ្ងៃនេះ ពួកយើងមិនអាចចាប់វា

បាន ចាំថ្ងៃស្អែកពួកយើងនឹងមកចាប់វា" លុះប្រឹក្សាគ្នាដូច្នេះហើយ ក៏នាំគ្នាកាន់យកកំណាត់ឈើបាក់ម្នាក់មួយបាច់ៗ បិទរន្ធទាំងនោះ រួចហើយក៏ចៀសចេញទៅ ។ លុះព្រឹកឡើង ក្មេងទាំងនោះមិនបាននឹកដល់មេទន្សងនោះ ក៏កៀងគោទៅឃ្វាលក្នុងទីដទៃ ដល់ថ្ងៃទី ៧ កៀងគោមកវិញឃើញដំបូកនោះ ក៏នឹកឃើញដល់មេទន្សង បានគិតគ្នាថា "តើមេទន្សងនោះ យ៉ាងណាហើយហ្ន៎?" បានបើករន្ធដែលខ្លួនបិទទុកនោះ ។ មេទន្សងអស់សេចក្តីអាល័យក្នុងជីវិត សល់តែឆ្អឹង និងស្បែក ញ័រទទ្រើកវារចេញមក ក្មេងទាំងនោះឃើញដូច្នោះហើយ ក៏អាណិត បាននិយាយគ្នាថា "ពួកយើងកុំសម្លាប់វាអី វាអត់ចំណីអស់ ៧ ថ្ងៃហើយ" លុះពោលដូច្នេះហើយ ក៏អង្អែលខ្នងទន្សងនោះ ហើយក៏លែងទៅ ដោយពោលថា "ឯងចូរធ្វើដំណើរទៅតាមសប្បាយចុះ" ។ ក្មេងទាំងនោះ មិនត្រូវឆេះនៅក្នុងនរក ព្រោះមិនបានសម្លាប់ទន្សងនោះ ។ តែជនទាំង ៧ នាក់នោះ ត្រូវអត់បាយរួមគ្នា ៧ ៗ ថ្ងៃ អស់ ១៤ អត្តភាពមកហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបានធ្វើនូវបាបកម្មនោះ ក្នុងកាលដែលអ្នកទាំងឡាយនៅជាក្មេងឃ្វាលគោនោះឯង ។

ព្រះសាស្តា ទ្រង់ព្យាករណ៍បញ្ហា ដែលភិក្ខុទាំងនោះបានទូលសួរហើយ ដោយប្រការដូច្នេះ ។

## បុគ្គលនោះនៅទីណាៗ ក៏មិនរួចចាកបាបកម្ម

គ្រានោះ ភិក្ខុមួយរូបបានទូលសួរព្រះសាស្តាថា “ព្រះអង្គដ៏ចម្រើន ការរួចខ្លួនរបស់បុគ្គលដែលធ្វើនូវបាបកម្មហើយ ហោះឡើងទៅកាន់អាកាសក្តី ស្ទុះទៅកាន់សមុទ្ទក្តី ចូលទៅកាន់ចន្លោះនៃភ្នំក្តី រមែងមិនមានទេឬ?”

ព្រះសាស្តាត្រាស់ប្រាប់ថា “ម្នាលភិក្ខុទាំងឡាយ យ៉ាងនុ៎ះឯង សូម្បីក្នុងទីទាំងឡាយ មានអាកាសជាដើម ប្រទេសសូម្បីត្រឹមតែមួយចំណែកដែលបុគ្គលរស់នៅហើយ គប្បីរួចចាកកម្មអាក្រក់បាន មិនមាន” កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

១១.ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិស្ស
ន វិជ្ជតី សោ ជគតិប្បទេសោ
យត្រដ្ឋិតោ មុច្ចេយ្យ បាបកម្មា ។

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្ទ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ គប្បីរួចចាកបាបកម្មបាននោះ មិនដែលមានឡើយ ។

### អធិប្បាយគាថា

សេចក្ដីនៃព្រះគាថានេះថា "ប្រសិនបើបុគ្គលណាម្នាក់ គិតថា អញនឹងរួចចាកបាបកម្មដោយឧបាយយ៉ាងនេះ" គប្បីអន្ទុយឰដ៏អាកាសក្ដី ចូលទៅកាន់មហាសមុទ្រដែលមានជម្រៅ ៨ ម៉ឺន ៤ ពាន់យោជន៍ក្ដី អន្ទុយក្នុងចន្លោះនៃភ្នំក្ដី ក៏មិនអាចរួចចាកបាបកម្មបានឡើយ ព្រោះថា ក្នុងចំណែកនៃផែនដី គឺភាគនៃផែនដី មានបុរត្ថិមទិសជាដើម ឱកាសសូម្បីប៉ុនចុងនៃរោមទ្រាយ ដែលបុគ្គលឋិតនៅហើយ គប្បីរួចចាកបាបបាន រមែងមិនមាន" ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះ បានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។ ព្រះធម្មទេសនា មានប្រយោជន៍ដល់ជនទាំងឡាយ ដែលមកប្រជុំគ្នាហើយ ដូច្នេះឯង ។

ចប់ រឿងជន ៣ នាក់

# ១២. រឿងព្រះបាទសុប្បពុទ្ធសក្យៈ

ព្រះសាស្តា កាលប្រថាប់នៅវត្តនិគ្រោធារាម ទ្រង់ប្រារព្ធព្រះបាទសុប្ប-ពុទ្ធៈ ត្រាស់ព្រះធម្មទេសនានោះថា ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ (បុគ្គលដែលធ្វើបាប គេចទៅហើយក្នុងអាកាស ក៏មិនគប្បីរួចផុតចាកបាប គេចទៅក្នុងកណ្តាលមហាសមុទ្ទ ក៏មិនគប្បីរួចផុតចាកបាបបាន) ជាដើម ។

## ព្រះបាទសុប្បពុទ្ធក្រេវអង្គុយបិទផ្លូវព្រះសាស្តា

បានឮថា ព្រះបាទសុប្បពុទ្ធអង្គនោះ ទ្រង់ចងអាឃាតនឹងព្រះសាស្តា ដោយហេតុ ២ ប្រការ គឺ ព្រះសមណគោតមអង្គនោះ ចេញទៅបួសចោលធីតារបស់យើង ១ បំបួសបុត្ររបស់យើងហើយ ស្ថិតនៅក្នុងឋានៈជាអ្នកមានវៀរនឹងបុត្ររបស់យើង ១ ។ ថ្ងៃមួយ ទ្រង់ត្រិះរិះថា “ឥឡូវនេះ យើងនឹងមិនឲ្យព្រះសមណគោតមនោះយាងទៅឆាន់ត្រង់ទីនិមន្ត” ដូច្នេះ ទើបបិទផ្លូវត្រង់ស្តេចយាងទៅ ទ្រង់គង់សោយទឹកចណ្ឌក្នុងចន្លោះផ្លូវ ។

លំដាប់នោះ កាលព្រះសាស្តា ដែលមានភិក្ខុសង្ឃហែហមស្តេចយាងមកដល់ទីនោះ ពួកមហាតលិកក្រាបទូលព្រះរាជាថា “បពិត្រមហារាជ ព្រះសាស្តាស្តេចយាងមកហើយ” ។ ព្រះបាទសុប្បពុទ្ធបានត្រាស់ថា “ពួកអ្នកចូរប្រញាប់ទៅមុន ចូរប្រាប់ព្រះសមណៈនោះថា ព្រះសមណគោតមអង្គនោះ មិនមែនជាធំ

ជាងយើងទេ យើងនឹងមិនឲ្យផ្លូវដល់ព្រះសមណគោតមអង្គនោះ” សូម្បីពួកមហាតលិកទូលតឿនរឿយៗ ហើយ ក៏ទ្រង់គង់ត្រាស់បញ្ហាយ៉ាងនោះឯង ។

ព្រះសាស្តា មិនបានផ្លូវអំពីសម្នាក់ព្រះមាតុលៈ (អំ) ទើបស្តេចយាងត្រឡប់អំពីទីនោះ ។ សូម្បីព្រះរាជាក៏បញ្ជូនចារបុរស (អ្នកស៊ើបការណ៍) ម្នាក់ទៅ ដោយព្រះតម្រាស់ថា “អ្នកចូរទៅស្តាប់នូវពាក្យ របស់ព្រះសមណ-គោតមអង្គនោះ ហើយចូរត្រឡប់មកវិញ” ។

## ព្រះចានសុប្បពុទ្ធធ្វើកម្មធ្ងន់ត្រូវដែនដីស្រូប

ចំណែកព្រះសាស្តាកាលស្តេចយាងត្រឡប់មកវិញ ទ្រង់ធ្វើការញញឹមឲ្យប្រាកដ ព្រះអានន្ទទូលសួរថា “បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាបច្ច័យនៃកម្ម គឺ ការញញឹមឲ្យប្រាកដ?” ទើបទ្រង់ត្រាស់ថា “អានន្ទ អ្នកមានឃើញព្រះបាទសុប្បពុទ្ធទេ?” ។

ព្រះអានន្ទទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ ។

ព្រះសាស្តាត្រាស់ថា ព្រះបាទសុប្បពុទ្ធនោះ មិនឲ្យផ្លូវដល់ព្រះពុទ្ធប្រាកដស្មើដូចជាតថាគត បានធ្វើនូវកម្មដ៏ធ្ងន់ ក្នុងថ្ងៃទី ៧ អំពីថ្ងៃនេះ ព្រះអង្គនឹងចូលទៅកាន់ផែនដី (ធរណីស្រូប) ត្រង់ទីជិតជើងជណ្តើរ ខាងក្រោមប្រាសាទ” ។

ចារបុរសនោះ បានស្តាប់នូវព្រះតម្រាស់របស់ព្រះមានព្រះភាគហើយ

ទៅកាន់សម្នាក់ព្រះបាទសុប្បពុទ្ធ ទ្រង់ត្រាស់សួរថា "ក្មួយរបស់យើងត្រឡប់ទៅវិញ បាននិយាយនូវពាក្យអ្វីខ្លះ?" ទើបក្រាបទូលតាមដែលខ្លួនបានឮ ។

ព្រះរាជាទ្រង់ស្តាប់នូវពាក្យ ដែលចារបុរសនោះបានក្រាបទូលហើយ ទ្រង់ត្រាស់ថា "ឥឡូវនេះ ទោសក្នុងការនិយាយ (កុហក) នៃក្មួយរបស់យើងរមែងមិនមាន ព្រះអង្គត្រាស់នូវពាក្យណា ពាក្យនោះរមែងមានដោយប្រការដូច្នោះមែន តែសូម្បីដូច្នោះក៏ដោយ ពេលនេះ យើងនឹងផ្ចាញ់ផ្ចាល់ព្រះអង្គដោយការនិយាយកុហក ព្រោះព្រះអង្គមិនបានត្រាស់នឹងយើង ដោយប្រាកដថា ព្រះបាទសុប្បពុទ្ធនឹងត្រូវធរណីស្រូបក្នុងថ្ងៃទី ៧ គ្រាន់តែត្រាស់ថា សុប្បពុទ្ធនឹងត្រូវធរណីស្រូបត្រង់ទីជិតជើងជណ្តើរ ខាងក្រោមប្រាសាទប៉ុណ្ណោះ បើដូច្នោះ តាំងអំពីថ្ងៃនោះទៅ យើងនឹងមិនទៅកាន់ទីនោះ យើងមិនត្រូវធរណីស្រូបក្នុងទីនោះឡើយ នឹងគ្របសង្កត់លោកដោយការនិយាយកុហក" ។

ព្រះបាទសុប្បពុទ្ធបញ្ជាឲ្យពួកមហាតលិក ជញ្ជូនគ្រឿងប្រើប្រាស់របស់ព្រះអង្គទៅទុកលើប្រាសាទ ៧ ជាន់ ឲ្យដកជណ្តើរចេញ បិទទ្វារ ដាក់មនុស្សមាឌមាំៗ ពីរនាក់ ត្រង់ទ្វារមួយៗ ហើយត្រាស់ថា "ប្រសិនបើពួកឯងឃើញយើងដើរចុះទៅខាងក្រោម ដោយសេចក្តីប្រមាទសោត អ្នកទាំងឡាយគប្បីហាមឃាត់យើង" លុះពោលដូច្នេះហើយ ក៏ទ្រង់ប្រថាប់ក្នុងបន្ទប់ដ៏មានសិរីលើផ្ទៃប្រាសាទជាន់ទី ៧ ។

## និងគេចអំពីផលនៃកម្មអាក្រក់ រមែងមិនផុត

ព្រះសាស្តាទ្រង់ស្តាប់រឿងនោះហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រះបាទសុប្បពុទ្ធនោះ កុំថាឡើយអង្គុយនៅលើផ្ទៃប្រាសាទរហូតនោះ ទោះបីហោះឡើងទៅកាន់វេហាស៍ហើយ អង្គុយក្នុងអាកាសក៏ដោយ ចូលទៅកាន់មហាសមុទ្រដោយសំពៅក៏ដោយ ចូលទៅកាន់ចន្លោះភ្នំក៏ដោយ ធម្មតាព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ រមែងមិនមានពីរ ព្រះអង្គនឹងត្រូវធរណីស្រូបក្នុងទីដែលតថាគតពោលហើយនោះឯង" កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

១២.ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ

ន បព្វតានំ វិវរំ បវិស្ស

ន វិជ្ជតី សោ ជគតិប្បទេសោ

យត្រដ្ឋិតំ នប្បសហេយ្យ មច្ចុ ។

បុគ្គលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះនៃភ្នំ

ទាំងឡាយ ក៏មិនរួចចាកសេចក្តីស្លាប់បាន ព្រោះប្រទេសលើ

ផែនដី ដែលបុគ្គលឋិតនៅហើយ សេចក្តីស្លាប់គ្របសង្កត់មិន

បាននោះ មិនដែលមានឡើយ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **នប្បសហេយ្យ មច្ចុ** (សេចក្ដីស្លាប់គប្បីគ្របសង្កត់មិនបាន) សេចក្ដីថា ប្រទេស គឺ ផែនដី សូម្បីត្រឹមតែប៉ុនចុងសក់ ដែលមរណៈមិនគប្បីញាំញី គឺ មិនគប្បីគ្របសង្កត់អ្នកដែលឋិតនៅទីហើយ រមែងមិនមាន ។ ពាក្យដ៏សេស ក៏ដូចពាក្យមុននោះឯង ។

ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

## ព្រះរាជាត្រូវដែនដីស្រូប នៅកើតក្នុងអវិចីនរក

ក្នុងថ្ងៃទី ៧ ក្នុងវេលាដូចវេលាដែលព្រះបាទសុប្បពុទ្ធបិទផ្លូវភិក្ខាចាររបស់ព្រះសាស្ដា សេះមង្គលរបស់ព្រះអង្គ ដែលនៅខាងក្រោមប្រាសាទលោតកញ្ជ្រោលឡើង ផាយធាក់ជញ្ជាំងនោះៗ ។ ព្រះអង្គប្រថាប់គង់នៅជាន់លើនោះឯង បានឮសំឡេងសេះនោះ ក៏ត្រាស់សួរថា "នុ៎ះជាសំឡេងអ្វី" ពួកមហាតលិក ទូលថា "សេះមង្គលលោតកញ្ជ្រោល ។ ចំណែកសេះនោះ គ្រាន់តែឃើញព្រះបាទសុប្បពុទ្ធក្លាម ក៏ឈប់ស្ងៀម ។

ខណៈនោះ ព្រះអង្គមានបំណងនឹងចាប់សេះនោះ ស្ដេចបានក្រោកចាកទីប្រថាប់ បែរព្រះភក្ដ្រមករកទ្វារ ។ ទ្វារទាំងឡាយរបើកឯង ជណ្ដើរតាំងនៅក្នុងទីរបស់ខ្លួនដូចដើម ។ ពួកមនុស្សដែលខ្លាំងៗ ឈរនៅត្រង់ទ្វារ ចាប់ព្រះ

រាជាត្រង់ព្រះសូរង ហើយប្រាន ឲ្យមានព្រះកក្រ្កចុះមកខាងក្រោម ។ ដោយឧបាយនោះ ទ្វារទាំង ៧ ជាន់ ក៏រលើកឯង ជណ្តើរទាំងឡាយក៏តាំងនៅដូចដើម ។ ពួកមនុស្សមានកម្លាំង (ប្រចាំទ្វារ) ត្រង់ជាន់នោះៗ ចាប់ព្រះរាជាត្រង់ព្រះសូរង ហើយប្រានឲ្យមានព្រះកក្រ្កចុះក្រោម ។

ខណៈនោះ មហាប្រឹថពីបើកចន្លោះរង់ចាំទទួលព្រះបាទសុប្បពុទ្ធ នៅជិតជើងជណ្តើរ ខាងក្រោមប្រាសាទនោះឯង ព្រះអង្គលិចចូលទៅក្នុងផែនដីកើតក្នុងអវិចីនរកហើយ ។

ចប់ រឿងព្រះធានសុប្បពុទ្ធសក្យៈ

# ចប់ធាបវគ្គវណ្ណនា វគ្គទី ៩

ក្នុងវគ្គនេះរួមមាន ១២ រឿង


| | |
|---|---|
| ១. រឿងចូឡេកសាដកព្រាហ្មណ៍ | ២. រឿងព្រះសេយ្យកត្ថេរ |
| ៣. រឿងនាងលាជទេវធីតា | ៤. រឿងអនាបិណ្ឌិកសេដ្ឋី |
| ៥. រឿងភិក្ខុមិនរក្សាបរិក្ខារ | ៦. រឿងសេដ្ឋីពិឡាលបទកៈ |
| ៧. រឿងមហាធនពាណិជ្ជ | ៨. រឿងព្រានកុក្កុដមិត្ត |
| ៩. រឿងព្រានសុនខឈ្មោះកោកៈ | ១០. រឿងព្រះតិស្សចូលកាន់... |
| ១១. រឿងជន ៣ នាក់ | ១២. រឿងព្រះធានសុប្បពុទ្ធ |

# ទណ្ឌវគ្គ ទី ១០

"ពោលអំពីអាជ្ញា"

# ១. រឿងឆព្វគ្គិយភិក្ខុ

[២០] *ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា* ***សព្វេ តសន្តិ (សត្វទាំងឡាយរមែងតក់ស្លុត)*** *ជាដើម ។*

## ហេតុទ្រង់បញ្ញត្តិប្បហារទានសិក្ខាបទ

*សេចក្តីពិស្តារថា ក្នុងសម័យមួយ កាលពួកសត្តរសវគ្គិយភិក្ខុបោសប្រាសសេនាសនៈស្អាតហើយ ឆព្វគ្គិយភិក្ខុ ពោលថា "ពួកលោកចូរចៀសចេញ ពួកយើងចាស់ជាង ដូច្នេះ សេនាសនៈនេះត្រូវបានមកពួកយើង" កាលពួកសត្តរសភិក្ខុពោលដូច្នេះថា "ពួកខ្ញុំមិនព្រមឲ្យទេ (ព្រោះ) សេនាសនៈនេះពួកខ្ញុំជួសជុលរៀបចំបោសសម្អាតបានមុន" ក៏ប្រហារពួកសត្តរសភិក្ខុ ។ សត្តរសវគ្គិយភិក្ខុ ត្រូវមរណភ័យគម្រាម ក៏នាំគ្នាស្រែកដោយមានសំឡេងខ្លាំងៗ ។*

*ព្រះសាស្តា ទ្រង់ស្តាប់សំឡេងរបស់ភិក្ខុទាំងនោះហើយ ក៏ត្រាស់សួរថា "មានរឿងអ្វី" ភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពួកឆព្វិយភិក្ខុ ប្រហារពួកសត្តរសភិក្ខុ" ក៏ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ចាប់តាំងពីពេលនេះទៅ ភិក្ខុមិនគួរធ្វើយ៉ាងនោះ ភិក្ខុណាធ្វើ ភិក្ខុនោះត្រូវអាបត្តិ*

ឈ្មោះនេះ" លុះទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់បញ្ញត្តិបហារទានសិក្ខាបទ ដល់ភិក្ខុទាំងឡាយ បន្ទាប់មកទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុតែងតែតក់ស្លុតចំពោះអាជ្ញា ខ្លាចចំពោះសេចក្ដីស្លាប់ យ៉ាងណា សូម្បីសត្វដទៃក៏តែងតែតក់ស្លុតចំពោះអាជ្ញា ខ្លាចចំពោះសេចក្ដីស្លាប់ដូច្នោះដែរ ដូច្នេះ មិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារអ្នកដទៃឡើយ" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងព្រះធម៌ បានត្រាស់ព្រះគាថានេះថា ៖

១.សព្វេ តសន្តិ ទណ្ឌស្ស   សព្វេ ភាយន្តិ មច្ចុនោ
អត្តានំ ឧបមំ កត្វា   ន ហនេយ្យ ន ឃាតយេ ។

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយតែងខ្លាចសេចក្ដីស្លាប់គ្រប់ៗ រូប បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា ហើយមិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា *សព្វេ តសន្តិ* (សត្វទាំងឡាយ រមែងតក់ស្លុត) សេចក្ដីថា សត្វសូម្បីទាំងអស់ កាលអាជ្ញាធ្លាក់មកលើខ្លួន តែងតែតក់ស្លុតចំពោះអាជ្ញានោះ ។ បទថា *មច្ចុនោ* (ដល់សេចក្ដីស្លាប់) បានដល់ រមែងខ្លាចសេចក្ដីស្លាប់ដោយពិត ។ ក៏ព្យញ្ជនៈនៃធម្មទេសនានេះ មិនមានសល់ ។ ចំណែកអត្ថ នៅមាន ។ ឧបមាដូចជា ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យពួករាជបុរស

ទូងស្គរប្រកាសថា "ជនទាំងអស់ចូរប្រជុំគ្នា" ជនដ៏សេស វៀរព្រះរាជា និង មហាមាត្យរបស់ព្រះរាជាចេញ រមែងមកប្រជុំគ្នា យ៉ាងណា សូម្បីកាលព្រះសាស្តាត្រាស់ថា សត្វទាំងអស់តែងតក់ស្លុត ដូច្នេះ សត្វទាំងឡាយដ៏សេស វៀរសត្វវិសេស ៤ ជំពូក គឺ ដំរីអាជានេយ្យ សេះអាជានេយ្យ គោឧសភ-អាជានេយ្យ និងព្រះខីណាស្រព បណ្ឌិតគប្បីជ្រាបថា តែងតក់ស្លុតទាំងអស់ពិតណាស់ បណ្តាសត្វវិសេសទាំងនោះ ព្រះខីណាស្រព មិនឃើញថា មានសត្វស្លាប់ ព្រោះលោកលះបង់សក្កាយទិដ្ឋិបានហើយ ទើបមិនភ័យខ្លាចស្លាប់ សត្វវិសេស ៣ ជំពូកក្រៅពីនេះ មិនឃើញសត្វដែលជាបដិបក្សចំពោះខ្លួន ព្រោះសក្កាយទិដ្ឋិមានកម្លាំង ទើបមិនខ្លាច ។

បទថា ន ហនេយ្យ ន ឃាតយេ (មិនគួរសម្លាប់ដោយខ្លួនឯង មិនគួរប្រើអ្នកដទៃឲ្យសម្លាប់) សេចក្តីថា បុគ្គលដឹងថា "យើងយ៉ាងណា សូម្បីសត្វដទៃក៏ដូច្នោះ" ដូច្នេះហើយ ទើបមិនគួរសម្លាប់ដោយខ្លួនឯង និងមិនគួរប្រើអ្នកដទៃឲ្យសម្លាប់ ។

លុះចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងឆព្វគ្គិយភិក្ខុ

# ២. រឿងឆព្វគ្គិយភិក្ខុ

*ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា* ***សព្វេ តសន្តិ (សត្វទាំងអស់រមែងតក់ស្លុត)*** *ជាដើម ។*

## ហេតុឱ្យព្រះអង្គបញ្ញត្តិ តលសត្តិកសិក្ខាបទ

*សេចក្ដីពិស្ដារថា សម័យមួយ ពួកឆព្វគ្គិយភិក្ខុងារឡើងនូវលំពែង គឺបាតដៃប្រហារពួកសត្តរសវគ្គិយភិក្ខុ ដោយហេតុ ដូចដែលខ្លួនប្រហារពួកសត្តរសវគ្គិយភិក្ខុ ក្នុងសិក្ខាបទមុននោះឯង ។*

*ចំណែកក្នុងរឿងនេះ ព្រះសាស្ដា ទ្រង់ស្ដាប់នូវសំឡេងរបស់ភិក្ខុទាំងនោះហើយ ក៏ទ្រង់ត្រាស់សួរថា "ម្នាលភិក្ខុ តើមានរឿងអ្វី" ភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពួកឆព្វិយភិក្ខុ ប្រហារពួកសត្តរសវគ្គិយភិក្ខុ" លុះភិក្ខុទាំងនោះក្រាបទូលដូច្នេះហើយ ក៏ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ចាប់ពីពេលនេះទៅ ធម្មតាភិក្ខុមិនគួរធ្វើយ៉ាងនេះ ភិក្ខុណាធ្វើ ភិក្ខុនោះត្រូវអាបត្តិឈ្មោះនេះ" ដូច្នេះហើយ ក៏ទ្រង់បញ្ញត្តិតលសត្តិកសិក្ខាបទ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុដឹងថា សូម្បីសត្វដទៃរមែងតក់ស្លុតចំពោះអាជ្ញា ដូចគ្នានឹងយើង ម្យ៉ាងទៀត ជីវិតក៏រមែងជាទីស្រឡាញ់របស់សត្វទាំងនោះ ដូចយើងដោយពិត ដូច្នេះអ្នកទាំងឡាយ មិនគួរប្រហារដោយខ្លួនឯង មិន*

គួរប្រើគេឲ្យប្រហារឡើយ” ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

២.សព្វេ តសន្តិ ទណ្ឌស្ស សព្វេសំ ជីវិតំ បិយំ

អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា (ព្រោះថា) ជីវិតជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា ហើយមិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា សព្វេសំ ជីវិត បិយំ (ជីវិតរមែងជាទីស្រឡាញ់របស់សត្វទាំងអស់) សេចក្តីថា វៀរព្រះខីណាស្រពចេញ ជីវិតរមែងជាទីស្រឡាញ់ដ៏ក្រៃលែងរបស់ពួកសត្វដ៏សេស ដែលព្រះខីណាស្រពរមែងជាអ្នកព្រងើយក្នុងជីវិត ឬក្នុងមរណៈដោយពិត ។ ពាក្យដ៏សេសមានន័យដូចពាក្យមុននោះឯង ។

លុះចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងឆព្វគ្គិយភិក្ខុ

# ៣. រឿងក្មេងច្រើននាក់

*ព្រះសាស្តា កាលប្រថាប់នៅនាវត្តជេតពន ទ្រង់ប្រារព្ធក្មេងច្រើននាក់ ត្រាស់ព្រះធម្មទេសនានេះថា* ***សុខកាមានិ ភូតានិ (សត្វដែលកើតហើយទាំងឡាយ ជាអ្នកប្រាថ្នាសុខ)*** *ជាដើម ។*

ព្រះសាស្តាទ្រង់ជួបពួកក្មេងវាយពស់

*សេចក្តីពិស្តារថា សម័យមួយ ព្រះសាស្តាទ្រង់ប្រដាប់បាត្រ និងចីវរ ចូលទៅកាន់ក្រុងសាវត្ថី ទ្រង់បានឃើញពួកក្មេងជាច្រើននាក់ យកឈើវាយពស់ផុះមួយ ត្រង់វាងផ្លូវ ក៏ទ្រង់ត្រាស់សួរថា "នែពួកក្មេងទាំងឡាយ ពួកអ្នកធ្វើអ្វី" កាលពួកក្មេងទាំងនោះក្រាបទូលថា "ពួកខ្ញុំព្រះអង្គយកឈើវាយពស់" ។ ព្រះអង្គក៏ទ្រង់ត្រាស់សួរទៀតថា "ព្រោះហេតុអ្វី ទើបពួកអ្នករាល់គ្នាវាយវា" កាលពួកក្មេងក្រាបទូលថា "ព្រោះពួកខ្ញុំព្រះអង្គខ្លាចវាខាំ" ទើបព្រះអង្គត្រាស់ថា "ពួកអ្នករាល់គ្នាវាយពស់នេះ ដោយគិតថា នឹងធ្វើសេចក្តីសុខឲ្យដល់ខ្លួន ដូច្នេះ អ្នកទាំងឡាយនឹងមិនបានទទួលនូវសេចក្តីសុខក្នុងទីដែលខ្លួនកើតហើយៗ ទេ ដោយពិត បុគ្គលកាលប្រាថ្នាសុខដល់ខ្លួន (តែ) ប្រហារសត្វដទៃ រមែងមិនគួរ" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖*

*៣. សុខកាមានិ ភូតានិ    យោ ទណ្ឌេន វិហឹសតិ*

*អត្តនោ សុខមេសានោ  បេច្ច សោ ន លភតេ សុខំ ។*

*សុខកាមានិ  ភូតានិ  យោ  ទណ្ឌេន  ន  ហឹសតិ*

*អត្តនោ សុខមេសានោ  បេច្ច សោ លភតេ សុខំ ។*

*ជនណា ស្វែងរកសេចក្តីសុខដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ នឹងមិនបានសេចក្តីសុខឡើយ ។*

*ជនណា ស្វែងរកសេចក្តីសុខដើម្បីខ្លួន តែមិនបៀតបៀនសត្វទាំងឡាយ អ្នកដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ រមែងបានសេចក្តីសុខ ។*

## អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា យោ ទណ្ឌេន (បុគ្គលណា...ដោយដំបង) សេចក្តីថា បុគ្គលណា រមែងបៀតបៀនអ្នកដទៃ ដោយដំបង ឬដោយវត្ថុទាំងឡាយ មានដុំដីជាដើម ។*

*បទថា បេច្ច សោ ន លភតេ សុខំ (បុគ្គលនោះលះលោកនេះទៅហើយរមែងមិនបានសុខ) សេចក្តីថា បុគ្គលនោះ រមែងមិនបានសុខសម្រាប់មនុស្ស សុខដែលជាទិព្វ ឬសុខ គឺ ព្រះនិព្វាន ដែលជាបរមត្ថ (សុខ) ក្នុងលោកខាងមុខ ។*

*ក្នុងព្រះគាថាទី ២ មានសេចក្តីថា បេច្ច សោ លភតេ សុខំ (បុគ្គល*

*នោះលះលោកនេះទៅហើយ រមែងបានសុខ)* សេចក្តីថា បុគ្គលនោះរមែងបាន សុខទាំង ៣ យ៉ាង មានប្រការដូចពោលហើយ ក្នុងបរលោក ។

ក្នុងកាលចប់ព្រះធម៌ទេសនា ក្មេងទាំង ៥០០ នាក់ បានតាំងនៅក្នុង សោតាបត្តិផល ដូច្នេះឯង ។

ចប់ រឿងក្មេងច្រើននាក់

# ៤. រឿងព្រះកោណ្ឌធានត្ថេរ

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះកោណ្ឌធានៈ ត្រាស់ព្រះធម្មទេសនានេះថា* ***មាវោច ផរុសំ កញ្ចិ (អ្នកកុំពោលពាក្យអាក្រក់នឹងនរណាៗ)*** *ជាដើម ។*

## រូបស្ត្រីជាប់តាមព្រះថេរៈគ្រប់កន្លែង

*ដូចបានស្តាប់មក ចាប់តាំងពីថ្ងៃដែលព្រះថេរៈនោះបួសហើយ មានរូបស្ត្រីម្នាក់ដើរតាមក្រោយលោកជានិច្ច (តែ) ព្រះថេរៈមិនបានឃើញរូបស្ត្រីនោះទេ ចំណែកមហាជនបានឃើញ ។ ពេលលោកនិមន្តទៅបិណ្ឌបាតក្នុងភូមិ ពួកមនុស្សប្រគេនភិក្ខា ដោយនិយាយថា "លោកម្ចាស់ដ៏ចម្រើន ភិក្ខាមួយវែកនេះសម្រាប់លោកម្ចាស់ ឯមួយវែកទៀតនេះ សម្រាប់ស្ត្រីដែលជាសំឡាញ់របស់លោកម្ចាស់" ដូច្នេះហើយ ក៏ប្រគេនភិក្ខា ២ វែក ។*

*សួរថា បុព្វកម្មរបស់លោក ដូចម្តេច ?*

*ឆ្លើយថា បានឮថា ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ មានភិក្ខុពីររូបជាសំឡាញ់នឹងគ្នា មានការស្និទ្ធស្នាលគ្នាយ៉ាងក្រៃលែង ដូចប្រសូតចាកគភ៌មាតាតែមួយ ។*

*ក៏ក្នុងកាលនៃព្រះពុទ្ធទ្រង់មានព្រះជន្មវែងៗ ភិក្ខុទាំងឡាយតែងតែប្រជុំគ្នា ១ ឆ្នាំម្តង ឬ ៦ ខែម្តង ព្រោះដូច្នោះ ភិក្ខុទាំងពីររូបនោះ ក៏និមន្តទៅកាន់*

ទីនោះ ដោយគិតថា "នឹងទៅកាន់រោងឧបោសថ" ។

## ទេវតាក្លែងធ្វើឱ្យព្រះថេរៈបែកគ្នា

ទេវតាដែលនៅក្នុងឋានតាវត្តិង្សមួយអង្គ ឃើញភិក្ខុទាំងពីររូបនោះ ក៏គិតថា "ភិក្ខុទាំងពីរនេះ ស្និទ្ធស្នាលគ្នាខ្លាំងម្ល៉េះ តើយើងអាចធ្វើភិក្ខុទាំងពីរអង្គនេះ ឲ្យបែកគ្នាបានដែរឬទេហ្ន៎" លុះគិតដូច្នេះហើយ ក៏បានមកកាន់ទីនោះតាមវេលាដែលខ្លួនគិតហើយនោះឯង ដោយអំណាចខ្លួនជាបុគ្គលពាល ។ ក្នុងភិក្ខុពីររូបនោះ ភិក្ខុមួយរូបពោលថា "អ្នកមានអាយុ សូមលោកចាំខ្ញុំមួយភ្លែត ខ្ញុំត្រូវការបន្ទោបង់ឧច្ចារៈ" ទេវតាទើបនិម្មិតខ្លួនជាមនុស្សស្រីម្នាក់ ។ ក្នុងពេលដែលព្រះថេរៈ ចូលទៅក្នុងចន្លោះគុម្ពឈើហើយចេញមក ក៏យកដៃម្ខាងបួងសក់ ដៃម្ខាងទៀតជជុះសំពត់ ដើរចេញមកតាមក្រោយព្រះថេរៈនោះ ។ ព្រះថេរៈនោះលោកមិនបានឃើញស្ត្រីនោះទេ តែភិក្ខុមួយរូបដែលឈរវង់ចាំនោះមើលឃើញស្ត្រីនោះ ធ្វើយ៉ាងនោះ (ដើរតាម) ចេញមក ។

## វង្វៀសគ្នាដោយសីលភេទ

ទេវតានោះដឹងថា ភិក្ខុនោះឃើញខ្លួនហើយ ក៏អន្តរធានទៅ ។ ភិក្ខុក្រៅនេះ (ភិក្ខុដែលឈរចាំ) និយាយនឹងភិក្ខុនោះ ក្នុងពេលដែលលោកដើរមកជិតខ្លួនថា "អ្នកមានអាយុ លោកទ្រុស្តសីលហើយ" ។

ភិក្ខុនោះពោលថា "អ្នកមានអាយុ កម្មបែបនេះរបស់ខ្ញុំ មិនមានទេ" ។

ភិក្ខុដែលរង់ចាំនោះពោលថា "អម្បាញ់មិញ ខ្ញុំបានឃើញស្ត្រីក្រមុំម្នាក់ ដើរតាមក្រោយលោក ចេញអំពីគុម្ពឈើ ធ្វើនូវអាការបែបនេះៗ លោកនៅនិយាយបដិសេធថា កម្មបែបនេះរបស់ខ្ញុំ មិនមានទៀតឬ?" ។

ភិក្ខុនោះមានអាការ ហាក់ដូចជាត្រូវរន្ទះបាញ់ចំក្បាល ពោលអង្វរថា "អ្នកមានអាយុ អ្នកកុំញុំាងខ្ញុំឲ្យវិនាសឡើយ ខ្ញុំមិនបានធ្វើកម្មបែបនោះដោយពិត" ។

ភិក្ខុក្រៅនេះពោលថា "ខ្ញុំបានឃើញផ្ទាល់នឹងភ្នែកទាំងពីររបស់ខ្ញុំៗ នឹងជឿលោកដូចម្ដេចបាន" ហើយក៏បែកគ្នាដូចកំណាត់ឈើ រួចចៀសចេញទៅ ។ សូម្បីនៅក្នុងរោងឧបោសថ ក៏អង្គុយដោយតាំងចិត្តថា "យើងនឹងមិនធ្វើឧបោ-សថរួមជាមួយភិក្ខុនេះឡើយ" ។

ចំណែកភិក្ខុអ្នកជាប់ចោទ ប្រាប់ភិក្ខុទាំងឡាយថា "ចំណុចខ្មៅសូម្បីប៉ុនគ្រាប់ល្ង ក៏មិនមានក្នុងសីលរបស់ខ្ញុំដែរ" ។

សូម្បីភិក្ខុដែលឈររង់ចាំនោះ បានពោលសង្កត់ថា "កម្មលាមកនោះខ្ញុំបានឃើញឯង" ។

ទេវតាឃើញភិក្ខុដែលរង់ចាំនោះ មិនព្រមធ្វើឧបោសថរួមជាមួយភិក្ខុដែលខ្ជួនក្មេងនោះ ក៏គិតថា "យើងបានធ្វើកម្មធ្ងន់ណាស់" ទើបបញ្ជាក់ប្រាប់ថា "ការធ្លុះធ្លាយសីលនៃលោកម្ចាស់របស់ខ្ញុំមិនមានទេ ចំណែកកម្មដ៏លាមកនោះ គឺ ខ្ញុំព្រះករុណាជាអ្នកធ្វើ ដោយចង់សាកល្បងមើល សូមលោកម្ចាស់

ធ្វើឧបោសថជាមួយលោកម្ចាស់នោះវិញចុះ” ។ ភិក្ខុដែលរង់ចាំនោះ កាល ទេវតានោះ ស្ថិតនៅក្នុងអាកាសប្រាប់យ៉ាងនោះទើបជឿ ព្រមធ្វើឧបោសថរួម ជាមួយគ្នា តែមិនបានស្និទ្ធស្នាលជាមួយគ្នា ដូចក្នុងកាលមុនឡើយ ។ បុព្វ-កម្មរបស់ទេវតាមានប្រមាណប៉ុណ្ណេះ ។ ក្នុងកាលអស់អាយុ ព្រះថេរៈទាំង ពីរអង្គនោះ បានទៅបដិសន្ធិក្នុងទេវលោកតាមសប្បាយ ។

## ទេវតាមកកើតជាព្រះកោណ្ឌធាន

ចំណែកទេវតានោះ ទៅកើតក្នុងអវិចីនរក ឆេះនៅក្នុងអវិចីនរកនោះ អស់មួយចន្លោះព្រះពុទ្ធ ក្នុងពុទ្ធុប្បាទកាលនេះ បានមកកើតនៅក្នុងក្រុងសាវត្ថី ចម្រើនវ័យហើយ បានបព្វជ្ជាឧបសម្បទានៅក្នុងព្រះពុទ្ធសាសនា ។ ចាប់តាំង ពីលោកបួសមក មានរូបស្ត្រីម្នាក់ដើរតាមក្រោយលោកជានិច្ច ។ ព្រោះហេតុ នោះឯង ទើបភិក្ខុទាំងឡាយដាក់ឈ្មោះលោកថា “**កោណ្ឌធាន**” ។

## ពួកភិក្ខុប្រាប់គ្រហស្ថឲ្យបណ្ដេញលោក

ភិក្ខុទាំងឡាយឃើញលោកត្រាច់ទៅយ៉ាងនោះ ក៏ប្រាប់អនាថបិណ្ឌិក-សេដ្ឋីថា “លោកសេដ្ឋី លោកចូរបណ្ដេញភិក្ខុទ្រុស្តសីលរូបនេះ ចេញពីវិហារ របស់លោកទៅ ព្រោះថា សេចក្ដីវិនាសនឹងកើតមានឡើងដល់ភិក្ខុដ៏សេស” ។

សេដ្ឋី. លោកម្ចាស់ដ៏ចម្រើន ព្រះសាស្ដា ព្រះអង្គមិនប្រថាប់នៅក្នុង វិហារទេឬ ។

ភិក្ខុ. ប្រថាប់នៅ លោកសេដ្ឋី ។

សេដ្ឋី. បើដូច្នោះ ព្រះសាស្តាព្រះអង្គគង់នឹងទ្រង់ជ្រាបនូវរឿងនោះ ។

ភិក្ខុទាំងឡាយ ក៏ទៅប្រាប់សូម្បីដល់នាងវិសាខាដូចគ្នា ។

សូម្បីនាងវិសាខា ក៏ប្រាប់ភិក្ខុទាំងនោះ ដូចលោកសេដ្ឋីដែរ ។

ចំណែកភិក្ខុទាំងឡាយ កាលអ្នកទាំងពីរ មិនព្រមធ្វើតាមពាក្យរបស់ខ្លួន ក៏ទូលព្រះរាជាថា "មហាបពិត្រ ភិក្ខុកោណ្ឌធាននាំស្ត្រីម្នាក់ដើរតាម នឹងធ្វើសេចក្តីវិនាសដល់ភិក្ខុគ្រប់រូប សូមមហាបពិត្រ បណ្តេញភិក្ខុនោះចេញពីដែនរបស់ព្រះអង្គទៅ" ។

ព្រះរាជា. ចុះភិក្ខុនោះនៅទីណា ? ។

ពួកភិក្ខុ. នៅក្នុងវិហារ មហាបពិត្រ ។

ព្រះរាជា. នៅកុដិមួយណា ? ។

ពួកភិក្ខុ. នៅក្នុងកុដិឈ្មោះឯណោះ ។

ព្រះរាជា. បើដូច្នោះ សូមលោកម្ចាស់និមន្តទៅមុនចុះ ខ្ញុំព្រះករុណានឹងបញ្ជាឲ្យគេទៅចាប់ភិក្ខុនោះ ។

## ព្រះរាជាយាងទៅសាកសួរព្រះកោណ្ឌធាន

ក្នុងវេលារសៀល ព្រះរាជាយាងទៅកាន់វិហារ បង្គាប់ពួករាជបុរសឲ្យឡោមព័ទ្ធកុដិនោះ រួចព្រះអង្គគង់បែរព្រះភក្ត្រចំទៅលំនៅរបស់ព្រះថេរៈ ។

ព្រះថេរៈបានឮសំឡេង ក៏ចេញចាកវិហារ (លំនៅ) មកឈរនៅខាងមុខកុដិ ។ ព្រះរាជាក៏បានទតឃើញរូបស្ត្រីនោះឈរនៅខាងក្រោយព្រះថេរៈ ។ ព្រះថេរៈជ្រាបថា ព្រះរាជាយាងមក ក៏ឡើងទៅគង់លើវិហារ ។ ព្រះរាជាទ្រង់មិនថ្វាយបង្គំព្រះថេរៈ ហើយក៏មិនបានទតឃើញស្ត្រីនោះ ។ ព្រះអង្គពិនិត្យមើលចន្លោះទ្វារខ្លះ ក្រោមគ្រែខ្លះ ក៏មិនឃើញ ទើបបានត្រាស់នឹងព្រះថេរៈថា "លោកម្ចាស់ដ៏ចម្រើន អម្បាញ់មិញនេះ ខ្ញុំព្រះករុណាបានឃើញស្ត្រីម្នាក់នៅទីនេះ ឥឡូវនេះ ស្ត្រីនោះទៅទីណា?" ។

ព្រះថេរៈទូលថា "អាត្មាភាពមិនឃើញទេ មហាបពិត្រ" ។ ព្រះរាជាក៏ត្រាស់ទៀតថា "អម្បាញ់មិញនេះ ខ្ញុំព្រះករុណាឃើញស្ត្រីម្នាក់ឈរនៅខាងក្រោយលោកម្ចាស់" ព្រះថេរៈក៏ទូលថា "អាត្មា មិនឃើញទេ មហាបពិត្រ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា "រឿងនេះយ៉ាងណាហ្ន៎" លុះទ្រង់មានព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់ត្រាស់ថា "សូមលោកម្ចាស់និមន្តចេញអំពីទីនេះសិន" កាលព្រះថេរៈចេញអំពីទីនោះ ទៅឈរនៅខាងមុខកុដិ ស្ត្រីនោះក៏បានឈរនៅខាងក្រោយព្រះថេរៈទៀត ។ ព្រះរាជាទតឃើញស្ត្រីនោះហើយ ទើបស្តេចឡើងទៅជាន់ខាងលើទៀត ។

សូម្បីព្រះរាជាទ្រង់រកមើលស្ត្រីនោះគ្រប់ទីកន្លែង ក៏មិនបានឃើញ ទើបត្រាស់សួរព្រះថេរៈដដែលទៀតថា "ស្ត្រីនោះនៅទីណា លោកម្ចាស់?" ។

ព្រះថេរៈ. បពិត្រមហារាជ អាត្មាភាពមិនឃើញស្ត្រីនោះទេ ។

ព្រះរាជា. សូមលោកម្ចាស់ ប្រោសប្រាប់ចុះ អម្បាញ់មិញនេះ ខ្ញុំព្រះករុណាបានឃើញស្ត្រីនោះ ឈរនៅខាងក្រោយលោកម្ចាស់ ។

ព្រះថេរ. ថ្វាយព្រះពរមហាបពិត្រ សូម្បីមហាជន ក៏បាននិយាយថា មានស្ត្រីម្នាក់ដើរតាមក្រោយអាត្មាដែរ តែអាត្មាមិនបានឃើញស្ត្រីនោះឡើយ ។

## ព្រះរាជាទ្រង់សន្និដ្ឋានថាជារូបស្រមោល

ព្រះរាជាទ្រង់សន្និដ្ឋានថា នុ៎ះពិតជារូបស្រមោល ហើយត្រាស់នឹងព្រះថេរៈម្ដងទៀតថា "លោកម្ចាស់ សូមលោកម្ចាស់និមន្តចុះទៅខាងក្រោមកុដិ" កាលព្រះថេរៈចុះទៅឈរនៅខាងក្រោមកុដិ ក៏បានទតឃើញស្ត្រីនោះឈរនៅខាងក្រោយព្រះថេរៈនោះទៀត លុះស្ដេចឡើងទៅខាងលើ ក៏មិនឃើញ ។ ព្រះរាជាសួរព្រះថេរៈម្ដងទៀត កាលព្រះថេរៈពោលថា "អាត្មាមិនឃើញ" ក៏ទ្រង់សន្និដ្ឋានបានថា "នុ៎ះជារូបស្រមោលដោយពិត" ទើបបានត្រាស់នឹងព្រះថេរៈថា "លោកម្ចាស់ កាលបើសេចក្ដីសៅហ្មងបែបនេះ ជាប់តាមក្រោយលោកម្ចាស់យ៉ាងនេះ ជនដទៃណាៗ ក៏គេមិនប្រគេនភិក្ខាដល់លោកម្ចាស់ដែរ ដូច្នេះសូមលោកម្ចាស់និមន្តទៅកាន់ព្រះរាជវាំងរបស់ខ្ញុំព្រះករុណាជានិច្ចចុះ ខ្ញុំព្រះករុណានឹងទំនុកបម្រុងលោកម្ចាស់ដោយបច្ច័យ ៤" ទ្រង់និមន្តព្រះថេរៈដូច្នេះហើយ ក៏ចៀសចេញទៅ ។

ភិក្ខុទាំងឡាយ លើកទោសថា "អ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរមើលនូវកិរិយាដ៏លាមករបស់ព្រះរាជាចុះ កាលពួកយើងទូលថា "សូមព្រះអង្គ

ទ្រង់បណ្តេញភិក្ខុនោះចេញចាកវិហារទៅ មិនបណ្តេញភិក្ខុនោះចេញពីវិហារ ត្រឡប់ជានិមន្តភិក្ខុនោះដោយបច្ច័យ ៤ ហើយយាងត្រឡប់" ។ ភិក្ខុទាំងឡាយក៏ពោលនឹងព្រះថេរៈនោះថា "នែបុគ្គលទ្រុស្តសីល ឥឡូវនេះ ព្រះរាជាក្លាយទៅជាមនុស្សអាក្រក់ហើយ" សូម្បីព្រះថេរៈនោះ កាលពីមុនមិនអាចពោលនូវពាក្យអ្វីៗ នឹងភិក្ខុទាំងឡាយបាន តែឥឡូវនេះ ក៏ពោលតបភ្លាមៗ ថា "ពួកលោកជាអ្នកទ្រុស្តសីល ពួកលោកជាមនុស្សអាក្រក់ ពួកលោកនាំស្រីដើរតាម" ។

ភិក្ខុទាំងនោះ ទៅក្រាបទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះកោណ្ឌធាន ត្រូវពួកខ្ញុំព្រះអង្គពោលហើយ ត្រឡប់ជាជេរពួកខ្ញុំព្រះអង្គដោយប្រការផ្សេងៗ ថា "ពួកលោកក៏ជាអ្នកទ្រុស្តសីលជាដើម" ។

## ព្រះសាស្តាទ្រង់សាកសួរទាំងពីរខាង

ព្រះសាស្តា ត្រាស់ឲ្យហៅព្រះកោណ្ឌធាននោះមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុ អ្នកបានពោលយ៉ាងនោះពិតមែនឬ?" ។

ព្រះថេរៈក្រាបទូលថា "ពិតមែន ព្រះអង្គ" ។

ព្រះសាស្តា. ព្រោះហេតុអ្វី ទើបអ្នកពោលដូច្នោះ ។

ព្រះថេរៈ. ព្រោះភិក្ខុទាំងនោះចោទខ្ញុំព្រះអង្គថា ជាអ្នកទ្រុស្តសីល ។

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុអ្វី ទើបអ្នកទាំងឡាយចោទភិក្ខុនេះដូច្នេះ ។

ពួកភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គឃើញស្ត្រីម្នាក់ដើរតាម

ក្រោយភិក្ខុនេះ ទើបពួកខ្ញុំព្រះអង្គពោលដូច្នោះ ។

ព្រះសាស្តា. ភិក្ខុទាំងនេះឃើញស្ត្រីម្នាក់ ដើរជាមួយនឹងអ្នក ទើបបាន ពោលដូច្នោះ ចំណែកខ្លួនអ្នកមិនបានឃើញឡើយ ហេតុអ្វី ទើបអ្នកពោលនឹង ភិក្ខុទាំងនេះ (យ៉ាងនេះ) ។ ផលនេះ កើតឡើង ព្រោះអាស្រ័យទិដ្ឋិដ៏លាមក របស់អ្នកក្នុងកាលមុនមិនមែនឬ ហេតុអ្វី ឥឡូវនេះ ទើបអ្នកនៅប្រកាន់ទិដ្ឋិ លាមកនោះទៀត? ។

ពួកភិក្ខុទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុនេះបានធ្វើកម្មដូច ម្តេចខ្លះក្នុងកាលមុន?" ។

គ្រានោះ ព្រះសាស្តាត្រាស់បុព្វកម្មរបស់លោក ឲ្យភិក្ខុទាំងនោះស្តាប់ ហើយមានព្រះពុទ្ធដីកាថា "ម្នាលភិក្ខុ អ្នកអាស្រ័យកម្មដ៏លាមកនេះ ទើបបាន ដល់នូវប្រការដ៏ប្លែកយ៉ាងនេះ ឥឡូវនេះ អ្នកនៅប្រកាន់ទិដ្ឋិដ៏លាមកបែបនោះ ទៀត មិនសមគួរឡើយ អ្នកកុំពោលពាក្យអ្វីៗ នឹងភិក្ខុទាំងឡាយទៀត អ្នក ចូរជាអ្នកមិនមានសំឡេងដូចគាំង ដែលគេកាត់កណ្តាប់មាត់ហើយ កាលធ្វើ យ៉ាងនោះ អ្នកនឹងបានសម្រេចនូវព្រះនិព្វាន" ដូច្នេះហើយ កាលនឹងទ្រង់បន្ត អនុសន្ធិដើម្បីសម្តែងធម៌ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖

៤.មាវោច ផរុសំ កញ្ចិ វុត្តា បដិវទេយ្យុ តំ
ទុក្ខា ហិ សារម្ភកថា បដិទណ្ឌា ផុសេយ្យុ តំ
សចេ នេរេសិ អត្តានំ កំសោ ឧបហតោ យថា

ឯស បត្តោសិ និព្វានំ    សារម្ភោ តេ ន វិជ្ជតិ ។

អ្នកកុំនិយាយពាក្យអាក្រក់ នឹងអ្នកណាមួយឡើយ ជនទាំង ឡាយ ដែលអ្នកស្តីថាឲ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថា ការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឲ្យកើត ទុក្ខ ការតស៊ូទាំងឡាយគប្បីប៉ះពាល់នូវអ្នក ។ បើអ្នកធ្វើខ្លួន មិនឲ្យញាប់ញ័រ ដូចគោងដែលចៀរមាត់ចេញហើយ (រមែង មិនលាន់ឮសូរ) ដូច្នោះ អ្នកនុ៎ះ ជាបុគ្គលដល់នូវព្រះនិព្វាន ការប្រណាំងប្រជែង មិនមានដល់អ្នក ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **កញ្ចិ** (នឹងនរណាៗ) សេចក្តីថា កុំពោល ពាក្យអាក្រក់នឹងនរណាៗ សូម្បីតែម្នាក់ ។

បទថា **វុត្តា** (ត្រូវអ្នកថាហើយ) សេចក្តីថា ជនពួកដទៃកាលត្រូវអ្នក ពោលថា "ពួកអ្នកជាបុគ្គលទ្រុស្តសីល" គប្បីពោលតបមករកអ្នកវិញ ។

បទថា **សារម្ភកថា** (ពាក្យប្រណាំងប្រជែង) ឈ្មោះថា ការពោលពាក្យ ប្រណាំងប្រជែងគ្នា ជាហេតុនាំឲ្យកើតទុក្ខ ។

បទថា **បដិទណ្ឌា** (ការធ្វើអាក្រក់តប) សេចក្តីថា កាលអ្នកប្រហារ អ្នកដទៃដោយអាជ្ញាទាំងឡាយ មានអាជ្ញាផ្លូវកាយជាដើម អាជ្ញានឹងធ្លាក់មក លើខ្លួនរបស់អ្នកវិញ ។

បទថា **សចេ នេរេសិ** (បើអ្នកញុំាងខ្លួនមិនឲ្យញាប់ញ័រ) សេចក្ដីថា បើអ្នកអាចធ្វើខ្លួនមិនឲ្យញាប់ញ័របានសោត ។

បទថា **កំសោ ឧបហតោ យថា** (ដូចគោំងត្រូវចៀរមាត់) សេចក្ដីថា ដូចគោំងដែលគេចៀរមាត់ចេញ ទុកតែផ្ទៃ ។ ពិតណាស់ គោំងដូច្នោះ សូម្បីបុគ្គលវាយដោយដៃ ជើង ឬដំបង យ៉ាងណា ក៏មិនលាន់ឮដែរ ។

បទថា **ឯស បត្តោសិ** (អ្នកនឹងជាអ្នកដល់) សេចក្ដីថា បើអ្នកអាចធ្វើខ្លួនឲ្យទៅជាបុគ្គលបែបនោះបាន អ្នកបំពេញបដិបទានេះហើយ ជាអ្នកមិនប្រមាទ ក្នុងពេលនេះ ឈ្មោះថា សម្រេចព្រះនិព្វាន ។

បទថា **សារម្ភោ តេ ន វិជ្ជតិ (ការប្រណាំងប្រជែង រមែងមិនមានដល់អ្នក)** សេចក្ដីថា បើដូច្នោះ សូម្បីការប្រណាំងប្រជែងគ្នា មានការពោលធ្វើឲ្យក្រៃលែងជាលក្ខណៈជាដើមយ៉ាងនេះថា "លោកជាបុគ្គលទ្រុស្តសីល" ជា "មនុស្សអាក្រក់" ដូច្នេះ រមែងមិនមានដល់អ្នកឡើយ ។

លុះចប់ព្រះធម៌ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ សូម្បីព្រះកោណ្ឌធានត្ថេរ តាំងនៅក្នុងឱវាទដែលព្រះសាស្ដាប្រទានហើយ ក៏បានសម្រេចព្រះអរហត្តផល ក្នុងកាលតមកមិនយូរប៉ុន្មាន លោកក៏បានហោះឡើងទៅកាន់អាកាស ចាប់ស្លាកជាលើកដំបូងបានមុនភិក្ខុទាំងឡាយ ដោយប្រកាដូច្នេះឯង ។

ចប់ រឿងព្រះកោណ្ឌធានត្ថេរ

# ៥. រឿងឧបោសថកម្ម

ព្រះសាស្តា កាលប្រថាប់នៅក្នុងបុព្វារាម ទ្រង់ប្រារព្ធឧបោសថកម្ម របស់ឧបាសិកាទាំងឡាយ មាននាងវិសាខាជាដើម ត្រាស់ព្រះធម្មទេសនានេះ ថា **យថា ទណ្ឌេន គោបាលោ (គង្វាលគោ រមែងកៀងគោទាំងឡាយទៅ កាន់ទីគោចរ ដោយដំបងយ៉ាងណា)** ជាដើម ។

## ស្ត្រីរក្សាឧបោសថប្រាថ្នាផលផ្សេងៗ គ្នា

ដូចបានស្តាប់មក ក្នុងថ្ងៃឧបោសថមួយ ស្ត្រីប្រមាណ ៥០០ រូប នៅ ក្នុងនគរសាវត្ថី ជាអ្នករក្សាឧបោសថ បានទៅកាន់វិហារ ។ នាងវិសាខាចូល ទៅរកស្ត្រីចាស់ៗ ក្នុងចំណោមស្ត្រីទាំង ៥០០ នោះ ហើយសួរថា "ម្នាលនាង ទាំងឡាយ ពួកនាងរក្សាឧបោសថដើម្បីអ្វី?" កាលស្ត្រីចាស់ៗ ទាំងនោះប្រាប់ ថា "ពួកខ្ញុំប្រាថ្នាទិព្វសម្បត្តិ ទើបរក្សាឧបោសថ" នាងក៏សួរពួកស្ត្រីកណ្តាលៗ ពួកស្ត្រីទាំងនោះប្រាប់ថា "ពួកខ្ញុំរក្សាឧបោសថ ព្រោះចង់ផុតចាកការនៅដោយ ស្ត្រីរួមប្តី" សួរពួកស្រីក្រមុំៗ ពួកស្រីក្រមុំៗ ទាំងនោះប្រាប់ថា "ពួកខ្ញុំរក្សា ឧបោសថ ព្រោះចង់បានបុត្រប្រុសក្នុងគភ៌ដំបូង" សួរពួកស្រីជំទង់ ស្រីទាំង នោះប្រាប់ថា "ពួកខ្ញុំរក្សាឧបោសថ ព្រោះចង់បានទៅកាន់ត្រកូលប្តីក្នុងវ័យ ក្មេង" (នាងវិសាខា) បានស្តាប់ពាក្យរបស់ស្ត្រីទាំងនោះហើយ ក៏នាំទៅកាន់ សម្នាក់ព្រះសាស្តា ក្រាបទូលសេចក្តីប្រាថ្នារបស់ស្ត្រីទាំងនោះ តាមលំដាប់ ។

## សព្វសត្វត្រូវបញ្ជូនទៅជាបណ្ដើរ ។

*ព្រះសាស្ដា ទ្រង់ស្ដាប់នូវពាក្យនោះហើយ ត្រាស់ថា "វិសាខា ធម្មតាសភាវធម៌ទាំងឡាយមានជាតិជាដើមរបស់សត្វទាំងនេះ ដូចជានាយគោបាលដែលមានរំពាត់ក្នុងដៃ ជាតិបញ្ជូនសព្វសត្វទៅកាន់ជរា ជរាបញ្ជូនទៅកាន់សម្នាក់ព្យាធិ ព្យាធិបញ្ជូនទៅកាន់សម្នាក់មរណៈ មរណៈរមែងកាត់ផ្ដាច់ជីវិតដូចជាបុគ្គលកាត់ដើមឈើដោយពូថៅ សូម្បីដូច្នោះក៏ដោយ ពួកសត្វក៏នៅតែមិនប្រាថ្នាវិវដ្ដៈ (ព្រះនិព្វាន) ពេញចិត្តតែវដ្ដៈប៉ុណ្ណោះ" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ បានត្រាស់ព្រះគាថានេះថា ៖*

*៥.យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ*
*ឯវំ ជរា ច មច្ចុ ច អាយុំ បាជេន្តិ បាណិនំ ។*

*គង្វាលគោ រមែងកៀងគោទៅកាន់ទីគោចរ ដោយអាជ្ញា*
*ដូចម្ដេចមិញ ជរា និងមច្ចុ តែងកៀងអាយុរបស់សត្វទាំង*
*ឡាយ ដូច្នោះឯង ។*

## អធិប្បាយគាថា

*បណ្ដាបទទាំងនោះ បទថា **បាជេតិ** (ដេញ) សេចក្ដីថា គង្វាលគោដែលឈ្លាស ហាមគោទាំងឡាយ ដែលចូលទៅកាន់ចន្លោះភ្លឺស្រែដោយដំបងវាយដោយដំបងនោះៗ ឯង នាំទៅ ឈ្មោះថា រមែងកៀង (គោទាំងឡាយ) ទៅកាន់ទីគោចរ ដែលមានស្មៅ និងទឹករកបានងាយ ។*

បទថា *អាយុំ បាជេន្តិ (រមែងកៀងនូវអាយុ)* សេចក្តីថា រមែងកាត់ផ្តាច់នូវជីវិតិន្ទ្រីយ៍ គឺ រមែងញ៉ាំងជីវិតិន្ទ្រីយ៍ឲ្យអស់ទៅ ។ ក្នុងព្រះគាថានេះ មានពាក្យឧបមាឧបមេយ្យដូច្នេះថា ជរា និងមច្ចុ ប្រៀបដូចនាយគោបាល ជីវិ-តិន្ទ្រីយ៍ប្រៀបដូចហ្វូងគោ មរណៈ ប្រៀបដូចទីគោចរ ។ បណ្តាសភាវធម៌ទាំងនោះ ជាតិបញ្ជូនជីវិតិន្ទ្រីយ៍របស់សត្វទៅកាន់សម្នាក់ជរា ជរាបញ្ជូនទៅកាន់សម្នាក់ព្យាធិ ព្យាធិបញ្ជូនទៅកាន់សម្នាក់មរណៈ មរណៈកាត់ផ្តាច់នូវជីវិតិន្ទ្រីយ៍របស់សត្វទាំងឡាយ ដូចជាបុគ្គលកាត់ដើមឈើដោយពូថៅ ដូច្នោះ ។

លុះចប់ព្រះធម៌ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នោះឯង ។

ចប់ រឿងឧទោសថកម្ម

# ៦. រឿងអជគរប្រេត

*ព្រះសាស្តា កាលប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធអជគរប្រេត បាន ត្រាស់ព្រះធម៌ទេសនានេះថា* ***អថ បាបានិ កម្មានិ (ដែលបុគ្គលពាល ធ្វើកម្ម ទាំងឡាយដ៏លាមក)*** *ជាដើម ។*

ព្រះមហាមោគ្គល្លានឃើញប្រេតត្រូវភ្លើងឆេះ

*សេចក្តីពិស្តារថា ក្នុងសម័យមួយ ព្រះមហាមោគ្គល្លានត្ថេរ និងព្រះ លក្ខណត្ថេរចុះអំពីភ្នំគិជ្ឈកូដ បានឃើញសត្វឈ្មោះ អជគរប្រេត មានអត្តភាព ប្រមាណ ២៥ យោជន៍ ដោយទិព្វចក្ខុ ។ អណ្តាតភ្លើងតាំងឡើងអំពីក្បាល របស់ប្រេតនោះឆេះរាលដល់កន្ទុយ តាំងឡើងអំពីកន្ទុយឆេះរាលដល់ក្បាល តាំងឡើងអំពីខាងទាំងពីរប្រជុំចុះនៅត្រង់កណ្តាលខ្លួន ។ ព្រះថេរៈលុះឃើញ ប្រេតនោះហើយ ក៏បានធ្វើការញញឹមឲ្យប្រាកដ ព្រះលក្ខណត្ថេរបានសួរនូវ ហេតុនៃការញញឹមនោះ ព្រះមហាមោគ្គល្លានក៏ប្រាប់ថា "ម្នាលអ្នកមានអាយុ កាលនេះ មិនមែនជាកាលសមគួរនឹងព្យាករណ៍បញ្ហានេះទេ ចាំសួរខ្ញុំក្នុងសម្នាក់ ព្រះសាស្តាចុះ" ហើយត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ។ កាលទៅកាន់ សម្នាក់ព្រះសាស្តា ព្រះលក្ខណត្ថេរសួរ ក៏ឆ្លើយប្រាប់ថា "អ្នកមានអាយុ ខ្ញុំ បានឃើញប្រេតមួយក្នុងទីនោះ អត្តភាពរបស់វា មានសភាពបែបនេះ លុះខ្ញុំ ឃើញហើយ ក៏ធ្វើនូវការញញឹមឲ្យប្រាកដ ដោយគិតថា "អត្តភាពបែបនេះយើង*

មិនធ្លាប់បានឃើញឡើយ" ។

## ព្រះសាស្តាក៏ទ្រង់ឃើញប្រេតនោះ

ព្រះសាស្តា ត្រាស់ពាក្យជាដើមថា "ម្នាលភិក្ខុទាំងឡាយ សាវករបស់តថាគត ជាអ្នកមានចក្ខុហ្ន៎" ទ្រង់ទទួលពាក្យរបស់ព្រះថេរៈហើយ ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ប្រេតនុ៎ះ សូម្បីតថាគតក៏បានឃើញដែរ តថាគតបានឃើញប្រេតនោះ តាំងពីតថាគតនៅពោធិមណ្ឌលម៉្លេះ ប៉ុន្តែតថាគតមិនបានសម្តែងឡើង ព្រោះគិតថា ពួកជនណា មិនជឿពាក្យរបស់តថាគត ការមិនជឿរបស់ជនទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ឥឡូវនេះតថាគត បានមោគ្គល្លានជាសាក្សីហើយ ទើបបានពោល" ភិក្ខុទាំងឡាយក៏ទូលសួរបុព្វកម្មរបស់ប្រេតនោះ ព្រះសាស្តាក៏ទ្រង់ព្យាករណ៍ដូចតទៅនេះថា ៖

## បុព្វកម្មរបស់អជគរប្រេត

បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ មានសេដ្ឋីម្នាក់ឈ្មោះសុមង្គល ក្រាលឥដ្ឋមាសលើផែនដី ឲ្យសាងវិហារក្នុងទីប្រមាណ ២០ ឧសភៈដោយទ្រព្យប៉ុណ្ណោះហើយ ក៏ឲ្យធ្វើការឆ្លងដោយទ្រព្យប៉ុណ្ណោះដែរ ។ ថ្ងៃមួយលោកសេដ្ឋីទៅកាន់សម្នាក់ព្រះសាស្តាអំពីព្រលឹម បានឃើញចោរម្នាក់ ដេកទទូរសំពត់កាសាយៈតាំងពីចុងជើងរហូតដល់ក្បាល ទាំងមានជើងប្រឡាក់ភក់ក្នុងសាលាមួយ ជិតទ្វារព្រះនគរ បានពោលដូច្នេះថា "បុគ្គលនេះ មានជើង

ប្រឡាក់កក់ ទំនងជាមនុស្សដើរយប់ហើយមើលទៅ" ។

ចោរបើកមុខឃើញសេដ្ឋីហើយ ក៏គិតក្នុងចិត្តថា "លើកទុកសិនចុះ យើងនឹងដឹងនូវអំពើដែលយើងគប្បីធ្វើដល់បុគ្គលនេះ" ហើយក៏ចងអាឃាតទុកក្រោយមក បានទៅដុតស្រែរបស់លោកសេដ្ឋីអស់ ៧ ដង កាត់ជើងគោទាំងឡាយក្នុងក្រោល ៧ ដង ដុតផ្ទះ ៧ ដង ។ ចោរនោះមិនអាចញ៉ាំងសេចក្ដីក្រោធឲ្យរលត់ទៅ ដោយអំពើមានប្រមាណប៉ុណ្ណោះបាន ទើបធ្វើនូវសេចក្ដីស្និទ្ធស្នាលដោយការៈជាមិត្រនឹងបុរសដែលជាកូនឈ្នួលរបស់លោកសេដ្ឋី រួចសួរថា "អ្វីជាទីស្រឡាញ់នៃចៅហ្វាយរបស់អ្នកជាងគេ" បានដឹងថា វត្ថុដែលជាទីស្រឡាញ់បំផុតនៃលោកសេដ្ឋី ក្រៅពីព្រះគន្ធកុដិ មិនមាន បានគិតថា "ល្អហើយ យើងនឹងដុតព្រះគន្ធកុដិ ដើម្បីរំលត់កំហឹងរបស់យើង" កាលព្រះសាស្ដាស្ដេចយាងទៅបិណ្ឌបាត បានវាយបំបែកក្អមទឹកសោយ និងទឹកប្រើប្រាស់ រួចហើយ ឆួលភ្លើងដុតព្រះគន្ធកុដិ ។

សេដ្ឋីបានឮដំណឹងថា "ព្រះគន្ធកុដិត្រូវភ្លើងឆេះ ក៏ដើរទៅមើល លុះទៅដល់ ភ្លើងក៏ឆេះព្រះគន្ធកុដិអស់ គាត់សម្លឹងមើលព្រះគន្ធកុដិដែលត្រូវភ្លើងឆេះនោះ ដោយមិនបានញ៉ាំងទោមនស្សឲ្យកើតឡើង សូម្បីតែប៉ុនរោមទ្រាយឡើយ បែរជាទះដៃខ្លាំងៗ ទៅវិញ ។ ខណៈនោះ ប្រជាជនដែលឈរនៅក្បែរនោះ សួរលោកសេដ្ឋីថា "លោកសេដ្ឋី ហេតុអ្វីទើបលោកទះដៃ នៅពេលដែលព្រះគន្ធកុដិ ដែលលោកចំណាយទ្រព្យប៉ុណ្ណោះកសាង ត្រូវភ្លើងឆេះ" សេដ្ឋីឆ្លើយ

ថា "ពុកម៉ែទាំងឡាយ ខ្ញុំធ្វើកម្មប្រមាណប៉ុណ្ណេះ ឈ្មោះថា បានកប់ទ្រព្យទុកក្នុងព្រះសាសនាដែលមិនជាសាធារណៈដល់អន្តរាយទាំងឡាយ មានភ្លើងជាដើម ទើបខ្ញុំមានចិត្តរីករាយ ទះដៃ ដោយគិតថា យើងនឹងបានចំណាយទ្រព្យប្រមាណប៉ុណ្ណេះ សាងព្រះគន្ធកុដិថ្វាយព្រះសាស្តាទៀត" ។

សេដ្ឋីចំណាយទ្រព្យប្រមាណប៉ុណ្ណោះ សាងព្រះគន្ធកុដិ ថ្វាយចំពោះព្រះសាស្តាដែលមានភិក្ខុសង្ឃ ២ ម៉ឺនរូប ជាបរិវារម្តងទៀត ។

ចោរឃើញកិរិយានោះហើយ គិតថា "បើយើងមិនសម្លាប់សេដ្ឋីនេះទេ នឹងមិនអាចរំលត់កំហឹងបានទេ ណ្ហើយចុះ យើងនឹងសម្លាប់វា" លុះគិតដូច្នេះហើយ "ក៏សៀតកូនកាំបិតទុកក្នុងសំពត់ស្លៀក ដើរទៅកាន់វិហារអស់ ៧ ថ្ងៃ ប៉ុន្តែមិនបានឱកាស ។

ចំណែកមហាសេដ្ឋី ថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន អស់ ៧ ថ្ងៃ ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន បុរសម្នាក់ដុតស្រែរបស់ខ្ញុំព្រះអង្គ ៧ ដង កាប់ជើងគោក្នុងក្រោល ៧ ដង ដុតផ្ទះ ៧ ដង សូម្បីព្រះគន្ធកុដិក៏ប្រហែលជាបុគ្គលនោះដុតដែរហើយមើលទៅ ដូច្នេះ ខ្ញុំព្រះអង្គសូមឲ្យចំណែកបុណ្យដែលកើតអំពីការធ្វើទាននេះ ដល់អ្នកនោះមុនគេ" ។

ចោរបានឮពាក្យនោះហើយ គិតថា "យើងបានធ្វើកម្មដ៏ធ្ងន់ តែសេដ្ឋីនេះ មិនបានញ៉ាំងសេចក្តីក្រោធសូម្បីតែបន្តិចចំពោះយើង ដែលជាអ្នកធ្វើនូវ

កំហុសយ៉ាងនេះ (បែរជាឲ្យ) ចំណែកបុណ្យក្នុងទាននេះដល់យើងមុនគេទៀត ការដែលយើងគិតប្រទូស្តចំពោះសេដ្ឋីនេះ មិនសមគួរឡើយ បើយើងមិនញ៉ាំងសេដ្ឋីនេះឲ្យអត់ទោសឲ្យទេ ទេវទណ្ឌពិតជាធ្លាក់មកត្រូវក្បាលរបស់យើងមិនខាន" លុះគិតដូច្នេះហើយ ក៏ចូលទៅក្រាបនៅក្បែរជើងរបស់លោកសេដ្ឋី ហើយពោលថា "បពិត្រលោកសេដ្ឋី សូមលោកអត់នូវទោសនោះឲ្យខ្ញុំផងចុះ" កាលសេដ្ឋីពោលថា "មានរឿងអ្វី?" ក៏ប្រាប់ថា "លោកសេដ្ឋី ខ្ញុំបានធ្វើកម្មប៉ុណ្ណេះៗ សូមលោកអត់នូវទោសនោះដល់ខ្ញុំផង" ។ គ្រានោះ សេដ្ឋីសួរកម្មគ្រប់ៗ ប្រការនឹងគេនោះថា "អ្នកធ្វើកម្មនេះផង នេះផង ប្រមាណប៉ុណ្ណេះដល់យើងឬ?" កាលចោរទទួលសារភាពថា "ខ្ញុំធ្វើ" បានសួរតទៅទៀតថា "យើងមិនធ្លាប់ឃើញអ្នកទេ ហេតុអ្វីទើបអ្នកក្រោធនឹងយើង ហើយធ្វើនូវអំពើយ៉ាងនេះចំពោះយើង" ។

គេញ៉ាំងសេដ្ឋីឲ្យរឭកឃើញនូវពាក្យដែលសេដ្ឋីពោល ក្នុងកាលដែលខ្លួនចេញអំពីព្រះនគរ ហើយបានប្រាប់ "សេដ្ឋីថា ខ្ញុំខឹងនឹងលោក ព្រោះហេតុនេះឯង" ។

សេដ្ឋីរឭកដល់ពាក្យដែលខ្លួនពោលបានហើយ ឲ្យចោរអត់ទោសឲ្យដោយពាក្យថា "ម្នាលអ្នកដ៏ចម្រើន យើងបាននិយាយពាក្យនោះពិតមែន អ្នកចូរអត់នូវទោសនោះដល់ខ្ញុំផង" ហើយពោលថា "ក្រោកឡើងចុះ យើងអត់ទោសឲ្យអ្នក ចូរអ្នកទៅចុះ" ។

ចោរ. លោកសេដ្ឋី បើលោកអត់ទោសឲ្យខ្ញុំហើយ សូមលោកធ្វើខ្ញុំ

ព្រមទាំងបុត្រ និងភរិយាឲ្យជាទាសៈនៅក្នុងផ្ទះរបស់លោកផងចុះ ។

សេដ្ឋី. នែអ្នក យើងពោលពាក្យប៉ុណ្ណឹង អ្នកបានធ្វើនូវអំពើបែបនេះ យើងមិនអាចនឹងពោលនូវពាក្យអ្វីៗ ជាមួយអ្នក នៅក្នុងផ្ទះរបស់យើងបានឡើយ កិច្ចដែលអ្នកនៅក្នុងផ្ទះរបស់យើងមិនមាន យើងអត់ទោសឲ្យអ្នកឯងហើយ អ្នកឯងទៅវិញចុះ ។

ចោរធ្វើកម្មនោះហើយ លុះអស់អាយុ កើតក្នុងអវីចិនរក ឆេះក្នុងអវីចីនោះអស់កាលដ៏យូរ ក្នុងសម័យនៃព្រះសម្មាសម្ពុទ្ធយើងនេះ កើតជាអជគរ-ប្រេត ត្រូវភ្លើងឆេះនៅត្រង់ភ្នំគិជ្ឈកូដ ដោយវិបាកនៃកម្មដ៏សេស ។

ព្រះសាស្តា ត្រាស់បុព្វកម្មរបស់ប្រេតនោះហើយ ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាបុគ្គលពាលធ្វើកម្មដ៏លាមកហើយ រមែងមិនដឹង ប៉ុន្តែក្រោយមក ត្រូវកម្មដែលខ្លួនធ្វើហើយដុត ដូចជាភ្លើងឆេះព្រៃ" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

៦.អថ  បាបានិ  កម្មានិ  ករំ ពាលោ ន ពុជ្ឈតិ
សេហិ កម្មេហិ ទុម្មេធោ  អគ្គិទឌ្ឍោវ តប្បតិ ។

បុគ្គលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់ រមែងមិនភ្ញាក់ខ្លួន
លុះកាលជាខាងក្រោយ ទើបក្តៅក្រហាយដោយសារកម្មរបស់
ខ្លួន ដូចត្រូវភ្លើងឆេះ ។

## អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា* ***អថ បាបានិ*** *(ដ៏លាមក) សេចក្តីថា ជនពាល មិនត្រឹមតែធ្វើបាបទាំងឡាយដោយអំណាចនៃសេចក្តីក្រោធប៉ុណ្ណោះទេ សូម្បីកាលធ្វើក៏មិនដឹងខ្លួន តែកាលធ្វើបាប មិនមែនមិនដឹងថា យើងធ្វើបាបទេ ព្រះមានព្រះភាគត្រាស់ថា មិនដឹង ព្រោះមិនដឹងថា ផលរបស់កម្មនេះមានសភាពបែបនេះ ។ បទថា* ***សេហិ*** *(ដែលជារបស់ខ្លួន) សេចក្តីថា ព្រោះកម្មដែលជារបស់ខ្លួននោះ ។ បទថា* ***ទុម្មេធោ*** *(មានបញ្ញាថោកទាប) សេចក្តីថា បុគ្គលមិនមានប្រាជ្ញា កើតក្នុងនរករមែងក្តៅក្រហាយ ដូចត្រូវភ្លើងឆេះ ។*

*លុះចប់ព្រះធម៌ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិជាដើម ដូច្នេះឯង ។*

ចប់ រឿងអជគរប្រេត

# ៧. រឿងព្រះមហាមោគ្គល្លាន

ព្រះសាស្តា កាលប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះមហាមោគ្គ-ល្លានត្ថេរ ត្រាស់ព្រះធម៌ទេសនានេះថា **យោ ទណ្ឌេន អទណ្ឌេសុ** (បុគ្គលណាប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយដែលមិនមានអាជ្ញា) ជាដើម ។

## ពួកតិត្ថិយគិតរកឧបាយសម្លាប់ព្រះថេរៈ

សេចក្តីពិស្តារថា សម័យមួយ ពួកតិត្ថិយប្រជុំប្រឹក្សាគ្នាថា “អ្នកមានអាយុអ្នកទាំងឡាយ មានដឹងទេថា ហេតុអ្វីលាភសក្ការៈកើតឡើងច្រើនដល់ព្រះសមណគោតម” តិត្ថិយមួយពួកពោលថា “ពួកខ្ញុំមិនជ្រាបទេ ចំណែកពួកលោកដឹងឬ” តិត្ថិយដែលដឹងរឿង ក៏នាំគ្នាឆ្លើយថា “ពួកខ្ញុំដឹង លាភ និងសក្ការៈកើតដល់ព្រះសមណគោតម ព្រោះអាស្រ័យព្រះថេរៈ មួយរូបឈ្មោះមហា-មោគ្គល្លាន ព្រោះព្រះថេរៈនោះ ទៅកាន់ទេវលោក សួរនូវកម្មដែលពួកទេវតាធ្វើហើយ ក៏ត្រឡប់មកប្រាប់ពួកមនុស្សថា ពួកទេវតាធ្វើកម្មឈ្មោះនេះ រមែងបាននូវសម្បត្តិបែបនេះ សូម្បីទៅនរក ក៏សួរនូវកម្មរបស់ពួកសត្វដែលកើតក្នុងនរក ហើយត្រឡប់មកប្រាប់ពួកមនុស្សថា ពួកនេរយិកសត្វធ្វើកម្មឈ្មោះនេះ រមែងសោយទុក្ខបែបនេះ ពួកមនុស្សបានស្តាប់ពាក្យរបស់ព្រះថេរៈនោះហើយ តែងនាំលាភសក្ការៈជាច្រើនទៅប្រគេន បើពួកយើងអាចសម្លាប់ព្រះថេរៈនោះបាន លាភសក្ការៈនោះ នឹងកើតដល់ពួកយើង” ។

## តិរ្ថិយជួលពួកចោរឱ្យសម្លាប់ព្រះថេរៈ

*តិរ្ថិយ៍ទាំងនោះព្រមព្រៀងគ្នាថា "ឧបាយនេះប្រើការបាន" គ្រប់គ្នាជាអ្នកមានធនុះតែមួយ សម្រេចគ្នាថា "ពួកយើងនឹងធ្វើកម្មយ៉ាងណានីមួយដើម្បីសម្លាប់ព្រះថេរៈនោះឲ្យបាន" ហើយបបួលពួកឧបដ្ឋាករបស់ខ្លួន បានទ្រព្យ ១ ពាន់កហាបណៈ ឲ្យហៅពួកចោរដែលជាអ្នកស៊ីឈ្នួលសម្លាប់មនុស្សមកហើយបង្គាប់ថា "ព្រះថេរៈឈ្មោះមហាមោគ្គល្លាន នៅឯកាឡសិលា ពួកអ្នកទៅកាន់ទីនោះ ហើយចូរសម្លាប់ព្រះថេរៈនោះចុះ" លុះពោលដូច្នេះហើយ ក៏ឲ្យកហាបណៈទៅពួកចោរទាំងនោះ ។ ពួកចោរយល់ព្រម ព្រោះសេចក្ដីលោភក្នុងទ្រព្យ តាំងចិត្តថា "ពួកយើងនឹងសម្លាប់ព្រះថេរៈ រួចហើយទៅឡោមព័ទ្ធទីនៅរបស់ព្រះមហាមោគ្គល្លាន ។ ព្រះថេរៈជ្រាបថា "ខ្លួនត្រូវពួកចោរឡោម-ព័ទ្ធហើយ" ទើបគេចអំពីកុដិចេញតាមប្រហោងកូនសោ ។ ក្នុងថ្ងៃនោះ ពួកចោរមិនបានឃើញព្រះថេរៈ ថ្ងៃស្អែកឡើងបានមកឡោមព័ទ្ធម្ដងទៀត ។ ព្រះថេរៈជ្រាបហើយ "ក៏ទម្លាយមណ្ឌលហោជាងហោះទៅកាន់អាកាស ។ កាលបើដូច្នោះ ក្នុងខែដំបូងក្ដី ក្នុងខែកណ្ដាលក្ដី ពួកតិរ្ថិយ៍ក៏មិនអាចចាប់ព្រះថេរៈបាន ប៉ុន្តែមកដល់ខែចុងក្រោយ ព្រះថេរៈជ្រាបភាវៈ គឺ កម្មដែលខ្លួនធ្វើទុកហើយ ទើបមិនបានគេចខ្លួន ។*

*ពួកចោរទៅចាប់ព្រះថេៈបានហើយ វាយដំឆ្អឹងទាំងឡាយរបស់លោកឲ្យបែកខ្ទេចខ្ទី ជាកំណាត់តូចៗ ប៉ុនគ្រាប់អង្ករបាក់ ។ គ្រានោះ ពួកចោរបោះ*

លោកទៅលើគុម្ពឈើមួយកន្ទែង ដោយសម្គាល់ថា "ស្លាប់ហើយ" ក៏នាំគ្នាគេចចេញទៅ ។

## ព្រះថេរៈផ្គុំធាតុហើយ នៅគាល់ព្រះសាស្តា

ព្រះថេរៈគិតថា "យើងទៅគាល់ព្រះសាស្តាសិន សឹមបរិនិព្វាន" ហើយបានផ្គុំអត្តភាពដោយគ្រឿងផ្គុំ គឺ ឈាន ធ្វើឲ្យមាំហើយ ហោះទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងបរិនិព្វាន" ។

ព្រះមានព្រះភាគ. ម្នាលមោគ្គល្លាន អ្នកនឹងបរិនិព្វានឬ? ។

ព្រះថេរៈ. ព្រះករុណា ព្រះអង្គ ។

ព្រះមានព្រះភាគ. អ្នកនឹងបរិនិព្វាននៅទីណា? ។

ព្រះថេរៈ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅកាន់កាឡសិលាប្រទេស ហើយបរិនិព្វាននៅទីនោះ ។

ព្រះមានព្រះភាគ. ម្នាលមោគ្គល្លាន បើដូច្នោះ អ្នកចូរសម្តែងធម៌ដល់តថាគតហើយសឹមទៅ ត្បិតថា ការឃើញសាវកដូចជាអ្នក របស់តថាគតមិនមានទៀតទេ ។ ព្រះថេរៈក្រាបទូលថា "ព្រះករុណាព្រះអង្គ" ហើយថ្វាយបង្គំព្រះសាស្តា ហោះឡើងទៅឰដ៏អាកាស សម្តែងឫទ្ធិ មានប្រការផ្សេងៗ ហើយសម្តែងធម៌ថ្វាយព្រះសម្មាសម្ពុទ្ធ ដូចកាលព្រះសារីបុត្រសម្តែងឫទ្ធិក្នុងថ្ងៃដែលបរិនិព្វាន ថ្វាយបង្គំព្រះសាស្តាហើយ ទៅកាន់ដងព្រៃជិតកាឡសិលាប្រទេស

បរិនិព្វានទៅទីនោះឯង ។ ពាក្យលិចឮថា ពួកចោរសម្លាប់ព្រះថេរៈហើយ ដូច្នេះ បានផ្សាយទៅកាន់ជម្ពូទ្វីបទាំងមូល ។

## ពួកចោរត្រូវចារបុរសចាប់ចាន

ព្រះបាទអជាតសត្តុ ទ្រង់បញ្ជូនចារបុរសទាំងឡាយទៅ ដើម្បីស្វែងរកពួកចោរទាំងនោះ ។ គាប់ជួនពេលដែលពួកចោរទាំងនោះ កំពុងផឹកស្រានៅក្នុងរោងសុរាមួយ ចោរម្នាក់បានទះខ្នងចោរម្នាក់ទៀតឲ្យដួលទៅនឹងដី ។ ចោរដែលត្រូវប្រហារនោះ គម្រាមចោរនោះ ហើយនិយាយថា "អើ អាចោរមាត់រឹង ដូចម្តេចបានជាឯងវាយអញ" ។

ចោរម្នាក់. អើ ម្នាលចោរកំណាច ព្រះមហាមោគ្គល្លាន ឯងជាអ្នកវាយមុនឬ? ។

ចោរម្នាក់ទៀត. ឯងមិនដឹងថា ព្រះមោគ្គល្លានត្រូវយើងវាយទេឬ? ។

កាលពួកចោរទាំងនោះ កំពុងតែពោលអួតអាងយ៉ាងនេះថា ព្រះមហា-មោគ្គល្លានត្រូវអញសម្លាប់ ចារបុរសទាំងនោះបានឮហើយ ក៏ចាប់ចោរទាំងនោះយកទៅថ្វាយព្រះរាជា ។ ព្រះរាជាទ្រង់មានព្រះរាជបញ្ជាឲ្យហៅពួកចោរទាំងនោះមក ហើយត្រាស់សួរថា "ពួកអ្នកសម្លាប់ព្រះថេរៈឬ" ។

ពួកចោរ. ព្រះករុណាថ្លៃវិសេស ។

ព្រះរាជា. នរណាប្រើពួកអ្នកឲ្យសម្លាប់ ។

ពួកចោរ. ពួកសមណៈអាក្រាត ។

ព្រះរាជា ទ្រង់ត្រាស់ឲ្យចាប់សមណៈអាក្រាត ប្រមាណ ៥០០ នាក់ មួយអន្លើដោយចោរ ៥០០ នាក់ ហើយត្រាស់ឲ្យជីករណ្តៅកប់ប្រមាណត្រឹមផ្ចិត ត្រង់ព្រះលានហ្លួង ត្រាស់ឲ្យយកចំបើងគ្រប ហើយត្រាស់ឲ្យដុតភ្លើងដុត ។ ចំណែកព្រះរាជាលុះទ្រង់ជ្រាបថា អចេលក៍ និងចោរទាំងនោះ ត្រូវភ្លើងឆេះ ហើយទើបត្រាស់ឲ្យភ្ជួរដោយនង្គ័លដែក ធ្វើសមណៈអាក្រាត និងចោរទាំងនោះឲ្យជាកំណាត់តូច-ធំ ហើយត្រាស់ឲ្យយកចោរ ៤ នាក់ ដោតដោយឈើអណ្តោត ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា "គួរឲ្យសង្វេគ ព្រះមហាមោគ្គល្លាន មរណភាពមិនសមគួរដល់ខ្លួន" ។

ព្រះសាស្តាស្តេចយាងមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ប្រជុំគ្នាដោយកថាអ្វី" កាលភិក្ខុទាំងនោះក្រាបទូលថា "ដោយកថាឈ្មោះនេះព្រះអង្គ" ដូច្នេះហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មោគ្គ-ល្លានដល់នូវមរណភាពមិនសមគួរនឹងអត្តភាពនេះ ក៏ពិតមែនហើយ តែសមគួរដល់កម្មដែលខ្លួនបានធ្វើទុកហើយក្នុងកាលមុន" កាលភិក្ខុទាំងឡាយទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ចុះបុព្វកម្មរបស់លោកដូចម្តេច" បានត្រាស់អតីតនិទានយ៉ាងពិស្តារ ដូចតទៅនេះ ៖

## បុព្វកម្មរបស់ព្រះមហាមោគ្គល្លាន

មានសេចក្តីតំណាលថា ក្នុងអតីតកាល មានកុលបុត្រម្នាក់ជាអ្នកក្រុង

ពារាណសី ធ្វើកិច្ចគ្រប់យ៉ាង មានបុកអង្ករ និងដាំបាយជាដើមដោយខ្លួនឯង ប្រតិបត្តិមាតាបិតាដោយយកចិត្តទុកដាក់ ។ ក្រោយមក មាតាបិតារបស់កុល-បុត្រនិយាយនឹងកូនរបស់ខ្លួនថា "បា! កូនឯងតែម្នាក់ឯងប៉ុណ្ណោះ ធ្វើការងារទាំងក្នុងផ្ទះផង ការងារក្នុងព្រៃផង ដូច្នោះ កូនឯងហត់ខ្លាំងណាស់ មាតាបិតានឹងនាំស្រីក្រមុំម្នាក់មកឲ្យកូន" ត្រូវកូនហាមថា "លោកឪពុក អ្នកម្តាយ ខ្ញុំមិនត្រូវការស្រីក្រមុំបែបនេះទេ ខ្ញុំនឹងបម្រើអ្នកទាំងពីរដោយដៃរបស់ខ្ញុំ ដរាបដល់អ្នកទាំងពីរអស់ជីវិត" ចំណែកមាតាបិតារបស់កុលបុត្រនោះអង្វរកូនញយៗ ហើយក៏នាំស្រីក្រមុំមកឲ្យកូន ។

ស្ត្រីនោះបម្រើម្តាយក្មេក និងឪពុកក្មេក បានពីរបីថ្ងៃប៉ុណ្ណោះ ក្រោយមក មិនចង់ឃើញម្តាយក្មេក និងឪពុកក្មេក ដែលជាជនចាស់ជរានោះឡើយ បានប្រាប់ប្តីថា "ខ្ញុំមិនអាចរស់នៅជាមួយមាតាបិតារបស់អ្នកបានទេ" លុះប្រាប់ប្តីដូច្នោះហើយ ក៏តិះដៀលដោយប្រការផ្សេងៗ កាលស្វាមីនោះមិនជឿពាក្យរបស់ខ្លួន ពេលដែលស្វាមីចេញទៅខាងក្រៅ ក៏កាន់យកចំរៀកសំបកក្រចៅ និងកំណាត់ឈើទាំងឡាយ និងពពុះបបរទៅរោយរាយក្នុងទីនោះៗ ឲ្យស្រកេកស្រកាកពេញផ្ទះ បុរសដែលជាស្វាមីមកពីធ្វើការខាងក្រៅវិញ ឃើញដូច្នោះក៏សួរថា "នេះជាអំពើរបស់នរណា" ក៏ប្រាប់ថា "នេះជាអំពើរបស់មនុស្សកញ្ចាស់ខ្វាក់ទាំងពីរនាក់នេះ កញ្ចាស់ទាំងពីរនាក់នេះ ធ្វើផ្ទះគ្រប់កន្លែងឲ្យស្មោកគ្រោក ខ្ញុំមិនអាចរស់នៅទីតែមួយជាមួយកញ្ចាស់ទាំងពីរនេះបានទេ" ។

កាលស្ត្រីនោះ ត្អូញត្អែរដូច្នោះរឿយៗ សត្វអ្នកមានបារមីបានបំពេញហើយ សូម្បីមានសភាពបែបនោះក៏ដោយ ក៏នៅបែកចិត្តពីមាតាបិតាបាន ។ ប្តីនិយាយថា "ណ្ហើយចុះ បងនឹងដឹងនូវកម្មដែលគប្បីធ្វើដល់លោកទាំងពីរ" លុះពោលដូច្នោះហើយ ក៏អញ្ជើញមាតាបិតាឲ្យបរិភោគហើយបបួលថា "ពុកនិងម៉ែ ពួកញាតិនៅឯណោះ ចង់ឲ្យពុក និងម៉ែទៅលេងផ្ទះគេ ខ្ញុំនឹងនាំពុក និងម៉ែទៅកាន់ទីនោះ" លុះពោលដូច្នេះហើយ ក៏លើកគាត់ទាំងពីរឡើងកាន់យានតូច ហើយបររទេះចេញទៅ លុះទៅដល់កណ្តាលដងព្រៃ ក៏ពោលកុហកថា "លោកពុក សូមកាន់ខ្សែឲ្យជាប់ គោនឹងដើរទៅដោយសញ្ញាជន្ទញ ទីនេះមានពួកចោរនៅ ខ្ញុំនឹងចុះទៅ" ហើយប្រគល់ខ្សែឲ្យបិតាកាន់ ចុះទៅហើយ បានធ្វើនូវសំឡេងសន្ធាប់នៃចោរទាំងឡាយ ដែលលាក់ខ្លួននៅក្នុងព្រៃ ។

មាតាបិតាបានឮសំឡេងនោះហើយ ក៏សម្គាល់ថា ពួកចោរចាំស្ទាក់ ទើបប្រាប់ថា "កូនអើយ! ម៉ែពុកជាមនុស្សចាស់ហើយ កូនចូររក្សាខ្លួនឲ្យផុតអំពីភ័យចុះ" ។ កាលបុត្រនោះធ្វើសំឡេងដូចចោរ វាយសំពងមាតាបិតាដែលកំពុងស្រែកដូច្នេះឲ្យស្លាប់ ហើយយកទៅបោះចោលក្នុងព្រៃ រួចត្រឡប់មកវិញ ។

## ផលរបស់កម្មអាក្រក់តាមឱ្យផល

ព្រះសាស្តា លុះទ្រង់ត្រាស់នូវបុព្វកម្មរបស់ព្រះមោគ្គល្លានហើយ ទ្រង់មានព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានធ្វើកម្មប៉ុណ្ណេះ ឆេះក្នុង

នរកអស់សែនកប្ប ដោយសេសសល់នៃវិបាក ទើបត្រូវពួកចោរវាយកំទេចឆ្អឹង ដល់នូវមរណភាពយ៉ាងនេះ អស់ ១០០ អត្តភាពហើយ មោគ្គល្លានដល់នូវមរណៈយ៉ាងនេះ សមគួរដល់កម្មរបស់ខ្លួន ឯពួកតិរ្ថិយ៍ ៥០០ និងចោរ ៥០០ នាក់ ប្រទូស្តចំពោះបុត្ររបស់តថាគត ដែលជាអ្នកមិនប្រទូស្តតប ក៏សមគួរដល់កម្មរបស់ពួកគេដែរ ព្រោះថា "បុគ្គលប្រទូស្តចំពោះបុគ្គលដែលមិនប្រទូស្តតប រមែងដល់នូវសេចក្ដីវិនាស ដោយហេតុ ១០ ប្រការ ដោយពិត ៗ លុះទ្រង់ត្រាស់ដូច្នេះហើយ ក៏ទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ ទ្រង់ទើបបានភាសិតព្រះគាថាទាំងនេះថា ៖

៧.យោ ទណ្ឌេន អទណ្ឌេសុ អប្បទុដ្ឋេសុ ទុស្សតិ
ទសន្នមញ្ញតរំ ឋានំ ខិប្បមេវ និគច្ឆតិ
វេទនំ ផរុសំ ជានឹ សរីរស្ស វ ភេទនំ
គរុកំ វាបិ អាពាធំ ចិត្តក្ខេបំ វ បាបុណេ
រាជតោ វា ឧបសគ្គំ អព្ភក្ខានំ វ ទារុណំ
បរិក្ខយំ វ ញាតីនំ ភោគានំ វ បភង្គុណំ
អថវស្ស អគារានិ អគ្គិ ឌហតិ បាវកោ
កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតិ ៗ

បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃ

សេចក្តីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺ គប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡកចិត្ត (ឆ្កួត) ១ រឹបជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់នូវពួកញាតិរលីង ១ ពុកផុយភោគសម្បត្តិ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា *អទណ្ឌេសុ* (អ្នកមិនមានអាជ្ញា) សេចក្តីថា ព្រះខីណាស្រពទាំងឡាយ ជាបុគ្គលវៀរចាកអាជ្ញា មានអាជ្ញាផ្លូវកាយជាដើម ។

បទថា *អប្បទុដ្ឋេសុ* (ក្នុងលោកដែលមិនប្រទូស្តទាំងឡាយ) សេចក្តីថា អ្នកមិនមានកំហុសចំពោះជនដទៃ ឬចំពោះខ្លួនឯង ។

បទថា *ទសន្នមញ្ញតរំ ឋានំ* (ឋានៈ ១០ យ៉ាងណាមួយ) សេចក្តីថា បណ្តាហេតុនៃសេចក្តីទុក្ខ ១០ យ៉ាងណាមួយ ។

បទថា *វេទនំ* (វេទនា) បានដល់ វេទនាដ៏ខ្លាំងដោយរោគ មានក្នុងរោគក្នុងក្បាលជាដើម ។

បទថា *ជានឹ* (ការវិនាសទ្រព្យ) បានដល់ សេចក្តីវិនាសទ្រព្យដែលខ្លួនរកបានមកដោយលំបាក ។

បទថា **ភេទនំ (ការបែកធ្លាយ)** បានដល់ ការបែកធ្លាយនៃសរីរៈ មានការកាត់ដៃជាដើម ។

បទថា **គរុកំ (ធ្ងន់)** បានដល់ អាពាធជាទម្ងន់ ដែលផ្សេងដោយរោគ មានរោគខ្វាក់ភ្នែកម្ខាង ខ្វិន ក្រញែង និងរោគឃ្លង់ជាដើម ។

បទថា **ចិត្តក្ខេបំ (សេចក្តីរាយមាយនៃចិត្ត)** បានដល់ ភាពជាបុគ្គលឆ្កួត ។

បទថា **ឧបសគ្គំ (ឧបសគ្គ)** បានដល់ ការរឹបអូសពីព្រះរាជា មានការបន្ថយយស និងដកហូតយកនូវតំណែង មានតំណែងជាសេនាបតីជាដើម ។

បទថា **អព្ភក្ខានំ (ការពោលបង្កាច់)** សេចក្តីថា ពាក្យមួលបង្កាច់ដ៏អាក្រក់ មានសភាពបែបនេះថា កម្មមានការកាត់ទីតជាដើមនេះក្តី កម្ម គឺ ការប្រព្រឹត្តខុសចំពោះព្រះរាជាក្តី អ្នកឯងបានធ្វើហើយ សូម្បីខ្លួនមិនធ្លាប់បានឃើញ មិនធ្លាប់បានឮ និងមិនធ្លាប់បានគិតក៏ដោយ ។

បទថា **បរិក្ខយំ វ ញាតីនំ (ការបែកបាក់ពពួកញាតិ)** បានដល់ ការអស់រលីងនៃញាតិសន្តាន ដែលជាអ្នកអាចជាទីពឹងពំនាក់របស់ខ្លួន ។

បទថា **បភង្គុណំ (សេចក្តីវិនាស)** គឺ ការវិនាស បានដល់ ការរលួយខូចទៅ ។ ក៏ស្រូវក្នុងផ្ទះរបស់បុគ្គលនោះ រមែងក្លាយជារបស់ស្អុយរលួយ មាសរមែងក្លាយជាធ្យូង កែវមុក្តារមែងក្លាយជាគ្រាប់កប្បាស កហាបណៈក៏រមែងក្លាយជាបំណែកនៃអំបែងជាដើម សត្វជើង ២-៤ ដល់ភាពជាសត្វខ្វាក់

*ជាដើម ។*

*បទថា **អគ្គិ ឌហតិ** (ភ្លើងព្រៃរមែងឆេះ) សេចក្ដីថា ក្នុងមួយឆ្នាំ បើភ្លើងដទៃណាបំផ្លាញមិនមាន ភ្លើង គឺ អសនីបាត រមែងធ្លាក់ចុះ ដុតបំផ្លាញ ២-៣ ដង ឬភ្លើងព្រៃតាំងឡើងតាមធម្មតា ឆេះដោយពិត ។*

*បទថា **និរយំ** (នរក) ជាដើម សេចក្ដីថា ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ថា "បុគ្គលនោះរមែងចូលដល់នរក" ក៏ដើម្បីសម្ដែងឋានៈដែលការកបុគ្គលដល់ឋានៈទាំង ១០ យ៉ាងនេះ ណានីមួយក្នុងបច្ចុប្បន្ននេះ និងក្នុងសម្បរាយភពទៀត ។*

*លុះចប់ព្រះធម៌ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។*

ចប់ រឿងព្រះមហាមោគ្គល្លានត្ថេរ

# ៨. រឿងភិក្ខុអ្នកមានភណ្ឌៈច្រើន

*ព្រះសាស្តា កាលព្រះអង្គប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកមានភណ្ឌៈច្រើន ត្រាស់ព្រះធម្មទេសនានេះថា ន នគ្គចរិយា (ការប្រព្រឹត្តជាបុគ្គលអាក្រាត ក៏ធ្វើសត្វឲ្យបរិសុទ្ធមិនបាន)* ជាដើម ។

កុដុម្ពិកត្រៀមគ្រឿងប្រើប្រាស់មុនបួស

*បានឮថា កុដុម្ពិកអ្នកក្រុងសាវត្ថីម្នាក់ កាលភរិយារបស់ខ្លួនធ្វើកាលកិរិយាទៅ ក៏ចេញទៅបួស ។ ប៉ុន្តែមុននឹងគាត់បួស គាត់ប្រើឲ្យគេសាងបរិវេណផង រោងភ្លើងផង បន្ទប់ដាក់ភណ្ឌៈផង រួចហើយប្រើឲ្យគេយកវត្ថុទាំងឡាយ មានទឹកដោះថ្លា និងប្រេងជាដើម ដាក់ឲ្យពេញក្នុងបន្ទប់ ទើបចេញទៅបួស ។ លុះបួសហើយ ប្រើឲ្យគេហៅពួកទាសៈរបស់ខ្លួនមកចម្អិនអាហារតាមដែលខ្លួនពេញចិត្ត ទើបបរិភោគ ។ លោកជាអ្នកមានភណ្ឌៈច្រើន និងមានបរិក្ខារច្រើន សំពត់សម្រាប់ស្លៀក និងសំពត់សម្រាប់ដណ្តប់ក្នុងពេលយប់មានមួយឈុតផ្សេង ពេលថ្ងៃមានមួយឈុតផ្សេង ហើយលោកមានប្រក្រតីនៅក្នុងវិហារខាងចុងគេបង្អស់ ។*

*ថ្ងៃមួយ កាលភិក្ខុនោះកំពុងហាលចីវរ និងកម្រាលទាំងឡាយ ភិក្ខុទាំងឡាយដើរទៅកាន់ទី ដែលជាទីត្រាច់ទៅក្នុងសេនាសនៈ ឃើញហើយសួរថា "អ្នកមានអាយុ ចីវរ និងកម្រាលដេកទាំងនេះ ជារបស់អ្នកណា" លោក*

ប្រាប់ថា "របស់ខ្ញុំករុណា លោកម្ចាស់" (ពួកភិក្ខុ)ពោលថា "អ្នកមានអាយុ ព្រះមានព្រះភាគទ្រង់អនុញ្ញាតចីវរត្រឹមតែ ៣ ចំណែកលោកបួសក្នុងសាសនារបស់ព្រះពុទ្ធ ដែលជាអ្នកមានសេចក្តីប្រាថ្នាតិចដូច្នេះ ម្តេចបានជាលោកមានបរិក្ខារច្រើនយ៉ាងនេះ" លុះស្តីបន្ទោសយ៉ាងនេះហើយ ក៏នាំភិក្ខុនោះទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុរូបនេះជាអ្នកមានភណ្ឌៈច្រើនដ៏លើសលប់ ។ ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា "ម្នាលភិក្ខុ យ៉ាងនោះពិតមែនឬ" ភិក្ខុនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពិតមែន" ទើបត្រាស់ថា "ម្នាលភិក្ខុ តថាគតសម្តែងធម៌ដើម្បីភាពជាអ្នកប្រាថ្នាតិច ហេតុអ្វីបែរជាអ្នកមានភណ្ឌៈច្រើនយ៉ាងនេះ" ភិក្ខុនោះក្រោធខឹង ដោយហេតុត្រឹមតែប៉ុណ្ណោះឯង ហើយគិតថា "ឥឡូវនេះ យើងនឹងត្រាច់ទៅដោយទំនងនេះ" ដោះចីវរចេញ ទុកតែស្បង់មួយប៉ុណ្ណោះ ឈរនៅកណ្តាលបរិស័ទ ។

## ព្រះសាស្តាញុំាងភិក្ខុនោះឱ្យមានហិរិ និងឱត្តប្បៈ

គ្រានោះ ព្រះសាស្តាទ្រង់គាំទ្រភិក្ខុរូបនោះ ដោយព្រះតម្រាស់ថា "ម្នាលភិក្ខុ កាលមុនអ្នកជាអ្នកស្វែងរកហិរិ និងឱត្តប្បៈ សូម្បីខ្លួនជាអារក្សទឹកអស់ ១២ ឆ្នាំ មិនមែនឬ?" ព្រោះហេតុអ្វី ឥឡូវនេះអ្នកបួសក្នុងព្រះពុទ្ធសាសនាដែលគួរគោរពយ៉ាងនេះហើយ បែរជាដោះចីវរចេញ លះបង់ហិរិ និងឱត្តប្បៈ ឈរនៅកណ្តាលបរិស័ទទាំង ៤ ទៅវិញ?" ។

ភិក្ខុនោះស្តាប់ព្រះតម្រាស់របស់ព្រះសាស្តាហើយ ញ៉ាំងហិរិ និងឱត្តប្បៈឲ្យកើតឡើង ដណ្តប់ចីវរនោះវិញ ថ្វាយបង្គំព្រះសាស្តា ហើយអង្គុយក្នុងទីដ៏សមគួរមួយ ។

ភិក្ខុទាំងឡាយ ទូលអារាធនាព្រះមានព្រះភាគ ដើម្បីយាងព្រះអង្គទ្រង់ប្រកាសសេចក្តីនោះ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់នាំអតីតនិទានមក ត្រាស់ថា ៖

## បុព្វកម្មរបស់ភិក្ខុនោះ

បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វបដិសន្ធិក្នុងព្រះគភ៌ព្រះអគ្គមហេសីនៃព្រះបាទក្រុងពារាណសី ។ ក្នុងថ្ងៃថ្វាយព្រះនាមព្រះពោធិសត្វនោះ ញាតិទាំងឡាយ បានថ្វាយព្រះនាមព្រះអង្គថា **មហិសាសកុមារ** ។ ព្រះកនិដ្ឋភាតារបស់ព្រះអង្គ មានព្រះនាមថា **ចន្ទកុមារ** ។ កាលព្រះមាតារបស់ព្រះរាជកុមារទាំងពីរនោះ អស់ព្រះជន្មហើយ ព្រះរាជាទ្រង់ស្ថាបនាស្ត្រីដទៃ ទុកក្នុងតំណែងជាព្រះអគ្គមហេសីជំនួស ។

ព្រះអគ្គមហេសីថ្មីនោះ ប្រសូតព្រះរាជឱរសមួយព្រះអង្គ ។ ញាតិទាំងឡាយ បានថ្វាយព្រះនាមព្រះរាជឱរសនោះថា **សុរិយកុមារ** ។ ព្រះរាជាទតឃើញសុរិយកុមារនោះហើយ ទ្រង់រីករាយព្រះទ័យយ៉ាងខ្លាំង ហើយត្រាស់ព្រះរាជទានពរថា យើងឲ្យពរដល់បុត្ររបស់នាង ។ ចំណែកព្រះទេវីក្រាបទូលថា "ខ្ញុំម្ចាស់នឹងទទួលយកក្នុងពេលដែលខ្ញុំម្ចាស់ត្រូវការ" ក្នុងកាលដែលព្រះ

រាជឱរសបចម្រើនវ័យហើយ ក៏ទូលព្រះរាជាថា “បពិត្រព្រះសម្មតិទេព ព្រះអង្គបានព្រះរាជទានពរឲ្យខ្ញុំម្ចាស់ ក្នុងវេលាបុត្ររបស់ខ្ញុំម្ចាស់ប្រសូត ដូច្នេះ សូមព្រះអង្គប្រោសព្រះរាជទានរាជសម្បត្តិដល់បុត្ររបស់ខ្ញុំម្ចាស់ចុះ” ។ ព្រះរាជាទ្រង់ហាមថា “បុត្រទាំងពីររបស់យើង រុងរឿងដូចគំនរភ្លើង យើងមិនអាចឲ្យរាជសម្បត្តិដល់សុរិយកុមារនោះបានទេ” ប៉ុន្តែទ្រង់ឃើញព្រះនាងអង្វរពេក ក៏ទ្រង់ព្រះតម្រិះថា “នាងនេះគប្បីធ្វើសេចក្តីអន្តរាយដល់បុត្ររបស់យើង” ទើបទ្រង់ត្រាស់ឲ្យហៅព្រះរាជបុត្រទាំងពីរមក ហើយត្រាស់ថា “ម្នាលបុត្រទាំងពីរ បិតាបានឲ្យពរក្នុងពេលសុរិយកុមារប្រសូត ឥឡូវនេះ មាតារបស់គេទូលសូមរាជសម្បត្តិដើម្បីឲ្យសុរិយកុមារនោះ បិតាមិនចង់ឲ្យដល់គេឡើយ មាតារបស់គេអាចធ្វើសេចក្តីអន្តរាយដល់បុត្រទាំងពីរ ដូច្នេះ ចូរបុត្រទៅនៅក្នុងព្រៃសិនចុះ ចាំអត់អំពីបិតា សឹមបុត្រត្រឡប់មកយករាជសម្បត្តិ” លុះមានព្រះរាជឱង្ការដូច្នេះហើយ ទ្រង់ក៏បញ្ជូនព្រះរាជកុមារទៅកាន់ព្រៃ ។

សុរិយកុមារ លេងនៅព្រះលានហ្លួង ឃើញព្រះរាជកុមារទាំងពីរនោះថ្វាយបង្គំព្រះរាជបិតា ហើយយាងចុះចាកប្រាសាទ ជ្រាបហេតុនោះហើយ ក៏ចេញទៅជាមួយព្រះរាជកុមារទាំងពីរអង្គនោះដែរ ។

បណ្តាព្រះរាជកុមារទាំងបីអង្គនោះ ក្នុងកាលដែលព្រះអង្គស្តេចចូលដល់ហិមវន្តប្រទេស ព្រះពោធិសត្វគេចចេញអំពីផ្លូវ គង់ក្បែរគល់ឈើមួយដើម ហើយត្រាស់ទៅកាន់សុរិយកុមារថា “នែប្អូន ប្អូនឯងចូរទៅកាន់ស្រះនោះ

ហើយ ចូរខ្ជីតផង និងផឹកផង ហើយកាច់ស្លឹកឈូកដាក់ទឹកនាំយកមកឲ្យបង ទាំងពីរផង ។ ក៏ឯស្រះនោះជាស្រះដែលអារក្សទឹក[១]មួយ បានការអនុញ្ញាត អំពីសម្នាក់នៃស្ដេចវេស្សវ័ណ ។ ស្ដេចវេស្សវ័ណត្រាស់ទៅកាន់អារក្សទឹក នោះថា "វៀរជនដែលដឹងនូវទេវធម៌ប៉ុណ្ណោះ ជនដទៃចុះកាន់ស្រះនេះ អ្នក អាចទំពាស៊ីនូវជនទាំងនោះបាន" ។ តាំងពីពេលនោះមក អារក្សទឹកនោះ តែង សួរនូវទេវធម៌ចំពោះអ្នកដែលចុះកាន់ស្រះនោះជានិច្ច ហើយតែងទំពាស៊ីអ្នក ដែលមិនដឹងនូវទេវធម៌ ។

ចំណែកសុរិយកុមារ មិនទាន់ពិចារណាស្រះនោះឲ្យបានដឹងជាក់ច្បាស់ ក៏ចុះទៅ ត្រូវអារក្សទឹកនោះសួរថា "អ្នកចេះទេវធម៌ឬទេ" ក៏ឆ្លើយថា "ព្រះច័ន្ទ និងព្រះអាទិត្យ ឈ្មោះថាទេវធម៌" ។ គ្រានោះ អារក្សទឹកពោលនឹងសុរិយ កុមារនោះថា "អ្នកមិនដឹងនូវទេវធម៌ទេ" ហើយក៏ទាញចុះកាន់ទឹករក្សាទុកនៅ ក្នុងភពរបស់ខ្លួន ។

ចំណែកព្រះពោធិសត្វ រង់ចាំសុរិយកុមារនោះយូរពេក មិនឃើញមក ក៏ប្រើឲ្យចន្ទកុមារទៅទៀត សូម្បីចន្ទកុមារនោះ ក៏ត្រូវអារក្សទឹកនោះសួរថា "អ្នកដឹងទេវធម៌ឬទេ" ក៏ឆ្លើយថា "ទិសទាំង ៤ ឈ្មោះថាទេវធម៌" អារក្សទឹក ក៏ចាប់ចន្ទកុមារយកទៅទុកនៅក្នុងភពរបស់ខ្លួនទៀត ។

---

១-ពាក្យថា អារក្សទឹក (ដាយក្ខ) ជាឈ្មោះរបស់អាសុរអាក្រក់ មាននិស្ស័យកាច ពេញចិត្តដើរ តាមព្រៃ ទម្លាយនូវពិធី ឬស៊ីមនុស្ស ។

ព្រះពោធិសត្វ កាលមិនឃើញចន្ទកុមារត្រឡប់មកវិញ ក៏គិតថា "ពិតជាមានអន្តរាយ" ទើបស្ដេចយាងទៅដោយព្រះអង្គឯង ឃើញស្នាមជើងចុះ ប៉ុន្តែមិនឃើញស្នាមជើងឡើង ក៏ជ្រាបថា "ស្រះនេះពិតជាមានអារក្សទឹកហួងហែង ក៏ហូតព្រះខ័នចេញមកកាន់ ឈរ (ក្បែរមាត់ស្រះ) ។ អារក្សទឹកនោះឃើញព្រះពោធិសត្វមិនព្រមចុះទឹក ក៏ក្លែងភេទជាអ្នកដើរព្រៃ មកពោលជាមួយថា "បុរសដ៏ចម្រើន អ្នកធ្វើដំណើរផ្លូវឆ្ងាយ ហត់នឿយហើយ ម្ដេចក៏មិនចុះកាន់ស្រះនេះ ងូត ផឹក ទំពាស៊ីក្រអៅឈូក ប្រដាប់ផ្កាឈើ" ។

ព្រះពោធិសត្វ គ្រាន់តែឃើញបុរសនោះភ្លាម ក៏ទ្រង់ជ្រាបថា "បុរសនេះជាយក្ខ" ទើបត្រាស់ទៅកាន់បុរសនោះថា "អ្នកចាប់យកប្អូនប្រុសទាំងពីររបស់យើងឬ"

យក្ខ. អើ ខ្ញុំចាប់ប្អូនប្រុសរបស់អ្នកមែន ។

ពោធិសត្វ. ចាប់ធ្វើអ្វី ។

យក្ខ. ខ្ញុំមានសិទ្ធិចាប់ អ្នកដែលចុះកាន់ស្រះនេះ ។

ពោធិសត្វ. អ្នកចាប់មនុស្សគ្រប់គ្នាឬ ។

យក្ខ. វៀរលែងអ្នកដែលដឹងនូវទេវធម៌ មនុស្សដ៏សេសខ្ញុំចាប់ទាំងអស់ ។

ពោធិសត្វ. ចុះអ្នកត្រូវការទេវធម៌ឬ ។

យក្ខ. ខ្ញុំត្រូវការ ។

ពោធិសត្វ. ខ្ញុំនឹងសម្ដែងឲ្យអ្នកស្ដាប់ ។

យក្ខ. បើដូច្នោះ សូមអ្នកពោលមកចុះ ។

ពោធិសត្វ. ខ្ញុំមានខ្លួនសៅហ្មង មិនអាចសម្ដែងបានទេ ។

យក្ខឲ្យព្រះពោធិសត្វងូតទឹក ផឹកទឹកដែលគួរផឹក ហើយអញ្ជើញឲ្យឡើងកាន់បល្ល័ង្កកណ្ដាលមណ្ឌលដែលខ្លួនតាក់តែងទុក រួចហើយអង្គុយទៀបបាទមូលនៃព្រះពោធិសត្វ ។ គ្រានោះ ព្រះពោធិសត្វប្រាប់យក្ខនោះថា "ចូរអ្នកស្ដាប់ដោយគោរពចុះ ហើយត្រាស់ព្រះគាថានេះថា ៖

អ្នកប្រាជ្ញ ហៅអ្នកដែលដល់ព្រមដោយហិរិ និងឱត្តប្បៈ អ្នក
មានចិត្តតាំងមាំក្នុងធម៌ស ជាអ្នកស្ងប់ស្ងៀម ជាសប្បុរស ថា
ជាអ្នកទ្រទ្រង់ទេវធម៌ក្នុងលោក ។

យក្ខស្ដាប់ធម្មទេសនានេះហើយជ្រះថ្លា ពោលទៅកាន់ព្រះពោធិសត្វថា "បពិត្របណ្ឌិត ខ្ញុំជ្រះថ្លាចំពោះលោក ខ្ញុំនឹងឲ្យប្អូនប្រុសម្នាក់ទៅលោក លោកត្រូវការប្អូនប្រុសរូបណា?" ។

ពោធិសត្វ. ខ្ញុំត្រូវការប្អូនពៅ ចូរនាំប្អូនប្រុសពៅមកឲ្យខ្ញុំ ។

យក្ខ. បពិត្របណ្ឌិត លោកគ្រាន់តែដឹងនូវទេវធម៌ប៉ុណ្ណោះ តែលោកមិនបានប្រព្រឹត្តក្នុងទេវធម៌ទាំងនោះទេ ។

ពោធិសត្វ. ព្រោះហេតុអ្វី ? ។

យក្ខ. ព្រោះលោកឲ្យខ្ញុំនាំប្អូនប្រុសពៅ វៀរប្អូនប្រុសច្បងចេញ មិន

ឈ្មោះថា ធ្វើអបចាយនកម្មចំពោះរៀមច្បង ព្រោះហេតុនោះ ទើបខ្ញុំពោលយ៉ាងនេះ ។

ព្រះពោធិសត្វត្រាស់ថា "ម្នាលយក្ខ យើងដឹងទាំងទេវធម៌ ទាំងប្រព្រឹត្តក្នុងទេវធម៌នោះ ព្រោះថា ការដែលយើងចូលមកកាន់ព្រៃនេះ ព្រោះអាស្រ័យប្អូនប្រុសពៅនោះ ព្រោះថា មាតារបស់ប្អូនប្រុសនោះ បានទូលសូមរាជសម្បត្តិអំពីបិតារបស់យើងទាំងពីរ ដើម្បីប្រយោជន៍ដល់ប្អូនប្រុសនោះ ប៉ុន្តែព្រះបិតារបស់យើងទ្រង់មិនប្រទានឲ្យ ទ្រង់អនុញ្ញាតឲ្យពួកយើងមកនៅក្នុងព្រៃដើម្បីប្រយោជន៍ដល់ការរក្សាយើងទាំងពីរ កុមារនោះ ឃើញពួកយើងមកកាន់ព្រៃនេះ ក៏មកជាមួយពួកយើងដែរ កាលបើខ្ញុំពោលថា មានយក្ខនៅក្នុងព្រៃស៊ីប្អូនប្រុសពៅនោះ អ្នកណាៗ ក៏មិនជឿ ព្រោះហេតុនោះ ខ្ញុំខ្លាចការតិះដៀលអំពីសម្នាក់អ្នកដទៃ ទើបខ្ញុំត្រូវការប្អូនប្រុសពៅនោះតែម្នាក់ប៉ុណ្ណោះ" ។

យក្ខជ្រះថ្លាចំពោះព្រះពោធិសត្វហើយ ពោលសរសើរថា "សាធុ ៗ បណ្ឌិត អ្នកបានដឹងនូវទេវធម៌ ថែមទាំងបានប្រព្រឹត្តដោយល្អក្នុងទេវធម៌នោះទៀតផង ដូច្នោះ ខ្ញុំសូមប្រគល់ប្អូនប្រុសទាំងពីរឲ្យលោក" ។

លំដាប់នោះ ព្រះពោធិសត្វ ពណ៌នាទោសក្នុងភាវៈជាយក្ខហើយ ក៏ញ៉ាំងយក្ខនោះឲ្យតាំងនៅក្នុងសីល ៥ ព្រះពោធិសត្វនៅក្នុងព្រៃនោះ ដោយបានទទួលការរក្សាដ៏ល្អអំពីយក្ខនោះ កាលព្រះរាជបិតាសោយទិវង្គតហើយ ក៏នាំយក្ខទៅកាន់ក្រុងពារាណសី គ្រប់គ្រងរាជសម្បត្តិ ព្រះរាជទានតំណែងជា

ឧបរាជដល់ចន្ទកុមារ ព្រះរាជទានតំណែងសេនាបតីដល់សុរិយកុមារ ឲ្យគេសាងទីនៅក្នុងរមណីយដ្ឋានដល់យក្ខ ហើយទ្រង់បានធ្វើយក្ខនោះឲ្យដល់នូវភាពជាអ្នកប្រសើរដោយលាភ ។

## ព្រះសាស្តាទ្រង់ប្រជុំជាតក

ព្រះសាស្តា ទ្រង់នាំព្រះធម៌ទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា "អារក្សទឹកក្នុងកាលនោះ បានមកជាភិក្ខុអ្នកមានភណ្ឌៈច្រើននេះឯង សុរិយកុមារ បានមកជាព្រះអានន្ទ , ចន្ទកុមារ បានមកជាព្រះសារីបុត្រ មហិសាសកុមារ គឺ តថាគតនេះឯង ។

ព្រះសាស្តា លុះត្រាស់ជាតកយ៉ាងនេះហើយ ទើបត្រាស់ថា "ម្នាលភិក្ខុ កាលមុន អ្នកស្វែងរកនូវទេវធម៌ ដល់ព្រមដោយហិរិ និងឱត្តប្បៈ ត្រាច់ទៅដូច្នោះ ឥឡូវនេះ អ្នកប្រកាន់ដោយទំនងនេះ កណ្តាលបរិស័ទទាំង ៤ ពោលពាក្យនៅចំពោះមុខតថាគតថា "ខ្ញុំមានការប្រាថ្នាតិច" ឈ្មោះថា បានធ្វើកម្មមិនសមគួរ ព្រោះថា បុគ្គលដែលមានឈ្មោះថាជាសមណៈ មិនមែនដោយហេតុត្រឹមតែហាមសំពត់សាដកជាដើមទេ" លុះទ្រង់ត្រាស់ដូច្នោះហើយ ក៏ទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះធម្មទេសនានេះថា ៖

៨. ន នគ្គចរិយា ន ជដា ន បង្កា នានាសកា ថណ្ឌិលសាយិកា វា
រជោជល្លំ ឧក្កុដិកប្បធានំ សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ ។

ការប្រព្រឹត្តអាក្រាតកាយ ទុកសក់ ដេកលើកក់ មិនបរិភោគបាយ

*ដេកលើផែនដី ប្រឡាក់ខ្លួនដោយធូលី ព្យាយាមអង្គុយប្រហោង មិនជម្រះសត្វ ដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យបានទេ ។*

អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា **នានាសកា** កាត់បទជា **ន អនាសកា** សេចក្តីថា ការហាមឃាត់ ។ ការដេកលើផែនដី ឈ្មោះថា **ថណ្ឌិលសាយិកា** (ការដេកលើដី) ។ ធូលីដែលផ្អាប់នៅក្នុងសរីរៈ ដោយអាការ គឺ ដូចជាការលាបដោយភក់ ឈ្មោះថា **រជោជល្លំ** (កិរិយាទ្រទ្រង់ទុកនូវធុលី) ។ សេចក្តីព្យាយាមដែលបុគ្គលប្រារព្ធហើយ ដោយការៈជាអ្នកអង្គុយប្រហោង ឈ្មោះថា **ឧក្កុដិកប្បធានំ** (កិរិយាតាំងទុកនូវឥរិយាបថប្រហោង) ព្រះមានព្រះភាគត្រាស់អធិប្បាយពាក្យនេះថា "ក៏សត្វណាយល់ថា យើងនឹងបរិសុទ្ធ ពោលគឺការចេញចាកលោក ដោយការបដិបត្តិយ៉ាងនេះ" ហើយសមាទានប្រព្រឹត្តវត្តណាមួយ មានការប្រព្រឹត្តនូវភាពជាមនុស្សអាក្រាតជាដើមនុ៎ះ សត្វនោះឈ្មោះថា ញុំាងការឃើញខុសឲ្យចម្រើនផង ជាអ្នកមានចំណែកនៃការលំបាកផង ព្រោះថា វត្តទាំងនោះ ដែលសត្វសមាទានដោយល្អហើយ រមែងមិនញុំាងសត្វ ដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យ ដែលមានវត្ថុ ៨ ឲ្យស្អាតស្អំបានឡើយ ។*

*ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើននាក់បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ជាដើម ដូច្នេះឯង ។*

ចប់ រឿងភិក្ខុអ្នកមានភណ្ឌៈច្រើន

# ៩. រឿងសន្ដតិមហាមាត្យ

ព្រះសាស្ដា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធសន្តតិមហាមាត្យ ត្រាស់ព្រះធម្មទេសនានេះថា *អលង្កតោ ចេ បិ សមញ្ចរេយ្យ (បើបុគ្គលប្រដាប់ហើយ គប្បីប្រព្រឹត្តស្មើ)* ជាដើម ។

## ព្រះសាស្ដាទ្រង់ព្យាករណ៍សន្តតិមហាមាត្យ

សេចក្ដីពិស្ដារថា សម័យមួយ សន្ដតិមហាមាត្យនោះ បង្ក្រាបបច្ចន្ត-ជនបទរបស់ព្រះបាទបសេនទិកោសល ដែលបះបោរដោយពួកចោរឲ្យស្ងប់ ហើយត្រឡប់មកវិញ ។ គ្រានោះ ព្រះរាជាទ្រង់សព្វព្រះហឫទ័យ ព្រះរាជទានរាជសម្បត្តិឲ្យ ៧ ថ្ងៃ ដោយបានព្រះរាជទានស្ត្រីដែលប៉ិនប្រសព្វក្នុងការរាំ និងច្រៀងម្នាក់ដល់គាត់ទៀត ។ គាត់ជាអ្នកស្រវឹងសុរាអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ឡើងកាន់ដំរីដ៏ប្រសើរ ទៅកាន់កំពង់ទឹក ឃើញព្រះសាស្ដាកំពុងស្ដេចយាងបិណ្ឌបាតត្រង់ចន្លោះទ្វារ នៅលើដំរីដ៏ប្រសើរនោះឯង បានញ៉ាំងសីសៈឲ្យកម្រើក សម្ដែងការគោរពព្រះសាស្ដា ។

ព្រះសាស្ដាទ្រង់ធ្វើការញញឹមឲ្យប្រាកដ ព្រះអានន្ទទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុ ជាបច្ច័យ ដែលធ្វើឲ្យព្រះអង្គទ្រង់ធ្វើការញញឹមឲ្យប្រាកដ" កាលទ្រង់ត្រាស់ប្រាប់ហេតុនៃការញញឹម ក៏ត្រាស់ថា "អានន្ទ អ្នកចូរមើលសន្ដតិមហាមាត្យនេះចុះ ថ្ងៃនេះមកកាន់សម្នាក់តថាគត នៅមានទាំង

គ្រឿងប្រដាប់ជាប់នឹងខ្លួន ហើយសម្រេចព្រះអរហត្តក្នុងវេលាចប់គាថា ដែលប្រកបដោយបទ ៤ រួចហើយអង្គុយលើអាកាសកម្ពស់ ៧ ដើមត្នោត បរិនិព្វានទៅទីនោះឯង" ។

មហាជនបានស្តាប់ព្រះតម្រាស់របស់ព្រះសាស្តា កាលដែលព្រះអង្គទ្រង់ត្រាស់ជាមួយនឹងព្រះអានន្ទ ។

បណ្តាជនទាំងនោះ ពួកមិច្ឆាទិដ្ឋិគិតដូច្នេះថា "អ្នកទាំងឡាយ ចូរមកមើលកិរិយារបស់ព្រះសមណគោតម ព្រះសមណគោតមនោះ រមែងពោលតែមាត់ប៉ុណ្ណោះ" ព្រះសមណគោតមពោលថា "ក្នុងថ្ងៃនេះ សន្តតិមហាមាត្យនោះស្រវឹងស្រាយ៉ាងនេះ តែងខ្លួនតាមប្រក្រតី ហើយស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសមណគោតម នឹងបរិនិព្វាន ថ្ងៃនេះពួកយើងនឹងផ្ចាញ់ផ្ចាល់ព្រះសមណគោតមនោះ ដោយមុសាវាទ" ។

ពួកសម្មាទិដ្ឋិ គិតដូច្នេះថា "គួរឲ្យអស្ចារ្យណាស់ ព្រះពុទ្ធទាំងឡាយមានអានុភាពច្រើន ថ្ងៃនេះ ពួកយើងនឹងបានឃើញនូវលីលារបស់ព្រះពុទ្ធនិងលីលារបស់សន្តតិមហាមាត្យ" ។

ចំណែកសន្តតិមហាមាត្យ លេងទឹកពេញមួយថ្ងៃត្រង់កំពង់ទឹកហើយទៅកាន់ឧទ្យាន គង់ក្នុងរោងផឹកសុរា ។

ចំណែកស្ត្រីនោះ ឡើងទៅត្រង់កណ្តាលទីរាំ ផ្តើមនឹងសម្តែងនូវការរាំ និងច្រៀង កាលស្ត្រីនោះកំពុងរាំច្រៀងនោះ ខ្យល់មានពិសដូចជាសស្រ្តា

កើតឡើងក្នុងពោះរបស់នាង កាត់សាច់បេះដូង ព្រោះនាងមានអាហារតិចអស់ ៧ ថ្ងៃ មកហើយ ដើម្បីសម្តែងការល្អិតល្អន់នៃសរីរៈ ។ ពេលនោះ នាងមានមាត់ហា និងភ្នែកស ហើយធ្វើមរណកាលក្នុងពេលនោះឯង ។

សន្តតិមហាមាត្យពោលថា "អ្នកទាំងឡាយ ចូរពិនិត្យមើលនាងមើល" គ្រាន់តែជនទាំងឡាយពោលថា "ស្ត្រីនោះស្លាប់ហើយ លោកម្ចាស់" សេចក្តីសោកដ៏ខ្លាំងក្លាគ្របសង្កត់សន្តតិមហាមាត្យភ្លាម ។ ក្នុងខណៈនោះឯង ស្រាដែលសន្តតិមហាមាត្យផឹកអស់ ៧ ថ្ងៃមកហើយនោះ បានដល់នូវការអស់ទៅ (ស្វាង) ដូចដំណក់ទឹកក្នុងអំបែងដ៏ក្តៅ ដូច្នោះ ។ សន្តតិមហាមាត្យគិតថា "បុគ្គលដទៃ វៀរព្រះតថាគតចេញ នឹងមិនអាចញ៉ាំងសេចក្តីសោករបស់យើងឲ្យស្ងប់បានឡើយ" គេមានពលចោមរោម ធ្វើដំណើរទៅកាន់សម្នាក់របស់ព្រះសាស្តាក្នុងវេលារសៀល ថ្វាយបង្គំហើយ ក៏ក្រាបទូលយ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីសោកបែបនេះកើតឡើងដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមកកាន់សម្នាក់ព្រះអង្គដោយសង្ឃឹមថា ព្រះអង្គអាចនឹងញ៉ាំងសេចក្តីសោករបស់ខ្ញុំព្រះអង្គឲ្យរលត់ទៅបាន សូមព្រះអង្គទ្រង់ជាទីពឹងរបស់ខ្ញុំព្រះអង្គផង" ។

## សន្តតិមហាមាត្យសម្រេចព្រះអរហត្ត

គ្រានោះ ព្រះសាស្តាត្រាស់ទៅកាន់សន្តតិមហាមាត្យថា "អ្នកមកកាន់សម្នាក់នៃបុគ្គលដែលអាចញ៉ាំងសេចក្តីសោកឲ្យរលត់បានដូច្នេះ អ្នកកុំបារម្ភឡើយ ទឹកភ្នែករបស់អ្នកដែលហូរចេញ ព្រោះអាស្រ័យការឃើញរបស់អ្នក

ដែលយំសោកក្នុងកាលដែលឃើញស្ត្រីនេះស្លាប់ដោយហេតុដដែលនេះ ច្រើនជាងទឹកមហាសមុទ្រទាំង ៤" លុះត្រាស់ដូច្នេះហើយ ក៏ត្រាស់ព្រះគាថានេះថា

កិលេសជាគ្រឿងកង្វល់ឯណា មានក្នុងកាលមុន អ្នកចូរញ៉ាំង
កិលេសជាគ្រឿងកង្វល់នោះ ឲ្យហួតហែងទៅ សេចក្តីកង្វល់ក្នុង
កាលជាខាងក្រោយ ចូរកុំមានដល់អ្នកឡើយ បើអ្នកមិនប្រកាន់
ខន្ធក្នុងបច្ចុប្បន្ន នឹងជាអ្នកស្ងប់រម្ងាប់ ហើយត្រាច់ទៅ ។

ក្នុងកាលចប់ព្រះគាថា សន្តតិមហាមាត្យ ក៏បានសម្រេចព្រះអរហត្ត បានពិចារណាមើលអាយុសង្ខាររបស់ខ្លួន ដឹងថា "ការប្រព្រឹត្តទៅមិនបាននៃអាយុសង្ខារ" បានក្រាបទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់អនុញ្ញាតការបរិនិព្វានដល់ខ្ញុំព្រះអង្គចុះ" ។

ព្រះសាស្តា សូម្បីទ្រង់បានជ្រាបនូវកម្មដែលសន្តតិមហាមាត្យធ្វើហើយក៏ដោយ ក៏ទ្រង់នៅតែត្រាស់ឲ្យសន្តតិមហាមាត្យសម្តែងអំពីបុព្វកម្មរបស់ខ្លួន ព្រោះទ្រង់ដឹងថា ពួកមិច្ឆាទិដ្ឋិប្រជុំគ្នា ដើម្បីសង្កត់សង្កិនព្រះអង្គដោយមុសាវាទ នឹងមិនបានឱកាស ពួកសម្មាទិដ្ឋិប្រជុំគ្នាដោយសង្ឃឹមថា ពួកយើងនឹងមើលនូវលីលារបស់ព្រះពុទ្ធជាម្ចាស់ និងលីលារបស់សន្តតិមហាមាត្យ ស្តាប់នូវកម្មដែលសន្តតិមហាមាត្យនោះធ្វើហើយ នឹងធ្វើការអើពើក្នុងបុណ្យទាំងឡាយ ទើបត្រាស់ថា "បើដូច្នោះ អ្នកចូរសម្តែងនូវកម្មដែលអ្នកបានធ្វើហើយ កាលបើអ្នកសម្តែង ចូរអ្នកកុំឈរលើផែនដីសម្តែង ចូរឈរលើអាកាសកម្ពស់ ៧

ដើមត្នោត ហើយសម្តែងចុះ ។

សន្តតិមហាមាត្យទទួលថា “ព្រះករុណា ព្រះអង្គ” ហើយថ្វាយបង្គំព្រះសាស្តា ហោះឡើងកាន់អាកាសបានមួយដើមត្នោត ចុះមកថ្វាយបង្គំព្រះសាស្តាម្តង ហោះឡើងទៅតែនក្នែនលើអាកាស ៧ ដើមត្នោត តាមលំដាប់ ហើយទូលថា “បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវបុព្វកម្មរបស់ខ្ញុំព្រះអង្គ” (ដូចតទៅនេះ) ៖

## បុព្វកម្មរបស់សន្តតិមហាមាត្យ

ក្នុងកប្បទី ៩១ រាប់អំពីកប្បនេះ ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថា **វិបស្សី** ខ្ញុំព្រះអង្គកើតក្នុងត្រកូលមួយ ថ្ងៃមួយ ខ្ញុំព្រះអង្គបានគិតថា “អ្វីហ្ន៎ ជាកម្មដែលមិនធ្វើការកាត់ ឬបៀតបៀនដល់ជនដទៃ កាលពិចារណាទៅ ក៏ឃើញកម្ម គឺ ការដើរឃោសនាក្នុងបុណ្យទាំងឡាយ” ចាប់តាំងពីពេលនោះមក ខ្ញុំព្រះអង្គក៏បានធ្វើនូវកម្មនោះ បបួលមហាជនឲ្យបំពេញបុណ្យថា “ពួកលោក ចូរធ្វើបុណ្យទាំងឡាយ ចូរសមាទានឧបោសថក្នុងថ្ងៃឧបោសថទាំងឡាយ ចូរថ្វាយទាន ចូរស្តាប់ធម៌ វត្ថុដទៃដែលប្រាកដស្មើដោយរតនៈទាំងឡាយ មានពុទ្ធរតនៈជាដើម មិនមានឡើយ ពួកលោកចូរធ្វើសក្ការៈ គោរពរាប់អានរតនៈទាំងឡាយ ៣ នោះចុះ” ។

## ផលនៃការបបួលមហាជនបំពេញកុសល

ព្រះបាទពន្ធុមមហារាជ ជាព្រះពុទ្ធបិតា ទ្រង់ព្រះសណ្តាប់នូវសំឡេង

របស់ខ្ញុំព្រះអង្គហើយ ទ្រង់ត្រាស់ឲ្យហៅខ្ញុំព្រះអង្គមកគាល់ ហើយត្រាស់សួរថា "នែអ្នក អ្នកដើរធ្វើអ្វី" កាលខ្ញុំព្រះអង្គទូលថា "បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គ ដើរប្រកាសគុណព្រះរតនៈទាំងបី ហើយបបួលមហាជនឲ្យបំពេញបុណ្យទាំងឡាយ" ក៏ត្រាស់សួរថា អ្នកដើរប្រកាសគុណព្រះរតនៈទាំងបីដោយអ្វី?" ខ្ញុំព្រះអង្គទូលថា "បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គត្រាច់ទៅដោយជើង" ទើបត្រាស់ថា "នែអ្នក អ្នកមិនគួរត្រាច់ទៅដូច្នោះទេ អ្នកចូរប្រដាប់កម្រងផ្កានេះ ហើយអង្គុយលើខ្នងសេះ ត្រាច់ទៅចុះ" លុះត្រាស់ដូច្នោះហើយ ទ្រង់ក៏ព្រះរាជទានកម្រងផ្កា ដូចកម្រងកែវមុក្តា ទាំងបានព្រះរាជទានសេះដែលនាយសារថីទូន្មានហើយដល់ខ្ញុំព្រះអង្គ ។ ក្រោយមក ព្រះរាជាត្រាស់ឲ្យហៅខ្ញុំព្រះអង្គ ដែលកំពុងដើរប្រកាសគុណព្រះរតនៈទាំងបី ដោយគ្រឿងបរិហារ ដែលព្រះរាជាទ្រង់ព្រះរាជទានមកគាល់ ហើយត្រាស់សួរទៀតថា នែនាយ អ្នកត្រាច់ទៅធ្វើអ្វី?" កាលខ្ញុំព្រះអង្គទូលថា "បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គធ្វើកម្មដូច្នេះ" ក៏ត្រាស់ថា "នែនាយ សូម្បីសេះក៏មិនសមគួរដល់អ្នកដែរ អ្នកចូរអង្គុយលើរថនេះ ត្រាច់ទៅចុះ" ហើយបានព្រះរាជទានរថដែលទឹមដោយសេះសិន្ធព ៤ ។ សូម្បីក្នុងលើកទី ៣ ព្រះរាជាទ្រង់ស្តាប់នូវសំឡេងរបស់ខ្ញុំព្រះអង្គហើយក៏ត្រាស់ឲ្យហៅខ្ញុំព្រះអង្គមក ត្រាស់សួរថា "នែនាយ អ្នកដើរធ្វើអ្វី?" កាលខ្ញុំព្រះអង្គទូលថា "បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គធ្វើកម្មដូច្នោះឯង" ទើបត្រាស់ថា "នែនាយ សូម្បីរថក៏មិនសមគួរដល់អ្នកដែរ ហើយព្រះរាជទានភោគៈជា

ច្រើន និងគ្រឿងប្រដាប់ទាំងឡាយ ទាំងបានព្រះរាជទានដំរីមួយដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គប្រដាប់ដោយអាករណៈគ្រប់យ៉ាង អង្គុយលើ.កដំរី ធ្វើនូវធម្មឃោស-កកម្មអស់ ៨ ម៉ឺនឆ្នាំ ខ្លឹមចន្ទន៍ផ្សាយចេញអំពីកាយរបស់ខ្ញុំព្រះអង្គ សូម្បីក្លិនឧប្បលក៏ផ្សាយចេញអំពីមាត់ រហូតអស់កាលប្រមាណប៉ុណ្ណេះ” នេះជាកម្មដែលខ្ញុំព្រះអង្គបានធ្វើហើយ ។

សន្តតិមហាមាត្យនោះ លុះសម្តែងនូវបុព្វកម្មរបស់ខ្លួនយ៉ាងនេះហើយ អង្គុយនៅក្នុងដ៏អាកាស ចូលតេជោធាតុ បរិនិព្វាននៅលើអាកាសនោះឯង ។ អណ្តាតភ្លើងតាំងឡើងអំពីសរីរៈ ញុាំងសាច់ និងឈាមឲ្យអស់ទៅ ។ នៅសល់តែធាតុទាំងឡាយ ដូចផ្កាម្លិះប៉ុណ្ណោះ ព្រះសាស្តាទ្រង់លាតសំពត់សដ៏ស្អាត ធាតុទាំងឡាយក៏ធ្លាក់ចុះមកលើសំពត់ដ៏សស្អាតនោះ ។ ព្រះសាស្តាទ្រង់បញ្ចុះធាតុទាំងនោះហើយ ត្រាស់ឲ្យកសាងស្តូបត្រង់ផ្លូវធំបែកជា ៤ ដោយព្រះបំណងថា “មហាជនថ្វាយបង្គំហើយ នឹងបានចំណែកបុណ្យដ៏ច្រើន” ។

## គួរហៅសន្តតិមហាមាត្យថាសមណៈ ឬព្រាហ្មណ៍

ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា “អ្នកមានអាយុទាំងឡាយ សន្តតិ-មហាមាត្យ បានសម្រេចព្រះអរហត្តក្នុងទីបំផុតនៃព្រះគាថា ទាំងនៅប្រដាប់តាក់តែងគ្រឿងអលង្ការនោះឯង ហើយបរិនិព្វាននៅលើអាកាស គួរហៅលោកថា “សមណៈ ឬក៏ព្រាហ្មណ៍ហ្ន៎” ។

ព្រះសាស្តា ស្តេចយាងមកហើយត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ

ពេលនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វី?" ។ កាលភិក្ខុទាំងនោះទូលថា "ពួកខ្ញុំព្រះអង្គអង្គុយប្រជុំគ្នា ដោយកថាឈ្មោះនេះ" ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ការហៅបុត្រតថាគតថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ហើយទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

៩.អលង្កតោ ចេបិ សមំ ចរេយ្យ
សន្តោ ទន្តោ និយតោ ព្រហ្មចារី
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ ។

បើបុគ្គលណា មានខ្លួនប្រដាប់ស្អិតស្អាងហើយ (ដោយគ្រឿងអម្ពរ) តែគប្បីប្រព្រឹត្តស្មើ អ្នកស្ងប់រម្ងាប់ ទូន្មាន (ឥន្ទ្រិយ) ជាបុគ្គលទៀង (ចំពោះមគ្គផល) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញាក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា អលង្កតោ (ប្រដាប់ហើយ) បានដល់ប្រដាប់ដោយសំពត់ និងអាភរណៈ ។ បណ្ឌិតគប្បីជ្រាបសេចក្តីនៃព្រះគាថានោះថា "ថ្វីបើបុគ្គលនោះ នៅប្រដាប់ដោយគ្រឿងអលង្ការ មានសំពត់ជាដើមក្តី តែលោកប្រព្រឹត្តស្មើដោយកាយជាដើម ឈ្មោះថា ជាអ្នកស្ងប់ ព្រោះការ

ស្ងប់រម្ងាប់រាគៈជាដើម ឈ្មោះថា ជាអ្នកទូន្មាន ព្រោះទូន្មានឥន្ទ្រិយ ឈ្មោះថា ជាបុគ្គលទៀង ព្រោះទៀងក្នុងមគ្គទាំង ៤ ឈ្មោះថា ព្រហ្មចារី ព្រោះប្រព្រឹត្ត ដ៏ប្រសើរ ឈ្មោះថា ដាក់អាជ្ញាក្នុងសត្វគ្រប់ជំពូក ព្រោះជាអ្នកដាក់ចុះនូវ អាជ្ញាផ្លូវកាយជាដើម បុគ្គលនោះ គឺ បុគ្គលបែបនោះ បុគ្គលគប្បីហៅថា ព្រាហ្មណ៍ ព្រោះជាអ្នកមានបាបបណ្តែតហើយក៏បាន ថាជាសមណៈ ព្រោះ ជាអ្នកមានបាបស្ងប់ហើយក៏បាន ថាជាភិក្ខុ ព្រោះជាអ្នកមានកិលេសទម្លាយ ហើយក៏បាន ។

ក្នុងទីបំផុតនៃព្រះធម្មទេសនារបស់ព្រះសម្មាសម្ពុទ្ធ ជនជាច្រើននាក់ បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចប់ រឿងសន្តតិមហាមាត្យ

# ១០. រឿងបិលោតិកៈ

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះបិលោតិកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ហិរិ និសេធោ បុរិសោ (បុរសហាមអកុសលវិតក្កៈដោយហិរិបាន"** ជាដើម ។*

ព្រះអានន្ទចាត់ចែងបំបួសបិលោតិកៈ

*សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះអានន្ទត្ថេរឃើញទារកម្នាក់ស្លៀកសំពត់ចាស់ (កន្ទប) កាន់អំបែងដើរសូមទាន ក៏ពោលទៅកាន់កុមារនោះថា "ម្នាលកុមារ ឯងបួសមិនល្អជាងការដើរសុំទានយ៉ាងនេះឬ?" កាលកុមារឆ្លើយថា "លោកម្ចាស់ដ៏ចម្រើន នរណានឹងបំបួសខ្ញុំព្រះករុណា" ទើបព្រះថេរៈពោលជានាថា "អាត្មាជាអ្នកបំបួសឲ្យ" លុះពោលដូច្នោះហើយ ក៏នាំក្មេងនោះទៅកាន់វិហារ ងូតទឹកឲ្យដោយដៃរបស់ខ្លួន ប្រាប់កម្មដ្ឋានហើយ ក៏ឲ្យបព្វជ្ជា ។*

*ព្រះអានន្ទ លាតសំពត់ចាស់ដែលកុមារនោះស្លៀក ពិនិត្យមើល ក៏មិនឃើញចំណែកណាមួយដែលសមគួរអាចយកទៅប្រើប្រាស់បាន សូម្បីត្រឹមតែធ្វើជាសំពត់ត្រងទឹក ទើបយកកំណាត់កន្ទបនោះទៅពាក់នឹងមែកឈើ មួយអន្ទើដោយអំបែង ។*

*កុមារនោះ បានបព្វជ្ជាឧបសម្បទាហើយ បរិភោគលាភ និងសក្ការៈដែលកើតឡើងចំពោះព្រះពុទ្ធទាំងឡាយ ស្លៀកដណ្តប់សំពត់ដ៏មានតម្លៃ មាន*

សរីរៈធាត់ កើតការអផ្សុកឡើង ក៏គិតថា “ប្រយោជន៍អ្វី ដោយការស្លៀកដណ្ដប់ចីវរ ដែលជនដទៃឲ្យដោយសទ្ធាយ៉ាងនេះ យើងនឹងស្លៀកសំពត់ចាស់របស់យើងវិញ” លុះគិតដូច្នោះហើយ ក៏និមន្តទៅកាន់ទីនោះ ចាប់សំពត់ចាស់ធ្វើសំពត់នោះឲ្យជាអារម្មណ៍ ហើយទូន្មានខ្លួនដោយខ្លួនឯងថា “បុគ្គលឥតខ្មាសមិនមានហិរិ និងឱត្តប្បៈ អ្នកឯងចង់លះបង់ឋានៈ គឺ ការស្លៀកសំពត់ទាំងឡាយបែបនេះ ហើយត្រឡប់ទៅស្លៀកកន្ទប កាន់អំបែងដើរសុំទានគេទៀតឬ?” ក៏កាលលោកឲ្យឱវាទខ្លួនឯងនោះ ចិត្តក៏ជ្រះថ្លា ។ លោកដាក់កន្ទបទុកកន្លែងដើម ហើយត្រឡប់ទៅកាន់វត្តវិញ ។ ដោយកាលកន្លងទៅបាន ២-៣ ថ្ងៃ លោកក៏កើតការអផ្សុកទៀត ទៅកាន់ទីនោះ ទូន្មានខ្លួនដូចលើកមុន ហើយក៏ត្រឡប់មកកាន់វិហារវិញ ។ ដល់អផ្សុកម្ដងទៀត ក៏ទៅពោលយ៉ាងនោះ ហើយក៏ត្រឡប់មកវិញ ដោយប្រការដូច្នេះ ។

## ព្រះបិលោតិកត្ថេរសម្រេចព្រះអរហត្ត

ភិក្ខុទាំងឡាយឃើញលោកនិមន្តទៅមកៗ ដូច្នេះ ក៏សួរថា “អាវុសោ លោកនិមន្តទៅណា” ។

លោកក៏ប្រាប់ថា “អាវុសោ ខ្ញុំទៅកាន់សម្នាក់អាចារ្យរបស់ខ្ញុំករុណា” លុះពោលដូច្នេះហើយ ក៏ទៅទីនោះ ធ្វើសំពត់ចាស់នោះឯងឲ្យជាអារម្មណ៍តាមទំនងនោះឯង ហាមឃាត់ខ្លួនបានហើយ ពីរបីថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចព្រះអរហត្ត ។

ភិក្ខុទាំងឡាយពោលថា "អ្នកមានអាយុ លោកមិនទៅកាន់សម្នាក់អាចារ្យទៀតទេឬ? ផ្លូវនេះជាទីត្រាច់ទៅមក របស់លោកមិនមែនឬ"

លោកឆ្លើយថា "អាវុសោ កាលការជាប់ជំពាក់ជាមួយអាចារ្យនៅមាន ទើបខ្ញុំទៅកាន់សម្នាក់អាចារ្យ តែឥឡូវនេះ ខ្ញុំកាត់ការជាប់ជំពាក់នោះបានហើយ ព្រោះដូច្នោះ ទើបខ្ញុំមិនទៅកាន់សម្នាក់អាចារ្យទៀត" ភិក្ខុទាំងនោះក្រាបទូលចំពោះព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះបិលោតិកត្ថេរ ពោលអួតអរហត្តផល" ។

ព្រះសាស្តា. ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ តើបិលោតិកៈពោលដូចម្តេច? ។

ពួកភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន លោកពោលពាក្យឈ្មោះនេះ ។

ព្រះសាស្តា. ទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ បុត្រតថាគត កាលនៅមានគ្រឿងជាប់ជំពាក់ ទើបទៅកាន់សម្នាក់អាចារ្យ លុះកាត់ការជាប់ជំពាក់បានហើយ លោកហាមឃាត់ខ្លួនដោយខ្លួនឯង សម្រេចព្រះអរហត្តហើយ មិនទៅកាន់សម្នាក់អាចារ្យទៀតឡើយ" ហើយទ្រង់បានភាសិតព្រះគាថាទាំងនេះថា ៖

១០.ហិរិនិសេធោ បុរិសោ កោចិ លោកស្មិ វិជ្ជតិ
យោ និទ្ទំ អបពោធតិ អស្សោ ភទ្រោ កសាមិវ
អស្សោ យថា ភទ្រោ កសានិវិដ្ឋោ

*អាតាបិនោ សំវេគិនោ ភវាថ*

*សទ្ធាយ សីលេន ច វីរិយេន ច*

*សមាធិនា ធម្មវិនិច្ឆយេន ច*

*សម្បន្នវិជ្ជាចរណា បតិស្សតា*

*បហស្សថ ទុក្ខមិទំ អនប្បកំ ។*

*បុរស អ្នកកំចាត់បង់នូវអកុសលវិតក្កៈ ដោយសេចក្តីខ្មាស បាប មានតិចក្នុងលោក បុគ្គលណាបន្ទោបង់នូវការដេកលក់ ដូចសេះល្អខ្លាចព្រោះរំពាត់ បុរសនោះ រកបានដោយក្រក្នុង លោក ។ សេះល្អ ដែលសារថីទូន្មានដោយរំពាត់ តក់ស្លុត យ៉ាងណា អ្នកទាំងឡាយ ចូរជាបុគ្គលមានព្យាយាម មាន សេចក្តីតក់ស្លុតយ៉ាងនោះឯង បើអ្នកទាំងឡាយ ប្រកបព្រម ដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង ធម្មវិនិច្ឆ័យ ផង ជាអ្នកមានវិជ្ជា និងចរណៈដ៏បរិបូណ៌ មានស្មារតីតំកល់ មាំ រមែងលះបង់ទុក្ខមានប្រមាណច្រើននេះ មិនខាន ។*

អធិប្បាយគាថា

*បុគ្គលឈ្មោះថា ហាមអកុសលវិតក្កៈដោយហិរិបាន ក្នុងព្រះគាថានោះ ក៏ព្រោះអត្ថថា ហាមអកុសលវិតក្កៈដែលខាងក្នុង ដោយការខ្មាសបាប ។*

*បទថា កោចិ លោកស្មឹ (តិចអ្នកនីងមានក្នុងលោក) សេចក្តីថា បុគ្គល*

បែបនោះ រកបានដោយកម្រ ទើបឈ្មោះថា មានតិចក្នុងលោក ។

បទថា **យោ និទ្ទំ (បុគ្គលណាកម្ចាត់ការលក់)** សេចក្តីថា បុគ្គលណា មិនប្រមាទហើយ ធ្វើសមណធម៌ បន្ទោបង់នូវការលង់លក់ដែលកើតដល់ខ្លួន ភ្ញាក់រឭកជានិច្ច បុគ្គលនោះ ឈ្មោះថា បន្ទោបង់នូវការលង់លក់ហើយ តែង ភ្ញាក់រឭកជានិច្ច ។

បទថា **កសាមិវ (ដូចសេះល្អគេចរំពាត់)** ជាដើម សេចក្តីថា បុគ្គល ណាភ្ញាក់រឭក ដូចសេះល្អគេចរំពាត់ដែលនឹងធ្លាក់ចុះមកលើខ្លួន គឺ មិនឲ្យធ្លាក់ ចុះមកលើខ្លួន យ៉ាងណា បុគ្គលនោះក៏រកបានដោយក្រ ។

ក្នុងគាថាទី ២ មានសេចក្តីសង្ខេបដូចតទៅនេះ ៖

“ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាអ្នកមានសេចក្តីព្យាយាម តក់ស្លុត ដូចសេះល្អអាស្រ័យការប្រមាទ ត្រូវគេវាយដោយរំពាត់ហើយ ដឹង ខ្លួនថា ខ្លួនអញត្រូវគេវាយដោយរំពាត់ហើយ ក្រោយមករមែងធ្វើការរាងចាល ធ្វើសេចក្តីព្យាយាម ដូច្នោះ អ្នកទាំងឡាយចូរជាអ្នកយ៉ាងនោះ ប្រកបដោយ សទ្ធា ២ យ៉ាង ដែលជាលោកិយៈ និងលោកុត្តរៈផង ដោយបារិសុទ្ធិសីល ៤ ផង ដោយសេចក្តីព្យាយាម ដែលប្រព្រឹត្តទៅតាមកាយ និងចិត្តផង ដោយ សមាធិ ដែលសម្បយុត្តដោយសមាបត្តិ ៨ ផង ដោយប្រាជ្ញាដែលជាគ្រឿង វិនិច្ឆ័យធម៌ មានការដឹងហេតុ និងមិនមែនហេតុជាលក្ខណៈផង ឈ្មោះថា មាន វិជ្ជា និងចរណៈបរិបូណ៌ ព្រោះដល់ព្រមដោយវិជ្ជា ៣ ឬវិជ្ជា ៨ និងចរណៈ

១៥ ឈ្មោះថា ជាអ្នកមានសតិតម្កល់មាំ ព្រោះជាអ្នកមានសតិតាំងមាំហើយ នឹងលះបង់នូវទុក្ខក្នុងវដ្ដៈ មានប្រមាណមិនតិចនេះបាន ។

ក្នុងទីបំផុតនៃព្រះធម៌ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិជាដើម ។

ចប់ រឿងបិលោតិកៈ

# ១១. រឿងសុខសាមណេរ

## សេចក្ដីខាងដើម

*ព្រះសាស្ដា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធសុខសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា* ***ឧទកំ ហិ ន យន្តិ នេត្តិកា (ធម្មតាអ្នកបង្ហូរ តែងបង្ហូរទឹក)*** *ជាដើម ។*

## រឿងគន្ធសេដ្ឋី

*សេចក្ដីពិស្ដារថា ក្នុងអតីតកាល មានសេដ្ឋីបុត្រអ្នកក្រុងពារាណសីម្នាក់ ឈ្មោះគន្ធកុមារ កាលបិតារបស់គន្ធកុមារនោះធ្វើមរណកាលទៅ ព្រះរាជាត្រាស់ឲ្យហៅគន្ធកុមារចូលគាល់ ទ្រង់លួងលោមហើយ បានព្រះរាជទានតំណែងសេដ្ឋីដល់កុមារនោះ ព្រមទាំងសក្ការៈជាច្រើន ។ ចាប់តាំងអំពីកាលនោះមក គន្ធកុមារនោះ ក៏បានប្រាកដនាមថា* ***គន្ធសេដ្ឋី*** *។ គ្រានោះ អ្នករក្សាឃ្លាំងរបស់សេដ្ឋីនោះ បើកទ្វារឃ្លាំង ជញ្ជូនទ្រព្យចេញមក ហើយប្រាប់ថា "លោកម្ចាស់ ទ្រព្យមានប្រមាណប៉ុណ្ណេះជារបស់បិតា ប្រមាណប៉ុណ្ណេះជារបស់បុព្វបុរស មានជីតាជាដើមរបស់លោកម្ចាស់ ។ សេដ្ឋីនោះ សម្លឹងមើលនូវគំនរទ្រព្យនោះហើយ និយាយថា "ដូចម្ដេចក៏បុព្វបុរសទាំងនោះមិនកាន់យកទ្រព្យទាំងនេះទៅជាមួយផង" អ្នករក្សាឃ្លាំងប្រាប់ថា "លោកម្ចាស់ ឈ្មោះថាអ្នកដែលកាន់យកទ្រព្យទៅជាមួយផង មិនបាន ពិតហើយ សត្វទាំងឡាយ*

រមែងនាំយកកុសល និងអកុសល ដែលខ្លួនបានធ្វើហើយប៉ុណ្ណោះទៅ ។

## សេដ្ឋីចំណាយទ្រព្យសាងវត្ថុផ្សេងៗ

សេដ្ឋីនោះគិតថា "បុព្វបុរសទាំងនោះ បានប្រមែប្រមូលនូវទ្រព្យទុកហើយ ក៏លះបង់ចោលទៅ ព្រោះខ្លួនជាមនុស្សល្ងង់ ចំណែកយើងនឹងកាន់យកទ្រព្យទុំះទៅជាមួយ" គន្ធសេដ្ឋីកាលគិតយ៉ាងនោះ មិនបានគិតថា "យើងនឹងឲ្យទាន ឬនឹងធ្វើការបូជាទេ" គិតតែថា "យើងនឹងបរិភោគទ្រព្យនេះឲ្យអស់ ហើយសឹមទៅ" ។ សេដ្ឋីនោះបានចំណាយទ្រព្យមួយសែនកហាបណៈ ឲ្យគេធ្វើបន្ទប់សម្រាប់ងូតទឹក ជាវិការៈនៃកែវផលិក ចំណាយទ្រព្យមួយសែនកហាបណៈ ឲ្យគេធ្វើផែនក្តារសម្រាប់ងូតទឹក ដែលជាវិការៈនៃកែវផលិកដូចគ្នា ចំណាយទ្រព្យមួយសែន ឲ្យគេធ្វើបល្ល័ង្កសម្រាប់អង្គុយ ចំណាយទ្រព្យមួយសែន ឲ្យគេធ្វើថាសសម្រាប់ដាក់ភោជន ចំណាយទ្រព្យមួយសែនទៀត ឲ្យគេធ្វើមណ្ឌបក្នុងទីជាទីបរិភោគ ចំណាយទ្រព្យមួយសែន ឲ្យគេធ្វើគ្រែទ្រថាសភោជន ឲ្យគេសាងសីហបញ្ជរទុកក្នុងផ្ទះដោយទ្រព្យមួយសែនទៀត ចំណាយទ្រព្យមួយពាន់ សម្រាប់អាហារពេលព្រឹករបស់ខ្លួន ចំណាយទ្រព្យមួយពាន់សម្រាប់អាហារពេលល្ងាច ក្នុងថ្ងៃពេញបុណ្ណមី បានចំណាយទ្រព្យមួយសែនសម្រាប់ភោជន ក្នុងថ្ងៃបរិភោគភត្តនោះ សេដ្ឋីបានលះបង់ទ្រព្យមួយសែនឲ្យគេតាក់តែងព្រះនគរ ហើយប្រើមនុស្សឲ្យដើរវាយស្គរប្រកាសថា "សូមមហាជនមកមើលនូវការបរិភោគរបស់គន្ធសេដ្ឋី" ។ មហាជនបានចងគ្រែតូច គ្រែធំ

ប្រជុំគ្នា ។

ចំណែកគន្ធសេដ្ឋីនោះ អង្គុយលើផែនក្ដារដែលមានតម្លៃមួយសែន ក្នុងបន្ទប់ទឹកដែលមានតម្លៃមួយសែន ងូតទឹកដែលលាយដោយគ្រឿងក្រអូបទាំងឡាយ ១៦ ក្អម បើកសីហបញ្ជរ ហើយអង្គុយលើបល្ល័ង្កនោះ ។ គ្រានោះពួកអ្នកបម្រើដាក់ថាសភោជនលើជើងទ្រនោះហើយ ដួសភោជនដែលមានតម្លៃមួយសែនជូនសេដ្ឋីនោះ ។ លោកសេដ្ឋី ដែលមានស្ត្រីបាំចោមរោមហើយបរិភោគភោជននោះ ដោយសម្បត្តិយ៉ាងនេះ ។

## អ្នកស្រុកក្រៅឃ្លានក្នុងភត្តរបស់សេដ្ឋី

ក្នុងសម័យដទៃ អ្នកស្រុកក្រៅម្នាក់ ផ្ទុកវត្ថុទាំងឡាយមានឧសជាដើមក្នុងយានតូច ហើយបរយានទៅកាន់ព្រះនគរ ដើម្បីដូរស្បៀងអាហារសម្រាប់ខ្លួន លុះទៅដល់ព្រះនគរ ក៏សម្រាកនៅក្នុងផ្ទះរបស់សម្លាញ់ ។ ក៏ក្នុងថ្ងៃនោះជាថ្ងៃពេញបូណ៌មី ។ ជនទាំងឡាយទូងស្គរប្រកាសក្នុងនគរថា "មហាជនចូរទៅមើលការបរិភោគរបស់គន្ធសេដ្ឋី" ។ គ្រានោះ បុរសជាសម្លាញ់ពោលនឹងអ្នកស្រុកក្រៅនោះថា "ម្នាលសម្លាញ់ៗ ឯង ធ្លាប់ឃើញការបរិភោគរបស់គន្ធសេដ្ឋីទេ" ។

អ្នកស្រុកក្រៅ. មិនធ្លាប់ឃើញទេ សម្លាញ់ ។

សំឡាញ់អ្នកនគរ. បើដូច្នោះ យើងនឹងទៅជាមួយគ្នា អ្នកទូងស្គរនេះដើរប្រកាសពេញនគរ ដើម្បីឲ្យមហាជនទៅមើលសម្បត្តិលោកសេដ្ឋី ដូច្នោះ

យើងទៅមើលនូវសម្បត្តិដ៏ធំរបស់លោកសេដ្ឋីទាំងពីរនាក់ ។ សម្លាញ់ក្នុងនគរបាននាំសម្លាញ់ស្រុកក្រៅទៅហើយ ។ សូម្បីមហាជន ក៏បាននាំគ្នាឡើងលើគ្រែតូច និងគ្រែធំ ដែលតម្រួតគ្នានោះ ឈរមើលការបរិភោគរបស់សេដ្ឋី ។ សម្លាញ់អ្នកស្រុកក្រៅ គ្រាន់តែបានធុំក្លិនភត្តនោះភ្លាម ក៏និយាយនឹងសម្លាញ់ក្នុងនគរថា "សម្លាញ់ ខ្ញុំឃ្លានជុំភត្តក្នុងថាសនោះណាស់" ។

សម្លាញ់ក្នុងនគរ. ម្នាលសម្លាញ់ៗ ឯងកុំប្រាថ្នាជុំភត្តនោះឡើយ យើងមិនអាចបានទេ ។

សម្លាញ់ស្រុកក្រៅ. សម្លាញ់ បើខ្ញុំមិនបានបរិភោគភត្តនោះទេ ខ្ញុំពិតជាស្លាប់ហើយ ។

សម្លាញ់ក្នុងនគរនោះ កាលមិនអាចហាមឃាត់សម្លាញ់របស់ខ្លួនបាន ក៏ក្រោកឈរនៅខាងចុងបរិស័ទ ពោលដោយមានសំឡេងខ្លាំងៗ ៣ ដងថា "លោកម្ចាស់ ខ្ញុំសូមសំពះលោក" កាលគន្ធសេដ្ឋីសួរថា "នរណាហ្នឹង?" ក៏ប្រាប់ថា "លោកម្ចាស់ គឺ ខ្ញុំ" ។

សេដ្ឋី. មានការអ្វី ?

សម្លាញ់ក្នុងនគរ. លោកម្ចាស់ សម្លាញ់របស់ខ្ញុំម្នាក់នេះ ចង់បរិភោគជុំភត្តដែលនៅក្នុងថាសរបស់លោក សូមលោកម្ចាស់ ករុណាឲ្យជុំភត្តមួយជុំដោយសេចក្តីអនុគ្រោះផងចុះ ។

សេដ្ឋី. មិនអាចឲ្យបានទេ ។

សម្លាញ់ក្នុងនគរ. ពាក្យរបស់លោកសេដ្ឋី សំឡាញ់ឯងបានឮហើយឬនៅ ? ។

អ្នកស្រុកក្រៅ. សម្លាញ់ ខ្ញុំបានឮហើយ ប៉ុន្តែថាកាលខ្ញុំបានបរិភោគភត្តនោះ ទើបខ្ញុំរស់នៅ បើមិនបានទេ ខ្ញុំនឹងស្លាប់ហើយ ។

សម្លាញ់ក្នុងនគរ ស្រែកទៀតថា “លោកម្ចាស់ បុរសនេះបើមិនបានបរិភោគភត្តនោះទេ នឹងស្លាប់ហើយ ដូច្នេះ សូមលោកឲ្យជីវិតដល់គេផង” ។

គន្ធសេដ្ឋី. នែអ្នកដ៏ចម្រើន ដែលឈ្មោះថាដុំភត្តនេះ រមែងមានតម្លៃដល់ទៅមួយរយក៏មាន ពីររយក៏មាន បើខ្ញុំឲ្យដល់អ្នកដែលសុំនោះ តើខ្ញុំបានអ្វីបរិភោគ ? ។

សម្លាញ់ក្នុងនគរ. លោកម្ចាស់ បុរសនេះ កាលមិនបាន នឹងស្លាប់ សូមលោកឲ្យជីវិតដល់គេផង ។

គន្ធសេដ្ឋី. គេមិនអាចបានទទេៗ ទេ កាលបើគេស្លាប់ ដោយមិនបានបរិភោគដុំភត្តនេះ អ្នកចូរឲ្យគេធ្វើការបម្រើយើង ៣ ឆ្នាំ យើងនឹងឲ្យភត្តដល់គេមួយថាស ។

## អ្នកជនបទព្រមធ្វើការបម្រើសេដ្ឋី

អ្នកស្រុកក្រៅស្តាប់ពាក្យនោះហើយ ទើបនិយាយជាមួយសម្លាញ់នោះថា “សម្លាញ់ ចូរលើកទុកចុះ” លុះពោលដូច្នេះហើយ ក៏ទៅលាបុត្រ និងភរិយា ចូលមកកាន់ផ្ទះរបស់សេដ្ឋី ដោយសន្សំថា នឹងធ្វើការបម្រើលោក

សេដ្ឋីរហូត ៣ ឆ្នាំ ដើម្បីប្រយោជន៍ដល់ភត្តមួយថាស ។ បុរសនោះ កាលធ្វើការបម្រើលោកសេដ្ឋី បានធ្វើកិច្ចគ្រប់យ៉ាងដោយសេចក្ដីមិនប្រមាទ ការងារដែលបុគ្គលគប្បីធ្វើក្នុងផ្ទះក្ដី ក្នុងព្រៃក្ដី ពេលថ្ងៃក្ដី ពេលយប់ក្ដី គេធ្វើបានល្អទាំងអស់ ។ មហាជនហៅគាត់ថា **នាយភត្តភតិកៈ** (បុរសអ្នកធ្វើការឈ្នួលដើម្បីភត្ត) ពាក្យនោះ បានប្រាកដក្នុងព្រះនគរទាំងមូល ។

កាលតមក កាលថ្ងៃបម្រើរបស់ភត្តភតិកៈ គ្រប់ហើយ អ្នកចាត់ចែងភត្តពោលថា "លោកម្ចាស់ ថ្ងៃបម្រើរបស់នាយភត្តភតិកៈ គ្រប់បរិបូណ៌ហើយ គាត់ធ្វើការបម្រើលោករហូត ៣ ឆ្នាំ ដោយលំបាក ការងារនេះកម្រមានអ្នកដទៃធ្វើបាន ការងារសូម្បីតែមួយ ក៏គេមិនដែលធ្វើឲ្យភ្លាត់ឡើយ គ្រានោះ លោកសេដ្ឋីបានចំណាយទ្រព្យ ៣ ពាន់ ឲ្យដល់អ្នកចាត់ចែងភត្តនោះ គឺ ពីរពាន់ដើម្បីអាហារល្ងាច និងអាហារព្រឹករបស់ខ្លួន មួយពាន់ដើម្បីប្រយោជន៍ដល់អាហារព្រឹករបស់នាយភត្តភតិកៈ ហើយប្រាប់អ្នកបម្រើថា "ថ្ងៃនេះ ពួកអ្នកចូរធ្វើការបរិហារនាយភត្តភតិកៈ ដូចដែលអ្នកទាំងឡាយ ធ្លាប់ធ្វើចំពោះយើងចុះ" ។ លុះប្រាប់ដូច្នោះហើយ ក៏បង្គាប់មនុស្សដ៏សេស វៀរតែភរិយាដែលជាទីស្រឡាញ់របស់ខ្លួនឈ្មោះចិន្តាមណី តែម្នាក់ ថា "ថ្ងៃនេះ ពួកអ្នកចូរហែហមនាយភត្តភតិកៈនោះចុះ" ហើយក៏ប្រគល់ទ្រព្យសម្បត្តិទាំងអស់ ឲ្យនាយភត្តភតិកៈនោះ ។

## នាយភត្តភត្តិកៈត្រៀមបរិភោគភត្ត

នាយកត្តកត្តិកៈនោះ អង្គុយលើផែនក្ដារ ក្នុងបន្ទប់ទឹកនោះឯង ងូតទឹក ដោយទឹកសម្រាប់ងូតរបស់លោកសេដ្ឋី ស្លៀកសំពត់សាដករបស់សេដ្ឋីនោះឯង ហើយអង្គុយ លើបល្ល័ង្ករបស់សេដ្ឋីនោះ ។ សូម្បីលោកសេដ្ឋី ក៏ប្រើឲ្យមនុស្សវាយស្គរប្រកាសក្នុងព្រះនគរទាំងមូលថា "នាយកត្តកត្តិកៈ ធ្វើការបម្រើគន្ធសេដ្ឋីអស់ ៣ ឆ្នាំ បានភត្តមួយថាស ដូច្នេះ សូមមហាជនទាំងឡាយចូរទៅមើលនូវសម្បត្តិ គឺ ការបរិភោគរបស់បុរសនោះចុះ" ។ មហាជនបានឡើងកាន់គ្រែតូច និងគ្រែធំឈរមើល ទីដែលអ្នកស្រុកក្រឡេកមើល ក៏បានដល់អាការញាប់ញ័រ ។ ពួកអ្នករបាំ បានឈរចោមរោមកត្តកត្តិកបុរសនោះ ។ ពួកអ្នកបម្រើយកភត្តមួយថាស តម្កល់ខាងមុខនាយកត្តកត្តិកៈនោះ ។

គ្រានោះ ក្នុងវេលាដែលនាយកត្តកត្តិកៈលាងដៃ ព្រះបច្ចេកពុទ្ធមួយអង្គនៅឯភ្នំគន្ធមាទន៍ ចេញចាកសមាបត្តិក្នុងថ្ងៃទី ៧ ពិចារណារកមើលនូវទីត្រាច់ទៅដើម្បីភិក្ខាថា "ថ្ងៃនេះ យើងនឹងទៅដើម្បីភិក្ខាចារក្នុងទីណាហ្ន៎" ។ គ្រានោះ ព្រះបច្ចេកពុទ្ធអង្គនោះ បានឃើញនាយកត្តកត្តិកៈ លោកពិចារណាតទៅទៀតថា "នាយកត្តកត្តិកៈនេះ ធ្វើការបម្រើសេដ្ឋីអស់ ៣ ឆ្នាំ ទើបបានភត្តមួយថាស តើគេមានសទ្ធា ឬក៏មិនមានទេហ្ន៎" ពិចារណាទៅក៏ជ្រាបថា "សទ្ធារបស់គេមាន" ពិចារណាទៅទៀតថា "មនុស្សពួកខ្លះ សូម្បីមានសទ្ធាក៏មិនអាចធ្វើការសង្គ្រោះបាន នាយកត្តកត្តិកៈនេះ នឹងអាចសង្គ្រោះបាន ឬមិន

អាចទេហ្ន៎" ដឹងថា "នាយកត្តកត្តិកៈនឹងអាច ហើយអាស្រ័យសេចក្តីអនុគ្រោះ គេរមែងបាននូវមហាសម្បត្តិ" លុះជ្រាបដូច្នោះហើយ ដណ្តប់ចីវរប្រដាប់បាត្រ ហោះឡើងកាន់វេហាស៍ ក្នុងចន្លោះបរិស័ទ សម្តែងព្រះអង្គប្រថាប់អំពីខាងមុខនាយកត្តកត្តិកៈនោះឯង ។

## នាយកត្តកត្តិកៈថ្វាយកត្តដល់ព្រះបច្ចេកពុទ្ធ

នាយកត្តកត្តិកៈ ឃើញព្រះបច្ចេកពុទ្ធហើយ គិតថា "យើងប្រាថ្នាកត្តមួយថាស ត្រូវធ្វើការឲ្យគេដល់ទៅ ៣ ឆ្នាំ កាលដែលយើងបានកត្តមួយថាសដោយលំបាកយ៉ាងនេះ ក៏ព្រោះតែយើងមិនបានឲ្យទានក្នុងកាលមុន ឥឡូវនេះ កត្តរបស់យើងនេះ អាចរក្សាយើងបានត្រឹមតែមួយថ្ងៃមួយយប់ប៉ុណ្ណោះ បើយើងថ្វាយកត្តនេះដល់លោកម្ចាស់ កត្តនេះនឹងរក្សាយើងអស់ពាន់កោដិកប្បទាំងឡាយ ដូច្នេះ យើងនឹងថ្វាយកត្តនេះដល់លោកម្ចាស់នេះចុះ" ។ នាយកត្តកត្តិកៈ សូម្បីធ្វើការស៊ីឈ្នួលអស់ ៣ ឆ្នាំ បានកត្តមួយថាសហើយ មិនទាន់បានដាក់កត្តសូម្បីតែមួយដុំទៅក្នុងមាត់ផង បន្ទោបង់ចំណង់បាន លើកកត្តមួយថាសនោះខ្លួនឯង ដើរសំដៅទៅរកព្រះបច្ចេកពុទ្ធ លុះទៅដល់ហើយ ក៏ឲ្យថាសកត្តនោះទៅអ្នកដទៃ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន យកដៃឆ្វេងចាប់ថាសកត្ត ដៃស្តាំកៀរកត្តចុះទៅក្នុងបាត្ររបស់ព្រះបច្ចេកពុទ្ធ ។ ព្រះបច្ចេកពុទ្ធបិទបាត្រដោយព្រះហស្ត ក្នុងកាលកត្តនៅពាក់កណ្តាល ។

គ្រានោះ នាយកត្តកត្តិកៈពោលទៅកាន់ព្រះបច្ចេកពុទ្ធថា "លោកម្ចាស់

ដ៏ចម្រើន កត្តនេះមានតែមួយចំណែកប៉ុណ្ណោះ ខ្ញុំព្រះករុណាមិនអាចបែងជាពីរចំណែកបានទេ សូមលោកម្ចាស់កុំសង្គ្រោះខ្ញុំព្រះករុណាក្នុងលោកនេះឡើយ សូមលោកម្ចាស់ ធ្វើនូវសេចក្តីសង្គ្រោះខ្ញុំព្រះករុណាក្នុងបរលោកវិញចុះ“ ខ្ញុំព្រះករុណាមានបំណងនឹងថ្វាយទាំងអស់ មិនឲ្យមានសេសសល់ឡើយ ។

## ទានដែលថ្វាយមិនសេសសល់ មានផលច្រើន

ពិតណាស់ ទានដែលបុគ្គលឲ្យដោយមិនបន្សល់ទុកដើម្បីខ្លួន ឈ្មោះថាទានមិនមានចំណែកសល់ ទាននោះ ជាទានមានផលច្រើន ។ នាយកត្តកត្តិកៈ កាលធ្វើដូច្នោះហើយ ក៏ថ្វាយទាំងអស់ចំពោះព្រះបច្ចេកពុទ្ធ រួចថ្វាយបង្គំព្រះបច្ចេកពុទ្ធ ពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា អាស្រ័យកត្តមួយថាសនេះ ត្រូវបម្រើជនដទៃអស់ ៣ ឆ្នាំ បានសោយនូវទុក្ខដ៏ធំ ឥឡូវនេះ សូមសេចក្តីសុខគប្បីមានដល់ខ្ញុំព្រះករុណាក្នុងទីដែលកើតហើយៗ ចុះ សូមឲ្យខ្ញុំព្រះករុណា មានចំណែកនៃធម៌ដែលលោកម្ចាស់បានឃើញហើយ” ។ ព្រះបច្ចេកពុទ្ធត្រាស់ថា “សេចក្តីប្រាថ្នា ដែលអ្នកប្រាថ្នាហើយយ៉ាងនេះ ចូរសម្រេចដល់អ្នក សេចក្តីត្រិះរិះទាំងពួងចូរពេញដល់អ្នក ដូចព្រះច័ន្ទក្នុងថ្ងៃពេញបូណ៌មី” ដូច្នោះ កាលនឹងធ្វើអនុមោទនា ក៏បានពោលគាថាដូច្នេះថា ៖

វត្ថុដែលអ្នកប្រាថ្នាហើយ ចូរសម្រេចដល់អ្នកឲ្យបានឆាប់
រួសរាន់ទាន់ចិត្ត សេចក្តីត្រិះរិះទាំងពួង ចូរពេញដល់អ្នក
ដូចព្រះច័ន្ទក្នុងថ្ងៃពេញបូណ៌មី វត្ថុដែលអ្នកប្រាថ្នាហើយ ចូរ

*សម្រេចឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សេចក្ដីត្រិះរិះទាំងពួង*

*ចូរពេញដល់អ្នក ដូចកែវមណីជោតិ ដូច្នោះ ។*

*ដូច្នោះហើយ បានអធិដ្ឋានថា "សូមឲ្យមហាជន ចូរឃើញយើងរហូតដល់ភ្នំគន្ធមាទន៍ចុះ" លុះអធិដ្ឋានដូច្នោះហើយ ក៏ហោះទៅកាន់ភ្នំគន្ធមាទន៍តាមអាកាស ។ សូម្បីមហាជន ក៏បានឈរមើលព្រះបច្ចេកពុទ្ធរហូតដល់ភ្នំគន្ធ-មាទន៍ ។ ព្រះបច្ចេកពុទ្ធអង្គនោះ លុះដល់ភ្នំគន្ធមាទន៍ ក៏បានបែងចែកបិណ្ឌបាតនោះ ដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ព្រះបច្ចេកពុទ្ធគ្រប់ៗ អង្គ បានកាន់យកនូវបិណ្ឌបាតដែលសមល្មមរៀងៗ ព្រះអង្គ ។ នរណាៗ មិនគប្បីគិតថា បិណ្ឌ-បាតបន្តិចបន្តួច នឹងគ្រប់គ្រាន់ដូចម្ដេចបាន? ព្រោះថា អចិន្តេយ្យ ៤ យ៉ាងដែលព្រះមានព្រះភាគត្រាស់ទុក បណ្ដាអចិន្តេយ្យ ៤ យ៉ាងនោះ នេះក៏ជាបច្ចេកពុទ្ធវិស័យដែរ ។*

## គន្ធសេដ្ឋីចែកទ្រព្យឱ្យនាយភត្តភត្តិកៈ

*មហាជនឃើញបិណ្ឌបាត ដែលព្រះបច្ចេកពុទ្ធអង្គនោះ បែងចែកឲ្យដល់ព្រះបច្ចេកពុទ្ធទាំងឡាយដូច្នោះ ការញុំាងពាន់នៃសាធុការឲ្យប្រព្រឹត្តទៅសំឡេងនៃសាធុការបានលាន់ឮដូចសំឡេងរន្ទះ ។ គន្ធសេដ្ឋីបានឮសំឡេងនោះហើយ ក៏គិតថា "នាយកត្តកត្តិកបុរស ប្រហែលជាមិនអាចទ្រទ្រង់នូវសម្បត្តិដែលយើងឲ្យបាន ព្រោះហេតុនោះ មហាជនទើបក្រោកឈរ ឡើងធ្វើការចំអក" ។ គន្ធសេដ្ឋីបញ្ជូនមនុស្សទៅ ដើម្បីឲ្យដឹងព្រឹត្តិការណ៍នោះ មនុស្ស*

ទាំងនោះទៅកាន់ទីនោះហើយ ត្រឡប់មកប្រាប់គន្ធសេដ្ឋីថា “លោកម្ចាស់ បុគ្គលអ្នកទ្រទ្រង់នូវសម្បត្តិបែបនេះមាន” ហើយជម្រាបរឿងរ៉ាវដែលបានកើតឡើងនោះ ។ សេដ្ឋីបានស្តាប់រឿងនោះហើយ ជាអ្នកមានសរីរៈដែលបីតិ ៥ យ៉ាងពាល់ត្រូវហើយ បានពោលថា “អស្ចារ្យណាស់ហ្ន៎ នាយកត្តកត្តិកៈនេះ បានធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ យើងតាំងនៅក្នុងសម្បត្តិបែបនេះ អស់កាលប្រមាណប៉ុណ្ណោះ មិនដែលឲ្យនូវវត្ថុអ្វីៗ ទៅនរណាៗ ឡើយ” បានឲ្យគេហៅនាយកត្តកត្តិកៈនោះមក ហើយសួរថា “ម្នាលអ្នកដ៏ចម្រើន ឮថា អ្នកបានធ្វើកម្មបែបនេះពិតឬ?” នាយកត្តកត្តិកៈប្រាប់គន្ធសេដ្ឋីថា “លោកម្ចាស់ ខ្ញុំបានធ្វើយ៉ាងនោះពិតមែន” ទើបពោលថា “បើដូច្នោះ អ្នកចូរកាន់យកទ្រព្យ ១.០០០ កហាបណៈ ហើយចែកចំណែកបុណ្យក្នុងទានរបស់អ្នកឲ្យខ្ញុំខ្លះ” ។ នាយកត្តកត្តិកៈនោះ ក៏បានធ្វើដូច្នោះ ។ មិនត្រឹមតែប៉ុណ្ណោះទេ គន្ធសេដ្ឋីបានបែងចែកទ្រព្យពាក់កណ្តាលដែលជារបស់ខ្លួន ឲ្យដល់នាយកត្តកត្តិកៈនោះ ។

## សម្បទា ៤ យ៉ាង

ពិតណាស់ សម្បទាមាន ៤ យ៉ាង គឺ **វត្ថុសម្បទា បច្ចយសម្បទា ចេតនាសម្បទា គុណាតិរេកសម្បទា** ។ បណ្តា សម្បទា ៤ យ៉ាងនោះ ព្រះអរហន្ត ឬព្រះអនាគាមី ដែលចូលដល់និរោធសមាបត្តិ ជាទក្ខិណេយ្យបុគ្គល ឈ្មោះថា **វត្ថុសម្បទា** , បច្ច័យដែលកើតឡើងដោយធម៌ ឈ្មោះថា **បច្ចយ-សម្បទា** , ចេតនាទាំង ៣ កាល គឺ ក្នុងកាលមុនឲ្យ ក្នុងកាលកំពុងឲ្យ ក្នុង

កាលឲ្យរួចហើយ ដែលសម្បយុត្តដោយញាណ កើតព្រមជាមួយសោមនស្ស ឈ្មោះថា **ចេតនាសម្បទា** , ចំណែក ទក្ខិណេយ្យបុគ្គលដែលចេញពីសមាបត្តិ ឈ្មោះថា **គុណាតិរេកសម្បទា** ។ ក៏សម្បទាទាំង ៤ យ៉ាង គឺ ព្រះបច្ចេកពុទ្ធ ដែលជាព្រះខីណាស្រព ជាទក្ខិណេយ្យបុគ្គល បច្ច័យដែលកើតឡើងដោយធម៌ ដោយការខិតខំធ្វើការងារបម្រើគេបានមក ចេតនាបរិសុទ្ធទាំង ៣ កាល ព្រះបច្ចេកពុទ្ធដែលចេញចាកសមាបត្តិ ដែលក្រៃលែងដោយគុណ សម្រេចហើយដល់នាយកត្តកត្តិកៈនេះ ។ ដោយអានុភាពនៃសម្បទាទាំង ៤ នេះ ទើបនាយកត្តកត្តិកៈបានទទួលមហាសម្បត្តិក្នុងបច្ចុប្បន្ន ព្រោះដូច្នោះ នាយកត្តកត្តិកៈនោះ ទើបបានសម្បត្តិអំពីសម្នាក់គន្ធសេដ្ឋី ។

ក៏ក្នុងកាលតមក សូម្បីព្រះរាជាទ្រង់បានស្តាប់នូវកម្ម ដែលនាយកត្ត-កត្តិកៈនោះបានធ្វើហើយ ទ្រង់បានត្រាស់ឲ្យហៅនាយកត្តកត្តិកបុរសចូលមកគាល់ ហើយព្រះរាជទានទ្រព្យឲ្យ ១.០០០ កហាបណៈ ដើម្បីទ្រង់ទទួលយកចំណែកបុណ្យ ទ្រង់មានព្រះហឫទ័យត្រេកអរ បានព្រះរាជទានភោគៈជាច្រើន ហើយព្រះរាជទាននូវតំណែងសេដ្ឋីឲ្យនាយកត្តកត្តិកៈ ។ នាយកត្តកត្តិកៈ មានឈ្មោះថា **កត្តកត្តិកសេដ្ឋី** ។ កត្តកត្តិកសេដ្ឋីនោះ ជាសម្លាញ់នឹងគន្ធសេដ្ឋី នៅជាមួយគ្នា តាំងនៅរហូតអស់អាយុ ចុតិចាកអត្តភាពនោះហើយ ក៏បានបដិសន្ធិក្នុងទេវលោក សោយសម្បត្តិទិព្វអស់មួយចន្លោះព្រះពុទ្ធ មកដល់ក្នុងពុទ្ធុប្បាទកាលនេះ បានបដិសន្ធិក្នុងត្រកូលឧបដ្ឋាករបស់ព្រះសារីបុត្រ ក្នុងក្រុង

សាវត្ថី ។

## នាយភត្តភតិកៈនៅកើតក្នុងក្រុងសាវត្ថី

គ្រានោះ មាតារបស់ទារកនោះ បានគភ៌រក្សាហើយ កន្លងទៅ ២-៣ ថ្ងៃប៉ុណ្ណោះ ក៏កើតចំណង់ (ចាញ់គភ៌) ថា "ឱហ្ន៎! យើងគប្បីប្រគេនភោជនមានរសមួយរយមុខ ដល់ព្រះសារីបុត្រព្រមទាំងភិក្ខុ ៥០០ ហើយស្លៀកសំពត់កាសាយៈ កាន់ផ្តិលមាសអង្គុយក្នុងទីបំផុតនៃអាសនៈរបស់ភិក្ខុទាំង ៥០០ រូបនោះ គប្បីបរិភោគភត្តដែលសល់អំពីភិក្ខុទាំងនោះ" ដូច្នេះហើយ ក៏បានធ្វើតាមការគិតនោះឯង ទើបបន្ទោបង់ចំណង់បាន ។ សូម្បីក្នុងកាលមង្គលដទៃៗ នាងក៏ថ្វាយដូច្នោះ ប្រសូតបុត្រហើយ ក្នុងថ្ងៃដាក់ឈ្មោះឲ្យបុត្ររបស់ខ្លួន បាននិមន្តព្រះថេរៈថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ឲ្យសិក្ខាបទដល់កូនប្រុសរបស់ខ្ញុំចុះ" ។ ព្រះថេរៈសួរថា "ក្មេងនេះឈ្មោះអ្វី" មាតារបស់ក្មេងនោះប្រាប់ថា "លោកម្ចាស់ដ៏ចម្រើន ចាប់តាំងពីកូនប្រុសរបស់ខ្ញុំ បដិសន្ធិមកកាលណា ដែលឈ្មោះថាទុក្ខ មិនធ្លាប់កើតមានដល់នរណាដែលនៅក្នុងផ្ទះនេះឡើយ ព្រោះហេតុនោះ ពាក្យថា **សុខកុមារ** នេះ ជាឈ្មោះរបស់ទារកនោះ" ។ ព្រះសារីបុត្របានកាន់យកឈ្មោះនោះឯង ឲ្យជាឈ្មោះរបស់ក្មេងនោះ ហើយឲ្យសិក្ខាបទដល់ក្មេងនោះ ។ ក្នុងកាលនោះ ការគិតបានកើតដល់មាតារបស់ក្មេងនោះថា "យើងមិនទម្លាយអធ្យាស្រ័យរបស់កូនប្រុសយើងទេ ។ សូម្បីក្នុងកាលមង្គលទាំងឡាយ មានកាលចោះត្រចៀកក្មេងនោះជាដើម នាង

ក៏បានថ្វាយទាន យ៉ាងនោះដូចគ្នា ។

ចំណែកកុមារ ក្នុងវេលាមានអាយុ ៧ ខួប ក៏និយាយថា "អ្នកម៉ែ ខ្ញុំប្រាថ្នាបួសក្នុងសម្នាក់ព្រះថេរៈ" ។ នាងឆ្លើយថា "ប្រពៃណាស់កូន ម៉ែនឹងមិនទម្លាយអធ្យាស្រ័យរបស់កូនទេ" លុះពោលដូច្នេះហើយ ក៏ទៅនិមន្តព្រះថេរៈមកឆាន់ក្នុងផ្ទះរបស់ខ្លួន ហើយប្រាប់ព្រះថេរៈថា "លោកម្ចាស់ដ៏ចម្រើន កូនប្រុសរបស់ខ្ញុំព្រះករុណាប្រាថ្នាបួស វេលារសៀល ខ្ញុំព្រះករុណានឹងនាំក្មេងនេះទៅកាន់វិហារ" បញ្ជូនព្រះថេរៈទៅហើយ បានឲ្យប្រជុំពួកញាតិ ពោលថា "ក្នុងពេលដែលកូនប្រុសរបស់ខ្ញុំនៅជាគ្រហស្ថ ពួកយើងនឹងធ្វើកិច្ចដែលគួរធ្វើក្នុងថ្ងៃនេះឯង" រួចតាក់តែងកូនប្រុស នាំទៅវិហារ ដោយសិរីសោភាគដ៏ធំ ហើយប្រគល់ឲ្យព្រះថេរៈ ។ ចំណែកព្រះថេរៈពោលនឹងសុខកុមារនោះថា "នែបា! ធម្មតា បព្វជ្ជាធ្វើបានដោយលំបាក អ្នកនឹងអាចបួសបានឬ" សុខកុមារឆ្លើយថា "លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណានឹងធ្វើតាមឱវាទរបស់លោកម្ចាស់" លុះកុមារនោះពោលដូច្នោះ ព្រះថេរៈក៏ឲ្យកម្មដ្ឋាន ឲ្យបួសហើយ ។ សូម្បីមាតាបិតាសុខកុមារនោះ កាលធ្វើសក្ការៈក្នុងការបព្វជ្ជា ក៏ថ្វាយភោជនមានរស ១០០ មុខ ចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ខាងក្នុងវិហារនោះឯង រហូត ៧ ថ្ងៃ ក្នុងវេលារសៀល ទើបទៅកាន់ផ្ទះរបស់ខ្លួន ។ ក្នុងថ្ងៃទី ៥ ព្រះសារីបុត្រ កាលភិក្ខុសង្ឃចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត បានធ្វើនូវកិច្ចដែលគួរក្នុងវិហារហើយ ទើបឲ្យសាមណេរកាន់បាត្រ និងចីវរចូលទៅ

កាន់ស្រុកដើម្បីបិណ្ឌបាត ។

## សាមណេរទូន្មានខ្លួន

សាមណេរឃើញដូចជាទឹកជាដើមក្នុងរវាងផ្លូវ បានសួរព្រះថេរៈ ដូចបណ្ឌិតសាមណេរដែរ សូម្បីព្រះថេរៈក៏ឆ្លើយតបនឹងសំណួររបស់សាមណេរ សាមណេរស្តាប់ហេតុនោះហើយ ពោលនឹងព្រះថេរៈថា "បើលោកម្ចាស់ទទួលបាត្រ និងចីវររបស់លោកម្ចាស់សោត ខ្ញុំព្រះករុណានឹងត្រឡប់" ព្រះថេរៈមិនទម្លាយអធ្យាស្រ័យរបស់សាមណេរនោះ ពោលថា "អ្នកចូរឲ្យបាត្រ និងចីវរមកខ្ញុំវិញ" ប្រគល់បាត្រ និងចីវរទៅព្រះថេរៈ ហើយថ្វាយបង្គំព្រះថេរៈ មុននឹងត្រឡប់វិញបានពោលថា "លោកម្ចាស់ បើលោកម្ចាស់នាំអាហារមកដើម្បីខ្ញុំព្រះករុណា សូមលោកម្ចាស់នាំភោជនដែលមានរស ១០០ មុខមក ។

ព្រះថេរៈ. នឹងបានភោជននោះអំពីទីណា ?

សាមណេរ. បពិត្រលោកម្ចាស់ដ៏ចម្រើន បើមិនបានដោយបុណ្យរបស់លោកម្ចាស់ទេ គង់នឹងបានដោយបុណ្យរបស់ខ្ញុំព្រះករុណាដែរ ។

គ្រានោះ ព្រះថេរៈឲ្យកូនសោទៅសាមណេរ ហើយក៏ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ សាមណេរនោះទៅកាន់វិហារ បើកបន្ទប់របស់ព្រះថេរៈ ចូលទៅខាងក្នុងបន្ទប់ហើយ បិទទ្វារ អង្គុយញុំាងញាណចុះក្នុងកាយរបស់ខ្លួន ដោយតេជះនៃគុណរបស់សាមណេរនោះ អាសនៈរបស់សក្កទេវរាជក៏សម្តែងអាការក្តៅ ។ សក្កទេវរាជពិចារណាមើលថា "តើមានហេតុអ្វីហ្ន៎" ពិចារណា

ទៅក៏ឃើញសាមណេរ ទ្រង់មានព្រះតម្រិះថា "សុខសាមណេរប្រគេនចីវរដល់ឧបជ្ឈាយ៍ហើយ ត្រឡប់មកកាន់វិហារវិញ ដោយគិតថា នឹងធ្វើសមណធម៌" យើងគួរទៅកាន់ទីនោះ ទើបត្រាស់ឲ្យហៅមហារាជទាំង ៤ មក ហើយទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា "ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយចូរទៅបន្អើលបក្សីដែលមានសំឡេងជាទោស នៅក្នុងព្រៃជិតវិហារឲ្យចេញទៅ" ។ មហារាជទាំង ៤ ធ្វើដូច្នោះហើយ ក៏នាំគ្នារក្សាដោយជុំវិញ ។ សក្កទេវរាជទ្រង់ត្រាស់បង្គាប់ចន្ទទេវបុត្រ និងសុរិយទេវបុត្រថា "ពួកអ្នក ចូរទប់វិមានរបស់ខ្លួនៗ" ។ សូម្បីចន្ទទេវបុត្រ និងសុរិយទេវបុត្រក៏ធ្វើដូច្នោះ ។ ចំណែកព្រះអង្គខ្លួនឯង ក៏ទ្រង់រក្សានៅក្នុងទីជាទីទាញមកនូវខ្សែយោល (ខ្សែទប់) ។ វិហារជាប្រទេសស្ងប់ស្ងាត់ប្រាសចាកសំឡេង ។ សាមណេរមានចិត្ត មានអារម្មណ៍តែមួយ ចម្រើនវិបស្សនា បានចាក់ធ្លុះនូវមគ្គ និងផល ៣ ហើយ ។

ព្រះថេរៈកាលសាមណេរពោលថា "លោកម្ចាស់ គប្បីនាំភោជនមានរស ១០០ មុខមក" ដូច្នេះហើយ ក៏គិតថា "យើងនឹងបានអំពីត្រកូលរបស់នរណាហ្ន៎" ពិចារណាមើលទៅ ក៏ឃើញត្រកូលឧបដ្ឋាកដែលសម្បូណ៌ដោយអធ្យាស្រ័យ ក៏ទៅកាន់ត្រកូលនោះ ជនទាំងនោះឃើញ ព្រះថេរៈនិមន្តមកកាន់ត្រកូលរបស់ខ្លួន ក៏មានចិត្តត្រេកអរថា "លោកម្ចាស់ដ៏ចម្រើន ការដែលលោកម្ចាស់និមន្តមកកាន់ផ្ទះនេះ ជាការប្រពៃណាស់" ទទួលយកបាត្រហើយ និមន្តឲ្យគង់ ប្រគេនយាគូ និងបន្អែមដល់ព្រះថេរៈឆាន់ ហើយអារាធនាព្រះថេរៈឲ្យ

សម្ដែងធម្មកថា ទម្រាំដល់កាលនៃភត្ត ព្រះថេរៈក៏សម្ដែងនូវសារាណីយកថា ដល់ជនទាំងនោះ កំណត់កាលវេលាហើយ ក៏បញ្ចប់ធម៌ទេសនា ។

## សុខសាមណេរបានសម្រេចព្រះអរហត្ត

គ្រានោះ ជនទាំងឡាយប្រគេនភោជនដែលមានរស ១០០ មុខ ដល់ព្រះថេរៈ ឃើញព្រះថេរៈទទួលភោជននោះហើយ បំណងនឹងត្រឡប់ទៅ ក៏ពោលថា "លោកម្ចាស់ដ៏ចម្រើន សូមនិមន្តឆាន់ចុះ ពួកខ្ញុំព្រះករុណានឹងប្រគេនភោជនដទៃទៀត" និមន្តព្រះថេរៈឲ្យឆាន់ហើយ ដាក់ភោជនដែលមានរស ១០០ មុខ ពេញក្នុងបាត្រ ហើយប្រគេនព្រះថេរៈម្ដងទៀត ។ ព្រះថេរៈទទួលភោជននោះហើយ ក៏ប្រញាប់ទៅកាន់វិហារ ដោយគិតថា "សាមណេររបស់យើងឃ្លានហើយ" ។ ថ្ងៃនោះ ព្រះសាស្ដាស្ដេចចេញប្រថាប់គង់ក្នុងព្រះគន្ធកុដិពីព្រលឹម ទ្រង់រំពឹងថា "ថ្ងៃនេះ សុខសាមណេរឲ្យបាត្រ ចីវរទៅឧបជ្ឈាយ៍របស់ខ្លួនហើយត្រឡប់ ដោយតាំងចិត្តថា នឹងធ្វើសមណធម៌ កិច្ចរបស់គេបានសម្រេចហើយឬ" ព្រះអង្គទ្រង់ឃើញសាមណេរសម្រេចមគ្គផលត្រឹមតែ ៣ ប៉ុណ្ណោះ ទើបទ្រង់ពិចារណាតទៅទៀតថា "តើសាមណេរនេះ អាចបានសម្រេចអរហត្តក្នុងថ្ងៃនេះទេ ចំណែកសារីបុត្រទទួលភត្តហើយ ក៏ប្រញាប់មកកាន់វិហារ ដោយគិតថា សាមណេររបស់យើងឃ្លានហើយ" កាលបើសាមណេរនេះ មិនទាន់បានសម្រេចព្រះអរហត្ត សារីបុត្រនឹងនាំភត្តមកមុន អន្តរាយក៏នឹងមានដល់សាមណេរនោះ ដូច្នេះ តថាគតគួរទៅកាន់ទីនោះ ដើម្បីរក្សាគេ នៅត្រង់ខ្លោង

ទ្វារ ។ ចំណែកព្រះថេរៈក៏នាំភត្តមក ។ គ្រានោះ ព្រះសាស្តាត្រាស់សួរបញ្ហា ៤ ប្រការ ដោយន័យដូចដែលបានពោលហើយក្នុងកាលមុន ។ ក្នុងទីបំផុតនៃការវិសជ្ជនាបញ្ហា សាមណេរក៏បានសម្រេចអរហត្ត ។

ព្រះសាស្តាទ្រង់ត្រាស់ហៅព្រះថេរៈមក ហើយត្រាស់ថា "ម្នាលសារីបុត្រ អ្នកចូរទៅចុះ ចូរឲ្យភត្តដល់សាមណេររបស់អ្នកចុះ" ។ ព្រះថេរៈទៅដល់កុដិហើយ គោះទ្វារ ។ សាមណេរចេញមកធ្វើវត្តចំពោះឧបជ្ឈាយ៍ កាលព្រះថេរៈប្រាប់ថា "ចូរធ្វើភត្តកិច្ចចុះ" សាមណេរដែលមានអាយុ ៧ ខួប បានសម្រេចព្រះអរហត្តក្នុងខណៈនោះឯង បានដឹងថា ព្រះថេរៈមិនត្រូវការភត្ត ក៏ពិចារណារកមើលទីអង្គុយដែលទាប ធ្វើភត្តកិច្ចហើយ ក៏លាងបាត្រ ។ ក្នុងកាលនោះ មហារាជទាំង ៤ អង្គ ក៏បានលើកការរក្សា ។ សូម្បីចន្ទទេវបុត្រនិងសុរិយទេវបុត្រ ក៏លើកការទប់វិមាន ។ សក្កទេវរាជ ក៏ទ្រង់លែងរក្សាខ្សែទប់ ព្រះអាទិត្យក៏រះជ្រេហើយ ។

ភិក្ខុទាំងឡាយ នាំគ្នានិយាយថា "ពេលល្ងាចរមែងប្រាកដ សាមណេរទើបតែធ្វើភត្តកិច្ចហើយ អម្បាញមិញនេះឯង ហេតុអ្វី ថ្ងៃនេះពេលព្រឹកយូរម្ល៉េះរសៀលឆាប់" ។ ព្រះសាស្តាស្តេចមក ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វី" ភិក្ខុទាំងនោះទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះ វេលាព្រឹកយូរ វេលារសៀលឆាប់ សាមណេរទើបនឹងឆាន់

កត្តុហើយអម្បាញមិញនេះឯង ព្រះអាទិត្យក៏ជ្រេទៅ" ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលធ្វើសមណធម៌របស់អ្នកមានបុណ្យទាំងឡាយ រមែងដូច្នោះឯង ក៏ក្នុងថ្ងៃនេះ មហារាជទាំង ៤ រក្សាដោយជុំវិញ ចន្ទទេវបុត្រ និងសុរិយទេវបុត្របានឈរទប់វិមាន សក្កទេវរាជទ្រង់រក្សានូវខ្សែទប់ សូម្បីតថាគតក៏រក្សានៅត្រង់ខ្លោងទ្វារ ថ្ងៃនេះ សុខសាមណេរឃើញអ្នកស្រែបង្ហូរទឹកចូលប្រឡាយ ជាងព្រួញពត់ព្រួញឲ្យត្រង់ ជាងចាំងៗ ទព្វសម្ភារៈទាំងឡាយ មានកង់ជាដើម ហើយទូន្មានខ្លួន បានសម្រេចព្រះអរហត្ត ទើបត្រាស់ព្រះគាថានេះថា ៖

១១.ឧទកំ ហិ នយន្តិ នេត្តិកា ឧសុការា នមយន្តិ តេជនំ
ទារុំ នមយន្តិ តច្ឆកា អត្តានំ ទមយន្តិ សុព្វតា ។

ធម្មតាអ្នកបង្ហូរ តែងបង្ហូរទឹក អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់)
អ្នកចាំង តែងចាំងឈើ អ្នកមានវត្តល្អ តែងទូន្មានខ្លួន ។

## អធិប្បាយគាថា

បណ្តាពាក្យទាំងនោះ ពាក្យថា សុព្វតា (អ្នកប្រដៅងាយទាំងឡាយ) សេចក្តីថា ប្រដៅងាយ គឺ គប្បីឲ្យឱវាទ គប្បីឲ្យអនុសាសន៍ ដោយស្រួល ។ បទដ៏សេស មានដូចន័យដែលពោលហើយក្នុងកាលមុននោះឯង ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ

មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងសុខសាមណេរ

## ចប់ទណ្ឌវគ្គវណ្ណនា វគ្គទី ១០

ក្នុងវគ្គនេះរួមមាន ១១ រឿង


១.រឿងភិក្ខុឆព្វគ្គិយៈ ២. រឿងភិក្ខុឆព្វគ្គិយៈ
៣.រឿងក្មេងច្រើននាក់ ៤. រឿងព្រះកោណ្ឌធានត្ថេរ
៥.រឿងឧបោសថកម្ម ៦.រឿងអជគរប្រេត
៧.រឿងព្រះមហាមោគ្គល្លាន ៨.រឿងភិក្ខុមានភណ្ឌៈច្រើន
៩.រឿងសន្តតិមហាមាត្យ ១០.រឿងព្រះបោតិកត្ថេរៈ
១១.រឿងសុខសាមណេរ

# ជរាវគ្គ ទី ១១

"ពោលអំពីវត្ថុដែលគ្រាំគ្រាជរា"

## ១. រឿងស្ត្រីជាសំឡាញ់នាងវិសាខា

**[២១]** *ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកស្ត្រីជាសម្លាញ់របស់នាងវិសាខា ត្រាស់ព្រះធម្មទេសនា នេះថា* ***កោ នុ ហាសោ កិមានន្ទោ*** *(ពួកអ្នកទាំងឡាយ ម្តេចក៏សើច ម្តេចក៏ត្រេកអរ)* ជាដើម ។

### ស្វាមីប្រគល់កិរិយារបស់ខ្លួនឱ្យនាងវិសាខា

*ដូចបានស្តាប់មក កុលបុត្រ ៥០០ នាក់ នៅក្នុងនគរសាវត្ថី បានប្រគល់កិរិយារៀងៗ ខ្លួន ឲ្យមហាឧបាសិកាវិសាខា ដោយគិតឃើញថា ដោយឧបាយយ៉ាងនេះ កិរិយារបស់ខ្លួននឹងជាអ្នករស់នៅដោយសេចក្តីមិនប្រមាទ ។ ព្រោះថា ស្ត្រីទាំងនោះ កាលទៅសួនក្តី ទៅវិហារក្តី តែងតែទៅជាមួយនាងវិសាខាជានិច្ច ។*

*សម័យមួយ កាលគេប្រកាសមហោស្រពថា នឹងមានមហោស្រពទាក់ទងនឹងសុរា ៧ ថ្ងៃ ស្ត្រីទាំងនោះក៏ចាត់ចែងរៀបចំសុរាដើម្បីស្វាមីរៀងៗ ខ្លួន ស្វាមីទាំងនោះ លេងមហោស្រពទាក់ទងនឹងសុរាអស់ ៧ ថ្ងៃ ដល់ថ្ងៃទី ៨ បានចេញទៅធ្វើការងារ (រៀងៗ ខ្លួន) ។*

## ស្ត្រីទាំងនោះគិតរកឧបាយផឹកស្រា

ស្ត្រីទាំងនោះ គិតគ្នាថា ពួកយើងមិនបានផឹកសុរាក្នុងទីចំពោះមុខស្វាមី សុរាក៏នៅមានសល់ដែរ ពួកយើងនឹងផឹកសុរាដោយកុំឲ្យស្វាមីរបស់យើងដឹង លុះគិតដូច្នេះហើយ ក៏ទៅកាន់សម្នាក់នាងវិសាខា ពោលប្រាប់នាងវិសាខាថា "ម៉ែម្ចាស់ ពួកខ្ញុំប្រាថ្នានឹងកំសាន្តសួន" កាលនាងវិសាខាប្រាប់ថា "ម្នាលនាងទាំងឡាយ ប្រពៃហើយ បើដូច្នោះ ចូរនាងទាំងឡាយ ធ្វើកិច្ចដែលគប្បីធ្វើឲ្យស្រេចហើយ សឹមចេញទៅ" លុះធ្វើកិច្ចការដែលគប្បីធ្វើស្រេចហើយ ក៏បានទៅកាន់សួនជាមួយនាងវិសាខា ដោយនាំយកសុរាទៅជាមួយ ទាំងមិនឲ្យនាងវិសាខាដឹង ផឹករហូតស្រវឹងហើយ ត្រាច់ទៅកាន់សួន ។ នាងវិសាខា គិតថា "ស្ត្រីទាំងនេះធ្វើនូវអំពើមិនសមគួរ" គ្រានេះ សូម្បីតែពួកតិរ្ថិយ៍ក៏នឹងតិះដៀលបានថា "សាវិកាទាំងឡាយរបស់ព្រះសមណគោតមផឹកសុរា" ទើបពោលនឹងស្ត្រីទាំងនោះថា "នែនាងទាំងឡាយ ពួកនាងធ្វើនូវអំពើមិនសមគួរ ជាអំពើដ៏ថោកទាបផង ធ្វើឲ្យអាប់ឱនដល់ខ្ញុំផង សូម្បីស្វាមីរបស់នាងទាំងឡាយ ក៏នឹងខឹងពួកនាង ឥឡូវនេះ ពួកនាងនឹងធ្វើដូចម្តេច" ស្ត្រីទាំងនោះឆ្លើយតបថា "ម៉ែម្ចាស់ នាងខ្ញុំទាំងឡាយនឹងធ្វើពុតជាឈឺ" នាងវិសាខាក៏ពោលថា បើដូច្នោះពួកនាងនឹងប្រាកដដោយកម្មរបស់ខ្លួនចុះ" ។ ស្ត្រីទាំងនោះ ទៅដល់ផ្ទះហើយធ្វើពុតជាឈឺ ។ គ្រានោះ ស្វាមីរបស់ស្ត្រីទាំងនោះសួរថា "ស្ត្រីឈ្មោះនេះ

និងឈ្មោះនេះទៅណា" បានឮថា ស្ត្រីទាំងនោះឈឺ ក៏កំណត់បានថា ស្ត្រីទាំងនោះ ប្រាកដជាផឹកសុរាដែលសេសសល់ដោយពិត ទើបបានវាយស្ត្រីទាំងនោះយ៉ាងដំណំ ។ ក្នុងថ្ងៃមហោស្រពដទៃទៀត ស្ត្រីទាំងនោះ ចង់ផឹកសុរាទៀត ទើបចូលទៅរកមហាឧបាសិកាឈ្មោះវិសាខា ហើយពោលថា "ម៉ែម្ចាស់ មេត្តានាំពួកនាងខ្ញុំទៅកំសាន្តសួនម្ដងទៀតចុះ ត្រូវនាងវិសាខាហាមឃាត់ថា "លើកមុន នាងទាំងឡាយធ្វើឲ្យខ្ញុំអាប់ឱនម្ដងហើយ ដូច្នោះ នាងទាំងឡាយទៅខ្លួនឯងចុះ ខ្ញុំមិននាំនាងទាំងឡាយទៅទេ" ក៏បាននិយាយលួងលោមថា "ពួកខ្ញុំនឹងមិនធ្វើដូច្នោះទៀតទេ" ហើយចូលទៅរកឧបាសិកាវិសាខានោះ ពោលជាថ្មីថា "ម៉ែម្ចាស់ នាងខ្ញុំទាំងឡាយប្រាថ្នានឹងធ្វើពុទ្ធបូជា សូមនាំនាងខ្ញុំទាំងឡាយទៅវិហារចុះ" ។ នាងវិសាខាឮដូច្នោះ ក៏និយាយថា "នែនាងទាំងឡាយ ការដែលនាងទាំងឡាយធ្វើដូច្នោះ ជាការប្រពៃណាស់ ដូច្នោះ នាងទាំងឡាយចូរទៅរៀបចំខ្លួនចុះ" ។ ស្ត្រីទាំងនោះ ញ៉ាំងគ្នានិងគ្នាឲ្យកាន់យកវត្ថុទាំងឡាយមានគ្រឿងក្រអូប និងកម្រងផ្កាជាដើមដោយប្រអប់ទាំងឡាយ ដៃទាំងពីរយួរដបស្រា ដណ្ដប់សំពត់ផ្ទាំងធំចូលទៅរកនាងវិសាខា ហើយចូលទៅកាន់វិហារជាមួយនាងវិសាខា អង្គុយចំណែកម្ខាងផឹកសុរានោះ ហើយទម្លាក់ដបចោលអង្គុយចំពោះព្រះភក្ត្រព្រះសាស្ដាក្នុងធម្មសភា ។ នាងវិសាខាក្រាបទូលព្រះសម្មាសម្ពុទ្ធថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់សម្ដែងធម៌ដល់ស្ត្រី

ទាំងនេះ" ។ ចំណែកស្ត្រីទាំងនោះ មានខ្លួនញាប់ញ័រដោយកម្លាំងសុរា ញ៉ាំងចិត្តឲ្យកើតឡើងថា "ពួកយើងនឹងរាំ នឹងច្រៀង" ។

## ទេវបុត្តមារបណ្ដាលឱ្យសម្ដែងកាយវិការតែមិនសម្រេច

គ្រានោះ ទេវតាមួយអង្គដែលជាបក្សពួករបស់មារ គិតថា "ឥឡូវនេះ យើងនឹងជ្រែកចូលសរីរៈរបស់ស្ត្រីទាំងនេះ ហើយសម្ដែងអាការប្លែកៗ ចំពោះព្រះភក្ត្រព្រះសមណគោតម" លុះគិតដូច្នេះហើយ ក៏ជ្រែកចូលក្នុងសរីរៈរបស់ស្ត្រីទាំងនោះ បណ្ដាលឲ្យស្ត្រីទាំងនោះ ប្រុងទះដៃសើចខ្លះ ប្រុងនឹងរាំចំពោះព្រះភក្ត្រព្រះសាស្ដាខ្លះ ។ ព្រះសាស្ដាទ្រង់រំពឹងថា "រឿងនេះដូចម្ដេចហ្ន៎" ទ្រង់ជ្រាបហេតុនោះហើយ ទ្រង់ព្រះតម្រិះថា "ឥឡូវនេះ តថាគតនឹងមិនឲ្យទេវតាដែលជាបក្ខពួករបស់មារបានឱកាសឡើយ ព្រោះតថាគតបំពេញបារមី អស់កាលប្រមាណប៉ុណ្ណេះ មិនមែនដើម្បីបើកឱកាសឲ្យទេវតាដែលជាបក្ខពួករបស់មារទេ បំពេញមកដើម្បីនឹងឲ្យស្ត្រីទាំងនោះសង្វេគ" ទើបទ្រង់បញ្ចេញព្រះរស្មីអំពីព្រះឧណ្ណាលោម ខណៈឯង ភាពងងឹតមហន្ធការ ក៏បានប្រាកដឡើង ។ ស្ត្រីទាំងនោះភ័យខ្លាច ត្រូវមរណភ័យគម្រាម សុរាក្នុងពោះរបស់ពួកនាងក៏ទ្រោមអស់ ។ ព្រះសាស្ដាទ្រង់បាត់អំពីបល្ល័ង្កទៅប្រថាប់ឈរនៅលើកំពូលសិនេរុ ទ្រង់បញ្ចេញព្រះរស្មីអំពីព្រះឧណ្ណាលោម ។ ខណៈនោះ ពន្លឺបានប្រាកដឡើងដូចព្រះច័ន្ទរះឡើងរាប់ពាន់ដួងដូច្នោះ ។ គ្រានោះ ព្រះសាស្ដាត្រាស់ហៅស្ត្រី

ទាំងនោះមកហើយ ត្រាស់ថា "ពួកនាងមកកាន់សម្នាក់របស់តថាគតដោយសេចក្ដីប្រមាទយ៉ាងនេះ មិនសមគួរឡើយ ទេវតាដែលជាបក្ខពួករបស់ពួកមារបានឱកាស ក៏ដោយសារតែសេចក្ដីប្រមាទរបស់ពួកនាងហ្នឹងឯង ញ៉ាំងពួកនាងឲ្យធ្វើនូវអាការទាំងឡាយ មានសើចជាដើម ក្នុងទីដែលមិនគួរធ្វើនូវអាការទាំងឡាយ មានការសើចជាដើម ការដែលនាងទាំងឡាយធ្វើនូវការខ្នះខ្នែងដើម្បីញ៉ាំងភ្លើងទាំងឡាយ មានភ្លើង គឺ រាគៈជាដើមឲ្យរលត់ ក្នុងកាលឥឡូវនេះ ទើបគួរ" ហើយត្រាស់ព្រះគាថានេះថា ៖

កោ នុ ហាសោ កិមានន្ទោ និច្ចំ បជ្ជលិតេ សតិ
អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ ។

កាលបើលោកសន្និវាស ត្រូវភ្លើង មានរាគៈជាដើម ឆេះ
ទ្រលោមជានិច្ច ម្ដេចក៏សើច ម្ដេចក៏ត្រេកត្រអាល អ្នកទាំង
ឡាយត្រូវងងឹត គឺ អវិជ្ជារួបរឹតហើយ (ម្ដេចឡើយ) ក៏មិន
ស្វែងរកប្រទីប គឺ ប្រាជ្ញា ។

អធិប្បាយគាថា

សេចក្ដីត្រេកអរ ឈ្មោះថា អានន្ទោ (សេចក្ដីត្រេកត្រអាល) ក្នុងព្រះគាថានោះ ។ ព្រះមានព្រះភាគជាម្ចាស់ត្រាស់អធិប្បាយទុកថា "កាលបើលោកសន្និវាសនេះ ត្រូវភ្លើង ១១ យ៉ាង មានរាគៈជាដើម ឆេះសន្ធោសន្ធៅអស់កាលជានិច្ច ម្ដេចក៏ពួកនាងខំប្រឹងសើចសប្បាយទៅវិញ អាការសើចជា

ដើមនោះ មិនសមគួរធ្វើឡើយ ពួកនាងត្រូវងងឹត គឺ អវិជ្ជា មានវត្ថុ ៨ រួបរឹតហើយ ម្ដេចឡើយក៏មិនស្វែងរក គឺ មិនធ្វើប្រទីប គឺ ញាណ ដើម្បីប្រយោជន៍ដល់ការកម្ចាត់បង់នូវភាពងងឹតនោះចេញ" ។

នាងវិសាខាបង្ហាញទោសសុរា ដោយបុគ្គលាធិដ្ឋាន

ក្នុងកាលចប់ព្រះធម្មទេសនា ស្ត្រីទាំង ៥០០ នាក់នោះ តាំងនៅក្នុងសោតាបត្តិផល ។ ព្រះសាស្ដា ទ្រង់ជ្រាបភាវៈនៃស្ត្រីទាំងនោះ ជាអ្នកតាំងមាំក្នុងអចលសទ្ធាហើយ ស្ដេចចុះចាកកំពូលភ្នំសិនេរុ ទ្រង់គង់លើពុទ្ធាសនៈ ។

គ្រានោះ នាងវិសាខាបានក្រាបទូលព្រះពុទ្ធអង្គថា "បពិត្រព្រះអង្គដ៏ចម្រើន សុរានេះជារបស់ដ៏លាមក ត្បិតថា ស្ត្រីទាំងនេះ មានសភាពបែបនេះ អង្គុយចំពោះព្រះភក្ត្រនៃព្រះពុទ្ធដូចព្រះអង្គ មិនអាចរក្សាសូម្បីត្រឹមតែឥរិយាបថឲ្យរៀបរយបាន ក្រោកឡើងទះដៃ ធ្វើការសើចសប្បាយ ច្រៀង និងរាំជាដើម" ។ ព្រះសាស្ដាត្រាស់ថា "យ៉ាងហ្នឹងឯងវិសាខា សុរានេះ ជារបស់លាមកដោយពិត ព្រោះប្រជាជនអាស្រ័យសុរានេះ ដល់សេចក្ដីវិនាសយ៉ាងច្រើន" កាលនាងវិសាខាក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ចុះសុរានេះកើតឡើងតាំងពីកាលណាមក" ដើម្បីនឹងត្រាស់ឧប្បត្តិហេតុនៃសុរានោះ ដល់នាងវិសាខាឲ្យពិស្ដារ ទើបទ្រង់នាំអតីតនិទានមកហើយ ត្រាស់កុម្ភជាតក" ។

ចប់ រឿងស្ត្រីជាសម្លាញ់របស់នាងវិសាខា

# ២. រឿងនាងសិរិមា

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនាងសិរិមា ត្រាស់ព្រះធម្មទេសនានេះថា *បស្ស ចិត្តកតំ ពិម្ពំ (អ្នកចូរមើលអត្តភាព... ដែលកម្មធ្វើទុកឲ្យវិចិត្រហើយ)* ជាដើម ។

នាងសិរិមាសម្រេចសោតាបត្តិផល

ដូចបានស្តាប់មក នាងសិរិមានោះ ជាស្ត្រីគណិកា មានរូបល្អឆើតនៅក្រុងរាជគ្រឹះ ខាងក្នុងវស្សាមួយ បានប្រទូស្តចំពោះនាងឧត្តរា ដែលជាធីតារបស់បុណ្ណកសេដ្ឋី ជាភរិយារបស់សុមនសេដ្ឋីបុត្រ បំណងនឹងឲ្យនាងឧត្តរានោះជ្រះថ្លា ទើបសូមខមាទោសព្រះសាស្តា នៅពេលដែលព្រះអង្គទ្រង់ធ្វើភត្តកិច្ចជាមួយភិក្ខុសង្ឃស្រេចហើយ ក្នុងរឿងរបស់នាងឧត្តរានោះ ក្នុងថ្ងៃនោះនាងបានស្តាប់ភត្តានុមោទនារបស់ព្រះទសពល ក៏បានសម្រេចសោតាបត្តិផល ក្នុងវេលាចប់ព្រះគាថា ថា ៖

*គប្បីឈ្នះមនុស្សក្រោធ ដោយសេចក្តីមិនក្រោធ គប្បីឈ្នះមនុស្សមិនល្អ ដោយសេចក្តីល្អ គប្បីឈ្នះមនុស្សកំណាញ់ ដោយការឲ្យ គប្បីឈ្នះមនុស្សនិយាយឡេះឡោះ ដោយពាក្យពិត ។*

នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ។ ចំណែកសេចក្តីពិស្តារ នឹងជាក់

ច្បាស់ក្នុងអដ្ឋកថា នៃអដ្ឋកថាអនុមោទនា ក្នុងកោធវគ្គនោះឯង ។

នាងសិរិមានោះ លុះបានសម្រេចសោតាបត្តិផលដូច្នេះហើយ ក៏យាងព្រះទសពល ដើម្បីថ្វាយមហាទាន ក្នុងថ្ងៃស្អែក ហើយបានតាំងនូវអដ្ឋកភត្ត (ភត្តសម្រាប់ភិក្ខុ ៨ រូប) ដើម្បីព្រះសង្ឃជាប្រចាំ ។ តាំងពីថ្ងៃនោះមក ភិក្ខុ ៨ រូប និមន្តទៅកាន់ផ្ទះនាងជានិច្ច ។ នាងពោលថា "និមន្តលោកម្ចាស់ទាំងឡាយ ទទួលទឹកដោះថ្លា ទទួលទឹកដោះស្រស់ជាដើម" ហើយតែងដាក់ភត្តពេញៗ បាត្ររបស់ភិក្ខុទាំងនោះ ។ អាហារបិណ្ឌបាត ដែលភិក្ខុមួយរូបបានហើយ ល្មមដល់ភិក្ខុ ៣ រូបខ្លះ ៤ រូបខ្លះ ។ នាងប្រគេនបិណ្ឌបាត ដោយចំណាយទ្រព្យអស់ ១៦ កហាបណៈរាល់ៗ ថ្ងៃ ។ ថ្ងៃមួយ ភិក្ខុមួយអង្គបានអដ្ឋកភត្តរបស់នាងហើយ ទៅកាន់វិហារមួយ ក្នុងទីប្រមាណ ៣ យោជន៍ គ្រានោះ ពួកភិក្ខុសួរលោកដែលអង្គុយនៅក្នុងទីបម្រើព្រះថេរៈ ក្នុងវេលារសៀលថា "អ្នកមានអាយុ (ទៅ) ទទួលភិក្ខាអំពីទីណាមក" លោកឆ្លើយថា "ខ្ញុំទៅបានអដ្ឋកភត្តរបស់នាងសិរិមា" ។ ពួកភិក្ខុសួរទៀតថា "អ្នកមានអាយុ នាងធ្វើរបស់ដែលពេញចិត្តប្រគេនឬ"

## ភិក្ខុពណ៌នាសេចក្ដីល្អរបស់នាងសិរិមា

ភិក្ខុនោះ ក៏ពោលគុណរបស់នាងថា "ខ្ញុំមិនអាចនឹងពណ៌នាភត្តរបស់នាងបានទេ នាងធ្វើនូវភត្តសែនប្រណីត ភត្តដែលភិក្ខុមួយរូបបាន អាចបានគ្រប់ល្មមដល់ភិក្ខុ ៣ រូបខ្លះ ៤ រូបខ្លះ មិនត្រឹមតែប៉ុណ្ណោះ ការបានឃើញនាង

នោះឯង ប្រសើរក្រៃលែងជាងទេយ្យធម៌របស់នាងទៅទៀត ព្រោះនាងស្រស់ស្អាតណាស់” ។ គ្រានោះ ភិក្ខុមួយរូបបានស្តាប់ការពណ៌នាគុណរបស់នាងសិរិមា ក៏កើតសេចក្តីស្រឡាញ់ឡើង ដោយមិនទាន់ទាំងបានឃើញខ្លួននាងផង (លោក) គិតថា “គួរតែយើងទៅមើលនាង” ហើយប្រាប់ចំនួនវស្សារបស់ខ្លួន រួចសួរលំដាប់នឹងភិក្ខុនោះ បានឮថា “អាវុសោ ព្រឹកនេះ លោកជាព្រះសង្ឃត្ថេរ នឹងបានអដ្ឋកកត្តក្នុងផ្ទះនោះ” ទើបប្រដាប់បាត្រ និងចីវរ ចេញទៅក្នុងខណៈនោះឯង អរុណរះឡើងស្រាងៗ ចូលទៅកាន់រោងភត្ត ឈររង់ចាំជាព្រះសង្ឃត្ថេរបានអដ្ឋកកត្តក្នុងផ្ទះរបស់នាង ។

ក៏ក្នុងវេលាដែលភិក្ខុនោះឆាន់ហើយ ចៀសចេញទៅ ក្នុងថ្ងៃម្សិលមិញនោះឯង រោគបានកើតឡើងក្នុងសរីរៈរបស់នាង ព្រោះហេតុនោះ ទើបនាងដោះគ្រឿងអាភរណៈចេញ ហើយដេក ។ គ្រានោះ ពួកទាសីរបស់នាងឃើញភិក្ខុទាំងឡាយអ្នកបានអដ្ឋកកត្តនិមន្តមក ក៏ប្រាប់នាង នាងមិនអាចទៅទទួលបាត្រ និមន្តឲ្យគង់ ឬអង្គាសដោយដៃរបស់ខ្លួនបាន ទើបបង្គាប់ពួកទាសីថា “នែនាងទាំងឡាយ ពួកនាងចូរទៅទទួលបាត្រ និមន្តលោកម្ចាស់ឲ្យគង់ហើយប្រគេនយាគូ បង្អែមដល់លោកម្ចាស់ទាំងឡាយឆាន់ចុះ ក្នុងវេលាភត្ត ចូរដាក់ភត្តឲ្យពេញបាត្រ ហើយប្រគេនចុះ” ។ ពួកទាសីទទួលថា “ចាំ ម្ចាស់ស្រី” ហើយនិមន្តភិក្ខុទាំងឡាយឲ្យចូលមក ប្រគេនយាគូ និងបង្អែមឲ្យភិក្ខុទាំងនោះឆាន់ ក្នុងវេលាភត្ត ដាក់ភត្តពេញបាត្រហើយ ទៅប្រាប់នាង ។ នាងពោលថា

"ចូរជួយគ្រាហ៍ខ្ញុំបន្តិច ខ្ញុំនឹងទៅថ្វាយបង្គំលោកម្ចាស់ទាំងឡាយ" ពួកនាងទាសីគ្រាហ៍នាងទៅជិតភិក្ខុទាំងនោះហើយ នាងថ្វាយបង្គំភិក្ខុទាំងនោះ ទាំងសរីរៈញញាក់ញញ័រ ។ ភិក្ខុនោះសំឡឹងមើលនាងហើយ គិតថា "ភាពស្រស់ស្អាតនៃរូបរបស់នាងដែលឈឺម្ល៉ឹងទៅហើយ ចំណាន់បើក្នុងកាលដែលនាងមិនមានរោគ ដែលប្រដាប់ដោយគ្រឿងអាភរណៈទាំងពួង នឹងប្រាកដដូចម្តេចទៅហ្ន៎" ។ គ្រានោះ កិលេសដែលលោកសន្សំទុកអស់កោដិឆ្នាំ ក៏បានផុសផុលឡើង ។ ភិក្ខុនោះ មិនមានចិត្តបែរទៅរកអារម្មណ៍ដទៃ (មានចិត្តមករកតែនាងប៉ុណ្ណោះ) កាលមិនអាចនឹងឆាន់អាហារបាន ទើបកាន់បាត្រត្រឡប់ទៅវិហារ បិទបាត្រទុកក្នុងកន្លែងមួយ ហើយក្រាលចីវរសិង ។ គ្រានោះ សូម្បីភិក្ខុជាសម្លាញ់របស់លោកមួយរូប អង្វរយ៉ាងណាក៏ដោយ ក៏មិនព្រមឆាន់ចង្ហាន់ដែរ ។ លោកសុខចិត្តដេកអត់អាហារ ។

## នាងសិរិមាដល់កម្មចាស់ (ស្លាប់)

ក្នុងវេលារសៀលថ្ងៃនោះឯង នាងក៏បានធ្វើកាលកិរិយាទៅ ។ ព្រះរាជាទ្រង់បញ្ជូនព្រះរាជសាសន៍ ទៅថ្វាយព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន នាងសិរិមាប្អូនស្រីរបស់ពេទ្យជីវកធ្វើមរណកាលហើយ" ។ ព្រះសាស្តាទ្រង់ស្តាប់នូវរឿងនោះហើយ ក៏ទ្រង់បញ្ជូនដំណឹងទៅថ្វាយព្រះរាជាថា "មហារាជកិច្ច គឺ ការដុតសពនាងសិរិមាមិនមាន សូមទ្រង់បញ្ជាឲ្យយកសាកសពនាងសិរិមានោះ ទៅតម្កល់ទុកក្នុងព្រៃដែលជាទីចោលសាកសពស្រស់ ហើយឲ្យ

រក្សាទុកដោយអាការដែលក្អែក និងស្អុនខ្ម ខាំស៊ីមិនបានចុះ" ។ ព្រះរាជា ក៏ទ្រង់បានធ្វើតាមព្រះតម្រាស់របស់ព្រះសាស្តា ។ បីថ្ងៃកន្លងទៅដោយលំដាប់ ក្នុងថ្ងៃទី ៤ សរីរៈក៏ហើមប៉ោង ។ ពួកដង្កូវវារចេញចាកមាត់ដំបៅទាំង ៩ ។ សរីរៈទាំងអស់បែកដូចបាយស្រូវសាលី ដូច្នោះ ។ ព្រះរាជាឲ្យរាជបុរសទូង ស្គរប្រកាសក្នុងព្រះនគរថា "វៀរតែពួកក្មេងៗ ដែលចាំផ្ទះចេញ អ្នកណាមិន មកមើលសាកសពនាងសិរិមា ត្រូវពិន័យ ៨ កហាបណៈ" ហើយបានបញ្ជូន ព្រះរាជសាសន៍ទៅកាន់សម្នាក់ព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន សូម ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន និមន្តមកមើលនាងសិរិមា" ។ ព្រះសាស្តា ទទួលហើយ ក៏ត្រាស់ឲ្យប្រាប់ដល់ភិក្ខុទាំងឡាយថា "យើងទាំងឡាយនឹងទៅ មើលនាងសិរិមា" ភិក្ខុកំលោះរូបនោះ មិនស្តាប់ពាក្យរបស់នរណាៗ ឡើយ ស្រុកចិត្តដេកអត់អាហាររហូត ៤ ថ្ងៃ ។ បាយក្នុងបាត្រផ្អូម ស្អិមតាំងឡើងក្នុង បាត្រ ។ លំដាប់នោះ ភិក្ខុជាសំឡាញ់នោះចូលទៅរកលោក ហើយប្រាប់ថា "អ្នកមានអាយុ ព្រះសាស្តាស្តេចទៅទតនាងសិរិមា" ។ ភិក្ខុនោះ សូម្បីត្រូវ សេចក្តីឃ្លានដុតរោលយ៉ាងនោះក៏ដោយ ក៏ក្រោកឡើងយ៉ាងរហ័ស ដោយគ្រាន់ តែឮពាក្យថា "សិរិមានោះឯង" សួរថា "អាវុសោ លោកនិយាយអ្វី" កាល ភិក្ខុដែលជាសម្លាញ់ប្រាប់ថា "ព្រះសាស្តា ស្តេចយាងទៅទតនាងសិរិមា លោក ទៅដែរឬទេ" ក៏ទទួលយ៉ាងរហ័សថា "ខ្ញុំទៅ" ចាក់បាយចោល លាងបាត្រ ប្រកក្នុងស្បោកហើយ និមន្តទៅកាន់ទីនោះជាមួយនឹងភិក្ខុសង្ឃ ។ ព្រះសាស្តា

មានពួកភិក្ខុចោមរោម ទ្រង់ប្រថាប់ឈរនៅចំណែកម្ខាង ។ ភិក្ខុនីសង្ឃក្តី រាជ-បរិស័ទក្តី ឧបាសកបរិស័ទក្តី ឧបាសិកាបរិស័ទក្តី ឈរនៅចំណែកម្ខាង ។

## សពនាងសិរិមាអស់សម្ផស្សរកតម្លៃមិនបាន

ព្រះសាស្តា ត្រាស់សួរព្រះរាជាថា “មហាបពិត្រ នរណាហ្នឹង”

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន ប្អូនស្រីរបស់ពេទ្យជីវក ឈ្មោះសិរិមា ។

ព្រះសាស្តា. នេះឬ នាងសិរិមា ?

ព្រះរាជា. ព្រះករុណា ព្រះអង្គ ។

ព្រះសាស្តា. បើដូច្នោះ សូមមហារាជត្រាស់ឲ្យរាជបុរសទូងស្គរប្រកាសក្នុងព្រះនគរថា “នរណាចង់បាននាងសិរិមា ឲ្យទ្រព្យមួយពាន់កហាបណៈមក ហើយចូរយកនាងសិរិមាចុះ” ។ ព្រះរាជាទ្រង់បានធ្វើដោយប្រការដូច្នោះ អ្នកដែលនិយាយថា “ខ្ញុំព្រះអង្គ ឬយើង សូម្បីតែម្នាក់ក៏មិនមាន” ។ ព្រះរាជាក្រាបទូលព្រះសាស្តាថា “បពិត្រព្រះអង្គដ៏ចម្រើន គ្មាននរណាទទួលយកទេ” ។ ព្រះសាស្តាត្រាស់ថា “បពិត្រមហារាជ បើដូច្នោះ ចូរត្រាស់ឲ្យបន្ថយតម្លៃ” ។ ព្រះរាជាត្រាស់ឲ្យទូងស្គរប្រកាសថា “នរណាចង់បាននាងសិរិមា ចូរឲ្យទ្រព្យ ៥០០ ហើយចូរយកចុះ” មិនឃើញមាននរណាៗ នឹងទទួលយក ទើបបង្គាប់ឲ្យទូងស្គរប្រកាសថា “នរណាចង់បាននាងសិរិមា ចូរឲ្យទ្រព្យ ២៥០-២០០-១០០-៥០-២៥ កហាបណៈ ១០-៥-១- កន្លះកហាបណៈ ១ បាទ ១ មាសកៈ

១ កាកណិក ហើយយកនាងសិរិមាចុះ” ក៏មិនឃើញមាននរណាយកទៅ ទើបត្រាស់ឲ្យទូងស្គរប្រកាសថា “ចូរយកទទេ ក៏បាន” ។ អ្នកដែលចេញស្តីថា “ខ្ញុំ ឬយើង សូម្បីតែម្នាក់ក៏មិនមាន” ។ ព្រះរាជាក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន អ្នកដែលទទួលយកសូម្បីទទេៗ ក៏មិនមានដែរ” ។ ទើបព្រះសាស្តាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមើលមាតុគ្រាម ដែលជាទីស្រឡាញ់របស់មហាជន កាលមុន ជនទាំងឡាយក្នុងនគរនេះឯង ឲ្យទ្រព្យមួយពាន់ហើយ ទើបបានអភិរម្យជាមួយនាងមួយថ្ងៃ ប៉ុន្តែឥឡូវនេះ សូម្បីតែឲ្យទទេ ក៏គ្មាននរណាយកដែរ រូបបែបនេះ ដល់ការអស់ទៅ និងសូន្យទៅហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមើលអត្តភាពដ៏ទុរទន់ទុរានេះចុះ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖

២. បស្ស ចិត្តកតំ ពិម្ពំ អរុកាយំ សមុស្សិតំ
អាតុរំ ពហុសង្កប្បំ យស្ស នត្ថិ ធុវំ ឋិតិ ។

អត្តភាពណា មិនទៀងទាត់ ឋិតថេរ អ្នកចូរមើលអត្តភាព (នោះ) ដែលកុសលាកុសលកម្ម ធ្វើវិចិត្រហើយ ជាកាយពាសពេញដោយដំបៅ ដែលឆ្អឹង ៣០០ កំណាត់ ផ្គុំគ្នាហើយ ជាអត្តភាពក្តៅក្រហាយជានិច្ច ជាទីរំពឹងត្រិះរិះ របស់ជនច្រើនគ្នា ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ចិត្តកតំ (ធ្វើឲ្យវិចិត្រហើយ)** សេចក្ដីថា មានការវិចិត្រ ដែលកម្មធ្វើហើយ គឺ ដែលបុគ្គលធ្វើឲ្យវិចិត្រដោយវត្ថុផ្សេងៗ មានអាភរណៈ មានសំពត់ និងគ្រឿងប្រដាប់ និងកម្រងផ្កាជាដើម ។ បទថា **ពិម្ពំ (អត្តភាព)** បានដល់ នូវអត្តភាពដែលតាំងព្រមដោយអវយវៈធំតូចទាំងឡាយ មានចំណែកវែងជាដើម ក្នុងទីដ៏សមគួរដល់អវយវៈវែងជាដើម ។ បទថា **អរុកាយំ (មានកាយជាដំបៅ)** គឺ មានកាយជាដំបៅ ដោយអំណាចមាត់ដំបៅទាំង ៩ ។ បទថា **សមុស្សិតំ (មានឆ្អឹងជាគ្រោង)** គឺ ដែលឆ្អឹង ៣០០ កំណាត់ផ្គុំផ្គុំឡើងហើយ ។ បទថា **អាតុរំ (ក្ដៅក្រហាយ)** សេចក្ដីថា ឈឺជានិច្ច ព្រោះជាការៈដែលត្រូវរក្សាដោយឥរិយាបថជាដើមគ្រប់ពេល ។ បទថា **ពហុសង្កប្បំ (ដែលមហាជនគិតចង់បានដោយច្រើន)** បានដល់ ដែលមហាជន ត្រូវការដោយច្រើន ។ បទថា **យស្ស នត្ថិ ធុវំ ឋិតិ (មិនទៀងទាត់មិនឋិតថេរ)** សេចក្ដីថា អ្នកទាំងឡាយចូរមើលអត្តភាពនេះ ដែលមិនមានការទៀង ឬឋិតថេរ មានការបែកធ្លាយ និងខ្ចាត់ខ្ចាយរាត់រាយទៅជាធម្មតាតែម្យ៉ាងប៉ុណ្ណោះ ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ធម្មាភិសម័យ (ការត្រាស់ដឹងធម៌) បានមានដល់សត្វ ៨៤.០០០ សូម្បីភិក្ខុនោះ ក៏បានតាំងនៅក្នុងសោតាបត្តិផលដែរ

ដូច្នេះឯង ។

ចប់ រឿងនាងសិរិមា

# ៣. រឿងព្រះនាងឧត្តរាថេរី

*កាលព្រះសាស្តាប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងឧត្តរាថេរី ត្រាស់ព្រះធម្មទេសនានេះថា **បរិជិណ្ណមិទំ រូបំ** (រូបនេះចាស់គ្រាំគ្រាហើយ) ជាដើម ។*

ព្រះថេរីអត់អាហារព្រោះធីកចិត្តករុណា

*ដូចបានស្តាប់មក ព្រះថេរីមានអាយុ ១២០ ឆ្នាំអំពីកំណើត ត្រាច់បិណ្ឌ-បាត បានបិណ្ឌបាតហើយ ឃើញភិក្ខុមួយរូបក្នុងវាងផ្លូវ បានសួរនាំដោយអើពើក្នុងបិណ្ឌបាត កាលភិក្ខុនោះមិនហាមឃាត់ទទួលយក ក៏ប្រគេនទាំងអស់ចំណែកខ្លួនសុខចិត្តអត់ សូម្បីក្នុងថ្ងៃទី ២ ទី៣ ក៏បានប្រគេនភត្តដល់ភិក្ខុនោះក្នុងទីនោះទៀត បានអត់អាហារហើយយ៉ាងនោះ ។ ក្នុងថ្ងៃទី ៤ ព្រះថេរីត្រាច់បិណ្ឌបាត បានជួបព្រះសាស្តាក្នុងទីដ៏ចង្អៀតមួយ កាលឈានថយក្រោយបានជាន់ជាយចីវររបស់ខ្លួនដែលសំយុងចុះ មិនអាចទប់ខ្លួនបាន ក៏ដួលទៅនឹងដី ។ ព្រះសាស្តាស្តេចយាងទៅជិត ហើយត្រាស់ថា "ម្នាលប្អូនស្រី អត្តភាពរបស់នាងគ្រាំគ្រាហើយ មិនយូរទៀតទេ ក៏នឹងបែកធ្លាយទៅ ហើយត្រាស់ព្រះគាថានេះថា ៖*

*៣. បរិជិណ្ណមិទំ រូបំ        រោគនិទ្ធំ បភង្គុណំ*
*ភិជ្ជតិ បូតិ សន្ទេហោ    មរណន្តំ ហិ ជីវិតំ ។*

*រូបនេះគ្រាំគ្រាហើយ ជាសម្នាក់នៃរោគ ជារបស់ពុកផុយ រាងកាយជារបស់ស្អុយ (នេះ) តែងបែកធ្លាយទៅវិញ ព្រោះថា ជីវិតមានសេចក្តីស្លាប់ជាទីបំផុត ។*

អធិប្បាយគាថា

*ព្រះគាថានោះមានសេចក្តីថា "ប្អូនស្រី រូបនេះ ពោលគឺ សរីរៈរបស់នាង ឈ្មោះថា ចាស់គ្រាំគ្រាហើយ ព្រោះជាមនុស្សចាស់ ក៏រូបនោះឯងជាសំបុករបស់រោគ ព្រោះអត្ថថា ជាទីនៅអាស្រ័យរបស់រោគគ្រប់ប្រភេទ ប្រៀបដូចសត្វចចកសូម្បីនៅក្មេង គេក៏ហៅថា សត្វចចកចាស់ វល្លិផោមសូម្បីនៅខ្ចី ក៏គេហៅថាវល្លិស្អុយ យ៉ាងណា រូបនេះ ក៏ដូច្នោះដែរ កើតក្នុងថ្ងៃនោះ សូម្បីជារូបមានពណ៌ដូចមាស ក៏ឈ្មោះថា កាយស្អុយ ពុកផុយ ព្រោះអត្ថថា ហូរចេញជានិច្ច កាយរបស់នាងនេះ ជារបស់ស្អុយ គប្បីជ្រាបថា នឹងបែក គឺថានឹងបែកធ្លាយក្នុងកាលមិនយូរ ព្រោះហេតុអ្វី? ព្រោះជីវិត មានសេចក្តីស្លាប់ជាទីបំផុត ។ ព្រះមានព្រះភាគត្រាស់អធិប្បាយទុកថា ព្រោះជីវិតរបស់សព្វសត្វ មានសេចក្តីស្លាប់ជាទីបំផុត" ។*

*ក្នុងវេលាចប់ព្រះធម៌ទេសនា ព្រះថេរីបានសម្រេចសោតាបត្តិផល ។ ទេសនាបានមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។*

ចប់ រឿងព្រះនាងឧត្តរាថេរី

# ៤. រឿងព្រះអធិមានិកភិក្ខុ

ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកភិក្ខុអ្នកមានការសម្គាល់ថា ខ្លួនបានសម្រេចព្រះអរហត្តផលជាច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **យានិមានិ (ឆ្អឹងទាំងនេះណា)** ជាដើម ។

ពួកភិក្ខុសម្គាល់ខុស

បានឮថា ភិក្ខុ ៥០០ រូប រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដាហើយ ចូលទៅកាន់ព្រៃ ប្រឹងប្រែងព្យាយាមរហូតញ៉ាំងឈានឲ្យកើតឡើង ក៏សម្គាល់ថា “កិច្ចនៃបព្វជិតរបស់ពួកយើងសម្រេចហើយ” ព្រោះកិលេសទាំងឡាយ មិនផុសផុលឡើង ទើបត្រឡប់មកដោយបំណងថា នឹងក្រាបទូលគុណដែលខ្លួនបានហើយ ចំពោះព្រះសាស្ដា ។ ក្នុងកាលដែលពួកលោកទាំងនោះ មកដល់ខ្លោងទ្វារខាងក្រៅ ព្រះសាស្ដាត្រាស់នឹងព្រះអានន្ទថា “ម្នាលអានន្ទ កុំអាលឲ្យភិក្ខុទាំងនោះចូលមកគាល់តថាគត អ្នកចូរប្រាប់ភិក្ខុទាំងនោះ ឲ្យទៅកាន់ព្រៃបោលខ្មោច (ជាមុនសិន) ត្រឡប់មកអំពីទីនោះហើយ សឹមឲ្យចូលមកគាល់តថាគត” ។ ព្រះថេរៈទៅប្រាប់សេចក្ដីនោះដល់ភិក្ខុទាំងនោះ ។ ក៏ភិក្ខុទាំងនោះមិនបានពោលថា “ពួកយើងនឹងបានប្រយោជន៍អ្វី ដោយព្រៃខ្មោច” ប៉ុន្តែបានគិតថា “ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ឃើញការណ៍វែង នឹងទ្រង់ឃើញការណ៍” ដូច្នេះហើយ ក៏និមន្តទៅកាន់ព្រៃខ្មោច កាលឃើញសាកសពដែលនៅក្នុងទីនោះ ក៏

ទាស់ចិត្តនឹងសាកសពដែលគេយកទៅចោលបានមួយថ្ងៃ ពីរថ្ងៃ ហើយកើតតម្រេកនឹងសរីរៈសាកសពដែលគេទើបតែយកទៅចោល ។ ខណៈនោះ ក៏ដឹងខ្លួនថា យើងនៅមានកិលេស ។ ព្រះសាស្តា ទ្រង់ប្រថាប់នៅក្នុងព្រះគន្ធកុដិនោះឯង ទ្រង់បញ្ចេញព្រះរស្មីទៅកាន់ទីនោះ ដូចជាប្រថាប់នៅចំពោះមុខភិក្ខុទាំងនោះ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កាលអ្នកទាំងឡាយឃើញរាងឆ្អឹងបែបនោះ សេចក្តីត្រេកអរដោយអំណាចរាគៈកើតឡើង គួរលេះឬ" ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា ៖

៤. យានិមានិ អបត្ថានិ   អលាពូនេវ សារទេ
កាបោតកានិ អដ្ឋីនិ   តានិ ទិស្វាន កា រតិ ។

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេចោល
ហើយ ដូចជាផ្លែឃ្លោកក្នុងសរទកាល សេចក្តីត្រេកអរអ្វីហ្ន៎
(របស់អ្នកទាំងឡាយ) ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អបត្ថានិ** (ដែលគេចោលហើយ) បានដល់ដែលគេចោលហើយ ។ បទថា **សារទេ** (ក្នុងសរទកាល) សេចក្តីថា ដូចផ្លែឃ្លោកដែលត្រូវខ្យល់ និងកម្តៅថ្ងៃប្រហារ រាត់រាយក្នុងទីនោះៗ ក្នុងសរទកាល ។ បទថា **កាបោតកានិ** ប្រែថា មានពណ៌ដូចជាពណ៌សត្វព្រាប ។ បទថា **តានិ ទិស្វាន** (ព្រោះឃើញឆ្អឹងទាំងនោះ) សេចក្តីថា សេចក្តីត្រេកអរអ្វីហ្ន៎របស់ពួក

អ្នក (នឹងមាន) ព្រោះឃើញភ្លើងទាំងនោះ គឺ ឃើញបែបនោះ ការធ្វើសេចក្ដីត្រេកអរក្នុងកាម សូម្បីមានប្រមាណតិច រមែងមិនគួរ មិនមែនឬ? ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ភិក្ខុទាំងនោះ បានសម្រេចអរហត្តផលទាំងកំពុងឈរស្ដាប់នោះឯង ក៏សរសើរព្រះមានព្រះភាគជាម្ចាស់ មកថ្វាយបង្គំដូច្នេះឯង ។

ចប់ រឿងអធិមានិកភិក្ខុ

# ៥. រឿងព្រះនាងរូបនន្ទាថេរី

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងរូប-នន្ទាថេរី ដែលជាស្ត្រីស្អាតក្នុងជនបទ ត្រាស់ព្រះធម្មទេសនានេះថា* ***អដ្ឋីនំ នគរំ កតំ (សរីរៈដែលកម្មសាងឲ្យជានគរនៃឆ្អឹងទាំងឡាយ)*** *ជាដើម ។*

ព្រះនាងរូបនន្ទាទ្រង់ព្រះផ្នួស

*បានឮថា ថ្ងៃមួយ ព្រះនាងរូបនន្ទានោះ ទ្រង់ព្រះតម្រិះថា "ម្ចាស់បងរបស់យើង លះបង់សិរីក្នុងរាជសម្បត្តិចេញ សាងព្រះផ្នួស ហើយបានត្រាស់ជាព្រះពុទ្ធ ជាបុគ្គលដ៏ធ្មើមក្នុងលោក សូម្បីឱរសរបស់ព្រះអង្គ ឈ្មោះរាហុល-កុមារ ក៏បួសហើយដែរ ម្ចាស់បងរបស់យើង (គឺព្រះនន្ទ) ក៏បួស សូម្បីព្រះមាតារបស់យើង ក៏ទ្រង់ព្រះផ្នួស បើពពួកញាតិមានប្រមាណប៉ុណ្ណេះ ចេញបួសអស់ហើយ តើផ្ទះមានប្រយោជន៍អ្វីសម្រាប់យើង យើងនឹងបួសដែរ" ។ ព្រះនាងស្តេចចូលទៅកាន់សម្នាក់ភិក្ខុនីទាំងឡាយ ហើយទ្រង់ព្រះផ្នួស ព្រះនាងទ្រង់ព្រះផ្នួស ព្រោះស្នេហាក្នុងព្រះញាតិប៉ុណ្ណោះ មិនមែនទ្រង់ព្រះផ្នួសដោយសទ្ធាឡើយ តែព្រោះ ព្រះនាងជាអ្នកមានព្រះរូបឆោមស្រស់ស្អាត ទើបប្រាកដព្រះនាមថា* ***រូបនន្ទា*** *។ ព្រះនាងទ្រង់បានស្តាប់ថា "បានឮថា ព្រះសាស្តាត្រាស់ថា រូបមិនទៀង ជាទុក្ខ ជាអនត្តា វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះ ទើបមិនហ៊ានចូលទៅកាន់ទីចំពោះព្រះភក្ត្រព្រះសាស្តា*

ដោយខ្វាចក្រែងថា "ព្រះសាស្តាត្រាស់សម្តែងទោសក្នុងរូបរបស់យើង ដែលគួរមើល គួរជ្រះថ្លាយ៉ាងនេះ" ។

## អ្នកនគរនិយមស្តាប់ធម៌

អ្នកនគរសាវត្ថីថ្វាយទានអំពីព្រឹក សមាទានឧបោសថ ស្លៀកដណ្តប់ស្អាតបាត មានដៃកាន់គ្រឿងក្រអូប និងផ្កាកម្រងជាដើម ក្នុងវេលារសៀលប្រជុំគ្នាស្តាប់ធម៌ក្នុងវត្តជេតពន ។ សូម្បីភិក្ខុនីសង្ឃ ដែលពេញចិត្តក្នុងព្រះធម្មទេសនារបស់ព្រះសាស្តា ក៏ទៅវិហារស្តាប់ធម៌ ។ អ្នកនគរសាវត្ថីទាំងនោះពេលស្តាប់ធម៌ហើយ មុននឹងចូលទៅកាន់ព្រះនគរ តែងតែពោលអំពីគុណរបស់ព្រះសាស្តាហើយ ទើបចូលទៅកាន់នគរ ។

## ការជ្រះថ្លារបស់បុគ្គល ៤ ពួក

ពិតណាស់ ពួកសត្វក្នុងលោកសន្និវាស ដែលមានប្រមាណ ៤ ពួក ពេលឃើញព្រះតថាគត មិនជ្រះថ្លា មានចំនួនតិច ។

## ១.រូបប្បមាណិកា

ព្រោះថា សត្វពួកខ្លះ ជារូបប្បមាណិកា (និយមក្នុងរូប) ឃើញព្រះសរីរៈរបស់ព្រះតថាគត ដែលប្រដាប់ដោយព្រះលក្ខណៈ និងអនុព្យញ្ជនៈ មានព្រះឆវីវណ្ណដូចមាស ទើបជ្រះថ្លា ។

## ២.ឃោសប្បមាណិកា

សត្វពួកខ្លះ ជាឃោសប្បមាណិកា (កាន់យកសំឡេងជាប្រមាណ) បាន

ស្ដាប់សូរសៀង ដែលប្រកាសអំពីព្រះគុណរបស់ព្រះសាស្ដា ដែលអាស្រ័យការប្រព្រឹត្តទៅហើយរាប់រយជាតិ និងព្រះសូរសៀងប្រកាសព្រះធម្មទេសនាដែលប្រកបដោយអង្គ ៨ ទើបជ្រះថ្លា ។

៣. លូខប្បមាណិកា

សត្វពួកខ្លះ ជាលូខប្បមាណិកា (កាន់យកការបដិបត្តិដ៏សៅហ្មងជាប្រមាណ) អាស្រ័យនូវការៈនៃបច្ច័យ មានចីវរប្បច្ច័យជាដើមរបស់ព្រះសាស្ដានោះ ជារបស់សៅហ្មង ទើបជ្រះថ្លា ។

៤. ធម្មប្បមាណិកា

ឯសត្វពួកខ្លះ ជាធម្មប្បមាណិកា (កាន់យកធម៌ជាប្រមាណ) ក៏រមែងជ្រះថ្លាថា សីលរបស់ព្រះទសពលបែបនេះ សមាធិបែបនេះ បញ្ញាបែបនេះ ព្រះមានព្រះភាគជាម្ចាស់គ្មានបុគ្គលស្មើ មិនមានបុគ្គលផ្ទឹម រកបុគ្គលប្រដូចគ្មាន មិនមានអ្នកប្រៀបផ្ទឹមដោយគុណទាំងឡាយ មានសីលជាដើម ។ ជនទាំងនោះពណ៌នាគុណរបស់ព្រះសាស្ដា មិនល្មមមាត់ឡើយ ។

ព្រះនាងរូបនន្ទាថេរីចូលគាល់ព្រះតថាគតស្ដាប់ធម៌

ព្រះនាងរូបនន្ទា ទ្រង់ស្ដាប់នូវពាក្យពណ៌នាគុណរបស់ព្រះតថាគតពីសម្នាក់របស់ពួកភិក្ខុនី និងពួកឧបាសិកា ទើបព្រះនាងទ្រង់ព្រះតម្រិះថា “ជនទាំងឡាយ តែងពោលសរសើរម្ចាស់បងរបស់យើងយ៉ាងពន់ពេក បងប្រុសកាលពោលទោសរូបរបស់យើង សូម្បីអស់មួយថ្ងៃ នឹងត្រាស់នូវទោស មាន

ប្រមាណប៉ុនណា ណ្ហើយចុះ យើងនឹងទៅជាមួយពួកនាងភិក្ខុនី មិនបង្ហាញខ្លួនឡើយ ចូលគាល់ព្រះតថាគតស្តាប់ធម៌ហើយសឹមមក" ។ ទើបព្រះនាងត្រាស់ប្រាប់ពួកភិក្ខុនីថា "ថ្ងៃនេះ ខ្ញុំនឹងទៅកាន់ទីស្តាប់ព្រះធម៌" ។ ពួកភិក្ខុនីមានចិត្តត្រេកអរ ដោយគិតថា "ព្រះនាងរូបនន្ទា ទ្រង់មានព្រះបំណងនឹងស្តេចចូលទៅកាន់ទីបម្រើព្រះសាស្តា អស់កាលជាយូរមកហើយ ថ្ងៃនេះព្រះសាស្តាទ្រង់អាស្រ័យព្រះនាងរូបនន្ទានេះហើយ មុខជាទ្រង់សម្តែងព្រះធម៌ទេសនាដ៏វិចិត្រ" ហើយនាំគ្នានាំព្រះនាងចេញទៅ ។ តាំងអំពីវេលាដែលចេញទៅ ព្រះនាងទ្រង់ត្រិះរិះថា "យើងនឹងមិនបង្ហាញខ្លួនឡើយ" ។ ព្រះសាស្តា ទ្រង់ព្រះចិន្តាថា "ថ្ងៃនេះ រូបនន្ទានឹងមកកាន់ទីជាទីបម្រើរបស់តថាគត ធម្មទេសនាបែបណាហ្ន៎ ទើបជាទីសប្បាយដល់នាង?" ទ្រង់ធ្វើការសម្រេចព្រះទ័យថា "រូបនន្ទានុ៎ះ ធ្ងន់ក្នុងរូប មានការជាប់ជំពាក់ក្នុងអត្តភាពយ៉ាងខ្លាំង ការបន្ទោបង់សេចក្តីស្រវឹងក្នុងរូបដោយរូបនុ៎ះឯង ទើបជាទីសប្បាយដល់នាង ដូចជាការដោះបន្លាដោយបន្លាដូច្នោះ" ក្នុងវេលាដែលព្រះនាងរូបនន្ទាចូលទៅកាន់វិហារ ព្រះសាស្តាទ្រង់និម្មិតរូបស្ត្រីម្នាក់ មានរូបដ៏ស្អាត អាយុ ១៦ ឆ្នាំ ស្លៀកសំពត់ក្រហមប្រដាប់ដោយគ្រឿងអាភរណៈទាំងពួង ឈរបក់ផ្លិតថ្វាយព្រះសម្មាសម្ពុទ្ធដោយកម្លាំងឫទ្ធិ មានតែព្រះសាស្តា និងព្រះនាងរូបនន្ទាប៉ុណ្ណោះ ទ្រង់ឃើញរូបស្ត្រីនោះ ។ ព្រះនាងស្តេចចូលទៅកាន់វិហារ ជាមួយភិក្ខុនីទាំងឡាយ ទ្រង់ឈរពីខាងក្រោយភិក្ខុនី ថ្វាយបង្គំព្រះសាស្តាដោយបញ្ចង្គប្រតិស្ឋាន ហើយអង្គុយ

ក្នុងចន្លោះពួកភិក្ខុនី ព្រះនាងគន់មើលព្រះតថាគតតាំងអំពីព្រះបាទ ឃើញព្រះសរីរៈរបស់ព្រះសាស្ដាដ៏វិចិត្រហើយដោយព្រះលក្ខណៈ រុងរឿងដោយអនុព្យញ្ជនៈ ឆ្វែលឆ្វាត់ដោយព្រះរស្មីប្រមាណមួយព្យាម ព្រះនាងគន់មើលព្រះភក្ត្រដ៏មានសិរី ដូចជាព្រះច័ន្ទពេញវង់ បានឃើញរូបស្ត្រីដែលឈរនៅក្នុងទីជិតព្រះសម្មាសម្ពុទ្ធ ។ ព្រះនាងទ្រង់ក្រឡេកមើលរូបស្ត្រីនោះហើយ ទ្រង់មើលងាយនូវអត្តភាពរបស់ខ្លួនថា "ដូចជាមេក្អែកក្នុងហ្វូងនៃមេរាជហង្សមាស" ។ ចាប់ពីពេលដែលព្រះនាងទ្រង់ឃើញរូប ដែលនិម្មិតដោយឫទ្ធិក្លាម ព្រះនេត្រទាំងពីររបស់ព្រះនាងក៏វិល ។ ព្រះនាងមានចិត្តដែលសិរីនៃរូបធោមនៃសរីរប្បទេសទាំងអស់ទាក់ទាញហើយថា "ឱ! សក់ទាំងឡាយរបស់ស្ត្រីនេះក៏ល្អថ្ងាសក៏ល្អ មានសេចក្ដីស្នេហាក្នុងរូបនោះយ៉ាងក្រៃលែង" ។ ព្រះសាស្ដាទ្រង់ជ្រាបសេចក្ដីត្រេកអរយ៉ាងខ្លាំងក្នុងរូបនោះរបស់ព្រះនាងហើយ ក៏ទ្រង់សម្ដែងព្រះធម៌បណ្ដើរ ទ្រង់សម្ដែងធ្វើរូបនោះឲ្យកន្លងភាវៈរបស់អ្នកមានអាយុ ១៦ ឆ្នាំឲ្យមានអាយុ ២០ ឆ្នាំបណ្ដើរ ។ ព្រះនាងរូបនន្ទា បានទតមើលរូបនោះទៅមានចិត្តនឿយណាយបន្តិចថា "ឱហ្ន៎! រូបនេះមិនដូចរូបមុនហ្ន៎" ។ ព្រះសាស្ដាទ្រង់សម្ដែងការប្រែប្រួលរបស់ស្ត្រីនោះដោយលំដាប់ គឺ ភេទស្ត្រីប្រសូតបុត្រម្ដង ភេទស្ត្រីវ័យកណ្ដាល ភេទស្ត្រីចាស់គ្រាំគ្រាហើយព្រោះជរា ។ ព្រះនាងក៏ទ្រង់នឿយណាយទីងរូបនោះ ក្នុងវេលាដែលរូបនោះទ្រុឌទ្រោម ព្រោះជរាដោយលំដាប់ថា "ឱ! រូបនេះ បាត់ទៅហើយៗ" លុះឃើញរូបនោះមានធ្មេញ

បាក់ សក់ស្កូវ ខ្នងកោង មានឈើច្រត់ទប់ខាងមុខ ញញាក់ញញ័រ ក៏ទ្រង់នឿយណាយយ៉ាងក្រៃលែង ។ គ្រានោះ ព្រះសាស្តាទ្រង់សម្តែងធ្វើរូបស្ត្រីនោះឲ្យជារូបត្រូវព្យាធិគ្របសង្កត់ បោះឈើច្រត់ និងផ្លិតស្លឹកត្នោតចោល ស្រែកថ្ងូរយ៉ាងខ្លាំង ដួលចុះលើផែនដី ជ្រមុជជ្រមុលក្នុងមូត្រ និងករីសៈរបស់ខ្លួនបម្រះនទៀលទៅមកៗ ក្នុងគ្រានោះឯង ។ ព្រះនាងរូបនន្ទាទ្រង់ឃើញរូបស្ត្រីនោះហើយ ទ្រង់នឿយណាយយ៉ាងក្រៃលែង ។ ព្រះសាស្តា ទ្រង់សម្តែងនូវរូបស្ត្រីនោះ ឲ្យដល់នូវការៈជាសាកសពហើមប៉ោងឡើង ខណៈនោះឯងខ្នាញ់នៃខ្ទុះទាំងឡាយផង ដង្កូវទាំងឡាយផង ហូរចេញចាកមាត់ដំបៅទាំង ៩ ។ សត្វទាំងឡាយ មានក្អែកជាដើម ប្រជុំគ្នាជញ្ជែងស៊ី ព្រះនាងរូបនន្ទាមើលសាកសពនោះហើយ ធ្វើទុកក្នុងចិត្តដោយការៈជារបស់មិនទៀងថា “ស្ត្រីនេះដល់នូវជរា ដល់នូវព្យាធិ ដល់នូវមរណៈក្នុងទីនេះឯង ការចាស់ ការឈឺ ការស្លាប់ នឹងមកដល់អត្តភាពនេះ (យើង) យ៉ាងនោះដែរ” ក៏អត្តភាពដែលភិក្ខុនីឈ្មោះរូបនន្ទានោះឃើញ ដោយភាពជាទុក្ខនោះ ក៏ឈ្មោះថា ឃើញហើយដោយភាពជារបស់មិនទៀងដែរ ព្រោះព្រះនាងបានឃើញ ដោយភាពជារបស់មិនទៀងប៉ុណ្ណោះ ។ គ្រានោះ ភពទាំងបីប្រាកដដល់ព្រះនាង ដូចត្រូវភ្លើងឆេះសន្ធោសន្ធៅ និងដូចសាកសពដែលចងត្រង់.ក ចិត្តក៏មានមុខឆ្ពោះទៅរកព្រះកម្មដ្ឋាន ព្រះសាស្តាទ្រង់ជ្រាបថា ព្រះនាងបានឃើញអត្តភាពនេះ ដោយភាពជារបស់មិនទៀងហើយ ទើបទ្រង់ពិចារណាមើលថា “ព្រះនាងនឹងអាចធ្វើនូវ

ទីពឹងដល់ខ្លួនឯងបាន ឬក៏មិនអាចហ្ន៎?” ទ្រង់ឃើញថា “នឹងអាច ក្នុងកាលព្រះនាងបានបច្ច័យខាងក្រៅជាមុនសិន ទើបសមគួរ” កាលនឹងទ្រង់សម្តែងព្រះធម៌ ដោយអំណាចធម៌ ដែលជាទីសប្បាយដល់ព្រះនាង បានត្រាស់ព្រះគាថាទាំងនេះថា ៖

ម្នាលនាងរូបនន្ទា នាងចូរមើលកាយ ដែលកម្មលើកឡើង
ដែលទុរន់ទុរា មិនស្អាត ជារបស់ស្អុយ ហូរចេញអំពីខាងលើ
ហូរចេញអំពីខាងក្រោម ដែលជនពាលទាំងឡាយប្រាថ្នាពន់
ពេក សរីរៈរបស់នាងនេះ យ៉ាងណា សរីរៈរបស់ស្ត្រីនុ៎ះ ក៏
ដូច្នោះ នាងចូរឃើញធាតុទាំងឡាយ ថាជារបស់សូន្យ ចូរកុំ
ត្រឡប់មកកាន់លោកនេះទៀត នាងប្រាសចាកសេចក្តីពេញ
ចិត្តក្នុងភពហើយ នឹងជាបុគ្គលស្ងប់ត្រាច់ទៅ ។

បានឮថា ព្រះមានព្រះភាគទ្រង់ប្រារព្ធនាងរូបនន្ទាភិក្ខុនី បានត្រាស់ព្រះគាថាទាំងនេះ ដោយប្រការដូច្នេះឯង ។ ព្រះនាងរូបនន្ទាបញ្ជូនញាណទៅតាមព្រះធម៌ទេសនា ក៏បានសម្រេចសោតាបត្តិផល ។

## ព្រះសាស្តាទ្រង់សម្តែងវិបស្សនា

គ្រានោះ ព្រះសាស្តាកាលនឹងទ្រង់ត្រាស់សុញ្ញតកម្មដ្ឋាន ដើម្បីអប់រំវិបស្សនាដើម្បីមគ្គផលទាំងបីខាងលើដល់ព្រះនាង ទើបត្រាស់ថា “ម្នាលនាងរូបនន្ទា នាងកុំធ្វើសេចក្តីសម្គាល់ថា សារៈក្នុងសរីរៈនេះ មានឲ្យសោះ ព្រោះ

សារៈក្នុងសរីរៈនេះ សូម្បីតែបន្តិចបន្តួចក៏មិនមានដែរ សរីរៈនេះមានឆ្អឹង ៣០០ កំណាត់ ដែលផ្គុំឡើងដោយកុសលាកុសលកម្ម ធ្វើឲ្យជានគរនៃឆ្អឹងទាំងឡាយ ហើយត្រាស់ព្រះគាថានេះថា ៖

៥. អដ្ឋីនំ នគរំ កតំ មំសលោហិតលេបនំ
យត្ថ ជរា ច មច្ចុ ច មានោ មក្ខោ ច ឱហិតោ ។

សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីប្រកាន់ខ្លួន និងសេចក្តីលុបគុណ ប្រជុំចុះក្នុងសរីរៈណា (សរីរៈនោះ) ដែលកុសលា-កុសលកម្មធ្វើហើយ ឲ្យជានគររបស់ឆ្អឹងទាំងឡាយ ជាគ្រឿងប្រឡាក់ដោយសាច់ និងឈាម ។

អធិប្បាយគាថា

ព្រះគាថានោះមានសេចក្តីថា "ដូចជា ជនទាំងឡាយ ឲ្យគេយកឈើទាំងឡាយ លើកឡើងហើយចងដោយវល្លិ លាបដោយដីស្អិត ធ្វើឲ្យជាផ្ទះខាងក្រៅ ពោលគឺ នគរ ដើម្បីប្រយោជន៍ដល់ការទុកដាក់បុព្វណ្ណជាតិ និងអបរណ្ណ-ជាតិជាដើម យ៉ាងណា សរីរៈនេះ ដែលប្រព្រឹត្តទៅខាងក្នុង ក៏ដូច្នោះ ដែលកម្មញ៉ាំងឆ្អឹង ៣០០ កំណាត់ ធ្វើឲ្យជានគរហើយ ចងរឹតដោយសរសៃ បូកលាបដោយសាច់ និងឈាម បិទបាំងដោយស្បែក ដើម្បីប្រយោជន៍ដល់ការដាក់ចុះនូវជរា ដែលមានការទ្រុឌទ្រោមជាលក្ខណៈ មច្ចុដែលមានការស្លាប់ជាលក្ខណៈ មានៈដែលមានការស្រវឹង ព្រោះអាស្រ័យការដល់ព្រមដោយការ

លើកតម្កើងជាដើមជាលក្ខណៈ និងមក្ខៈ (ការលុបគុណរបស់អ្នកដទៃ) ដែលមានការធ្វើកម្ម ដែលគេធ្វើល្អហើយ ឲ្យវិនាសជាលក្ខណៈ ព្រោះអាពាធដែលប្រព្រឹត្តទៅតាមកាយ និងចិត្តទាំងឯង ធ្លាក់ចុះក្នុងសរីរៈនេះ ក្រៅអំពីនេះ ក៏មិនមានអ្វីៗ ដែលបុគ្គលគប្បីកាន់យកបាន ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ព្រះនាងរូបនន្ទាថេរី បានសម្រេចអរហត្តផល ។ ព្រះធម្មទេសនា បានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

ចប់ រឿងព្រះនាងរូបនន្ទា

# ៦. រឿងព្រះនាងមល្លិកាទេវី

*ព្រះសាស្តា កាលប្រថាប់នៅព្រះជេតពន ទ្រង់ប្រារព្ធព្រះនាងមល្លិកា-ទេវី ត្រាស់ព្រះធម្មទេសនានេះថា* ***ជីរន្តិ វេ រាជរថា សុចិត្តា*** *(រាជរថដែលវិចិត្រល្អ នៅគ្រាំគ្រាបាន) ជាដើម ។*

ព្រះនាងមល្លិកាទេវីធ្វើសន្ថវៈជាមួយនឹងសុនខ

*បានឮថា ថ្ងៃមួយ ព្រះនាងមល្លិកាទេវីនោះ ទ្រង់ចូលទៅកាន់បន្ទប់ទឹក ទ្រង់ជម្រះព្រះឱស្ឋហើយ ទ្រង់ឱនសរីរៈចុះ ដើម្បីជម្រះជង្ឃា (ស្មង) នៅពេលនោះ មានសុនខសំណប់មួយ ចូលទៅកាន់បន្ទប់ទឹកនោះជាមួយនឹងព្រះនាងដែរ វាឃើញព្រះនាងឱនចុះដូច្នោះ ក៏ប្រារព្ធនឹងធ្វើអសទ្ធម្មសន្ថវៈ ។ ព្រះនាងមល្លិកាត្រេកអរនឹងសម្ផស្សរបស់វា ទើបទ្រង់ឈរនៅស្ងៀម ។ ព្រះរាជាទ្រង់ទតតាមសីហបញ្ជរ (បង្អួច) នៃប្រាសាទជាន់លើ ទ្រង់ក៏ឃើញកិរិយានោះ លុះព្រះនាងមល្លិកាស្តេចយាងចេញមកអំពីបន្ទប់ទឹកនោះ ក៏ត្រាស់ថា "ស្រីចង្រៃ ស្រីថោកទាប នាងចូរវិនាសទៅ ព្រោះហេតុអ្វី ទើបនាងធ្វើនូវអំពើបែបនេះ" ។*

*ព្រះនាង. ខ្ញុំម្ចាស់ធ្វើកម្មអ្វី ព្រះអង្គ ?*

*ព្រះរាជា. ធ្វើសន្ថវៈជាមួយនឹងសុនខ ។*

*ព្រះនាង. រឿងនេះមិនពិតទេ ព្រះអង្គ ។*

*ព្រះរាជា. យើងឃើញដោយខ្លួនឯង នាងនៅប្រកែកទៀតឬ យើងនឹង*

ជឿនាងដូចម្ដេចបាន ស្រីចង្រៃ ស្រីថោកទាប ចូរវិនាសទៅ ។

ព្រះនាង. បពិត្រមហារាជ អ្នកណាម្នាក់ចូលទៅកាន់បន្ទប់ទឹកនោះ តែម្នាក់ប៉ុណ្ណោះ ក៏ប្រាកដជាពីរនាក់ ដល់អ្នកដែលក្រឡេកមើលតាមសីហបញ្ជរនេះ ។

ព្រះរាជា. នាងនិយាយមិនពិត ស្រីអាក្រក់ ។

ព្រះនាង. បពិត្រមហារាជ បើព្រះអង្គទ្រង់មិនជឿខ្ញុំម្ចាស់ សូមព្រះអង្គស្ដេចចូលទៅកាន់បន្ទប់ទឹកនោះចុះ ខ្ញុំម្ចាស់នឹងមើលតាមសីហបញ្ជរនេះ ។

ព្រះរាជាទ្រង់ជាប់ដោយសេចក្ដីឆោត ទើបទ្រង់ជឿពាក្យរបស់ព្រះនាងមល្លិកា ហើយស្ដេចចូលទៅកាន់បន្ទប់ទឹកនោះ ។ ចំណែកព្រះនាងមល្លិកា-ទេវី ឈរទតត្រង់សីហបញ្ជរ ទ្រង់ព្រះក្អែងទូលថា "មហារាជល្ងង់ ហេតុអ្វីព្រះអង្គទ្រង់ធ្វើសន្ថវៈជាមួយនឹងមេពពែ" សូម្បីព្រះរាជាត្រាស់ថា "ម្នាលនាងដ៏ចម្រើន យើងមិនបានធ្វើអំពើបែបនោះទេ" ក៏ទូលថា ខ្ញុំម្ចាស់ឃើញដោយខ្លួនឯង ខ្ញុំម្ចាស់នឹងជឿព្រះអង្គដូចម្ដេចបាន" ព្រះរាជាទ្រង់ស្ដាប់នូវពាក្យនោះហើយ ក៏ទ្រង់ជឿថា អ្នកដែលចូលទៅកាន់បន្ទប់ទឹកនេះ តែម្នាក់ប៉ុណ្ណោះ ក៏ប្រាកដជាមនុស្សពីរនាក់ដោយពិត ។ ព្រះនាងមល្លិកាទ្រង់ត្រិះរិះថា "ព្រះរាជានេះ ត្រូវយើងបញ្ឆោតបាន ក៏ព្រោះព្រះអង្គជាអ្នកឆោតល្ងង់ យើងបានធ្វើកម្មអាក្រក់ហើយ ថែមទាំងបានពោលមួលបង្កាច់ព្រះរាជាដោយពាក្យមិនពិតទៀតមិនត្រឹមតែប៉ុណ្ណោះ ព្រះសាស្ដា ព្រះអង្គក៏ទ្រង់ជ្រាបនូវអំពើរបស់យើង ព្រះ

អគ្គសាវកទាំងពីរក្តី ព្រះអសីតិមហាសាវកក្តី នឹងជ្រាបនូវអំពើរបស់យើងដែរ ឱហ្ន៎! កម្មដ៏ធ្ងន់ យើងបានធ្វើហើយ” ។ បានឮថា ព្រះនាងមល្លិកានេះ បានជាសំឡាញ់ក្នុងអសទិសទានរបស់ព្រះរាជា ។

## ព្រះនាងមល្លិកាកើតក្នុងអវីចី

ក៏ក្នុងអសទិសទាននោះ ព្រះរាជាបរិច្ចាគទ្រព្យមួយថ្លៃអស់ ១៤ កោដិ វត្ថុ ៤ យ៉ាង គឺ ស្វេតច្ឆ័ត្រ បល្ល័ង្កសម្រាប់គង់ ជើងបាត្រ តាំងសម្រាប់ទ្រព្រះបាទរបស់ព្រះតថាគត ជារបស់កាត់ថ្លៃមិនបាន ។ ក្នុងវេលាអស់ព្រះជន្មព្រះនាងមល្លិកានោះ ទ្រង់មិនបាននឹកដល់មហាបរិច្ចាគបែបនោះទេ ទ្រង់នឹកដល់តែកម្មដ៏លាមកនោះប៉ុណ្ណោះ អស់ព្រះជន្មទៅ ក៏កើតក្នុងអវីចី ។ ក៏ព្រះនាងមល្លិកានោះ ជាទីប្រោសប្រាណរបស់ព្រះរាជាយ៉ាងក្រៃលែង ។ ព្រះរាជាត្រូវសេចក្តីសោកដ៏មានកម្លាំងគ្របសង្កត់ ទ្រង់ត្រាស់បង្គាប់ឲ្យធ្វើឈាបនកិច្ចសរីរៈរបស់ព្រះនាងមល្លិកា ហើយទ្រង់គិតថា “យើងនឹងទូលសួរនូវទីកើតរបស់ព្រះនាងមល្លិកា” ទើបស្តេចយាងទៅកាន់សម្នាក់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់ធ្វើឲ្យព្រះរាជារឭកដល់ហេតុ ដែលស្តេចយាងមកមិនបាន ។ ព្រះរាជាទ្រង់ស្តាប់នូវធម៌ដែលនាំឲ្យរឭកដល់គ្នា ក្នុងសម្នាក់របស់ព្រះសាស្តាហើយ ក៏ទ្រង់ភ្លេចទៅ កាលព្រះអង្គស្តេចចូលទៅកាន់រាជនិវេសន៍ ក៏ទ្រង់រឭកបាន ទើបត្រាស់ថា “ម្នាលនាយ យើងតាំងចិត្តថា នឹងទូលសួរដល់ទីកើតរបស់ព្រះនាងមល្លិកាទេវី តែទៅដល់សម្នាក់របស់ព្រះសាស្តា ក៏ភ្លេចទៅ ព្រឹកនេះយើងនឹង

ទូលសួរទៀត" លុះព្រឹកឡើង ព្រះរាជាយាងទៅកាន់សម្នាក់របស់ព្រះសាស្តា ចំណែកព្រះសាស្តា ទ្រង់បានធ្វើឲ្យព្រះរាជាភ្លេចអស់ ៧ ថ្ងៃ ដោយលំដាប់ ។ ចំណែកព្រះនាងមល្លិកានោះ ឆេះក្នុងនរកអស់ ៧ ថ្ងៃ ដល់ថ្ងៃទី ៨ ចុតិចាកទីនោះហើយ កើតក្នុងឋានតុសិត ។

សួរថា ព្រោះហេតុអ្វី ទើបព្រះសាស្តាទ្រង់ធ្វើឲ្យព្រះរាជាភ្លេច ?

ឆ្លើយថា ជ្រាបថា ព្រះនាងមល្លិកានោះ ជាទីប្រោសប្រាណពេញព្រះហឫទ័យរបស់ព្រះរាជាជាទីបំផុត ព្រោះដូច្នោះ ប្រសិនបើព្រះអង្គទ្រង់ជ្រាបថា ព្រះនាងមល្លិកាកើតក្នុងនរក ទ្រង់ប្រកបដោយមិច្ឆាទិដ្ឋិ ដោយទ្រង់ព្រះតម្រិះថា "បើស្ត្រីដែលសម្បូណ៌ដោយសទ្ធាបែបនេះ កើតក្នុងនរកសោត យើងនឹងថ្វាយទានធ្វើអ្វី?" ទ្រង់ក៏ត្រាស់បង្គាប់ឲ្យជកនិច្ចភត្ត ដែលទ្រង់ឲ្យប្រព្រឹត្តទៅក្នុងព្រះរាជនិវេសន៍ ដើម្បីភិក្ខុ ៥០០ រូបចេញ ហើយគប្បីទៅកើតក្នុងនរក ព្រោះហេតុដូច្នោះ ទើបព្រះសាស្តាទ្រង់ធ្វើឲ្យព្រះរាជាភ្លេចអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៨ ទ្រង់ត្រាច់បិណ្ឌបាត ស្តេចយាងចូលទៅកាន់ទ្វារព្រះរាជវាំងដោយព្រះអង្គឯង ។ ព្រះរាជាទ្រង់ស្តាប់ថា ព្រះសាស្តាទ្រង់យាងមក ស្តេចក៏ចេញទៅទទួលបាត្រ ហើយអារាធនាឲ្យទ្រង់យាងឡើងកាន់ប្រាសាទ ។ តែព្រះសាស្តាទ្រង់សម្តែងនូវព្រះអាការដើម្បីប្រថាប់ក្នុងរោងរាជរថ ។ ទើបព្រះរាជាទូលអារាធនាព្រះសាស្តាឲ្យប្រថាប់ក្នុងទីនោះ ទ្រង់ថ្វាយយាគូ និងបង្អែមហើយ ទើបថ្វាយបន្ទុំ គ្រាន់តែព្រះអង្គប្រថាប់ភ្លាម ក៏ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំ

ព្រះអង្គមកដោយបំណងថា នឹងទូលសួរដល់ទីកើតរបស់ព្រះនាងមល្លិកាទេវី ហើយក៏ភ្លេចទៅ បពិត្រព្រះអង្គដ៏ចម្រើន តើព្រះនាងមល្លិកាកើតក្នុងទីណាហ្ន៎”

ព្រះសាស្តា. បពិត្រមហារាជ នាងកើតក្នុងឋានតុសិត ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន បើព្រះនាងមិនកើតក្នុងភពតុសិត អ្នកដទៃណា នឹងទៅកើតបាន ព្រះអង្គដ៏ចម្រើន ស្ត្រីដូចជាព្រះនាងមល្លិកានោះ មិនមានឡើយ ព្រោះក្នុងទីដែលព្រះនាងគង់ជាដើម កិច្ចដទៃវៀរការចាត់ចែងទាន ដោយគិតថា ព្រឹកនេះនឹងថ្វាយរបស់នេះ នឹងចាត់ចែងវត្ថុនេះ ថ្វាយដល់ព្រះតថាគតដូច្នេះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន តាំងពីពេលដែលព្រះនាងមល្លិកាទៅកាន់បរលោក សរីរៈរបស់ខ្ញុំព្រះអង្គ មិនរហ័សរហួនឡើយ ។

## ធម៌របស់សប្បុរសមិនចូលដល់ការចាស់ជរា

គ្រានោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា “កុំឡើយ មហាបពិត្រ នេះជាធម៌ដ៏ទៀងទាត់របស់សត្វគ្រប់ជំពូក” ត្រាស់សួរថា “បពិត្រមហារាជ នេះជារថរបស់អ្នកណា?” ព្រះរាជាទ្រង់ផ្គងអញ្ជលីលើព្រះសិរសា ហើយទូលថា “ព្រះអង្គដ៏ចម្រើន ជារបស់ព្រះអយ្យកោរបស់ខ្ញុំព្រះអង្គ” ។

ព្រះសាស្តា. នេះរបស់នរណា ?

ព្រះរាជា. របស់ព្រះបិតានៃខ្ញុំព្រះអង្គ ព្រះអង្គ។

ព្រះសាស្តា. នេះ ជារបស់អ្នកណា ?

ព្រះរាជា. របស់ទូលបង្គំ ព្រះអង្គ ។

កាលព្រះរាជាក្រាបទូលយ៉ាងនោះហើយ ព្រះសាស្តាក៏ទ្រង់ត្រាស់ថា "មហាបពិត្រ រថរបស់ព្រះអយ្យកោរបស់មហាបពិត្រ ព្រោះហេតុអ្វី ទើបមិនដល់រថរបស់ព្រះបិតារបស់មហាបពិត្រ រថរបស់ព្រះបិតារបស់មហាបពិត្រ ក៏មិនដល់រថរបស់មហាបពិត្រ ការទ្រុឌទ្រោមតែងមកដល់ សូម្បីតែអង្កត់ឈើបែបនេះ នឹងពោលទៅថ្វីនឹងមិនមកដល់អត្តភាពរបស់មហាបពិត្រ តាមពិតមានតែធម៌របស់សប្បុរសប៉ុណ្ណោះ ទើបមិនចូលដល់ការទ្រុឌទ្រោម ចំណែកសត្វទាំងឡាយ ឈ្មោះថា មិនទ្រុឌទ្រោមគ្រាំគ្រា មិនមានឡើយ ហើយត្រាស់ព្រះគាថានេះថា ៖

៦. ជីរន្តិ វេ រាជរថា សុចិត្តា
អថោ សរីរម្បិ ជរំ ឧបេតិ
សតញ្ច ធម្មោ ន ជរំ ឧបេតិ
សន្តោ ហវេ សព្ភិ បវេទយន្តិ ។

រាជរថទាំងឡាយ ដ៏វិចិត្រដោយល្អ រមែងគ្រាំគ្រា សូម្បីសរីរៈក៏ដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា ទើបឯធម៌ របស់សប្បុរសទាំងឡាយ មិនដល់នូវសេចក្តីចាស់គ្រាំគ្រា (ដូច្នោះ) ទេ សប្បុរសទាំងឡាយ តែងនិយាយឲ្យពួកសប្បុរសផងគ្នាដឹងបាន ។

## អធិប្បាយគាថា

សព្ទថា វេ ក្នុងព្រះគាថានោះ ជានិបាត ។ បទថា **សុចិត្តា** (ដែល វិចិត្រល្អ) សេចក្តីថា រថទាំងឡាយ សូម្បីរបស់ព្រះរាជាទាំងឡាយ ដែលបាន វិចិត្រល្អហើយដោយរតនៈ ៧ ប្រការ និងដោយគ្រឿងអលង្ការសម្រាប់ប្រដាប់ រថដទៃទៀតក៏ដោយ រមែងគ្រាំគ្រាបាន ។ បទថា **សរីរម្បិ** (ដល់នូវសរីរៈ) សេចក្តីថា មិនមែនតែរថប៉ុណ្ណោះទេ សូម្បីសរីរៈដែលខំថែទាំដោយល្អ នេះ ក៏រមែងដល់នូវការទ្រុឌទ្រោម មានធ្មេញបាក់ជាដើម ទើបឈ្មោះថា ចូល ដល់ការគ្រាំគ្រា ។ បទថា **សតញ្ច** (របស់សប្បុរស) សេចក្តីថា តែលោកុ- ត្តរធម៌ ៩ យ៉ាង របស់សប្បុរសទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម រមែង មិនបៀតបៀននរណាៗ ឡើយ ទើបឈ្មោះថា មិនចូលដល់ការគ្រាំគ្រា ។ បទ ថា **បវេទយន្តិ** (រមែងប្រាស្រ័យ) សេចក្តីថា សប្បុរសទាំងឡាយ មានព្រះ សម្មាសម្ពុទ្ធជាដើម រមែងប្រាស្រ័យជាមួយសប្បុរស គឺ ជាមួយបណ្ឌិតទាំង ឡាយយ៉ាងនេះ ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំង ឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងព្រះនាងមល្លិកាទេវី

# ៧. រឿងព្រះលោឡុទាយី

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះលោឡុទាយី ត្រាស់ព្រះធម្មទេសនានេះថា **អប្បស្សុតាយំ បុរិសោ** (បុគ្គលអ្នកស្តាប់តិច) ជាដើម ។*

ព្រះថេរៈពោលធម៌មិនសមគួរដល់ការងារ

*បានឮថា ព្រះលោឡុទាយីនោះ ទៅកាន់ផ្ទះនៃជនទាំងឡាយអ្នកធ្វើនូវមង្គល ក៏ពោលនូវអពមង្គល ដោយន័យជាដើម **តិរោកុឌ្ឌេសុ តិដ្ឋន្តិ (ប្រេតទាំងឡាយរមែងឈរនៅខាងក្រៅជញ្ជាំងខ្ទះ)** ទៅកាន់ផ្ទះជនអ្នកធ្វើអពមង្គល កាលដែលគួរពោលតិរោកុឌ្ឌសូត្រជាដើម ត្រឡប់ជាពោលមង្គលគាថា ដោយន័យជាដើមថា **ទានញ្ច ធម្មចរិយា ច (ទាន និងធម្មចរិយា)** ឬរតនសូត្រ ជាដើមថា **យំកិញ្ចិ វិត្តំ ឥធ វា ហុរំ វា (ទ្រព្យជាទីពេញចិត្តណាមួយក្នុងលោកនេះ ឬលោកដទៃ)** ទៅវិញ លោកគិតថា "យើងនឹងពោលសូត្រដទៃ" សូម្បីពោលសូត្រដទៃក្នុងទីនោះៗ ដូច្នោះ ក៏មិនដឹងថា "យើងពោលសូត្រដទៃ" ។*

*ភិក្ខុទាំងឡាយស្តាប់នូវកថារបស់លោកហើយ ក៏ក្រាបទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី ព្រះលោឡុទាយី ក្នុងទីធ្វើមង្គល និងអពមង្គល គួរពោលសូត្រដទៃ ក៏បែរជាពោលសូត្រដទៃវិញ" ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ លោឡុទាយីនេះ តែងពោលយ៉ាងនោះ មិន*

មែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីកាលមុន លោឡុទាយី កាលពាក្យដទៃ ដែលខ្លួនគួរពោល ក៏បែរជាពោលពាក្យដទៃវិញដែរ” ភិក្ខុទាំងនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះ ៖

## បុព្វកម្មរបស់ព្រះលោឡុទាយី

ក្នុងអតីតកាល បុត្ររបស់អគ្គិទត្តព្រាហ្មណ៍ ឈ្មោះសោមទត្តកុមារ ជាអ្នកបម្រើព្រះរាជា ។ សោមទត្តកុមារ បានជាទីប្រោសប្រាណពេញព្រះទ័យរបស់ព្រះរាជា ។ ចំណែកខាងព្រាហ្មណ៍ រស់នៅអាស្រ័យរបរកសិកម្ម ។ ព្រាហ្មណ៍នោះ មានគោពីរក្បាល បណ្ដាគោពីរក្បាលទាំងនោះ គោមួយងាប់ទៅ ។ ទើបព្រាហ្មណ៍ពោលនឹងបុត្រថា “សោមទត្តកូន ចូរកូនទូលសូមគោអំពីព្រះរាជាឲ្យពុកមួយក្បាល” ។

មហាតលិកសោមទត្ត គិតថា “ប្រសិនបើយើងទូលសូមព្រះរាជទានពីព្រះរាជាសោត ភាពជាមនុស្សអន់ខ្សោយរបស់យើងរមែងប្រាកដ” លុះគិតដូច្នោះហើយ ក៏និយាយនឹងឪពុករបស់ខ្លួនថា “លោកពុក សូមពុកទូលសូមខ្លួនឯងចុះ” កាលបិតានិយាយថា “បើដូច្នោះ ចូរកូននាំពុកទៅ” ទើបគិតថា “ព្រាហ្មណ៍នេះ មានបញ្ញាទន់ខ្សោយ រមែងមិនដឹងសូម្បីត្រឹមតែពាក្យនិយាយជាដើមថា ចូរឈានទៅខាងមុខ ចូរឈានថយក្រោយ” កាលពាក្យដែលខ្លួនគប្បីពោល ក៏បែរជាពោលពាក្យដទៃទៅវិញ យើងនឹងបង្រៀនគាត់ ហើយសឹមនាំគាត់ទៅ” ។ សោមទត្តៈនាំបិតាទៅកាន់ព្រៃខ្មោច ឈ្មោះវីរណត្ថម្ភកៈ

ទើបចងបាច់ស្មៅច្រើនបាច់ ធ្វើនូវការកំណត់ថា "បាច់ស្មៅនេះជាស្ដេចផែនដី បាច់ស្មៅនេះជាឧបរាជ បាច់ស្មៅនេះជាសេនាបតី" ដូច្នេះជាដើម ប្រាប់បិតាតាមលំដាប់ហើយ ទើបបន្ទាប់ថា "លោកពុក ពុកធ្វើដំណើរទៅដល់រាជត្រកូល ត្រូវដើរទៅមុខយ៉ាងនេះ ត្រូវថយក្រោយយ៉ាងនេះ ស្ដេចផែនដីត្រូវក្រាបបង្គំទូលយ៉ាងនេះ ឧបរាជត្រូវពោលយ៉ាងនេះ ពុកចូលគាល់ស្ដេចផែនដីហើយ ត្រូវថ្វាយជ័យមង្គលយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រកបដោយជ័យជម្នះចុះ គប្បីពោលគាថានេះ ហើយទូលសូមឲ្យព្រះរាជាព្រះរាជទានគោ" ឲ្យបិតារៀនគាថាថា

បពិត្រមហារាជ គោសម្រាប់ភ្ជួរស្រែរបស់ខ្ញុំព្រះអង្គ
មានពីរក្បាល បណ្ដាគោទាំងពីរក្បាលនោះ គោមួយ
ក្បាលងាប់ទៅហើយ បពិត្រព្រះមហាក្សត្រិយ សូម
ព្រះអង្គទ្រង់ព្រះរាជទានគោទី ២ ដល់ខ្ញុំព្រះអង្គ ។

### សោមទត្តនាំបិតាចូលទៅគាល់ព្រះរាជា

ព្រាហ្មណ៍នោះ ទន្ទេញគាថានោះ ឲ្យចាំស្ទាត់អស់កាលប្រមាណមួយឆ្នាំ ទើបប្រាប់ភាវៈនៃការចាំស្ទាត់ដល់បុត្រ កាលសោមទត្តៈពោលថា "លោកពុក បើដូច្នោះ សូមពុកកាន់យកគ្រឿងបណ្ណាការបន្តិចបន្តួចនេះទៅតាមក្រោយចុះ ខ្ញុំទៅមុន" ក៏ពោលថា "ប្រពៃហើយកូន" ហើយកាន់គ្រឿងបណ្ណាការធ្វើដំណើរទៅកាន់រាជត្រកូល ក្នុងកាលដែលសោមទត្តៈឈរនៅក្នុងរាជសំណាក់

ជាអ្នកមានព្រះរាជបដិសណ្ឋារៈ ដែលព្រះរាជាមានព្រះទ័យត្រេកអរ ទ្រង់ធ្វើ ហើយ កាលព្រះរាជាត្រាស់ថា "លោកតា មកដល់យូរហើយឬ នេះទីអង្គុយ ចូរអង្គុយហើយពោលមកចុះ អ្នកត្រូវការវត្ថុណា" ទើបពោលគាថានេះថា ៖

បពិត្រព្រះមហារាជ គោសម្រាប់ភ្ជួរស្រែរបស់ខ្ញុំព្រះអង្គ មាន
ពីរក្បាល ក្នុងគោពីរក្បាលនោះ គោមួយក្បាលងាប់ទៅហើយ
បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ទទួលយកគោក្បាលទី
២ នោះចុះ ។

សូម្បីកាលព្រះរាជាត្រាស់ថា "លោកតា លោកពោលអ្វី ចូរពោលម្តង ទៀត" ព្រាហ្មណ៍នោះ ក៏ពោលគាថាបទនោះឯង ។ ព្រះរាជាទ្រង់ជ្រាបថា ព្រាហ្មណ៍នេះពោលគាថាខុស ក៏ទ្រង់ញញឹម ហើយត្រាស់ថា "ម្នាលសោមទត្ត ក្នុងផ្ទះរបស់អ្នកប្រហែលជាមានគោច្រើនហើយមើលទៅ" កាលសោមទត្តក្រាប ទូលថា "បពិត្រព្រះសម្មតិទេព ប្រសិនបើព្រះអង្គទ្រង់ប្រោសព្រះរាជទានគោ ក្នុងផ្ទះរបស់ខ្ញុំព្រះអង្គនឹងមានច្រើន" លុះទ្រង់ស្តាប់ដូច្នេះហើយ ទ្រង់ត្រេកអរ ចំពោះគាថារបស់សោមទត្តពោធិសត្វ ទើបព្រះរាជទានគោ ១៦ ក្បាល ដល់ ព្រាហ្មណ៍ មួយអន្លើដោយគ្រឿងអលង្ការ និងស្រុកសួយដល់ព្រះពោធិសត្វ ឲ្យជាទេយ្យវត្ថុដ៏ប្រសើរ ហើយទ្រង់បញ្ជូនព្រាហ្មណ៍ទៅដោយយសដ៏ធំ ។

## អ្នកមានស្តាប់តិចប្រៀបដូចជាគោបម្រើ

ព្រះសាស្តា ទ្រង់នាំធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា "ព្រះ

រាជាក្នុងកាលនោះ បានមកជាអានន្ទ តាព្រាហ្មណ៍ បានមកជាលោឡុទាយី មហាតលិកសោមទត្ត គឺ តថាគត" ហើយទ្រង់មានព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ លោឡុទាយីនេះ កាលពាក្យដទៃដែលខ្លួនគួរពោល ក៏បែរជាពោលពាក្យដទៃវិញ មិនមែនតែក្នុងឥឡូវនេះទេ សូម្បីក្នុងកាលមុន គេក៏និយាយហើយ ព្រោះខ្លួនជាអ្នកមានធម៌បានស្តាប់តិច ព្រោះថា បុគ្គលមានការស្តាប់តិច ឈ្មោះថា ដូចជាគោបម្រើ" ទើបត្រាស់ព្រះគាថានេះថា ៖

*៧. អប្បស្សុតាយំ បុរិសោ ពលិពទ្ទោវ ជីរតិ*
*មំសានិ តស្ស វឌ្ឍន្តិ បញ្ញា តស្ស ន វឌ្ឍតិ ។*

*បុរសអ្នកមានការស្តាប់តិច តែងចាស់ (ឥតអំពើ) ដូចគោបម្រើ សាច់របស់វាតែងចម្រើនឡើង តែប្រាជ្ញារបស់វាមិនចម្រើនឡើយ ។*

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អប្បស្សុតាយំ (បុគ្គលមានការស្តាប់តិច)** សេចក្តីថា បុគ្គលដែលឈ្មោះថា អ្នកមានការស្តាប់តិច ព្រោះមិនមានបណ្ណាសកៈមួយ ឬពីរ ឬក៏ព្រោះមិនមានវគ្គនៃសូត្រមួយ ឬពីរ ដោយហោចទៅសូម្បីតែមួយព្រះសូត្រ ឬពីរព្រះសូត្រក៏មិនមាន តែបានរៀនកម្មដ្ឋានតិចតួច ហើយប្រកបសេចក្តីព្យាយាមរឿយៗ ក៏គង់ជាពហុស្សុតបានដែរ ។

បទថា **ពលិពទ្ទោវ ជីរតិ (រមែងចាស់ដូចគោប្រើ)** សេចក្តីថា ដូចគោ

បម្រើ កាលចាស់ គឺ ចម្រើនសាច់ រមែងធំធាត់ដើម្បីប្រយោជន៍ដល់មេបាក៏ទេ ដល់គោជាបងប្អូនដ៏សេសក៏ទេ ដោយពិត ក៏ចាស់មិនមានប្រយោជន៍យ៉ាងណា សូម្បីអ្នកដែលមានការស្ដាប់តិចនេះ មិនធ្វើឧបជ្ឈាយវត្ត មិនធ្វើអាចរិយវត្ត និងមិនធ្វើវត្តដទៃ មានអាគន្តុកវត្តជាដើម មិនខំប្រកបព្យាយាម សូម្បីត្រឹមតែភាវនា ឈ្មោះថា រមែងចាស់ទៅរកប្រយោជន៍គ្មានដូច្នោះឯង ។

បទថា **មំសានិ តស្ស វឌ្ឍន្តិ** (សាច់របស់គេរមែងចម្រើន) មានអធិប្បាយថា សាច់របស់គោបម្រើដែលម្ចាស់គិតថា "គោនេះ មិនអាចនាំនូវនង្គ័លជាដើមក្ដូវបាន" ហើយលែងចោលទៅក្នុងព្រៃ ដើរស៊ីផឹកក្នុងព្រៃនោះឯង រមែងធាត់ យ៉ាងណា សូម្បីបុគ្គលមានការស្ដាប់តិចនេះ ដែលព្រះគរុដ្ឋានិយ មានព្រះឧបជ្ឈាយ៍ជាដើមលះបង់ហើយ អាស្រ័យសង្ឃ បានបច្ច័យ ៤ ធ្វើកិច្ចមានការបញ្ចុះផ្ទៃជាដើម ចិញ្ចឹមខ្លួន រមែងចម្រើន គឺថា លោកជាអ្នកមានរាងកាយធំធាត់ ត្រាច់ទៅ ដូច្នោះនោះឯង ។

ពីរបទថា **បញ្ញា តស្ស** (បញ្ញានោះ) នេះ មានសេចក្ដីថា ចំណែកបញ្ញាដែលជាលោកិយៈ និងលោកុត្តរៈ របស់បុគ្គលស្ដាប់តិចនោះ សូម្បីតែមួយអង្គុលី ក៏មិនចម្រើនដែរ តែតណ្ហា និងមានះ ៩ យ៉ាង រមែងចម្រើន ព្រោះអាស្រ័យទ្វារ ៦ ដូចជាគុម្ពស្មៅ និងវល្លិជាដើម ចម្រើនហើយក្នុងព្រៃ ដូច្នោះ ។

ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន ក៏បានសម្រេចអរិយផល

*ទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។*

ចប់ រឿងព្រះលោឡុទាយី

# ៨. រឿងបឋមពោធិកាល

ព្រះសាស្តា កាលប្រថាប់នៅត្រង់គល់ពោធិព្រឹក្ស ទ្រង់បន្លឺនូវឧទានវាចា ដោយអំណាចសេចក្តីរីករាយព្រះហឫទ័យ ក្នុងសម័យក្រោយមក ព្រះអានន្ទទូលសួរ ទើបត្រាស់ព្រះធម្មទេសនានេះថា **អនេកជាតិសំសារំ (មកកាន់សង្សារមានជាតិជាអនេក)** ជាដើម ។

ទ្រង់កម្ចាត់មារហើយបន្លឺឧទាន

ព្រះសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ប្រថាប់នៅត្រង់គល់ពោធិព្រឹក្ស ទ្រង់បានកម្ចាត់នូវមារ និងពលនៃមារ ទាំងដែលព្រះអាទិត្យមិនទាន់អស្តង្គតម្ល៉េះ ក្នុងបឋមយាម ទ្រង់ទម្លាយបង់កាពង់ងឹត ដែលបិទបាំងនូវបុព្វេនិវាសញ្ញាណ ក្នុងមជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុឲ្យបរិសុទ្ធ ក្នុងបច្ឆិមយាម ទ្រង់អាស្រ័យបានសេចក្តីករុណាក្នុងសត្វទាំងឡាយ ទ្រង់ញ៉ាំងព្រះញាណចុះក្នុងបច្ចយាការហើយទ្រង់ពិចារណាបច្ចយាការនោះ ដោយអំណាចនៃអនុលោមបដិលោម ។ ក្នុងវេលាអរុណរះឡើង ទ្រង់សម្រេចព្រះសម្មាសម្ពោធិញ្ញាណ មួយអន្លើដោយហេតុអស្ចារ្យច្រើនយ៉ាង កាលនឹងទ្រង់បន្លឺឧទានដែលព្រះពុទ្ធគ្រប់ៗ ព្រះអង្គទ្រង់មិនលះបង់ ទើបបានភាសិតព្រះគាថាទាំងនេះថា ៖

*៨. អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ*
*គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។*

គហការក ទិដ្ឋោសិ        បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា    គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ          តណ្ហានំ ខយមជ្ឈគា ។

កាលតថាគត មិនទាន់បានជួបប្រទះ (ពោធិញ្ញាណវល់តែ) ស្វះស្វែងរកជាងផ្ទះ គឺ តណ្ហា អ្នកធ្វើផ្ទះ គឺ អត្តភាព ក៏អន្ទោល ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ការកើតជាទុក្ខរឿយៗ ។ នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺ អត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត) ទៀតមិនបានឡើយ ឆ្អឹងជំនីរ គឺ កិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ជំបូលផ្ទះ គឺ អវិជ្ជា តថាគតកំចាត់ចោលហើយ ចិត្តរបស់ តថាគត ដល់ព្រះនិព្វានដែលមានសង្ខារទៅប្រាសហើយ តថា-គតបានដល់នូវធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទពីរថា គហការំ គវេសន្តោ (ស្វែងរកជាងអ្នកធ្វើផ្ទះ) សេចក្តីថា តថាគតកាលស្វែងរកជាង គឺ តណ្ហា ដែលធ្វើផ្ទះ ពោល គឺ អត្តភាពនេះ មានអភិនីហារធ្វើទុកហើយទៀបបាទមូលនៃព្រះពុទ្ធព្រះនាម ទីបង្ករ ដើម្បីប្រយោជន៍ដល់ញាណ ដែលជាគ្រឿងអាចឃើញជាងនោះបាន គឺ ពោធិញ្ញាណ កាលមិនជួបប្រទះ គឺ មិនបានព្រះញាណនោះឯង ទើបស្ទុះ

ទៅ គឺ អន្ទោលទៅហើយ បានវិលវល់ទៅមកៗ កាន់សង្សារ មានជាតិជាអនេក គឺ កាន់សង្សារវដ្តនេះ មានការរាប់ដោយសែនជាតិ នៃជាតិជាអនេកអស់កាលមានប្រមាណប៉ុណ្ណេះ ។

បទថា **ទុក្ខា ជាតិ បុនប្បុនំ (ការកើតរឿយៗ ជាទុក្ខ)** នេះ ជាពាក្យសម្តែងហេតុនៃការស្វែងរកជាងធ្វើផ្ទះ ដែលឈ្មោះថា ជាតិនេះ គឺ ការចូលដល់រឿយៗ ឈ្មោះថា ជាទុក្ខ ព្រោះការៈដែលលាយដោយជរា ព្យាធិ និងមរណៈ ក៏ជាតិនោះ កាលជាងផ្ទះនោះ ដែលនរណាៗ មិនជួបហើយ រមែងមិនត្រឡប់ ដូច្នោះ តថាគតកាលស្វែងរកជាងផ្ទះ ទើបបានអន្ទោលទៅ ។

បទថា **ទិដ្ឋោសិ (តថាគតជួបអ្នកហើយ)** សេចក្តីថា ឥឡូវនេះ តថាគតត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ បានឃើញអ្នកច្បាស់ហើយ ។ បទថា **បុន គេហំ (ផ្ទះទៀត)** អ្នកនឹងធ្វើផ្ទះរបស់តថាគត ពោលគឺ អត្តភាពក្នុងសង្សារវដ្តនេះទៀតមិនបានឡើយ ។

បទថា **សព្វា តេ ផាសុកា ភគ្គា (ឆ្អឹងជំនីគ្រប់ចំណែករបស់អ្នក តថា-គតកាច់បំបាក់ហើយ)** សេចក្តីថា ឆ្អឹងជំនីរ ពោលគឺ កិលេសដ៏សេសទាំងអស់របស់អ្នក តថាគតកាច់បំបាក់ហើយ ។ បទថា **គហកូដំ វិសង្ខតំ (ដំបូលផ្ទះតថាគតក៏រុះរើចេញហើយ)** សេចក្តីថា សូម្បីមណ្ឌលហោជាង ពោលគឺ អវិជ្ជានៃផ្ទះ គឺ អត្តភាពដែលអ្នកសាងហើយ តថាគតក៏កម្ចាត់បង់ចោលហើយ ។

បទថា **វិសង្ខារគតំ ចិត្តំ (ចិត្តរបស់តថាគតដល់នូវធម៌ដែលជាគ្រឿង

***តាក់តែងប្រាសទៅហើយ)*** សេចក្តីថា ឥឡូវនេះ ចិត្តរបស់តថាគតដល់ គឺ ចូលដល់ធម៌ដែលប្រាសចាកគ្រឿងតាក់តែងហើយ គឺ ព្រះនិព្វាន ដោយអំណាច នៃការធ្វើឲ្យជាអារម្មណ៍ ។ បទថា ***តណ្ហានំ ខយមជ្ឈគា (តថាគតចាក់ធ្លុះធម៌ ដែលអស់តណ្ហាហើយ)*** សេចក្តីថា តថាគតបានសម្រេចព្រះអរហត្ត ពោលគឺ ធម៌ដែលជាទីអស់ទៅនៃតណ្ហាទាំងឡាយហើយ ។

ចប់ រឿងបឋមពោធិកាល

# ៩. រឿងបុត្រសេដ្ឋីមានទ្រព្យច្រើន

*ព្រះសាស្តា កាលប្រថាប់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់ប្រារព្ធបុត្រសេដ្ឋីអ្នកមានទ្រព្យច្រើន ត្រាស់ព្រះធម្មទេសនានេះថា* ***អចរិត្វា ព្រហ្មចរិយំ (មិនប្រព្រឹត្តព្រហ្មចរិយៈ)*** *ជាដើម ។*

ពួកអ្នកលេងបបួលសេដ្ឋីបុត្រឱ្យផឹកសុរា

*ដូចបានស្តាប់មក សេដ្ឋីបុត្រនោះ កើតក្នុងត្រកូលអ្នកមានសម្បត្តិ ៨០ កោដិ ក្នុងក្រុងពារាណសី ។ គ្រានោះ មាតាបិតានៃសេដ្ឋីបុត្រនោះ គិតគ្នាថា "ត្រកូលរបស់យើង មានគំនរទ្រព្យច្រើន យើងនឹងប្រគល់គំនរទ្រព្យនោះឲ្យបុត្ររបស់យើងប្រើប្រាស់យ៉ាងសប្បាយ កិច្ចដោយការងារដទៃមិនចាំបាច់មាន" ដូច្នេះហើយ ទើបឲ្យកូនសិក្សាសិល្បៈ ត្រឹមតែការរាំ ច្រៀង និងការប្រគំតែប៉ុណ្ណោះ ។ ក៏ក្នុងនគរនោះឯង មានធីតាម្នាក់កើតក្នុងត្រកូលមួយទៀត ដែលមានសម្បត្តិ ៨០ កោដិដែរ ។ សូម្បីមាតាបិតារបស់នាង ក៏គិតដូចមាតាបិតារបស់សេដ្ឋីបុត្រដែរ ហើយក៏ឲ្យនាងសិក្សាសិល្បៈត្រឹមតែការរាំ ច្រៀង និងការប្រគំតែប៉ុណ្ណោះ ។ កាលអ្នកទាំងពីរចម្រើនវ័យហើយ ក៏រៀបការជាមួយគ្នា ក្រោយមក មាតាបិតារបស់អ្នកទាំងពីរនោះបានស្លាប់ទៅ ។ ទ្រព្យ ១៦០ កោដិ ក៏បានរួមនៅក្នុងផ្ទះតែមួយ ។ សេដ្ឋីបុត្រតែងតែទៅកាន់ទីជាទីបម្រើនៃព្រះរាជាមួយថ្ងៃ ៣ ដង ។ គ្រានោះ ពួកអ្នកលេងក្នុងនគរនោះគិតគ្នាថា "បើ*

សេដ្ឋីបុត្រនេះ នឹងជាអ្នកលេងសុរា សេចក្តីសប្បាយនឹងមានដល់ពួកយើងជាមិនខាន យើងនឹងញ៉ាំងសេដ្ឋីបុត្រឲ្យរៀនទូវភាពជាអ្នកលេងសុរា" ។ ពួកអ្នកលេងទាំងនោះ ទើបកាន់យកសុរា ចងសាច់ និងដុំអំបិលទុកក្នុងជាយសំពត់ កាន់ផែថាវ អង្គុយចាំមើលផ្លូវសេដ្ឋីបុត្រនោះ ចេញមកអំពីរាជត្រកូល ឃើញសេដ្ឋីបុត្រកំពុងដើរមក ក៏ផឹកសុរា យកដុំអំបិលដាក់ចូលទៅក្នុងមាត់ ខាំផែថាវ ពោលថា "សូមសេដ្ឋីបុត្ររស់នៅអស់រយនៃឆ្នាំចុះ ពួកខ្ញុំអាស្រ័យលោកគប្បីជាអ្នកអាចក្នុងការទំពាស៊ី និងការផឹក" ។

បុត្រសេដ្ឋីស្តាប់ពាក្យរបស់ពួកអ្នកលេងនោះហើយ ទើបសួរអ្នកបម្រើជិតដិតដែលដើរមកតាមក្រោយថា "ពួកនុ៎ះ គេកំពុងផឹកអ្វី?"

អ្នកបម្រើ. ពួកគេកំពុងផឹកទឹកមួយប្រភេទ លោកម្ចាស់ ។

សេដ្ឋីបុត្រ. ទឹកនោះមានរសជាតិឆ្ងាញ់ឬ?

អ្នកបម្រើ. លោកម្ចាស់ ធម្មតាទឹកដែលគួរផឹក ប្រាកដស្មើដោយទឹកនេះ មិនមានក្នុងលោកនេះទេ ។

## សេដ្ឋីបុត្រខូចខ្លួនព្រោះប្រព្រឹត្តអបាយមុខ

បុត្រសេដ្ឋីនោះនិយាយថា "បើដូច្នោះ សូម្បីយើងផឹកក៏គួរ" ហើយឲ្យគេនាំយកមកបន្តិច ហើយក៏ផឹក តមកមិនយូរប៉ុន្មាន អ្នកលេងទាំងនោះដឹងថាសេដ្ឋីបុត្រចេះផឹកហើយ ក៏នាំគ្នាចោមរោមសេដ្ឋីបុត្រនោះ កាលកន្លងទៅមិនយូរ សេដ្ឋីបុត្រក៏មានបរិវារច្រើន ។ សេដ្ឋីបុត្រនោះប្រើឲ្យគេនាំសុរាមកដោយ

ទ្រព្យមួយរយខ្ទះ ពីររយខ្ទះ ហើយផឹក តាំងគំនរកហាបណៈទុកក្នុងទីអន្តុយជាដើម ផឹកសុរាបណ្តើរ ពោលបណ្តើរថា "ចូរនាំយកផ្កាឈើមក ដោយកហាបណៈនេះ ចូរនាំយកគ្រឿងក្រអូបមកដោយកហាបណៈនេះ អ្នកនេះឈ្លាសក្នុងការរាំ អ្នកនេះឈ្លាសក្នុងការច្រៀង អ្នកនេះឈ្លាសក្នុងការប្រគំ ចូរឲ្យទ្រព្យមួយពាន់ដល់អ្នកនេះ ចូរឲ្យទ្រព្យពីរពាន់ដល់អ្នកនេះ" កាលសេដ្ឋីបុត្រចាយទ្រព្យខ្ជះខ្ជាយយ៉ាងនោះ អស់កាលមិនយូរប៉ុន្មាន ក៏ធ្វើទ្រព្យ ៨០ កោដិដែលជាទ្រព្យរបស់ខ្លួនឲ្យអស់ទៅ កាលហេរញ្ញិកប្រាប់ថា "លោកម្ចាស់ ទ្រព្យរបស់លោកអស់ហើយ ក៏និយាយថា "ទ្រព្យភរិយារបស់អញ មិនមានទេឬ" កាលហេរញ្ញិកប្រាប់ថា "នៅមាន" ទើបប្រាប់ថា "បើដូច្នោះ ចូរយកទ្រព្យនោះមក" បានធ្វើទ្រព្យសម្បត្តិទាំងនោះ ឲ្យអស់ទៅយ៉ាងនោះដូចគ្នា ហើយលក់សម្បត្តិរបស់ខ្លួនទាំងអស់ គឺ ស្រែ ចំការ យាន ពាហនៈជាដើម ដោយហោចទៅ សូម្បីតែភាជនៈសម្រាប់ប្រើប្រាស់ សំពត់សម្រាប់ដណ្តប់ និងសំពត់ក្រាលលក់ស៊ីផឹកអស់គ្មានសល់ ។

## សេដ្ឋីបុត្រដើរសូមទាន

ក្នុងកាលដែលគេកុហក ម្ចាស់ផ្ទះបានដេញគេចេញអំពីផ្ទះ ព្រោះគេមានទ្រព្យអស់ហើយ លក់ផ្ទះរបស់ខ្លួន ដែលធ្លាប់អាស្រ័យនៅអំពីមុន គេនាំភរិយាទៅអាស្រ័យនៅតាមសំយាបផ្ទះនៃជនដទៃ កាន់អំបែងដើរសូមទានគេបរិភោគភត្តដ៏សេសអំពីជនដទៃ ។ ថ្ងៃមួយ ព្រះសាស្តាទតឃើញអ្នកទាំងពីរ

នោះឈរនៅត្រង់ទ្វារសាលាធាន់ រង់ចាំទទួលភោជនដែលជារបស់ភិក្ខុកំលោះ និងសាមណេរឲ្យ ទើបទ្រង់ធ្វើការញញឹមឲ្យប្រាកដ ។ គ្រានោះ ព្រះអានន្ទ ទូលសួរនូវហេតុដែលនាំឲ្យព្រះអង្គទ្រង់ញញឹម ។ ព្រះសាស្ដាកាលនឹងត្រាស់ប្រាប់នូវហេតុដែលនាំឲ្យព្រះអង្គទ្រង់ញញឹម ក៏បានត្រាស់ដូច្នេះថា "ម្នាលអានន្ទ អ្នកចូរមើលនូវសេដ្ឋីបុត្រដែលមានទ្រព្យច្រើននេះ បំផ្លាញទ្រព្យ ១៦០ កោដិឲ្យអស់ទៅ ហើយនាំភរិយាដើរសូមទានគេក្នុងនគរនេះឯង ម្នាលអានន្ទ បើសេដ្ឋីបុត្រនេះ មិនញុំាំងភោគៈទាំងឡាយឲ្យអស់ទៅ ហើយខំប្រកបការងារក្នុងបឋមវ័យ គេនឹងបានជាអគ្គសេដ្ឋីក្នុងនគរនេះឯង បើចេញបួស នឹងបានសម្រេចព្រះអរហត្ត ភរិយារបស់គេនឹងតាំងនៅក្នុងអនាគាមិផល បើមិនបំផ្លាញទ្រព្យឲ្យអស់ទៅ ហើយខំប្រកបការងារក្នុងមជ្ឈិមវ័យ នឹងបានជាសេដ្ឋីទីពីរ បើចេញបួសនឹងបានជាអនាគាមី ភរិយារបស់គេ នឹងតាំងនៅក្នុងសកទាគាមិផល បើមិនធ្វើទ្រព្យឲ្យអស់ទៅ ប្រកបការងារក្នុងបច្ឆិមវ័យ នឹងបានជាសេដ្ឋីទីបី បើចេញបួសនឹងបានជាសកទាគាមី ភរិយារបស់គេនឹងតាំងនៅក្នុងសោតាបត្តិផល តែឥឡូវនេះ បុត្រសេដ្ឋីនោះ សាបសូន្យទាំងភោគៈជារបស់គ្រហស្ថ សាបសូន្យទាំងសាមញ្ញផល (ផលរបស់សមណៈ) ក៏កាលសាបសូន្យហើយ ទើបដូចជាសត្វក្រៀលក្នុងកក់ស្ងួតដូច្នោះ" ដូច្នេះហើយ ទើបត្រាស់ព្រះគាថាទាំងនេះថា ៖

៩. អចរិត្វា ព្រហ្មចរិយំ   អលទ្ធា យោព្វនេ ធនំ

ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្លលេ
អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ
សេន្តិ ចាបាតិខីណាវ បុរាណានិ អនុត្ថុនំ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលខ្លួននៅជាកំលោះក្រមុំ រមែងសញ្ជប់សញ្ជឹង ដូចសត្វក្រៀលចាស់សំកុកនៅក្នុង ភក់ដែលអស់ត្រីហើយ ។ ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្លួននៅជាកំលោះក្រមុំ រមែងដេកថ្ងូរ សោកស្តាយទ្រព្យចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែបន្ទោះដូច្នោះ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អចរិត្វា** (មិនប្រព្រឹត្ត) សេចក្តីថា មិននៅដោយការប្រព្រឹត្តព្រហ្មចរិយាវាស ។ បទថា **យោព្វនេ** (គ្រានៅកំលោះក្រមុំ) សេចក្តីថា មិនបានទ្រព្យក្នុងកាលដែលខ្លួនអាចញុំាងភោគៈដែលមិនទាន់កើតឲ្យកើតឡើង ឬរក្សាភោគៈដែលកើតឡើងហើយ ។ បទថា **ខីណមច្ឆេ** (ទីអស់ត្រី) សេចក្តីថា ជនពាលបែបនោះ រមែងសោកសៅ ដូចសត្វក្រៀលចាស់មានស្លាបអស់ហើយ សោកសៅនៅក្នុងភក់ ។ ដែលឈ្មោះថា អស់ត្រីហើយព្រោះមិនមានទឹក មានពាក្យអធិប្បាយទុកដូច្នេះថា "ការមិនមានទីនៅរបស់ជនពាលទាំងនេះ ដូចជាការមិនមានទឹកក្នុងភក់ ។ ការមិនមានភោគៈរបស់ជន

ជនពាលទាំងនេះ ដូចជាការអស់ត្រី ការមិនអាចនឹងប្រមូលភោគៈទុកបានតាមផ្លូវទឹក ឬតាមផ្លូវគោកជាដើម ក្នុងកាលនេះឯង ជនពាលទាំងនេះ ទុកដូចជាការមិនមានការហើរឡើងទៅនៃសត្វក្រៀលដែលអស់ស្លាបហើយ ព្រោះហេតុនោះ ជនពាលទាំងនោះ ទើបដេកសញ្ជប់សញ្ជឹងនៅក្នុងទីនេះឯង ដូចសត្វក្រៀលដែលមានស្លាបអស់ហើយ ដូច្នោះ ។

បទថា **ចាបាតិខីណាវ (ដូចគ្រាប់ព្រួញដែលផុតអំពីបន្ទោះ)** សេចក្តីថា ផុតចាកបន្ទោះ គឺ ផុតហើយចាកខ្សែបន្ទោះ មានពាក្យអធិប្បាយពោលទុកដូច្នេះថា "កូនសររបូតផុតពីបន្ទោះទៅតាមកម្លាំង ហើយធ្លាក់ កាលមិនមាននរណាចាប់លើកឡើង ក៏ត្រូវជាចំណីរបស់ពពួកសត្វកណ្តៀរក្នុងទីនោះឯង យ៉ាងណា ជនពាលទាំងនេះ ក៏ដូច្នោះ កន្លងវ័យទាំងបីទៅហើយ ក៏នឹងចូលដល់មរណៈ ព្រោះការមិនអាចនឹងរើខ្លួនឡើងបានក្នុងកាលនេះ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **សេន្តិ ចាបាតិខីណាវ (រមែងដេក... ដូចកូនសរដែលផុតចាកបន្ទោះ**" ។

បទថា **បុរាណានិ អនុត្ថុនំ (វិនាសសូម្បីផ្ទះចាស់)** សេចក្តីថា រមែងដេកសោកសង្រេង គឺ សោកស្តាយរបស់ដែលខ្លួនធ្លាប់ស៊ី ធ្លាប់ផឹក របាំរាំច្រៀង និងការប្រគំជាដើម ដែលខ្លួនធ្វើហើយក្នុងកាលមុនថា "ពួកយើងស៊ីហើយយ៉ាងនេះ ផឹកហើយយ៉ាងនេះ" ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំង

ឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងបុត្រសេដ្ឋីអ្នកមានទ្រព្យច្រើន

## ចប់ជរាវគ្គវណ្ណនា វគ្គទី ១១

ក្នុងវគ្គនេះរួមមាន ០៩ រឿង

១.រឿងស្ត្រីជាសំឡាញ់នាងវិសាខា ២. រឿងនាងសិរិមា
៣.រឿងព្រះនាងឧត្តរាថេរី ៤. រឿងព្រះអធិមានិកភិក្ខុ
៥.រឿងព្រះនាងរូបនន្ទាថេរី ៦.រឿងព្រះនាងមល្លិកាទេវី
៧.រឿងភិក្ខុលោឡុទាយី ៨.រឿងបឋមពោធិកាល
៩.រឿងបុត្តសេដ្ឋីអ្នកមានទ្រព្យច្រើន

# អត្តវគ្គទី ១២

"ពោលអំពីរឿងខ្លួន"

## ១. រឿងពោធិរាជកុមារ

**[ ២២]** *ព្រះសាស្តា កាលប្រថាប់នៅភេសកឡាវ័ន ទ្រង់ប្រារព្ធពោធិ-រាជកុមារ ត្រាស់ព្រះធម្មទេសនានេះថា* ***អត្តានញ្ចេ (បើបុគ្គលដឹងថាខ្លួន)*** *ជាដើម ។*

ពោធិរាជកុមារសាងប្រាសាទហើយគិតសម្លាប់ជាង

*ដូចបានស្តាប់មក ពោធិរាជកុមារឲ្យជាងសាងប្រាសាទឈ្មោះ កោកនទៈ មានទ្រង់ទ្រាយមិនដូចប្រាសាទដទៃៗ លើផែនដី ដូចជាអណ្តែតឰដ៏អាកាស ហើយត្រាស់សួរជាងថា "ប្រាសាទដែលមានរូបរាងយ៉ាងនេះ អ្នកធ្លាប់សាងក្នុងទីដទៃខ្លះហើយឬ ឬថានេះជាសិល្បៈដំបូងរបស់អ្នក" កាលជាងទូលថា "បពិត្រព្រះសម្មតិទេព នេះជាសិល្បៈដំបូងបង្អស់របស់ខ្ញុំព្រះអង្គ" ពោធិរាជកុមារទ្រង់ត្រិះរិះថា "បើជាងនេះសាងប្រាសាទ ដែលមានរូបរាងយ៉ាងនេះ ដល់ជនដទៃសោត ប្រាសាទនេះក៏នឹងមិនគួរឲ្យអស្ចារ្យ កាលដែលយើងសម្លាប់ជាងនេះ កាត់ដៃ និងជើងរបស់គេ ឬខ្វេះភ្នែកទាំងពីរចេញ រមែងគួរ កាលបើដូច្នោះ គេនឹងសាងប្រាសាទដល់ជនដទៃមិនបានឡើយ" ព្រះអង្គបានប្រាប់សេចក្តីនោះ ដល់មាណពបុត្ររបស់សញ្ជីវកដែលជាសំឡាញ់របស់ខ្លួន ។*

## ជាងធ្វើសត្វគ្រុឌជិះគេចពីភ័យ

មាណពនោះគិតថា "ព្រះរាជកុមារអង្គនេះ នឹងបំផ្លាញជាងឲ្យវិនាស ដោយឥតសង្ស័យ បុគ្គលដែលមានសិល្បៈរកតម្លៃមិនបាន បើយើងនៅមាន គេចូរកុំវិនាសឡើយ យើងនឹងឲ្យសញ្ញាដល់គេ" ។ មាណពនោះចូលទៅរកជាង ហើយសួរថា "ការងាររបស់អ្នកត្រង់ប្រាសាទសម្រេចហើយឬនៅ" កាលជាង ប្រាប់ថា "សម្រេចហើយ" ទើបពោលថា "ព្រះរាជកុមារមានបំណងនឹងសម្លាប់ អ្នក ព្រោះដូច្នោះ អ្នកត្រូវរក្សាខ្លួនឲ្យល្អ" ជាងនិយាយថា "លោកប្រាប់សេចក្តី នោះដល់ខ្ញុំ ល្អហើយ ខ្ញុំនឹងជ្រាបកិច្ចដែលគួរធ្វើក្នុងរឿងនេះ" ដូច្នេះហើយ កាល ព្រះរាជកុមារត្រាស់សួរថា "សំឡាញ់ ការងាររបស់អ្នកត្រង់ប្រាសាទរបស់ យើងសម្រេចហើយឬ?" ទើបទូលថា "បពិត្រព្រះសម្មតិទេព ការងារត្រង់ ប្រាសាទនៅមិនទាន់សម្រេចទេ នៅសល់ច្រើនទៀត ។

ព្រះរាជកុមារ. ការងារអ្វី ដែលនៅសល់?

ជាង. បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គនឹងទូល (ឲ្យទ្រង់ជ្រាប) ជាខាង ក្រោយ សូមព្រះអង្គត្រាស់បញ្ជាឲ្យនរណាៗ នាំកំណាត់ឈើមកចុះ ។

រាជកុមារ. នឹងឲ្យគេយកកំណាត់ឈើប្រភេទណា?

ជាង. ឈើស្ងួតមិនមានខ្លឹម ព្រះអង្គ ។

ព្រះអង្គបានត្រាស់បង្គាប់ឲ្យគេជញ្ជូនមកឲ្យហើយ លំដាប់នោះ ជាង ទូលព្រះរាជកុមារនោះថា "បពិត្រព្រះសម្មតិទេព ពីពេលនេះទៅព្រះអង្គមិន

គប្បីមកកាន់សម្នាក់របស់ខ្ញុំព្រះអង្គឡើយ ព្រោះកាលខ្ញុំព្រះអង្គធ្វើការងារដែលល្អិត កាលមានការសន្ទនាគ្នានឹងជនដទៃ សេចក្តីរាយមាយក៏នឹងមាន ម្យ៉ាងទៀត វេលាទទួលទានអាហារ កិរិយារបស់ខ្ញុំព្រះអង្គប៉ុណ្ណោះ នឹងនាំអាហារមក" ។ ព្រះរាជកុមារទទួលថា "ល្អហើយ" ។ ចំណែកជាងអង្គុយចាំងឈើទាំងនោះនៅក្នុងបន្ទប់មួយ ធ្វើជាសត្វគ្រុឌ ដែលគួរដល់បុត្រ និងកិរិយារបស់ខ្លួនអង្គុយខាងក្នុងបាន ក្នុងវេលាទទួលទានអាហារ ប្រាប់កិរិយាថា "នាងចូរលក់របស់គ្រប់យ៉ាងដែលមាននៅក្នុងផ្ទះ ហើយកាន់យកតែមាស និងប្រាក់ចុះ" ។ ចំណែកព្រះរាជកុមារ ត្រាស់បញ្ជាឲ្យឡោមព័ទ្ធប្រាសាទ ទ្រង់ចាត់តាំងការរក្សាដើម្បីប្រយោជន៍មិនឲ្យជាងចេញទៅបាន ។ ឯនាយជាង ក្នុងវេលាដែលធ្វើសត្វស្រេចហើយ ប្រាប់កិរិយាថា "ថ្ងៃនេះ នាងគប្បីនាំក្មេងទាំងអស់មក" ទទួលទានអាហារព្រឹកស្រេចហើយ ឲ្យបុត្រ និងកិរិយាអង្គុយក្នុងពោះសត្វគ្រុឌ គេចចេញតាមបង្អួចទៅ ។ កាលពួកអារក្ខទាំងនោះ កន្ទក់កន្ទេញទូលថា "បពិត្រព្រះសម្មតិទេព ជាងលួចរត់ទៅហើយ" ដូច្នេះ ។ ជាងនោះក៏ទៅចុះត្រង់ហិមវន្តប្រទេស សាងនគរមួយ បានជាព្រះរាជាទ្រង់ព្រះនាមថា **កដ្ឋវាហនៈ** ក្នុងនគរនោះ ។

ព្រះសាស្តាទ្រង់មិនប្រថាប់ជាន់លើសំពត់កម្រាល

ចំណែកព្រះរាជកុមារទ្រង់ត្រិះរិះថា "យើងនឹងធ្វើការឆ្លងប្រាសាទ ទើបត្រាស់ឲ្យនិមន្តព្រះសាស្តា ទ្រង់ធ្វើការប្រស់ព្រំក្នុងប្រាសាទដោយរបស់ក្រអូប

ដែលផ្សំដោយវត្ថុ ៤ យ៉ាង ទ្រង់ក្រាលផ្ទាំងសំពត់តូចតាំងអំពីខ្លោងទ្វារជំបូង មក ។ បានឮថា ព្រះអង្គមិនមានព្រះឱរស ព្រោះដូច្នោះ ទើបទ្រង់ត្រិះរិះថា "បើយើងនឹងបានបុត្រ ឬធីតាសោត ព្រះសាស្តានឹងទ្រង់ជាន់ផ្ទាំងសំពត់នេះ" ទើបទ្រង់ក្រាល ។ ព្រះអង្គ កាលព្រះសាស្តាស្តេចយាងមក បានថ្វាយបង្គំ ព្រះសាស្តាដោយបញ្ចង្គប្រតិស្ឋានហើយ ទទួលបាត្រ ទើបក្រាបទូលថា "សូម ព្រះអង្គស្តេចយាងចុះ ព្រះអង្គ ។ ព្រះសាស្តាស្តេចមិនយាងចូលទៅ ។ ព្រះ រាជកុមារទ្រង់អង្វរ ២-៣ ដង ព្រះសាស្តាក៏ស្តេចមិនយាងចូលទៅ ទ្រង់បាន បែរមើលព្រះអានន្ទ ។ ព្រះថេរៈជ្រាបការដែលទ្រង់មិនប្រថាប់ជាន់លើសំពត់ ទាំងឡាយ ដោយសញ្ញាដែលព្រះអង្គទ្រង់ឆ្មៀងព្រះនេត្រនោះឯង ទើបទូល ឲ្យព្រះរាជកុមារ ប្រមូលសំពត់ទាំងឡាយចេញ ដោយពាក្យថា "ព្រះរាជកុមារ សូមព្រះអង្គប្រមូលសំពត់ទាំងឡាយចេញចុះ ព្រះមានព្រះភាគ ទ្រង់មិនយាង លើផ្ទាំងសំពត់នេះទេ ព្រោះព្រះតថាគត ទ្រង់សម្លឹងឃើញដល់ពពួកជនជំនាន់ ក្រោយ ។

## ព្រះសាស្តាត្រាស់ហេតុដែលទ្រង់មិនយាងជាន់សំពត់

ព្រះរាជកុមារទ្រង់ប្រមូលសំពត់ទាំងឡាយហើយ ទូលនិមន្តព្រះសាស្តា ឲ្យស្តេចយាងចូលទៅខាងក្នុង ទ្រង់អង្គាសឲ្យស្កប់ស្កល់ដោយយាគូ និងរបស់ ទំពាហើយ ក៏គង់នៅត្រង់ចំណែកម្ខាង ថ្វាយបង្គំ ហើយទូលថា "បពិត្រព្រះ អង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាឧបដ្ឋាករបស់ព្រះអង្គ ដល់ព្រះអង្គជាទីពឹង ៣ ដង

ហើយ គឺ ខ្ញុំព្រះអង្គនៅក្នុងផ្ទៃ ដល់ព្រះអង្គជាទីពឹងម្ដង លើកទីពីរក្នុងគ្រា ដែលខ្ញុំព្រះអង្គនៅជាកុមារតូច ចំណែកលើកទី ៣ ក្នុងកាលដែលខ្ញុំព្រះអង្គ ដល់ភាពជាអ្នកដឹងក្ដី ព្រះអង្គទ្រង់មិនប្រថាប់ជាន់ផ្ទាំងសំពត់របស់ខ្ញុំព្រះអង្គ នោះ ព្រោះហេតុអ្វី ?

ព្រះសាស្ដា. រាជកុមារ ចុះព្រះអង្គត្រិះរិះយ៉ាងណា ទើបក្រាលផ្ទាំង សំពត់ ?

រាជកុមារ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគិតដូច្នេះថា "បើយើង នឹងបានបុត្រ ឬធីតាសោត ព្រះសាស្ដាទ្រង់នឹងប្រថាប់ជាន់ផ្ទាំងសំពត់របស់ យើង" ទើបក្រាលផ្ទាំងសំពត់ ។

ព្រះសាស្ដា. ព្រោះហេតុនោះ តថាគតទើបមិនជាន់ ។

រាជកុមារ. បពិត្រព្រះអង្គដ៏ចម្រើន ចុះខ្ញុំព្រះអង្គមិនបានបុត្រ ឬធីតា ពិតមែនឬ ?

ព្រះសាស្ដា. ពិតមែនហើយ រាជកុមារ ។

រាជកុមារ. ព្រោះហេតុអ្វី ព្រះអង្គ ?

ព្រះសាស្ដា. ព្រោះកាលព្រះអង្គ និងព្រះជាយា ជាអ្នកមានសេចក្ដី ប្រមាទក្នុងអត្តភាពមុន ។

រាជកុមារ. ក្នុងកាលណា ព្រះអង្គ ?

## បុព្វកម្មរបស់ពោធិរាជកុមារ

លំដាប់នោះ ព្រះសាស្តាទ្រង់នាំអតីតនិទានមកសំដែងប្រាប់ព្រះរាជ-កុមារនោះ ៖

ដូចបានស្តាប់មក ក្នុងអតីតកាល មនុស្សជាច្រើនរយនាក់ជិះសំពៅដ៏ធំទៅកាន់មហាសមុទ្ទ ។ សំពៅបានក្រឡាប់កណ្តាលសមុទ្ទ ពីរនាក់ស្វាមីភរិយាប្រវេប្រវាបានបន្ទះក្តារមួយ ហែលចូលទៅកាន់កោះតូច ដែលមាននៅក្នុងចន្លោះនោះ មនុស្សដ៏សេស បានស្លាប់ក្នុងមហាសមុទ្ទនោះឯងទាំងអស់ ។ ក៏ពួកសត្វស្លាបជាច្រើន រស់នៅលើកោះនោះឯង ពីរនាក់ប្តីប្រពន្ធមិនឃើញវត្ថុដទៃដែលគួរបរិភោគបាន ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ ក៏ដុតពងសត្វទាំងឡាយហើយបរិភោគ កាលពងសត្វទាំងនោះមិនគ្រប់គ្រាន់ ក៏ចាប់កូនសត្វទាំងឡាយអាំងស៊ី កាលកូនទាំងនោះមិនគ្រប់គ្រាន់ ក៏ចាប់សត្វទាំងឡាយស៊ីទៀត ក្នុងបឋមវ័យក្តី មជ្ឈិមវ័យក្តី បច្ឆិមវ័យក្តី បានបរិភោគយ៉ាងនេះឯង សូម្បីក្នុងវ័យណាមួយ ក៏មានតែសេចក្តីប្រមាទ ម្យ៉ាងទៀត បណ្តាជនទាំងពីរនាក់នោះ សូម្បីតែម្នាក់ ក៏ដល់នូវសេចក្តីប្រមាទនោះឯង ។

## គប្បីរក្សាខ្លួនឲ្យល្អក្នុងវ័យទាំងបី

ព្រះសាស្តា ទ្រង់សំដែងបុព្វកម្មនេះ របស់ពោធិរាជកុមារនោះហើយ ទ្រង់មានព្រះពុទ្ធដីកាត្រាស់ថា "ម្នាលរាជកុមារ ក្នុងកាលនោះ បើព្រះអង្គ និងភរិយាមិនប្រមាទក្នុងវ័យណាមួយសោត បុត្រ ឬធីតា គប្បីកើតឡើងក្នុងវ័យ

ណាមួយ បើអ្នកទាំងពីរសូម្បីតែម្នាក់ជាអ្នកមិនប្រមាទ បុត្រ ឬធីតានឹងអាស្រ័យអ្នកដែលមិនប្រមាទនោះឯង នឹងកើតឡើងបាន ម្នាលរាជកុមារ បុគ្គលកាលបើសម្គាល់ខ្លួនឯងថា ជាទីស្រឡាញ់ គប្បីកុំប្រមាទ រក្សាខ្លួនក្នុងវ័យទាំង ៣ បើមិនអាចរក្សាបានដូច្នោះ គប្បីរក្សាឲ្យបានក្នុងវ័យណាមួយ ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា ៖

១ អត្តានញ្ចេ បិយំ ជញ្ញា     រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណមញ្ញតរំ យាមំ     បដិជគ្គេយ្យ បណ្ឌិតោ ។

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឲ្យល្អ
គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំង ៣ វ័យណាមួយ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **យាមំ** (យាម) នេះ ព្រះសាស្ដាទ្រង់សម្ដែងធ្វើវ័យទាំង ៣ វ័យណាមួយ ឲ្យឈ្មោះថា យាម ព្រោះព្រះអង្គទ្រង់ជាធំក្នុងធម៌ផង ព្រោះព្រះអង្គទ្រង់ឈ្លាសក្នុងវិធីទេសនាផង ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបសេចក្ដីដូច្នេះថា "បើបុគ្គលដឹងខ្លួនឯងថា ជាទីស្រឡាញ់ គប្បីរក្សាខ្លួននោះឲ្យល្អ គឺ គប្បីរក្សាខ្លួននោះ ដោយប្រការដែលខ្លួនបានរក្សាល្អហើយ" ។ បណ្ដាជនអ្នករក្សាខ្លួនទាំងនោះ បើអ្នកជាគ្រហស្ថគប្បីគិតថា "នឹងរក្សាខ្លួន" ដូច្នេះ គប្បីចូលទៅក្នុងបន្ទប់ដែលគេបិទបាំងដោយល្អ ជាអ្នកមានការរក្សាដ៏សម្បូរ នៅលើផ្ទៃប្រាសាទជាន់លើក្ដី បើបព្វជិត នៅក្នុងល្អាងដែលបិទបាំង

យ៉ាងល្អ មានទ្វារ និងបង្អួចដែលបិទហើយក្តី ក៏មិនឈ្មោះថា រក្សាខ្លួនឡើយ ។ តែបុគ្គលជាគ្រហស្ថធ្វើបុណ្យទាំងឡាយ មានទាន សីលជាដើម តាមកម្លាំងរបស់ខ្លួន ឬជាបព្វជិតខ្វល់ខ្វាយក្នុងវត្តបដិវត្ត សិក្សាបរិយត្តិ និងមនសិការហើយ ឈ្មោះថា រមែងរក្សាខ្លួន ។ បុរសជាបណ្ឌិត កាលមិនអាចធ្វើបានយ៉ាងនោះ ក្នុងវ័យទាំង ៣ ត្រូវរក្សាខ្លួនទុកក្នុងវ័យណាមួយ ក៏បានដូចគ្នា ។ បើជាគ្រហស្ថ មិនអាចធ្វើកុសលបានក្នុងបឋមវ័យ ព្រោះវល់នៅក្នុងការលេងក្នុងមជ្ឈិមវ័យ គប្បីជាអ្នកមិនប្រមាទ បំពេញកុសល ។ បើក្នុងមជ្ឈិមវ័យវល់ចិញ្ចឹមបុត្រ និងភរិយា មិនអាចបំពេញកុសលបាន ក្នុងបច្ឆិមវ័យគប្បីបំពេញកុសលឲ្យបាន ។ ដោយអាការយ៉ាងនេះឯង ខ្លួនទើបជាការដែលស្ងួនគ្រងល្អហើយដោយពិត តែបើគេមិនធ្វើដូច្នោះ ខ្លួនរមែងឈ្មោះថា មិនជាទីស្រឡាញ់ឡើយ បុគ្គលនោះ ស្មើគ្នានឹងធ្វើខ្លួននោះ ឲ្យមានអបាយជាទីទៅខាងមុខនោះឯង ។

បើបព្វជិត ក្នុងបឋមវ័យធ្វើការស្វាធ្យាយ ទ្រទ្រង់ចាំ ប្រាប់ ធ្វើវត្ត និងបដិបត្តិ ឈ្មោះថា ប្រមាទ ក្នុងមជ្ឈិមវ័យគប្បីជាអ្នកមិនប្រមាទ បំពេញសមណធម៌ ។

ម្យ៉ាងទៀត បើវល់សាកសួរអដ្ឋកថា និងវិនិច្ឆ័យ និងហេតុនៃព្រះបរិយត្តិដែលខ្លួនរៀនហើយក្នុងបឋមវ័យ ឈ្មោះថា ដល់នូវសេចក្តីប្រមាទក្នុងមជ្ឈិមវ័យ ។ ក្នុងបច្ឆិមវ័យ គប្បីជាអ្នកមិនប្រមាទបំពេញសមណធម៌ចុះ ។

ដោយអាការយ៉ាងនេះ ខ្លួនរមែងជាការដែលបព្វជិតនោះ ស្ងួនគ្រងល្អហើយ ។ តែបើមិនធ្វើដូច្នោះទេ ខ្លួនរមែងឈ្មោះថា មិនជាទីស្រឡាញ់ឡើយ បព្វជិតនោះ ស្មើនឹងធ្វើខ្លួនឲ្យក្តៅក្រហាយ ដោយសេចក្តីក្តៅក្រហាយក្នុងខាងក្រោយ ។

ក្នុងកាលចប់ទេសនា ពោធិរាជកុមារក៏តាំងនៅក្នុងសោតាបត្តិផល ។ ព្រះធម្មទេសនា បានសម្រេចប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

ចប់ រឿងពោធិរាជកុមារ

# ២. រឿងព្រះឧបនន្ទសក្យបុត្រ

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះឧបនន្ទសក្យ-បុត្រ ត្រាស់ព្រះធម្មទេសនានេះថា **អត្តានមេវ បឋមំ** (គប្បីតម្កល់ខ្លួននោះឯង... មុន) ជាដើម ។*

ព្រះថេរៈចេញកិតឧបាយរកលាភ

*ដូចបានស្តាប់មក ព្រះថេរៈនោះឆ្លាតក្នុងធម្មកថា ។ ភិក្ខុជាច្រើនរូបបានស្តាប់ធម្មកថា ដែលបដិសំយុត្តដោយភាពជាអ្នកប្រាថ្នាតិចជាដើមរបស់លោកហើយ តែងបូជាលោកដោយចីវរទាំងឡាយ ហើយសមាទានធុតង្គ ។ ព្រះឧបនន្ទនោះប៉ុណ្ណោះ ទទួលយកបរិក្ខារដែលភិក្ខុទាំងនោះលះហើយ ។ កាលវជ្ជវស្សាមួយជិតចូលមកដល់ ព្រះឧបនន្ទនោះ ក៏ចូលទៅកាន់ជនបទ លំដាប់នោះ សាមណេរ និងភិក្ខុក្នុងវត្តមួយពោលនឹងលោកដោយការស្រឡាញ់ក្នុងធម្មកថិកថា "លោកម្ចាស់ សូមលោកម្ចាស់ចាំវស្សាក្នុងទីនេះចុះ" ។ ព្រះឧប-នន្ទសួរថា "ក្នុងវិហារនេះ បានសំពត់ចំណាំវស្សាប៉ុន្មានផ្ទាំង" កាលភិក្ខុទាំងនោះប្រាប់ថា "បានសំពត់សាដកមួយអន្លមួយផ្ទាំង" ក៏ដាក់ស្បែកជើងទុកក្នុងទីនោះ បានទៅកាន់ទីដទៃទៀត ដល់វិហារទី ២ ហើយសួរថា "ក្នុងវិហារនេះភិក្ខុទាំងឡាយបានអ្វីខ្លះ" កាលពួកភិក្ខុប្រាប់ថា "បានសំពត់ពីរផ្ទាំង" ទើបដាក់ឈើច្រត់ទុក ដល់វិហារទី ៣ សួរថា "ក្នុងវិហារនេះភិក្ខុទាំងឡាយបានអ្វីខ្លះ"*

កាលភិក្ខុទាំងនោះប្រាប់ថា "បានសំពត់ ៣ ផ្ទាំង" ក៏ដាក់កំសៀវទឹកទុក ដល់វិហារទី ៤ សួរថា "ក្នុងវិហារនេះ ភិក្ខុទាំងឡាយបានអ្វីខ្លះ" កាលពួកភិក្ខុប្រាប់ថា "បានសំពត់សាដក ៤ ផ្ទាំង" ក៏ពោលថា "ល្អណាស់ យើងនឹងនៅក្នុងទីនេះ" ហើយក៏ចូលចាំវស្សាក្នុងវិហារនោះ ពោលធម្មកថាដល់គ្រហស្ថ និងភិក្ខុទាំងឡាយនោះឯង ។ គ្រហស្ថ និងភិក្ខុទាំងឡាយនោះ បូជាព្រះឧបនន្ទដោយសំពត់ និងចីវរជាច្រើនសន្ធឹក ។ ព្រះឧបនន្ទនោះ លុះចេញវស្សាហើយ បញ្ជូនដំណឹងទៅក្នុងវិហារដទៃទៀតថា "យើងគួរបានសំពត់ចំណាំវស្សា ព្រោះយើងបានដាក់បរិក្ខារទុកដែរ" ភិក្ខុទាំងឡាយ ត្រូវបញ្ជូនសំពត់ចំណាំវស្សាឲ្យយើង" ឲ្យគេនាំសំពត់ចំណាំវស្សាមកហើយ ផ្ទុកក្នុងយានតូច បរចេញទៅ ។

## ព្រះឧបនន្ទកាត់ក្ដីរឿងវិវាទ

គ្រានោះ ភិក្ខុកំលោះ ២ រូប នៅក្នុងវិហារមួយ បានសំពត់សាដក ២ ផ្ទាំង និងសំពត់កម្ពល ១ ផ្ទាំង មិនអាចនឹងចែកគ្នាបានថា សំពត់សាដកចូរជារបស់លោក សំពត់កម្ពលជារបស់ខ្ញុំ អង្គុយទាស់គ្នានៅក្បែរផ្លូវ ។ ភិក្ខុកំលោះ ២ រូបនោះ ឃើញព្រះថេរៈនោះដើរមក ក៏ពោលថា "សូមលោកម្ចាស់ជួយចែកឲ្យពួកខ្ញុំផង" ។

ព្រះថេរៈ. ពួកលោកចូរចែកគ្នាចុះ ។

ភិក្ខុ. ពួកខ្ញុំមិនអាចទេ លោកម្ចាស់ សូមលោកម្ចាស់ជួយចែកឲ្យពួក

ខ្ញុំផង ។

ព្រះថេរៈ. ពួកលោកនឹងតាមពាក្យរបស់យើងឬ ?

ភិក្ខុ. លោកម្ចាស់ ពួកខ្ញុំនឹងតាម ។

ព្រះថេរៈនោះពោលថា "បើដូច្នោះ ល្អហើយ" ក៏ឲ្យសំពត់សាដក ២ ផ្ទាំងដល់ភិក្ខុកំលោះ ២ រូបនោះ ហើយពោលថា "សំពត់កម្ពលនេះចូរជារបស់ខ្ញុំអ្នកពោលធម្មកថា" ហើយក៏កាន់យកសំពត់កម្ពលដែលមានតំលៃច្រើនចៀសចេញទៅ ។ ពួកភិក្ខុកំលោះក៏កើតសេចក្តីក្តៅក្រហាយ ទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលរឿងនោះ ។

បុព្វកម្មរបស់ព្រះឧបនន្ទ

ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ឧបនន្ទនេះ កាន់យករបស់ពួកអ្នក ធ្វើឲ្យពួកអ្នកក្តៅក្រហាយមិនមែនតែក្នុងឥឡូវនេះទេ សូម្បីកាលមុនក៏ធ្លាប់ធ្វើហើយដូចគ្នា" ហើយទ្រង់នាំអតីតនិទានមក ត្រាស់ថា ៖

ក្នុងអតីតកាល មានសត្វភេ ២ គឺ ភេរកស៊ីតាមមាត់ច្រាំងមួយ ភេរកស៊ីតាមទឹកជ្រៅមួយ បានត្រីថ្កិន ១ ធំ ឈ្លោះទាស់ទែងគ្នាថា "ក្បាលចូរជារបស់យើង កន្ទុយចូរជារបស់អ្នក" មិនអាចចែកគ្នាបាន ឃើញចចកមួយក៏ពោលថា "លោកអើ សូមលោកជួយចែកត្រីនេះឲ្យពួកខ្ញុំ" ។

ចចក. យើងដែលព្រះរាជា តាំងទុកក្នុងតំណែងនៃអ្នកប្រឹក្សា យើងអង្គុយក្នុងទីវិនិច្ឆ័យនោះយូរហើយ ទើបចេញមកដើម្បីត្រូវការសម្រាក ឥឡូវ

នេះ យើងគ្មានឱកាសទេ ។

គេ. លោកអ៊ំ លោកកុំធ្វើយ៉ាងនេះឡើយ មេត្តាជួយចែកឲ្យពួកខ្ញុំផង ។

ចចក. ពួកអ្នកនឹងធ្វើតាមពាក្យរបស់យើងឬ ?

គេ. ពួកខ្ញុំនឹងធ្វើតាម លោកអ៊ំ ។

ចចកនោះពោលថា "បើដូច្នោះ ល្អហើយ" ក៏បានកាត់ក្បាលទុកម្ខាង កាត់កន្ទុយទុកម្ខាង កាលកាត់ហើយពោលថា "នែក្មួយទាំងពីរ ពួកអ្នកទាំងពីរ អ្នកណាត្រាច់តាមមាត់ច្រាំង អ្នកនោះត្រូវបានកន្ទុយ, អ្នកត្រាច់ទៅក្នុងទឹកជ្រៅ ក្បាលត្រូវបានអ្នកនោះ, ចំណែកកណ្ដាលនេះ ត្រូវបានមកយើងជាអ្នកតាំងនៅក្នុងការវិនិច្ឆ័យធម៌" កាលនឹងឲ្យគេទាំងពីរយល់ព្រម ទើបពោលគាថានេះថា ៖

កន្ទុយជារបស់គេ អ្នកត្រាច់រកស៊ីតាមមាត់ច្រាំង, ក្បាលជា
របស់គេ អ្នកត្រាច់រកស៊ីក្នុងទឹកជ្រៅ, ចំណែកកណ្ដាលនេះ
នឹងជារបស់យើងអ្នកតាំងនៅក្នុងធម៌ ។

រួចហើយក៏ពាំកំណាត់កណ្ដាលចៀសចេញទៅ ។ ចំណែកគេទាំងពីរនោះ ក៏កើតសេចក្ដីក្ដៅក្រហាយ បានឈរសម្លឹងមើលចចកនោះ (ទាំងអាក់អន់ចិត្ត) ។

ព្រះសាស្ដាទ្រង់នាំរឿងអតីតនេះហើយ ទើបមានព្រះតម្រាស់ថា "សូម្បីក្នុងអតីតកាល ឧបនន្ទនេះក៏បានធ្វើឲ្យពួកអ្នកឲ្យក្ដៅក្រហាយដែរ" ឲ្យភិក្ខុទាំង

*នោះសុខចិត្តហើយ កាលនឹងទ្រង់តិះដៀលព្រះឧបនន្ទ ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ធម្មតាអ្នកប្រៀនប្រដៅអ្នកដទៃ គប្បីធ្វើខ្លួនឲ្យតាំងនៅក្នុងគុណដ៏សមគួរមុនសិន ហើយបានត្រាស់ព្រះគាថានេះថា ៖*

**២. *អត្តានមេវ បឋមំ បដិរូបេ និវេសយេ***

***អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ ។***

***បណ្ឌិតគួរតម្កល់ខ្លួនទុក ក្នុងគុណដ៏សមគួរជាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃ ជាខាងក្រោយ (ធ្វើយ៉ាងនេះ) នឹងមិនលំបាកឡើយ ។***

អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា បដិរូបេ និវេសយេ (គប្បីតម្កល់... ក្នុងគុណដ៏សមគួរ) បានដល់ គប្បីធ្វើខ្លួនឲ្យតាំងនៅក្នុងគុណដ៏សមគួរ ព្រះសាស្តាត្រាស់ពាក្យនេះថា “បុគ្គលណាបំណងនឹងប្រៀនប្រដៅអ្នកដទៃ ដោយគុណមានការប្រាថ្នាតិចជាដើម ឬដោយបដិបទារបស់ព្រះអរិយវង្សជាដើម បុគ្គលនោះគប្បីធ្វើខ្លួននោះឯង ឲ្យតាំងនៅក្នុងគុណនោះជាមុនសិន លុះតម្កល់ខ្លួនដូច្នោះហើយ គប្បីប្រៀនប្រដៅអ្នកដទៃដោយគុណនោះជាខាងក្រោយ ព្រោះថាបុគ្គលកាលមិនញុំាងខ្លួនឲ្យតាំងនៅក្នុងគុណនោះ ប្រដៅអ្នកដទៃ តែងបានការនិន្ទាពីអ្នកដទៃ ឈ្មោះថា រមែងលំបាក ។ បុគ្គលកាលញុំាងខ្លួនឲ្យតាំងនៅក្នុងគុណនោះហើយ ប្រៀនប្រដៅអ្នកដទៃ រមែងបានការសរសើរអំពីអ្នកដទៃ*

ព្រោះដូច្នោះ ឈ្មោះថា រមែងមិនលំបាកឡើយ ។ បណ្ឌិតកាលធ្វើយ៉ាងនេះ ឈ្មោះថា មិនគប្បីលំបាក" ។

ក្នុងវេលាចប់ទេសនា ភិក្ខុទាំងពីររូបនោះ ក៏តាំងនៅក្នុងសោតាបត្តិ-ផល ។ ព្រះធម្មទេសនារមែងបានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

ចប់ រឿងព្រះឧបនន្ទសក្យបុត្រ

# ៣. រឿងព្រះបធានិកតិស្សត្ថេរ

*ព្រះសាស្ដា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះបធានិកតិ-ស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* ***អត្តានញ្ចេ*** *(បើបុគ្គល... គប្បីធ្វើខ្លួន) ជាដើម ។*

ព្រះបធានិកតិស្សៈចាន់តែប្រដៅអ្នកដទៃ ខ្លួនឯងមិនធ្វើ

*ដូចបានស្ដាប់មក ព្រះថេរៈនោះ រៀនព្រះកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដា ហើយ នាំពួកភិក្ខុប្រមាណ ៥០០ រូប ទៅចាំវស្សាក្នុងព្រៃ ពោលប្រដៅថា "លោកដ៏មានអាយុទាំងឡាយ ពួកលោករៀនព្រះកម្មដ្ឋាន ក្នុងសម្នាក់របស់ព្រះពុទ្ធជាម្ចាស់ដែលទ្រង់ព្រះជន្មនៅ ត្រូវជាអ្នកមិនប្រមាទធ្វើសមណធម៌ចុះ" ដូច្នេះហើយ ខ្លួនឯងក៏ទៅដេក ។ ភិក្ខុទាំងនោះចង្ក្រមក្នុងបឋមយាមហើយ ចូលទៅកាន់វិហារក្នុងមជ្ឈិមយាម ។ ព្រះថេរៈនោះ ទៅកាន់សម្នាក់របស់ភិក្ខុទាំងនោះ ក្នុងវេលាខ្លួនភ្ញាក់ឡើង ពោលថា "ពួកលោកមកដោយគិតថានឹងដេកដូច្នេះឬ ចូរប្រញាប់ទៅធ្វើសមណធម៌ចុះ" ដូច្នេះហើយ ខ្លួនឯងក៏ទៅដេកយ៉ាងនោះទុំឯង ។ ពួកភិក្ខុក៏ចង្ក្រមនៅខាងក្រៅ ក្នុងមជ្ឈិមយាមហើយ ចូលទៅកាន់វិហារក្នុងបច្ឆិមយាម ។ ព្រះថេរៈនោះភ្ញាក់ឡើងម្ដងទៀត ទៅកាន់សម្នាក់របស់ភិក្ខុទាំងនោះ នាំភិក្ខុទាំងនោះចេញចាកវិហារ ហើយខ្លួនឯងក៏ទៅដេកទៀត ។ កាលព្រះថេរៈនោះធ្វើដូច្នោះ រហូតកាលជានិច្ច ភិក្ខុទាំង*

នោះ មិនអាចនឹងធ្វើការស្វាធ្យាយ ឬចម្រើនព្រះកម្មដ្ឋានទុកក្នុងចិត្តបាន ក៏បានដល់នូវភាពជាអ្នករាយមាយ ។ ភិក្ខុទាំងនោះប្រឹក្សាគ្នាថា អាចារ្យរបស់ពួកយើងប្រារព្ធសេចក្ដីព្យាយាមអ្វីខ្លាំងម៉្លេះ ពួកយើងនឹងចាំយាំមើលលោក ពេលយាំចាំមើលលោក ឃើញកិរិយារបស់ព្រះថេរៈនោះ ក៏ពោលថា "អ្នកមានអាយុទាំងឡាយ ពួកយើងវិនាសហើយ អាចារ្យរបស់ពួកយើងស្រែកទទេៗ" បណ្ដាភិក្ខុទាំងនោះ លំបាកពន់ពេក សូម្បីភិក្ខុមួយរូបក៏មិនអាចញ៉ាំងគុណវិសេសឲ្យកើតឡើងបាន ។ ភិក្ខុទាំងនោះចេញវស្សាហើយ ក៏ទៅកាន់សម្នាក់ព្រះសាស្ដា បានបដិសណ្ឋារៈដែលព្រះសាស្ដាទ្រង់ធ្វើហើយ ពេលទ្រង់ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកជាអ្នកមិនប្រមាទ ធ្វើសមណធម៌ឬ" ក៏នាំគ្នាក្រាបទូលរឿងនោះ ។

## រឿងមាន់រងាវមិនត្រូវវេលា

ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះបានធ្វើអន្តរាយដល់ពួកអ្នកមិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនោះក៏បានធ្វើអន្តរាយដល់ពួកអ្នកដែរ" កាលភិក្ខុទាំងនោះទូលអង្វរហើយ ទ្រង់ក៏ញ៉ាំងអកាលរវិកុក្កុដជាតកឲ្យពិស្ដារ (សេចក្ដីសង្ខេប) ថា ៖

មាន់នេះ ធំធាត់ហើយ ក្នុងសម្នាក់របស់អ្នកមិនមែនជា
មាតាបិតា នៅក្នុងត្រកូលមួយមិនមែនជាអាចារ្យ ទើប
មិនស្គាល់កាល ឬមិនមែនកាល ។

ដូច្នេះហើយ ទ្រង់មានព្រះតម្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុកាល ទូន្មានអ្នកដទៃ គប្បីទូន្មានខ្លួនឯងឲ្យល្អ ព្រោះភិក្ខុទូន្មានយ៉ាងនោះ ជាអ្នកហ្វឹកហាត់ល្អហើយ ឈ្មោះថា គប្បីទូន្មានបាន" ហើយត្រាស់ព្រះគាថានេះថា ៖

៣. អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ

សុទន្តោ វត ទមេថ អត្តា ហិ កិរ ទុទ្ទមោ ។

បុគ្គលប្រៀនប្រដៅអ្នកដទៃ យ៉ាងណា ត្រូវធ្វើខ្លួនឲ្យបាន

យ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មាន

អ្នកដទៃបាន ព្រោះថា ខ្លួនកម្រទូន្មានបានពេកណាស់ ។

អធិប្បាយគាថា

គប្បីជ្រាបសេចក្តីនៃព្រះគាថានេះថា ៖

ភិក្ខុពោលហើយថា គប្បីចង្រ្កមក្នុងបឋមយាមជាដើម ឈ្មោះថា រមែងពោលប្រៀនប្រដៅអ្នកដទៃ យ៉ាងណា ខ្លួនឯងក៏ដូច្នោះ ត្រូវអធិដ្ឋានកិច្ចមានចង្រ្កមជាដើម ទើបឈ្មោះថា ធ្វើខ្លួនឯងដូចទូន្មានអ្នកដទៃ ។ កាលបើដូច្នេះ ភិក្ខុនោះជាអ្នកមានខ្លួនទូន្មានល្អហើយ ទើបគួរទូន្មានបុគ្គលដទៃបាន ។ បទថា **សុទន្តោ វត ទមេថ** (អ្នកមានខ្លួនទូន្មានល្អហើយ ទើបគួរទូន្មានដល់អ្នកដទៃ) សេចក្តីថា ភិក្ខុប្រៀនប្រដៅអ្នកដទៃដោយគុណណា ត្រូវជាអ្នកហ្វឹកហាត់ល្អហើយដោយខ្លួនឯង ដោយគុណនោះសិន ទើបគួរទូន្មានអ្នកដទៃ ។ បទថា **អត្តា ហិ កិរ ទុទ្ទមោ** (ព្រោះថា បាបញ្ចថា ខ្លួនទូន្មានបានដោយក្រ) សេចក្តី

ថា ព្រោះថា ឈ្មោះថាខ្លួននេះ ជាសភាពដែលបុគ្គលទូន្មានបានដោយលំបាក ព្រោះហេតុនោះ ខ្លួននោះបុគ្គលគប្បីទូន្មានល្អហើយ ដោយប្រការណា គប្បីទូន្មានខ្លួនដោយប្រការនោះ ។

ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុប្រមាណ ៥០០ រូបនោះ បានសម្រេចព្រះអរហត្តផលហើយ ដូច្នេះឯង ។

ចប់ រឿងព្រះបធានិកតិស្សត្ថេរ

# ៤. រឿងមាតាព្រះកុមារកស្សបៈ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមាតារបស់ព្រះកុមារកស្សបៈ ត្រាស់ព្រះធម្មទេសនានេះថា* ***អត្តា ហិ អត្តនោ នាថោ (ខ្លួននេះឯង ជាទីពឹងរបស់ខ្លួន)*** *ជាដើម ។*

មាតារបស់ព្រះកុមារកស្សបៈបួស

*បានឮថា មាតារបស់ព្រះថេរៈនោះ ជាសេដ្ឋីធីតាក្នុងក្រុងរាជគ្រឹះ បានសូមបព្វជ្ជាតាំងពីខ្លួនទើបនឹងដឹងក្តី តែទោះខំអង្វររឿយៗ ក៏មាតា និងបិតាមិនឲ្យបព្វជ្ជា ចម្រើនវ័យហើយទៅកាន់ត្រកូលស្វាមី ជាអ្នកមានស្វាមីដូចជាទេវតានៅគ្រប់គ្រងផ្ទះ ។ កាលតមកមិនយូរប៉ុន្មាន នាងក៏មានគភ៌ តែនាងមិនដឹងថា ខ្លួនមានគភ៌ឡើយ ញ៉ាំងស្វាមីឲ្យត្រេកអរហើយ ក៏បានសូមបព្វជ្ជា ។ គ្រានោះ ស្វាមីនាំនាងទៅកាន់សម្នាក់នាងភិក្ខុនីជាមួយសក្ការៈដ៏ធំ មិនដឹង ក៏ឲ្យបួសក្នុងសម្នាក់ភិក្ខុនីដែលជាបក្ខពួករបស់ព្រះទេវទត្ត ។ សម័យក្រោយមកនាងត្រូវពួកភិក្ខុនីនោះដឹងថា មានគភ៌ហើយ សួរថា "នេះដូចម្តេចហ្ន៎?" ក៏ប្រាប់ថា "ម៉ែម្ចាស់ នាងខ្ញុំមិនជ្រាបថា នេះដូចម្តេចទេ តែសីលរបស់នាងខ្ញុំមិនបានធ្លុះធ្លាយឡើយ" ។ ពួកនាងភិក្ខុនី នាំនាងទៅកាន់សម្នាក់ព្រះទេវទត្ត ហើយសួរថា "នាងភិក្ខុនីនេះបួសដោយសទ្ធា ពួកខ្ញុំមិនជ្រាបថានាងមានគភ៌ ឥឡូវនេះ ពួកខ្ញុំនឹងធ្វើដូចម្តេច?" ព្រះទេវទត្តគិតហេតុត្រឹមតែប៉ុណ្ណេះថា សេចក្តីអាប់*

ឪន ចូរកុំកើតឡើងដល់ពួកភិក្ខុនីអ្នកធ្វើតាមឱវាទយើង ក៏ពោលថា “ពួកនាង ចូរឲ្យនាងនោះសឹកចេញទៅ” ។ ភិក្ខុនីនោះ ស្តាប់ពាក្យនោះហើយ ពោលថា “នាងម្ចាស់ សូមនាងម្ចាស់ទាំងឡាយកុំឲ្យខ្ញុំវិនាសឡើយ ខ្ញុំមិនបានបួសឧទ្ទិសព្រះទេវទត្តទេ នាងម្ចាស់ទាំងឡាយចូរមកចុះ ចូរនាំខ្ញុំទៅកាន់វត្តជេតពនដែលជាសម្នាក់ព្រះសាស្តា” ។ នាងភិក្ខុនីទាំងនោះនាំនាងទៅកាន់វត្តជេតពន ហើយក្រាបទូលដល់ព្រះសាស្តា ។

## ព្រះកុមារកស្សបៈកើត

ព្រះសាស្តាសូម្បីទ្រង់ជ្រាបថា នាងមានគភ៌តាំងពីនៅជាគ្រហស្ថ តែដើម្បីដោះស្រាយវាទៈជនដទៃ ទើបទ្រង់ឲ្យព្រះបាទបសេនទិកោសល អនាថ-បិណ្ឌិកសេដ្ឋី ចូឡអនាថបិណ្ឌិក មហាឧបាសិកាវិសាខា និងត្រកូលធំៗ ដទៃទៀតមក ហើយទ្រង់បង្គាប់ព្រះឧបាលីថា “អ្នកចូរទៅ ចូរជម្រះកម្មរបស់ភិក្ខុនីនេះឲ្យល្អ កណ្តាលបរិស័ទទាំង ៤” ។ ព្រះថេរៈ ឲ្យគេអញ្ជើញនាងវិសាខាចំពោះព្រះភក្ត្រព្រះរាជា ហើយឲ្យសម្រុះសម្រួលអធិករណ៍នោះ ។ នាងវិសាខាឲ្យមនុស្សព័ទ្ធគ្រឿងបិទបាំង គឺ វាំងនន ពិនិត្យមើលដៃ ជើង ផ្ចិត និងទីបំផុតនៃផ្ទៃរបស់នាងភិក្ខុនីនោះខាងក្នុងវាំងនន ហើយរាប់ខែ និងថ្ងៃទៅដឹងថានាងមានគភ៌កាលនៅជាគ្រហស្ថម្ល៉េះ ទើបប្រាប់សេចក្តីនោះដល់ព្រះថេរៈ គ្រានោះ ព្រះថេរៈញ៉ាំងភាវៈដែលនាងជាអ្នកបរិសុទ្ធឲ្យត្រឡប់តាំងឡើងនៅកណ្តាលបរិស័ទ ។ ក្នុងសម័យដទៃ នាងបានប្រសូតបុត្រ មានអានុភាពច្រើន ដែល

មានការប្រាថ្នាទុកទៀបបាទមូលរបស់ព្រះពុទ្ធជាម្ចាស់ព្រះនាមថា **បទុមុត្តរៈ** ។

ក្រោយមកថ្ងៃមួយ ព្រះរាជាស្ដេចយាងទៅទីជិតសម្នាក់របស់នាងភិក្ខុនី ទ្រង់ស្ដាប់សំឡេងទារក ត្រាស់សួរថា "នេះសំឡេងអ្វី" កាលអាមាត្យក្រាបទូលថា "ព្រះអង្គ បុត្ររបស់នាងភិក្ខុនីនោះកើត នុ៎ះជាសំឡេងបុត្ររបស់នាងភិក្ខុនីនោះ" ទ្រង់ឲ្យនាំកុមារនោះទៅកាន់ព្រះរាជមន្ទីររបស់ព្រះអង្គ បានប្រទានឲ្យដល់មេដោះទាំងឡាយ ។ ក៏ក្នុងថ្ងៃដាក់ឈ្មោះ ជនទាំងឡាយដាក់ឈ្មោះកុមារនោះថា "**កស្សបៈ**" តែចំណាំបានថា កុមារកស្សបៈ ព្រោះកុមារនោះជាអ្នកដែលព្រះរាជាឲ្យចម្រើនហើយ ដោយគ្រឿងរក្សារបស់កុមារ ។ កុមារនោះ វាយក្មេងក្នុងទីលានកីឡា កាលពួកក្មេងពោលថា "ពួកយើងត្រូវមនុស្សមិនមានម៉ែឪវាយ" ទើបចូលទៅគាល់ព្រះរាជា ទូលសួរថា "បពិត្រព្រះអង្គទ្រង់ជាសម្មតិទេព ពួកក្មេងពោលនឹងខ្ញុំព្រះអង្គថា មិនមានមាតា និងបិតា សូមព្រះអង្គត្រាស់ប្រាប់មាតាដល់ខ្ញុំព្រះអង្គ" ព្រះរាជាទ្រង់បង្ហាញស្ត្រីមេដោះទាំងឡាយ ហើយត្រាស់ប្រាប់ថា "ស្ត្រីទាំងនេះជាមាតារបស់អ្នក" ក៏ក្រាបទូលថា "មាតារបស់ខ្ញុំព្រះអង្គមិនមានប៉ុណ្ណេះទេ មាតាខ្ញុំព្រះអង្គមានតែមួយប៉ុណ្ណោះ សូមព្រះអង្គត្រាស់ប្រាប់មាតានោះដល់ខ្ញុំព្រះអង្គចុះ" ។ ព្រះរាជាទ្រង់ព្រះចិន្តាថា "យើងមិនអាចបញ្ឆោតកុមារនេះបាន" ទើបប្រាប់ថា "បា! មាតារបស់អ្នកជាភិក្ខុនី អ្នក គឺ យើងនាំមកអំពីសម្នាក់របស់នាងភិក្ខុនី" ។

## កុមារកស្សបៈចេញបួសសម្រេចព្រះអរហត្ត

កុមារនោះ មានសេចក្ដីសង្វេគកើតឡើងហើយ ដោយហេតុត្រឹមតែប៉ុណ្ណោះឯង ទើបក្រាបទូលថា "បពិត្រព្រះបិតា សូមព្រះអង្គទ្រង់ឲ្យទូលបង្គំបួសចុះ" ព្រះរាជាទ្រង់ទទួលថា "ល្អៗ បុត្រ" ហើយឲ្យកុមារនោះបួសក្នុងសម្នាក់ព្រះសាស្ដា ព្រមទាំងសក្ការៈជាច្រើន ។ កុមារកស្សបៈនោះ បានឧបសម្បទាហើយ ប្រាកដនាមថា **ព្រះកុមារកស្សបៈ** ។ លោករៀនកម្មដ្ឋានទៅក្នុងសម្នាក់ព្រះសាស្ដា ចូលទៅកាន់ព្រៃព្យាយាម មិនអាចនឹងញ៉ាំងនូវគុណវិសេសឲ្យកើតឡើងបាន ទើបគិតថា "យើងនឹងរៀនកម្មដ្ឋានឲ្យវិសេសឡើង" មកកាន់សម្នាក់ព្រះសាស្ដា ហើយនៅក្នុងព្រៃអន្ធវន គ្រានោះភិក្ខុអ្នកធ្វើសមណធម៌រួមគ្នា ក្នុងកាលនៃសាសនាព្រះសម្មាសម្ពុទ្ធកស្សបៈ សម្រេចអនាគាមិផលហើយកើតក្នុងព្រហ្មលោក មកអំពីព្រហ្មលោកសួរបញ្ហា ១៥ ប្រការ ដល់ព្រះកុមារកស្សបៈនោះ ហើយបញ្ជូនទៅដោយពាក្យថា "អ្នកដទៃវៀរព្រះសាស្ដាចេញហើយ ដែលអាចនឹងព្យាករណ៍បញ្ហាទាំងនេះមិនមានទេ" ។ លោកចូរទៅ ចូររៀនសេចក្ដីនៃបញ្ហាទាំងនេះក្នុងសម្នាក់ព្រះសាស្ដាចុះ ។ លោកបានធ្វើដូច្នោះ ក៏សម្រេចព្រះអរហត្ត ក្នុងវេលាដែលព្រះសាស្ដាទ្រង់ឆ្លើយបញ្ហាចប់ ។

## មាតារបស់ព្រះកុមារកស្សបៈសម្រេចព្រះអរហត្ត

ក៏តាំងអំពីថ្ងៃដែលព្រះថេរៈនោះចេញទៅហើយ ទឹកភ្នែកហូរចេញចាកនេត្រាទាំងពីររបស់នាងភិក្ខុនី ដែលជាមាតាអស់ ១២ ឆ្នាំ ។ នាងមានទុក្ខព្រោះ

ប្រាត់ប្រាសចាកបុត្រ (ដូចប្តីប្រពន្ធព្រាត់ប្រាសគ្នាដូច្នោះ) មានមុខជោកដោយទឹកភ្នែកជានិច្ច ត្រាច់ទៅដើម្បីកិច្ចា គ្រាន់តែឃើញព្រះថេរៈក្នុងចន្លោះផ្លូវ ក៏ស្រែកឡើងថា "កូនៗ" ស្ទុះចូលទៅដើម្បីនឹងចាប់ព្រះថេរៈ ក៏បានដួលចុះ ។ នាងមានទឹកដោះហូរចេញ ក្រោកឡើង មានចីវរសើម ទៅចាប់ព្រះថេរៈ ។ ព្រះថេរៈគិតថា "បើមាតានេះ បានពាក្យពីរោះអំពីយើង នាងនឹងវិនាស យើងនឹងចរចាជាមួយមាតានេះដោយពាក្យទ្រគោះ" ។ ខណៈនោះ ព្រះថេរៈពោលនឹងនាងភិក្ខុនីដែលជាមាតានោះថា "នាងដើរមកធ្វើអ្វី ប៉ុណ្ណឹងក៏មិនអាចកាត់ត្រឹមតែសេចក្តីស្រឡាញ់បាន" នាងគិតថា "ឱ! ពាក្យរបស់ព្រះថេរៈគ្រោតគ្រាតណាស់ហ្ន៎" ទើបពោលថា "កូន កូននិយាយអ្វី?" ត្រូវព្រះថេរៈពោលឲ្យដូច្នោះទៀត ទើបគិតថា "យើងមិនអាចទប់ទឹកភ្នែកបានអស់ ១២ ឆ្នាំ ព្រោះហេតុតែបុត្រនេះ តែបុត្ររបស់យើងនេះ មានចិត្តរឹងត្អឹង ប្រយោជន៍អ្វីចំពោះយើងដោយបុត្រនេះ" កាត់សេចក្តីស្នេហាក្នុងបុត្របានហើយ ក៏សម្រេចព្រះអរហត្តក្នុងថ្ងៃនោះឯង ។

## ពួកភិក្ខុនាំគ្នាសរសើរព្រះពុទ្ធគុណ

សម័យក្រោយមក ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា "អ្នកមានអាយុទាំងឡាយ ព្រះកុមារកស្សបៈ និងព្រះថេរី ជាអ្នកសម្បូណ៌ដោយឧបនិស្ស័យយ៉ាងនេះ ត្រូវព្រះទេវទត្តធ្វើឲ្យវិនាសហើយ ចំណែកព្រះសាស្តាទ្រង់ជាទីពឹងរបស់អ្នកទាំងពីរនោះ គួរអស្ចារ្យណាស់ ធម្មតាព្រះពុទ្ធទាំងឡាយទ្រង់ជា

អ្នកអនុគ្រោះលោក" ។

ព្រះសាស្តាស្តេចយាងមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ពេលនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី?" ភិក្ខុទាំងនោះ ក្រាបទូលថា "ដោយរឿងឈ្មោះនេះ ទ្រង់ក៏ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតជាបច្ច័យ ជាទីពំនាក់របស់អ្នកទាំងពីរនេះ មិនមែនតែក្នុងពេលឥឡូវនេះទេ ក្នុងកាលមុន តថាគតក៏បានជាទីពំនាក់របស់អ្នកទាំងពីរនោះដែរ" ហើយទ្រង់ត្រាស់និគ្រោធ-ជាតកនេះ ដោយពិស្តារថា ៖

> អ្នក ឬអ្នកដទៃ គប្បីគប់ម្រឹគឈ្មោះនិគ្រោធតែម្យ៉ាង កុំចូល
> ទៅគប់រកម្រឹគឈ្មោះសាខៈឡើយ ការស្លាប់ក្នុងសម្នាក់របស់
> ម្រឹគឈ្មោះនិគ្រោធប្រសើរជាង ការរស់នៅក្នុងសម្នាក់របស់
> ម្រឹគឈ្មោះសាខៈនោះ មិនប្រសើរឡើយ ។

ទ្រង់ប្រជុំជាតកថា "ម្រឹគឈ្មោះសាខៈក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ សូម្បីបរិស័ទរបស់ម្រឹគឈ្មោះសាខៈនោះ ក៏បានជាបរិស័ទ របស់ទេវទត្តនោះឯង មេម្រឹគដែលដល់វារៈបានមកជាព្រះថេរី កូនម្រឹគបាន មកជាកុមារកស្សបៈ ចំណែកស្តេចម្រឹគឈ្មោះនិគ្រោធ ដែលទៅលះបង់ជីវិត ដល់មេម្រឹគមានគភ៌ គឺ តថាគត" ទ្រង់ប្រកាសភាពដែលព្រះថេរីកាត់សេចក្តី ស្រឡាញ់ក្នុងបុត្រហើយ ធ្វើទីពឹងដល់ខ្លួនឯង ទើបត្រាស់ថា "ម្នាលភិក្ខុទាំង ឡាយ បុគ្គលអាស្រ័យមនុស្សដទៃ មិនអាចដើម្បីនឹងមានសួគ៌ ឬមគ្គសម្រាប់

ទៅបរលោកបានទេ ដូច្នោះ ខ្លួននោះឯងជាទីពឹងរបស់ខ្លួន មនុស្សដទៃទីងធ្វើអ្វីបាន” ហើយត្រាស់ព្រះគាថានេះថា ៖

៤. អត្តា ហិ អត្តនោ នាថោ  កោ ហិ នាថោ បរោ សិយា
អត្តនា ហិ សុទន្តេន  នាថំ លភតិ ទុល្លភំ ។

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **នាថោ** (ទីពឹង) គឺ ជាទីពំនាក់ ព្រះមានព្រះភាគត្រាស់ពាក្យនេះទុកថា “បុគ្គលតាំងនៅក្នុងខ្លួន គឺ សម្បូណ៌ហើយក្នុងខ្លួន អាចធ្វើកុសលហើយដល់សួគ៌ ឬដើម្បីញ៉ាំងមគ្គឲ្យចម្រើន ឬធ្វើឲ្យជាក់ច្បាស់នូវផលបាន ព្រោះហេតុនោះឯង ខ្លួនឯងទើបជាទីពឹងរបស់ខ្លួន អ្នកដទៃណាសោត គប្បីជាទីពឹងរបស់បុគ្គលដទៃបាន ព្រោះបុគ្គលមានខ្លួនហ្វឹកហាត់ល្អហើយ គឺ មិនមានការសេពគប់ខុស រមែងបានទីពឹងដែលគេបានដោយកម្រពោលគឺ អរហត្តផល ។ ក៏បទថា **នាថំ លភតិ ទុល្លភំ** (រមែងបាននូវទីពឹងដែលបុគ្គលបានដោយលំបាក) នេះ ព្រះមានព្រះភាគត្រាស់សំដៅយកព្រះអរហត្ត ។

ក្នុងវេលាចប់ទេសនា ជនជាច្រើននាក់ សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងមាតារបស់ព្រះកុមារកស្សបៈ

# ៥. រឿងឧបាសកឈ្មោះមហាកាល

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកជាព្រះសោតាបន្នម្នាក់ ឈ្មោះមហាកាល ត្រាស់ព្រះធម្មទេសនានេះថា* ***អត្តនា ហិ កតំ បាបំ (បាបដែលខ្លួនធ្វើទុកដោយខ្លួនឯង)*** *ជាដើម ។*

មហាកាលត្រូវចោទថាជាចោរ ត្រូវគេវាយស្លាប់

*បានឮថា ឧបាសកនោះជាអ្នករក្សាឧបោសថ ៨ ថ្ងៃ នៃខែ (មួយខែ ៨ ថ្ងៃ) ស្តាប់ធម្មកថារហូតពេញមួយយប់ក្នុងវិហារ ។ គ្រានោះ ពួកចោរកាត់ទី.តនៃផ្ទះមួយក្នុងវេលាយប់ កាន់យកបង្វេចកណ្ឌៈទៅ ត្រូវពួកម្ចាស់របស់ភ្ញាក់ឡើងទាន់ ព្រោះសំឡេងកាជនៈលោហៈទង្គិចគ្នា ក៏ដេញតាមទៅ បានទម្លាក់ចោលនូវរបស់ដែលខ្លួនកាន់យក ហើយក៏រត់គេចចេញទៅ ។*

*ចំណែកពួកម្ចាស់របស់ ជាប់តាមចោរនោះរឿយៗ ទៅ ។ ពួកចោរទាំងនោះក៏រត់បែកផ្លូវគ្នាទៅគ្រប់ទិស ។ ចំណែកចោរម្នាក់កាន់យកផ្លូវទៅវិហារ ទម្លាក់បង្វេចកណ្ឌៈទុកខាងមុខមហាកាលឧបាសក ដែលស្តាប់ធម្មកថារហូតពេញមួយយប់ កំពុងលប់លាងមុខជិតមាត់ព្រះបោក្ខរណីអំពីព្រលឹម ហើយរត់ចេញទៅ ។ ពួកមនុស្សជាប់តាមពួកចោរមក ឃើញបង្វេចកណ្ឌៈហើយក៏ចាប់មហាកាលនោះ ដោយពោលថា "ឯងកាត់ទី.តក្នុងផ្ទះរបស់ពួកយើង លួចយកបង្វេចកណ្ឌៈទៅហើយ មកធ្វើដូចជាស្តាប់ធម៌ បានវាយគាត់រហូតស្លាប់*

ហើយក៏ចៀសចេញទៅ ។

គ្រានោះ ភិក្ខុកំលោះ និងពួកសាមណេរទាំងឡាយ កាន់ក្អមទឹកទៅអំពីព្រលឹម ជួបមហាកាលនោះ ពោលថា “ឧបាសក ស្តាប់ធម្មកថានៅក្នុងវិហារ បានមរណៈមិនសមគួរឡើយ ហើយក៏នាំគ្នាក្រាបទូលដល់ព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ មហាកាលបានមរណៈមិនសមគួរនៅក្នុងអត្តភាពនេះពិតមែនហើយ តែគេបានមរណៈសមគួរដល់កម្មដែលធ្វើទុកហើយក្នុងកាលមុននោះឯង” ភិក្ខុកំលោះ និងសាមណេរទាំងនោះអារាធនាហើយ ទ្រង់ក៏ត្រាស់បុព្វកម្មរបស់មហាកាលនោះថា ៖

## បុព្វកម្មរបស់មហាកាល

បានឮថា ក្នុងអតីតកាល មានពួកចោរនៅចាំស្ទាក់ត្រង់មាត់ព្រៃ នៃបច្ចន្តគ្រាមមួយកន្លែង ក្នុងដែននៃព្រះចៅក្រុងពារាណសី ។ ព្រះរាជាទ្រង់ចាត់តាំងរាជបុរសម្នាក់ទុកត្រង់មាត់ព្រៃ ។ រាជបុរសនោះ ទទួលថ្លៃឈ្នួលហើយក៏នាំមនុស្សទៅអំពីត្រើយខាងនេះ ទៅកាន់ត្រើយខាងនោះ នាំមនុស្សអំពីត្រើយខាងនោះ មកកាន់ត្រើយខាងនេះ ។ គមកមនុស្សម្នាក់ នាំភរិយារូបស្អាតរបស់ខ្លួនឡើងកាន់យានតូចហើយ បានទៅដល់ទីនោះ ។ រាជបុរសគ្រាន់តែឃើញស្ត្រីនោះ ក៏កើតសេចក្តីស្នេហា កាលមនុស្សនោះពោលថា “នាយសូមលោកជួយនាំខ្ញុំទាំងពីរឆ្លងឲ្យផុតព្រៃផង” ក៏ប្រាប់ថា ឥឡូវនេះយប់ហើយ ចាំព្រឹកចុះយើងនឹងជួយឲ្យឆ្លងផុត” ។

មនុស្ស. នាយ នៅទាន់វេលាទេ មេត្តានាំខ្ញុំទាំងពីរទៅឥឡូវនេះចុះ ។

រាជបុរស. ត្រឡប់ចុះអ្នកដ៏ចម្រើន អាហារ និងទីស្នាក់អាស្រ័យក្នុងផ្ទះរបស់ខ្ញុំមាន ។

មនុស្សនោះមិនប្រាថ្នានឹងត្រឡប់ឡើយ ។ ចំណែករាជបុរសនេះ ឲ្យសញ្ញាដល់ពួកបុរសដទៃ ញុំាងយានតូចឲ្យត្រឡប់ហើយ ឲ្យទីស្នាក់អាស្រ័យត្រង់ខ្លោងទ្វារ ឲ្យគេរៀបចំអាហារដល់មនុស្សនោះ ទាំងដែលបុរសនោះមិនប្រាថ្នាឡើយ ។ ក៏ក្នុងផ្ទះរាជបុរសនោះ មានកែវមណីមួយ ។ រាជបុរសនោះឲ្យគេយកកែវមណីទៅលាក់ទុកក្នុងចន្លោះនៃយានតូចរបស់មនុស្សនោះ ក្នុងវេលាជិតភ្លឺ ក៏ធ្វើសំឡេងដូចជាពួកចោរចូលស្រុក ។ លំដាប់នោះ ពួកបុរសបង្ហាញដល់រាជបុរសថា "នាយ កែវមណី ត្រូវពួកចោរលួចយកទៅហើយ" ។ រាជបុរសបញ្ជាថា "ពួកអ្នកចូរតាំងកងរក្សាទុកត្រង់ទ្វារស្រុកទាំងឡាយ ហើយពិនិត្យមើលអ្នកចេញទៅអំពីខាងក្នុងស្រុក" ។ ចំណែកមនុស្សក្រៅនេះ រៀបចំយានតូចស្រេចហើយ ក៏បរចេញទៅពីព្រលឹម ។ ខណៈនោះ ពួកអ្នកបម្រើរបស់រាជបុរសក៏ឆែកឆេយានតូចរបស់មនុស្សនោះ ឃើញកែវមណី ដែលខ្លួនលាក់ទុក ក៏គម្រាមថា "អ្នកឯងលួចយកកែវមណីឬ ក៏វាយបង្ហាញដល់មេស្រុកថា "នាយ ពួកខ្ញុំចាប់ចោរបានហើយ" ។ មេស្រុកនិយាយថា "យើងជារាជ-បុរស ឲ្យអ្នកស្នាក់អាស្រ័យក្នុងផ្ទះ ឲ្យភត្តហើយ ឯងហ៊ានលួចយកកែវមណីទៀត ពួកអ្នកចូរចាប់អាបុរសអាក្រក់នេះ ហើយឲ្យនាំគ្នាវាយទាល់តែស្លាប់" ។

នេះជាបុព្វកម្មរបស់មហាកាលនោះ ។ រាជបុរសនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងអវីចិ ឆេះក្នុងអវីចិនោះអស់កាលដ៏យូរ ត្រូវគេវាយរហូតស្លាប់យ៉ាងនេះឯង អស់ ១០០ អត្តភាព ព្រោះវិបាកដែលសេសសល់ ។

បាបរមែងញាំញីអ្នកធ្វើ

ព្រះសាស្តា លុះទ្រង់សំដែងបុព្វកម្មរបស់មហាកាលនោះហើយ មានព្រះពុទ្ធដីកាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បាបកម្មដែលខ្លួនធ្វើទុកនោះឯង រមែងញាំញីសត្វទាំងនេះក្នុងអបាយទាំង ៤" ហើយត្រាស់ព្រះគាថានេះថា ៖

*៥. អត្តនា ហិ កតំ បាបំ    អត្រជំ អត្តសម្ភវំ*
*អភិមត្ថតិ  ទុម្មេធំ    វជិរំវម្ហយំ មណឹ ។*

*បាបកើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ*
*តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់កាត់កែវមណី*
*ដែលកើតអំពីថ្មដូច្នោះឯង ។*

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា ***វជិរំវម្ហយំ មណឹ*** ***(ដូចពេជ្រកាត់នូវកែវមណីដែលកើតអំពីថ្ម)*** សេចក្តីថា ដូចជាពេជ្រសម្រាប់កាត់កែវមណី ដែលកើតពីថ្ម ។ លោកអធិប្បាយពាក្យនេះទុកថា ពេជ្រដែលសម្រេចអំពីថ្ម មានថ្មជាដែនកើត រមែងកាត់កែវមណីដែលកើតអំពីថ្ម គឺ កែវមណីដែលសម្រេចអំពីថ្ម ដែលរាប់ថា ជាទីតាំងរបស់ខ្លួននោះនុ៎ះឯង គឺ ធ្វើឲ្យមានប្រហោងតូចធំ ឲ្យជា

កំណាត់តូច-ធំ ធ្វើឲ្យប្រើប្រាស់មិនបាន យ៉ាងណា បាបដែលខ្លួនធ្វើហើយ កើតក្នុងខ្លួន មានខ្លួនជាដែនកើត រមែងញាំញី គឺ កម្ចាត់បុគ្គលអ្នកមានបញ្ញាតិច គឺ អ្នកឥតបញ្ញា ឲ្យទៅកាន់អបាយ ៤ ដូច្នោះឯង ។

ក្នុងវេលាចប់ទេសនា ភិក្ខុដែលមកប្រជុំគ្នា ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ដូច្នេះឯង ។

ចប់ រឿងមហាកាលឧបាសក

# ៦. រឿងព្រះទេវទត្ត

*ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះទេវទត្ត ត្រាស់ព្រះធម្មទេសនានេះថា* ***យស្ស អច្ចន្តទុស្សីល្យំ (ភាពជាអ្នកទ្រុស្តសីលដោយសព្វគ្រប់)*** *ជាដើម ។*

ការសន្ទនារឿងដ៏លាមករបស់ព្រះទេវទត្ត

*សេចក្ដីពិស្ដារថា ថ្ងៃមួយ ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា "អ្នកមានអាយុទាំងឡាយ ព្រះទេវទត្តជាអ្នកទ្រុស្តសីល មានធម៌លាមក បានញុះញង់ព្រះបាទអជាតសត្រូវ ញុាំងលាភ និងសក្ការៈជាច្រើនឲ្យកើតឡើង បបួលព្រះបាទអជាតសត្រូវក្នុងការសម្លាប់ព្រះរាជបិតា ព្យាយាមដើម្បីនឹងសម្លាប់ព្រះតថាគតដោយប្រការផ្សេងៗ ព្រោះតណ្ហា ដែលចម្រើនឡើងហើយ ព្រោះហេតុ គឺ ភាពជាអ្នកទ្រុស្តសីលនោះឯង" ។*

*ព្រះសាស្ដាស្ដេចយាងមក ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកកំពុងសន្ទនាគ្នាដោយកថាអ្វី" ភិក្ខុទាំងនោះ "ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គសន្ទនាគ្នា ដោយកថាឈ្មោះនេះ" ទ្រង់ក៏ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ក្នុងកាលមុន ទេវទត្តក៏ព្យាយាមដើម្បីសម្លាប់តថាគតដោយប្រការផ្សេងៗ ដែរ ហើយត្រាស់ព្រះជាតកទាំងឡាយ មានកុរុង្គជាតកជាដើម ហើយទ្រង់មានព្រះពុទ្ធ-*

ដីកាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ តណ្ហាដែលកើតឡើង ព្រោះហេតុ គឺជាអ្នកទ្រុស្តសីល រួបរឹតបន្សាត់ចំពោះបុគ្គលទ្រុស្តសីលដោយសព្វគ្រប់ ឲ្យទៅកាន់អបាយ មាននរកជាដើម ដូចជាពួរជ្រៃរួបរឹតដើមឈើ ហើយកាច់បំបាក់ដើមឈើនោះ ដូច្នោះ ហើយត្រាស់ព្រះគាថានេះថា ៖

៦. យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ
ករោតិ សោ តថត្តានំ យថា នំ ឥច្ឆតី ទិសោ ។

ភាពជាអ្នកទ្រុស្តសីលហួសហេតុ គ្របសង្កត់ (នូវអត្តភាព)
របស់បុគ្គលណា ដូចវល្លិ៍ដែលរួបរឹតដើមឈើ បុគ្គលនោះ
ឈ្មោះថា ធ្វើខ្លួនឯងឲ្យវិនាស ដូចជាចោរអ្នកប្រាថ្នាធ្វើបុគ្គល
នោះឲ្យវិនាស ដូច្នោះ ។

អធិប្បាយគាថា

ការៈជាអ្នកទ្រុស្តសីលដោយសព្វគ្រប់ ឈ្មោះថា **អច្ចន្តទុស្សីល្យំ** (ភាពជាអ្នកទ្រុស្តសីលដោយអស់ជើង) ក្នុងព្រះគាថានោះ ។ បុគ្គលជាគ្រហស្ថធ្វើអកុសលកម្មបថ ១០ តាំងអំពីកើតក្តី បុគ្គលជាបព្វជិត ត្រូវគរុកាបត្តិ គឺបារាជិក និងសង្ឃាទិសេស តាំងអំពីថ្ងៃឧបសម្បទាមកក្តី ឈ្មោះថា បុគ្គលទ្រុស្តសីលដោយអស់ជើង ។ តែបទថា **អច្ចន្តទុស្សីល្យំ** (ការៈជាបុគ្គលទ្រុស្ត-សីលដោយអស់ជើង) នេះ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ក្នុងព្រះគាថានេះទ្រង់សំដៅយកភាពជាអ្នកទ្រុស្តសីល ដែលមកហើយតាមគតិរបស់បុគ្គលអ្នក

ទ្រុស្តសីល ២-៣ អត្តភាព ។ ម្យ៉ាងទៀត តណ្ហាដែលអាស្រ័យទ្វារ ៦ របស់បុគ្គលទ្រុស្តសីលកើតឡើង បណ្ឌិតគប្បីជ្រាបថា "ភាពជាអ្នកទ្រុស្តសីល" ក្នុងព្រះគាថានេះ ។

បទថា **មាលុវា សាលមិវោត្ថតំ** (ដូចពួរជ្រៃដុះរួបរឹតដើមឈើ ដូច្នោះ) សេចក្តីថា ភាពជាអ្នកទ្រុស្តសីល ពោលគឺ តណ្ហា រួបរឹត គឺ គ្របសង្កត់អត្តភាពរបស់បុគ្គលណា ដូចជាពួរជ្រៃរួបរឹតដើមឈើ គឺ ដុះព័ទ្ធសព្វអន្លើ ដោយអំណាចការស្រូបយកទឹកដោយស្លឹក ក្នុងកាលភ្លៀងធ្លាក់ ហើយកាច់បំបាក់ចុះ ដូច្នោះឯង ។ បុគ្គលនោះ គឺ អ្នកត្រូវតណ្ហា ពោលគឺ ភាពជាអ្នកទ្រុស្តសីលនោះ រួបរឹតហើយ រមែងទាញឲ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ ដូចដើមឈើត្រូវពួរជ្រៃរួបរឹត ឲ្យដួលចុះលើផែនដីដូច្នោះ ទើបឈ្មោះថា ធ្វើខ្លួនឯងឲ្យវិនាស ដូចជាចោរអ្នកប្រាថ្នាធ្វើបុគ្គលនោះឲ្យវិនាសដូច្នោះឯង ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងព្រះទេវទត្ត

# ៧. រឿងការខ្វល់ខ្វាយដើម្បីបំបែកសង្ឃ

*ព្រះសាស្តា កាលស្តេចប្រថាប់នៅវេឡុវ័ន ទ្រង់ប្រារព្ធការខ្វល់ខ្វាយដើម្បីនឹងបំបែកសង្ឃ ត្រាស់ព្រះធម្មទេសនានេះថា សុករានិ (ធ្វើបានងាយ) ជាដើម ។*

ព្រះទេវទត្តព្យាយាមបំបែកសង្ឃ

*សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះទេវទត្តខ្វល់ខ្វាយដើម្បីនឹងបំបែកសង្ឃ ឃើញព្រះអានន្ទកំពុងត្រាច់បិណ្ឌបាត ក៏ប្រាប់បំណងរបស់ខ្លួន ។ ព្រះថេរៈស្តាប់ដំណឹងនោះហើយ ទៅកាន់សម្នាក់របស់ព្រះសាស្តា បានទូលពាក្យនេះនឹងព្រះមានព្រះភាគថា "បពិត្រព្រះអង្គ វេលាព្រឹក ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រត្រង់វេឡុវ័ននេះហើយ ចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត បពិត្រព្រះអង្គ ព្រះទេវទត្តបានឃើញខ្ញុំព្រះអង្គ ត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះហើយ ចូលទៅរកខ្ញុំព្រះអង្គ បានពោលពាក្យនេះថា "អាវុសោអានន្ទ ចាប់តាំងពីថ្ងៃនេះ ខ្ញុំនឹងធ្វើឧបោសថ និងសង្ឃកម្មបែកអំពីព្រះមានព្រះភាគ និងភិក្ខុសង្ឃ" បពិត្រព្រះមានព្រះភាគ ថ្ងៃនេះព្រះទេវទត្តនឹងបំបែកសង្ឃ គឺ នឹងធ្វើឧបោសថ និងសង្ឃកម្ម ។*

សេចក្តីល្អមនុស្សល្អធ្វើបានងាយ

*កាលព្រះអានន្ទក្រាបទូលដូច្នោះហើយ ព្រះសាស្តាទ្រង់បន្លឺព្រះឧទាន*

នេះថា ៖

សេចក្តីល្អ មនុស្សល្អធ្វើបានងាយ សេចក្តីល្អ មនុស្សអាក្រក់ធ្វើបានលំបាក, សេចក្តីអាក្រក់ មនុស្សអាក្រក់ធ្វើបានងាយ, សេចក្តីអាក្រក់ អរិយបុគ្គលធ្វើបានដោយលំបាក ។

ហើយទ្រង់ត្រាស់ថា "ម្នាលអានន្ទ ឈ្មោះថា កម្មដែលមិនជាប្រយោជន៍ដល់ខ្លួន ធ្វើបានងាយ, កម្មដែលជាប្រយោជន៍ដល់ខ្លួន ធ្វើបានដោយលំបាកពន់ពេក ហើយត្រាស់ព្រះគាថានេះថា ៖

៧. សុករានិ អសាធូនិ អត្តនោ អហិតានិ ច
យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ។

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះ ដែលជនពាលធ្វើបានដោយងាយ កម្មណា ជាប្រយោជន៍ផង ល្អផង កម្មនុ៎ះឯង ដែលជនពាលធ្វើបានដោយលំបាក ។

អធិប្បាយគាថា

ព្រះគាថានោះមានសេចក្តីថា ៖

កម្មទាំងឡាយណាមិនល្អ គឺ មានទោស និងប្រព្រឹត្តទៅដើម្បីអបាយ ឈ្មោះថា មិនមានប្រយោជន៍ដល់ខ្លួន ព្រោះការធ្វើនោះ កម្មទាំងនោះធ្វើបានងាយ ។ ចំណែកកម្មណា ឈ្មោះថា មានប្រយោជន៍ដល់ខ្លួន ព្រោះការធ្វើនោះ

ឈ្មោះថា ល្អ ព្រោះអត្ថថា គ្មានទោស គឺ ប្រព្រឹត្តទៅដើម្បីសុគតិ និងប្រព្រឹត្ត ទៅព្រះនិព្វាន កម្មនោះធ្វើសែនលំបាក ដូចបង្វែរទឹកស្ទឹងគង្គាដែលហូរទៅកាន់ ទិសខាងកើត ឲ្យហូរត្រឡប់ ដូច្នោះ" ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើន បានសម្រេចលោកុត្តរផល មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងការបំបែកសង្ឃ

# ៨. រឿងព្រះកាលត្ថេរ

*ព្រះសាស្ដា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះកាលត្ថេរ បាន ត្រាស់ព្រះធម្មទេសនានេះថា យោ សាសនំ (បុគ្គលណា... ពាក្យទូន្មាន) ជាដើម ។*

ព្រះថេរៈមិនឱ្យឧបដ្ឋាយិកានៅស្ដាប់ធម៌

*ដូចបានឮមក ស្ត្រីម្នាក់ក្នុងក្រុងសាវត្ថី តាំងនៅក្នុងភាពនៃមាតាទំនុក បម្រុងព្រះថេរៈអង្គនោះ ។ ពួកមនុស្សក្នុងផ្ទះនៃអ្នកស្និទ្ធស្នាលរបស់ស្ត្រីនោះ ស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដាហើយ ត្រឡប់មកផ្ទះ សរសើរថា ឱ! ឈ្មោះ ថា ព្រះពុទ្ធទាំងឡាយអស្ចារ្យហ្ន៎ ឱ! ព្រះធម្មទេសនាក៏ពីរោះ" ។ ស្ត្រីនោះ ស្ដាប់ពាក្យរបស់ជនទាំងនោះហើយ ក៏ប្រាប់ដល់ព្រះកាលៈថា "លោកម្ចាស់ ខ្ញុំចង់ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា" ។ លោកហាមនាងថា "កុំទៅទី នោះឡើយ" ។ ស្ត្រីនោះ ក្នុងថ្ងៃព្រឹកឡើងក៏សូមទៀត សូម្បីត្រូវកាលៈនោះ ហាមដល់ទៅ ៣ ដង ក៏នៅតែចង់ស្ដាប់ធម៌នោះទៀត ។ មានពាក្យសួរជ្រែក ចូលមកថា "ចុះហេតុអ្វី បានជាលោកហាមនាង?" ឆ្លើយថា "បានឮថាលោក មានគំនិតឃើញដូច្នេះថា បើឧបាសិកានេះបានស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា ហើយ នឹងបែកអំពីខ្លួន" ហេតុនោះ បានជាលោកហាមឃាត់នាង ។*

*ថ្ងៃមួយ ស្ត្រីនោះបរិភោគអាហារស្រេច សមាទានឧបោសថហើយ ផ្ដាំ*

បុត្រីទុកថា "កូនចូរអង្គាសលោកម្ចាស់ឲ្យល្អ" ហើយបានទៅវិហារតាំងអំពីព្រលឹម ។ ចំណែកបុត្រីរបស់នាង ក៏អង្គាសព្រះកាលៈដោយយកចិត្តទុកដាក់ពេលលោកមកដល់ លោកសួរថា "មហាឧបាសិកាទៅណា?" (នាង) ប្រាប់ថា "ទៅវិហារស្តាប់ធម៌" ពេលលោកបានស្តាប់ដំណឹងនោះហើយ ក៏ក្តៅធ្លលព្រោះការទាស់ចិត្តបានតាំងឡើង ក៏នឹកថា "ឥឡូវនេះ ឧបាសិកានោះបែកពីអញហើយ" បានទៅយ៉ាងប្រញាប់ ឃើញស្ត្រីនោះស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ក៏ទូលព្រះសាស្តាថា "ព្រះអង្គ ស្ត្រីនេះជាមនុស្សល្ងង់ មិនចូលចិត្តធម្មកថាដ៏ល្អិត កុំត្រាស់ធម្មកថាដ៏ល្អិតដែលប្រដាប់ដោយសភាវធម៌ មានខន្ធជាដើមឡើយ ត្រាស់ត្រឹមតែទានកថា ឬសីលកថាដល់នាងក៏ល្មម" ។

### សក្ការៈរមែងសម្លាប់មនុស្សអាក្រក់

ព្រះសាស្តា ទ្រង់ជ្រាបអធ្យាស្រ័យរបស់លោកហើយ ត្រាស់ថា "អ្នកជាមនុស្សឆោត អាស្រ័យទិដ្ឋិដ៏អាក្រក់ ហាមឃាត់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ អ្នកឯងព្យាយាមដើម្បីសម្លាប់ខ្លួនហើយ ទើបត្រាស់ព្រះគាថានេះថា ៖

៨. យោ សាសនំ អរហតំ អរិយានំ ធម្មជីវិនំ
បដិក្កោសតិ ទុម្មេធោ ទិដ្ឋឹ និស្សាយ បាបិកំ
ផលានិ កណ្ដកស្សេវ អត្តឃញ្ញាយ ផល្លតិ ។

បុគ្គលណាអប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់សាសនា
របស់ព្រះអរហន្តទាំងឡាយដ៏ប្រសើរ រស់នៅដោយធម៌ ការឃាត់

*យាំង របស់បុគ្គលនោះ រមែងចេញផលដើម្បីសម្លាប់ខ្លួន ដូច ផ្លែឫស្សីដូច្នោះ ។*

អធិប្បាយគាថា

*ព្រះគាថានោះ មានសេចក្ដីថា ៖*

*បុគ្គលណាឆោត អាស្រ័យទិដ្ឋិដ៏អាក្រក់ ហាមប្រាមពួកជនដែលកំពុង ពោលថា នឹងស្ដាប់ធម៌ក្ដី ថានឹងថ្វាយទានក្ដី ព្រោះខ្លាចដល់ការសូន្យសក្ការៈ របស់ខ្លួន ឈ្មោះថា ជំទាស់ពាក្យប្រៀនប្រដៅរបស់ព្រះអរិយបុគ្គល ដែល ជាព្រះអរហន្ត មានប្រក្រតីរស់នៅដោយធម៌ គឺ ព្រះពុទ្ធជាម្ចាស់ ការជំទាស់ និងទិដ្ឋិដ៏លាមកនោះ របស់បុគ្គលនោះ រមែងដូចជាផ្លែរបស់ឈើមានបន្ទា ពោល គឺ ដើមឫស្សី ព្រោះដើមឫស្សី កាលផ្លែ រមែងផ្លែដើម្បីសម្លាប់ខ្លួនប៉ុណ្ណោះ យ៉ាងណា សូម្បីបុគ្គលនោះ ក៏រមែងកើតមកដើម្បីសម្លាប់ខ្លួន គឺថា កើតមក ដើម្បីបំផ្លាញខ្លួនឯងដូច្នោះ ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ ទុកថា ៖*

*ផ្លែចេកនោះឯង រមែងសម្លាប់ដើមចោល ផ្លែឫស្សីតែងសម្លាប់ ដើមចោល ផ្លែបបុសតែងសម្លាប់ដើមបបុសចោល កូនក្នុងគភ៌ តែងសម្លាប់មេសេះអស្សតរចោល យ៉ាងណា សក្ការៈក៏រមែង សម្លាប់បុរសអាក្រក់ ដូច្នោះ ។*

*ក្នុងវេលាចប់ព្រះធម៌ទេសនា ឧបាសិកាក៏តាំងនៅក្នុងសោតាបត្តិផល*

*ព្រះធម៌ទេសនាបានមានប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នា ដូច្នោះឯង ។*

ចប់ រឿងកាលត្ថេរ

# ៩. រឿងចុល្លកាលឧបាសក

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកម្នាក់ឈ្មោះចុល្លកាល ត្រាស់ព្រះធម្មទេសនានេះថា* ***អត្តនាវ កតំ បាបំ (បាបដែលបុគ្គលណាធ្វើហើយដោយខ្លួនឯង)*** *ជាដើម ។*

ចុល្លកាលត្រូវចោទថាជាចោរ

*សេចក្តីពិស្តារថា ថ្ងៃមួយពួកចោរជីកឧម្មង្គ ត្រូវពួកម្ចាស់ទ្រព្យទាំងឡាយដេញតាម ក៏ទម្លាក់បង្វេចទ្រព្យទុកខាងមុខឧបាសកដែលស្តាប់ធម្មកថាក្នុងវិហារមួយរាត្រី ដែលដើរចេញមកពីវិហារអំពីព្រលឹមមកកាន់ក្រុងសាវត្ថីហើយរត់គេចចេញទៅ ដោយន័យដូចពោលហើយ ក្នុងរឿងមហាកាលនោះឯង ។ ពួកមនុស្សឃើញគាត់ហើយនិយាយថា "មនុស្សនេះធ្វើចោរកម្មពេលរាត្រីហើយ ធ្វើខ្លួនដូចជាមកពីស្តាប់ធម៌ អ្នកទាំងឡាយ ចូរជួយចាប់វាទុក" ហើយក៏វាយឧបាសកនោះ ។ ពួកនាងកុម្ភទាសីដើរទៅកំពង់ទឹក ប្រទះហេតុនោះ ក៏ពោលថា "នាយ លោកទាំងឡាយចូរចៀសចេញទៅ អ្នកនេះមិនបានធ្វើកម្មបែបនេះទេ" ហើយឲ្យមនុស្សទាំងនោះលែងគាត់មកវិញ ។ ឧបាសកទៅកាន់វិហារ ប្រាប់ដល់ភិក្ខុទាំងឡាយថា "លោកម្ចាស់ ខ្ញុំព្រះករុណាត្រូវពួកមនុស្សទាំងឡាយឲ្យវិនាសហើយ ខ្ញុំករុណាបានជីវិត ព្រោះអាស្រ័យពួកនាងកុម្ភទាសី ។ ភិក្ខុទាំងឡាយ ក៏ក្រាបទូលរឿងនោះដល់ព្រះតថាគត ។*

## សេចក្តីសៅហ្មង ឬសេចក្តីបរិសុទ្ធព្រោះខ្លួនឯង

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ចុល្លកាលឧបាសកបានជីវិត ព្រោះអាស្រ័យពួកនាងកុម្ភទាសី និងការដែលខ្លួនមិនមែនជាអ្នកធ្វើ ព្រោះថា ធម្មតាសត្វទាំងនេះធ្វើបាបកម្មដោយខ្លួនឯងហើយ រមែងសៅហ្មងដោយខ្លួនឯង ក្នុងអបាយមាននរកជាដើម ចំណែកសត្វទាំងឡាយ ធ្វើកុសលហើយ ទៅកាន់សុគតិ និងនិព្វាន ឈ្មោះថាបរិសុទ្ធបានដោយខ្លួនឯង" ហើយត្រាស់ព្រះគាថានេះថា ៖

៩. អត្តនាវ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនាវ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធមានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃឲ្យបរិសុទ្ធពុំបានទេ ។

### អធិប្បាយគាថា

ព្រះគាថានោះមានសេចក្តីថា ៖

អកុសលកម្ម ជាកម្មដែលអ្នកណាធ្វើហើយដោយខ្លួនឯង អ្នកនោះកាលសោយទុក្ខក្នុងអបាយ ៤ ឈ្មោះថា សៅហ្មងដោយខ្លួនឯង ចំណែកបាបដែលអ្នកណាមិនបានធ្វើដោយខ្លួនឯង អ្នកនោះរមែងទៅកាន់សុគតិ និងនិព្វាន ឈ្មោះ

ថា រមែងបរិសុទ្ធដោយខ្លួនឯង សេចក្តីបរិសុទ្ធ គឺ កុសលកម្ម និងសេចក្តីមិនបរិសុទ្ធ គឺ អកុសលកម្ម ជារបស់ចំពោះខ្លួន គឺ រមែងឲ្យផលចំពោះខ្លួនដល់សត្វអ្នកធ្វើទាំងឡាយ ។ បុគ្គលដទៃធ្វើបុគ្គលដទៃឲ្យបរិសុទ្ធមិនបាន គឺ ឲ្យផូរផង់មិនបានឡើយ ឲ្យសៅហ្មងមិនបានឡើយ ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ចុល្លកាលឧបាសក ក៏បានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះធម្មទេសនា មានប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាដូច្នេះឯង ។

ចប់ រឿងចុល្លកាលឧបាសក

# ១០. រឿងព្រះអត្តទត្ថថេរ

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះអត្តទត្ថថេរៈ ត្រាស់ព្រះធម្មទេសនានេះថា **អត្តទត្ថំ បរត្ថេន (ធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍អ្នកដទៃ)** ជាដើម ។*

ព្រះថេរៈព្យាយាមបំពេញប្រយោជន៍

*សេចក្តីពិស្តារថា កាលព្រះសាស្តាត្រាស់ក្នុងកាលជិតនឹងបរិនិព្វានថា "ម្នាលភិក្ខុទាំងឡាយ ដោយកាលកន្លងទៅ ៤ ខែទៀតរាប់អំពីថ្ងៃនេះ តថាគត នឹងបរិនិព្វាន" ភិក្ខុប្រមាណ ៧០០ រូប ដែលនៅជាបុថុជ្ជនកើតសេចក្តីសង្វេគ មិនលះសម្នាក់ព្រះសាស្តាឡើយ ត្រាច់ប្រឹក្សាគ្នាថា "អ្នកមានអាយុ ពួកយើង នឹងធ្វើដូចម្តេចហ្ន៎" ចំណែកព្រះអត្តទត្ថៈគិតថា ឮថា ព្រះសាស្តានឹងបរិនិព្វាន ដោយកាលកន្លងទៅ ៤ ខែទៀត ក៏ខ្លួនយើងនៅជាអ្នកមានរាគៈ កាលព្រះ សាស្តាទ្រង់នៅព្រះជន្មនេះឯង យើងនឹងព្យាយាមដើម្បីព្រះអរហត្ត ។ ព្រះថេរៈ នោះ ទើបមិនបានទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ ។ លំដាប់នោះ ភិក្ខុ ទាំងឡាយពោលនឹងលោកថា "អ្នកមានអាយុ ហេតុអ្វីទើបលោក មិនមកក្នុង សម្នាក់របស់ពួកខ្ញុំ លោកមិនប្រឹក្សាអ្វីៗ ?" ហើយក៏នាំទៅកាន់សម្នាក់របស់ ព្រះសាស្តា ក្រាបទូលថា "បពិត្រព្រះអង្គ ភិក្ខុរូបនេះធ្វើយ៉ាងនេះ" ។*

*ព្រះអត្តទត្ថៈនោះ សូម្បីព្រះសាស្តាត្រាស់ថា "ហេតុអ្វី ទើបអ្នកធ្វើយ៉ាង*

នោះ” ក៏ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ឮថាព្រះអង្គនឹងបរិនិព្វានដោយកាលកន្លងទៅ ៤ ខែទៀត ខ្ញុំព្រះអង្គព្យាយាមដើម្បីសម្រេចព្រះអរហត្ត ក្នុងកាលព្រះអង្គទ្រង់ព្រះជន្មនៅនេះឯង” ។

អ្នកបដិបត្តិធម៌ឈ្មោះថាបូជាព្រះសាស្តា

ព្រះសាស្តាប្រទានសាធុការដល់ព្រះថេរៈនោះ ហើយត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ បុគ្គលណាស្រឡាញ់ក្នុងតថាគត បុគ្គលនោះគួរដូចជាអត្ថទត្ថៈ ព្រោះថា ជនទាំងឡាយបូជាដោយវត្ថុទាំងឡាយផ្សេងៗ មានគ្រឿងក្រអូបជាដើម មិនឈ្មោះថាបូជាតថាគតឡើយ តែបុគ្គលបូជាដោយការបដិបត្តិធម៌ដ៏សមគួរដល់ធម៌ ទើបឈ្មោះថាបូជាតថាគត ព្រោះដូច្នោះ សូម្បីភិក្ខុរូបដទៃក៏គប្បីដូចជាអត្ថទត្ថៈ ហើយត្រាស់ព្រះគាថានេះថា ៖

១០. អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ
អត្តទត្ថមភិញ្ញាយ សទត្ថបសុតោ សិយា ។

បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍
របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់
ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន (នោះ) ។

អធិប្បាយគាថា

ខ្លឹមសារនៃព្រះគាថានោះថា ៖

បុគ្គលជាគ្រហស្ថ មិនគប្បីធ្វើប្រយោជន៍របស់ខ្លួន សូម្បីមួយកាកណិក

ឲ្យវិនាស ព្រោះតែប្រយោជន៍របស់អ្នកដទៃ សូម្បីប្រមាណ ១.០០០ ព្រោះថា ប្រយោជន៍របស់ខ្លួនចំពោះបុគ្គលនោះឯង សូម្បីត្រឹមមួយកាកណិក ក៏អាចញុំាងជារបស់គួរទំពា ឬបរិភោគឲ្យសម្រេចបាន ប្រយោជន៍របស់អ្នកដទៃឲ្យសម្រេចមិនបាន ។ ឯពីរបាទនៃព្រះគាថានេះ ព្រះមានព្រះភាគមិនបានត្រាស់យ៉ាងនោះ ត្រាស់ដោយលំនាំនៃកម្មដ្ឋានប៉ុណ្ណោះ ព្រោះដូច្នោះ ភិក្ខុតាំងចិត្តថា យើងនឹងមិនញុំាងប្រយោជន៍របស់ខ្លួនឲ្យវិនាស ដូច្នេះហើយ ក៏មិនគប្បីញុំាងកិច្ចមានការជួសជុលព្រះចេតិយជាដើម ដែលកើតឡើងដល់សង្ឃ ឬវត្តមានឧបជ្ឈាយវត្តជាដើមឲ្យវិនាស ព្រោះថា ភិក្ខុបំពេញអភិសមាចារិកវត្តឲ្យបរិបូណ៌ រមែងធ្វើឲ្យជាក់ច្បាស់នូវផលទាំងឡាយ មានអរិយផលជាដើម ។ ព្រោះដូច្នោះ ការបំពេញវត្តឲ្យបរិបូណ៌នេះឯង ទើបឈ្មោះថា ជាប្រយោជន៍របស់ខ្លួនដោយពិត ។

ម្យ៉ាងទៀត ភិក្ខុណា មានវិបស្សនាប្រារព្ធយ៉ាងខ្លាំងក្លា ហើយប្រាថ្នាការចាក់ធ្លុះថា យើងនឹងចាក់ធ្លុះក្នុងថ្ងៃនេះៗ ឯង ដូច្នេះហើយ ប្រព្រឹត្តព្យាយាម ភិក្ខុនោះ សូម្បីញុំាងវត្ត មានឧបជ្ឈាយវត្តជាដើមឲ្យវិនាសហើយ ក៏គប្បីធ្វើកិច្ចរបស់ខ្លួនឲ្យបាន ។ ក៏ភិក្ខុដឹងច្បាស់ប្រយោជន៍របស់ខ្លួនបែបនោះ គឺ កំណត់បានថា នេះជាប្រយោជន៍របស់ខ្លួន គប្បីជាអ្នកខ្វល់ខ្វាយប្រកបក្នុងប្រយោជន៍របស់ខ្លួននោះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ព្រះថេរៈក៏បានតាំងនៅក្នុងអរហត្តផល ។

ព្រះធម៌ទេសនាបានជាប្រយោជន៍ដល់ភិក្ខុអ្នកប្រជុំគ្នាទាំងឡាយ ដូច្នេះឯង ។

ចប់ រឿងព្រះអត្តទត្ថេរៈ

## ចប់អត្តវគ្គវណ្ណនា វគ្គទី ១២

ក្នុងវគ្គនេះរួមមាន ១០ រឿង


១.រឿងពោធិរាជកុមារ
២. រឿងឧបនន្ទសក្យបុត្ត
៣.រឿងព្រះបធានិកតិស្សៈ
៤. រឿងមាតាព្រះកុមារកស្សបៈ
៥.រឿងមហាកាលឧបាសក
៦.រឿងព្រះទេវទត្ត
៧.រឿងការបំបែកសង្ឃ
៨.រឿងព្រះកាលត្ថេរៈ
៩.រឿងចុល្លកាលឧបាសក
១០.រឿងព្រះអត្តទត្ថេរៈ

# លោកវគ្គ ទី ១៣

"ពោលអំពីរឿងលោក"

## ១. រឿងភិក្ខុកំលោះ

**[២៣]** *ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកំលោះមួយរូប ត្រាស់ព្រះធម្មទេសនានេះថា* ***ហីនំ ធម្មំ (ធម៌ថោកទាប)*** *ជាដើម ។*

ភិក្ខុឈ្លោះជាមួយចៅស្រីនាងវិសាខា

*បានឮថា ព្រះថេរៈមួយអង្គនិងភិក្ខុកំលោះ បានទៅកាន់ផ្ទះនាងវិសាខាតាំងអំពីព្រឹក ធុរយាគូដែលគេតាក់តែងទុកដើម្បីភិក្ខុ ៥០០ រូប មានជាប្រចាំក្នុងផ្ទះនាងវិសាខា ។ ព្រះថេរៈឆាន់បបរហើយ ឲ្យភិក្ខុកំលោះអង្គុយលើផ្ទះរបស់នាងវិសាខានោះ ។ ឯខ្លួនឯងបានទៅកាន់ផ្ទះដទៃ ។ ក៏សម័យនោះ ធីតារបស់បុត្រនាងវិសាខា តាំងនៅក្នុងតំណែងរបស់យាយ ធ្វើការខ្វល់ខ្វាយដល់ភិក្ខុទាំងឡាយ ។ នាងត្រងទឹកដើម្បីភិក្ខុកំលោះនោះ ឃើញស្រមោលមុខរបស់ខ្លួនក្នុងផ្តិលក៏សើច ។ ឯភិក្ខុកំលោះសំឡឹងមើលនាងក៏សើចដែរ ។ នាងឃើញភិក្ខុកំលោះនោះសើច ក៏ពោលថា "មនុស្សដាច់ក្បាលសើច" ។ លំដាប់នោះ ភិក្ខុកំលោះជេរនាងថា "នាងក៏ដាច់ក្បាល មាតាបិតានាងក៏ដាច់ក្បាល*

ដែរ" ។ នាងស្រែកយំ បានទៅកាន់សម្នាក់របស់យាយក្នុងរោងបាយ កាល នាងវិសាខាពោលថា "មានរឿងអ្វីចៅ" ក៏បានប្រាប់សេចក្ដីនោះ ។ នាងវិសាខា នោះមកកាន់សម្នាក់ភិក្ខុកំលោះហើយ និយាយថា "លោកម្ចាស់កុំក្រោធឡើយ ពាក្យនោះ ជាពាក្យមិនធ្ងន់ធ្ងរសម្រាប់លោកម្ចាស់ដែលមានសក់ និងក្រចក កាត់ហើយ មានសំពត់ស្លៀក និងសំពត់ដណ្ដប់កាត់ហើយ ជាអ្នកកាន់អំបែង ដាច់ត្រង់កណ្ដាល ត្រាច់ទៅដើម្បីភិក្ខាទេ" ។ ភិក្ខុកំលោះនិយាយថា "អើ ឧបាសិកា នាងជ្រាបដល់អាត្មាជាអ្នកមានសក់កាត់ហើយជាដើម តែការដែល ចៅរបស់នាងជេរអាត្មាថា "អ្នកមានក្បាលដាច់ដូច្នេះ គួរឬ?" នាងវិសាខាមិន អាចដើម្បីឲ្យភិក្ខុកំលោះ និងចៅស្រីព្រមព្រៀងគ្នាឡើយ ។ ខណៈនោះ ព្រះ ថេរៈមកហើយ សួរថា "នេះដូចម្ដេច ឧបាសិកា?" ស្ដាប់សេចក្ដីនោះហើយ ពោលប្រដៅភិក្ខុកំលោះថា "អ្នកមានអាយុ អ្នកចូរចេញទៅ ស្ត្រីនេះមិនបាន ជេរអ្នកដែលមានសក់ ក្រចក និងសំពត់កាត់ហើយ អ្នកកាន់អំបែងដាច់ត្រង់ កណ្ដាលត្រាច់ទៅដើម្បីភិក្ខាទេ អ្នកចូរស្ងៀមទៅ" ។ ភិក្ខុកំលោះពោលថា "យ៉ាងនោះលោកម្ចាស់ លោកមិនគំរាមឧបជ្ឈាយិការបស់ខ្លួន មកគំរាមខ្ញុំធ្វើ អ្វី? កាលដែលនាងជេរខ្ញុំថា អ្នកមានក្បាលដាច់ គួរឬ" ។

ខណៈនោះ ព្រះសាស្ដាស្ដេចយាងមក ត្រាស់សួរថា "នេះដូចម្ដេច" នាងវិសាខា ក៏បានក្រាបទូលហេតុនោះតាំងអំពីដើម ។

ព្រះសាស្ដាប្រទានឱវាទដល់ភិក្ខុកំលោះ

*ព្រះសាស្ដា ទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់ភិក្ខុកំលោះនោះហើយ ទ្រង់មានព្រះតម្រិះថា "តថាគតបណ្ដោយតាមភិក្ខុនេះគួរ" ទើបត្រាស់នឹងនាងវិសាខាថា "វិសាខា ចុះទារិការបស់នាង ជេរពួកសាវករបស់តថាគតថា ជាអ្នកមានក្បាលដាច់ គួរឬ?" ភិក្ខុកំលោះក៏ក្រោកឡើងផ្គងអញ្ជលីក្នុងខណៈនោះឯង ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ជ្រាបបញ្ហានោះដោយល្អ ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គ និងមហាឧបាសិកាមិនជ្រាបទេ" ព្រះសាស្ដា ទ្រង់ជ្រាបនូវភាពដែលព្រះអង្គជាអ្នកអនុគ្រោះដល់ភិក្ខុកំលោះនោះហើយ បានត្រាស់ថា "ភាវៈ គឺ ការសើចប្រាវព្ធកាមគុណ ដែលជាធម៌ថោកទាប ទាំងការសេពធម៌ដែលថោកទាប និងការនៅរួមជាមួយសេចក្ដីប្រមាទ មិនគួរឡើយ" ហើយក៏ត្រាស់ព្រះគាថានេះថា ៖*

**១. ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ**
**មិច្ឆាទិដ្ឋឹ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ ។**

*បុគ្គលមិនគួរសេពធម៌ថោកទាប មិនគួរនៅដោយសេចក្ដីប្រមាទ*
*មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សចង្អៀតលោក ។*

អធិប្បាយគាថា

*បណ្ដាបទទាំងនោះ បទថា **ហីនំ ធម្មំ** (ធម៌ថោកទាប) បានដល់ ធម៌ គឺ កាមគុណ ៥ ។ ពិតណាស់ ធម៌ គឺ បញ្ចកាមគុណនោះ ដែលជនថោក-*

*ទាប ដោយហោចទៅ សូម្បីអូដ្ឋ និងគោជាដើមគប្បីសេព ។ ធម៌ គឺ បញ្ច-កាមគុណ រមែងនាំសត្វអ្នកសេពទៅកើតក្នុងទីថោកទាបទាំងឡាយ មាននរកជាដើម ព្រោះដូច្នោះ ធម៌ គឺ បញ្ចកាមគុណនោះ ទើបឈ្មោះថា ជាធម៌ថោកទាប បុគ្គលមិនគប្បីសេពធម៌ដ៏ថោកទាបនោះឡើយ ។ បទថា* ***បមាទេន (ដោយសេចក្តីប្រមាទ)*** *សេចក្តីថា មិនគប្បីនៅរួមដោយសេចក្តីប្រមាទ ដែលមានការបណ្តោយសតិជាលក្ខណៈ ។ បទថា* ***ន សេវេយ្យ (មិនគប្បីសេព)*** *បានដល់មិនគប្បីឃើញខុស ។ បទថា* ***លោកវឌ្ឍនោ (ចង្រៀតលោក)*** *សេចក្តីថា ក៏បុគ្គលណាធ្វើដូច្នេះ បុគ្គលនោះ ឈ្មោះថា ជាមនុស្សចង្រៀតលោក ព្រោះដូច្នោះ មិនគប្បីជាមនុស្សចង្រៀតលោក ព្រោះមិនធ្វើដូច្នោះ ។*

*ក្នុងកាលចប់ទេសនា ភិក្ខុកំលោះ ក៏បានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះធម៌ទេសនា មានប្រយោជន៍ដល់ជនទាំងឡាយអ្នកប្រជុំគ្នា ដូច្នេះឯង ។*

ចប់ រឿងភិក្ខុកំលោះ

# ២. រឿងព្រះបាទសុទ្ធោទនៈ

*ព្រះសាស្ដា កាលស្ដេចប្រថាប់នៅនិគ្រោធារាម ទ្រង់ប្រារព្ធព្រះបិតា ត្រាស់ព្រះធម្មទេសនានេះថា* ***ឧត្តិដ្ឋេ នប្បមជ្ជេយ្យ (មិនគប្បីប្រមាទក្នុងដុំបាយដែលខ្លួនក្រោកឡើងទទួល)*** *ជាដើម ។*

ព្រះសាស្ដាស្ដេចយាងទៅក្រុងកបិលពស្តុគ្រាដំបូង

*សេចក្ដីពិស្ដារថា សម័យមួយ ព្រះសាស្ដាស្ដេចយាងទៅក្រុងកបិល-ពស្តុបុរី ដោយស្ដេចទៅជាគ្រាដំបូង មានការក្រោកទទួលដែលព្រះញាតិទាំងឡាយធ្វើហើយ ស្ដេចយាងទៅកាន់និគ្រោធារាម ទ្រង់បាននិម្មិតរតនចង្ក្រមក្នុងអាកាស ទ្រង់ចង្ក្រមលើរតនចង្ក្រមនោះ ទ្រង់សំដែងព្រះធម៌ដើម្បីទម្លាយមានះរបស់ពួកព្រះញាតិទាំងឡាយ ។ ព្រះញាតិទាំងឡាយមានចិត្តជ្រះថ្លាហើយ ក៏ថ្វាយបង្គំ តាំងអំពីព្រះបាទសុទ្ធោទនៈជាដើមទៅ ។ ភ្លៀងបោក្ខរព័ស្សក៏បានធ្លាក់ចុះក្នុងសមាគមនៃព្រះញាតិនោះ ។ កាលមហាជនប្រារព្ធភ្លៀងនោះ សន្ទនាគ្នាហើយ ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនមានតែក្នុងឥឡូវប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភ្លៀងបោក្ខរព័ស្សក៏ធ្លាក់ចុះក្នុងសមាគមនៃព្រះញាតិរបស់តថាគតដែរ" ហើយក៏ត្រាស់* ***វេស្សន្តរជាតក*** *។ បណ្ដាព្រះញាតិដែលស្ដាប់ធម្មទេសនាហើយ ក៏ចៀសចេញទៅ សូម្បីតែមួយអង្គក៏មិនបាននិមន្តព្រះសាស្ដាឡើយ ។ សូម្បីព្រះរាជាក៏ទ្រង់មិនបាននិមន្ត ដោយព្រះតម្រិះ*

ថា "បុត្ររបស់យើងមិនមកកាន់សម្នាក់យើង នឹងទៅទីណា" ហើយស្តេចក៏ទៅ ។ លុះស្តេចយាងទៅហើយ ត្រាស់បង្គាប់ឲ្យមនុស្សតាក់តែងបបរជាដើម ឲ្យក្រាលអាសនៈទាំងឡាយទុក ដើម្បីភិក្ខុប្រមាណ ២ ម៉ឺនអង្គ ក្នុងព្រះរាជ-មន្ទីរ ។

ព្រឹកឡើង ព្រះសាស្តាស្តេចយាងចូលទៅព្រះនគរដើម្បីបិណ្ឌបាត ទ្រង់ពិចារណាថា "ព្រះពុទ្ធក្នុងអតីតទាំងឡាយ ស្តេចយាងដល់ព្រះនគរនៃព្រះបិតាហើយ ស្តេចយាងទៅកាន់ត្រកូលនៃព្រះញាតិតែម្តងឬហ្ន៎ ឬថា ស្តេចយាងទៅបិណ្ឌបាតតាមលំដាប់" ទ្រង់ក៏ជ្រាបថា "ស្តេចយាងទៅដោយលំដាប់" ដូច្នេះហើយ ទើបទ្រង់និមន្តទៅដើម្បីបិណ្ឌបាត តាំងអំពីផ្ទះដំបូងមក ។ ព្រះមាតារបស់ព្រះរាហុល ប្រថាប់គង់លើផ្ទៃប្រាសាទឃើញហើយ ក៏ក្រាបទូលព្រឹត្តិហេតុនោះដល់ព្រះរាជា ព្រះរាជាទ្រង់ចាត់ចែងសំពត់សាដក ស្តេចប្រញាប់យាងចេញទៅ ថ្វាយបង្គំព្រះសាស្តាហើយ ត្រាស់ថា "ព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វីបានជាធ្វើឲ្យខ្ញុំព្រះអង្គវិនាស ព្រះអង្គយាងទៅដើម្បីភិក្ខា រមែងធ្វើសេចក្តីខ្មាសអៀនឲ្យកើតឡើងដល់ខ្ញុំព្រះអង្គជាពន់ពេក ព្រះអង្គធ្វើកម្មមិនគួរឡើយ កាលព្រះអង្គយាងទៅដោយអង្រឹងមាសជាដើម ដើម្បីភិក្ខាក្នុងនគរនេះនោះឯង ទើបគួរ សូមព្រះអង្គ កុំធ្វើឲ្យខ្ញុំព្រះអង្គអៀនខ្មាស" ។

## ការបិណ្ឌបាតជាវង្សរបស់ព្រះពុទ្ធ

ព្រះសាស្តា. មហាបពិត្រ តថាគតមិនបានឲ្យព្រះអង្គខ្មាសឡើយ តែ

តថាគតប្រព្រឹត្តតាមវង្សរបស់ខ្លួន ។

ព្រះរាជា. បុត្រ ចុះការត្រាច់ទៅដើម្បីកិក្ខា ហើយចិញ្ចឹមជីវិត ជាវង្សរបស់ខ្ញុំព្រះអង្គឬ ។

ព្រះសាស្តាត្រាស់ថា "មហាបពិត្រ ទុំះមិនមែនជាវង្សរបស់ព្រះអង្គទេ តែទុំះជាវង្សរបស់តថាគត ព្រោះព្រះពុទ្ធច្រើនអង្គ ស្តេចត្រាច់ទៅដើម្បីបិណ្ឌ-បាតយ៉ាងនេះដូចគ្នា" ដូច្នេះហើយ បានភាសិតព្រះគាថាទាំងនេះថា ៖

២. ឧត្តិដ្ឋេ នប្បមជ្ជេយ្យ   ធម្មំ សុចរិតំ ចរេ
ធម្មចារី សុខំ សេតិ   អស្មឹ លោកេ បរម្ហិ ច ។
ធម្មំ ចរេ សុចរិតំ   ន តំ ទុច្ចរិតំ ចរេ
ធម្មចារី សុខំ សេតិ   អស្មឹ លោកេ បរម្ហិ ច ។

បុគ្គលមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។ បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា ឧត្តិដ្ឋេ (ក្នុងដុំបាយដែលខ្លួនគប្បីក្រោក

**ឡើងទទួល)** សេចក្តីថា ក្នុងដុំបាយដែលខ្លួនត្រូវក្រោកឈរឡើងទទួល ត្រង់ទ្វារផ្ទះរបស់ពួកជនដទៃ ។ បទថា **នប្បមជ្ជេយ្យ (មិនគប្បីប្រមាទ)** សេចក្តីថា ក៏ភិក្ខុធ្វើឲ្យធម្មទំនៀមរបស់អ្នកត្រាច់បិណ្ឌបាតជាប្រក្រតីវិនាសហើយ ស្វែងរកភោជនដ៏ប្រណីត ឈ្មោះថា រមែងប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល តែថា កាលត្រាច់ទៅតាមលំដាប់ច្រកល្ហកដើម្បីបិណ្ឌបាត ឈ្មោះថា រមែងមិនប្រមាទ ។ ការធ្វើយ៉ាងនេះ ឈ្មោះថា មិនគប្បីប្រមាទក្នុងដុំបាយដែលខ្លួនគប្បីក្រោកឈរឡើងទទួល ។

បទថា **ធម្មំ (ធម៌)** សេចក្តីថា កាលលះបង់អនេសនៈ (ការស្វែងរកមិនគួរ)ចេញហើយ ត្រាច់ទៅតាមលំដាប់ច្រកល្ហក ឈ្មោះថា ប្រព្រឹត្តធម៌ គឺការត្រាច់ទៅដើម្បីភិក្ខានោះឯង ឲ្យជាសុចរិត ។ បទថា **សុខំ សេតិ (រមែងនៅជាសុខ)** នោះ ត្រឹមតែជាទេសនា ។ អធិប្បាយថា កាលប្រព្រឹត្តធម៌ គឺការត្រាច់ទៅដើម្បីភិក្ខា ឈ្មោះថា ប្រព្រឹត្តធម៌ជាប្រក្រតី រមែងនៅជាសុខដោយឥរិយាបថទាំង ៤ ក្នុងលោកនេះ និងលោកខាងមុខ ។

ពីរបទថា **ន តំ ទុច្ចរិតំ (មិនគប្បីប្រព្រឹត្តធម៌នោះឲ្យទុច្ចរិត)** សេចក្តីថា កាលត្រាច់ទៅក្នុងអគោចរ ផ្សេងដោយអគោចរ មានស្រ្តីពេស្យាជាដើម ឈ្មោះថា រមែងប្រព្រឹត្តធម៌ គឺ ការត្រាច់ទៅដើម្បីភិក្ខាឲ្យជាទុច្ចរិត ។ មិនប្រព្រឹត្តយ៉ាងនោះ គប្បីប្រព្រឹត្តធម៌នោះឲ្យជាសុចរិត មិនគប្បីប្រព្រឹត្តធម៌នោះឲ្យជាទុច្ចរិតឡើយ ។ ពាក្យដ៏សេស មានន័យដូចពោលហើយ ។

*ក្នុងវេលាចប់ព្រះធម៌ទេសនា ព្រះរាជាបានតាំងនៅក្នុងសោតាបត្តិផល ព្រះធម៌ទេសនាមានប្រយោជន៍ដល់ជនទាំងឡាយ ដែលប្រជុំគ្នា ដូច្នេះឯង ។*

ចប់ រឿងព្រះបាទសុទ្ធោទនៈ

# ៣. រឿងភិក្ខុអ្នកចម្រើនវិបស្សនា

*ព្រះសាស្ដា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកចម្រើនវិបស្សនាប្រមាណ ៥០០ រូប ត្រាស់ព្រះធម្មទេសនានេះថា យថា បុព្ពុឡកំ បស្សេ (ដូចបុគ្គលឃើញដុំនៃពពុះទឹក) ជាដើម ។*

ភិក្ខុកាន់យកព្រេញថ្ងៃជាអារម្មណ៍

*បានឮថា ភិក្ខុទាំងនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដាហើយ ចូលទៅព្រៃខំប្រឹងប្រែង ក៏នៅមិនបានសម្រេចគុណវិសេស ទើបគិតថា "ពួកយើងនឹងរៀនកម្មដ្ឋានឲ្យវិសេសឡើងថែមទៀត" ក៏មកកាន់សម្នាក់របស់ព្រះសាស្ដា ឃើញថ្ងៃបណ្ដើរកូនពាក់កណ្ដាលផ្លូវ ចម្រើនកម្មដ្ឋាន ដែលមានថ្ងៃបណ្ដើរកូនជាអារម្មណ៍នោះឯងបណ្ដើរ ដើរមកបណ្ដើរ ។ ភ្លៀងក៏ធ្លាក់ក្នុងខណៈដែលភិក្ខុទាំងនោះចូលទៅកាន់វិហារនោះឯង ។ ភិក្ខុទាំងនោះ ឈរត្រង់ខាងមុខនោះៗ ឃើញពពុះទឹកទាំងឡាយប៉ោងឡើង ហើយបែកទៅវិញដោយសន្ទុះនៃខ្សែទឹក ក៏កាន់យកជាអារម្មណ៍ថា "អត្តភាពនេះក៏ដូចជាពពុះទឹក ព្រោះកើតឡើងហើយបែកធ្លាយទៅវិញ" ។ ព្រះសាស្ដាប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ជ្រាបដល់ភិក្ខុនោះហើយ ទ្រង់ផ្សាយព្រះឱភាស ដូចជាត្រាស់នឹងភិក្ខុទាំងនោះ បានត្រាស់ព្រះគាថានេះថា ៖*

*៣. យថា បុព្ពុឡកំ បស្សេ យថា បស្សេ មរីចិកំ*

*ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។*

*បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញព្រេញថ្ងៃយ៉ាងណា ស្តេចមច្ចុ មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។*

អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា* **មរីចិកំ** *គឺ ព្រេញថ្ងៃ ពិតណាស់ ព្រេញថ្ងៃសូម្បីប្រាកដឡើងអំពីទីឆ្ងាយ ដោយអំណាចមានសណ្ឋាន ដូចជាសណ្ឋានផ្ទះជាដើម តែជារូបដែលកាន់យកមិនបាន ជារបស់សូន្យទទេ (រមែងប្រាកដ) ដល់ជនទាំងឡាយអ្នកចូលទៅជិត ព្រោះហេតុនោះ ទើបមានពាក្យអធិប្បាយថា "មច្ចុរាជ រមែងមិនឃើញបុគ្គលអ្នកពិចារណាឃើញនូវលោក មានខន្ធជាដើម ដូចបុគ្គលឃើញពពុះទឹក ព្រោះអត្ថថា កើតឡើងហើយក៏បែកធ្លាយទៅ និងដូចបុគ្គលឃើញព្រេញថ្ងៃ ព្រោះជាធម្មជាតិសូន្យទទេជាដើម ដូច្នោះ ។*

*ក្នុងកាលចប់ព្រះធម៌ទេសនា ភិក្ខុទាំងនោះបានសម្រេចព្រះអរហត្តក្នុងទីដែលខ្លួនអង្គុយនោះឯង ដោយប្រការដូច្នេះ ។*

ចប់ រឿងភិក្ខុអ្នកចម្រើនវិបស្សនា

# ៤. រឿងអភយរាជកុមារ

ព្រះសាស្តា ស្តេចប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធអភយរាជកុមារ ត្រាស់ព្រះធម្មទេសនានេះថា **ឯថ បស្សថិមំ លោកំ (អ្នកទាំងឡាយចូរមក មើលលោកនេះ)** ជាដើម ។

ព្រះកុមារបានទទួលរាជសម្បត្តិ

បានឮថា កាលអភយរាជកុមារនោះ ទ្រង់បង្ក្រាបបច្ចន្តជនបទឲ្យស្ងប់ រម្ងាប់មកហើយ ព្រះបាទពិម្ពិសារជាព្រះបិតាទ្រង់សព្វព្រះហឫទ័យ ព្រះរាជទាន ស្រីរបាំម្នាក់ដែលឆ្លាតក្នុងការរាំ និងច្រៀង ហើយបានព្រះរាជទានរាជសម្បត្តិ ៧ ថ្ងៃ ។ អភយរាជកុមារនោះ ស្តេចមិនបានចេញខាងក្រៅព្រះរាជមន្ទីរឡើយ សោយសិរីនៃភាពជាព្រះរាជាអស់ ៧ ថ្ងៃ ស្តេចទៅកាន់កំពង់ទឹកក្នុងថ្ងៃទី ៨ ទ្រង់ស្រង់ទឹកហើយ ស្តេចចូលទៅកាន់ព្រះឧទ្យាន ប្រថាប់គង់ទតការរាំ និង ការច្រៀងរបស់ស្រីនោះ ដូចសន្តតិមហាមាត្យ ។ ក្នុងខណៈនោះឯង ស្ត្រីរបាំ នោះ ក៏បានធ្វើមរណកាលដោយអំណាចខ្យល់ដូចជាសស្ត្រា ដូចស្ត្រីរបាំរបស់ សន្តតិមហាមាត្យដែរ ។ ព្រះរាជកុមារមានសេចក្តីសោកកើតឡើងហើយ ព្រោះ កាលកិរិយារបស់ស្ត្រីរបាំនោះ ទ្រង់ព្រះតម្រិះថា "អ្នកដទៃវៀរព្រះសាស្តាចេញ នឹងមិនអាចធ្វើសេចក្តីសោកនេះឲ្យរលត់បានឡើយ" ហើយស្តេចក៏ចូលទៅគាល់ ព្រះសាស្តា ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គរំលត់សេចក្តី

សោករបស់ខ្ញុំព្រះអង្គផង" ។

ឧបាយរម្ងាប់សេចក្តីសោក

ព្រះសាស្តា ទ្រង់លួងលោមព្រះកុមារនោះហើយ ត្រាស់ថា "ក៏ប្រមាណទឹកភ្នែកទាំងឡាយ ដែលអ្នកទួញយំក្នុងកាលនៃស្ត្រីនេះស្លាប់យ៉ាងនេះឯង ឲ្យប្រព្រឹត្តទៅហើយមិនមាន ក្នុងសង្សារដែលមានទីបំផុត ដែលនរណាៗ ដឹងមិនបាន" ទ្រង់ជ្រាបភាវៈនៃសេចក្តីសោកមានសភាពស្រាលស្តើង ព្រោះទេសនានោះហើយ ទើបមានព្រះពុទ្ធដីកាត្រាស់ថា "កុមារអ្នកកុំសោយសោកឡើយ រឿងនោះ ជាឋានៈសម្រាប់លិចចុះរបស់ជនពាលទាំងឡាយទេ" ដូច្នេះហើយ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖

៤. ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ
យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ ។

អ្នកទាំងឡាយ ចូរមកមើលលោកនេះ ដ៏ត្រកាលដូចរាជរថ
ជនពាលទាំងឡាយ រមែងលិចលង់ក្នុងលោកណា សេចក្តី
ជាប់ជំពាក់ក្នុងលោកនោះ រមែងមិនមាន ដល់ជនជាបណ្ឌិត
ទាំងឡាយដែលដឹងច្បាស់ទេ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា ឯថ បស្សថ (អ្នកទាំងឡាយចូរមកមើល) ព្រះសាស្តាត្រាស់សំដៅយកព្រះរាជកុមារនោះឯង ។ បទថា ឥមំ លោកំ

(លោកនេះ) បានដល់ អត្តភាព ពោលគឺ ខន្ធលោកជាដើមនេះ ។ បទថា **ចិត្តំ** (ដ៏ត្រកាល) សេចក្តីថា ដែលវិចិត្រដោយគ្រឿងប្រដាប់ មានគ្រឿងប្រដាប់ គឺ សំពត់ជាដើម ដូចរាជរថ ដែលវិចិត្រដោយគ្រឿងប្រដាប់ មានកែវ ៧ ប្រការ ជាដើម ។ បទថា **យត្ថ ពាលា** (ដែលពួកជនពាល) សេចក្តីថា ពួកជនពាល ប៉ុណ្ណោះ លិចលង់ក្នុងអត្តភាពណា ។ បទថា **វិជានតំ** (អ្នកប្រាជ្ញ) សេចក្តីថា តែចំពោះពួកអ្នកប្រាជ្ញ គឺ បណ្ឌិតទាំងឡាយ មិនមានសេចក្តីជាប់ជំពាក់ក្នុង កិលេសដែលជាគ្រឿងជាប់ជំពាក់ មានរាគៈជាដើមសូម្បីក្នុងអត្តភាពនោះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ព្រះរាជកុមារក៏បានតាំងនៅក្នុងសោតាបត្តិផល ព្រះធម្មទេសនាបានមានប្រយោជន៍ដល់ជនអ្នកប្រជុំគ្នា ដូច្នេះឯង ។

ចប់ រឿងអភយរាជកុមារ

# ៥. រឿងព្រះសម្មជ្ជនត្ថេរ

*ព្រះសាស្តា កាលស្តេចប្រថាប់នៅនាវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះសម្មជ្ជ-នត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* ***យោ ច បុព្វេ បមជ្ជិត្វា (ជនណាប្រមាទអំពីមុន)*** *ជាដើម ។*

អ្នកមិនប្រមាទរមែងញុំាងលោកឱ្យភ្លឺស្វាង

*បានឮថា ព្រះថេរៈនោះ មិនធ្វើវេលាឲ្យជាប្រមាណថា ព្រឹក ឬល្ងាចទេ តែងតែដើរបោសសម្អាតរឿយៗ ។ ថ្ងៃមួយ ព្រះថេរៈនោះកាន់អំបោសទៅកាន់សម្នាក់របស់ព្រះរេវតៈ ដែលអង្គុយក្នុងទីសម្រាកពេលថ្ងៃ បានពោលថា "ព្រះថេរៈនេះ មហាខ្ជិល បរិភោគរបស់ដែលជនឲ្យដោយសទ្ធាហើយ គិតតែអង្គុយ" កាលដែលព្រះថេរៈនុ៎ះកាន់យកអំបោស ហើយបោសត្រង់កន្លែងមួយ មិនគួរទេឬ" ព្រះថេរៈគិតថា "យើងនឹងឲ្យឱវាទដល់លោក" ហើយបានពោលថា "មកនេះ អាវុសោ" ។*

*ព្រះសម្មជ្ជនត្ថេរ. អ្វី លោកម្ចាស់ ។*

*ព្រះរេវតៈ. លោកចូរទៅ ស្រង់ទឹកហើយសឹមមក ។*

*ព្រះសម្មជ្ជនត្ថេរនោះ ក៏បានធ្វើដូច្នោះ ។*

*លំដាប់នោះ ព្រះថេរៈឲ្យលោកអង្គុយក្នុងទីដ៏សមគួរមួយហើយ ពោលប្រដៅថា "អាវុសោ ធម្មតាភិក្ខុដើរតែបោសគ្រប់វេលា មិនគួរទេ ក៏ភិក្ខុបោស*

អំពីព្រលឹមហើយ ត្រាច់បិណ្ឌបាត ត្រឡប់អំពីបិណ្ឌបាតហើយ មកអង្គុយក្នុងទីសម្រាកពេលថ្ងៃ ឬពេលយប់ ស្វាធ្យាយអាការ ៣២ ផ្ដើមពិចារណាការអស់ទៅ និងការសូន្យទៅក្នុងអត្តភាពហើយ ក្រោកឡើងបោសក្នុងវេលាសៀលទើបគួរ ភិក្ខុមិនគប្បីបោសគ្រប់កាលជានិច្ចទេ គប្បីធ្វើឱកាសសម្រាប់ខ្លួនផង ។ ព្រះសម្មជ្ជនត្ថេរនោះ តាំងនៅក្នុងឱវាទរបស់ព្រះថេរៈហើយ មិនយូរប៉ុន្មានក៏តាំងនៅក្នុងព្រះអរហត្ត ។ ទីនោះៗ ក៏បានជាគំនរសំរាមធំ ។

លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងព្រះសម្មជ្ជនត្ថេរនោះថា "សម្មជ្ជនៈដ៏មានអាយុ ទីនោះៗ បានជាគំនរសំរាមធំ ព្រោះហេតុអ្វី ទើបលោកមិនបោសទៀត" ។

ព្រះសម្មជ្ជនត្ថេរ. លោកដ៏ចម្រើន ខ្ញុំធ្វើហើយដូច្នោះ កាលនៅប្រមាទ តែឥឡូវនេះ ខ្ញុំជាអ្នកមិនប្រមាទ ។

ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលដល់ព្រះសាស្ដាថា "ភិក្ខុនេះ ព្យាករណ៍អរហត្តផល ។ ព្រះសាស្ដាត្រាស់ថា "យ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគត ដើរបោសក្នុងកាលប្រមាទក្នុងពេលមុន តែឥឡូវនេះ បុត្រតថា-គត សម្រាកសម្រាន្តដោយសុខដែលកើតអំពីមគ្គផល ទើបមិនបោស ហើយត្រាស់ព្រះគាថានេះថា ៖

៥. យោ ច បុព្វេ បមជ្ជិត្វា    បច្ឆា សោ នប្បមជ្ជតិ
សោមំ លោកំ បភាសេតិ  អព្ភា មុត្តោវ ចន្ទិមា ។

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាង
ក្រោយ គេមិនប្រមាទវិញ បុគ្គលនោះឈ្មោះថា ញុំាងខន្ធា-
ទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះច័ន្ទរះផុតចាកពពក ។

អធិប្បាយគាថា

បណ្ឌិតគប្បីជ្រាបសេចក្ដីនៃព្រះគាថានោះថា ៖

បុគ្គលណា ប្រមាទហើយក្នុងកាលមុន ដោយការធ្វើវត្តបដិបត្តិ ឬព្រោះការស្វាធ្យាយជាដើម ខាងក្រោយសម្រាកសម្រាន្តដោយសុខ ដែលកើតអំពីមគ្គផល ឈ្មោះថា មិនប្រមាទ បុគ្គលនោះរមែងញុំាងលោក មានខន្ធជាដើមនេះឲ្យភ្លឺ គឺ រមែងធ្វើឲ្យភ្លឺស្វាងដោយមគ្គញាណ ដូចព្រះច័ន្ទរះផុតហើយចាកពពក ញុំាងឱកាសលោកឲ្យភ្លឺ ដូច្នោះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងព្រះសម្មជ្ជនត្ថេរ

# ៦. រឿងព្រះអង្គុលិមាល

*ព្រះសាស្ដា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះអង្គុលិមាល ត្រាស់ព្រះធម្មទេសនានេះថា* **យស្ស បាបំ កតំ កម្មំ (បុគ្គលណាលះបាបកម្ម ដែលខ្លួនធ្វើហើយ ដោយកុសល)** *ជាដើម ។*

ដើមរឿងចុងត្រង់ប្រើច្រាស់ចាន

*សេចក្ដីនៃរឿងនេះ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃអង្គុលិមាល-សូត្រនោះឯង ។ ក៏ព្រះថេរៈបួសក្នុងសម្នាក់របស់ព្រះសាស្ដា បានសម្រេចព្រះអរហត្ត ។ គ្រានោះឯង ព្រះអង្គុលិមាលទៅក្នុងទីស្ងាត់ គេចចេញអំពីពួកសោយវិមុត្តិសុខ បន្លឺឧទាននេះក្នុងវេលានោះថា ៖*

> **អ្នកដែលប្រមាទអំពីមុនហើយ ដល់មកខាងក្រោយ គេមិនប្រមាទ នឹងញុំាងលោកឲ្យភ្លឺបាន ដូចព្រះច័ន្ទរះផុតហើយចាកពពកដូច្នោះឯង ។**

*លុះបន្លឺឧទានហើយ ក៏បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា "អ្នកមានអាយុ ព្រះថេរៈកើតក្នុងទីណាហ្ន៎" ព្រះសាស្ដាស្ដេចយាងមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នក ឥឡូវនេះអង្គុយសន្ទនាគ្នាដោយពាក្យអ្វី" កាលភិក្ខុទាំងនោះ ក្រាបទូលថា "ដោយពាក្យប្រារព្ធដល់ទីកើតរបស់ព្រះអង្គុលិមាល ព្រះអង្គ" ក៏ត្រាស់ថា*

ម្នាលភិក្ខុទាំងឡាយ "បុត្ររបស់តថាគតបរិនិព្វានហើយ" ភិក្ខុទាំងឡាយទូលសួរថា "ព្រះអង្គុលិមាលសម្លាប់មនុស្សមានប្រមាណប៉ុណ្ណេះ បរិនិព្វានហើយឬ ព្រះអង្គ" ទើបត្រាស់ថា "យ៉ាងនោះហើយ ម្នាលភិក្ខុទាំងឡាយ ព្រោះអង្គុលិមាលនោះ មិនបានកល្យាណមិត្តត្រឹមតែម្នាក់ ទើបបានធ្វើបាបមានប្រមាណប៉ុណ្ណេះក្នុងកាលមុន តែក្រោយមក បានកល្យាណមិត្តជាបច្ច័យ ទើបជាអ្នកមិនប្រមាទ ព្រោះហេតុនោះ បាបកម្មនោះ គឺ បុត្ររបស់តថាគតលះបានហើយដោយកុសល ហើយត្រាស់ព្រះគាថានេះថា ៖

៦. យស្ស បាបំ កតំ កម្មំ  កុសលេន បិធីយតិ
សោមំ លោកំ បភាសេតិ  អព្ភា មុត្តោវ ចន្ទិមា ។

បុគ្គលណា ធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាបនោះដោយ
កុសល គឺ អរហត្តមគ្គបាន បុគ្គលនោះឈ្មោះថា ញុំាងខន្ធា-
ទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះច័ន្ទរះផុតចាកពពក ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា កុសលេន (ដោយកុសល) ព្រះសាស្ដាត្រាស់សំដៅយកព្រះអរហត្តមគ្គ ។ ពាក្យដ៏សេស មានអត្ថងាយទាំងអស់ ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចលោកុត្តរផល

*មានសោតាបត្តិផលជាដើម ។*

ចប់ រឿងព្រះអង្គុលិមាល

# ៧. រឿងធីតាជាងតម្បាញ

*ព្រះសាស្តា កាលស្តេចប្រថាប់នៅនាអគ្គាឡវចេតិយ ទ្រង់ប្រារព្ធធីតារបស់ជាងតម្បាញម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា* ***អន្ធភូតោ អយំ លោកោ (សត្វលោកនេះ ដូចជាអ្នកខ្វាក់ភ្នែក)*** *ជាដើម ។*

អ្នកចម្រើនមរណស្សតិមិនខ្លាចស្លាប់

*សេចក្តីពិស្តារថា ថ្ងៃមួយ ពួកអ្នកក្រុងអាឡវី កាលព្រះសាស្តាស្តេចយាងដល់ក្រុងអាឡវីហើយ ក៏បានទូលនិមន្តថ្វាយទាន ។ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាក្នុងវេលាស្រេចភត្តកិច្ចហើយថា "អ្នកទាំងឡាយ ចូរចម្រើនមរណស្សតិយ៉ាងនេះថា ជីវិតរបស់យើងមិនទៀងទាត់ សេចក្តីស្លាប់របស់យើងទៀង យើងត្រូវស្លាប់ជាប្រាកដ ជីវិតរបស់យើងមានសេចក្តីស្លាប់ជាទីបំផុត ជីវិតរបស់យើងមិនទៀង សេចក្តីស្លាប់ទៀង ក៏មរណៈ ដែលជនទាំងឡាយណាមិនបានចម្រើនហើយ ក្នុងកាលទីបំផុត (ក្នុងវេលាជិតស្លាប់) ជនទាំងឡាយនោះ រមែងតក់ស្លុត ធ្វើនូវសំឡេងគួរឲ្យខ្លាចហើយធ្វើមរណកាល ដូចបុរសឃើញអាសិរពិសហើយ ភ័យខ្លាចដូច្នោះ រីឯមរណៈដែលជនទាំងឡាយណាបានចម្រើនហើយ ជនទាំងឡាយនោះ រមែងមិនតក់ស្លុតក្នុងកាលជិតស្លាប់ ដូចបុរសឃើញអាសិរពិសអំពីចម្ងាយ ហើយក៏យកមែកឈើគ្គាះចោលទៅ ដូច្នោះ ព្រោះដូច្នោះ អ្នកទាំងឡាយគប្បីចម្រើនមរណស្សតិ" ។*

ពួកជនដ៏សេស ស្តាប់ព្រះធម្មទេសនានោះហើយ បានខ្វល់ខ្វាយតែក្នុងកិច្ចការរបស់ខ្លួនប៉ុណ្ណោះ ។ ចំណែកធីតារបស់ជាងតម្បាញអាយុ ១៦ ឆ្នាំម្នាក់ គិតថា "ឱ! ធម្មតាពាក្យរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយអស្ចារ្យ យើងគួរតែចម្រើនមរណស្សតិ ហើយក៏ខំចម្រើនមរណស្សតិអស់ថ្ងៃ និងយប់" ។ ចំណែកព្រះសាស្តា ស្តេចយាងចេញចាកក្រុងអាឡវីហើយ ស្តេចក៏បានយាងទៅជេតវនារាម ។ នាងកុមារិកានោះ ក៏ចម្រើនមរណស្សតិជានិច្ច អស់ ៣ ឆ្នាំ ។ តមកថ្ងៃមួយ ព្រះសាស្តាទ្រង់ប្រមើលមើលលោកក្នុងវេលាទៀបភ្លឺ ទ្រង់ឃើញនាងកុមារិកានោះចូលក្នុងសំណាញ់ គឺ ព្រះញាណរបស់ព្រះអង្គ ទ្រង់ពិចារណាថា "នឹងមានហេតុអ្វីហ្ន៎" ទ្រង់ក៏ជ្រាបថា នាងកុមារិកានេះ ចម្រើននូវមរណ-ស្សតិអស់ ៣ ឆ្នាំ តាំងអំពីថ្ងៃដែលស្តាប់ធម្មទេសនារបស់ព្រះអង្គ ឥឡូវនេះតថាគតទៅទីនោះ ហើយសួរបញ្ហា ៤ ប្រការនឹងនាងកុមារិកានេះ កាលនាងឆ្លើយបញ្ហាចប់ នឹងឲ្យសាធុការ ក្នុងឋានៈទាំង ៤ ហើយភាសិតគាថានេះ ក្នុងវេលាចប់គាថា នាងកុមារិកានោះ នឹងតាំងនៅក្នុងសោតាបត្តិផល ព្រោះហេតុនាងកុមារិកានោះ ទេសនានឹងមានប្រយោជន៍ដល់មហាជន ដូច្នេះហើយ ទ្រង់មានភិក្ខុប្រមាណ ៥០០ រូបជាបរិវារ ស្តេចបានយាងចេញចាកជេតវនារាមទៅកាន់អគ្គាឡវវិហារដោយលំដាប់ ។ ពួកអ្នកក្រុងអាឡវីជ្រាបថា ព្រះសាស្តាស្តេចយាងមកហើយ ក៏បាននាំគ្នាទៅវិហារទូលនិមន្ត ។ ឯនាងកុមារិកានោះជ្រាបដល់ការយាងមករបស់ព្រះសាស្តា មានចិត្តរីករាយថា "ឮថា ព្រះមហាគោ-

តមជាព្រះបិតា ទ្រង់ជាធំ ជាព្រះអាចារ្យ ទ្រង់មានព្រះភក្ត្រ ដូចព្រះច័ន្ទពេញវង់របស់យើង ស្តេចយាងមកហើយ ទើបគិតថា ព្រះសាស្តាមានពណ៌ដូចមាស យើងធ្លាប់ឃើញអស់ ៣ ឆ្នាំហើយមកដល់ថ្ងៃនេះ តែឥឡូវនេះ យើងនឹងបានឃើញព្រះសរីរៈដែលមានពណ៌ដូចមាស និងបានស្តាប់ ធម៌ដែលជាឱវាទ និងមានឱជាដ៏ពីរោះគួរឲ្យចាប់ចិត្តរបស់ព្រះសាស្តានោះ" ។

ចំណែកបិតារបស់នាង កាលទៅកាន់រោងតម្បាញ បានផ្តាំកូនស្រីទុកថា "កូន អំបោះសម្រាប់ត្បាញសំពត់សាដកជារបស់អ្នកដទៃ បិតាកំពុងត្បាញអំបោះសំពត់នោះនៅមួយដុំទៀតមិនទាន់ហើយ បិតានឹងធ្វើឲ្យហើយក្នុងថ្ងៃនេះ កូនខារហើយត្រូវនាំមកឲ្យបិតា ឲ្យឆាប់ ។ នាងកុមារិកានោះគិតថា "យើងចង់ស្តាប់ធម៌របស់ព្រះសាស្តា តែបិតាប្រើយើង ដូច្នេះ យើងនឹងស្តាប់ធម៌របស់ព្រះសាស្តា ឬនឹងខារអំបោះហើយនាំទៅឲ្យបិតា" គ្រានោះ នាងកុមារិកានោះមានគំនិតយ៉ាងនេះថា "បើយើងមិននាំខ្នារអំបោះទៅឲ្យ បិតាគប្បីវាយយើងខ្លះប្រហារយើងខ្លះ ដូច្នោះ យើងខារអំបោះឲ្យគាត់ហើយ សឹមស្តាប់ធម៌ជាខាងក្រោយ" ហើយអង្គុយខារលើតាំង ។ ឯពួកអ្នកក្រុងអាឡវី អង្គាសព្រះសាស្តាហើយ បានទទួលបាត្រ ឋិតនៅដើម្បីចាំទទួលអនុមោទនា ។ ព្រះសាស្តាបានប្រថាប់ស្ងៀម ព្រោះទ្រង់ព្រះតម្រិះថា "តថាគត អាស្រ័យកុលធីតាណា មកហើយអស់ផ្លូវ ៣០ យោជន៍ កុលធីតានោះមិនមានឱកាសក្នុងថ្ងៃនេះ កាលកុលធីតាបានឱកាស ទើបតថាគតធ្វើអនុមោទនា" ។ ក៏នរណាៗ ក្នុងលោក

ព្រមទាំងទេវលោក មិនអាចនឹងទូលអ្វីៗ នឹងព្រះសាស្ដា ដែលទ្រង់គង់ស្ងៀមយ៉ាងនោះបាន ចំណែកកុមារិកានោះឯង ខារអំបោះហើយដាក់ក្នុងកញ្ច្រែង ដើរទៅកាន់សម្នាក់របស់បិតា ទៅដល់ខាងក្រោយបរិស័ទហើយ ក៏បានងាកមើលព្រះសាស្ដាបណ្ដើរ ដើរបណ្ដើរ ។ ឯព្រះសាស្ដា ក៏ទ្រង់ងើបព្រះសុរងទតនាងកុមារិកានោះ ។ នាងកុមារិកានោះបានជ្រាបដោយអាការដែលព្រះសាស្ដាទតថា "ព្រះសាស្ដាប្រថាប់គង់កណ្ដាលបរិស័ទបែបនោះ ទតព្រះនេត្រមកយើង ទ្រង់រង់ចាំការមករបស់យើង ទ្រង់ចាំយើងមកកាន់សម្នាក់របស់ព្រះអង្គ" ។ នាងដាក់កញ្ច្រែងខ្នារអំបោះហើយ បានទៅកាន់សម្នាក់របស់ព្រះសាស្ដា ។

សួរថា ព្រោះហេតុអ្វី ទើបព្រះសាស្ដាទតព្រះនេត្រមករកនាងកុមារិកានោះ ។

ឆ្លើយថា បានឮថា ព្រះអង្គបានទ្រង់ព្រះបរិវិតក្កៈយ៉ាងនេះថា "នាងកុមារិកានោះ កាលទៅអំពីទីនេះ នឹងធ្វើមរណកាលទាំងជាបុថុជ្ជន នឹងជាអ្នកមានគតិមិនទៀងទាត់ តែបើមកកាន់សម្នាក់តថាគតហើយទៅ នឹងបានសម្រេចសោតាបត្តិផល ជាបុគ្គលមានគតិទៀង នឹងកើតក្នុងតុសិតវិមាន ។ ឮថា ថ្ងៃនោះ នាងកុមារិកានោះ មិនរួចចាកអំពីសេចក្ដីស្លាប់បានឡើយ ។

នាងកុមារិកានោះ ចូលទៅគាល់ព្រះសាស្ដាដោយសញ្ញា ដែលព្រះ-សាស្ដាទតព្រះនេត្រនោះឯង ចូលទៅចន្លោះនៃព្រះរស្មីមានពណ៌ ៦ ថ្វាយបង្គំហើយ បានឈរនៅក្នុងទីដ៏សមគួរមួយ ។

## ព្រះសាស្តាត្រាស់សួរបញ្ហានឹងធីតាជាងតម្បាញ

ក្នុងខណៈដែលនាងកុមារិកានោះថ្វាយបង្គំព្រះសាស្តា ដែលទ្រង់ប្រថាប់គង់ស្ងៀមនាកណ្តាលបរិស័ទនោះហើយ នៅឈរនោះឯង ព្រះសាស្តាត្រាស់នឹងនាងថា "កុមារិកានាង មកពីណា" ។

កុមារិកា. ខ្ញុំព្រះអង្គមិនដឹងទេ ព្រះអង្គ ។

ព្រះសាស្តា. នាងនឹងទៅទីណា ?

កុមារិកា. ខ្ញុំព្រះអង្គមិនដឹងទេ ព្រះអង្គ ។

ព្រះសាស្តា. នាងមិនដឹងឬ ?

កុមារិកា. ខ្ញុំព្រះអង្គដឹង ព្រះអង្គ ។

ព្រះសាស្តា. នាងដឹងទេឬ ?

កុមារិកា. ខ្ញុំព្រះអង្គមិនដឹងទេ ព្រះអង្គ ។

ព្រះសាស្តា ត្រាស់សួរបញ្ហា ៤ ប្រការនឹងកុមារិកានោះ ដោយប្រការដូច្នេះ ។

មហាជនលើកទោសថា "អ្នកដ៏ចម្រើនទាំងឡាយ លោកទាំងឡាយចូរមើល ធីតាជាងតម្បាញនេះ និយាយពាក្យដែលខ្លួនប្រាថ្នាហើយ នឹងព្រះសម្មាសម្ពុទ្ធ កាលព្រះអង្គត្រាស់ថា នាងមកពីណា? ធីតាជាងតម្បាញនេះ គួរនិយាយថា មកពីផ្ទះ កាលទ្រង់ត្រាស់ថា នាងនឹងទៅទីណា? ក៏គួរទូលថា ទៅរោងជាងតម្បាញ មិនមែនឬ?" ព្រះសាស្តាទ្រង់ធ្វើមហាជនឲ្យស្ងាត់សំឡេង

ហើយត្រាស់សួរថា “កុមារិកា នាងកាលតថាគតពោលថា មកពីណា? ហេតុអ្វី ទើបនាងឆ្លើយថា មិនដឹង?”

កុមារិកា. “បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរមែងបានជ្រាបសេចក្តីដែលខ្ញុំព្រះអង្គមកពីផ្ទះ តែព្រះអង្គត្រាស់សួរថា នាងមកពីណា បំណងត្រាស់សួរថា នាងមកពីណា ទើបកើតក្នុងទីនេះ? តែខ្ញុំព្រះអង្គមិនដឹងថា យើងមកអំពីទីណា ទើបកើតក្នុងទីនេះទេ” ។ លំដាប់នោះ ព្រះសាស្តាប្រទានសាធុការជាគ្រាដំបូងដល់នាង កុមារិកានោះថា “សាធុ សាធុ” កុមារិកា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយបានហើយ ហើយត្រាស់សួរតទៅទៀតថា នាង តថាគតសួរថា នាងនឹងទៅទីណា? ហេតុអ្វី ទើបពោលថាមិនដឹង? ។

កុមារិកា. បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ជ្រាបថាខ្ញុំព្រះអង្គកាន់កញ្ច្រែងខ្នារដើរទៅកាន់រោងតម្បាញហើយ, តែព្រះអង្គត្រាស់សួរថា ក៏នាងទៅអំពីលោកនេះហើយ នឹងកើតក្នុងទីណា? ខ្ញុំព្រះអង្គចុតិចាកលោកនេះហើយរមែងមិនដឹងថា នឹងទៅកើតក្នុងទីណាទេ ។

លំដាប់នោះ ព្រះសាស្តាក៏ប្រទានសាធុការដល់នាង ជាលើកទីពីរថា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយបានហើយ ហើយក៏ត្រាស់សួរតទៅទៀតថា បើដូច្នោះ នាង ដែលតថាគតសួរថា នាងមិនដឹងទេឬ ហេតុអ្វីទើបនិយាយថាដឹង ។

កុមារិកា. ខ្ញុំព្រះអង្គបានជ្រាបតែការៈ គឺ សេចក្តីស្លាប់របស់ខ្ញុំព្រះអង្គ

ប៉ុណ្ណោះព្រះអង្គ ហេតុនោះ ទើបពោលដូច្នោះ ។

លំដាប់នោះ ព្រះសាស្ដាបានប្រទានសាធុការដល់នាងជាលើកទី ៣ ថា បញ្ហាដែលតថាគតសួរហើយនោះឯង នាងក៏ឆ្លើយបាន ហើយទ្រង់ត្រាស់សួរតទៅទៀតថា បើដូច្នោះ នាង កាលតថាគតសួរថា នាងដឹងឬទេ? ហេតុអ្វីទើបពោលថា មិនដឹង? ។

កុមារិកា. ខ្ញុំព្រះអង្គជ្រាបតែការៈ គឺ សេចក្ដីស្លាប់របស់ខ្ញុំព្រះអង្គប៉ុណ្ណោះព្រះអង្គ តែមិនដឹងថា នឹងស្លាប់ពេលយប់ ពេលថ្ងៃ ឬពេលព្រឹកជាដើមទេ ព្រោះហេតុនោះ ទើបពោលដូច្នោះ ។

ជនមានបញ្ញាឈ្មោះថាមានចក្ខុ

លំដាប់នោះ ព្រះសាស្ដាប្រទានសាធុការលើកទី ៤ ដល់នាងថា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយត្រូវហើយ រួចត្រាស់ដាស់តឿនបរិស័ទថា "ពួកអ្នកមិនដឹងប្រមាណនូវពាក្យដែលនាងកុមារិកានេះពោលហើយទេ ទើបពោលទោសតែម្យ៉ាងប៉ុណ្ណោះ ព្រោះចក្ខុ គឺ បញ្ញារបស់ពួកជនណាមិនមាន ពួកជននោះដូចជាមនុស្សខ្វាក់ ចក្ខុ គឺ បញ្ញារបស់ពួកជនណាមាន ជនទាំងនោះនុ៎ះឯង ទើបជាអ្នកមានចក្ខុ ហើយបានត្រាស់ព្រះគាថានេះថា ៖

៧. អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ

សកុន្តោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្ដាជនទាំងនេះ

*ជនតិចគ្នាដែលឃើញច្បាស់ (នូវខន្ធាទិលោកនេះដោយអំណាច អនិច្ចលក្ខណៈជាដើម) ជនតិចគ្នា ដែលទៅកាន់ឋានសួគ៌ ដូច សត្វស្លាប (ដែលជាប់សំណាញ់របស់ព្រានហើយ) តិចណាស់ ដែលរួចចាកអំពីសំណាញ់ ដូច្នោះ ។*

អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា **អយំ លោកោ** (សត្វលោកនេះ) សេចក្តីថា លោកិយមហាជននេះ ឈ្មោះថា ដូចជាមនុស្សខ្វាក់ ព្រោះមិនមានចក្ខុ គឺបញ្ញា ។ ពីរបទថា **តនុកេត្ថ** (ក្នុងលោកនេះតិចអ្នកណាស់) សេចក្តីថា ជនក្នុងលោកនេះ តិចនាក់ គឺ មិនច្រើន នឹងឃើញច្បាស់ដោយអំណាចនៃត្រៃ-លក្ខណ៍ មានមិនទៀងជាដើម ។ បទថា **ជាលមុត្តោវ** (ដូចសត្វបក្សារួចពីសំណាញ់) បណ្តាហ្វូងសត្វចាប ដែលនាយព្រានអ្នកឆ្លាតដាក់សំណាញ់ចាប់យក សត្វចាបខ្លះប៉ុណ្ណោះរួចចាកសំណាញ់បាន ចាបដ៏សេស រមែងជាប់នៅក្នុងសំណាញ់នោះឯង យ៉ាងណា បណ្តាសត្វដែលជាប់សំណាញ់របស់មាររួចទុកហើយ សត្វជាច្រើន រមែងទៅកាន់អបាយ តិចនាក់ណាស់ គឺ បុគ្គលខ្លះប៉ុណ្ណោះទៅកាន់សួគ៌ គឺ រមែងដល់សុគតិ ឬនិព្វាន ដូច្នោះឯង ។*

*ក្នុងវេលាចប់ព្រះធម៌ទេសនា នាងកុមារិកានោះបានតាំងនៅក្នុងសោ-តាបត្តិផល ព្រះធម៌ទេសនាមានប្រយោជន៍ដល់មហាជន ដូច្នេះ ។*

ធីតាជាងតម្បាញស្លាប់ហើយ ទៅកើតក្នុងភពតុសិត

ឯនាងកុមារិកានោះ បានកាន់កញ្ច្រែងខ្នារអំបោះទៅកាន់សម្នាក់របស់បិតា ។ ចំណែកបិតានោះ ក៏អង្គុយដេកលក់ ។ កាលនាងមិនបានកំណត់ហើយបង្អោនកញ្ច្រែងខ្នារចូលទៅ កញ្ច្រែងខ្នារប៉ះត្រង់ទីដែលដាក់ត្រល់ ហើយធ្លាក់ ធ្វើឲ្យមានសំឡេងឡើង ។ បិតានោះភ្ញាក់ឡើងហើយ ក៏ចាប់ត្រល់ចោលទៅ ត្រង់និមិត្តដែលខ្លួនកាន់យកហើយនោះឯង ។ ចុងត្រល់ក៏បានទៅប្រហារនាងកុមារិកានោះត្រង់ទ្រូង នាងក៏ស្លាប់នៅត្រង់ទីនោះឯង បានទៅកើតក្នុងភពតុសិត ។ លំដាប់នោះ បិតារបស់នាង ក្រឡេកមើលនាង បានឃើញសរីរៈរបស់នាងទាំងអស់ប្រឡាក់ដោយឈាម ដេកស្លាប់ហើយ ។ គ្រានោះ សេចក្តីសោកដ៏ធំកើតឡើងដល់បិតានោះ ។ គាត់ស្រែកយំ ដោយគិតថា "អ្នកដទៃនឹងមិនអាចរំលត់សេចក្តីសោករបស់យើងបានឡើយ ទើបទៅកាន់សម្នាក់របស់ព្រះសាស្តា ក្រាបទូលរឿងនោះ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ញ៉ាំងសេចក្តីសោករបស់ខ្ញុំឲ្យរលត់" ។ ព្រះសាស្តាបានត្រាស់លួងលោមគាត់ហើយ ត្រាស់ថា "អ្នកកុំសោកឡើយ ព្រោះថា ទឹកភ្នែករបស់អ្នកដែលហូរចេញក្នុងកាលដែលធីតារបស់អ្នកស្លាប់ ដោយអាការយ៉ាងនេះនេះឯងក្នុងសង្សារ ដែលគ្មានទីបំផុត ដែលនរណាៗ នឹងដឹងបានឡើយ ក្រៃលែងជាងទឹកមហាសមុទ្ទទាំង ៤ ហើយទ្រង់បានត្រាស់អនមតគ្គសូត្រ" គេមានសេចក្តីសោកស្រាលស្តើង ទូលសូមបព្វជ្ជានឹងព្រះសាស្តា បានឧបសម្បទាហើយ ត

មក មិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្ត ដូច្នេះឯង ។

ចប់ រឿងធីតារបស់ជាងតម្បាញ

# ៨. រឿងភិក្ខុ ៣០ រូប

*ព្រះសាស្តា កាលប្រថាប់នៅក្នុងជេតពន ទ្រង់បានប្រារព្ធភិក្ខុ ៣០ រូប ត្រាស់ព្រះធម្មទេសនានេះថា* ***ហំសា អាទិច្ចបថេ យន្តិ (ហង្សទាំងឡាយរមែងតែងហើរទៅតាមគន្លងផ្លូវព្រះអាទិត្យ)*** *ជាដើម ។*

បុគ្គលចម្រើនឥទ្ធិបាទ រមែងហោះទៅបាន

*សេចក្តីពិស្តារថា ក្នុងថ្ងៃមួយ ភិក្ខុអ្នកមានប្រក្រតីនៅក្នុងទិសប្រមាណ ៣០ រូប ចូលទៅគាល់ព្រះសាស្តា ។ ព្រះអានន្ទមកក្នុងវេលាដែលធ្វើវត្តដល់ព្រះសាស្តា ឃើញភិក្ខុទាំងនោះហើយ គិតថា "កាលព្រះសាស្តាធ្វើបដិសណ្ឋារៈជាមួយភិក្ខុទាំងនេះហើយ ឯយើងធ្វើវត្តហើយ" ដូច្នេះ ក៏បានទៅឈរត្រង់ខ្លោងទ្វារ ។ ចំណែកព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយនឹងភិក្ខុទាំងនោះហើយ ក៏ត្រាស់កថាដែលប្រារព្ធធម៌ជាគ្រឿងឲ្យរឭកដល់គ្នានឹងគ្នា ដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះស្តាប់ធម្មកថានោះហើយ បានសម្រេចព្រះអរហត្តគ្រប់អង្គ បានហោះទៅឰដ៏អាកាស ។ ព្រះអានន្ទត្ថេរ កាលភិក្ខុទាំងនោះនៅយូរពេក ក៏ចូលទៅគាល់ព្រះសាស្តា ទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុ ៣០ រូប មកក្នុងទីនេះ ភិក្ខុទាំងនោះទៅណាហើយ?"*

*ព្រះសាស្តា. ម្នាលអានន្ទ បានទៅហើយ ។*

*អានន្ទ. បពិត្រព្រះអង្គ ទៅតាមផ្លូវណា ?*

ព្រះសាស្តា. ម្នាលអានន្ទ ផ្លូវអាកាស ។

អានន្ទ. ចុះភិក្ខុទាំងនោះ ជាព្រះខីណាស្រពឬ ព្រះអង្គ?

ព្រះសាស្តា. ម្នាលអានន្ទ ត្រូវហើយ ភិក្ខុទាំងនោះស្តាប់ធម៌ក្នុងសម្នាក់តថាគតបានសម្រេចព្រះអរហត្ត ។ ក៏ក្នុងខណៈនោះឯង ហង្សទាំងឡាយហើរទៅ ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ឥទ្ធិបាទ ៤ ដែលបុគ្គលណាចម្រើនល្អហើយ បុគ្គលនោះរមែងហោះទៅបានដូចហង្ស ដូច្នោះ ហើយក៏ត្រាស់ព្រះគាថានេះថា ៖

៨. ហំសាទិច្ចបថេ យន្តិ អាកាសេ យន្តិ ឥទ្ធិយា
នីយន្តិ ធីរា លោកម្ហា ជេត្វា មារំ សវាហនំ ។

ពួកហង្ស តែងហើរទៅក្នុងគន្លងផ្លូវព្រះអាទិត្យ អ្នកមានឫទ្ធិ
តែងហោះទៅក្នុងអាកាសដោយឫទ្ធិ អ្នកប្រាជ្ញផ្ចាញ់កិលេស-
មារ ព្រមទាំងពាហនៈ គឺ តណ្ហាបានហើយ រមែងរលាស់ខ្លួន
ចេញចាកលោកបាន ។

អធិប្បាយគាថា

បណ្ឌិតគប្បីជ្រាបសេចក្តីនៃព្រះគាថានោះថា ៖

ហង្សទាំងនេះ រមែងទៅក្នុងគន្លងផ្លូវនៃព្រះអាទិត្យ គឺ ក្នុងអាកាស ។ ឯឥទ្ធិបាទដែលជនពួកណាចម្រើនល្អហើយ ជនពួកនោះឯង រមែងទៅក្នុងអាកាសដោយឫទ្ធិបាន ឯធីរជនទាំងឡាយ គឺ បណ្ឌិត ឈ្នះមារព្រមទាំងពាហនៈហើយ

រមែងចេញទៅ គឺ រមែងរលាស់ចេញចាកលោក គឺ វដ្តៈនេះ បានដល់ ព្រះនិព្វាន ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងភិក្ខុ៣០រូប

# ៩. រឿងនាងចិញ្ចមាណវិកា

*ព្រះសាស្តា កាលប្រថាប់នៅក្នុងជេតពន ទ្រង់ប្រារព្ធនាងចិញ្ចមាណ-វិកា ត្រាស់ព្រះធម្មទេសនានេះថា* ***ឯកធម្មអតីតស្ស*** *(អ្នកឈានកន្លងធម៌ឯក) ជាដើម ។*

*ពួកតិរ្ថិយ៍ប្រណៃងព្រះពុទ្ធសាសនា*

*សេចក្តីពិស្តារថា ក្នុងបឋមពោធិកាល កាលសាវកព្រះទសពលមានប្រមាណច្រើន ពួកទេវតា និងពួកមនុស្ស ឈានចុះកាន់អរិយភូមិ ការកើតឡើងនៃព្រះគុណរបស់ព្រះសាស្តា បានផ្សព្វផ្សាយទៅ ទើបលាភសក្ការៈជាច្រើនបានកើតឡើង ។ ពួកតិរ្ថិយ៍ប្រាកដដូចជាពន្លឺអំពិលអំពែក ក្នុងពេលព្រះអាទិត្យរះ ជាអ្នកសាបសូន្យលាភសក្ការៈ ។ ពួកតិរ្ថិយ៍ទាំងនោះ ឈរកណ្តាលផ្លូវ ប្រកាសឲ្យពួកមនុស្សដឹងច្បាស់យ៉ាងនេះថា "ព្រះសមណគោតមប៉ុណ្ណោះឬ ជាព្រះពុទ្ធ សូម្បីយើងក៏ជាព្រះពុទ្ធដែរ ទានដែលឲ្យដល់ព្រះសមណគោ-តមប៉ុណ្ណោះឬ មានផលច្រើន សូម្បីទានដែលឲ្យហើយដល់ពួកយើង ក៏មានផលច្រើន ដូចគ្នាដែរ អ្នកទាំងឡាយចូរឲ្យ ចូរធ្វើដល់ពួកយើងខ្លះ" កាលមិនបានលាភសក្ការៈ ក៏ប្រជុំគ្នាក្នុងទីស្ងាត់ថា "ពួកយើងគប្បីញុំាងទោសឲ្យកើតឡើងដល់ព្រះសមណគោតម ក្នុងចំណោមមនុស្សទាំងឡាយ គប្បីញុំាងលាភសក្ការៈឲ្យវិនាសដោយឧបាយដូចម្តេចហ្ន៎?" កាលនោះ ក្នុងក្រុងសាវត្ថី មាន*

នាងបរិព្វាជិកាម្នាក់ ឈ្មោះចិញ្ចមាណវិកា ជាអ្នកមានរូបឆោមល្អ ដល់នូវការប្រសើរដោយភាពល្អស្អាត ដូចស្រីទេពអប្សរដូច្នោះ រស្មីបានផ្សាយចេញចាកសរីរៈរបស់នាង ។

## នាងចិញ្ចមាណវិកាទទួលអាសាពួកតិរ្ថិយ៍

លំដាប់នោះ តិរ្ថិយ៍អ្នកឈ្លាសវៃម្នាក់ ពោលយ៉ាងនេះថា “ពួកយើងអាស្រ័យនាងចិញ្ចមាណវិកា គប្បីញ៉ាំងទោសឲ្យកើតឡើងដល់ព្រះសមណគោតម ធ្វើលាភសក្ការៈរបស់លោកឲ្យវិនាសបាន” ។ តិរ្ថិយ៍ទាំងនោះទទួលព្រមថា “ឧបាយនេះល្អ” ។ តមក នាងចិញ្ចមាណវិកានោះទៅកាន់អារាមរបស់តិរ្ថិយ៍ ថ្វាយបង្គំហើយក៏បានឈរ ។ ពួកតិរ្ថិយ៍មិនតបតជាមួយនាង ។ នាងទើបគិតថា “យើងមានទោសអ្វីហ្ន៎” សូម្បីនាងនិយាយអស់ ៣ ដងថា “លោកម្ចាស់ទាំងឡាយ នាងខ្ញុំថ្វាយបង្គំហើយ ក៏និយាយថា លោកម្ចាស់ទាំងឡាយ នាងខ្ញុំមានទោសអ្វី? ព្រោះហេតុអ្វី ទើបលោកម្ចាស់ទាំងឡាយមិននិយាយជាមួយនាងខ្ញុំ?” ។

តិរ្ថិយ៍. ម្នាលប្អូនស្រី នាងមិនដឹងថាព្រះសមណគោតមបៀតបៀនពួកយើង ត្រាច់ធ្វើពួកយើងឲ្យសាបសូន្យចាកលាភសក្ការៈទេឬ?

នាងចិញ្ចា. នាងខ្ញុំមិនដឹងទេ លោកម្ចាស់ ចុះក្នុងរឿងនេះ នាងខ្ញុំគួរធ្វើយ៉ាងណា? ។

តិរ្ថិយ៍. ម្នាលប្អូនស្រី បើនាងប្រាថ្នាសេចក្តីសុខដល់ពួកយើង ចូរញ៉ាំង

ទោសឲ្យកើតឡើងដល់ព្រះសមណគោតម ហើយញ៉ាំងលាភសក្ការៈឲ្យសាប-សូន្យ ព្រោះអាស្រ័យខ្លួននាង ។ នាងពោលថា "ល្អហើយ លោកម្ចាស់ទាំងឡាយ រឿងនេះចូរទុកជាភារៈរបស់នាងខ្ញុំ លោកម្ចាស់ទាំងឡាយកុំគិតឡើយ" ហើយក៏ចៀសចេញទៅ ដណ្តប់សំពត់មានពណ៌ដូចមេភ្លៀង មានគ្រឿងក្រអូបនិងផ្កាកម្រងជាដើមក្នុងដៃ តម្រង់មុខឆ្ពោះវត្តជេតពន ទៅក្នុងសម័យដែលកំពុងស្តាប់ធម្មកថារបស់អ្នកក្រុងសាវត្ថី ហើយចេញអំពីវត្តជេតពនវិញក្នុងកាលនោះ ព្រោះនាងជាអ្នកឆ្លាតក្នុងមាយារបស់ស្ត្រី កាលអ្នកដទៃសួរនាងថា "នាងទៅណាក្នុងវេលានេះ?" ក៏ពោលថា "ប្រយោជន៍អ្វីរបស់ពួកលោកក្នុងទីដែលខ្ញុំទៅ" សម្រាកក្នុងវត្តរបស់តិរ្ថិយ៍ជិតវត្តជេតពន កាលមនុស្សជាឧបាសកចេញអំពីព្រះនគរពីព្រលឹម ដោយសង្ឃឹមថា នឹងថ្វាយបង្គំព្រះសាស្តា នាងធ្វើដូចជាទៅក្នុងវត្តជេតពន ចូលទៅកាន់ព្រះនគរ, កាលជនជាឧបាសកសួរថា "នាងនៅទីណា?" ក៏ពោលថា "ប្រយោជន៍អ្វីរបស់ពួកលោកចំពោះទីដែលខ្ញុំនៅ" ដោយកាលកន្លងទៅ ២-៣ ខែ កាលត្រូវគេសួរ ក៏ពោលថា "ខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណគោតម ក្នុងវត្តជេតពន" ញ៉ាំងសេចក្តីសង្ស័យដល់ពួកបុថុជ្ជនថា "រឿងនុ៎ះពិត ឬមិនពិតហ្ន៎" ដោយកាលកន្លងទៅ ៣-៤ ខែ យកកំណាត់សំពត់ចងពោះ សំដែងភេទរបស់ស្ត្រីមានគភ៌ ឲ្យពួកជនអន្ធពាលជឿថា គភ៌កើតឡើង ព្រោះអាស្រ័យព្រះសមណគោតម ដោយកាលកន្លងទៅ ៨-៩ ខែ ចងដុំឈើមូលត្រង់ពោះ ដណ្តប់សំពត់ពីលើ យកឆ្អឹងគោ

វាយដៃ និងជើង សំដែងអាការផ្សេងៗ មានឥន្ទ្រីយ៍មិនស្រស់បស់ កាលព្រះ-តថាគតប្រថាប់គង់សំដែងធម៌លើធម្មាសនៈដែលគេតាក់តែងហើយ ក្នុងវេលារសៀល ទៅកាន់ធម្មសភា ឈរខាងមុខព្រះភក្ត្ររបស់ព្រះសាស្តា ហើយបានពោលថា “មហាសមណៈ ព្រះអង្គល្អតែខាងសំដែងធម៌ដល់មហាជនប៉ុណ្ណោះ សំឡេងរបស់ព្រះអង្គពីរោះ ព្រះឱស្ឋរបស់ព្រះអង្គស្និទ្ធ ចំណែកខ្ញុំម្ចាស់អាស្រ័យព្រះអង្គ ក៏មានគភ៌គ្រប់កំណត់ហើយ ព្រះអង្គមិនទ្រង់ជ្រាបផ្ទះសំរាប់ប្រសូតមិនជ្រាបគ្រឿងរក្សាគភ៌ មានទឹកដោះថ្លា និងទឹកឃ្មុំជាដើម បើទ្រង់មិនធ្វើខ្លួនឯង ម្តេចមិនត្រាស់ប្រាប់ព្រះបាទកោសល ឬអនាថបិណ្ឌិក ឬក៏នាងវិសាខាមហាឧបាសិកាណាមួយ បណ្តាឧបដ្ឋាកទាំងឡាយថា អ្នកចូរធ្វើកិច្ចដែលគួរធ្វើដល់នាងចិញ្ចមាណវិកានេះ ព្រះអង្គទ្រង់ដឹងតែអភិរម្យប៉ុណ្ណោះ ទ្រង់មិនដល់ដឹងការរក្សាគភ៌ទេ” ។

ព្រះមានព្រះភាគ ទ្រង់ផ្អាកការសម្តែងធម្មកថា កាលទ្រង់បន្លឺសីហនាទថា “ប្អូនស្រី ពាក្យដែលនាងពោលហើយ នឹងពិត ឬមិនពិត មានតែតថាគតនិងនាងប៉ុណ្ណោះ ទើបដឹង ។

នាងចិញ្ចមាណវិកា. ត្រូវហើយ មហាសមណៈ រឿងនុ៎ះ កើតឡើងចំពោះព្រះអង្គ និងខ្ញុំ ទើបដឹង ។

ខណៈនោះ អាសនៈរបស់សក្កទេវរាជសំដែងអាការក្តៅ ។ ព្រះអង្គពិចារណាមើល ក៏ជ្រាបថា “នាងចិញ្ចមាណវិកា ជេរព្រះតថាគតដោយពាក្យ

មិនពិត ហើយទ្រង់ត្រិះរិះទៀតថា យើងនឹងជម្រះរឿងនេះឲ្យបរិសុទ្ធ" ទើបស្ដេចមកជាមួយនឹងទេវបុត្រ ៤ អង្គ ។ ទេវបុត្រទាំងឡាយ ក្លែងជាកណ្ដុរខាំខ្សែដែលចងដុំឈើ ដោយខាំតែម្ដងប៉ុណ្ណោះ ។ ខ្យល់ក៏បក់ផ្ទាំងសំពត់ដណ្ដប់ឡើង ។ ដុំឈើរបូតធ្លាក់ចុះមកលើខ្នងជើងរបស់នាងចិញ្ចមាណវិកានោះ ។ ចុងជើងទាំងពីរខាងក៏បានបែក ។ មនុស្សទាំងឡាយនិយាយថា នែ៎នាងកាឡកណ្ណី នាងជេរព្រះសម្មាសម្ពុទ្ធ ហើយបានស្ដោះទឹកមាត់លើក្បាល មានដៃកាន់ដុំដី និងដំបង បណ្ដេញនាងចេញពីវត្តជេតពន ។

## នាងចិញ្ចមាណវិកាត្រូវផែនដីស្រូប

ពេលដែលនាងទៅផុតគន្លងព្រះនេត្ររបស់ព្រះតថាគត មហាផែនដីក៏បើកចន្លោះហើយ ។ អណ្ដាតភ្លើងតាំងឡើងអំពីអវីចីនរក ។ នាងចិញ្ចមាណវិកានោះ ទៅកើតក្នុងអវីចី ដូចជាដណ្ដប់សំពត់កម្ពលដែលត្រកូលឲ្យ ។ លាភសក្ការៈរបស់ពួកតិរ្ថិយ៍ក៏បានសាបសូន្យ ។ ត្រឡប់ជាកាន់តែចម្រើនដល់ព្រះទសពលប្រមាណក្រៃលែង ។

ក្នុងថ្ងៃព្រឹកឡើង ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា "អ្នកដ៏មានអាយុទាំងឡាយ នាងចិញ្ចមាណវិកាជេរព្រះសម្មាសម្ពុទ្ធ ជាអគ្គទក្ខិណេយ្យទ្រង់មានគុណប្រមាណមិនបានយ៉ាងនេះ ដោយពាក្យមិនពិត ទើបដល់មហាវិនាស" ។ ព្រះសាស្ដាស្ដេចយាងមក ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះពួកអ្នក អង្គុយប្រជុំគ្នាដោយពាក្យអ្វី" កាលភិក្ខុទាំងឡាយក្រាបទូលថា "ដោយពាក្យ

ឈ្មោះនេះ” ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះទេ ក្នុងកាលមុន នាងចិញ្ចមាណវិកានោះ ក៏ជេរតថាគតដោយពាក្យមិនពិត ហើយដល់សេចក្ដីវិនាសដូចគ្នាដែរ” ហើយត្រាស់មហាបទុមជាតក ក្នុងទ្វាទសកនិបាតនេះឲ្យពិស្ដារថា ៖

**បុគ្គលជាធំ មិនឃើញទោសតូច-ធំ របស់អ្នកដទៃដោយប្រការ**

**ទាំងពួងហើយ មិនទាន់ពិចារណាខ្លួនឯង មិនគប្បីដាក់អាជ្ញា ។**

ព្រះពោធិសត្វត្រូវទម្លាក់ចុះក្នុងជ្រោះតែមិនស្លាប់

(ព្រះអង្គត្រាស់ថា) បានឮថា ក្នុងកាលនោះ នាងចិញ្ចមាណវិកានោះ ជាអ្នករួមស្វាមីរបស់ព្រះមាតានៃព្រះពោធិសត្វ ព្រះនាមថា **មហាបទុមកុមារ** ជាអគ្គមហេសីរបស់ព្រះរាជា បបួលព្រះមហាសត្វដោយអសទ្ធម្ម មិនបានការយល់ព្រមពីព្រះពោធិសត្វ ក៏ធ្វើប្រការប្លែកក្នុងខ្លួនដោយខ្លួនឯង សម្ដែងអាការជាឈឺ ក្រាបទូលដល់ព្រះរាជាថា “ព្រះឱរសរបស់ព្រះអង្គ ធ្វើឲ្យខ្ញុំម្ចាស់ដែលមិនប្រាថ្នាហើយ ដល់អាការប្លែកនេះ” ។ ព្រះរាជាទ្រង់ខ្ញាល់ ក៏ទម្លាក់ព្រះពោធិសត្វទៅក្នុងជ្រោះ ដែលជាកន្លែងសម្រាប់ទម្លាក់ចោរ ។

គ្រានោះ ទេវតាដែលអាស្រ័យនៅត្រង់ផ្ទៃនៃភ្នំ (ជ្រោះ) បានទទួលព្រះមហាសត្វហើយ ឲ្យប្រតិស្ឋាននៅក្នុងផ្ទៃពពាររបស់ស្ដេចនាគ ។ ស្ដេចនាគនាំព្រះមហាសត្វទៅកាន់ពិភពនាគ ទ្រង់រាប់អានដោយរាជសម្បត្តិពាក់កណ្ដាល ។ ព្រះមហាសត្វនៅក្នុងពិភពនាគអស់មួយឆ្នាំ ប្រាថ្នានឹងបួស ក៏មកកាន់ហិមវន្ត-

ប្រទេស បួសហើយក៏បានញ៉ាំងឈាន និងអភិញ្ញាឲ្យកើតឡើង ។

ព្រះពោធិសត្វថ្វាយព្រះឱវាទដល់ព្រះរាជា

តមក ព្រានព្រៃម្នាក់ឃើញព្រះមហាសត្វនោះ ក៏បានក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាស្ដេចក៏ទៅកាន់សម្នាក់របស់ព្រះពោធិសត្វនោះហើយ នឹងបានបដិសណ្ឋារៈដែលព្រះពោធិសត្វធ្វើហើយ ទ្រង់បានជ្រាបព្រឹត្តិហេតុនោះទាំងអស់ ទ្រង់បានអញ្ជើញព្រះមហាសត្វដោយរាជសម្បត្តិ ព្រះមហាសត្វថ្វាយព្រះឱវាទថា "កិច្ចដោយរាជសម្បត្តិរបស់ខ្ញុំព្រះអង្គមិនមាន ក៏ព្រះអង្គចូរកុំឲ្យរាជធម៌ ១០ ប្រការកម្រើក ទ្រង់លះអគតិចេញ ហើយសោយរាជ្យដោយធម៌ចុះ" ហើយស្ដេចក្រោកចាកអាសនៈ ទ្រង់ព្រះកន្សែង ស្ដេចទៅកាន់ព្រះនគរ ត្រាស់សួរអាមាត្យទាំងឡាយត្រង់ពាក់កណ្ដាលផ្លូវថា "យើងដល់នូវការព្រាត់ប្រាសចាកបុត្រដែលសម្បូណ៌ដោយអាចារៈយ៉ាងនេះ ព្រោះអាស្រ័យនរណា"

អាមាត្យ. បពិត្រព្រះអង្គ ព្រោះអាស្រ័យអគ្គមហេសី ។

ព្រះរាជាត្រាស់ឲ្យចាប់ព្រះអគ្គមហេសីនោះ ធ្វើឲ្យមានជើងឡើងលើទម្លាក់ទៅក្នុងជ្រោះសម្រាប់ទម្លាក់ចោរ ស្ដេចចូលទៅកាន់ព្រះនគរ សោយរាជ-សម្បត្តិដោយធម៌ ។ ព្រះមហាបទុមកុមារក្នុងកាលនោះ បានមកជាព្រះមហា-សត្វ ស្ត្រីរួមស្វាមីនឹងព្រះមាតា បានមកជានាងចិញ្ចមាណវិកា ។

ព្រះសាស្ដា ទ្រង់ប្រកាសសេចក្ដីនេះហើយ មានព្រះពុទ្ធដីកាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលលះពាក្យសត្យៈដែលជាធម៌ឯកហើយ តាំងនៅក្នុង

មុសាវាទ ជាអ្នកមានបរលោកលះបង់ហើយ មិនធ្វើបាបរមែងមិនមាន” ទើប ត្រាស់ព្រះគាថានេះថា ៖

៩. ឯកំ ធម្មំ អតីតស្ស មុសាវាទិស្ស ជន្តុនោ
វិតិណ្ណបរលោកស្ស នត្ថិ បាបំ អការិយំ ។

បុគ្គលប្រព្រឹត្តកន្លង (ពាក្យសច្ចៈ) ដែលជាធម៌ឯក និយាយ
តែពាក្យកុហក មានបរលោកលះចោលហើយ ឈ្មោះថា មិន
ធ្វើអំពើបាប មិនមែនឡើយ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ឯកំ ធម្មំ** (ធម៌ឯក) គឺ នូវពាក្យសត្យៈ ។ បទថា **មុសាវាទិស្ស** (និយាយកុហក) សេចក្ដីថា បណ្ដាពាក្យនិយាយ ១០ ពាក្យ ពាក្យសច្ចៈសូម្បីតែ ១ មិនមានដល់បុគ្គលណា បុគ្គលបែបនេះ ឈ្មោះថា ជាអ្នកនិយាយកុហក ។ បទថា **វិតិណ្ណបរលោកស្ស** (**អ្នកមានបរលោកកន្លងផុតហើយ**) បានដល់ អ្នកមានបរលោកដែលលះបង់ចោលហើយ ក៏បុគ្គលបែបនេះ រមែងមិនប្រទះនឹងសម្បត្តិទាំង ៣ គឺ មនុស្សសម្បត្តិ ទេពសម្បត្តិ និព្វានសម្បត្តិក្នុងអវសានឡើយ ។ បទថា **នត្ថិ បាបំ** (**មិនគប្បីធ្វើបាប រមែងមិនមាន**) សេចក្ដីថា សេចក្ដីសង្ស័យថា បាបឈ្មោះនេះដែលបុគ្គលនោះ គឺ បុគ្គលបែបនោះ មិនគប្បីធ្វើ រមែងមិនមាន ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំង

ឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងនាងចិញ្ចមាណវិកា

# ១០. រឿងអសទិសទាន

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអសទិសទាន ត្រាស់ព្រះធម្មទេសនានេះថា **ន វេ កទរិយា ទេវលោកំ វជន្តិ (ពួកបុគ្គលកំណាញ់ទៅកាន់ទេវលោកមិនបានឡើយ)** ជាដើម ។

ព្រះរាជាថ្វាយទានប្រជែងជាមួយនឹងរាស្ត្រ

សេចក្តីពិស្តារថា សម័យមួយ ព្រះសាស្តាស្តេចចារិកទៅហើយ មានភិក្ខុប្រមាណ ៥០០ ជាបរិវារ ស្តេចយាងចូលទៅក្នុងវត្តជេតពន ។ ព្រះរាជាស្តេចទៅវិហារនិមន្តព្រះសាស្តា ក្នុងថ្ងៃព្រឹកឡើង ទ្រង់ចាត់ចែងអាគន្តុកទាន ហើយត្រាស់ហៅអ្នកនគរថា "ចូរមើលទានរបស់យើង" ។ អ្នកនគរមកឃើញទានរបស់ព្រះរាជាហើយ ក្នុងថ្ងៃព្រឹកឡើង ទូលនិមន្តព្រះសាស្តាចាត់ចែងទាន ហើយបញ្ជូនដំណឹងទៅក្រាបទូលដល់ព្រះរាជាថា "សូមព្រះសម្មតិទេព សូមទតមើលទានរបស់ពួកខ្ញុំព្រះអង្គ" ។ ព្រះរាជាស្តេចទៅទតទានរបស់ពួកអ្នកនគរនោះហើយ ទ្រង់ត្រិះរិះថា "ជនទាំងនេះធ្វើទានក្រៃលែងជាងទានរបស់យើង យើងនឹងធ្វើទានទៀត" ទើបត្រាស់ឲ្យចាត់ចែងទានក្នុងថ្ងៃព្រឹកឡើងទៀត ។ សូម្បីពួកអ្នកនគរឃើញទាននោះហើយ ក្នុងថ្ងៃព្រឹកឡើង ក៏ចាត់ចែងទានដោយប្រការដូច្នេះ ។ ដោយអាការយ៉ាងនេះឯង ព្រះរាជាទ្រង់មិនអាចធ្វើឲ្យអ្នកនគរចាញ់បាន ឯពួកអ្នកនគរក៏មិនអាចធ្វើឲ្យព្រះរាជាចាញ់បាន ។ តមក ក្នុងវារៈ

ទី ៦ អ្នកនគរប្រឹក្សាគ្នាថា "យើងនឹងចាត់ចែងទានដោយប្រការដែលនរណាៗ មិនអាចនិយាយបានថា វត្ថុនេះមានក្នុងទានរបស់អ្នកនគរទាំងនេះ" ព្រះរាជាទតមើលទាននោះហើយ ទ្រង់ត្រិះរិះថា "បើយើងមិនអាចធ្វើទានឲ្យក្រៃលែងជាងទានរបស់អ្នកនគរទាំងនោះសោត ប្រយោជន៍អ្វីរបស់យើងក្នុងការរស់នៅ" ដូច្នេះ ហើយបានផ្ទំត្រិះរិះរកឧបាយ ។

ព្រះនាងមល្លិកាចាត់ចែងទាន

លំដាប់នោះ ព្រះនាងមល្លិកាទេវីចូលទៅគាល់ព្រះអង្គ ហើយទូលសួរថា "បពិត្រមហារាជ ហេតុអ្វីបានជាព្រះអង្គផ្ទំយ៉ាងនេះ" ព្រះរាជាត្រាស់ថា "ទេវី ឥឡូវនេះ នាងនៅមិនទាន់ជ្រាបទេឬ" ។

ព្រះទេវី. ខ្ញុំម្ចាស់មិនជ្រាបទេ ព្រះអង្គ ។

ព្រះអង្គក៏បានត្រាស់ប្រាប់សេចក្តីនោះដល់ព្រះនាង ។

លំដាប់នោះ ព្រះនាងមល្លិកាក្រាបទូលព្រះអង្គថា "បពិត្រព្រះសម្មតិទេព ព្រះអង្គទ្រង់កុំគិតឡើយ ព្រះរាជាជាធំក្នុងផែនដី ត្រូវពួកអ្នកនគរផ្ចាញ់បាន ព្រះអង្គធ្លាប់ទតឃើញឬ ឬធ្លាប់ស្តាប់ហើយនៅទីណា? ខ្ញុំម្ចាស់នឹងចាត់ចែងទានជំនួសព្រះអង្គ" ។

ព្រះនាងក្រាបទូលដល់ព្រះអង្គយ៉ាងនេះ ព្រោះព្រះនាងបំណងនឹងចាត់ចែងអសទិសទាន ហើយក្រាបទូលថា "បពិត្រព្រះមហារាជ សូមព្រះអង្គត្រាស់បង្គាប់ឲ្យគេធ្វើមណ្ឌបសម្រាប់គង់ខាងក្នុងជារង្វង់មូល ដើម្បីភិក្ខុប្រមាណ ៥០០

រូប ដោយរនាបដែលធ្វើដោយដើមសាលៈ និងដើមក្លៅនាង ពួកភិក្ខុដ៏សេស នឹងគង់ខាងក្រៅរង្វង់មូល សូមត្រាស់បង្គាប់ឲ្យធ្វើស្វេតច្ឆត្រ ៥០០ មានដំរីប្រមាណ ៥០០ ឲ្យកាន់ស្វេតច្ឆត្រទាំងនោះ ឈរបាំងពីខាងលើភិក្ខុប្រមាណ ៥០០ រូប សូមត្រាស់បង្គាប់ឲ្យធ្វើទូក ដែលសម្រេចដោយមាសពណ៌ក្រហម ៨ ឬ ១០ ទូក នឹងមានមណ្ឌបត្រង់កណ្ដាល ខត្តិយធីតាមួយអង្គៗ ឈរកាន់ផ្លិតបក់ភិក្ខុ ២ រូបៗ ខត្តិយធីតាដ៏សេសនឹងនាំគ្រឿងក្រអូបដែលអប់ហើយមកដាក់ក្នុងទូកមាសទាំងឡាយ បណ្ដាខត្តិយធីតាទាំងនោះ ខត្តិយធីតាពួកខ្លះឲ្យកាន់បាច់ផ្កាឧប្បលខៀវ លាយដោយគ្រឿងក្រអូបទុកក្នុងទូកមាស ហើយប្រោះព្រំភិក្ខុ ព្រោះខត្តិយធីតាមិនមានដល់ពួកអ្នកនគរឡើយ ស្វេតច្ឆត្រក៏មិនមាន ដំរីក៏មិនមាន ពួកអ្នកនគរនឹងចាញ់ដោយហេតុទាំងនេះ បពិត្រមហារាជ សូមព្រះអង្គត្រាស់ឲ្យធ្វើយ៉ាងនេះចុះ" ។ ព្រះរាជាព្រមទទួលថា "ល្អហើយៗ ព្រះទេវី រឿងល្អនាងបានប្រាប់ហើយ" ក៏ត្រាស់ឲ្យធ្វើកិច្ចទាំងអស់ តាមទំនងដែលព្រះនាងក្រាបទូលហើយ ។ តែខ្វះដំរី ១ ទើបគ្រប់ដល់ភិក្ខុមួយរូប ។

លំដាប់នោះ ព្រះរាជាត្រាស់នឹងព្រះនាងមល្លិកាថា "នាងដ៏ចម្រើន នៅខ្វះដំរី ១ ទើបគ្រប់ដល់ភិក្ខុមួយរូប យើងនឹងធ្វើដូចម្ដេច?" ។

ព្រះទេវី. ដំរី ៥០០ មិនមានឬ ព្រះអង្គ ?

ព្រះរាជា. មាន ព្រះទេវី តែដំរីដ៏សេសជាដំរីកាច ដំរីទាំងនោះគ្រាន់តែឃើញភិក្ខុទាំងឡាយ ក៏ទៅជាសត្វកាចដូចខ្យល់កំបុតត្បូង ។

ព្រះទេវី. បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់ជ្រាបទីសម្រាប់ឈរកាន់ឆ័ត្រ របស់កូនដំរីកាចនោះហើយ ។

ព្រះរាជា. យើងនឹងឲ្យឈរត្រង់ទីណា ?

ព្រះទេវី. ឲ្យឈរជិតព្រះអង្គុលិមាលត្ថេរ ។

ព្រះរាជា ក៏បានត្រាស់ឲ្យរាជបុរសធ្វើដូច្នោះ ។ កូនដំរីស៊កកន្ទុយចូលក្នុងចន្លោះភ្លៅ បានទម្លាក់ត្រចៀកទាំងពីរ ឈរធ្មេចភ្នែក ។ មហាជនក្រឡេកមើលដំរីដែលប្រដាប់ដោយស្វេតច្ឆ័ត្រ ដើម្បីព្រះថេរៈប៉ុណ្ណោះ ដោយគិតថា "នេះជាអាការរបស់ដំរីកាច ដំរីបែបនេះ ព្រះអង្គុលិមាលត្ថេរក៏អាចធ្វើបាន" ។ ព្រះរាជាទ្រង់អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយអាហារដ៏ប្រណីតហើយ ថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន វត្ថុណាជាកប្បិយភ័ណ្ឌ ឬជាអកប្បិយភ័ណ្ឌក្នុងរោងទាននេះ ខ្ញុំព្រះអង្គនឹងថ្វាយវត្ថុទាំងអស់នោះដល់ព្រះអង្គប៉ុណ្ណោះ ។

ទានដែលព្រះនាងមល្លិកាចាត់ចែងឈ្មោះអសទិសទាន

ក៏ក្នុងទាននោះឯង ទ្រព្យមានប្រមាណ ១៤ កោដិ ជាទ្រព្យដែលព្រះរាជាទ្រង់បរិច្ចាគមួយថ្ងៃប៉ុណ្ណោះ ។ ក៏របស់ ៤ យ៉ាង គឺ ស្វេតច្ឆ័ត្រ ១ បល្ល័ង្កសម្រាប់គង់ ១ ជើងបាត្រ ១ តាំងសម្រាប់ជូតជើង ១ ជារបស់កាត់ថ្លៃមិនបាន ដើម្បីព្រះសាស្តា ។ នរណាៗ ដែលអាចធ្វើទានបែបនេះហើយថ្វាយទានដល់ព្រះពុទ្ធទាំងឡាយ មិនមានឡើយ ។ ព្រោះហេតុនោះឯង ទើប

ទាននោះឈ្មោះថា **អសទិសទាន** ។ បានឮថា អសទិសទាននោះ មានចំពោះព្រះពុទ្ធគ្រប់ៗ ព្រះអង្គតែប៉ុណ្ណោះ ។ ស្ត្រីប៉ុណ្ណោះ រមែងចាត់ចែងទានដើម្បីព្រះសាស្តា និងភិក្ខុទាំងពួង ។

ក៏អាមាត្យរបស់ព្រះរាជាមាន ២ នាក់ គឺ កាឡៈ ១ ជុណ្ហៈ ១ ។ បណ្តាអាមាត្យទាំង ២ នោះ កាឡអាមាត្យគិតថា "ឱ! សេចក្តីវិនាសនៃរាជត្រកូលទ្រព្យ ១៤ កោដិដល់នូវការអស់ទៅត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ភិក្ខុទាំងនេះបរិភោគទានហើយ នឹងទៅដេក ឱ! រាជត្រកូលវិនាសហើយ" ។ ចំណែកជុណ្ហអាមាត្យ គិតថា "ឱ! ទានរបស់ព្រះរាជា ក៏នរណាៗ មិនតាំងនៅក្នុងភាពជាព្រះរាជា មិនអាចថ្វាយទានបែបនេះបានទេ ព្រះរាជាឈ្មោះថា មិនឲ្យចំណែកបុណ្យដល់សត្វទាំងពួង រមែងមិនមាន យើងសូមអនុមោទនាទាននេះ" ។

ក្នុងទីបំផុតកត្តកិច្ចនៃព្រះសាស្តា ព្រះរាជាទ្រង់ទទួលបាត្រ ដើម្បីត្រូវការអនុមោទនា ។ ព្រះសាស្តាទ្រង់ត្រិះរិះថា "ព្រះរាជាថ្វាយមហាទាន ដូចឲ្យអន្លង់ទឹកជំប្រព្រឹត្តទៅ មហាជនអាចដើម្បីញុំាងចិត្តឲ្យជ្រះថ្លា ឬមិនជ្រះថ្លាហ្ន៎" ព្រះអង្គទ្រង់ជ្រាបវារៈចិត្តរបស់អាមាត្យទាំងនោះហើយ ទ្រង់ជ្រាបថា "បើតថាគតធ្វើអនុមោទនាឲ្យសមគួរដល់ទានរបស់ព្រះរាជាសោត សីសៈរបស់កាឡអាមាត្យនឹងបែកជា ៧ ចំរៀក ជុណ្ហអាមាត្យនឹងតាំងនៅក្នុងសោតាបត្តិផល" ទ្រង់អាស្រ័យសេចក្តីអនុគ្រោះក្នុងកាឡអាមាត្យ ទើបត្រាស់ព្រះគាថា ៤ បាទប៉ុណ្ណោះដល់ព្រះរាជា ដែលទ្រង់ថ្វាយទានបែបនេះ ប្រថាប់ឈរហើយ ស្តេច

ក្រោកអាសនៈយាងទៅកាន់ព្រះវិហារ ។

ទ្រង់ត្រាស់សរសើរព្រះអង្គុលិមាល

ភិក្ខុទាំងឡាយសួរព្រះអង្គុលិមាលថា "អ្នកមានអាយុ លោកឃើញដំរីកាចឈរបាំងឆ័ត្រ មិនខ្លាចទេឬ" ។

ព្រះអង្គុលិ. អ្នកមានអាយុទាំងឡាយ ខ្ញុំមិនខ្លាចទេ ។

ភិក្ខុទាំងនោះ ចូលទៅគាល់ព្រះសាស្តាហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គុលិមាលព្យាករណ៍អរហត្តផល" ។ ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អង្គុលិមាលមិនខ្លាចទេ ព្រោះថា ភិក្ខុទាំងឡាយជាអ្នកប្រាកដស្មើដូចជាបុត្រតថាគត ប្រាកដស្មើដោយគោឧសភៈដ៏ប្រសើរ ក្នុងចំណោមនៃគោឧសភៈ គឺ ព្រះខីណាស្រពទាំងឡាយ រមែងមិនខ្លាច" ហើយទ្រង់ត្រាស់ព្រះគាថាក្នុងព្រាហ្មណវគ្គថា ៖

តថាគតហៅបុគ្គលអ្នកអង់អាច អ្នកប្រសើរ អ្នកក្លៀវក្លា
អ្នកស្វែងរកគុណដ៏ធំ អ្នកឈ្នះដោយវិសេស អ្នកមិនញាប់
ញ័រ អ្នកជម្រះហើយ អ្នកត្រាស់ដឹងហើយនោះឯង ថាជា
ព្រាហ្មណ៍ ។

សូម្បីព្រះរាជាដល់សេចក្តីទោមនស្សថា "ព្រះសាស្តា ទ្រង់មិនបានធ្វើអនុមោទនាឲ្យសមគួរដល់យើង ដែលថ្វាយទានហើយ ឈរនៅក្នុងកណ្តាលបរិស័ទបែបនេះ ត្រាស់ត្រឹមតែមួយព្រះគាថាប៉ុណ្ណោះ ហើយស្តេចក្រោកចាក

អាសនៈយាងទៅ យើងនឹងជាអ្នកដែលមិនធ្វើទានឲ្យសមគួរ ដែលព្រះសាស្តាធ្វើទាន ដែលមិនសមគួរ យើងនឹងជាអ្នកមិនថ្វាយកប្បិយភ័ណ្ឌ ថ្វាយតែអ-កប្បិយភណ្ឌប៉ុណ្ណោះ យើងនឹងជាអ្នកដែលព្រះសាស្តាទ្រង់មិនពេញព្រះទ័យការធ្វើអនុមោទនាដ៏សមគួរដល់ទានរបស់បុគ្គលណាមួយទុំះឯង ទើបគួរ" ហើយស្តេចចូលទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្តាហើយ បានក្រាបទូលពាក្យនេះថា "បពិត្រព្រះអង្គដ៏ចម្រើន ទានដែលគួរនឹងថ្វាយ ខ្ញុំព្រះអង្គមិនបានថ្វាយឬ ឬខ្ញុំព្រះអង្គមិនបានថ្វាយកប្បិយភ័ណ្ឌដ៏សមគួរដល់ទាន ថ្វាយតែអកប្បិយភ័ណ្ឌប៉ុណ្ណោះ?" ។

ព្រះសាស្តា. មានរឿងអ្វី មហាបពិត្រ ?

ព្រះរាជា. ព្រះអង្គទ្រង់មិនធ្វើអនុមោទនាដ៏សមគួរ ដល់ទានរបស់ខ្ញុំព្រះអង្គ ។

ព្រះសាស្តា. មហាបពិត្រ ព្រះអង្គថ្វាយទានដ៏សមគួរហើយ ក៏ទាននោះឈ្មោះថា អសទិសទាន នរណាៗ អាចថ្វាយដល់ព្រះពុទ្ធអង្គតែម្តងប៉ុណ្ណោះ ធម្មតាទានបែបនេះ ជារបស់លំបាក ដែលបុគ្គលនឹងអាចថ្វាយបាន ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ ព្រោះហេតុអ្វី ទើបព្រះអង្គមិនធ្វើអនុមោទនាឲ្យសមគួរដល់ទាន របស់ខ្ញុំព្រះអង្គ? ។

ព្រះសាស្តា. ព្រោះបរិស័ទមិនបរិសុទ្ធ មហាបពិត្រ ។

ព្រះរាជា. ទោសអ្វីរបស់បរិស័ទ ព្រះអង្គ ?

ព្រះរាជានិរទេសអាមាត្យអាក្រក់

លំដាប់នោះ ព្រះសាស្ដាទ្រង់ត្រាស់ប្រាប់វារៈចិត្តរបស់អាមាត្យទាំងពីរ ហើយ ត្រាស់ប្រាប់ការអនុមោទនា ដែលព្រះអង្គអាស្រ័យសេចក្ដីអនុគ្រោះក្នុង កាឡអាមាត្យ ទើបទ្រង់មិនធ្វើដល់ព្រះរាជា ។ ព្រះរាជាត្រាស់សួរថា "កាឡះ បានឮថា "អ្នកគិតយ៉ាងនេះពិតមែនឬ" កាឡអាមាត្យក្រាបទូលថា "ពិតមែន" ទើបត្រាស់ថា "យើងព្រមទាំងបុត្រភរិយារបស់យើង មិនបានកាន់យកទ្រព្យ សម្បត្តិរបស់អ្នក ឲ្យតែទ្រព្យសម្បត្តិរបស់ខ្លួនដែលមាន តើបៀតបៀនអ្វីអ្នក វត្ថុណាដែលយើងឲ្យដល់អ្នកហើយ វត្ថុនោះក៏ជាវត្ថុដែលឲ្យហើយ តែអ្នកចូរ ចេញចាកដែនរបស់យើង" ហើយទ្រង់និរទេសនាយកាឡះនោះឲ្យចេញចាកដែន ត្រាស់ឲ្យហៅជុណ្ហអាមាត្យមកសួរថា បានឮថា "អ្នកគិតយ៉ាងនេះពិតមែនឬ" កាលជុណ្ហអាមាត្យក្រាបទូលថា "ពិតមែន" ក៏ត្រាស់ថា "ល្អហើយ យើងជ្រះ ថ្លានឹងអ្នក អ្នកចូរទទួលរាជសម្បត្តិរបស់យើង ហើយឲ្យទាន ៧ ថ្ងៃ តាមទំនង ដែលយើងឲ្យហើយនោះឯង" ទ្រង់ប្រគល់រាជសម្បត្តិដល់ជុណ្ហអាមាត្យ អស់ ៧ ថ្ងៃ ហើយក៏ក្រាបទូលដល់ព្រះសាស្ដាថា "បពិត្រព្រះអង្គដ៏ចម្រើន សូម ព្រះអង្គទតការធ្វើរបស់ជនពាល គេបានឲ្យការប្រហារក្នុងទានដែលខ្ញុំព្រះអង្គ ថ្វាយហើយយ៉ាងនេះ ។

មនុស្សកំណាញ់ទៅកាន់ទេវលោកមិនបាន

ព្រះសាស្ដាត្រាស់ថា "ពិតហើយមហាបពិត្រ ឈ្មោះថា ពួកជនពាល

មិនត្រេកអរក្នុងទានរបស់អ្នកដទៃ ជាអ្នកមានទុគ្គតិជាទីទៅខាងមុខ ចំណែកពួកអ្នកប្រាជ្ញ អនុមោទនាទានរបស់ពួកជនដទៃ ទើបជាអ្នកមានសួគ៌ជាទីទៅខាងមុខដោយពិត ហើយត្រាស់ព្រះគាថានេះថា ៖

១០ ន វេ កទរិយា ទេវលោកំ វជន្តិ
ពាលា ហវេ នប្បសំសន្តិ ទានំ
ធីរោ ច ទានំ អនុមោទមានោ
តេនេវ សោ ហោតិ សុខី បរត្ថ ។

បុគ្គលកំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ
ជនពាលទាំងឡាយ មិនសរសើរទានឡើយ ចំណែកអ្នក
ប្រាជ្ញតែងអនុមោទនាទាន ព្រោះហេតុនោះ លោកតែងបាន
សេចក្តីសុខក្នុងលោកខាងមុខ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **កទរិយា** (ពួកបុគ្គលកំណាញ់) គឺ អ្នកមានសេចក្តីកំណាញ់ស្វិតស្វាញ ។ អ្នកមិនដឹងប្រយោជន៍លោកនេះ និងលោកខាងមុខ ឈ្មោះថា ពួកបុគ្គលពាល ។ បណ្ឌិតឈ្មោះថា **ធីរោ** (ធីរជន) ។ បទថា **សុខី បរត្ថ** (ជាអ្នកមានសេចក្តីសុខក្នុងលោកខាងមុខ) សេចក្តីថា ធីរជននោះ កាលសោយទិព្វសម្បត្តិ ឈ្មោះថា ជាអ្នកមានសេចក្តីសុខក្នុងលោកខាងមុខ ព្រោះបុណ្យដែលសម្រេចពីការអនុមោទនាទាននោះនុ៎ះឯង ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជុណ្ហអាមាត្យក៏តាំងនៅក្នុងសោតាបត្តិ-ផល ។ ព្រះធម៌ទេសនា មានប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នា ដូច្នេះ ។ ជុណ្ហអាមាត្យ កាលជាព្រះសោតាបន្នហើយ បានថ្វាយទានដោយទំនងដែលព្រះរាជាថ្វាយហើយ អស់ ៧ ថ្ងៃ ដូចគ្នា ដូច្នោះឯង ។

ចប់ រឿងអសទិសទាន

# ១១. រឿងនាយកាលសេដ្ឋីបុត្រ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងជេតពន ទ្រង់ប្រារព្ធបុត្ររបស់អនាថបិណ្ឌិកសេដ្ឋីឈ្មោះ កាលៈ ត្រាស់ព្រះធម្មទេសនានេះថា* ***បឋព្យា ឯករជ្ជេន (ភាពជាធំជាឯកឯករាជ្យលើផែនដី)*** *ជាដើម ។*

បិតាជួលបុត្រឱ្យស្តាប់ធម៌

*បានឮថា នាយកាលៈនោះជាបុត្រ របស់សេដ្ឋីអ្នកដល់ព្រមហើយដោយសទ្ធា ដូច្នោះ ក៏មិនប្រាថ្នានឹងទៅកាន់សម្នាក់នៃព្រះសាស្តាឡើយ មិនប្រាថ្នានឹងស្តាប់ធម៌ មិនប្រាថ្នានឹងធ្វើការខ្វល់ខ្វាយដល់សង្ឃ សូម្បីត្រូវបិតានិយាយថា "អ្នកកុំធ្វើយ៉ាងនេះ កូន" ក៏មិនស្តាប់ពាក្យរបស់គាត់ ។*

*លំដាប់នោះ បិតារបស់គេគិតថា "កាលៈនេះ កាលមានទិដ្ឋិបែបនេះ នឹងជាអ្នកមានអវិចីជាទីទៅខាងមុខ ក៏កាលយើងនៅរស់ ឃើញបុត្ររបស់យើងទៅកាន់នរក ទុំះមិនសមគួរដល់យើងឡើយ ក៏ឈ្មោះថា សត្វអ្នកមិនសម្ងឹងព្រោះការឱ្យទ្រព្យ មិនមានក្នុងលោកនេះឡើយ យើងនឹងទម្លាយទិដ្ឋិបុត្រនោះដោយទ្រព្យ ។*

*លំដាប់នោះ សេដ្ឋីបាននិយាយនឹងនាយកាលៈថា "កូន ចូរជាអ្នករក្សាឧបោសថ ទៅវិហារស្តាប់ធម៌ ហើយមកចុះ យើងនឹងឱ្យកហាបណៈ ១០០ ដល់អ្នក" ។*

កាលៈ. នឹងឲ្យឬ ពុក ?

សេដ្ឋី. នឹងឲ្យ កូន ។

កាលកាលៈនោះទទួលប្ដេជ្ញា ៣ ដងហើយ ក៏ជាអ្នករក្សាឧបោសថបានទៅកាន់វិហារ តែកិច្ចដោយការស្ដាប់ធម៌របស់គេមិនមាន គេដេកក្នុងទីតាមសេចក្ដីសប្បាយ បានទៅផ្ទះវិញអំពីព្រឹក ។ លំដាប់នោះ បិតារបស់គេនិយាយថា "បុត្ររបស់យើងបានជាអ្នករក្សាឧបោសថ អ្នកទាំងឡាយ ចូរនាំយកបាយជាដើមមកឲ្យគេដោយរហ័ស ហើយក៏ប្រើមនុស្សឲ្យឲ្យ" ។ នាយកាលៈនោះហាមអាហារ ដោយនិយាយថា "យើងមិនទាន់បានទទួលកហាបណៈ នឹងមិនបរិភោគ" ។ លំដាប់នោះ បិតារបស់គេ កាលអត់ធន់ការរំអុកមិនបាន ក៏ឲ្យបញ្ជូនកហាបណៈ ។ នាយកាលៈនោះ បន្ទាប់អំពីទទួលកហាបណៈទុកក្នុងដៃហើយ ទើបបរិភោគអាហារ ។

តមក ក្នុងថ្ងៃមួយ សេដ្ឋីបញ្ជូនគេទៅ ដោយនិយាយថា "កូន យើងនឹងឲ្យកហាបណៈ ១.០០០ ដល់ឯង ឯងឈរខាងមុខព្រះភ័ក្ត្ររបស់ព្រះសាស្ដារៀនយកបទនៃធម៌ ឲ្យបានមួយបទ ហើយសឹមមក" ។ នាយកាលៈទៅវិហារហើយឈរចំព្រះភ័ក្ត្រព្រះសាស្ដា បានជាអ្នកប្រាថ្នារៀនយកបទនៃធម៌ ១ បទប៉ុណ្ណោះ ហើយចៀសចេញទៅ ។ លំដាប់នោះ ព្រះសាស្ដាទ្រង់បានធ្វើអាការគឺ ការចាំមិនបានដល់គេ ។ នាយកាលៈកំណត់បទនោះមិនបាន ទើបឈរស្ដាប់ហើយស្ដាប់ទៀត ដោយគិតថា "យើងនឹងរៀនបទធម៌តទៅ" ។ ន័យថា

ជនទាំងឡាយ កាលតាំងចិត្តស្តាប់ ព្រោះគិតថា "យើងនឹងរៀនឲ្យបាន ឈ្មោះថា ស្តាប់ដោយគោរព" ។

ក៏ធម្មតា កាលជនទាំងឡាយស្តាប់យ៉ាងនេះ ធម៌រមែង ឲ្យសោតាបត្តិមគ្គជាដើម ។ សូម្បីនាយកាលៈនោះ ស្តាប់ធម៌ដោយគិតថា នឹងរៀនឲ្យបាន ។ សូម្បីព្រះសាស្តា ក៏ទ្រង់ធ្វើអាការ គឺ ការចាំមិនបានដល់គេ ។ នាយកាលៈឈរស្តាប់នោះឯង ដោយគិតថា "នឹងរៀនតទៅ" ហើយក៏បានតាំងនៅក្នុងសោតាបត្តិផល ។

លុះព្រឹកឡើង នាយកាលៈនោះ ទៅកាន់ក្រុងសាវត្ថីព្រមទាំងភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន មហាសេដ្ឋីគ្រាន់តែឃើញកូន ក៏គិតថា "ថ្ងៃនេះ យើងពេញចិត្តក្នុងអាការរបស់បុត្រ" ។ ឯនាយកាលៈនោះ ក៏មានបរិវិតក្កៈយ៉ាងនេះថា "ឱហ្ន៎! ថ្ងៃនេះ បិតារបស់យើង មិនគប្បីឲ្យកហាបណៈក្នុងទីជិតព្រះសាស្តា គប្បីបិទបាំងសេចក្តីដែលយើងជាអ្នករក្សាឧបោសថ ព្រោះហេតុនៃកហាបណៈ" ។ តែព្រះសាស្តាទ្រង់បានជ្រាបដល់នាយកាលៈនោះ ដែលជាអ្នករក្សាឧបោសថ ព្រោះហេតុនៃកហាបណៈហើយ តាំងអំពីថ្ងៃម្សិលមិញ មហាសេដ្ឋីឲ្យគេថ្វាយបបរដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ ក៏ប្រាប់ឲ្យគេឲ្យដល់បុត្រ ។ នាយកាលៈនោះ ជាអ្នកអង្គុយស្ងៀម ដូចសត្វស្វាបសំកាំងស្វាបហើរ ស្រស់ស្រូបបបរ ទំពារបស់គួរទំពា និងបរិភោគភត្ត ។

ក្នុងវេលាស្រេចភត្តកិច្ចរបស់ព្រះសាស្តា មហាសេដ្ឋីឲ្យគេដាក់បង្វេច

កហាបណៈ ១.០០០ ទុកខាងមុខ ហើយនិយាយថា "កូន បិតាថានឹងឲ្យកហា-បណៈ ១.០០០ ដល់កូន ឲ្យកូនសមាទានឧបោសថ បញ្ជូនទៅវិហារ នេះជាកហាបណៈ ១.០០០ របស់កូន" ។ នាយកាលៈនោះ ឃើញកហាបណៈដែលបិតាឲ្យចំពោះព្រះភក្ត្រព្រះសាស្ដា ខ្មាសអៀន ក៏និយាយថា "ខ្ញុំមិនត្រូវការដោយកហាបណៈទាំងឡាយទេ" សូម្បីត្រូវបិតានិយាយថា "យកចុះកូន" ក៏មិនទទួលឡើយ ។

សោតាបត្តិផលប្រសើរជាងសម្បត្តិគ្រប់យ៉ាង

លំដាប់នោះ បិតារបស់គេ ថ្វាយបង្គំព្រះសាស្ដាហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះខ្ញុំព្រះអង្គពេញចិត្តក្នុងអាការរបស់បុត្រ" កាលព្រះសាស្ដាត្រាស់សួរថា "ដូចម្ដេចមហាសេដ្ឋី" ទើបក្រាបទូលថា "ក្នុងថ្ងៃមុនបុត្ររបស់ខ្ញុំព្រះអង្គនេះ គឺខ្ញុំព្រះអង្គនិយាយថា យើងនឹងឲ្យកហាបណៈ ១០០ ដល់គេ ហើយប្រើទៅវិហារ លុះព្រឹកឡើង មិនទាន់បានទទួលកហាបណៈ ក៏មិនបរិភោគ តែថ្ងៃនេះ គេមិនប្រាថ្នាកហាបណៈ ដែលខ្ញុំព្រះអង្គឲ្យ" ។ ព្រះសាស្ដាត្រាស់ថា "ពិតហើយ មហាសេដ្ឋី ថ្ងៃនេះសោតាបត្តិផលនោះឯង នៃបុត្ររបស់អ្នក ប្រសើរជាងសម្បត្តិស្ដេចចក្រពត្តិ ប្រសើរជាងសម្បត្តិទេវលោកនិងព្រហ្មលោក ទើបត្រាស់ព្រះគាថានេះថា ៖

១១. បឋព្យា ឯករជ្ជេន  សគ្គស្ស គមនេន វា
សព្វលោកាធិបច្ចេន  សោតាបត្តិផលំ វរំ ។

សោតាបត្តិផល ជាគុណជាតដ៏ប្រសើរជាង ភាពនៃឯករាជ្យ
លើផែនដីផង ជាងដំណើរទៅកាន់ឋានសួគ៌ផង ជាងភាពជា
ធំក្នុងលោកទាំងមូលផង ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **បឋព្យា ឯករជ្ជេន** (ប្រសើរជាងឯករាជ្យក្នុងផែនដី) គឺ ធំជាងភាពជាស្ដេចចក្រពត្តិ ។ បទថា **សគ្គស្ស គមនេន វា** (ប្រសើរជាងការទៅកាន់ស្ថានសួគ៌) សេចក្ដីថា ជាងការដល់សួគ៌ ២៦ ជាន់ ។ បទថា **សព្វលោកាធិបច្ចេន** (ប្រសើរជាងភាពជាធំលើលោកទាំងពួង) សេចក្ដីថា ប្រសើរជាងភាពជាធំក្នុងលោក មានប្រមាណប៉ុណ្ណោះៗ គឺ ក្នុងលោកទាំងពួង ព្រមទាំងនាគ គ្រុឌ និងវេមានិកប្រេត ។ បាទព្រះគាថាថា **សោតា-បត្តិផលំ វរំ** (សោតបត្តិផលប្រសើរជាង) សេចក្ដីថា ព្រោះព្រះរាជា សូម្បីសោយរាជសម្បត្តិក្នុងទីមានប្រមាណប៉ុណ្ណោះ ក៏ជាអ្នកមិនផុតចាកនរកជាដើមបានឡើយ ចំណែកព្រះសោតាបន្ន ជាអ្នកមានទ្វារអបាយបិទហើយ សូម្បីមានកំឡាំងខ្សោយ ក៏មិនកើតក្នុងភពទី ៨ ដូច្នោះ សោតាបត្តិផលនោះឯង ទើបប្រសើរ គឺ ខ្ពង់ខ្ពស់ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនទាក់សម្រេចអរិយផលទាំង

ឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងនាយកាលៈបុត្រអនាថបិណ្ឌិកសេដ្ឋី

# ចប់លោកវគ្គវណ្ណនា វគ្គទី ១៣

ក្នុងវគ្គនេះរួមមាន ១១ រឿង


១.រឿងភិក្ខុកំលោះ
២. រឿងព្រះចាទសុទ្ទោទនៈ
៣.រឿងភិក្ខុចម្រើនវិបស្សនា
៤. រឿងអភយរាជកុមារ
៥.រឿងព្រះសម្មជ្ជនត្ថេរ
៦.រឿងព្រះអង្គុលិមាលត្ថេរ
៧.រឿងធីតាជាងតម្បាញ
៨.រឿងភិក្ខុ ៣០ រូប
៩.រឿងនាងចិញ្ចមាណវិកា
១០.រឿងអសទិសទាន
១១.រឿងនាយកាលៈបុត្តអនាថបិណ្ឌិកសេដ្ឋី

# ពុទ្ធវគ្គ ទី ១៤

"ពោលអំពីរឿងព្រះពុទ្ធ"

## ១. រឿងធីតារបស់មារ

**[២៤]** *ព្រះសាស្តា កាលប្រថាប់នៅត្រង់ពោធិមណ្ឌលស្ថាន ទ្រង់ប្រារព្ធធីតារបស់មារ ត្រាស់ព្រះធម្មទេសនានេះថា* **យស្ស ជិតំ** *(ដែលព្រះ-សម្មាសម្ពុទ្ធព្រះអង្គណា ឈ្នះហើយ)* ដូច្នេះជាដើម ។

ព្រាហ្មណ៍រកស្វាមីឱ្យកូនក្រមុំ

ព្រះសាស្តា ទ្រង់ញ៉ាំងធម្មទេសនា ឲ្យតាំងឡើងនាក្រុងសាវត្ថីហើយ ត្រាស់ចំពោះព្រាហ្មណ៍ ឈ្មោះមាគន្ទិយៈ ក្នុងដែនកុរុទៀត ។

បានឮមកថា ក្នុងដែនកុរុ ធីតារបស់មាគន្ទិយព្រាហ្មណ៍ មានឈ្មោះថា មាគន្ទិយាដែរ ជាស្ត្រីមានរូបឆោមស្រស់ស្អាត ។ ព្រាហ្មណមហាសាលជាច្រើន និងពួកខត្តិយមហាសាលប្រាថ្នាចង់បាននាងមាគន្ទិយានោះ ទើបបញ្ជូនដំណឹងទៅប្រាប់មាគន្ទិយព្រាហ្មណថា "ចូរឲ្យធីតាដល់យើងទាំងឡាយចុះ" ។ សូម្បីមាគន្ទិយព្រាហ្មណ៍ ក៏បានហាមឃាត់ព្រាហ្មណ៍ និងខត្តិយមហាសាលទាំងនោះ ដោយពាក្យថា "ពួកលោកមិនសមនឹងធីតារបស់ខ្ញុំទេ" ។ តមក ថ្ងៃមួយ ក្នុងវេលាទៀបភ្លឺ ព្រះសាស្តាទ្រង់ប្រមើលមើលនូវសត្វលោក ទ្រង់ឃើញ

មាគន្ទិយព្រាហ្មណ៍ចូលក្នុងសំណាញ់ គឺ ព្រះញាណរបស់ព្រះអង្គ ទើបទ្រង់ពិចារណាមើលថា "នឹងមានហេតុអ្វីហ្ន៎" ទ្រង់បានឃើញនូវធម៌ដែលជាឧបនិស្ស័យនៃមគ្គ និងផលទាំង ៣ របស់ព្រាហ្មណ៍ និងនាងព្រាហ្មណី ។ ចំណែកព្រាហ្មណ៍តែងតែបម្រើភ្លើងនៅខាងក្រៅស្រុកជានិច្ច ។ ព្រះសាស្តាទ្រង់បានប្រដាប់បាត្រ និងចីវរ ស្តេចយាងទៅកាន់ទីនោះតាំងអំពីព្រលឹម ។ ព្រាហ្មណ៍ពិនិត្យមើលរូបសិរីនៃព្រះសាស្តាបណ្តើរ គិតបណ្តើរថា "បុរសក្នុងលោកនេះដែលដូចបុរសនេះ មិនមាន បុរសនេះទើបសមនឹងធីតារបស់យើង យើងនឹងលើកធីតារបស់យើងឲ្យបុរសនេះ" លុះគិតដូច្នោះហើយ ក៏ក្រាបទូលព្រះសាស្តាថា "បពិត្រសមណៈ ខ្ញុំមានធីតាម្នាក់ ខ្ញុំនៅមិនទាន់ឃើញបុរសណាដែលសមនឹងនាង ទើបខ្ញុំមិនបានឲ្យនាងដល់នរណាៗ ចំណែកលោក ទើបសមនឹងនាង ខ្ញុំនឹងប្រគល់ធីតាឲ្យលោក ធ្វើជាស្ត្រីបម្រើជិតជើង (ប្រពន្ធ) លោកចូររង់ចាំនៅទីនេះសិន ចាំខ្ញុំនាំធីតាមក" ។ ព្រះសាស្តា ស្តាប់នូវពាក្យរបស់គេហើយ ទ្រង់មិនត្រេកអរ ទាំងទ្រង់មិនហាម ។

ឯព្រាហ្មណ៍ទៅដល់ផ្ទះហើយ ប្រាប់នាងព្រាហ្មណីថា "នាងដ៏ចម្រើន ថ្ងៃនេះ ខ្ញុំបានឃើញបុរសដែលសមនឹងធីតារបស់យើងហើយ ពួកយើងនឹងឲ្យធីតារបស់យើងដល់គេ លុះពោលដូច្នោះហើយ ក៏ឲ្យធីតាតាក់តែងកាយហើយនាំទៅកាន់ទីនោះ មួយអន្លើដោយនាងព្រាហ្មណី ។ សូម្បីមហាជន ក៏ភ្ញាក់ផ្អើល នាំគ្នាចេញទៅមើលដែរ ។ ព្រះសាស្តា ទ្រង់មិនប្រថាប់នៅក្នុងទី

ដែលព្រាហ្មណ៍ប្រាប់នោះទេ ទ្រង់សម្ដែងចេតិយ គឺ ស្នាមព្រះបាទទុកត្រង់ទី នោះ ហើយទ្រង់ប្រថាប់ក្នុងទីដទៃ ។ បានឮថា ចេតិយ គឺ ស្នាមព្រះបាទរបស់ព្រះពុទ្ធទាំងឡាយ រមែងប្រាកដក្នុងទីដែលព្រះអង្គទ្រង់អធិដ្ឋានថា "បុគ្គលឯណោះ ចូរឃើញចេតិយ គឺ ស្នាមជើងនេះ" ហើយទ្រង់ជាន់ទុកប៉ុណ្ណោះ ។ ឈ្មោះថា អ្នកដែលឃើញចេតិយ គឺ ស្នាមព្រះបាទនោះក្នុងទីដ៏សេសមិនមានឡើយ ។ ព្រាហ្មណ៍ ត្រូវនាងព្រាហ្មណីដែលទៅជាមួយខ្លួនសួរថា "បពិត្រព្រហ្មណ៍ បុរសនោះនៅទីណា" ក៏ប្រាប់ថា "ខ្ញុំបានប្រាប់គេឲ្យឈររង់ចាំនៅទីនេះ" និយាយបណ្ដើរ រកមើលបណ្ដើរ ឃើញស្នាមព្រះបាទហើយ ក៏បង្ហាញថា "ម្នាលនាងដ៏ចម្រើន នេះស្នាមជើងរបស់គេ" ។

## ស្នាមជើងជាគ្រឿងសម្ដែងលក្ខណៈរបស់មនុស្ស

នាងព្រាហ្មណីនោះពោលថា "បពិត្រព្រាហ្មណ៍ នេះមិនមែនជាស្នាមជើងរបស់បុគ្គលអ្នកបរិភោគកាមទេ" ដែលព្រាហ្មណីពោលដូច្នោះ ព្រោះនាងជាស្ត្រីឆ្លាតក្នុងមន្តទាយលក្ខណៈ កាលព្រាហ្មណ៍ពោលថា "នែនាងដ៏ចម្រើន នាងឃើញក្រពើក្នុងពាងទឹកហើយ សមណៈនោះ យើងប្រាប់ហើយថា "យើងនឹងឲ្យធីតាដល់គេ" សូម្បីគេក៏ទទួលពាក្យរបស់យើងហើយដែរ ក៏ពោលថា "ព្រាហ្មណ៍ លោកប្រាប់យ៉ាងនោះក៏ពិត ប៉ុន្តែស្នាមជើងនេះជាស្នាមជើងរបស់អ្នកអស់កិលេសតែម្យ៉ាង" ដូច្នេះហើយ បានពោលគាថានេះថា ៖

*ស្នាមជើងរបស់បុគ្គលរាគចរិត ផតកណ្ដាល របស់បុគ្គល*

*ទោសចរិត រមែងមានស្នាមជើងផូនមុខ ស្នាមជើនរបស់*

*បុគ្គលមោហចរិត មានស្នាមកែងលិចចុះ ( ផូនកែង ) ។*

*បុគ្គលអ្នកមានកិលេសជាគ្រឿងប្រក់ របើកហើយ មាន*

*ស្នាមជើងយ៉ាងនេះឯង ។*

*គ្រានោះ ព្រាហ្មណ៍ពោលទៅកាន់នាងព្រាហ្មណីថា "នាងដ៏ចម្រើន នាងកុំនិយាយឡើយ នាងចូរស្ងៀមចុះ" ហើយដើរទៅរកព្រះសាស្តា កាលឃើញព្រះសាស្តាហើយ ក៏បង្ហាញនាងព្រាហ្មណីនោះថា "នេះ គឺ បុរសនោះ" ហើយចូលទៅជិតព្រះសាស្តា ក្រាបទូលថា "បពិត្រសមណៈ យើងនឹងឲ្យធីតាដល់លោក" ។ ព្រះសាស្តាទ្រង់មិនត្រាស់ថា "តថាគតមិនត្រូវការធីតារបស់អ្នកទេ" ត្រឡប់ជាត្រាស់ដូច្នេះថា "ម្នាលព្រាហ្មណ៍ តថាគតនឹងប្រាប់នូវហេតុមួយដល់អ្នក អ្នកនឹងស្តាប់ឬ" កាលព្រាហ្មណ៍ទូលថា "សមណៈដ៏ចម្រើន សូមលោកពោលមកចុះ ខ្ញុំនឹងស្តាប់" ទើបទ្រង់នាំអតីតរឿង ផ្តើមអំពីកិរិយាចេញមហាភិនេស្រ្កមណ៍មកសម្តែង ។*

មារតាមចាប់កំហុសព្រះមហាសត្វតែមិនជួប

*កថាដោយសង្ខេបក្នុងរឿងនោះ មានដូចតទៅនេះ ៖*

*ព្រះមហាសត្វ ទ្រង់លះបង់សិរីរាជសម្បត្តិ ទ្រង់ឡើងកាន់សេះកណ្ឋកៈ (សេះពណ៌ស) មាននាយឆន្នៈជាសំឡាញ់ ស្តេចចេញសាងមហាភិនេស្រ្កមណ៍ កាលមារឈរក្បែរទ្វារព្រះនគរ ពោលថា "នែសិទ្ធត្ថៈ អ្នកចូរត្រឡប់វិញចុះ*

ចក្ករតន៍នឹងកើតប្រាកដដល់អ្នកក្នុងថ្ងៃទី ៧ អំពីថ្ងៃនេះដល់លោក ក៏ត្រាស់ថា "ម្នាលមារ សូម្បីយើងក៏ដឹងចក្ករតន៍នោះដែរ ប៉ុន្តែយើងមិនត្រូវការចក្ករតន៍នោះឡើយ" ។

មារ. បើដូច្នោះ អ្នកចេញទៅដើម្បីអ្វី ?

មហាសត្វ. ដើម្បីប្រយោជន៍ដល់សព្វញ្ញុតញ្ញាណ ។

មារ. បើដូច្នោះ ចាប់តាំងពីថ្ងៃនេះទៅ បណ្តាវិតក្កៈទាំងឡាយ មានកាមវិតក្កៈជាដើម សូម្បីត្រឹមតែ ១ យើងនឹងដឹងនូវកិច្ចដែលគួរធ្វើដល់អ្នក ។ តាំងពីថ្ងៃនោះមក មារអ្នកស្វែងរកនូវចន្លោះ គឺ ចាំចាប់កំហុសព្រះបរមពោធិសត្វ បានជាប់តាមព្រះមហាសត្វអស់ ៧ ឆ្នាំ ។ ចំណែកព្រះសាស្តា ទ្រង់ប្រព្រឹត្តទុក្ករកិរិយាអស់ ៦ ឆ្នាំ ទ្រង់អាស្រ័យនូវកិច្ចការរបស់បុរសចំពោះព្រះអង្គឯង ទ្រង់ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណ សោយវិមុត្តិសុខ (សុខដែលកើតពីការរួចផុតចាកកិលេស) ទៀបគល់ពោធិព្រឹក្ស ក្នុងសប្តាហ៍ទី ៥ ទ្រង់ប្រថាប់នៅទៀបគល់នៃដើមអជបាលនិគ្រោធ ។

ក្នុងសម័យនោះ មារដល់នូវសេចក្តីទោមនស្សហើយ អង្គុយក្បែរផ្លូវធំ រំពឹងថា "យើងជាប់តាមព្រះសិទ្ធត្ថៈអស់កាលមានប្រមាណប៉ុណ្ណេះ សូម្បីស្វែងរកនូវចន្លោះ ក៏មិនបានឃើញនូវសេចក្តីភ្លាំងភ្លាត់អ្វីៗ របស់សិទ្ធត្ថៈនេះឥឡូវនេះ លោកកន្លងនូវវិស័យរបស់យើងហើយ" ។ គ្រានោះ ធីតាទាំង ៣ នាក់របស់មារនោះ គឺ នាងតណ្ហា នាងអរតី នាងរាគា ត្រិះរិះថា "បិតារបស់

ឃើញមិនប្រាកដ ឥឡូវនេះ លោកទៅទីណាហ្ន៎" ដើររក ក៏ឃើញបិតារបស់ខ្លួនអង្គុយដោយប្រការដូច្នោះ ក៏ចូលទៅជិត ហើយសួរថា "បពិត្រព្រះបិតា ព្រោះហេតុអ្វី ទើបបិតាកើតទុក្ខ លំបាកចិត្ត" មារនោះ ក៏ប្រាប់សេចក្ដីនោះដល់ធីតាទាំងនោះ ។ គ្រានោះ ធីតាទាំងនោះ ក៏ប្រាប់មារដែលជាបិតាខ្លួនថា "បិតា សូមបិតាកុំព្រួយ ពួកខ្ញុំនឹងធ្វើព្រះសិទ្ធត្ថៈនោះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន ហើយនាំមក" ។

មារ. កូនទាំងឡាយ នរណាៗ ក៏មិនអាចធ្វើគេឲ្យនៅក្នុងអំណាចបានដែរ ។

ធីតា. បពិត្របិតា ពួកខ្ញុំជាស្រ្តី ពួកខ្ញុំនឹងចងព្រះសិទ្ធត្ថៈនោះ ដោយចំណង មានចំណង គឺ រាគៈជាដើម ហើយនាំមកក្នុងកាលឥឡូវនេះឯង សូមបិតាកុំព្រួយ ហើយក៏នាំគ្នាចូលទៅរកព្រះសាស្ដា ក្រាបទូលថា "បពិត្រព្រះសមណៈ ពួកនាងខ្ញុំនឹងបម្រើព្រះបាទរបស់ព្រះអង្គ" ។

## ធីតារបស់មារប្រលោមព្រះសាស្ដា

ព្រះសាស្ដា ទ្រង់មិនបានធ្វើទុកក្នុងព្រះហឫទ័យចំពោះពាក្យរបស់ធីតាមារទាំងនោះឡើយ ទ្រង់មិនបើកនូវព្រះនេត្រទាំងពីរទតមើលឡើយ ។ ពួកធីតារបស់មារគិតគ្នាទៀតថា "បំណងពួកបុរសផ្សេងៗ គ្នា ពួកខ្លះស្រឡាញ់ស្រ្តីជំទង់ទាំងឡាយ ពួកខ្លះស្រឡាញ់ពួកស្រ្តីដែលតាំងនៅក្នុងបឋមវ័យ ពួកខ្លះ ស្រឡាញ់ពួកស្រ្តីដែលតាំងនៅក្នុងមជ្ឈិមវ័យ ពួកខ្លះ ស្រឡាញ់ពួកស្រ្តី

ដែលតាំងនៅក្នុងបច្ឆិមវ័យ ពួកយើង នឹងប្រលោមលោកដោយប្រការផ្សេងៗ ម្នាក់ៗ និម្មិតអត្តភាពបាន ១០០ ៗ ដោយអំណាចនៃភេទ មានភេទជាកុមារិកាជាដើម ជាកុមារិកាខ្លះ ជាស្ត្រីមិនទាន់សម្រាលខ្លះ សម្រាលបានម្តងខ្លះ សម្រាលបានពីរដងខ្លះ ជាស្ត្រីកណ្តាលមនុស្សខ្លះ និងជាស្ត្រីចាស់ខ្លះ ចូលទៅជិតព្រះមានព្រះភាគជាម្ចាស់ ហើយក្រាបទូលថា "បពិត្រព្រះសមណៈ ពួកនាងខ្ញុំនឹងបម្រើព្រះបាទទាំងពីររបស់ព្រះអង្គ" ដូច្នេះអស់វារៈ ៦ ដង ។ ព្រះមានព្រះ-ភាគជាម្ចាស់ ទ្រង់មិនបានធ្វើទុកក្នុងព្រះទ័យ ចំពោះពាក្យរបស់មារធីតាទាំងនោះឡើយ ទ្រង់មានព្រះទ័យយាងចុះស៊ប់ក្នុងនិព្វានធម៌ ដែលជាគ្រឿងអស់ទៅនៃកិលេស ដែលមិនមានធម៌ដទៃក្រៃលែងជាង ដោយប្រការដូច្នេះ ។ គ្រានោះ ព្រះសាស្តាត្រាស់នឹងធីតាមារ ដែលជាប់តាមមកដោយហេតុត្រឹមប៉ុណ្ណេះថា "ពួកនាងចូរចេញទៅ ពួកនាងឃើញអ្វី ទើបព្យាយាមយ៉ាងនេះ ការធ្វើកម្មបែបនេះក្នុងទីចំពោះមុខបុគ្គល អ្នកមានរាគៈមិនទាន់ទៅប្រាស ទើបគួរ ឯតថាគតលះបង់កិលេសទាំងឡាយ មានរាគៈជាដើមបានហើយ ពួកនាងនឹងនាំតថាគតទៅក្នុងអំណាចរបស់ខ្លួន បានដោយហេតុដូចម្តេច" លុះត្រាស់ដូច្នេះហើយ ទ្រង់ក៏ភាសិតព្រះគាថាទាំងនេះថា ៖

១. យស្ស ជិតំ នាវជីយតិ
ជិតមស្ស នោយាតិ កោចិ លោកេ
តំ ពុទ្ធំ អនន្តគោចរំ

អបទំ កេន បទេន នេស្សថ ។

យស្ស ជាលិនី វិសត្តិកា

តណ្ហា នត្ថិ កុហិញ្ចិ នេតវេ

តំ ពុទ្ធំ អនន្តគោចរំ

អបទំ កេន បទេន នេស្សថ ។

ជ័យជំនះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេស ណាមួយក្នុងលោក រមែងមិនជាប់តាមជ័យជំនះរបស់ព្រះពុទ្ធ អង្គនោះ នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែល មានគោចររក ទីបំផុតគ្មាន មិនមានកិលេស ដូចស្នាមជើង ដោយកិលេសដូចស្នាមជើង ម្ដេចកើត ។ តណ្ហា ដែលមាន បណ្ដាញផ្សាយទៅ ក្នុងអារម្មណ៍ផ្សេងៗ មិនមានដល់ព្រះពុទ្ធ អង្គណា ដើម្បីនឹងនាំទៅក្នុងភពណាមួយ នាងទាំងឡាយនឹង ប្រលោម ព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើង ម្ដេចកើត ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា យស្ស ជិតំ នាវជិយតិ (កិលេសជាត មានរាគៈជាដើម ដែលព្រះសម្មាសម្ពុទ្ធអង្គណាឈ្នះហើយ ព្រះអង្គមិនត្រឡប់

ចាញ់វិញឡើយ) សេចក្ដីថា កិលេសជាត មានរាគៈជាដើម ដែលព្រះសម្មា-សម្ពុទ្ធអង្គណាទ្រង់ឈ្នះហើយ ដោយមគ្គនោះៗ ព្រះអង្គមិនត្រឡប់ចាញ់វិញ ព្រោះការមិនត្រឡប់កើតទៀតឡើយ គឺថា ឈ្នះហើយដោយល្អ ។

បទថា **នោយាតិ** កាត់បទជា **ន ឧយ្យាតិ** ប្រែថា រមែងមិនជាប់តាម ។ អធិប្បាយថា បណ្ដាកិលេសមានរាគៈជាដើម សូម្បីកិលេសណាទីមួយ ក្នុងលោកត្រឡប់កើតទៀត មិនមាន គឺ មិនជាប់តាមកិលេសជាត ដែលព្រះស-ម្មាសម្ពុទ្ធទ្រង់ឈ្នះហើយ ។

បទថា **អនន្តគោចរំ អ្នកមានអារម្មណ៍មិនមានទីបំផុត)** សេចក្ដីថា អ្នកមានអារម្មណ៍មិនមានទីបំផុត ដោយអំណាចនៃព្រះសព្វញ្ញុតញ្ញាណ ដែលមានអារម្មណ៍រកទីបំផុតគ្មាន ។

បទថា **កេន បទេន (ដោយស្នាមអ្វី)** ជាដើម សេចក្ដីថា បណ្ដាស្នាមទាំងឡាយ មានស្នាម គឺ រាគៈជាដើម សូម្បីតែ ១ មិនមានដល់ព្រះសម្មា-សម្ពុទ្ធអង្គណា ពួកនាងនឹងនាំព្រះសម្មាសម្ពុទ្ធអង្គនោះទៅ ដោយស្នាមអ្វី គឺ សូម្បីស្នាមត្រឹមតែ ១ ក៏មិនមានដល់ព្រះពុទ្ធអង្គនោះ ពួកនាងនឹងនាំព្រះពុទ្ធអង្គនោះ អ្នកមិនមានស្នាមទៅ ដោយស្នាមអ្វី ? ។

វិនិច្ឆ័យក្នុងគាថាទី ២ តណ្ហានោះឯង ឈ្មោះថា **ជាលិនី** ព្រោះមានបទវិគ្រោះថា ជាចំណង៉ខ្វះ មានប្រក្រតីធ្វើនូវចំណង់ខ្វះ ប្រៀបដូចជាចំណង់ខ្វះ ព្រោះអត្ថថា រួបរឹតចងទុក ឈ្មោះថា **វិសត្តិកា** ព្រោះជាធម្មជាតិផ្សាយ

ទៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ព្រោះប្រៀបដូចជាអាហារដែលមានពិស ព្រោះប្រៀបដូចជាផ្កាដែលមានពិស ព្រោះប្រៀបដូចជាផ្លែដែលមានពិស ព្រោះប្រៀបដូចជាគ្រឿងបរិភោគដែលមានពិស អធិប្បាយថា តណ្ហានោះមិនមានដល់ព្រះពុទ្ធជាម្ចាស់អង្គណា ដែលនាំទៅកាន់ភពណាៗ ពួកនាងនឹងនាំព្រះពុទ្ធអង្គនោះ ដែលមិនមានស្នាម ទៅដោយស្នាមអ្វី ? ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ធម្មាភិសម័យក៏មានដល់ទេវតាជាច្រើន សូម្បីធីតាមារ ក៏អន្តរធានទៅក្នុងទីនោះឯង ។

ព្រះសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ត្រាស់ថា “ម្នាលមាគន្ទិយព្រាហ្មណ៍ កាលមុនតថាគត បានឃើញធីតារបស់មារទាំង ៣ មានអត្តភាពដូចជាដុំមាស មិនប្រឡាក់ដោយរបស់ស្មោកគ្រោក មានស្ლេស្ម៍ជាដើម សូម្បីក្នុងកាលនោះ តថាគតមិនមានសេចក្តីពេញចិត្តក្នុងមេថុនធម្មឡើយ ក៏សរីរៈនៃធីតារបស់អ្នកពោរពេញទៅដោយសាកសព គឺ អាការ ៣២ ដូចជាក្អមពេញទៅដោយរបស់មិនស្អាត ដែលវិចិត្រហើយអំពីខាងក្រៅ សូម្បីបើមេជើងរបស់តថាគត ជាអវយវៈប្រឡាក់ដោយរបស់មិនស្អាត ល្អិកណាធីតារបស់អ្នក គប្បីឈរនៅត្រង់ធរណីទ្វារ សូម្បីដោយអាការដូច្នោះ តថាគតក៏មិនគប្បីញ៉ាំងជើងឲ្យពាល់ត្រូវនូវធីតារបស់អ្នកនោះដែរ” ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា ៖

សូម្បីសេចក្តីត្រូវការក្នុងមេថុន មិនមានហើយ ព្រោះឃើញ

*នាងតណ្ហា នាងអរតី និងនាងរាគា ព្រោះឃើញសរីរៈនៃ*

*ធីតារបស់អ្នកនេះ ដែលពេញទៅដោយមូត្រ និងករីសៈ*

*(តថាគតនឹងមានសេចក្តីត្រូវការក្នុងមេថុន ដូចម្តេចបាន)*

*តថាគតរមែងមិនប្រាថ្នា នឹងប៉ះពាល់សរីរៈធីតារបស់អ្នក*

*នោះ សូម្បីដោយជើង ។*

*ក្នុងវេលាចប់ព្រះធម៌ទេសនា ប្តីប្រពន្ធទាំងពីរនាក់ ក៏បានតាំងនៅក្នុង អនាគាមិផល ដូច្នេះឯង ។*

ចប់ រឿងមារធីតា

# ២. រឿងយមកប្បាដិហារ្យ

ព្រះសាស្តា ទ្រង់ប្រារព្ធទេវតា និងពួកមនុស្សជាច្រើន ត្រង់ទ្វារសង្កស្សនគរ ត្រាស់ព្រះធម្មទេសនានេះថា យេ ឈានប្បសុតា ធីរា (ព្រះសម្មាសម្ពុទ្ធជាម្ចាស់ណាជាអ្នកប្រាជ្ញ ខ្វល់ខ្វាយក្នុងឈាន) ជាដើម ។

### សេដ្ឋីចាងឈើចន្ទន៍ធ្វើបាត្រ

ក៏ព្រះធម៌ទេសនាតាំងឡើងក្នុងក្រុងរាជគ្រឹះ ។

សេចក្តីពិស្តារថា សម័យមួយ សេដ្ឋីក្រុងរាជគ្រឹះ ប្រើឲ្យគេហ៊ុមព័ទ្ធសំណាញ់ដើម្បីដោះភ័យ និងដើម្បីរក្សាអាភរណៈជាដើម ដែលរបូតទៅដោយការភ្លាំងភ្លាត់ ក្នុងការលេងល្បែងក្នុងទន្លេគង្គា ។ ក្នុងកាលនោះ ឈើចន្ទន៍ក្រហមមួយដើមដុះក្បែរឆ្នេរខាងលើនៃទន្លេគង្គា មានឫសត្រូវទឹកទន្លេគង្គាច្រោះបាក់ធ្លាក់ទៅលើថ្មទាំងឡាយក្នុងទីនោះៗ ។ គ្រានោះ មានពកមួយដុំប្រមាណប៉ុនក្អម ត្រូវថ្មត្រដុស ត្រូវរលកទឹកទាំងឡាយបក់បោកឲ្យជារបស់រលើបរលោងរសាត់ទៅដោយលំដាប់ ត្រូវសារាយ (ស្លែ) រុំរឹតជុំវិញ ហើយមកជាប់នៅក្នុងសំណាញ់របស់រាជគហសេដ្ឋីនោះ ។ សេដ្ឋីសួរថា "អ្វីហ្នឹង" ពួកអ្នកបម្រើប្រាប់ថា "លោកសេដ្ឋី ពកឈើ" ក៏ប្រើអ្នកបម្រើឲ្យនាំពកឈើនោះមក ចាំងដោយចុងកាំបិតដើម្បីពិនិត្យមើលថា ពកឈើនោះ ជាពកឈើអ្វី? ចន្ទន៍ក្រហមមានពណ៌ដូចជាល័ក្ខស្រស់ប្រាកដក្នុងខណៈនោះឯង ។ ក៏ក្នុងពេលនោះ សេដ្ឋីនោះ

មិនមែនជាអ្នកសម្មាទិដ្ឋិ មិនមែនជាអ្នកមិច្ឆាទិដ្ឋិ ជាអ្នកមានសភាពជាកណ្តាល គាត់គិតថា "ចន្ទន៍ក្រហមក្នុងផ្ទះរបស់យើងមានច្រើន យើងនឹងយកចន្ទន៍ក្រហមនេះធ្វើអ្វីហ្ន៎" គ្រានោះ សេចក្តីត្រិះរិះកើតមានដល់សេដ្ឋីនោះដូច្នេះថា "ក្នុងលោកនេះ ពួកអ្នកពោលថា យើងទាំងឡាយជាព្រះអរហន្តដូច្នេះ មានច្រើនគ្នា យើងមិនដឹងព្រះអរហន្តសូម្បីតែ ១ អង្គ យើងនឹងឲ្យប្រកបគ្រឿងក្រឡឹងទុកក្នុងផ្ទះឲ្យក្រឡឹងបាត្រ ហើយដាក់ក្នុងសង្រែក ព្យួរក្នុងអាកាសប្រមាណ ៦០ ហត្ថដោយតៗ នៃដើមឫស្សីហើយ និងពោលថា បើព្រះអរហន្តមានពិត សូមមកតាមអាកាស ហើយសូមកាន់យកបាត្រនេះចុះ អ្នកណានឹងកាន់យកបាត្រនោះបាន យើងព្រមទាំងបុត្រ និងភរិយានឹងដល់អ្នកនោះជាសរណៈ" ។ គាត់ឲ្យគេក្រឡឹងបាត្រដូចដែលគាត់បានគិតទុកនោះឯង ឲ្យលើកឡើងដោយដើមឫស្សីតៗ គ្នា ហើយពោលថា "ក្នុងលោកនេះ អ្នកណាជាព្រះអរហន្ត អ្នកនោះសូមមកតាមអាកាស កាន់យកបាត្រនេះចុះ" ។

## គ្រូទាំងទាំង ៦ ចង់បានបាត្រខ្លឹមចន្ទន៍

គ្រូទាំង ៦ ពោលថា បាត្រនោះសមគួរដល់យើងទាំងឡាយ លោកចូរឲ្យបាត្រនោះដល់យើងទាំងឡាយចុះ សេដ្ឋីនោះពោលថា "ពួកលោកចូរមកតាមអាកាសហើយ ចូរកាន់យកចុះ" ។

ក្នុងថ្ងៃទី ៦ និគ្រន្ថនាដបុត្របញ្ជូនពួកអន្តេវាសិកទៅ ដោយពាក្យថា "ពួកអ្នកចូរទៅ ចូរនិយាយនឹងសេដ្ឋីនោះយ៉ាងនេះថា បាត្រនុ៎ះ សមគួរដល់

អាចារ្យរបស់ពួកយើង លោកកុំធ្វើការមកតាមអាកាស ព្រោះហេតុនៃរបស់បន្តិចបន្តួចឡើយ ន័យថា សូមលោកឲ្យបាត្រនោះចុះ” ។ ពួកអន្តេវាសិកទៅនិយាយនឹងសេដ្ឋីដោយប្រការយ៉ាងនោះ ។ សេដ្ឋីពោលថា “អ្នកដែលអាចមកតាមអាកាសទើបកាន់យកបាន ចូរកាន់យកទៅចុះ” ។ នាដបុត្រជាអ្នកប្រាថ្នានឹងទៅខ្លួនឯង ទើបបានឲ្យសញ្ញាដល់ពួកអន្តេវាសិកថា “យើងនឹងលើកដៃ និងជើងម្ខាង ធ្វើដូចជាប្រាថ្នានឹងហោះឡើង ពួកអ្នកចូរស្រែកប្រាប់យើងថា លោកអាចារ្យ លោកប្រុងធ្វើអ្វី? លោកចូរកុំសម្តែងនូវភាពជាព្រះអរហន្ត ដែលជាគុណជាតដ៏កំបាំង ព្រោះហេតុនៃបាត្រឈើដល់មហាជនឡើយ លុះពោលដូច្នេះហើយ ចូរនាំគ្នាចាប់ជើង និងដៃរបស់យើងទាញមក ឲ្យដួលទៅលើផែនដី” ។ គេទៅកាន់ទីនោះហើយ ពោលនឹងសេដ្ឋីថា “មហាសេដ្ឋី បាត្រនេះសមគួរដល់យើង មិនសមគួរដល់ពួកជនដទៃទេ លោកកុំគាប់ចិត្តនឹងការហោះឡើងទៅក្នុងអាកាសរបស់អាត្មាភាព ព្រោះហេតុនៃរបស់ត្រឹមតែបន្តិចបន្តួចឡើយ ចូរឲ្យបាត្រនោះដល់អាត្មាភាពចុះ” ។

សេដ្ឋី. លោកដ៏ចម្រើន លោកចូរហោះឡើងទៅតាមអាកាស ហើយកាន់យកចុះ ។

លំដាប់នោះ នាដបុត្រពោលថា “បើដូច្នោះ ពួកអ្នកចូរចៀសចេញ” លុះពួកអន្តេវាសិកចៀសចេញហើយ ក៏ពោលថា “យើងនឹងហោះឡើងទៅក្នុងអាកាស” ដូច្នេះហើយ ក៏លើកដៃម្ខាង និងជើងម្ខាងឡើង ។ ភ្លាមនោះ ពួក

អន្ត្រវាសិកពោលនឹងនាដបុត្រថា "លោកអាចារ្យ លោកធ្វើអ្វីហ្នឹង ប្រយោជន៍អ្វី ដោយគុណដ៏កំបាំងដែលលោកសម្តែងដល់មហាជន ព្រោះហេតុនៃបាត្រឈើនេះឡើយ" ហើយជួយគ្នាចាប់នាដបុត្រនោះត្រង់ដៃ និងជើងទាញឲ្យដួលទៅលើផែនដី ។ និគន្ថនាដបុត្រប្រាប់សេដ្ឋីថា "មហាសេដ្ឋី អន្តេវាសិកទាំងនេះមិនឲ្យអាត្មាភាពហោះទេ លោកចូរឲ្យបាត្រដល់អាត្មាភាពចុះ" ។

សេដ្ឋី. លោកដ៏ចម្រើន លោកចូរហោះឡើង ហើយកាន់យកចុះ ។

ពួកតិរ្ថិយ សូម្បីព្យាយាមយ៉ាងនេះអស់ ៦ ថ្ងៃហើយ នៅតែមិនបានបាត្រនោះដដែល ។

ព្រះបិណ្ឌោលភារទ្វាជៈសម្តែងបាដិហារ្យ

ក្នុងថ្ងៃទី ៧ ក្នុងកាលដែលព្រះមហាមោគ្គល្លាន និងព្រះបិណ្ឌោលភារទ្វាជៈ គង់លើថ្មដាមួយកន្លែង ហើយឃ្លុំចីវរ ដោយតាំងចិត្តថា "នឹងត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ" ពួកអ្នកលេងជដែកគ្នាថា "ពួកយើងអើយ ក្នុងកាលមុន គ្រូទាំង ៦ តែងតែពោលថា ពួកយើងជាព្រះអរហន្តក្នុងលោក តែកាលសេដ្ឋីក្នុងក្រុងរាជគ្រឹះឲ្យយកបាត្រ បានពោលថា ប្រសិនបើព្រះអរហន្តមាន សូមមកតាមអាកាសហើយកាន់យកចុះ នេះជាថ្ងៃទី ៧ ហើយ សូម្បីតែមនុស្សម្នាក់ ដែលអាចហោះឡើងទៅក្នុងអាកាស ហើយសម្តែងខ្លួនថា យើងជាព្រះអរហន្ត ក៏មិនមាន ថ្ងៃនេះ ពួកយើងបានដឹងថា ព្រះអរហន្តមិនមានក្នុងលោកទេ" ។ ព្រះមហាមោគ្គល្លានបានឮពាក្យនោះហើយ ក៏ពោលនឹងព្រះបិ-

ណ្ឌោលភារទ្វាជៈថា "អាវុសោភារទ្វាជៈ លោកបានឮពាក្យអ្នកលេងទាំងនេះទេ? ពួកអ្នកលេងទាំងនេះនិយាយគ្នា ដូចជាកោសរូសទីងព្រះពុទ្ធសាសនាខ្លាំងណាស់ ក៏លោកជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ដូច្នេះ អ្នកចូរទៅចូរទៅតាមអាកាស ហើយកាន់យកបាត្រនោះចុះ" ។

ព្រះបិណ្ឌោលភារទ្វាជៈ. អាវុសោ មោគ្គល្លាន លោកជាអ្នកប្រសើរលើសសាវ័កអ្នកមានឫទ្ធិទាំងឡាយ លោកចូរកាន់យកបាត្រនោះចុះ តែកាលលោកមិនកាន់យកទេ ខ្ញុំនឹងកាន់យក ។ កាលព្រះមហាមោគ្គល្លានពោលយ៉ាងនេះថា "អាវុសោបិណ្ឌោលភារទ្វាជៈ លោកចូរកាន់យកចុះ ក៏ចូលចតុត្ថជ្ឈានមានអភិញ្ញាជាបាទ ចេញហើយ យកម្រាមជើងគាបថ្មដាទំហំប្រមាណបីគាវុតយោងឡើងទៅក្នុងអាកាសដូចសំឡី ហើយធ្វើលជុំវិញខាងលើព្រះនគរាជគ្រឹះអស់វារៈ ៧ ជុំ ។ ថ្មដានោះ ប្រាកដដូចជាគម្របព្រះនគរមានប្រមាណ ៣ គាវុត ។ ពួកអ្នកនគរ ភ័យខ្លាចស្រែកថា "ថ្មនឹងធ្លាក់សង្កត់ខ្ញុំ" ទើបធ្វើគ្រឿងការពារទាំងឡាយ មានចង្អេរជាដើមអំពីលើក្បាល ហើយពួនក្នុងទីនោះៗ ។ បាន ៧ ជុំ ព្រះថេរៈទើបបានទម្លាយថ្មដា ហើយសម្តែងខ្លួន ។ មហាជនបានឃើញព្រះថេរៈហើយ ក៏ពោលថា "លោកម្ចាស់បិណ្ឌោលភារទ្វាជៈដ៏ចម្រើន សូមលោកម្ចាស់ចាប់ថ្មរបស់លោកម្ចាស់ឲ្យជាប់ កុំធ្វើពួកខ្ញុំទាំងអស់គ្នា ឲ្យវិនាសឡើយ ។ ព្រះថេរៈបោះថ្មចោលដោយចុងជើង ។ ផែនថ្មនោះទៅតាំងនៅក្នុងកន្លែងដើមវិញ ។ ព្រះថេរៈបានឈរនៅក្នុងទីបំផុតនៃផ្ទះរបស់សេដ្ឋី ។

សេដ្ឋីឃើញព្រះថេរៈហើយ ក៏ក្រាបចុះ ហើយពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមនិមន្តចុះមក" និមន្តព្រះថេរៈដែលចុះមកអំពីអាកាសឲ្យគង់ហើយ ប្រើគេសម្រូតបាត្រចុះមក ធ្វើបាត្រនោះឲ្យពេញដោយវត្ថុដែលមានរសឆ្ងាញ់ ៤ មុខ ហើយប្រគេនព្រះថេរៈៗ ទទួលបាត្រនោះហើយ ក៏និមន្តទៅកាន់វិហារវិញ ។ គ្រានោះ ពួកជនណានៅក្នុងព្រៃក្តី នៅក្នុងស្រុកក្តី មិនបានឃើញបាដិហារ្យរបស់ព្រះថេរៈ ជនទាំងនោះប្រជុំគ្នាហើយ ពោលអង្វរព្រះថេរៈថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់សម្តែងបាដិហារ្យឲ្យដល់ពួកខ្ញុំបានឃើញផង" ដូច្នេះហើយ ក៏នាំគ្នាជាប់តាមព្រះថេរៈ ។ ព្រះថេរៈសម្តែងបាដិហារ្យដល់ពួកជននោះៗ បណ្តើរ និមន្តទៅកាន់ព្រះវិហារបណ្តើរ ។

ព្រះសាស្តាទ្រង់ហាមមិនឲ្យភិក្ខុធ្វើបាដិហារ្យ

ព្រះសាស្តា ទ្រង់ស្តាប់នូវសំឡេងរបស់មហាជន ដែលជាប់តាមព្រះថេរៈហើយ ក៏ត្រាស់សួរថា "ម្នាលអានន្ទ នុ៎ះជាសំឡេងរបស់នរណា" លុះទ្រង់ស្តាប់ថា "ព្រះបិណ្ឌោលភារទ្វាជៈ ហោះឡើងទៅក្នុងអាកាស ហើយកាន់យកបាត្រខ្លឹមច័ន្ទន៍ នុ៎ះជាសំឡេងមហាជន ដែលនៅក្នុងសម្នាក់របស់លោក ទើបត្រាស់ឲ្យហៅព្រះបិណ្ឌោលភារទ្វាជៈមក ត្រាស់សួរថា "ម្នាលបិណ្ឌោលអ្នកបានធ្វើយ៉ាងនោះពិតមែនឬ" កាលព្រះបិណ្ឌោលភារទ្វាជៈ ក្រាបទូលថា "ព្រះករុណា ព្រះអង្គ" ក៏ត្រាស់ថា "ម្នាលភារទ្វាជៈ ហេតុអ្វីទើបអ្នកធ្វើយ៉ាងនោះ" ទ្រង់តិះដៀលព្រះថេរៈ ហើយត្រាស់ឲ្យទម្លាយបាត្រនោះឲ្យជាកំណាត់

តូចកំណាត់ធំ ហើយត្រាស់ឲ្យទៅភិក្ខុទាំងឡាយ ដើម្បីប្រយោជន៍ដល់ការកិន ធ្វើជាថ្នាំបន្តក់ភ្នែក ហើយទ្រង់បញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយ ដើម្បីជាប្រយោជន៍ដល់កិរិយាមិនធ្វើនូវបាដិហារ្យ ។ ចំណែកពួកតិរ្ថិយបានឮថា ព្រះមានព្រះភាគឲ្យទម្លាយបាត្រនោះ ហើយទ្រង់បញ្ញត្តិសិក្ខាបទដល់សាវកទាំងឡាយ ហាមសាវកមិនឲ្យធ្វើបាដិហារ្យ ទើបដើរប្រាប់គ្នាតាមថ្នល់នៃព្រះនគរថា "សាវកទាំងឡាយរបស់ព្រះសមណគោតមមិនឈានកន្លងសិក្ខាបទ ដែលទ្រង់បញ្ញត្តិហើយទេ សូម្បីព្រោះហេតុនៃជីវិត សូម្បីព្រះសមណគោតមក៏នឹងរក្សាសិក្ខាបទដែលទ្រង់បញ្ញត្តិនោះដែរ ឥឡូវនេះ ពួកយើងបានឱកាសហើយ" ហើយពោលថា "ពួកយើងរក្សាគុណរបស់ខ្លួន ទើបមិនសម្តែងគុណរបស់ខ្លួនដល់មហាជន ព្រោះហេតុនៃបាត្រក្នុងកាលមុន ពួកសាវករបស់ព្រះសមណ-គោតមសម្តែងគុណរបស់ខ្លួន ព្រោះហេតុនៃបាត្រ ព្រះសមណគោតមត្រាស់ឲ្យទម្លាយបាត្រនោះហើយ ទ្រង់បញ្ញត្តិសិក្ខាបទដល់ពួកសាវក ព្រោះព្រះអង្គជាបណ្ឌិត ឥឡូវនេះ ពួកយើងនឹងធ្វើបាដិហារ្យជាមួយព្រះសមណគោតម" ។

ព្រះបាទពិម្ពិសារ ទ្រង់ស្តាប់នូវពាក្យនោះហើយ ស្តេចទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ព្រះអង្គទ្រង់បញ្ញត្តិសិក្ខាបទដល់ពួកសាវក ដើម្បីត្រូវការមិនឲ្យធ្វើបាដិហារ្យពិតឬ" ។

ព្រះសាស្តា. ថ្វាយព្រះពរមហាបពិត្រ ពិតមែនហើយ ។

ព្រះរាជា. ឥឡូវនេះ ពួកតិរ្ថិយនាំគ្នាពោលថា ពួកយើងនឹងធ្វើបាដិហារ្យ

ជាមួយព្រះអង្គ ឥឡូវនេះ ព្រះអង្គទ្រង់នឹងធ្វើដូចម្ដេច? ។

ព្រះសាស្ដា. មហាបពិត្រ បើតិរ្ថិយទាំងនោះធ្វើ តថាគតក៏នឹងធ្វើដែរ ។

ព្រះរាជា. ព្រះអង្គទ្រង់បញ្ញត្តិសិក្ខាបទុកហើយមិនមែនឬ ?

ព្រះសាស្ដា. មហាបពិត្រ តថាគតមិនបានបញ្ញត្តិសិក្ខាបទដើម្បីខ្លួនទេ សិក្ខាបទនោះ តថាគតបញ្ញត្តិទុកដើម្បីសាវកទាំងឡាយប៉ុណ្ណោះ ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន សិក្ខាបទឈ្មោះថា ព្រះអង្គបញ្ញត្តិដល់សាវកទាំងឡាយ វៀរព្រះអង្គចេញឬ ?

ព្រះសាស្ដា. មហាបពិត្រ បើដូច្នោះ តថាគតនឹងសួរមហាបពិត្រក្នុងរឿងនេះថា មហាបពិត្រ ក៏ព្រះរាជឧទ្យានក្នុងដែនរបស់ព្រះអង្គ មានឬ ?

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន មាន ។

ព្រះសាស្ដា. មហារាជ ប្រសិនបើមហាជនគប្បីទំពាស៊ីនូវផ្លែឈើទាំងឡាយ មានផ្លែស្វាយជាដើម ក្នុងព្រះរាជឧទ្យានរបស់ព្រះអង្គ ព្រះអង្គទ្រង់ធ្វើយ៉ាងណាចំពោះជនទាំងនោះ ?

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន គប្បីដាក់អាជ្ញា ។

ព្រះសាស្ដា. ចំណែកព្រះអង្គសោយបានឬទេ ?

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន អាជ្ញាមិនមានដល់ខ្ញុំព្រះអង្គទេ ខ្ញុំព្រះអង្គអាចសោយនូវវត្ថុជារបស់នៃខ្លួនបាន ។

ព្រះសាស្ដា. បពិត្រមហារាជ អាជ្ញារបស់ព្រះអង្គរមែងផ្សាយទៅក្នុង

រាជាណាចក្រប្រមាណ ៣០០ យោជន៍ អាជ្ញានោះមិនមានដល់ព្រះអង្គក្នុងការសោយនូវផ្លែឈើទាំងឡាយ មានផ្លែស្វាយជាដើមក្នុងឧទ្យានរបស់ព្រះអង្គ តែរមែងមានដល់ជនទាំងឡាយដទៃ យ៉ាងណា សូម្បីអាជ្ញារបស់តថាគត រមែងផ្សាយទៅក្នុងសែនកោដិចក្រវាឡ អំពើល្មើស ព្រោះកិរិយាប្រព្រឹត្តកន្លងនូវសិក្ខាបទរបស់ខ្លួន រមែងមិនមានដល់តថាគត តែរមែងមានដល់សាវកទាំងឡាយដទៃ ព្រោះហេតុនោះ ទើបតថាគតនឹងធ្វើបាដិហារ្យ ។ ពួកតិរ្ថិយឮនូវព្រះពុទ្ធតម្រាស់នោះហើយ ប្រឹក្សាគ្នាថា "ឥឡូវនេះ ពួកយើងវិនាសហើយ" បានឮថា ព្រះសមណគោតមទ្រង់បញ្ញត្តិសិក្ខាបទដល់សាវកទាំងឡាយប៉ុណ្ណោះ ទ្រង់មិនបញ្ញត្តិដល់ខ្លួនទេ បានឮថា ព្រះសមណគោតមប្រាថ្នានឹងធ្វើនូវបាដិ-ហារ្យ ដោយខ្លួនឯងតែម្តង ពួកយើងនឹងធ្វើដូចម្តេចហ្ន៎ ព្រះរាជាទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ធ្វើបាដិហារ្យក្នុងកាលណា"

ព្រះសាស្តា. បពិត្រមហារាជ តថាគតនឹងធ្វើក្នុងតិថី ពេញបូណ៌មី ខែអាសាឍ ដោយកាលកន្លងទៅ ៤ ខែទៀត អំពីថ្ងៃនេះ ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់នឹងធ្វើនៅទីណា ?

ព្រះសាស្តា. បពិត្រមហារាជ តថាគតនឹងធ្វើនៅក្នុងក្រុងសាវត្ថី ។

មានពាក្យសួរចូលមកថា "ហេតុដូចម្តេច ទើបព្រះសាស្តាទ្រង់សម្តែងទីដ៏ឆ្ងាយយ៉ាងនេះ ?" ។

ឆ្លើយថា "ព្រោះទីនោះ ជាទីដែលធ្វើមហាបាដិហារ្យរបស់ព្រះពុទ្ធគ្រប់ៗ

ព្រះអង្គ, ន័យមួយទៀតថា ព្រះអង្គទ្រង់សម្តែងនូវទីដ៏ឆ្ងាយយ៉ាងនោះ ព្រោះដើម្បីប្រយោជន៍ឲ្យមហាជនប្រជុំគ្នា” ។ ពួកតិរ្ថិយបានឮនូវពុទ្ធតម្រាស់នោះហើយ ពោលថា “បានឮថា នៅសល់ ៤ ខែទៀត ព្រះសមណគោតមនឹងធ្វើបាដិហារ្យនៅក្នុងសាវត្ថី” ឥឡូវនេះ ពួកយើងកុំលះបង់ព្រះសមណគោតម ត្រូវជាប់តាមព្រះអង្គជានិច្ច មហាជនឃើញពួកយើងហើយ នឹងសួរថា “តើមានរឿងអ្វី?” ពេលនោះ ពួកយើងនឹងប្រាប់មហាជនថា “ពួកយើងនិយាយហើយថា នឹងធ្វើបាដិហារ្យជាមួយនឹងព្រះសមណគោតម ព្រះសមណគោតមរមែងរត់គេច ពួកយើងមិនឲ្យព្រះសមណគោតមរត់គេច ទើបជាប់តាមមក” ។ ព្រះសាស្តា ស្តេចយាងទៅដើម្បីបិណ្ឌបាតក្នុងរាជគ្រឹះ ហើយស្តេចយាងចេញមក ចំណែកពួកតិរ្ថិយ ក៏ចេញមកអំពីខាងក្រោយព្រះអង្គ ហើយឋិតនៅក្នុងទីជិតព្រះអង្គធ្វើភត្តកិច្ច ។ ថ្ងៃស្អែកឡើង ពួកគេនាំគ្នាបរិភោគអាហារពេលព្រឹកក្នុងទីដែលខ្លួននៅនោះឯង ។ ពួកតិរ្ថិយទាំងនោះ ត្រូវមនុស្សទាំងឡាយសួរថា “ការណ៍នេះដូចម្តេច” ក៏ប្រាប់តាមន័យដូចដែលបានពោលហើយខាងដើម ។ ចំណែកមហាជនក៏បានជាប់តាមព្រះសាស្តា ដោយគិតថា “ពួកយើងនឹងមើលបាដិហារ្យ” ។ ព្រះសាស្តាស្តេចយាងដល់ក្រុងសាវត្ថីដោយលំដាប់ ។

សូម្បីពួកតិរ្ថិយក៏ទៅជាមួយព្រះអង្គដែរ បបួលឧបដ្ឋាករបស់ខ្លួនបានទ្រព្យមួយសែន ហើយប្រើគេឲ្យធ្វើមណ្ឌបដោយសសរឈើគគីរទាំងឡាយ ឲ្យប្រក់ដោយផ្កាឧប្បលខៀវទាំងឡាយ ហើយអង្គុយនិយាយគ្នាថា “ពួកយើងនឹងធ្វើបាដិហារ្យ

ក្នុងទីនេះ" ។

គ្រានោះ ព្រះបាទបសេនទិកោសល ស្ដេចយាងចូលគាល់ព្រះសាស្ដា ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពួកតិរ្ថិយឲ្យគេធ្វើមណ្ឌបហើយ ចំណែកខ្ញុំព្រះអង្គនឹងបញ្ជាឲ្យគេធ្វើមណ្ឌបសម្រាប់ព្រះអង្គដែរ" ។

ព្រះសាស្ដា. កុំឡើយ មហាបពិត្រ អ្នកធ្វើមណ្ឌបដើម្បីតថាគត មានហើយ ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន អ្នកណាទៅ វៀរតែខ្ញុំព្រះអង្គចេញនឹងអាចធ្វើបាន ។

ព្រះសាស្ដា. សក្កទេវរាជ ។

ព្រះរាជាទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ធ្វើបាដិហារ្យក្នុងទីណា" ។

ព្រះសាស្ដា. បពិត្រមហារាជ តថាគតនឹងធ្វើនៅទៀបគល់នៃគណ្ឌាម-ព្រឹក្ស ។

ពួកតិរ្ថិយបានឮថា ព្រះសម្មាសម្ពុទ្ធទ្រង់នឹងធ្វើបាដិហារ្យក្បែរគល់ដើមស្វាយ ក៏ប្រាប់ឧបដ្ឋាករបស់ខ្លួន ឲ្យដកកូនស្វាយ ដោយហោចទៅសូម្បីទើបតែដុះក្នុងថ្ងៃនោះ ក្នុងទីប្រមាណមួយយោជន៍ ហើយឲ្យយកទៅចោលក្នុងព្រៃ ។

## ប្រវត្តិគណ្ឌាមព្រឹក្ស

ក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ព្រះសាស្ដាស្ដេចយាងចូលទៅខាងក្នុង

ព្រះនគរ ។ បុរសអ្នករក្សាឧទ្យានរបស់ព្រះរាជា ឈ្មោះគណ្ឌ: ឃើញផ្លែស្វាយទុំមួយផ្លែ ក្នុងសំណុំស្លឹកដែលស្រមោចក្រហម (អង្រ្កង) ទាំងឡាយធ្វើសំបុកដេញសត្វក្អែកទាំងឡាយ ដែលមកចោមរោមផ្លែស្វាយនោះ ដោយសេចក្តីលោភក្នុងក្លិន និងរសនៃផ្លែស្វាយនោះឲ្យរត់ទៅ ហើយកាន់យកទៅដើម្បីថ្វាយដល់ព្រះរាជា កាលដើរទៅ បានឃើញព្រះសាស្តាក្នុងរវាងផ្លូវ ក៏គិតថា "ព្រះរាជាសោយផ្លែស្វាយនេះហើយ គប្បីព្រះរាជទានកហាបណៈដល់យើង ៨ កហាបណៈ ឬ ១៦ កហាបណៈប៉ុណ្ណោះ ហើយកហាបណៈនោះមិនល្មមដល់ការចិញ្ចឹមជីវិត ក្នុងមួយអត្តភាពរបស់យើងផង តែប្រសិនបើយើងនឹងថ្វាយអម្ពទាននេះចំពោះព្រះសាស្តា នឹងជាគុណនាំមកនូវប្រយោជន៍ដល់យើងរកទីបំផុតគ្មាន ។ លុះគិតដូច្នោះហើយ ក៏បង្អោនផ្លែស្វាយនោះថ្វាយចំពោះព្រះសាស្តា ។

ព្រះសាស្តាទ្រង់ទតមើលព្រះអានន្ទ ។ លំដាប់នោះ ព្រះអានន្ទនាំបាត្រដែលមហារាជទាំង ៤ ថ្វាយចេញមក ហើយតម្កល់ក្នុងព្រះហស្តរបស់ព្រះអង្គព្រះសាស្តាទ្រង់បង្អោនបាត្រចូលទៅទទួលផ្លែស្វាយ ហើយទ្រង់សម្តែងនូវអាការគឺ កិរិយាប្រថាប់គង់ក្នុងទីនោះឯង ។ ព្រះថេរៈ ក្រាលចីវរថ្វាយ ។ គ្រានោះព្រះថេរៈត្រងទឹកស្អាត ប្របាច់ផ្លែស្វាយទុំធ្វើឲ្យទៅជាទឹកគួរផឹក (ទឹកបានៈ) ថ្វាយចំពោះព្រះមានព្រះភាគ ដែលប្រថាប់គង់ហើយក្នុងទីនោះ ។ ព្រះសាស្តាទ្រង់សោយទឹកបាននោះហើយ ទ្រង់ត្រាស់នឹងនាយគណ្ឌៈថា "អ្នកចូរកកាយអាចម៍ដីឡើង ហើយចូរដាំគ្រាប់ស្វាយក្នុងទីនេះចុះ" ។ គេក៏បានធ្វើយ៉ាងនោះ

ឯង ។

ព្រះសាស្តា ទ្រង់លាងព្រះហស្តលើគ្រាប់ស្វាយនោះ ។ គ្រាន់តែព្រះសាស្តាទ្រង់លាងព្រះហស្តហើយភ្លាម ដើមស្វាយទំហុំប៉ុនយាមនង្គ័ល កម្ពស់ ៥០ ហត្ថ ដុះឡើង ។ មានមែកធំ ៥ គឺ ក្នុងទិសទាំង ៤ៗ មែក និងទិសខាងលើមួយមែក ក្នុងមែកនីមួយៗ មានប្រវែង ៥០ ហត្ថ ជាឈើដល់ព្រមហើយដោយផ្កា និងផ្លែ ជាឈើទ្រទ្រង់នូវចង្កោមនៃផ្លែស្វាយទុំដោយជុំវិញ ។ ពួកភិក្ខុដែលនិមន្តមកខាងក្រោយ ក៏បានឆាន់ផ្លែស្វាយទុំនោះដែរ ។ ព្រះរាជាទ្រង់ស្តាប់ថា "បានឮថា ដើមស្វាយបែបនោះដុះឡើងហើយ" ទ្រង់ក៏ត្រាស់បង្គាប់ឲ្យគេរក្សាយ៉ាងល្អ ដោយព្រះតម្រាស់ថា "នរណាៗ កុំកាត់ដើមស្វាយនោះ" ។ ដើមស្វាយនោះ ប្រាកដឈ្មោះថា "គណ្ឌាមព្រឹក្ស" ព្រោះជាដើមស្វាយដែលឧទ្យានបាលឈ្មោះគណ្ឌៈជាអ្នកដាំ ។ សូម្បីពួកអ្នកលេង ស៊ីផ្លែស្វាយទុំនោះហើយ ពោលថា "ម្នាលតិរ្ថិយគម្រក់ទាំងឡាយ ពួកអ្នកដឹងថា ព្រះសមណគោតមទ្រង់នឹងធ្វើបាដិហារ្យត្រង់ដើមគណ្ឌាមព្រឹក្ស ទើបប្រើគេឲ្យដកកូនស្វាយទាំងឡាយ សូម្បីទើបតែដុះក្នុងថ្ងៃនោះ ក្នុងទីប្រមាណមួយយោជន៍ តែដើមស្វាយនេះ ឈ្មោះថា គណ្ឌាម្ពៈ" ហើយក៏យកគ្រាប់ស្វាយប្រហារពួកតិរ្ថិយទាំងនោះ ។ សក្កទេវរាជទ្រង់បង្គាប់វាតវលាហកទេវបុត្ត (ទេវបុត្រអ្នកបង្អុរមកនូវខ្យល់) ថា "អ្នកចូរបំបើនមណ្ឌបរបស់ពួកតិរ្ថិយដោយខ្យល់ ហើយឲ្យខ្យល់បក់ចេញពីលើផែនដីទៅចោលក្នុងគំនរសំរាម ។ ទេវបុត្រនោះ បានធ្វើ

ដោយប្រការៈដូច្នោះ ។ សក្កទេវរាជត្រាស់បង្គាប់សុរិយទេវបុត្រថា អ្នកចូរពង្រីកមណ្ឌលព្រះអាទិត្យ ញ៉ាំង (ពួកតិរ្ថិយ) ឲ្យក្តៅចុះ ។សូម្បីទេវបុត្តនោះក៏បានធ្វើហើយដូច្នោះ ។ សក្កទេវរាជទ្រង់បង្គាប់វាតវលាហកទេវបុត្តទៀតថា "អ្នកចូរញ៉ាំងមណ្ឌលនៃខ្យល់ (ខ្យល់កំបុតត្បូង) ឲ្យតាំងឡើងតទៅទៀតចុះ" ។ ទេវបុត្តនោះ ក៏ធ្វើហើយដោយប្រការដូច្នោះ ហើយរោយធូលីលើសរីរៈដែលប្រកបដោយញើសរបស់តិរ្ថិយទាំងឡាយ ។ តិរ្ថិយទាំងនោះ ជាបុគ្គលប្រាកដស្មើដោយដំបូកក្រហម ។ សក្កទេវរាជទ្រង់បង្គាប់ សូម្បីវស្សវលាហកទេវបុត្តថា "អ្នកចូរញ៉ាំងតំណក់ទឹកគ្រាប់ធំៗ ឲ្យធ្លាក់ចុះ" ។ ទេវបុត្រនោះក៏បានធ្វើហើយដូច្នោះ ។ គ្រានោះ កាយរបស់ពួកតិរ្ថិយទាំងនោះ ប្រៀបដូចជាមេគោពពាល ។ ពួកតិរ្ថិយទាំងនោះបែកពួកគ្នា រត់ទៅកាន់ទិសផ្សេងៗ ។ កាលពួកគេរត់ទៅយ៉ាងនោះ អ្នកស្រែម្នាក់ ដែលជាឧបដ្ឋាករបស់បូរណកស្សបៈគិតថា "ពេលនេះ ជាពេលធ្វើបាដិហារ្យនៃលោកម្ចាស់របស់យើង យើងនឹងទៅមើលនូវបាដិហារ្យនោះ" លុះគិតដូច្នោះហើយ ក៏លែងគោ កាន់ផ្ទាំងបបរដែលខ្លួននាំមកអំពីព្រលឹម និងខ្សែដើរមក ឃើញសាស្តាឈ្មោះបូរណៈ កំពុងរត់ដូច្នោះ ក៏សួរថា "បពិត្រលោកអាចារ្យ ខ្ញុំមកដោយបំណងថា នឹងមើលនូវបាដិហារ្យរបស់លោកអាចារ្យ តើលោកអាចារ្យនឹងទៅកាន់ទីណា?" ។

បូរណៈ. ប្រយោជន៍អ្វីដល់អ្នក ដោយបាដិហារ្យនោះ ចូរឲ្យផ្ទាំង និងខ្សែនោះមកយើង ។

គេកាន់យកថ្នាំង និងខ្សែដែលឧបដ្ឋាករបស់ខ្លួនឲ្យហើយ ដើរទៅកាន់ឆ្នេរស្ទឹង ចងថ្នាំងនឹង.ករបស់ខ្លួនដោយខ្សែ ហើយលោតចុះទៅក្នុងអន្លង់ទឹក ញាំងពពុះឲ្យតាំងឡើង ធ្វើកាលកិរិយាហើយ ទៅកើតក្នុងនរកឈ្មោះអវីចិ ។ ព្រះសាស្តា ទ្រង់និម្មិតនូវទីចង្ក្រមជាវិការៈនៃកែវក្នុងអាកាស ។ ក្នុងទីបំផុតម្ខាងនៃទីចង្ក្រមនោះ ឋិតនៅក្នុងកណ្តាប់មាត់ចក្រវាឡខាងកើត ចុងម្ខាងទៀតនៅក្នុងកណ្តាប់មាត់ចក្រវាឡខាងលិច ។ ព្រះសាស្តា កាលបរិស័ទប្រមាណ ៣៦ យោជន៍ ប្រជុំគ្នាហើយ ក្នុងវេលារសៀល ស្តេចចេញចាកព្រះគន្ធកុដិ ដោយទ្រង់ព្រះតម្រិះថា "ពេលនេះជាពេលធ្វើបាដិហារ្យ" ហើយទ្រង់បានប្រថាប់ឈរនៅត្រង់ទីខាងមុខបរិស័ទទាំងនោះ ។

សាវកសាវិកាសូមទទួលធ្វើបាដិហារ្យជំនួស

គ្រានោះ ឧបាសិកាជាអនាគាមីម្នាក់ ជាមាតារបស់នន្ទមាណព ឈ្មោះ **ឃរណី** ចូលទៅគាល់ព្រះអង្គ ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន កាលធីតាដូចជាខ្ញុំព្រះអង្គនៅមាន កិច្ចដែលព្រះអង្គត្រូវលំបាក រមែងមិនមាន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យជំនួសព្រះអង្គ" ។

ព្រះសាស្តា. ម្នាលនាងឃរណី នាងនឹងធ្វើដូចម្តេច ?

ឃរណី. ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើនូវមហាប្រឹថពីក្នុងផ្ទៃចក្រវាឡឲ្យទៅជាទឹក ហើយមុជចុះក្នុងទឹក សម្តែងខ្លួនក្នុងកណ្តាប់ចក្រវាឡខាងកើត កណ្តាប់ចក្រវាឡខាងលិច ខាងជើង និងខាងត្បូង

និងត្រង់កណ្តាល ពេលនោះ មហាជនឃើញខ្ញុំព្រះអង្គហើយ ក៏សួរថា នរណានោះ? ក៏ប្រាប់ថា នោះជាយរណីឧបាសិកា អានុភាពរបស់ស្ត្រីម្នាក់នេះ ដល់ម្ល៉ោះទៅហើយ ចាំបាច់ពោលថ្វីដល់អានុភាពរបស់ព្រះពុទ្ធ នឹងប្រាកដដូចម្តេចទៅ? ពួកតិរ្ថិយមិនបាច់ឃើញព្រះអង្គទេ នឹងរត់ទៅដោយប្រការយ៉ាងនេះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា "ម្នាលនាងយរណី តថាគតរមែងដឹងនូវការៈនៃនាងជាស្ត្រី អាចធ្វើបាដិហារ្យបែបនេះបាន ប៉ុន្តែកម្រងផ្កានេះ គេមិនបានចងទុកដើម្បីប្រយោជន៍ដល់នាងទេ" លុះទ្រង់ត្រាស់ដូច្នោះហើយទ្រង់ក៏ហាមឃាត់ ។

នាងយរណីនោះគិតថា "ព្រះសាស្តាទ្រង់មិនអនុញ្ញាតដល់យើង ប្រាកដជាមានអ្នកដទៃដែលអាចធ្វើបាដិហារ្យ ឲ្យក្រៃលែងជាងយើងដោយពិត" លុះគិតដូច្នោះហើយ ក៏ឈរនៅក្នុងចំណែកម្ខាង ។

ឯព្រះសាស្តាទ្រង់ត្រិះរិះថា គុណរបស់សាវកទាំងនោះនឹងប្រាកដដោយអាការយ៉ាងនេះឯង ទ្រង់សម្គាល់ថា "ពួកសាវកនឹងបន្លឺសីហនាទត្រង់កណ្តាលបរិស័ទ មានប្រមាណ ៣៦ យោជន៍ ដោយអាការយ៉ាងនេះ" ទើបត្រាស់សួរសាវកមួយពួកទៀតថា "ពួកអ្នកនឹងធ្វើបាដិហារិយដូចម្តេច" សាវកទាំងនោះក៏ក្រាបទូលថា "ពួកខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនេះៗ ព្រះអង្គ" ហើយឈរនៅចំពោះព្រះភក្ត្រព្រះសាស្តា បន្លឺសីហនាទ ។

បណ្តាសាវកទាំងនោះ បានឮថា ចូឡអនាថបិណ្ឌិកៈ គិតថា "កាលបុត្រ

ជាអនាគាមីឧបាសកប្រាកដដូចជាយើងនៅមាន កិច្ចដែលព្រះសាស្តានឹងត្រូវលំបាករមែងមិនមាន ទើបក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ ត្រូវព្រះសាស្តាត្រាស់សួរថា "អ្នកនឹងធ្វើដូចម្តេច" ក៏ក្រាបទូលថា "បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងនិម្មិតអត្តភាពជាព្រហ្ម មានប្រមាណ ១២ យោជន៍ នឹងទះដៃដូចព្រហ្ម ឲ្យមានសំឡេងដូចជាមហាមេឃគ្រហឹមក្នុងកណ្តាលបរិស័ទ មហាជននឹងសួរគ្នាថា "នេះឈ្មោះថា ជាសំឡេងអ្វី?" នឹងបានឮថា សំឡេងនុ៎ះ ជាសំឡេងទះដៃដូចជាព្រហ្មរបស់ចូឡអនាថបិណ្ឌិកៈ ពួកតិរ្ថិយគិតថា អានុភាពរបស់គហបតីដល់ម៉្លោះទៅហើយ ចំណាន់បើអានុ-ភាពរបស់ព្រះពុទ្ធជាម្ចាស់ នឹងប្រាកដដូចម្តេចទៅ? ពួកតិរ្ថិយមិនចាំបាច់ឃើញព្រះអង្គឡើយ នឹងរត់ទៅ" ។ ព្រះសាស្តាក៏ត្រាស់យ៉ាងនោះដូចគ្នា សូម្បីដល់ចូឡអនាថបិណ្ឌិកៈនោះថា "តថាគតជ្រាបអានុភាពរបស់អ្នក ហើយទ្រង់ក៏មិនអនុញ្ញាតការធ្វើបាដិហារ្យ ។ តមក សាមណេរីឈ្មោះ *វីរា* មានអាយុ ៧ ខួប សម្រេចបដិសម្ភិទា ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ" ។

ព្រះសាស្តា. ម្នាលនាងវីរា នាងនឹងធ្វើដូចម្តេច ?

វីរា. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនាំភ្នំសិនេរុផង ភ្នំចក្រវាឡផង ភ្នំហិមពាន្តផង តម្រៀបទុកក្នុងទីនេះ ហើយនឹងចេញអំពីភ្នំនោះៗ ទៅមិនឲ្យជាប់ ដូចជាមេហង្ស មហាជនឃើញខ្ញុំព្រះអង្គហើយ នឹងសួរថា "នុ៎ះជា

នរណា?" ហើយនឹងពោលថា "វីរសាមណេរី" ពួកតិរ្ថិយគិតគ្នាថា អានុភាព របស់សាមណេរីដែលមានអាយុ ៧ ខួប ដល់ម៉្លោះទៅហើយ ចំណង់បើអានុ-ភាពរបស់ព្រះពុទ្ធនឹងប្រាកដដូចម្តេចទៅ មិនចាំបាច់ឃើញព្រះអង្គឡើយ នឹងរត់ចេញទៅ ។ បន្ទាប់អំពីនេះទៅ គប្បីជ្រាបពាក្យបែបនេះ តាមទំនងដែលពោលហើយនោះចុះ ។ ព្រះដ៏មានព្រះភាគ ត្រាស់ទៅកាន់សាមណេរីនោះថា "តថាគតជ្រាបអានុភាពរបស់អ្នកហើយ លុះទ្រង់មានព្រះតម្រាស់ដូច្នោះហើយ ទ្រង់ក៏មិនអនុញ្ញាតឲ្យធ្វើបាដិហារ្យ ។

គ្រានោះ សាមណេរឈ្មោះចុន្ទៈ ដែលជាព្រះខីណាស្រព សម្រេចបដិ-សម្ភិទា មានអាយុ ៧ ខួប អំពីកំណើត ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ ត្រូវព្រះសាស្តាត្រាស់សួរថា "ម្នាលចុន្ទៈ អ្នកនឹងធ្វើដូចម្តេច?" ទើបក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងចាប់ដើមព្រីងធំ ដែលជាទង់នៃជម្ពូទ្វីបត្រង់ដើម ហើយអង្រួននាំផ្លែព្រីងធំមកឲ្យបរិស័ទទាំងនេះបរិភោគ និងព្រះអង្គនឹងនាំមកនូវផ្កាបារិច្ឆត្តព្រឹក្សទាំងឡាយ ថ្វាយព្រះអង្គ" ។ ព្រះសាស្តាត្រាស់ថា "តថាគតជ្រាបអានុភាពរបស់អ្នកហើយ ហើយក៏ទ្រង់ហាមការធ្វើនូវបាដិហារ្យរបស់សាមណេរ ។

លំដាប់នោះ ព្រះថេរីឈ្មោះឧប្បលវណ្ណា ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ" ព្រះសាស្តា

ត្រាស់សួរថា "ម្នាលឧប្បលវណ្ណា នាងនឹងធ្វើដូចម្តេច?" ក៏ក្រាបទូលថា ខ្ញុំព្រះអង្គនឹងសម្តែងបរិស័ទដែលមានប្រមាណ ១ យោជន៍ដោយជុំវិញ ជាស្តេចចក្រពត្តិ ត្រង់បរិស័ទមានប្រមាណ ៣៦ យោជន៍ហែហមហើយ មកថ្វាយបង្គំព្រះអង្គ" ។ ព្រះសាស្តាត្រាស់ថា តថាគតជ្រាបអានុភាពរបស់នាងហើយ ក៏ទ្រង់ហាមការធ្វើបាដិហារ្យ សូម្បីរបស់ព្រះថេររូបនោះ ។

លំដាប់នោះ ព្រះមហាមោគ្គល្លានត្ថេរ ថ្វាយបង្គំព្រះមានព្រះភាគហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ ព្រះសាស្តាត្រាស់សួរថា "ម្នាលមោគ្គល្លាន អ្នកនឹងធ្វើដូចម្តេច?" ក៏ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងយកស្តេចភ្នំឈ្មោះសិនេរុ ទុកក្នុងចន្លោះធ្មេញ ហើយទំពាភ្នំនោះឲ្យដូចជាទំពាគ្រាប់ស្ពៃ ។

ព្រះសាស្តា. អ្នកនឹងធ្វើអ្វីដទៃទៀត ?

មោគ្គល្លាន. ខ្ញុំព្រះអង្គនឹងមូរមហាប្រឹថពីនេះឲ្យដូចជាកន្ទេល ហើយគៀតទុកត្រង់ចន្លោះម្រាមដៃ ។

ព្រះសាស្តា. អ្នកនឹងធ្វើអ្វីដទៃទៀត ?

មោគ្គល្លាន. ខ្ញុំព្រះអង្គនឹងបង្វិលមហាប្រឹថពីឲ្យដូចជាបង្វិលកង់កាជនៈដីរបស់ស្មូនឆ្នាំង ហើយឲ្យមហាជនទំពាស៊ីឱជានៃផែនដី ។

ព្រះសាស្តា. អ្នកនឹងធ្វើអ្វីដទៃទៀត ?

មោគ្គល្លាន. ខ្ញុំព្រះអង្គនឹងធ្វើផែនដីទុកក្នុងដៃខាងឆ្វេង ហើយដាក់សត្វ

ទាំងនេះទុកក្នុងទ្វីបដទៃដោយដៃខាងស្តាំ ។

ព្រះសាស្តា. អ្នកនឹងធ្វើអ្វីដទៃទៀត ?

មោគ្គល្លាន. ខ្ញុំព្រះអង្គនឹងធ្វើភ្នំសិនេរុឲ្យជាដងឆត្រ ហើយលើកមហាប្រឹថពីឡើងដាក់ពួដ៏ខាងលើភ្នំសិនេរុនោះ យកដៃម្ខាងកាន់ ដូចជាភិក្ខុអ្នកមានឆត្រក្នុងដៃ ចង្ក្រមក្នុងអាកាស ។

ព្រះសាស្តាត្រាស់ថា "តថាគតជ្រាបអានុភាពរបស់អ្នកហើយ" ដូច្នេះហើយ ក៏ទ្រង់មិនអនុញ្ញាតការធ្វើបាដិហារ្យ សូម្បីរបស់ព្រះថេរៈនោះ ។ ព្រះថេរៈគិតថា "ប្រហែលជាព្រះសាស្តា ទ្រង់ជ្រាបអ្នកដែលអាចធ្វើបាដិហារ្យក្រៃលែងជាងយើងហើយ" លុះគិតដូច្នោះហើយ ក៏បានឋិតនៅក្នុងចំណែកម្ខាង ។

## ព្រះសាស្តាត្រាស់ហេតុមិនឱ្យសាវកសម្តែងបាដិហារ្យ

គ្រានោះ ព្រះសាស្តាត្រាស់ទៅកាន់ព្រះមហាមោគ្គល្លានថា "ម្នាលមោគ្គល្លាន កម្រងផ្កានេះគេមិនបានចងទុកដើម្បីអ្នកទេ ព្រោះថា តថាគតជាអ្នកមានធុរៈ រកបុគ្គលស្មើគ្មាន អ្នកដទៃឈ្មោះថា ជាអ្នកអាចនាំទៅនូវធុរៈរបស់តថាគតមិនមាន អ្នកដែលអាចនាំទៅនូវធុរៈរបស់តថាគតមិនមានទេ ក្នុងកាលឥឡូវនេះ ដោយហេតុណា ហេតុនុ៎ះមិនមែនជាអស្ចារ្យឡើយ សូម្បីក្នុងកាលដែលតថាគតកើតក្នុងកំណើតសត្វតិរច្ឆាន ដែលជាអហេតុកកំណើត អ្នកដទៃដែលអាចនាំទៅនូវធុរៈរបស់តថាគត ក៏មិនមានដូចគ្នា កាលព្រះថេរៈទូលសួរថា រឿងនោះមានហើយក្នុងកាលណា ព្រះអង្គ ? ទើបទ្រង់នាំអតីតនិទានមក

ត្រាស់កណ្ហឧសភជាតកឲ្យពិស្តារថា ៖

ធុរៈធ្ងន់មានហើយក្នុងទីណាៗ ផ្លូវទៅក្នុងទីដ៏ជ្រៅ មានហើយ ក្នុងទីណា ក្នុងកាលនោះឯង ពួកម្ចាស់របស់រមែងទឹមគោឈ្មោះ កណ្ហៈ គោឈ្មោះកណ្ហៈនោះឯង រមែងនាំធុរៈនោះទៅ ។

កាលទ្រង់សម្តែងរឿងនោះ ឲ្យពិស្តារក្រៃលែងតទៅទៀត ទើបត្រាស់ នន្ទវិសាលជាតកនេះ ឲ្យពិស្តារថា ៖

បុគ្គល គប្បីពោលពាក្យជាទីពេញចិត្តប៉ុណ្ណោះ មិនគប្បីពោល នូវពាក្យមិនជាទីពេញចិត្តក្នុងកាលណាៗ ឡើយ (ព្រោះ) កាល ព្រាហ្មណ៍ជាម្ចាស់ពោលនូវពាក្យជាទីពេញចិត្ត គោឈ្មោះនន្ទ-វិសាល នឹងនាំភារៈដ៏ធ្ងន់ទៅបាន ញុំាងព្រាហ្មណ៍នោះឲ្យបាន ទ្រព្យ ទាំងព្រាហ្មណ៍នោះ ក៏បានជាអ្នកមានចិត្តរីករាយ ព្រោះ ការបានទ្រព្យនោះ ។

លុះទ្រង់ត្រាស់រឿងនោះចប់ហើយ ទ្រង់ក៏ឡើងកាន់ទីចង្រ្កមកែវនោះ ។ ខាងមុខមានបរិស័ទប្រមាណ ១២ យោជន៍ ខាងក្រោយ ខាងឆ្វេង និងខាងស្តាំ ក៏ដូចគ្នា ចំណែកដោយត្រង់ មានប្រមាណ ២៤ យោជន៍ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើយមកបាដិហារ្យក្នុងកណ្តាលបរិស័ទ ។ យមកបាដិហារ្យនោះ បណ្ឌិត គប្បីជ្រាបតាមព្រះបាលីយ៉ាងនេះចុះ ។

## លក្ខណៈរបស់យមកប្បាដិហារ្យ

ញាណក្នុងយមកប្បាដិហារ្យរបស់ព្រះតថាគត តើដូចម្តេច? ព្រះតថាគតទ្រង់ធ្វើយមកប្បាដិហារ្យ ដែលមិនទូទៅដល់ពួកសាវកក្នុងលោកនេះ គឺផ្ការភ្លើងចេញអំពីព្រះកាយខាងលើ ផ្ការទឹកចេញអំពីកាយខាងក្រោម ផ្ការភ្លើងចេញអំពីកាយខាងក្រោម ផ្ការទឹកចេញអំពីកាយខាងលើ ផ្ការភ្លើងចេញអំពីព្រះកាយខាងមុខ ផ្ការទឹកចេញអំពីព្រះកាយខាងក្រោយ ផ្ការភ្លើងចេញអំពីព្រះកាយខាងក្រោយ ផ្ការទឹកចេញអំពីព្រះកាយខាងមុខ ផ្ការភ្លើងចេញអំពីព្រះនេត្រខាងស្តាំ ផ្ការទឹកចេញអំពីព្រះនេត្រខាងឆ្វេង ផ្ការភ្លើងចេញអំពីព្រះនេត្រខាងឆ្វេង ផ្ការទឹកចេញអំពីព្រះកាយខាងស្តាំ ផ្ការភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង ផ្ការភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ ផ្ការភ្លើងចេញអំពីរន្ធព្រះនាសិកខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះនាសិកខាងឆ្វេង ផ្ការភ្លើងចេញអំពីរន្ធព្រះនាសិកខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាងស្តាំ ផ្ការភ្លើងចេញអំពីចន្លុយព្រះអង្សាខាងស្តាំ ផ្ការទឹកចេញអំពីចន្លុយព្រះអង្សាខាងឆ្វេង ផ្ការភ្លើងចេញអំពីចន្លុយព្រះអង្សាខាងឆ្វេង ផ្ការទឹកចេញអំពីចន្លុយព្រះអង្សាខាងស្តាំ ផ្ការភ្លើងចេញអំពីព្រះហស្តខាងស្តាំ ផ្ការទឹកចេញអំពីព្រះហស្តខាងឆ្វេង ផ្ការភ្លើងចេញអំពីព្រះហស្តខាងឆ្វេង ផ្ការទឹកចេញអំពីព្រះហស្តខាងស្តាំ ផ្ការភ្លើងចេញអំពីព្រះពាហាខាងស្តាំ ផ្ការទឹកចេញអំពីព្រះពាហាខាងឆ្វេង ផ្ការភ្លើងចេញអំពីព្រះពាហាខាង

ឆ្វេង ផ្ការទឹកចេញអំពីព្រះពាហាខាងស្តាំ ផ្ការភ្លើងចេញអំពីព្រះបាទខាងស្តាំ ផ្ការទឹកចេញអំពីព្រះបាទខាងឆ្វេង ផ្ការភ្លើងចេញអំពីព្រះបាទខាងឆ្វេង ផ្ការទឹកចេញអំពីព្រះបាទខាងស្តាំ ផ្ការភ្លើងចេញអំពីព្រះអង្គុលីមួយៗ ផ្ការទឹកចេញអំពីចន្លោះនៃព្រះអង្គុលី ផ្ការភ្លើងចេញអំពីចន្លោះនៃព្រះអង្គុលី ផ្ការទឹកចេញអំពីព្រះអង្គុលីមួយៗ ផ្ការភ្លើងចេញអំពីរណ្តៅព្រះលោមាមួយៗ ផ្ការទឹកចេញអំពីសរសៃព្រះលោមាមួយៗ ផ្ការភ្លើងចេញអំពីសរសៃព្រះលោមាមួយៗ ផ្ការទឹកចេញអំពីរណ្តៅព្រះលោមាមួយៗ ។ រស្មីទាំងឡាយ រមែងប្រព្រឹត្តទៅដោយអំណាចនៃរស្មី ៦ ពណ៌ គឺ ពណ៌ខៀវ លឿង ក្រហម ស ហង្សបាទ និងពណ៌ផ្លេក ព្រះមានព្រះភាគទ្រង់ចង្ក្រម ព្រះពុទ្ធនិម្មិតទ្រង់ប្រថាប់ឈរ ឬទ្រង់ប្រថាប់អង្គុយ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ប្រថាប់ឈរ ព្រះពុទ្ធនិម្មិតទ្រង់ចង្ក្រម ឬទ្រង់ប្រថាប់អង្គុយ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ប្រថាប់អង្គុយ ព្រះពុទ្ធនិម្មិតទ្រង់ចង្ក្រម ឬទ្រង់ប្រថាប់ឈរ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ចង្ក្រម ឬទ្រង់ប្រថាប់ឈរ ឬទ្រង់ប្រថាប់អង្គុយ ព្រះពុទ្ធនិម្មិតទ្រង់ចង្ក្រម ព្រះមានព្រះភាគទ្រង់ប្រថាប់ឈរ ទ្រង់ប្រថាប់អង្គុយ ឬទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ប្រថាប់ឈរ ព្រះមានព្រះភាគទ្រង់ចង្ក្រម ឬទ្រង់ប្រថាប់អង្គុយ ឬទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ប្រថាប់អង្គុយ ព្រះមានព្រះភាគទ្រង់ចង្ក្រម ទ្រង់ប្រថាប់ឈរ ឬទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ចង្ក្រម ទ្រង់ប្រថាប់ឈរ ឬប្រថាប់អង្គុយ នេះឈ្មោះថា ញាណក្នុងយមកបាដិហារ្យរបស់

ព្រះតថាគត ។

ព្រះសាស្តាស្តេចទ្រង់ចង្រ្កមលើទីចង្រ្កមនោះ ទ្រង់ធ្វើបាដិហារ្យហើយដោយប្រការដូច្នេះ ។ ព្រះសារីបុត្តពោលថា “**ហេដ្ឋិមកាយតោ ឧបរិមកាយ-តោ**” ។ ដើម្បីនឹងសម្តែងនូវសេចក្តីនោះថា ផ្ការភ្លើងចេញអំពីព្រះកាយខាងលើ ដោយអំណាចតេជោកសិណសមាបត្តិរបស់ព្រះសាស្តា ផ្ការទឹកហូរចេញអំពីព្រះកាយខាងក្រោម ដោយអំណាចអាបោកសិណសមាបត្តិ ផ្ការភ្លើងរមែងផ្សាយចេញអំពីទីដែលផ្ការទឹកហូរចេញហើយទៀត ឯផ្ការទឹកក៏ផ្សាយចេញអំពីទីដែលផ្ការភ្លើងផ្សាយចេញហើយ ។ ន័យក្នុងបទទាំងពួង ក៏ដូច្នេះ ។ ក៏ក្នុងយមកបា្បដិហារ្យនេះ ផ្ការភ្លើងមិនបានលាយឡំនឹងផ្ការទឹកឡើយ ផ្ការទឹកក៏មិនបានលាយឡំនឹងផ្ការភ្លើងដែរ ក៏ន័យថា ផ្ការភ្លើង និងផ្ការទឹកទាំងពីរនេះ ផ្សាយឡើងដរាបដល់ព្រហ្មលោក និងផ្សាយទៅដល់កណ្តាប់ចក្រវាឡ ។ ក៏ព្រោះហេតុដែលព្រះសារីបុត្រពោលទុកថា “**ឆន្នំ វណ្ណានំ**” ព្រះរស្មីមានពណ៌ ៦ ប្រការ របស់ព្រះសាស្តានោះ ផ្សាយឡើងពេញផ្ទៃចក្រវាឡមួយ ដូចជាមាសរលាយដែលហូរចេញអំពីទ្បូ និងដូចជាផ្ការទឹកនៃមាស ដែលហូរចេញអំពីនាឡិយន្ត រហូតដល់ព្រហ្មលោក ហើយត្រឡប់មកកាន់កណ្តាប់ចក្រវាឡដូចដើម ។ ផ្ទៃចក្រនៃចក្រវាឡមួយ មានពន្លឺតែមួយ ដូចជាខឿននៃពោធិព្រឹក្សដែលគេចងព័ទ្ធហើយដោយបន្ទង់កោង ។ ក្នុងថ្ងៃនោះ ព្រះសាស្តាស្តេចទ្រង់ចង្រ្កម ទ្រង់ធ្វើ (យមកៈ) បាដិហារិយ៍ សម្តែងធម្មកថាដល់មហាជនជាចន្លោះៗ

ក៏កាលទ្រង់សម្តែង ទ្រង់មិនធ្វើមហាជនឲ្យមានជន្លើមតឹងទេ ទ្រង់បានប្រទាននូវជន្លើមដ៏ធូរក្រៃលែង ។ ក្នុងគ្រានោះ មហាជនញ៉ាំងសាធុការឲ្យប្រព្រឹត្តទៅហើយ ។ ក្នុងកាលដែលសាធុការនៃមហាជន កំពុងតែប្រព្រឹត្តទៅនោះ ព្រះសាស្តាទ្រង់រមិលមើលនូវចិត្តរបស់បរិស័ទដ៏ច្រើន ទ្រង់ជ្រាបវារៈចិត្តរបស់ជនម្នាក់ៗ ដោយអាការ ១៦ យ៉ាង ។ ចិត្តរបស់ព្រះពុទ្ធទាំងឡាយ ប្រព្រឹត្តទៅដោយរហ័សយ៉ាងនេះ ។ បុគ្គលឯណាៗ ជ្រះថ្លាក្នុងធម៌ណា និងក្នុងបាដិហារ្យណា ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់សម្តែងធម៌ និងទ្រង់សម្តែងនូវបាដិហារ្យដោយអំណាចអធ្យាស្រ័យនៃបុគ្គលនោះៗ ។ កាលព្រះអង្គទ្រង់សម្តែងធម៌និងទ្រង់សម្តែងបាដិហារ្យ ដោយអាការយ៉ាងនេះ ធម្មាភិសម័យបានកើតមានហើយដល់មហាជន ។ ព្រះសាស្តា ទ្រង់មិនឃើញបុគ្គលដទៃដែលអាចកាន់យកព្រះទ័យរបស់ព្រះអង្គ ហើយសួរបញ្ហាក្នុងសមាគមនោះ ទើបព្រះអង្គទ្រង់និម្មិតព្រះពុទ្ធនិម្មិត ។ ព្រះសាស្តាទ្រង់ដោះស្រាយនូវប្រស្នាដែលព្រះពុទ្ធនិម្មិតនោះ សួរហើយ ។ ព្រះពុទ្ធនិម្មិតនោះ ទ្រង់ដោះស្រាយនូវប្រស្នាដែលព្រះសាស្តាត្រាស់សួរហើយ ។ ក្នុងវេលាដែលព្រះមានព្រះភាពទ្រង់ចង្ក្រម ព្រះពុទ្ធនិម្មិតសម្រេចឥរិយាបថទាំងឡាយ មានឥរិយាបថឈរជាដើមណាមួយ ។ ក្នុងវេលាដែលព្រះពុទ្ធនិម្មិតចង្ក្រម ព្រះមានព្រះភាព ទ្រង់សម្រេចនូវឥរិយាបថទាំងឡាយ មានឥរិយាបថឈរជាដើមណាមួយ ។ ដើម្បីនឹងសម្តែងនូវសេចក្តីនោះ ព្រះធម្មសង្គាហកាចារ្យ ក៏ពោលពាក្យជាដើមថា “ព្រះពុទ្ធនិម្មិត ទ្រង់ចង្ក្រម

ខ្វះ" ជាដើម ។

ធម្មាភិសម័យ (កិរិយាត្រាស់ដឹងនូវលោកុត្តរធម៌) បានកើតមានដល់សត្វ ២០ កោដិ ក្នុងសមាគមនោះ ព្រោះឃើញបាដិហារ្យរបស់ព្រះសាស្ដាដែលទ្រង់ធ្វើយ៉ាងនោះ ព្រោះបានស្ដាប់ធម្មកថា ។

ព្រះសាស្ដាស្ដេចចាំវស្សានៅឋានតាវតិង្ស

ព្រះសាស្ដា កាលទ្រង់កំពុងធ្វើបាដិហារ្យនោះ ទ្រង់រំពឹងថា "ព្រះពុទ្ធក្នុងអតីតៈទាំងឡាយ ធ្វើបាដិហារ្យនេះហើយ ចាំវស្សានៅទីណាហ្ន៎" ទ្រង់ជ្រាបថា "ចាំវស្សាក្នុងភពតាវតិង្ស ហើយទ្រង់សម្ដែងអភិធម្មបិដកប្រោសព្រះពុទ្ធ-មាតា" ដូច្នេះហើយ ទ្រង់លើកព្រះបាទស្ដាំប្រថាប់ជាន់លើកំពូលភ្នំយុគន្ធរ ទ្រង់លើកព្រះបាទឆ្វេង ប្រថាប់លើកំពូលភ្នំសិនេរុ ។ វារៈនៃជំហានទាំងឡាយបីបានមានហើយក្នុងទី ៦៨ សែនយោជន៍ ដោយអាការយ៉ាងនេះ ។ ចន្លោះនៃព្រះបាទទាំងពីរ ជាចន្លោះមានកិរិយាដាក់ចុះ ប្រាកដស្មើដោយជំហាននៃព្រះបាទជាប្រក្រតី ។ នរណាៗ មិនគប្បីកំណត់ថា "ព្រះសាស្ដាទ្រង់សណ្ដូកព្រះបាទជាន់ហើយ" ព្រោះក្នុងពេលដែលព្រះអង្គ ទ្រង់លើកព្រះបាទឡើង ភ្នំទាំងនោះ ក៏មកកាន់ទីជិតព្រះបាទទទួលហើយ ក្នុងវេលាដែលព្រះសាស្ដាទ្រង់ប្រថាប់ជាន់ហើយ ភ្នំទាំងនោះក៏តាំងនៅក្នុងទីដើមវិញ ។ សក្កទេវរាជទ្រង់ទតឃើញហើយទ្រង់គិតថា "អើហ្ន៎ ព្រះសាស្ដា ទ្រង់នឹងចាំវស្សាត្រង់កណ្ដាលបណ្ឌុកម្ពលសិលា (សិលាមានសណ្ឋានដូចជាសំពត់កម្ពលពណ៌លឿង) ឧបការៈ

នឹងមានដល់ពួកទេវតាដ៏ច្រើនហ្ន៎" តែថា កាលព្រះសាស្ដាទ្រង់ចាំវស្សានៅទីនោះ ពួកទេវតាដទៃៗ មិនអាចដាក់ដៃបាន ។ ឯបណ្ឌុកម្ពលសិលានេះ មានបណ្ដោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្រាស់ ១៥ យោជន៍ កាលព្រះសាស្ដាទ្រង់ប្រថាប់អង្គុយហើយ ក៏នឹងក្លាយទៅជារបស់ទទេ ។ ព្រះសាស្ដាទ្រង់ជ្រាបអធ្យាស្រ័យរបស់សក្កទេវរាជ ទ្រង់បោះសង្ឃាដីរបស់ព្រះអង្គ ទៅគ្របជិតផ្ទៃសិលានោះ ។ សក្កទេវរាជ ទ្រង់ព្រះតម្រិះថា "ព្រះសាស្ដាទ្រង់បោះសង្ឃាដីមកគ្របមុន ក៏ព្រះអង្គនឹងទ្រង់ប្រថាប់គង់ក្នុងទីមានប្រមាណតិចដោយព្រះអង្គឯង" ។ ព្រះសាស្ដា ទ្រង់ជ្រាបអធ្យាស្រ័យរបស់សក្កទេវរាជ ទ្រង់ក៏ប្រថាប់អង្គុយ ធ្វើបណ្ឌុកម្ពលសិលាឲ្យនៅក្នុងផ្នត់ចីវរនោះឯង ដូចជាភិក្ខុអ្នកទ្រទ្រង់នូវមហាចីវរបង្សុកូល ប្រថាប់ធ្វើនូវតាំងដ៏ទាប ឲ្យនៅតែក្នុងផ្នត់ចីវរនោះ ។ ខណៈនោះឯង មហាជនរកមើលព្រះសាស្ដាក៏មិនឃើញ ។ កាលនោះ ប្រៀបដូចជាកាលនៃព្រះច័ន្ទអស្ដង្គតហើយផង និងប្រៀបដូចជាកាលនៃព្រះអាទិត្យអស្តង្គតហើយផង ។ មហាជនក៏ខ្សឹកខ្សួលពោលនូវគាថានេះថា ៖

> ព្រះសាស្ដាស្ដេចយាងទៅកាន់ភ្នំចិត្រកូដ ឬក៏យាងទៅកាន់
> ភ្នំកៃលាស ឬក៏ស្ដេចយាងទៅកាន់ភ្នំយុគន្ធរ យើងទាំងឡាយ
> មិនឃើញព្រះសម្ពុទ្ធជាម្ចាស់ដែលជាលោកជេដ្ឋៈ ទ្រង់ប្រសើរ
> ជាងនរៈ ។

មួយពួកទៀត ខ្សឹកខ្សួលថា "ឈ្មោះថា ព្រះសាស្ដា ព្រះអង្គទ្រង់ត្រេកអរ

ហើយក្នុងវិវេក ព្រះអង្គស្ដេចនឹងយាងទៅកាន់ដែនដទៃ ឬជនបទដទៃហើយ ព្រោះទ្រង់ខ្មាស់ថា "តថាគតធ្វើបាដិហារ្យបែបនេះ ដល់បរិស័ទបែបនេះ" ឥឡូវនេះ យើងទាំងឡាយនឹងមិនបានឃើញព្រះអង្គទៀតទេ" ដូច្នេះ ហើយពោលគាថានេះថា ៖

ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់ត្រេកអរហើយក្នុងវិវេក ស្ដេចនឹងមិនត្រឡប់មកកាន់លោកនេះទៀតទេ យើងទាំងឡាយនឹងមិនឃើញព្រះសម្ពុទ្ធជាម្ចាស់ ដែលជាលោកជេដ្ឋៈ ទ្រង់ប្រសើរជាងនរៈ ។

ជនទាំងនោះ សួរព្រះមោគ្គល្លានថា "ព្រះសាស្ដាស្ដេចយាងទៅទីណា លោកម្ចាស់" សូម្បីលោកជ្រាប ក៏ពោលថា "ចូរសួរព្រះអនុរុទ្ធចុះ" ដោយបំណងថា "គុណរបស់សាវកដទៃៗ ក៏ប្រាកដ" ដូច្នេះ ។ ជនទាំងនោះសួរព្រះថេរៈយ៉ាងនេះថា "លោកម្ចាស់ ព្រះសាស្ដាស្ដេចយាងទៅកាន់ទីណា?" ។

ព្រះអនុរុទ្ធ. ស្ដេចទៅចាំវស្សានៅនាបណ្ឌុកម្ពលសិលា ក្នុងភពតាវតិង្សហើយទ្រង់សម្ដែងអភិធម្មបិដកប្រោសព្រះមាតា ។

មហាជន. លោកម្ចាស់ ស្ដេចនឹងត្រឡប់មកវិញនៅពេលណា ?

ព្រះអនុរុទ្ធ. ទ្រង់សម្ដែងអភិធម្មបិដករហូត ៣ ខែហើយ ទើបស្ដេចនឹងត្រឡប់មកវិញ ក្នុងថ្ងៃមហាបវារណា ។

ជនទាំងនោះគិតគ្នាថា "ប្រសិនបើពួកយើងមិនបានឃើញព្រះសាស្ដា

ទេ នឹងមិនទៅ” លុះគិតដូច្នេះហើយ ក៏បានធ្វើទីស្នាក់អាស្រ័យនៅក្នុងទីនោះឯង ។ បានឮថា ជនទាំងនោះ មានអាកាសជាគ្រឿងប្រក់ ជាគ្រឿងបិទបាំង ឈ្មោះថា ញើសហូរចេញចាកសរីរៈនៃបរិស័ទដ៏ច្រើននោះ មិនបានប្រាកដ ។ ផែនដីបានឲ្យនូវចន្លោះហើយ ។ ផ្ទៃផែនដីក្នុងទីទាំងឡាយ មានផ្ទៃដ៏ស្អាត ។ ព្រះសាស្ដា មុននឹងព្រះអង្គស្ដេចយាងទៅកាន់កពតាវតិង្ស ព្រះអង្គទ្រង់ត្រាស់នឹងព្រះមហាមោគ្គល្លានដូច្នេះថា “ម្នាលមោគ្គល្លាន អ្នកគប្បីសម្ដែងធម៌ដល់បរិស័ទ ចុល្លអនាថបិណ្ឌិកនឹងឲ្យនូវអាហារ” ។ ព្រោះហេតុនោះ ចុល្លអនាថ-បិណ្ឌិកនោះឯង បានឲ្យហើយនូវបបរ កត្ត របស់ទំពា គ្រឿងក្រអូប កម្រងផ្កា និងគ្រឿងតាក់តែងទាំងឡាយ ដល់បរិស័ទទាំងនោះគ្រប់កាលទាំងពួង ទាំងពេលព្រឹក និងពេលល្ងាច រហូត ៣ ខែ ។ ព្រះមហាមោគ្គល្លានសម្ដែងធម៌ហើយដោះស្រាយនូវបញ្ហា ដល់ពួកជនមកដើម្បីមើលនូវបាដិហារ្យសាកសួរ ។

ព្រះសម្ពុទ្ធរុងរឿងកណ្ដាលពួកទេវតា

ទេវតាក្នុងម៉ឺនចក្រវាឡ ចោមរោមព្រះសាស្ដា ដែលទ្រង់ចាំវស្សានាបណ្ឌុកម្ពលសិលា ដើម្បីសម្ដែងអភិធម្មដល់ព្រះមាតា ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលដូច្នេះថា ៖

ក្នុងកាលណា ព្រះពុទ្ធ ដែលជាកំពូលបុរសទ្រង់ប្រថាប់លើ
បណ្ឌុកម្ពលសិលា ត្រង់ក្រោមដើមបារិច្ឆត្តកៈ ក្នុងកពតាវ-
តិង្ស ក្នុងកាលនោះ ទេវតាទាំងឡាយក្នុងម៉ឺនលោកធាតុប្រជុំ

ព្រមគ្នាហើយ ចូលគាល់ព្រះសម្មាសម្ពុទ្ធ ដែលប្រថាប់គង់លើ
កំពូលភ្នំ គ្មានទេវតាអង្គណាមួយ រុងរឿងជាងព្រះសម្ពុទ្ធដោយ
វណ្ណៈឡើយ ព្រះសម្ពុទ្ធប៉ុណ្ណោះ រមែងរុងរឿងជាងពួកទេវតា
ទាំងអស់ ។

ក៏កាលព្រះសាស្តាអង្គនោះ ទ្រង់គ្របសង្កត់នូវទេវតាទាំងពួង ដោយព្រះរស្មីដែលផ្សាយចេញអំពីព្រះសរីរៈរបស់ព្រះអង្គ ហើយទ្រង់ប្រថាប់គង់នៅយ៉ាងនេះ ព្រះពុទ្ធមាតាស្តេចមកអំពីតុសិតវិមាន ទ្រង់គង់នៅក្នុងចំណែកខាងស្តាំ ។ សូម្បីឥន្ទកទេវបុត្រ ក៏មកគង់នៅក្នុងចំណែកខាងស្តាំដូចគ្នា ។ ឯអង្កុរទេវបុត្រមកគង់នៅក្នុងចំណែកខាងឆ្វេង ។ អង្កុរទេវបុត្រនោះ កាលពួកទេវតាទាំងឡាយអ្នកមានសក្តិធំមកប្រជុំគ្នាហើយ ក៏ថយទៅរហូត ១២ យោជន៍អំពីព្រះសម្មាសម្ពុទ្ធ ។ ឥន្ទកទេវបុត្រ ក៏អង្គុយនៅក្នុងទីនោះឯង ។ ព្រះសាស្តាទ្រង់ទតនូវទេវបុត្រទាំងពីរនោះហើយ មានព្រះបំណងនឹងញ៉ាំងបរិស័ទឲ្យដឹងនូវភាវៈនៃទាន ដែលបុគ្គលឲ្យហើយដល់ទក្ខិណេយ្យបុគ្គលក្នុងសាសនារបស់ព្រះអង្គ ជាកុសលមានផលច្រើន ទើបត្រាស់យ៉ាងនេះថា “ម្នាលអង្កុរៈ អ្នកធ្វើនូវជួរនៃជើងក្រានប្រមាណ ១២ យោជន៍ ឲ្យទានជាច្រើន ក្នុងកាលអ្នកនៅមនុស្ស មានអាយុមួយម៉ឺនឆ្នាំ ក្នុងចន្លោះកាលដ៏វែង ឥឡូវនេះ អ្នកមកកាន់សមាគមរបស់តថាគត បានឱកាសក្នុងទីប្រមាណ ១២ យោជន៍ ដែលឆ្ងាយជាងទេវបុត្រទាំងអស់ អ្វីហ្ន៎ ជាហេតុក្នុងរឿងនេះ?” ពិតណាស់ ព្រះធម្មស-

ន្តាហកាចារ្យទាំងឡាយ ក៏បានពោលទុកដូច្នេះថា ៖

ព្រះសម្ពុទ្ធ ទ្រង់ទតអង្កុរទេវបុត្រ និងឥន្ទកទេវបុត្រហើយ
កាលនឹងទ្រង់សរសើរទក្ខិណេយ្យបុគ្គលបានត្រាស់ព្រះពុទ្ធ-
វចនៈនេះថា ម្នាលអង្កុរៈ អ្នកឲ្យទានដ៏ច្រើនក្នុងចន្លោះកាល
ដ៏វែង អ្នកកាលមកកាន់សម្នាក់របស់តថាគត អង្គុយក្នុង
ទីឆ្ងាយយ៉ាងក្រៃលែង ។

ព្រះសាស្តាត្រាស់ឱ្យឮដល់មនុស្សលោក

ព្រះសូរសៀងនោះ ( ឮ ) ពេញផែនដី ។ បរិស័ទទាំងអស់ បានឮព្រះសូរសៀងនោះ ។ កាលព្រះសាស្តាត្រាស់យ៉ាងនោះហើយ អង្កុរទេវបុត្រដែល ព្រះមានព្រះភាគ ទ្រង់មានព្រះកាយអប់រំហើយ ទ្រង់ជាស់តឿនហើយបានក្រាបទូលពាក្យនេះថា ៖

ទានដែលសូន្យចាកទក្ខិណេយ្យបុគ្គល នឹងមានប្រយោជន៍អ្វី
ដល់ខ្ញុំព្រះអង្គ យក្ស(១) ឈ្មោះឥន្ទកៈនេះ ថ្វាយទានតិចតួច
រមែងរុងរឿងក្រៃលែងជាងខ្ញុំព្រះអង្គ ដូចជាព្រះច័ន្ទក្នុងហ្វូង
តារា ។

បណ្តាបទទាំងនោះ បទថា ទជ្ជា កែជា ទត្វា ប្រែថា ឲ្យហើយ ។

---

១.ទេវបុត្រដែលបុគ្គលគប្បីបូជា។

កាលអង្កុរទេវបុត្រពោលយ៉ាងនោះហើយ ព្រះសាស្តាត្រាស់សួរឥន្ទកទេវបុត្រថា "ឥន្ទកៈ អ្នកអង្គុយក្នុងចំណែកខាងស្តាំតថាគត ព្រោះហេតុអ្វីទើបអ្នកមិនឃ្លាតចេញ នៅអង្គុយក្នុងទីនោះដដែល?" ឥន្ទកទេវបុត្រក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពីព្រោះខ្ញុំព្រះអង្គបានទទួលទក្ខិណេយ្យសម្បត្តិ ដូចអ្នកស្រែ ព្រោះពូជតិចតួចក្នុងស្រែដែលល្អ ដូច្នោះ" ដូច្នេះហើយ កាលនឹងប្រកាសទក្ខិណេយ្យបុគ្គល ទើបក្រាបទូលថា ៖

ពូជសូម្បីមានច្រើន ដែលបុគ្គលព្រោះហើយក្នុងស្រែទួល
ផល រមែងមិនសម្បូរណ៍ ទាំងមិនញ៉ាំងអ្នកស្រែឲ្យត្រេកអរ
យ៉ាងណា ទានមានប្រមាណច្រើន ដែលបុគ្គលតាំងទុកក្នុង
ពពួកជនអ្នកទ្រុស្តសីល ផលរមែងមិនសម្បូរណ៍ ទាំងមិន
បានញ៉ាំងទាយកឲ្យត្រេកអរ ដូច្នោះដូចគ្នា ពូជសូម្បីតិចតួច
ដែលបុគ្គលព្រោះហើយក្នុងស្រែល្អ កាលភ្លៀងបង្អូរធ្លាកទឹក
មកដោយប្រពៃ (តាមកាល) ផល ក៏រមែងញ៉ាំងអ្នកស្រែឲ្យ
ត្រេកអរបាន យ៉ាងណា កាលសក្ការៈសូម្បីតិចតួច ដែល
ទាយកធ្វើហើយចំពោះបុគ្គលអ្នកមានសីល អ្នកមានគុណ
ទាំងឡាយ ផល ក៏រមែងញ៉ាំងទាយកឲ្យត្រេកអរបាន យ៉ាង
នោះដូចគ្នា ។

ទានដែលឲ្យចំពោះទក្ខិណេយ្យបុគ្គល មានផលច្រើន

សួរថា “បុព្វកម្មរបស់ឥន្ទកទេវបុត្រនុ៎ះ ដូចម្ដេច?” ។

ឆ្លើយថា “បានឮថា ឥន្ទកទេវបុត្រនោះ បានថ្វាយភិក្ខាមួយវែកដែលគេនាំមកដើម្បីខ្លួន ចំពោះព្រះអនុរុទ្ធ ដែលចូលទៅបិណ្ឌបាតក្នុងស្រុក ។ បុណ្យរបស់ឥន្ទកទេវបុត្រនោះ មានផលច្រើនជាងទាន ដែលអង្កុរទេវបុត្រធ្វើដោយជួរនៃជើងក្រានប្រមាណ ១២ យោជន៍ ឲ្យហើយអស់មួយម៉ឺនឆ្នាំ ព្រោះហេតុនោះ ទើបឥន្ទកទេវបុត្រក្រាបទូលយ៉ាងនោះ” ។ កាលឥន្ទកទេវបុត្រក្រាបទូលយ៉ាងនោះហើយ ព្រះសាស្ដាក៏ត្រាស់ថា “អង្កុរៈ ការពិចារណាហើយសឹមឲ្យទាន ទើបគួរ ទាននោះ រមែងមានផលច្រើនដោយអាការយ៉ាងនេះ ដូចពូជដែលគេព្រោះដោយល្អក្នុងស្រែល្អ ដូច្នោះ តែអ្នកមិនបានធ្វើយ៉ាងនោះ ព្រោះហេតុនោះ ទើបទានរបស់អ្នកមិនមានផលច្រើន” កាលទ្រង់ប្រកាសសេចក្ដីនេះឲ្យជាក់ច្បាស់ ទើបត្រាស់ដូច្នេះថា ៖

ទានដែលបុគ្គលឲ្យហើយក្នុងខេត្តណា មានផលច្រើន បុគ្គលគប្បីពិចារណាឲ្យទានក្នុងខេត្តនោះ ការពិចារណាហើយឲ្យ ព្រះសុគតទ្រង់សរសើរហើយ ទានដែលបុគ្គលឲ្យហើយ ក្នុងទក្ខិ-ណេយ្យបុគ្គលទាំងឡាយ ដែលមាននៅក្នុងលោក គឺ ពួកសត្វដែលមានជីវិត មានផលច្រើន ដូចពូជដែលបុគ្គលព្រោះហើយក្នុងស្រែល្អ ដូច្នោះ ។

កាលនឹងទ្រង់សម្ដែងធម៌ឲ្យក្រៃលែង ទើបបានត្រាស់ព្រះគាថាទាំងនេះថា ៖

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វមានរាគៈជាទោស ព្រោះហេតុនោះ ទាន ដែលបុគ្គលឲ្យហើយចំពោះបុគ្គលអ្នកមានរាគៈទៅប្រាសហើយទាំងឡាយ ទើបមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វមានទោសៈជាទោសព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយចំពោះបុគ្គលអ្នកមានទោសៈ ទៅប្រាសហើយទាំងឡាយ ទើបមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វមានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយចំពោះបុគ្គលអ្នកមានមោហៈទៅប្រាសហើយទាំងឡាយ ទើបមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះ មានសេចក្ដីប្រាថ្នាជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយចំពោះបុគ្គលអ្នកមានសេចក្ដីប្រាថ្នា ទៅប្រាសទាំងឡាយ ទើបមានផលច្រើន ។

ក្នុងកាលចប់ទេសនា អង្កុរទេវបុត្រ និងឥន្ទកទេវបុត្រ ក៏បានសម្រេចសោតាបត្តិផល ។ (ព្រះធម្មទេសនា មានប្រយោជន៍សួម្បីមហាជន ដូច្នេះ) ។

## ព្រះសាស្តាស្តេចទៅទ្រោសព្រះមាតានៅឋានតាវត្តិង្ស

គ្រានោះ ព្រះសាស្តាទ្រង់ប្រថាប់គង់កណ្តាលទេវបរិស័ទ ទ្រង់ប្រារព្ធព្រះមាតា ផ្តើមអភិធម្មបិដកថា "កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា" (ធម៌ទាំងឡាយជាកុសល ធម៌ទាំងឡាយជាអកុសល ធម៌ទាំងឡាយជាអព្យាកត) ដូច្នេះជាដើម ។ ទ្រង់សម្តែងអភិធម្មបិដក ដោយន័យនេះរៀងទៅ រហូតមិនមានចន្លោះ អស់ ៣ ខែ ។ ក៏កាលទ្រង់សម្តែងធម៌ ក្នុងវេលាភិក្ខាចារ ទ្រង់និម្មិតព្រះពុទ្ធនិម្មិត ដោយទ្រង់អធិដ្ឋានថា "ពុទ្ធនិម្មិតនេះ ចូរសម្តែងធម៌មានប្រមាណប៉ុនណា ដរាបតថាគតមក" ហើយស្តេចទៅកាន់ព្រៃហិមពាន្ត ទ្រង់ជម្រះព្រះទន្តដោយឈើស្ទន់ឈ្មោះនាគលតា ទ្រង់លប់លាង (ព្រះភក្ត្រ) ឯអនោត្តតស្រះ ទ្រង់នាំបិណ្ឌបាតមកអំពីឧត្តរកុរុទ្វីប ទ្រង់ប្រថាប់គង់ធ្វើភត្តកិច្ចនៅក្នុងរោងដ៏ធំ ។ ព្រះសារីបុត្ត ទៅធ្វើវត្តចំពោះព្រះសាស្តានៅទីនោះ ។ ព្រះសាស្តាទ្រង់ធ្វើភត្តស្រេចកិច្ចហើយ ត្រាស់ទៅកាន់ព្រះថេរៈថា "ម្នាលសារីបុត្រ ថ្ងៃនេះតថាគតភាសិតធម៌បានប្រមាណប៉ុនណា អ្នកចូរយកទៅប្រាប់ (ភិក្ខុ ៥០០) ដែលជាសិស្សរបស់អ្នកចុះ" ។ បានឮថា កុលបុត្រ ៥០០ រូប ជ្រះថ្លានឹងយមកបាដិហារ្យ បួសហើយក្នុងសម្នាក់របស់ព្រះសារីបុត្រ ។ ព្រះសាស្តាត្រាស់យ៉ាងនោះ ទ្រង់សំដៅយកភិក្ខុទាំងនោះ ។ លុះត្រាស់ដូច្នេះហើយ ស្តេចក៏ទៅកាន់ទេវលោក ទ្រង់សម្តែងព្រះធម៌តពីព្រះពុទ្ធនិម្មិតសម្តែង ។ រីឯព្រះថេរៈ ក៏ទៅសម្តែងធម៌ប្រាប់ភិក្ខុទាំងនោះ ។ ភិក្ខុទាំង

នោះ កាលព្រះមានព្រះភាគទ្រង់ប្រថាប់នៅក្នុងទេវលោកនោះឯង បានជាអ្នកជំនាញក្នុងបករណ៍ទាំង ៧ ។ បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ ភិក្ខុទាំងនោះជាសត្វប្រចៀវតូច រស់នៅក្នុងញកភ្នំមួយ កាលព្រះថេរៈ ២ រូបចង្រ្កម ហើយស្វាធ្យាយព្រះអភិធម្ម ស្តាប់ហើយ កាន់យកនិមិត្តក្នុងសំឡេងនោះ សត្វប្រចៀវទាំងនោះ មិនដឹងថា "ទាំងនេះឈ្មោះថា ជាខន្ធ ទាំងនេះឈ្មោះថា ជាធាតុ ឡើយ" ដោយហេតុត្រឹមតែការកាន់យកនិមិត្តក្នុងសំឡេងប៉ុណ្ណោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយទិព្វសម្បត្តិអស់មួយចន្លោះព្រះពុទ្ធ ចុតិចាកទេវលោកហើយ កើតក្នុងត្រកូលនៅក្នុងក្រុងសាវត្ថី កើតសេចក្តីជ្រះថ្លាក្នុងយមកប្បដិហារ្យ បួសក្នុងសម្នាក់ព្រះថេរៈ ហើយបានជាអ្នកជំនាញក្នុងបករណ៍ទាំង ៧ មុនភិក្ខុទាំងពួង ។ សូម្បីព្រះសាស្តាទ្រង់សម្តែងអភិធម្មអស់ត្រៃមាស តាមទំនងនោះឯង រហូតអស់ ៣ ខែ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ធម្មាភិសម័យ បានកើតមានដល់ទេវតា ៨ ម៉ឺនកោដិ ។ សូម្បីព្រះមហាមាយា ក៏តាំងនៅក្នុងសោតាបត្តិផល ។

## ព្រះមហាមោគ្គល្លានឡើងទៅទូលសួរដំណើរស្តេចនិងចុះ

បរិស័ទមានប្រមាណ ៣៦ យោជន៍នោះ បានគិតគ្នាថា "តិថីនៃមហាបវារណានឹងមានក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះទៅ" លុះគិតដូច្នោះហើយ ក៏ចូលទៅរកព្រះមហាមោគ្គល្លាន ហើយពោលថា "លោកម្ចាស់ដ៏ចម្រើន យើងទាំងឡាយគួរដឹងនូវថ្ងៃដែលស្តេចចុះទេវលោករបស់ព្រះសាស្តា ព្រោះថា បើខ្ញុំព្រះ

ករុណាទាំងឡាយ មិនបានឃើញព្រះសាស្តាទេ នឹងមិនទៅណាឡើយ" ។ ព្រះមហាមោគ្គល្លានស្តាប់ពាក្យនោះហើយ ទទួលថា "សាធុ ប្រពៃហើយ" ហើយមុជចុះក្នុងផែនដីក្នុងទីនោះឯង អធិដ្ឋានថា "បរិស័ទចូរឃើញយើង ដែលទៅដល់ជើងភ្នំសិនេរុ ហើយឡើងទៅ" មានរូបប្រាកដដូចជាចេសនៃសម្ពត់កម្ពលពណ៌លឿង ដែលគេដោតចូលទៅក្នុងកែវមណីរតន៍ ឡើងទៅហើយដល់ពាក់កណ្តាលភ្នំសិនេរុ ។ សូម្បីពួកមនុស្សក៏បានឃើញព្រះថេរៈ "ព្រះថេរៈឡើងទៅបាន ១ យោជន៍ហើយ ឡើងទៅបាន ២ យោជន៍ហើយ" ដូច្នេះជាដើម ឯព្រះថេរៈឡើងទៅ ថ្វាយបង្គំព្រះយុគលបាទរបស់ព្រះមានព្រះភាគ ដូចជាទូលដោយព្រះសីសៈ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន បរិស័ទសុទ្ធតែប្រាថ្នានឹងគាល់ព្រះអង្គ ហើយទើបទៅ ព្រះអង្គស្តេចនឹងចុះចាកទេវលោកនៅពេលណា?" ។

ព្រះសាស្តា. មោគ្គល្លាន តើសារីបុត្របងប្រុសរបស់អ្នកនៅទីណា?

មោគ្គល្លាន. ព្រះអង្គដ៏ចម្រើន លោកចាំវស្សានៅសង្កស្សនគរ ។

ព្រះសាស្តា. មោគ្គល្លាន ក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះទៅ តថាគតនឹងចុះត្រង់ក្បែរទ្វារក្រុងសង្កស្សៈ ក្នុងថ្ងៃមហាបវារណា ជនទាំងឡាយឯណាប្រាថ្នានឹងគាល់តថាគត ក៏ចូរទៅកាន់ទីនោះចុះ ឯពីសង្កស្សនគរទៅក្រុងសាវត្ថីមានប្រមាណ ៣០ យោជន៍ ក្នុងរយៈផ្លូវប៉ុណ្ណោះ កិច្ចដែលនឹងត្រូវត្រៀមស្បៀងរមែងមិនមានដល់អ្នកណា ៗ អ្នកគប្បីប្រាប់ជនទាំងនោះថា "អ្នកទាំងឡាយ ចូរ

រក្សាឧបោសថ ដូចទៅកាន់វិហារដែលជិត ដើម្បីស្តាប់ធម៌ចុះ ។

ព្រះសម្ពុទ្ធអង្គទ្រង់បើកលោក

ព្រះថេរៈទូលថា "ព្រះករុណា ព្រះអង្គ" ហើយបានប្រាប់បរិស័ទទាំងនោះ តាមព្រះពុទ្ធតម្រាស់" ។ ព្រះសាស្តាស្តេចចាំវស្សា ទ្រង់បវារណាហើយ ត្រាស់ប្រាប់សក្កទេវរាជថា "មហារាជ តថាគតនឹងទៅកាន់ឋានមនុស្សវិញ" ។ សក្កទេវរាជទ្រង់និម្មិតជណ្តើរ ៣ ប្រភេទ គឺ ជណ្តើរមាស ជណ្តើរកែវមណី ជណ្តើរប្រាក់ ។ ជើងជណ្តើរទាំងនោះ តាំងនៅត្រង់ទ្វារនៃសង្កស្សនគរ ឯក្បាលជណ្តើរតាំងនៅលើកំពូលភ្នំសិនេរុ បណ្តាជណ្តើរទាំងនោះ ជណ្តើរមាសនៅខាងស្តាំ ដើម្បីពួកទេវតា, ជណ្តើរប្រាក់នៅខាងឆ្វេង សម្រាប់មហាព្រហ្មទាំងឡាយ, ជណ្តើរកែវមណីនៅត្រង់កណ្តាល សម្រាប់ព្រះសម្ពុទ្ធ ។ ព្រះសាស្តាទ្រង់ប្រថាប់ឈរនៅលើកំពូលភ្នំសិនេរុ ទ្រង់សម្តែងយមកប្បាដិហារ្យ ក្នុងកាលដែលស្តេចយាងចុះចាកទេវលោក ទ្រង់ទតទៅខាងលើ ត្រង់ទីដែលព្រះអង្គទ្រង់ទតហើយ ក៏មានចន្លោះតែមួយ រហូតដល់ព្រហ្មលោក, ទ្រង់ទតទៅខាងក្រោម ត្រង់ទីដែលព្រះអង្គទ្រង់ទតហើយនោះ ក៏មានចន្លោះតែមួយ រហូតដល់អវិចី, ទ្រង់ទតទិសធំ និងទិសតូចទាំងឡាយ, ចក្រវាឡច្រើនសែន ក៏មានចន្លោះតែមួយ, ទេវតាឃើញពួកមនុស្ស សូម្បីពួកមនុស្សក៏ឃើញពួកទេវតា ។ ពួកទេវតា និងពួកមនុស្សទាំងអស់ ម្នាក់ៗ ឃើញគ្នាចំពោះមុខតែម្តង ។ ព្រះមានព្រះភាគ ទ្រង់ផ្សាយព្រះឆព្វណ្ណរង្សីទៅហើយ ។ មនុស្សនៅក្នុងបរិស័ទដែល

មានប្រមាណ ៣៦ យោជន៍ សូម្បីតែម្នាក់ កាលមើលនូវពុទ្ធសិរីរបស់ព្រះពុទ្ធក្នុងថ្ងៃនោះហើយ ដែលថា មិនប្រាថ្នានូវភាពជាព្រះពុទ្ធមិនមានឡើយ ។ ពួកទេវតាចុះតាមជណ្ដើរមាស, ពួកមហាព្រហ្មចុះតាមជណ្ដើរប្រាក់, ព្រះសម្មាសម្ពុទ្ធស្ដេចយាងចុះតាមជណ្ដើរកែវមណី ។ ទេវបុត្រអ្នកកំណាព្យឈ្មោះបញ្ចសិខៈកាន់ពិណពណ៌លឿងដូចផ្លែព្នៅ ឈរនៅខាងស្ដាំបូជាព្រះសម្មាសម្ពុទ្ធដោយការរាំចុះមក មាតលិសង្គាហកទេវបុត្រឈរនៅខាងឆ្វេង កាន់គ្រឿងក្រអូបនិងកម្រងផ្កាដែលមានក្លិនទិព្វ នមស្ការ ធ្វើការបូជាព្រះសម្មាសម្ពុទ្ធហើយចុះមក ។ មហាព្រហ្មបាំងឆត្រ, សុយាមកាន់ផ្លិតវាលវិជនី ។ ព្រះសាស្ដាស្ដេចយាងចុះ ព្រមដោយបរិវារនេះ ទ្រង់ប្រតិស្ឋានត្រង់ទ្វារសង្កស្សនគរ ។ ចំណែកព្រះសារីបុត្តត្ថេរ ក៏មកថ្វាយបង្គំព្រះសម្មាសម្ពុទ្ធដែរ ព្រោះព្រះសាស្ដាស្ដេចចុះមកដោយពុទ្ធសិរីបែបនេះ លោកមិនធ្លាប់បានឃើញក្នុងកាលមុន ព្រោះហេតុនោះ ទើបលោកប្រកាសសេចក្ដីត្រេកអររបស់ខ្លួន ដោយគាថាទាំងឡាយមានជាដើមថា ៖

ព្រះសាស្ដា ទ្រង់មានព្រះសូរសៀងដ៏ពីរោះ ទ្រង់ជាអាចារ្យនៃគណៈ ស្ដេចយាងមកអំពីភពឈ្មោះតុសិតបែបនេះ យើងមិនដែលឃើញ ឬមិនដែលបានឮអំពីអ្នកណា ក្នុងកាលមុនឡើយ ។

ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះទេវតា និងមនុស្ស

ទាំងអស់ រមែងស្រឡាញ់ រមែងប្រាថ្នាចំពោះព្រះអង្គ” ។

លំដាប់នោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់នឹងព្រះសារីបុត្រថា “សារីបុត្រ ឈ្មោះថា ព្រះពុទ្ធអ្នកប្រកបព្រមដោយគុណបែបនេះ រមែងជាទីស្រឡាញ់នៃទេវតា និងមនុស្សទាំងឡាយដោយពិត” ។ កាលទឹងទ្រង់សម្តែងធម៌ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖

២. យេ ឈានបសុតា ធីរា  នេក្ខម្មូបសមេ រតា
ទេវាបិ តេសំ បិហយន្តិ  សម្ពុទ្ធានំ សតីមតំ ។

អ្នកប្រាជ្ញទាំងឡាយណា ជាអ្នកខ្វល់ខ្វាយក្នុងឈាន ត្រេកអរ
ក្នុងនេក្ខម្ម: ជាឋានស្ងប់រម្ងាប់កិលេស សូម្បីទេវតានិងមនុស្ស
ទាំងឡាយ តែងរាប់រក ចំពោះអ្នកប្រាជ្ញទាំងឡាយនោះ ដែល
ជាអ្នកត្រាស់ដឹងខ្លួនឯង ទាំងមានស្មារតី ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា យេ ឈានបសុតា (ព្រះសម្ពុទ្ធជាម្ចាស់ពួកណា... ខ្វល់ខ្វាយក្នុងឈាន) សេចក្តីថា ប្រកបហើយ ខ្វល់ខ្វាយហើយក្នុងឈាន ២ យ៉ាង គឺ លក្ខណូបនិជ្ឈាន អារម្មណូបនិជ្ឈាន ដោយការនឹកការចូល ការអធិដ្ឋាន ការចេញ និងការពិចារណា ។ បពុជ្ជា ជាអ្នកសិក្សាមិនគប្បីកាន់យកថា “នេក្ខម្ម:” ក្នុងពាក្យថា នេក្ខម្មូបសមេ រតា (ត្រេកអរហើយក្នុងធម៌ដែលចូលទៅស្ងប់ គឺ នេក្ខម្ម:) នេះ ។ ក៏ពាក្យថា “នេក្ខម្ម:”

នោះ ព្រះអង្គទ្រង់ត្រាស់សំដៅយកសេចក្តីត្រេកអរក្នុងព្រះនិព្វាន ដែលជាទីចូលទៅស្ងប់កិលេស ។ បទថា **ទេវាបិ (សូម្បីទេវតា និងមនុស្សទាំងឡាយ)** សេចក្តីថា ទេវតា និងមនុស្សទាំងឡាយ រមែងស្រឡាញ់ គឺ រមែងប្រាថ្នាចំពោះព្រះសម្ពុទ្ធជាម្ចាស់ទាំងឡាយនោះ ។ បទថា **សតីមតំ (អ្នកមានសតិ)** សេចក្តីថា ទេវតា និងមនុស្សទាំងឡាយប្រាថ្នាភាពជាព្រះពុទ្ធថា "ឱហ្ន៎! គួរអស្ចារ្យពិតមែន សូម្បីយើងក៏គប្បីជាព្រះពុទ្ធដែរ" ដូច្នេះឈ្មោះថា រមែងស្រឡាញ់ចំពោះព្រះសម្ពុទ្ធទាំងឡាយនោះ ដែលទ្រង់មានព្រះគុណបែបនេះ ដែលទ្រង់ប្រកបព្រមហើយដោយសតិ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ធម្មាភិសម័យ បានកើតមានដល់សត្វប្រមាណ ៣០ កោដិ ។ ភិក្ខុ ៥០០ រូបដែលជាសទ្ធិវិហារិករបស់ព្រះថេរៈ បានតាំងនៅហើយក្នុងព្រះអរហត្ត ។

សង្កស្សនគរជាទីដែលស្តេចចុះចាកភពតាវតិង្ស

បានឮថា ការធ្វើយមកបាដិហារ្យហើយ ទ្រង់គង់ចាំវស្សានៅក្នុងទេវលោក ហើយស្តេចយាងចុះចាកទេវលោកត្រង់ទ្វារនៃសង្កស្សនគរ ជាដំណើរដែលព្រះពុទ្ធគ្រប់ៗ ព្រះអង្គ មិនទ្រង់លះបង់ ក៏ទីតាំងនៃព្រះបាទខាងស្តាំដែលព្រះសាស្តាទ្រង់ប្រតិស្ឋានហើយ ត្រង់ទ្វារនៃសង្កស្សនគរនោះ ឈ្មោះថា **អចលចេតិយដ្ឋាន** ព្រះសាស្តាប្រថាប់ឈរនៅត្រង់អចលចេតិយដ្ឋាននោះ ទ្រង់ត្រាស់សួរនូវបញ្ហាទាំងឡាយ ក្នុងវិស័យនៃបុគ្គលទាំងឡាយ មានបុថុជ្ជនជា

ដើម, ពួកបុថុជ្ជនដោះស្រាយបញ្ហាបាន តែក្នុងវិស័យរបស់ខ្លួនប៉ុណ្ណោះ មិនអាចដោះស្រាយនូវបញ្ហាក្នុងវិស័យរបស់ព្រះសោតាបន្នបានឡើយ ។ ព្រះអរិយបុគ្គលទាំងឡាយ មានព្រះសោតាបន្នជាដើម ក៏ដូចគ្នា មិនអាចដោះស្រាយនូវបញ្ហាក្នុងវិស័យនៃព្រះអរិយបុគ្គលទាំងឡាយ មានព្រះសកទាគាមីជាដើម ។ ព្រះមហាសាវកដ៏សេស មិនអាចនឹងដោះស្រាយនូវបញ្ហា ក្នុងវិស័យរបស់ព្រះមហាមោគ្គល្លាន, ព្រះមហាមោគ្គល្លាន មិនអាចដោះស្រាយបញ្ហា ក្នុងវិស័យនៃព្រះសារីបុត្របានឡើយ, សូម្បីព្រះសារីបុត្រ ក៏មិនអាចដោះស្រាយបញ្ហាក្នុងវិស័យរបស់ព្រះពុទ្ធបានដែរ ។ ព្រះសាស្តា ទ្រង់ទតមើលនូវទិសទាំងពួងតាំងអំពីទិសខាងលិច ។ ស្ថានទីទាំងពួង ក៏មានចន្លោះតែមួយដូចគ្នា ទេវតានិងមនុស្សក្នុងទាំងទិស ៨ និងទេវតាជាន់លើរហូតព្រហ្មលោក និងយក្សនាគ និងគ្រុឌ ដែលនៅក្នុងភាគខាងក្រោម ផ្គងអញ្ជលីក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ដែលឈ្មោះថា បុគ្គលនឹងវិសជ្ជនានូវបញ្ហានេះបាន នៅក្នុងសមាគមនេះ សូមព្រះអង្គទ្រង់ពិចារណាមើលក្នុងសមាគមនេះចុះ” ។

## ព្រះសារីបុត្តមានបញ្ញាច្រើន

ព្រះសាស្តាទ្រង់ព្រះតម្រិះថា “សារីបុត្ររមែងលំបាក ព្រោះថា សារីបុត្រ បានស្តាប់នូវបញ្ហាដែលតថាគតសួរហើយ ក្នុងពុទ្ធវិស័យយ៉ាងនេះថា ៖

ម្នាលអ្នកនិទុក្ខ អ្នកមានបញ្ញាជាគ្រឿងរក្សាខ្លួន ដែលតថាគត
សួរហើយដល់ការប្រព្រឹត្តទៅរបស់លោកអ្នកមានធម៌ ដែលដល់

ព្រមហើយទាំងឡាយ និងព្រះសេក្ខៈទាំងឡាយ ដែលមានច្រើន
ក្នុងលោកនេះ ចូរប្រាប់នូវការ ប្រព្រឹត្តទៅនោះ ដល់តថាគត ។

ដូច្នេះ ជាអ្នកអស់សេចក្តីសង្ស័យក្នុងបញ្ហាថា "ព្រះសាស្តា ទ្រង់រមែងត្រាស់សួរដល់បដិបទាជាទីមក (មគ្គប្បដិបទា) របស់ព្រះសេក្ខៈ និងព្រះអសេក្ខៈ ចំពោះយើង ដូច្នេះក៏ពិត តែថា ក៏នៅកង្វល់ក្នុងអធ្យាស្រ័យយើងថា យើងកាលពោលបដិបទានេះ ដោយធម៌ណាៗ ក្នុងធម៌ទាំងឡាយ មានខន្ធជាដើម ទើបនឹងអាចកាន់យកអធ្យាស្រ័យរបស់ព្រះសាស្តាបាន សារីបុត្រនោះ កាលតថាគតមិនឲ្យន័យ នឹងមិនអាចដោះស្រាយនូវបញ្ហាបាន តថាគតនឹងឲ្យន័យដល់អ្នក" កាលនឹងទ្រង់សម្តែងន័យ ទើបត្រាស់ថា "សារីបុត្រ អ្នកចូរពិចារណាមើលសេចក្តីពិតនេះ" ។ បានឮថា ព្រះអង្គទ្រង់ព្រះតម្រិះយ៉ាងនេះថា "សារីបុត្រ កាលកាន់យកអធ្យាស្រ័យរបស់តថាគត ហើយដោះស្រាយ និងដោះស្រាយដោយអំណាចនៃខន្ធ" បញ្ហានោះ ប្រាកដដល់ព្រះថេរៈទាំងរយន័យទាំងពាន់ន័យ ព្រមជាមួយនឹងការប្រទានន័យ ។ លោកតាំងនៅក្នុងន័យដែលព្រះសាស្តាទ្រង់ប្រទានហើយ បានដោះស្រាយនូវបញ្ហានោះ បានឮថា បុគ្គលដទៃវៀរព្រះសម្មាសម្ពុទ្ធចេញ ឈ្មោះថា ជាអ្នកអាចដោះស្រាយបញ្ហារបស់ព្រះសារីបុត្តបាន រមែងមិនមាន ។ ន័យថា ព្រោះហេតុនោះឯង ព្រះថេរៈទើបឈរក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តា បន្លឺសីហនាទថា "បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើភ្លៀងធ្លាក់អស់កប្បទាំងមូល ខ្ញុំព្រះអង្គក៏អាចរាប់ ហើយលើកឡើង

កាន់ខ្ទាច់ថា ដំណក់ទឹកទាំងឡាយ ធ្លាក់ក្នុងមហាសមុទ្រ មានប្រមាណប៉ុណ្ណេះតំណក់ ធ្លាក់លើផែនដីប៉ុណ្ណេះតំណក់ លើភ្នំប៉ុណ្ណេះតំណក់" ។ សូម្បីព្រះសាស្ដាក៏ត្រាស់នឹងលោកថា "សារីបុត្រ តថាគតក៏ជ្រាបនូវសមត្ថភាពក្នុងការរាប់របស់អ្នកដែរ" ។ ឈ្មោះថា ការឧបមាប្រៀបដោយបញ្ញារបស់អ្នកនោះ រមែងមិនមាន ។ ព្រោះហេតុនោះ ទើបលោកក្រាបទូលថា ៖

> *ខ្សាច់ក្នុងទន្លេគង្គា គប្បីអស់ទៅ ទឹកក្នុងមហាសមុទ្រ គប្បីអស់ទៅ ដីស្ថិតក្នុងផែនដី គប្បីអស់ទៅ ការដោះស្រាយនូវបញ្ហាដោយប្រាជ្ញាជាគ្រឿងដឹងរបស់ខ្ញុំព្រះអង្គ រមែងមិនអស់ទៅដោយការគណនាឡើយ ។*

មានពាក្យអធិប្បាយទុកដូច្នេះថា "បពិត្រព្រះអង្គដ៏ចម្រើន អ្នកដល់ព្រមដោយបញ្ញាជាគ្រឿងត្រាស់ដឹង ជាទីពឹងនៃសត្វលោក កាលបើខ្ញុំព្រះអង្គដោះស្រាយនូវបញ្ហាមួយហើយ បុគ្គលគប្បីដាក់នូវគ្រាប់ខ្សាច់មួយគ្រាប់ ឬដំណក់ទឹកមួយដំណក់ ឬអាចម៍ដីមួយដុំ កាលខ្ញុំព្រះអង្គដោះស្រាយនូវបញ្ហាមួយរយ ឬមួយពាន់ ឬមួយសែន គប្បីរាប់ដោយការគណនាទាំងឡាយ មានគ្រាប់ខ្សាច់ជាដើម តែមួយៗ ឲ្យនៅក្នុងចំណែកម្ខាងនៃទន្លេគង្គា ការរាប់ដោយការគណនាទាំងឡាយ មានគ្រាប់ខ្សាច់ជាដើមក្នុងទន្លេគង្គាជាដើម គប្បីដល់នូវកិរិយាអស់ទៅឆាប់រហ័សជាង ការដោះស្រាយនូវបញ្ហារបស់ខ្ញុំព្រះអង្គ រមែងមិនអស់ទៅឡើយ" ។

ភិក្ខុសូម្បីមានបញ្ហាច្រើនយ៉ាងនេះ ក៏មិនឃើញនូវទីបំផុតខាងដើម ឬខាងចុងនៃបញ្ហាដែលព្រះសាស្តា ត្រាស់សួរហើយក្នុងពុទ្ធវិស័យ លុះត្រាតែតាំងនៅក្នុងន័យដែលព្រះសាស្តាទ្រង់ប្រទានហើយ ទើបដោះស្រាយបញ្ហាបាន ភិក្ខុទាំងឡាយ ស្តាប់ដូច្នោះហើយ សន្ទនាគ្នាថា “ជនសូម្បីទាំងអស់ ដែលព្រះសាស្តាត្រាស់សួរបញ្ហាណាហើយ មិនអាចដោះស្រាយនូវបញ្ហានោះបាន ព្រះសារីបុត្រដែលជាធម្មសេនាបតីតែមួយអង្គគត់ ដោះស្រាយបញ្ហានោះបាន” ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យនោះហើយ ក៏ត្រាស់ថា “សារីបុត្រ ដោះស្រាយបញ្ហាដែលមហាជនមិនអាចដោះស្រាយបាន មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកពមុន សារីបុត្រក៏ដោះស្រាយបានហើយដែរ” លុះទ្រង់ត្រាស់ដូច្នេះហើយ ក៏ទ្រង់នាំអតីតនិទានមក ត្រាស់ជាតកនេះដោយពិស្តារថា ៖

ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីទាំងពាន់ជាការកំណត់
ជនទាំងនោះរកប្រាជ្ញាមិនបាន គប្បីកន្ទក់កន្ទេញអស់ ១០០ ឆ្នាំ
បុរសណាប្រកបដោយប្រាជ្ញា ដឹងច្បាស់នូវអត្ថនៃភាសិត បុរស
នោះនៅតែម្នាក់ឯងប៉ុណ្ណោះ ប្រសើរជាង ដូច្នេះឯង ។

ចប់ រឿងយមកបាដិហារ្យ

# ៣. រឿងនាគរាជឈ្មោះឯរកបត្ត

*ព្រះសាស្តា កាលស្តេចប្រថាប់នៅនគរពារាណសី ទ្រង់ប្រថាប់គង់នៅទៀបគល់នៃដើមស្រេស ៧ ដើម ទ្រង់ប្រារព្ធស្តេចនាគ ឈ្មោះឯរកបត្ត ត្រាស់ព្រះធម្មទេសនានេះថា **កិច្ឆោ មនុស្សបដិលាភោ (ការបានអត្តភាពជាមនុស្សជាការលំបាក)** ជាដើម ។*

អាបត្តិតូចមិនសម្តែងចេញ រមែងឱ្យទោស

*បានឮថា ក្នុងសាសនានៃព្រះកស្សបសម្មាសម្ពុទ្ធ នាគរាជនោះជាភិក្ខុកំលោះ ឡើងកាន់ទូកទៅតាមទន្លេគង្គា ចាប់កាន់ស្លឹករំពឹកក្នុងគុម្ពរំពឹក កាលទូកស្ទុះទៅដោយរហ័ស ក៏មិនលែង ។ ស្លឹករំពឹកក៏ដាច់ ។ ភិក្ខុកំលោះនោះមិនសម្តែងអាបត្តិ ដោយគិតឃើញថា "នេះជាទោសត្រឹមតែបន្តិចបន្តួច" សូម្បីធ្វើសមណធម៌ក្នុងព្រៃអស់ ២ ម៉ឺនឆ្នាំ ក៏ជួយមិនរួច ក្នុងកាលមរណៈ ស្លឹករំពឹកក៏ដូចជាមកប្រាកដត្រង់ក សូម្បីមានសេចក្តីប្រាថ្នានឹងសម្តែងអាបត្តិ កាលមិនឃើញភិក្ខុដទៃ ក៏កើតសេចក្តីក្តៅក្រហាយឡើងថា "យើងមានសីលមិនបរិសុទ្ធ" ចុតិចាកអត្តភាពនោះហើយ ក៏កើតជាស្តេចនាគ មានរាងកាយប្រមាណប៉ុនទូកកម្រោល ។ ស្តេចនាគនោះ មានឈ្មោះថា "**ឯរកបត្ត**" ។ ក្នុងខណៈដែលខ្លួនកើតហើយ ស្តេចនាគនោះ រមិលមើលអត្តភាពរបស់ខ្លួនហើយ ក៏កើតសេចក្តីក្តៅក្រហាយថា "យើងធ្វើសមណធម៌ រហូតអស់កាលប្រមាណ*

*ប៉ុណ្ណោះ ជាអ្នកកើតក្នុងទីមានកង្កែបជាអាហារ ក្នុងកំណើតនៃអហេតុកសត្វ” ។ ក្នុងកាលជាខាងក្រោយមក ស្តេចនាគនោះមានធីតាម្នាក់ លើកនូវពពារធំលើខ្នងទឹកក្នុងទន្លេគង្គា ដាក់ធីតារបស់ខ្លួនលើពពារនោះ ញ៉ាំងធីតាឲ្យរាំច្រៀងនៅលើពពារនោះ ។*

ស្តេចនាគញ៉ាំងឧបាយដើម្បីបានជ្រាបការឧប្បត្តិនៃព្រះពុទ្ធ

*បានឮថា ស្តេចនាគនោះ មានការគិតយ៉ាងនេះថា “កាលព្រះពុទ្ធកើតឡើង យើងនឹងបានឮនូវការៈនៃព្រះពុទ្ធនោះកើតឡើង ដោយឧបាយនេះឯង អ្នកណានាំមកនូវចម្រៀង ច្រៀងដោះស្រាយនឹងចម្រៀងរបស់យើងបាន យើងនឹងឲ្យធីតា មួយអន្លើដោយសម្បត្តិរបស់នាគដ៏ធំដល់អ្នកនោះ” ដាក់ធីតានោះលើពពារក្នុងថ្ងៃឧបោសថរាល់កន្លះខែ ។ ធីតារបស់នាគនោះ ឈររាំលើពពារច្រៀងនូវបទចម្រៀងនេះថា ៖*

> *“បុគ្គលជាអធិបតីលើអ្វី ឈ្មោះថា ព្រះរាជា អ្វីហ្ន៎ ព្រះរាជាឈ្មោះថា មានធូលីលើព្រះសិរសៈ អ្វីហ្ន៎ ឈ្មោះថា ប្រាសចាកធូលី អ្វីហ្ន៎ លោកហៅថា បុគ្គលពាល” ។*

*មនុស្សអ្នកជម្ពូទ្វីបទាំងអស់ មកដោយសេចក្តីប្រាថ្នាថា “យើងនឹងនាំយកនាងនាគមាណវិកា” ហើយធ្វើនូវចម្រៀង ច្រៀងត ដោយកម្លាំងប្រាជ្ញារៀងខ្លួនៗ ។ នាងនាគមាណវិកា រមែងហាមឃាត់នូវចម្រៀងតនោះ ។ កាលនាងឈរលើពពារស្តេចនាគជារៀងរាល់កន្លះខែ ហើយច្រៀងយ៉ាងនេះ អស់មួយ*

ចន្ទោះព្រះពុទ្ធ ។

## ព្រះសាស្ដាទ្រង់ចងជាបទចម្រៀងដើម្បីដោះប្រស្នា

គ្រានោះ ព្រះសាស្ដាទ្រង់ឧប្បត្តិឡើងហើយក្នុងលោក ថ្ងៃមួយវេលាជិតភ្លឺ ទ្រង់ត្រួតមើលសត្វលោក ទ្រង់ធ្វើឯរកបត្តនាគរាជឲ្យជាដើមហេតុ ទ្រង់ឃើញមាណពឈ្មោះឧត្តរៈចូលក្នុងសំណាញ់ គឺ ព្រះញាណរបស់ព្រះអង្គ ទ្រង់ពិចារណាមើលថា "នឹងមានហេតុអ្វី?" ទ្រង់បានឃើញហើយថា "ថ្ងៃនេះ ជាថ្ងៃដែលឯរកបត្តនាគរាជ ធ្វើធីតាទុកលើពពារ ហើយញុំាងធីតាឲ្យរាំ ឧត្តរមាណពនេះ រៀនយកបទចម្រៀងសម្រាប់ច្រៀងដោះប្រស្នា ដែលតថាគតឲ្យហើយ នឹងបានជាសោតាបន្ន រៀនយកបទចម្រៀងនោះទៅកាន់សម្នាក់នាគរាជនោះ នាគរាជនោះស្ដាប់ចម្រៀងនោះហើយ នឹងដឹងថា ព្រះពុទ្ធទ្រង់ឧប្បត្តិឡើងហើយ នឹងមកកាន់សំណាក់របស់តថាគត កាលនាគរាជនោះមកហើយ តថាគតនឹងពោលគាថាក្នុងសមាគមដ៏ធំ ក្នុងកាលចប់គាថា សត្វប្រមាណ ៨ ម៉ឺន ៤ ពាន់ នឹងត្រាស់ដឹងធម៌" ។ ព្រះសាស្ដាស្ដេចទៅកាន់ទីនោះហើយ ទ្រង់ប្រថាប់គង់ក្បែរគល់នៃដើមច្រេស ១ ដើម ក្នុងបណ្ដាដើមច្រេសទាំង ៧ ដើមនោះ នៅមិនឆ្ងាយអំពីក្រុងពារាណសី ។ អ្នកជម្ពូទ្វីបនាំយកចម្រៀងប្រជុំគ្នា ។ ព្រះសាស្ដា ទ្រង់ទតឃើញឧត្តរមាណពដែលនៅក្នុងទីមិនឆ្ងាយប៉ុន្មាន ក៏ត្រាស់ថា "ឧត្តរៈ" ។

ឧត្តរមាណព. ព្រះករុណា ព្រះអង្គ ។

ព្រះសាស្តា. អ្នកចូរមកខាងនេះ ។

គ្រានោះ ព្រះសាស្តាត្រាស់សួរឧត្តរមាណព ដែលមកថ្វាយបង្គំ ហើយអង្គុយថា "ឧត្តរៈ អ្នកទៅណា?" ។

ឧត្តរមាណព. ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទៅកាន់ទីដែលធីតារបស់ឯរកបត្តនាគរាជច្រៀង ។

ព្រះសាស្តា. អ្នកដឹងចម្រៀងសម្រាប់ច្រៀងតបហើយឬ ?

ឧត្តរមាណព. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចេះហើយ ។

ព្រះសាស្តា. អ្នកចូរច្រៀងចម្រៀងទាំងនោះមកមើល ។

គ្រានោះ ព្រះសាស្តាត្រាស់ទៅកាន់ឧត្តរមាណពដែលពោលតាមទំនងនៃការដឹងរបស់ខ្លួន ថា "ម្នាលឧត្តរៈ នោះមិនមែនជាចម្រៀងតទេ តថាគតនឹងឲ្យចម្រៀងសម្រាប់ច្រៀងតដល់អ្នក អ្នកត្រូវរៀនចម្រៀងនោះឲ្យបាន" ។

ឧត្តរមាណព. ព្រះករុណា ព្រះអង្គ ។

### ឧត្តរមាណពរៀនចម្រៀងតអំពីព្រះសាស្តា

ពេលនោះ ព្រះសាស្តាត្រាស់នឹងគេថា "ឧត្តរៈ ក្នុងកាលដែលនាងនាគមាណវិកាច្រៀង អ្នកគប្បីច្រៀងចម្រៀងនេះថា ៖

បុគ្គលជាធំក្នុងទ្វារទាំង ៦ ឈ្មោះថា ព្រះរាជា ព្រះរាជាកាល
ត្រេកត្រអាល ឈ្មោះថា អ្នកមានធូលីលើព្រះសិរសៈ បុគ្គល
អ្នកមិនត្រេកត្រអាល ឈ្មោះថា ប្រាសចាកធូលី បុគ្គលអ្នក

ត្រេកត្រអាល លោកហៅថា បុគ្គលពាល ។

ក៏ចម្រៀងរបស់នាងនាគមាណវិកាមានអធិប្បាយថា បទថា **កឹសុ អធិ-បតី រាជា** សេចក្ដីថា បុគ្គលជាអធិបតីលើអ្វីហ្ន៎ ទើបឈ្មោះថា ព្រះរាជា? ។ បទថា **កឹសុ រាជា រជស្សិរោ** សេចក្ដីថា ព្រះរាជាដូចម្ដេច រមែងមានឈ្មោះថា មានធូលីលើព្រះសិរសៈ ។ បទថា **កថំ សុ** សេចក្ដីថា ហេតុអ្វីហ្ន៎ ព្រះរាជានោះ ឈ្មោះថា ប្រាសចាកធូលី ។ ចំណែកចម្រៀងត មានការអធិប្បាយថា បទថា **ឆទ្វារាធិបតី រាជា** សេចក្ដីថា បុគ្គលណាជាធំលើទ្វារទាំង ៦ ដែលអារម្មណ៍ទាំង ៦ មានរូបជាដើមគ្របសង្កត់មិនបាន សូម្បីក្នុងទ្វារណាមួយ ឈ្មោះថា ជាព្រះរាជា ។ បទថា **រជមានោ រជស្សិរោ** សេចក្ដីថា ក៏ព្រះរាជាណារីករាយហើយក្នុងអារម្មណ៍ទាំងនោះ ព្រះរាជាអ្នករីករាយនោះ ឈ្មោះថា មានធូលីលើព្រះសិរសៈ ។ បទថា **អរជំ** សេចក្ដីថា ចំណែកព្រះរាជាអ្នកមិនរីករាយ ឈ្មោះថា ជាអ្នកមានធូលីទៅប្រាសហើយ ។ បទថា **រជំ** សេចក្ដីថា ព្រះរាជាអ្នករីករាយ លោកហៅថា "បុគ្គលពាល" ។

ព្រះសាស្ដា លុះទ្រង់ប្រទានទូវចម្រៀងតដល់ឧត្តរមាណពនោះ យ៉ាងនេះហើយ ទ្រង់ត្រាស់ថា "ឧត្តរៈ កាលអ្នកច្រៀងនូវចម្រៀងតនេះហើយ នាងនឹងច្រៀងតនូវចម្រៀងរបស់អ្នកយ៉ាងនេះថា ៖

បុគ្គលពាល អ្វីហ្ន៎ រមែងបន្សាត់ទៅ បណ្ឌិតរមែងបន្ទោបង់អ្វី

អ្វីហ្ន៎ ទើបជាអ្នកមានសេចក្ដីក្សេមចាកយោគៈ នៃអ្នក កាល

យើងសួរហើយ ចូរប្រាប់សេចក្ដីនោះដល់យើង ។

ពេលនោះ អ្នកគប្បីច្រៀងនូវចម្រៀងតនេះនឹងនាងថា ៖

"បុគ្គលពាល ដែលអន្ទង់ទឹក (គឺ កាមោឃៈជាដើម) រមែង

បន្សាត់ទៅ បណ្ឌិតរមែងបន្ទោបង់ (ឱឃៈនោះ) ចេញដោយ

សេចក្ដីព្យាយាម បណ្ឌិតអ្នកមិនប្រកបដោយយោគៈទាំងពួង

លោកហៅថា ជាអ្នកមានសេចក្ដីក្សេមចាកយោគៈ" ។

ចម្រៀងតនោះ មានសេចក្ដីអធិប្បាយថា ៖

"បុគ្គលពាល ដែលឱឃៈ (កិលេសដូចអន្ទង់ទឹក) ៤ យ៉ាង មានកាមោឃៈជាដើម រមែងបន្សាត់ទៅ បណ្ឌិត រមែងបន្ទោបង់នូវឱឃៈនោះ ដោយសេចក្ដីព្យាយាម ពោលគឺ សម្មប្បធាន (សេចក្ដីព្យាយាមដែលតាំងទុកដោយប្រពៃ) បណ្ឌិតនោះ មិនប្រកបដោយយោគៈទាំងពួង មានកាមយោគៈជាដើម លោកហៅថា អ្នកមានសេចក្ដីក្សេមចាកយោគៈ" ។

ឧត្តរមាណព កាលកំពុងរៀននូវចម្រៀងតនោះ ក៏តាំងនៅក្នុងសោតាបត្តិផល ។ គេជាសោតាបន្ន រៀនយកគាថានោះ ទៅហើយ ពោលថា "អ្នកដ៏ចម្រើនទាំងឡាយ ខ្ញុំបាននាំចម្រៀងសម្រាប់ច្រៀងតមកហើយ សូមពួកលោកឲ្យឱកាសដល់ខ្ញុំ" បានបង្អោនខ្លួនចូលទៅកណ្ដាលបរិស័ទដែលឈរនៅទីនោះ ។ នាងនាគមាណវិកាឈរនៅលើពពាររបស់ព្រះបិតា ហើយច្រៀងថា ៖

"បុគ្គលជាធំលើអ្វី ទើបឈ្មោះថា ជាព្រះរាជា" ជាដើម ។

ឧត្តរមាណពច្រៀងតថា ៖

*"បុគ្គលជាធំក្នុងទ្វារទាំង ៦ ទើបឈ្មោះថា ជាព្រះរាជា"* ជាដើម ។

នាងនាគមាណវិកា ច្រៀងតទឹងឧត្តរមាណពនោះទៀតថា ៖

*"បុគ្គលពាល អ្វីហ្ន៎ រមែងបន្សាត់ទៅ"* ជាដើម ។

ពេលនោះ ឧត្តរមាណពកាលទឹងច្រៀងតទឹងនាង ក៏បានពោលគាថានេះថា ៖

*"បុគ្គលពាល អន្លង់ទឹករមែងបន្សាត់នាំទៅ"* ដូច្នេះជាដើម ។

ណាគរាជដឹងថាព្រះពុទ្ធឧប្បត្តិឡើងហើយ

នាគរាជស្ដាប់គាថានោះភ្លាម ដឹងថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក មានចិត្តត្រេកអរថា "យើងមិនដែលឮបទបែបនេះអស់មួយចន្លោះព្រះពុទ្ធហើយ អ្នកដ៏ចម្រើនទាំងឡាយ ព្រះពុទ្ធកើតឡើងក្នុងលោកហើយហ្ន៎" ទើបយកកន្ទុយគោះទឹក ញ៉ាំងរលកធំឲ្យកើតឡើង ប្រាំងច្នេរទាំងសងខាងក៏បាក់ធ្លាក់ចុះទឹក ។ ពួកមនុស្សក្នុងទីប្រមាណមួយឧសភៈ ដែលនៅត្រើយអាយ និងត្រើយនាយ ក៏ធ្លាក់ចុះទៅក្នុងទឹក ។ នាគរាជនោះ លើកមហាជនមានប្រមាណប៉ុណ្ណោះដាក់លើពពារ នាំទៅដាក់លើគោក ។ នាគរាជនោះ ចូលទៅរកឧត្តរមាណព ហើយសួរថា "នែ! នាយ ព្រះសាស្ដាប្រថាប់នៅទីណា ?"

ឧត្តរមាណព. បពិត្រមហារាជ ព្រះសាស្ដា ព្រះអង្គទ្រង់ប្រថាប់នៅក្បែរដើមឈើមួយដើម ។

នាគរាជនោះពោលថា "មកនាយ ពួកយើងនឹងនាំគ្នាទៅ" លុះពោលដូច្នោះហើយ ក៏បានទៅកាន់ទីនោះជាមួយនឹងឧត្តរមាណព ។ ចំណែកមហាជនក៏បានទៅជាមួយដែរ ។ នាគរាជនោះទៅដល់ទីនោះហើយ ចូលទៅក្នុងចន្លោះព្រះរស្មី ៦ ពណ៌ ថ្វាយបង្គំព្រះសាស្តាហើយ ក៏ឈរយំ ។ លំដាប់នោះ ព្រះសាស្តាត្រាស់សួរនាគរាជនោះថា "មហារាជ ហេតុដូចម្តេច មហារាជយំ?"

នាគរាជ. ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាសាវករបស់ព្រះពុទ្ធប្រាកដដូចជាព្រះអង្គ បានធ្វើសមណធម៌អស់ ២ ម៉ឺនឆ្នាំ សូម្បីសមណធម៌នោះ ក៏មិនអាចនឹងជួយខ្ញុំព្រះអង្គបាន ។ ខ្ញុំព្រះអង្គអាស្រ័យកម្មតែបន្តិចបន្តួច គឺ ធ្វើឲ្យដាច់ស្លឹករំពេកមួយសន្លឹក ក៏មកបដិសន្ធិក្នុងអហេតុកសត្វ កើតក្នុងទីដែលត្រូវលូនទៅដោយទ្រូង មិនបាននូវភាវៈជាមនុស្ស មិនបានស្តាប់ព្រះសទ្ធម្ម មិនបានឃើញព្រះពុទ្ធ ប្រាកដដូចជាព្រះអង្គអស់មួយចន្លោះព្រះពុទ្ធ ។

ព្រះសាស្តា ទ្រង់ស្តាប់នូវពាក្យរបស់នាគរាជហើយ ត្រាស់ថា "មហារាជ ឈ្មោះថា ភាវៈជាមនុស្សរកបានដោយក្រក្រៃលែង ការស្តាប់ព្រះសទ្ធម្មក៏យ៉ាងនោះ កិរិយាកើតឡើងនៃព្រះពុទ្ធ ក៏រកបានដោយលំបាកដូចគ្នា ព្រោះថា ទាំងបីយ៉ាងនេះ បុគ្គលរមែងរកបានដោយក្រយ៉ាងក្រៃលែង" កាលនឹងទ្រង់សម្តែងធម៌ ទ្រង់បានត្រាស់ព្រះគាថានេះថា ៖

៣. កិច្ឆោ មនុស្សបដិលាភោ កិច្ឆំ មច្ចាន ជីវិតំ
កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ ។

ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ ការរស់នៅរបស់សត្វទាំងឡាយ បានដោយក្រ ការស្តាប់ធម៌របស់សប្បុរស បានដោយកម្រ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ ។

អធិប្បាយគាថា

សេចក្តីនៃព្រះគាថានោះ គប្បីជ្រាបដូច្នេះថា "ដែលឈ្មោះថា ការបានអត្តភាពជាមនុស្ស ឈ្មោះថា ជាការលំបាក គឺ រកបានដោយលំបាក ព្រោះភាពជាមនុស្ស បុគ្គលត្រូវបានដោយសេចក្តីព្យាយាមច្រើន ដោយកុសលច្រើន សូម្បីជីវិតរបស់សត្វទាំងឡាយ ក៏ឈ្មោះថា រស់នៅបានដោយកម្រ ព្រោះត្រូវធ្វើការងារទាំងឡាយ មានកសិកម្មជាដើមរឿយៗ ទើបញុំាងជីវិតឲ្យប្រព្រឹត្តទៅបានខ្លះ ព្រោះជីវិតជាធម្មជាតតិចខ្លះ ។ សូម្បីការស្តាប់ព្រះសទ្ធម្ម ក៏ជាការក្រ ព្រោះបុគ្គលអ្នកសម្តែងនូវធម៌ រកបានដោយក្រ ក្នុងកប្បសូម្បីមិនមែនតិច ម្យ៉ាងទៀត ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ក៏ជាការក្រដូចគ្នា គឺ បានដោយលំបាកយ៉ាងក្រៃលែង ព្រោះអភិនីហារសម្រេចបានដោយការព្យាយាមដ៏ធំ និងព្រោះការកើតឡើងនៃអ្នកមានអភិនីហារ ដែលសម្រេចហើយ ជាការបានដោយលំបាក ដោយពាន់នៃកោដិកប្បដ៏អនេក" ។

នាគរាជមិនបានសម្រេចសោតាបន្ន

ក្នុងកាលចប់ព្រះធម៌ទេសនា ពួកសត្វ ៨ ម៉ឺន ៤ ពាន់ បានត្រាស់ដឹង

ធម៌ហើយ ។ ចំណែកនាគរាជ គួរនឹងបានសោតាបត្តិផលក្នុងថ្ងៃនោះ តែមិនបាន ព្រោះខ្លួនជាសត្វតិរច្ឆាន ។ នាគរាជនោះ ដល់នូវការ: គឺ ការមិនលំបាកក្នុងឋាន: ៥យ៉ាង គឺ ការបដិសន្ធិ, ការសកនូវសំណក, ការដាក់ចិត្តហើយឈាងចុះកាន់ការដេកដ៏ស៊ប់ស្ងួន, ការសេពមេថុនធម្មនឹងនាងនាគ ដែលមានជាតិស្មើគ្នា និងការចុតិ ដែលពួកនាគកាន់យកសរីរ:ជានាគនោះឯង រមែងលំបាក រមែងបានដើម្បីត្រាច់ទៅដោយរូបជាមាណពនោះឯង ដូច្នេះ ។

ចប់ រឿងនាគរាជឈ្មោះឯរកបត្ត:

# ៤. រឿងបញ្ហារបស់ព្រះអានន្ទ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់ព្រះអានន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សព្វបាបស្ស អករណំ (ការមិនធ្វើបាបទាំងអស់)** ជាដើម ។*

កាលនៃព្រះពុទ្ធផ្សេងគ្នា តែពាក្យទូន្មានដូចគ្នា

*បានឮថា ព្រះថេរៈគង់នៅក្នុងទីសម្រាកពេលថ្ងៃ គិតថា "ព្រះសាស្តាត្រាស់ប្រាប់ហេតុនៃព្រះពុទ្ធ ៧ អង្គ គ្រប់យ៉ាង គឺ ព្រះមាតា និងព្រះបិតា ការកំណត់ព្រះជន្មាយុ ដើមឈើជាទីត្រាស់ដឹង សាវកសន្និបាត ព្រះអគ្គសាវក ឧបដ្ឋាក ប៉ុន្តែឧបោសថ ទ្រង់មិនបានត្រាស់ប្រាប់ឧបោសថរបស់ព្រះពុទ្ធទាំងនោះយ៉ាងនេះ ឬក៏យ៉ាងដទៃ" ។ លុះគិតដូច្នោះហើយ ក៏ចូលទៅគាល់ព្រះសាស្តា ហើយសួរនូវសេចក្តីនោះ ។ ក៏ការផ្សេងគ្នានៃកាលរបស់ព្រះពុទ្ធទាំងនោះ មាន ឯការផ្សេងគ្នានៃគាថា រមែងមិនមាន ព្រោះថា ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមវិបស្សី ទ្រង់ធ្វើឧបោសថរាល់ៗ ៧ ឆ្នាំម្តង ព្រោះព្រះឱវាទដែលព្រះអង្គប្រទានហើយ តែក្នុងថ្ងៃមួយប៉ុណ្ណោះ អាចប្រព្រឹត្តទៅបាន ៧ ឆ្នាំ, ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមសិខី និងវេស្សភូ ទ្រង់ធ្វើឧបោសថរាល់ៗ ៦ ឆ្នាំម្តង (ព្រោះព្រះឱវាទដែលព្រះសម្មាសម្ពុទ្ធទាំង ២ ព្រះអង្គនោះ ទ្រង់ប្រទានហើយតែក្នុងថ្ងៃមួយប៉ុណ្ណោះ អាចប្រព្រឹត្តទៅបាន ៦ ឆ្នាំ) ព្រះសម្មា-*

សម្មុទ្ធទ្រង់ព្រះនាមកកុសន្ធៈ និងកោនាគមនៈ ទ្រង់ធ្វើឧបោសថមួយឆ្នាំម្តង ព្រោះព្រះឱវាទដែលព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គនោះ ទ្រង់ប្រទានតែក្នុងថ្ងៃមួយប៉ុណ្ណោះ អាចប្រព្រឹត្តទៅបានមួយឆ្នាំ, ព្រះកស្សបទសពល ទ្រង់ធ្វើឧបោសថរាល់ៗ ៦ ខែម្តង ព្រោះព្រះឱវាទដែលព្រះពុទ្ធអង្គនោះ ទ្រង់ប្រទានតែក្នុងថ្ងៃមួយប៉ុណ្ណោះ អាចប្រព្រឹត្តទៅបាន ៦ ខែ ដូច្នោះ ទើបព្រះសាស្តាត្រាស់សេចក្តីផ្សេងគ្នានៃកាលរបស់ព្រះពុទ្ធទាំងនោះហើយ ត្រាស់ថា "ចំណែកឱវាទគាថានៃព្រះពុទ្ធទាំងនោះដូចគ្នា" ដូច្នេះហើយ កាលនឹងទ្រង់ធ្វើឧបោសថនៃព្រះពុទ្ធគ្រប់ៗ ព្រះអង្គ ឲ្យជាឧបោសថតែមួយ ឲ្យជាក់ច្បាស់ ទើបបានត្រាស់ព្រះគាថាទាំងនេះថា ៖

៤. សព្វបាបស្ស អករណំ កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។
ខន្តិ បរមំ តបោ តីតិក្ខា
និព្វានំ បរមំ វទន្តិ ពុទ្ធា
ន ហិ បព្វជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ ។
អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ
អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។

ការមិនធ្វើបាបទាំងពួង ការញុំាងកុសលឲ្យកើតឡើង ការធ្វើចិត្ត
របស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។
ខន្តិ គឺ សេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយ តែង
ពោលថា ព្រះនិព្វានជាធម្មជាតដ៏ឧត្តម បុគ្គលដែលសម្លាប់សត្វ
ដទៃមិនឈ្មោះថា បព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏
មិនឈ្មោះថា សមណៈឡើយ ។ ការមិនតិះដៀល ១ ការមិន
បៀតបៀន ១ ការសង្រួមក្នុងបាតិមោក្ខ ១ ភាពជាអ្នកដឹងប្រមាណ
ក្នុងភត្ត ១ ការដេក និងអង្គុយក្នុងទីស្ងាត់ ១ ការព្យាយាមក្នុង
អធិចិត្ត ១ នុ៎ះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា សព្វបាបស្ស (បាបទាំងពួង) បានដល់អកុសលកម្មគ្រប់ប្រភេទ ។ ការញុំាងកុសលឲ្យកើតឡើងចាប់តាំងពីការចេញបួស ដរាបដល់ព្រះអរហត្តមគ្គ និងការញុំាងកុសលដែលខ្លួនបានឲ្យកើតឡើងហើយ ឲ្យចម្រើន ឈ្មោះថា ឧបសម្បទា (ការញុំាងកុសលឲ្យដល់ព្រម) ។ ការញុំាងចិត្តរបស់ខ្លួនឲ្យផូរផង់ចាកនីវរណទាំង ៥ ឈ្មោះថា សចិត្តបរិយោទបនំ (ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់) ។

បទថា ឯតំ ពុទ្ធាន សាសនំ (នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធគ្រប់ៗព្រះអង្គ) ដោយអត្ថថា នេះជាឱវាទពាក្យប្រដៅរបស់ព្រះពុទ្ធគ្រប់ៗ ព្រះអង្គ ។

បទថា **ខន្តិ** (សេចក្តីអត់ធន់) ឈ្មោះថា សេចក្តីអត់ធន់ឯណា ជាតបធម៌ដ៏ឧត្តម គឺ ដ៏ខ្ពង់ខ្ពស់ក្នុងព្រះសាសនានេះ ។

បទថា **និព្វានំ បរមំ វទន្តិ ពុទ្ធា** (បណ្ឌិតទាំងឡាយរមែងពោលដល់ព្រះនិព្វានថាជាធម្មជាតដ៏ឧត្តម) សេចក្តីថា ពុទ្ធបុគ្គលទាំង ៣ ពួកនេះ គឺ ព្រះពុទ្ធ ១ ព្រះបច្ចេកពុទ្ធ ១ ព្រះអនុពុទ្ធ ១ រមែងពោលព្រះនិព្វានថា "ជាធម្មជាតដ៏ឧត្តម" ។

បទថា **ន ហិ បព្វជិតោ** (មិនឈ្មោះថាបព្វជិត) សេចក្តីថា បុគ្គលដែលចូលទៅបៀតបៀនសត្វដទៃ ដោយគ្រឿងប្រហារផ្សេងៗ មានបាតដៃជាដើម ឈ្មោះថា ជាអ្នកបៀតបៀនសត្វដទៃ មិនឈ្មោះថា ជាបព្វជិតឡើយ ។ បទថា **សមណោ** (សមណៈ) សេចក្តីថា បុគ្គលដែលនៅបៀតបៀនសត្វដទៃតាមន័យដែលពោលហើយនោះ មិនឈ្មោះថា ជាសមណៈដូចគ្នា ។ ការមិនតិះដៀលដោយខ្លួនឯង និងការមិនញុំាងអ្នកដទៃឲ្យតិះដៀល ឈ្មោះថា **អនូបវាទោ** (ការមិនពោលតិះដៀល) ។ ការមិនបៀតបៀនដោយខ្លួនឯង និងការមិនប្រើអ្នកដទៃឲ្យបៀតបៀន ឈ្មោះថា **អនូបឃាតោ** (ការមិនបៀតបៀន) ។

បទថា **បាតិមោក្ខេ** (ក្នុងព្រះបាតិមោក្ខ) បានដល់ ក្នុងសីលដែលជាប្រធាន ។ ការបិទ ឈ្មោះថា **សំវរោ** (ការសង្រួម) ។ **មត្តញ្ញុតា** ឈ្មោះថា ភាវៈនៃបុគ្គលជាអ្នកដឹងនូវប្រមាណ ។ បទថា **បន្តំ** (ស្ងាត់) បានដល់ ស្ងៀមស្ងាត់ ។ បទថា **អធិចិត្តេ** (ក្នុងអធិចិត្ត) សេចក្តីថា ក្នុងចិត្តដ៏ក្រៃលែង ពោល

គឺ ចិត្តដែលសហគតៈដោយសមាបត្តិ ៨ ។ ការធ្វើនូវសេចក្តីព្យាយាម ឈ្មោះថា **អាយោគោ** (ការប្រកបដោយសេចក្តីអើពើ) ។ បទថា **ឯតំ** (នោះ) សេចក្តីថា នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់ៗ ព្រះអង្គ ។ ក៏ក្នុងព្រះគាថានេះ ព្រះមានព្រះភាគត្រាស់សីលដែលប្រព្រឹត្តទៅតាមផ្លូវវាចា ដោយ **អនូបវាទ** ត្រាស់សីលដែលប្រព្រឹត្តទៅតាមផ្លូវកាយ ដោយ **អនូបឃាត** ។ ទ្រង់ត្រាស់បាតិមោក្ខសីល និងឥន្ទ្រិយសំវរសីល ដោយពាក្យនេះថា **បាតិមោក្ខេ ច សំវរោ** ។ ត្រាស់អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល ដោយពាក្យនេះថា **មត្តញ្ញុតា** ត្រាស់សេនាសនៈដែលសប្បាយ ដោយ **បន្តសេនាសនៈ** ត្រាស់សមាបត្តិ ៨ ដោយ **អធិចិត្ត** ដោយប្រការដូច្នេះ សិក្ខាសូម្បីទាំង ៣ រមែងជាការដែលព្រះអង្គត្រាស់ហើយដោយព្រះគាថានេះ ដូច្នេះឯង ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចប់ រឿងបញ្ហារបស់ព្រះអានន្ទ

# ៥. រឿងភិក្ខុអ្នកមិនត្រេកអរ

*ព្រះសាស្តា កាលប្រថាប់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកមិនត្រេកអរ (ក្នុងព្រហ្មចារ្យ) មួយរូប ត្រាស់ព្រះធម្មទេសនានេះថា ន កហាបណវស្សេន (ព្រោះភ្លៀង គឺ កហាបណៈ) ជាដើម ។*

ភិក្ខុកាំលោះអដ្ឋក្រច្រាថ្នាចង់សឹក

*បានឮថា ភិក្ខុនោះបួសហើយក្នុងព្រះសាសនា បានឧបសម្បទាហើយ កាលព្រះឧបជ្ឈាយ៍បញ្ជូនទៅដោយពាក្យថា "អ្នកចូរទៅកាន់ទីឯណោះ ហើយរៀនឧទ្ទេស" ក៏បានទៅកាន់ទីនោះតាមពាក្យរបស់ព្រះឧបជ្ឈាយ៍ ។ គ្រានោះ រោគកើតឡើងដល់បិតារបស់ភិក្ខុនោះ បិតារបស់ភិក្ខុនោះប្រាថ្នានឹងឃើញបុត្រ (ប៉ុន្តែ) មិនមានអ្នកណាអាចនឹងទៅហៅបុត្រនោះមកបាន ទើបរវើរវាយដោយសេចក្តីសោកចំពោះបុត្រ ជាអ្នកមានសេចក្តីស្លាប់មកជិតហើយ ទើបទុកដាក់កហាបណៈមួយរយក្នុងដៃប្អូនប្រុស ដោយពាក្យថា "ឯងគប្បីធ្វើទ្រព្យនេះឲ្យជាតម្លៃបាត្រ និងចីវរដល់បុត្ររបស់យើង" លុះផ្តាំផ្ញើរួចស្រេចហើយ ក៏ធ្វើកាលកិរិយាទៅ ។ ក្នុងកាលដែលភិក្ខុនោះមក ប្អូនប្រុសនោះ ក្រាបចុះទៀបជើងភិក្ខុនោះ យំបម្រះននៀលទៅមកបណ្តើរ ពោលបណ្តើរថា "លោកម្ចាស់ដ៏ចម្រើន បិតារបស់លោកម្ចាស់ មុននឹងគាត់ស្លាប់ គាត់រវើរវាយសួររកតែលោកម្ចាស់ គាត់ស្លាប់ទៅទាំងការអាឡោះអាល័យលោកម្ចាស់ មុននឹងគាត់*

ស្លាប់ គាត់បានទុកដាក់កហាបណៈ ១០០ ក្នុងដៃរបស់ខ្ញុំ ខ្ញុំនឹងធ្វើអ្វីចំពោះទ្រព្យនោះ" ភិក្ខុកំលោះនោះក៏ហាមឃាត់ថា "អាត្មាភាពមិនត្រូវការទ្រព្យនោះទេ" ក្រោយមកក៏គិតថា "ប្រយោជន៍អ្វីរបស់អញ ដោយការត្រាច់ទៅបិណ្ឌបាតក្នុងត្រកូលដទៃចិញ្ចឹមជីវិតនោះ យើងអាស្រ័យកហាបណៈ ១០០ នោះអាចចិញ្ចឹមជីវិតបាន យើងនឹងសឹក" ។ ត្រូវសេចក្តីមិនត្រេកអរបៀតបៀនហើយ ក៏លះបង់ការស្វាធ្យាយ និងព្រះកម្មដ្ឋានចោល មានអាការដូចជាអ្នកមានរោគស្គមលឿង ។ គ្រានោះ ភិក្ខុកំលោះ និងសាមណេរទាំងឡាយសួរលោកថា "អាវុសោ លោកមានបញ្ហាអ្វី" កាលលោកប្រាប់ថា "ខ្ញុំអផ្សុក" ក៏នាំគ្នាទៅប្រាប់អាចារ្យ និងឧបជ្ឈាយ៍របស់លោក ពេលនោះអាចារ្យ និងឧបជ្ឈាយ៍របស់លោក នាំលោកទៅកាន់សម្នាក់ព្រះសាស្តា សម្តែងចំពោះព្រះសាស្តា ។

ព្រះសាស្តាត្រាស់ថា "ភិក្ខុ បានឮថា អ្នកអផ្សុកពិតមែនឬ?" កាលភិក្ខុនោះក្រាបទូលថា "ព្រះករុណា ព្រះអង្គ" ក៏ត្រាស់ថា "ព្រោះហេតុអ្វី? ទើបអ្នកធ្វើយ៉ាងនោះ ក៏អ្វីៗ ដែលជាបច្ច័យនៃការចិញ្ចឹមជីវិតរបស់អ្នកមានឬ?" ។

ភិក្ខុ. មាន ព្រះអង្គ ។

ព្រះសាស្តា. អ្នកមាននូវរបស់អ្វី ?

ភិក្ខុ. កហាបណៈ ១០០ ព្រះអង្គ ។

ព្រះសាស្តា. បើដូច្នោះ អ្នកចូរនាំដុំគ្រួសទាំងឡាយមក ត្រឹមតែបន្តិច

ហើយអ្នកសាកល្បងរាប់មើល នឹងដឹងបានថា "អ្នកអាចចិញ្ចឹមជីវិតបានដោយកហាបណៈចំនួនប៉ុណ្ណោះឬ ឬមិនអាចចិញ្ចឹមជីវិតបាន"។

ភិក្ខុកំលោះនោះ ទើបនាំដុំគ្រួសមក ។

គ្រានោះ ព្រះសាស្ដាក៏ត្រាស់នឹងភិក្ខុនោះថា "អ្នកចូរ តម្កល់កហាបណៈ ៥០ ទុក ដើម្បីប្រយោជន៍ដល់គ្រឿងបរិភោគ ចូរតម្កល់ទុក ២៨ កហាបណៈ ដើម្បីប្រយោជន៍ដល់គោ ២ ក្បាល ចូរតម្កល់ទុកនូវកហាបណៈប្រមាណប៉ុណ្ណោះដើម្បីប្រយោជន៍ដល់ពូជ ដើម្បីប្រយោជន៍ដល់នង្គ័ល និងការក្ខរ ដើម្បីប្រយោជន៍ដល់ចប ដល់កាំបិត និងពូថៅ" ។ កាលអ្នករាប់ដោយអាការយ៉ាងនេះ កហាបណៈ ១០០ នោះ រមែងមិនគ្រប់គ្រាន់ ។ គ្រានោះ ព្រះសាស្ដាត្រាស់នឹងភិក្ខុនោះថា "ភិក្ខុ កហាបណៈរបស់អ្នកមានប្រមាណតិចណាស់ អ្នកអាស្រ័យកហាបណៈទាំងនោះ នឹងញ៉ាំងតណ្ហាឲ្យពេញដោយអាការដូចម្ដេច? បានឮថា ក្នុងអតីតកាល បណ្ឌិតទាំងឡាយគ្រប់គ្រងចក្រពត្តិរាជសម្បត្តិ អាចនឹងញ៉ាំងភ្លៀង គឺ រតនៈ ៧ ប្រការឲ្យធ្លាក់ចុះមកត្រឹមចង្កេះក្នុងទីប្រមាណ ១២ យោជន៍ ដោយអាការត្រឹមតែទះដៃ មិនត្រឹមតែប៉ុណ្ណោះ គ្រប់គ្រងរាជសម្បត្តិក្នុងទេវលោកអស់ ៣៦ ជំនាន់ព្រះឥន្ទ ក្នុងកាលមរណៈ ក៏មិនអាចញ៉ាំងតណ្ហាឲ្យពេញផង ក៏ធ្វើមរណកាលទៅ" ត្រូវភិក្ខុកំលោះនោះទូលអារាធនា ទ្រង់ក៏នាំអតីតនិទានមក ញ៉ាំងមន្ធាតុរាជជាតកឲ្យពិស្ដារក្នុងលំដាប់នៃព្រះគាថានេះថា ៖

“ព្រះចន្ទ និងព្រះអាទិត្យ (រមែងវិលទៅ) បំភ្លឺទិសទាំងឡាយ រមែងភ្លឺស្វាងដោយការកំណត់ត្រឹមណា សត្វទាំងឡាយដែលអាស្រ័យផែនដីទាំងមូល រមែងជាទាសៈរបស់ព្រះបាទមន្ធាតុរាជទាំងអស់” ។

ទ្រង់បានភាសិត ២ គាថានេះថា ៖

៥. ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ
អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ
អបិ ទិព្វេសុ កាមេសុ រតឹ សោ នាធិគច្ឆតិ
តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ។

ការស្កប់ស្កល់ក្នុងកាមទាំងឡាយ រមែងមិនមាន ព្រោះកហាបណៈ (ដែលធ្លាក់ចុះ) ដូចទឹកភ្លៀងទេ កាមទាំងឡាយ មានសុខតិច មានទុក្ខច្រើន អ្នកប្រាជ្ញដឹងច្បាស់ យ៉ាងនេះហើយ លោកមិនបានត្រេកអរក្នុងកាមទាំងឡាយ សូម្បីជាទិព្វឡើយ សាវករបស់ព្រះសម្មាសម្ពុទ្ធ រមែងជាអ្នកត្រេកអរក្នុងធម៌ជាគ្រឿងអស់តណ្ហា ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា កហាបណវស្សេន (ព្រោះភ្លៀង គឺ កហាបណៈ) សេចក្ដីថា បណ្ឌិតនោះទះដៃហើយ ញ៉ាំងភ្លៀង គឺ រតនៈ ៧ ប្រការ

ឲ្យធ្លាក់ចុះមក ។ ភ្លៀង គឺ រតនៈ ៧ ប្រការនោះ ត្រាស់ឲ្យឈ្មោះថា **កហាបណវស្សំ** ក្នុងព្រះគាថានេះ ។ ដែលឈ្មោះថា សេចក្ដីឆ្អែតក្នុងវត្ថុកាម និងកិលេសកាមទាំងឡាយ រមែងមិនមាន សូម្បីដោយភ្លៀង គឺ រតនៈទាំង ៧ ប្រការនោះ តណ្ហាទុំ៎ះ បុគ្គលធ្វើឲ្យពេញបានដោយក្រយ៉ាងនេះឯង ។

បទថា **អប្បស្សាទា (មានរសផ្អែមតិច)** គឺ ឈ្មោះថា មានសុខតិច ព្រោះកាម មានសេចក្ដីឧបមាដូចជាការយល់សប្ដិជាដើម ។

បទថា **ទុក្ខា (មានទុក្ខច្រើន)** គឺ ឈ្មោះថា មានទុក្ខច្រើនដោយពិត ដោយអំណាចនៃទុក្ខ ដែលមកហើយក្នុងទុក្ខក្ខន្ធសូត្រជាដើម ។

បទថា **ឥតិ វិញ្ញាយ (ដឹងច្បាស់ដូច្នេះហើយ)** គឺ ដឹងនូវកាមទាំងឡាយនោះ ដោយអាការយ៉ាងនេះ ។

បទថា **អបិ ទិព្វេសុ (សូម្បីជាទិព្វ)** សេចក្ដីថា ប្រសិនបើមានបុគ្គលណាៗ គប្បីអញ្ជើញដោយកាម ដែលចូលទៅសម្រេចដល់ទេវតាទាំងឡាយសូម្បីយ៉ាងនោះ លោកក៏មិនត្រេកអរក្នុងកាមទាំងនោះឡើយ ដូចព្រះសមិទ្ធិដ៏មានអាយុ ដែលត្រូវពួកទេវតាអញ្ជើញ ដូច្នោះ ។

បទថា **តណ្ហក្ខយរតោ (ត្រេកអរក្នុងការអស់ទៅនៃតណ្ហា)** សេចក្ដីថា ជាអ្នកត្រេកអរដ៏ក្រៃលែងក្នុងព្រះអរហត្ត និងក្នុងព្រះនិព្វាន គឺ ប្រាថ្នានូវព្រះអរហត្តផង ព្រះនិព្វានផង ។ ភិក្ខុជាព្រះយោគាវចរ អ្នកកើតក្នុងទីបំផុតនៃការស្ដាប់ធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងហើយ ឈ្មោះថា សាវករបស់

*ព្រះសម្ពុទ្ធ ។*

*ក្នុងកាលចប់ព្រះធម៌ទេសនា ភិក្ខុនោះ ក៏តាំងនៅក្នុងសោតាបត្តិផល ។ ព្រះធម៌ទេសនា មានប្រយោជន៍ដល់បរិស័ទដែលមកប្រជុំគ្នាហើយ ដូច្នេះ ។*

ចប់ រឿងភិក្ខុអ្នកមិនត្រេកអរ

# ៦. រឿងបុរោហិតឈ្មោះអគ្គិទត្ត

ព្រះសាស្តា (កាលប្រថាប់នៅក្នុងវត្តជេតពន) ទ្រង់ប្រថាប់គង់នៅលើគំនរដីខ្សាច់ ទ្រង់ប្រារព្ធបុរោហិតរបស់ព្រះបាទកោសល ឈ្មោះអគ្គិទត្ត ត្រាស់ព្រះធម្មទេសនានេះថា **ពហុំ វេ សរណំ យន្តិ** (មនុស្សជាច្រើន ត្រូវភ័យគម្រាមហើយ រមែងដល់... ថាជាទីពឹង) ជាដើម ។

អគ្គិទត្តទូលលាបួស

បានឮថា អគ្គិទត្តព្រាហ្មណ៍នោះ ជាបុរោហិតរបស់ព្រះបាទមហាកោសល ។ ក្រោយមក កាលព្រះបាទមហាកោសលសោយទិវង្គតទៅ ព្រះរាជាទ្រង់ព្រះនាមថា បសេនទិកោសល ទ្រង់ព្រះតម្រិះថា "ព្រាហ្មណ៍នេះ ជាបុរោហិតនៃព្រះបិតារបស់យើង" ទើបទ្រង់បានតាំងគេទុកនូវក្នុងតំណែងនោះដដែល ដោយសេចក្តីគោរព ក្នុងវេលាដែលគេមកកាន់ទីបម្រើ របស់ព្រះអង្គៗ តែងតែទ្រង់ធ្វើនូវកិរិយាក្រោកទទួលជានិច្ច ។ ត្រាស់ឲ្យព្រះរាជទានអាសនៈដ៏ស្មើ ដោយព្រះតម្រាស់ថា "លោកអាចារ្យ ចូរអង្គុយលើអាសនៈនេះ" ។

អគ្គិទត្តនោះគិតថា "ព្រះរាជាអង្គនេះ ទ្រង់ធ្វើសេចក្តីគោរពក្នុងយើងក្រៃលែងណាស់ តែយើងក៏មិនអាចយកព្រះទ័យព្រះរាជាទាំងឡាយអស់កាលជានិច្ចបានឡើយ មួយវិញទៀត ទ្រង់នៅក្មេង នៅកំលោះ ឈ្មោះថា ភាពជាព្រះរាជា ជាមួយបុគ្គលអ្នកមានវ័យស្មើគ្នានោះឯង ទើបជាសុខ ចំណែកយើង

ជាមនុស្សចាស់ យើងគួរបួស" គេក៏ក្រាបទូលដល់ព្រះរាជាឲ្យទ្រង់ព្រះរាជទាន ព្រះបរមរាជានុញ្ញាតហើយ ឲ្យគេទូងស្គរត្រាច់ទៅក្នុងព្រះនគរ លះបង់ទ្រព្យរបស់ខ្លួនទាំងអស់ ឲ្យទានធំអស់ ៧ ថ្ងៃ ហើយបួសជាអ្នកបួសក្រៅព្រះពុទ្ធ-សាសនា ។ បុរស ១ ម៉ឺននាក់ ដែលអាស្រ័យអគ្គិទត្តនោះ ក៏បួសតាមហើយ ។ អគ្គិទត្តនោះ ព្រមដោយអ្នកបួសទាំងនោះ សម្រេចការនៅក្នុងចន្លោះដែនអង្គៈ ដែនមគធៈ និងដែនកុរុ ហើយតែងតែឲ្យឱវាទយ៉ាងនេះថា "នៃអ្នកទាំងឡាយ បណ្ដាអ្នកទាំងឡាយ អ្នកណាមានកាមវិតក្កៈជាដើមកើតឡើង អ្នកនោះចូរកើបខ្សាច់មួយធ្នាំងៗ អំពីស្ទឹង (មក) គរនៅទីនេះ" ។ ពួកអ្នកបួសទាំងនោះទទួលថា "ប្រពៃហើយ" ក្នុងកាលណា កាមវិតក្កៈជាដើមកើតឡើង ក៏ធ្វើដោយប្រការដូច្នោះ ។ ក្នុងសម័យដទៃទៀត គំនរនៃដីខ្សាច់ដ៏ធំ បានមានហើយនៅទីនោះ ។ នាគរាជឈ្មោះ អហិច្ឆត្តៈ កាន់កាប់ហួងហែងក្នុងគំនរខ្សាច់នោះ ។ អ្នកស្រុកអង្គៈ មគធៈ និងអ្នកដែនកុរុ នាំគ្រឿងសក្ការៈជាច្រើនទៅថ្វាយចំពោះពួកអ្នកបួសទាំងនោះរាល់ៗ ខែ ។ គ្រានោះ អគ្គិទត្តបានឲ្យឱវាទដល់ជនទាំងនោះដូច្នេះថា "អ្នកទាំងឡាយ ចូរយកភ្នំជាសរណៈ ចូរយកព្រៃជាសរណៈ ចូរយកអារាមជាសរណៈ ចូរយកដើមឈើជាសរណៈ អ្នកទាំងឡាយនឹងរួចចាកទុក្ខទាំងពួងបាន ដោយអាការយ៉ាងនេះ" ។ ទូន្មានអន្តេវាសិកទាំងឡាយរបស់ខ្លួន ក៏ដោយឱវាទនេះដូចគ្នា ។

ព្រះមហាមោគ្គល្លានទៅទូន្មានអគ្គិទត្ត:

ចំណែកព្រះពោធិសត្វ ស្ដេចចេញមហាភិនិស្ក្រមណ៍ ទ្រង់បានសម្រេចសម្មាសម្ពោធិញ្ញាណហើយ ក្នុងសម័យនោះ ទ្រង់អាស្រ័យក្រុងសាវត្ថី ទ្រង់ប្រថាប់គង់នៅក្នុងវត្តជេតពន ។ ក្នុងវេលាជិតភ្លឺទ្រង់រមិលមើលនូវសត្វលោក ទ្រង់ឃើញអគ្គិទត្ត:ព្រមទាំងអន្តេវាសិក ចូលទៅក្នុងសំណាញ់ គឺ ព្រះញាណរបស់ព្រះអង្គ ហើយទ្រង់ជ្រាបថា "ជនសូម្បីទាំងអស់នេះ ជាអ្នកដល់ព្រមហើយនូវធម៌ដែលជាឧបនិស្ស័យនៃព្រះអរហត្ត" ក្នុងវេលារសៀល ទ្រង់ត្រាស់ទៅកាន់ព្រះមហាមោគ្គល្លានថា "មោគ្គល្លាន អ្នកឃើញអគ្គិទត្តព្រាហ្មណ៍ញុំាងមហាជនឲ្យហែលទៅតាមទីដែលមិនមែនជាកំពង់ទេ អ្នកចូរទៅ ចូរឲ្យឱវាទដល់មហាជនទាំងនោះ" ។

ព្រះថេរ:. បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងនោះច្រើន ខ្ញុំព្រះអង្គតែម្នាក់ឯង នឹងញុំាំញីមិនបាន ប្រសិនបើព្រះអង្គស្ដេចយាងទៅដែរ ពួកជនទាំងនោះនឹងញុំាំញីបាន ។

ព្រះសាស្ដា. មោគ្គល្លាន សូម្បីតថាគតក៏នឹងទៅ អ្នកចូរទៅមុនចុះ ។

ព្រះថេរ:និមន្តទៅបណ្ដើរ គិតបណ្ដើរថា "ជនទាំងនោះ ទាំងជាអ្នកមានកម្លាំងច្រើនផង ទាំងគ្នាច្រើនផង បើយើងនឹងពោលនូវពាក្យអ្វីៗ ក្នុងទីប្រជុំនៃជនទាំងនោះសោត ជនសូម្បីទាំងអស់នោះគប្បីក្រោកឡើងជាពួកៗ" ទើបញុំាងភ្លៀងដែលមានដំណក់ដ៏ថ្លោសឲ្យតាំងឡើង ដោយអានុភាពរបស់ខ្លួន ។

ជនទាំងនោះ កាលភ្លៀងមានដំណក់ដ៏ថ្លោសធ្លាក់ចុះមក ម្នាក់ៗ ក៏ក្រោកឡើង ហើយចូលទៅកាន់បណ្ណសាលារបស់ខ្លួនៗ ។ ព្រះថេរៈឈរនៅត្រង់ទ្វារបណ្ណ-សាលារបស់អគ្គិទត្តៈ ពោលថា "អគ្គិទត្តៈ" ។ គេបានឮសំឡេងរបស់ព្រះថេរៈហើយ ពោលថា "នោះជានរណា" ព្រោះជាអ្នករឹងត្អឹងដោយមានះថា "ក្នុងលោកនេះ អ្នកដែលហៅយើងចំណោះ រមែងមិនមាន នរណាហ្ន៎ ហៅយើងដោយចំណោះ" ។

ព្រះថេរៈ. ព្រាហ្មណ៍ អាត្មា ។

អគ្គិទត្តៈ. លោកនិយាយថាម៉េច?

ព្រះថេរៈ. សូមលោកចូរប្រាប់ទីសម្រាកក្នុងទីនេះដល់អាត្មាមួយយប់ក្នុងថ្ងៃនេះ ។

អគ្គិទត្តៈ. ទីស្នាក់ក្នុងទីនេះ មិនមាន បណ្ណសាលាតែមួយ ក៏សម្រាប់តែមនុស្សម្នាក់ប៉ុណ្ណោះ ។

ព្រះថេរៈ. អគ្គិទត្តៈ ធម្មតាពួកមនុស្ស រមែងទៅកាន់សម្នាក់នៃពួកមនុស្ស គោក៏ទៅកាន់សម្នាក់គោ ពួកបព្វជិតក៏ទៅកាន់សម្នាក់នៃពួកបព្វជិត លោកកុំធ្វើយ៉ាងនេះឡើយ ចូរឲ្យកន្លែងសម្រាកដល់អាត្មាផង ។

អគ្គិទត្តៈ. លោក ជាបព្វជិតឬ ?

ព្រះថេរៈ. អើ អាត្មាជាបព្វជិត ។

អគ្គិទត្តៈ. ប្រសិនបើអ្នកជាបព្វជិត វត្ថុ គឺ បរិក្ខាររបស់បព្វជិតរបស់

លោកនៅឯណា ?

ព្រះថេរ:. បរិក្ខាររបស់អាត្មាមាន តែអាត្មាគិតឃើញថា ការកាន់យកនូវបរិក្ខារនោះហើយ ត្រាច់ទៅជាការលំបាក ដូច្នេះហើយ ទើបកាន់យកនូវបរិក្ខារនោះដោយចំណែកជាខាងក្នុង ហើយត្រាច់ទៅប៉ុណ្ណោះ ព្រាហ្មណ៍ ។

ព្រាហ្មណ៍នោះខឹងចំពោះព្រះថេរៈថា "លោកនឹងកាន់យកបរិក្ខារនោះត្រាច់ទៅឬ?" គ្រានោះ ព្រះថេរៈនិយាយទៅកាន់ព្រាហ្មណ៍នោះថា "អគ្គិទត្តៈ អ្នកចូរចៀសចេញ អ្នកកុំខឹងអាត្មាអី ចូរប្រាប់ទីសម្រាកដល់អាត្មាចុះ ។

អគ្គិទត្តៈ. ក្នុងទីនេះ មិនមាន ។

ព្រះថេរ:. ចុះនរណា នៅលើគំនរដីខ្សាច់នោះ ?

អគ្គិទត្តៈ. នាគរាជមួយ ។

ព្រះថេរ:. អ្នកចូរឲ្យទីនោះដល់អាត្មាចុះ ។

អគ្គិទត្តៈ. ខ្ញុំមិនអាចឲ្យបានទេ អំពើរបស់នាគរាជនោះ កាចណាស់ ។

ព្រះថេរ:. ហ្នឹងយចុះ ចូរលោកឲ្យដល់អាត្មាចុះ ។

អគ្គិទត្តៈ. បើដូច្នោះ អ្នកចូរដឹងដោយខ្លួនឯងចុះ ។

ព្រះថេរៈផ្ចាញ់នាគរាជ

ព្រះថេរៈមានមុខឆ្ពោះទៅរកដីខ្សាច់ ហើយនិមន្តទៅកាន់ទីនោះ ។ នាគរាជឃើញព្រះថេរៈកំពុងនិមន្តមក ក៏គិតថា "សមណៈនេះនិមន្តមកនេះ ប្រហែលជាមិនដឹងថា យើងនៅទីនេះទេមើលទៅ យើងនឹងបង្ហុយផ្សែងញាំងសមណៈ

នេះឲ្យស្លាប់" លុះគិតដូច្នោះហើយ ក៏បន្ហុយផ្សែងចេញមក ។ ព្រះថេរៈគិតថា "នាគរាជនេះប្រហែលជាយល់ថា អញតែឯងអាចបន្ហុយផ្សែងបាន អ្នកដទៃរមែងមិនអាច" លុះគិតដូច្នេះហើយ ក៏បន្ហុយផ្សែងដែរ ។ ផ្សែងទាំងឡាយដែលហុយចេញអំពីសរីរៈនៃអ្នកទាំងពីររូប គឺ នាគរាជ និងព្រះថេរៈ តាំងឡើងរហូតដល់ព្រហ្មលោក ។ ផ្សែងទាំងពីរចំណែកនោះ មិនបានបៀតបៀនព្រះថេរៈទេ បៀតបៀនតែនាគរាជប៉ុណ្ណោះ ។ នាគរាជមិនអាចអត់ទ្រាំនឹងកម្លាំងផ្សែងបាន ក៏ឆេះ (ជាភ្លើង) ចំណែកព្រះថេរៈចូលសមាបត្តិ ដែលមានតេជោធាតុជាអារម្មណ៍ ឲ្យឆេះ (ជាភ្លើង) ព្រមជាមួយនឹងនាគរាជនោះដែរ ។ អណ្ដាតភ្លើងទាំងឡាយ តាំងឡើងរហូតដល់ព្រហ្មលោក ។ អណ្ដាតភ្លើងទាំងពីរចំណែកនោះ មិនបានបៀតបៀនព្រះថេរៈទេ បៀតបៀនតែនាគរាជប៉ុណ្ណោះ ។

ឆនាគរាជចាញ់ព្រះថេរៈ

គ្រានោះ សរីរៈទាំងមូលរបស់នាគរាជនោះ ដូចជា ត្រូវគប់ភ្លើងឆេះដូច្នោះ ។ ពួកឥសីមើលមើលហើយ គិតថា "នាគរាជដុតសមណៈៗ ដ៏ចម្រើននេះ មិនជឿពាក្យរបស់ពួកយើង ទើបវិនាសយ៉ាងនេះ" ។ ព្រះថេរៈបានទូន្មាននាគរាជ ធ្វើឲ្យអស់យសហើយ គង់លើគំនរជីឡាច់ ។ នាគរាជព័ទ្ធគំនរជីឡាច់ដោយក្អែនទាំងឡាយ បើកពពារប្រមាណប៉ុនផ្ទះកំពូលបាំងអំពីខាងលើព្រះថេរៈ ពួកឥសីទៅកាន់សម្នាក់របស់ព្រះថេរៈតាំងអំពីព្រលឹម ដោយគិតថា "ពួកយើងនឹងដឹងថា សមណៈនោះស្លាប់ហើយ ឬក៏មិនទាន់ស្លាប់" ឃើញព្រះថេរៈគង់

នៅលើគំនរខ្សាច់ហើយ ក៏ផ្គងអញ្ជលីសរសើរថា "បពិត្រសមណៈ នាគរាជមិនបានបៀតបៀនលោកទេឬ ?" ។

ព្រះថេរៈ. អ្នកទាំងឡាយមិនឃើញនាគរាជបើកពពារ ខាងលើអាត្មាទេឬ ?

ឥសីទាំងនោះ និយាយគ្នាថា "នែអ្នកដ៏ចម្រើនទាំងឡាយ គួរឲ្យអស្ចារ្យណាស់ហ្ន៎! អានុភាពរបស់សមណៈនេះបែបនេះ សមណៈនេះទូន្មាននាគរាជបានហើយ" លុះពោលដូច្នេះ ក៏ឈរចោមរោមព្រះថេរៈ ។

ក្នុងខណៈនោះឯង ព្រះសាស្តាស្តេចយាងមក ។ ព្រះថេរៈឃើញព្រះសាស្តាហើយ ក៏ក្រោកឡើងថ្វាយបង្គំ ។ គ្រានោះ ឥសីទាំងនោះ សួរព្រះថេរៈថា "សមណៈនេះធំជាងលោកទៅទៀតឬ ?" ។

ព្រះថេរៈ. ព្រះមានព្រះភាគអង្គនោះ ជាព្រះសាស្តា ខ្ញុំព្រះអង្គជាសាវករបស់ព្រះមានព្រះភាគ ។

ពួកឥសីសរសើរព្រះសាស្តា

ព្រះសាស្តា ទ្រង់ប្រថាប់គង់នៅលើគំនរដីខ្សាច់ ។ ពួកឥសីផ្គងអញ្ជលីសរសើរព្រះសាស្តាថា "អានុភាពរបស់សាវកដល់ម៉្លោះទៅហើយ ចំណង់បើអានុភាពរបស់ព្រះសាស្តា នឹងជាយ៉ាងណាទៅ" ។ ព្រះសាស្តាត្រាស់ហៅអគ្គិទត្តៈមកហើយ ត្រាស់ថា "អគ្គិទត្តៈ អ្នកកាលឲ្យឱវាទដល់សាវក និងឧបដ្ឋាកទាំងឡាយរបស់អ្នក រមែងឲ្យយ៉ាងណា?" ។

អគ្គិទត្ត:. ខ្ញុំព្រះអង្គ រមែងឲ្យឱវាទដល់សាវក និងឧបដ្ឋាកទាំងនោះយ៉ាងនេះថា "អ្នកទាំងឡាយ អ្នកទាំងឡាយចូរដល់ភ្នំថាជាទីពឹង ជាទីរឭក ចូរដល់ព្រៃ អារាម ចូរដល់ដើមឈើថាជាទីពឹង ជាទីរឭក ដ្បិតថា បុគ្គលអ្នកដល់វត្ថុទាំងឡាយ មានភ្នំជាដើមនោះ ថាជាទីពឹង ជាទីរឭកហើយ រមែងរួចចាកទុក្ខទាំងពួងបាន ។

## សរណៈដែលក្សេម និងមិនក្សេម

ព្រះសាស្តាត្រាស់ថា "អគ្គិទត្ត: បុគ្គលដែលដល់នូវវត្ថុទាំងឡាយ មានភ្នំជាដើមនោះ ថាជាទីពឹង ទីរឭកហើយ រមែងមិនរួចចាកទុក្ខទាំងពួងឡើយ លុះតែកណាបុគ្គលដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹង ទីរឭក ទើបរួចចាកទុក្ខទាំងពួងបាន" លុះទ្រង់ត្រាស់ដូច្នោះហើយ ក៏ទ្រង់បានភាសិតព្រះគាថាទាំងនេះថា ៖

៦. ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច
អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា
នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ
នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។
យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ

អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ
ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

មនុស្សទាំងឡាយច្រើននាក់ ត្រូវភ័យគម្រាមហើយតែងយកភ្នំ អារាម និងរុក្ខចេតិយ ជាទីពឹង ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលអាស្រ័យនូវទីពឹងនេះហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ ។ លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ហើយឃើញច្បាស់នូវអរិយសច្ចទាំង ៤ គឺ ទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ និរោធសច្ច ១ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វាន ដែលជាទីរម្ងាប់ទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ នេះឯងជាទីពឹងដ៏ក្សេម នេះឯងជាទីពឹងដ៏ឧត្តម បុគ្គលអាស្រ័យនូវទីពឹងនេះ រមែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ពហុំ បានដល់ ពហូ ប្រែថា ច្រើន ។ បទថា បព្វតានិ (ភ្នំ) ជាដើម សេចក្ដីថា មនុស្សទាំងឡាយនោះៗ ត្រូវភ័យនោះៗ គម្រាមហើយ ប្រាថ្នាដើម្បីរួចចាកភ័យ ឬប្រាថ្នាលាភទាំងឡាយ មានការបាន

បុត្រជាដើម រមែងយកភ្នំ មានភ្នំឥសិគិលិ វេបុល្ល: និងវេភារ:ជាដើម ព្រៃទាំងឡាយ មានព្រៃមហាវ័ន ព្រៃគោសិង្គសាលវ័នជាដើម អារាមទាំងឡាយ មានវេឡុវ័ន និងជីវកម្ពវ័នជាដើម និងរុក្ខចេតិយទាំងឡាយ មានឧទេនចេតិយ និងគោតមចេតិយជាដើម ក្នុងទីនោះៗ ជាទីពឹង ។ បទថា **នេតំ សរណំ (សរណ:នោះមិន...)** សេចក្ដីថា សរណវត្ថុ មានភ្នំជាដើមនុ៎ះ សូម្បីទាំងអស់ មិនមែនជាទីពឹងដ៏ក្សេម មិនមែនជាទីពឹងដ៏ឧត្ដមទេ មួយ៉ាងទៀត បណ្ដាសត្វទាំងឡាយអ្នកមានការកើតជាធម្មតា សូម្បីតែម្នាក់អាស្រ័យនូវសរណវត្ថុ មានភ្នំជាដើមនុ៎ះ រមែងមិនរួចចាកទុក្ខទាំងពួង មានជាតិជាដើមបានឡើយ ។

បទថា **យោ ច (ចំណែកបុគ្គលណា)** ជាដើមនេះ ព្រះមានព្រះភាគទ្រង់សម្ដែងសរណ:ដែលមិនក្សេម មិនឧត្ដមហើយ ទ្រង់ប្រារព្ធដើម្បីសម្ដែងនូវសរណ:ដ៏ក្សេម ដ៏ឧត្ដម ។ អត្ថនៃបទថា **យោ ច** ជាដើមនោះ (មានដូចតទៅនេះ) ៖

បុគ្គលណា ជាគ្រហស្ថក្ដី ជាបព្វជិតក្ដី អាស្រ័យកម្មដ្ឋាន មានការតាមរឭកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាដើមថា សូម្បីព្រោះហេតុនេះ ព្រះមាន-ព្រះភាគអង្គនោះ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹង ដោយអំណាចនៃវត្ថុដ៏ប្រសើរបំផុត ការដល់សរណ:នោះ របស់បុគ្គលនោះ រមែងកម្រើក រមែងញាប់ញ័រ ដោយកិច្ចទាំងឡាយ មានការសំពះអន្យ-តិរ្ថិយជាដើម តែព្រះមានព្រះភាគ កាលទ្រង់ប្រកាសនូវការដល់សរណ:នោះ

ដែលមិនកម្រើក កាលទឹងទ្រង់ប្រកាសសរណៈដែលមកហើយដោយមគ្គនោះឯង ទើបត្រាស់ថា "រមែងឃើញអរិយសច្ចៈ ៤ ដោយបញ្ញាដ៏ប្រពៃ" ព្រោះថា បុគ្គលណាដល់នូវរតនៈទាំងឡាយ មានពុទ្ធរតនៈជាដើមនោះ ជាទីពឹង ដោយអំណាចនៃការឃើញនូវអរិយសច្ចៈទាំងនោះ សរណៈនោះរបស់បុគ្គលនោះ ជាសរណដ៏ក្សេម ដ៏ឧត្តម បុគ្គលនោះអាស្រ័យសរណៈនោះ រមែងរួចចាកទុក្ខក្នុងវដ្ដៈ សូម្បីទាំងអស់បាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឯតំ ខោ សរណំ ខេមំ (សរណៈនោះឯង របស់បុគ្គលនោះទើបក្សេម)** ជាដើម ។

ក្នុងកាលចប់ព្រះធម៌ទេសនា ឥសីទាំងអស់នោះ ក៏បានសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ហើយថ្វាយបង្គំព្រះសាស្ដាទូលសូមបព្វជ្ជា ។ ព្រះសាស្ដាទ្រង់លាព្រះហស្ដចេញអំពីខាងក្នុងចីវរហើយ ទ្រង់ត្រាស់ថា "អ្នកទាំងឡាយ ចូរជាភិក្ខុចុះ ចូរប្រព្រឹត្តព្រហ្មចរិយៈ" ។

អ្នកស្រុកយល់ថា អគ្គិទត្តៈធំជាងព្រះសាស្ដា

ក្នុងខណៈនោះឯង ឥសីទាំងនោះទទួលនូវបរិក្ខារ ៨ ដូចជាព្រះថេរៈមានវស្សា ១០០ ។ ក៏ក្នុងថ្ងៃនោះ ជាថ្ងៃដែលអ្នកដែនអង្គៈ អ្នកដែនមគធៈនិងអ្នកដែនកុរុ នាំគ្រឿងសក្ការៈមក ។ ជនទាំងនោះនាំគ្រឿងសក្ការៈមកហើយ ឃើញឥសីទាំងអស់នោះបួសហើយ ក៏គិតថា "អគ្គិទត្តព្រាហ្មណ៍របស់ពួកយើងជាធំ ឬក៏ព្រះសមណគោតមជាធំ ហ្ន៎! " សម្គាល់ថា "អគ្គិទត្តៈធំជាងព្រះមាន-

ព្រះភាគដោយពិត ទើបព្រះគោតមសមណៈមករក” ។ ព្រះសាស្តាទ្រង់រមិល មើលនូវអធ្យាស្រ័យរបស់ជនទាំងនោះហើយ ត្រាស់ថា “អគ្គិទត្តៈ អ្នកចូរកាត់សេចក្តីសង្ស័យរបស់បរិស័ទ” ។ ព្រះអគ្គិទត្តៈនោះក្រាបទូលថា “សូម្បីខ្ញុំព្រះអង្គ ក៏ទន្ទឹងរង់ចាំនូវហេតុមានប្រមាណប៉ុណ្ណោះឯង” ដូច្នេះហើយ ក៏ហោះឡើងទៅកាន់វេហាស៍ដោយកម្លាំងឫទ្ធិ ហើយចុះមកថ្វាយបង្គំព្រះសាស្តារឿយៗ អស់វារៈ ៧ ដង ហើយប្រកាសភាវៈនៃខ្លួនជាសាវកថា “បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក” ដូច្នេះឯង ។

ចប់ រឿងបុរោហិតឈ្មោះអគ្គិទត្តៈ

# ៧. រឿងបញ្ហារបស់ព្រះអានន្ទ

*ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់ព្រះអានន្ទ ត្រាស់ព្រះធម្មទេសនានេះថា* ***ទុល្លភោ បុរិសាជញ្ញោ (បុរសអាជានេយ្យ រកបានដោយលំបាក)*** *ជាដើម ។*

ព្រះថេរៈរំពឹងដល់ទីកើតរបស់បុរសអាជានេយ្យ

*សេចក្ដីពិស្ដារថា ថ្ងៃមួយព្រះថេរៈគង់នៅក្នុងទីសម្រាកពេលថ្ងៃ គិតថា "ព្រះសាស្ដាកាលត្រាស់ពាក្យថា ដំរីអាជានេយ្យកើតឡើងក្នុងត្រកូលដំរីឆទ្ទន្ត ឬត្រកូលដំរីឧបោសថ សេះអាជានេយ្យ កើតឡើងក្នុងត្រកូលសេះសិន្ធព ឬក្នុងត្រកូលស្ដេចសេះ ឈ្មោះវលាហកៈ គោអាជានេយ្យ កើតក្នុងទក្ខិណាបថជនបទ ដូច្នេះជាដើម ជាការដែលព្រះអង្គត្រាស់នូវទីកើតនៃសត្វដ៏ប្រសើរ មានដំរីអាជានេយ្យជាដើម ឯបុរសអាជានេយ្យ តែងកើតឡើងក្នុងទីណាហ្ន៎?" ព្រះថេរៈនោះ ចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយទូលសួររឿងនោះ ។ ព្រះសាស្ដាត្រាស់ថា "អានន្ទ ឈ្មោះថា បុរសអាជានេយ្យ រមែងមិនកើតក្នុងទីទាំងពួងទេ តែរមែងកើតឡើងក្នុងមជ្ឈិមប្រទេស ដែលមានបណ្ដោយ ៣០០ យោជន៍ ដោយជុំវិញ ៩០០ យោជន៍ ក៏កាលទីងកើតឡើង រមែងមិនកើតឡើងក្នុងត្រកូលសាមញ្ញទេ រមែងកើតក្នុងត្រកូលខត្តិយមហាសាល និងកើតក្នុងត្រកូលព្រាហ្មណមហាសាល ត្រកូលណាមួយប៉ុណ្ណោះ" ដូច្នេះ ទើបបាន*

ត្រាស់ព្រះគាថានេះថា ៖

៧. ទុល្លភោ បុរិសាជញ្ញោ ន សោ សព្វត្ថ ជាយតិ
យត្ថ សោ ជាយតី ធីរោ តំ កុលំ សុខមេធតិ ។

បុរសអាជានេយ្យ រកបានដោយកម្រ លោកមិនកើតក្នុងសព្វ
ឋានឡើយ លោកជាអ្នកមានប្រាជ្ញាកើតក្នុងត្រកូលណា ត្រកូល
នោះ តែងដល់នូវសេចក្តីសុខ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា ទុល្លភោ (រកបានដោយលំបាក) ជាដើម សេចក្តីថា បុរសអាជានេយ្យ ជាបុគ្គលរកបានដោយក្រ គឺ មិនមែនជាអាជា-នេយ្យដែលបុគ្គលរកបានដោយងាយ ដូចជា តិរច្ឆានអាជានេយ្យទាំងឡាយ មានដំរីអាជានេយ្យជាដើមឡើយ បុរសអាជានេយ្យនោះ រមែងមិនកើតក្នុងទីទាំងពួង គឺ ក្នុងបច្ចន្តប្រទេស ឬក្នុងត្រកូលដ៏ទាប រមែងកើតតែក្នុងត្រកូលណាមួយ ក្នុងបណ្តាត្រកូលក្សត្រ និងត្រកូលព្រាហ្មណ៍ ក្នុងទីជាទីធ្វើសក្ការៈមានអភិវាទជាដើមនៃមហាជន ក្នុងមជ្ឈិមប្រទេសប៉ុណ្ណោះ ក៏បុរសអាជានេយ្យនោះ ជាអ្នកប្រាជ្ញ គឺ ជាអ្នកមានបញ្ញាដ៏ខ្ពង់ខ្ពស់ បានដល់ ព្រះសម្មាសម្ពុទ្ធកាលនឹងកើត រមែងកើតក្នុងត្រកូលណា ត្រកូលនោះ រមែងដល់នូវសេចក្តីសុខ គឺ រមែងជាត្រកូលដែលសម្រេចបាននូវសេចក្តីសុខពិត ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើន ក៏បានសម្រេចអរិយផល

ទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចប់ រឿងបញ្ហារបស់ព្រះអានន្ទ

# ៨. រឿងភិក្ខុច្រើនរូប

*ព្រះសាស្តា កាលប្រថាប់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការសន្ទនារបស់ភិក្ខុច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា* ***សុខោ ពុទ្ធានមុប្បាទោ (ការកើតឡើងរបស់ព្រះពុទ្ធទាំងឡាយ ជាហេតុនាំមកសេចក្ដីសុខ)*** *ជាដើម ។*

ការយល់ក្នុងបញ្ហាផ្សេង ៗ គ្នា

*សេចក្ដីពិស្ដារថា ថ្ងៃមួយ ភិក្ខុ ៥០០ រូប គង់នៅក្នុងសាលាជាទីបម្រើ (ឧបដ្ឋានសាលា) សន្ទនាគ្នាថា "អាវុសោទាំងឡាយ អ្វីហ្ន៎ ជាសុខក្នុងលោកនេះ?" បណ្ដាភិក្ខុទាំងនោះ ភិក្ខុពួកខ្លះពោលថា "ដែលឈ្មោះថា សុខ ដូចជាសុខក្នុងរាជសម្បត្តិ រមែងមិនមាន" ពួកខ្លះពោលថា "ដែលឈ្មោះថា សុខ ដូចជាសុខក្នុងកាម រមែងមិនមាន" ។ ពួកខ្លះពោលថា "ដែលឈ្មោះថា សុខ ដូចជាសុខដែលកើតអំពីការបរិភោគបាយអង្ករស្រូវសាលី និងសាច់ រមែងមិនមាន" ។*

ព្រះសាស្តាទ្រង់ដោះស្រាយបញ្ហានោះ

*ព្រះសាស្តា ស្ដេចយាងមកកាន់ទីដែលភិក្ខុទាំងនោះគង់ ហើយត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ អង្គុយប្រជុំគ្នាដោយកថាអ្វី?" កាលភិក្ខុទាំងនោះក្រាបទូលថា "ដោយកថាឈ្មោះនេះ" ទ្រង់ក៏ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយពោលអ្វី? ក៏សេចក្ដីសុខសូម្បីទាំងអស់ សុទ្ធតែ*

ជាសុខរាប់បញ្ចូលក្នុងវដ្ដទុក្ខទាំងអស់ តែហេតុនេះប៉ុណ្ណោះ គឺ ការឧប្បត្តិឡើងរបស់ព្រះពុទ្ធ ការស្ដាប់ធម៌ ការព្រមព្រៀងគ្នានៃពួកក្រុម ភាពជាអ្នករីករាយរកគ្នា ទើបចាត់ជាសុខក្នុងលោកនេះ" លុះត្រាស់ដូច្នេះហើយ ក៏ត្រាស់ព្រះគាថានេះថា ៖

៨. សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា
សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។
ការកើតឡើងនៃព្រះពុទ្ធ ជាសុខ ការសម្ដែងព្រះសទ្ធម្ម ជាសុខ សេចក្ដីព្រមព្រៀងគ្នានៃពួក ជាសុខ តបធម៌ របស់បុគ្គលអ្នកព្រមព្រៀងគ្នាទាំងឡាយ ជាសុខ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ពុទ្ធានមុប្បាទោ (ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ) សេចក្ដីថា ព្រះពុទ្ធទាំងឡាយ កាលទ្រង់ឧប្បត្តិឡើង រមែងញ៉ាំងមហាជនឲ្យឆ្លងចាកកន្ដារទាំងឡាយ មានកន្ដារ គឺ រាគៈជាដើម ព្រោះហេតុណា ហេតុនោះ ទើបជាហេតុនាំមកនូវសេចក្ដីសុខ ។ សត្វទាំងឡាយអ្នកមានទុក្ខ មានជាតិទុក្ខជាដើមជាធម្មតា អាស្រ័យការសម្ដែងធម៌របស់សប្បុរស រមែងរួចចាកទុក្ខទាំងពួង មានជាតិទុក្ខជាដើម ព្រោះហេតុណា ហេតុនោះ ការសម្ដែងធម៌របស់សប្បុរស ទើបឈ្មោះថា ជាហេតុនាំមកនូវសេចក្ដីសុខ ។ ភាពជាអ្នកមានចិត្តស្មើគ្នា ឈ្មោះថា សាមគ្គី ។ សូម្បីសាមគ្គីនោះ ក៏ជាហេតុនាំមកនូវ

សេចក្តីសុខដោយពិត ។ម្យ៉ាងទៀត ការរៀនព្រះពុទ្ធវចនៈក្តី ការរក្សាធុតង្គទាំងឡាយក្តី ការធ្វើសមណធម៌ក្តី នៃបុគ្គលអ្នកព្រមព្រៀងគ្នា គឺ អ្នកមានចិត្តតែមួយ ជាហេតុនាំមកនូវសេចក្តីសុខ ព្រោះហេតុណា ហេតុនោះឯង ទើបព្រះសាស្តាត្រាស់ថា **សមគ្គានំ តបោ សុខោ (ការព្រមព្រៀងគ្នានៃពួក ជាហេតុនាំមកនូវសេចក្តីសុខ)** ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយព្រមព្រៀងគ្នាប្រជុំ និងព្រមព្រៀងគ្នាលើកការប្រជុំ ព្រមព្រៀងគ្នាធ្វើនូវកិច្ចដែលគួររបស់សង្ឃ អស់កាលត្រឹមណា សេចក្តីចម្រើននឹងមានដល់អ្នកទាំងឡាយ អស់កាលត្រឹមនោះដែរ អ្នកទាំងឡាយ គប្បីសង្ឃឹមបាននូវសេចក្តីចម្រើននោះដោយពិត សេចក្តីសាបសូន្យនឹងមិនមានដល់អ្នកទាំងឡាយឡើយ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ភិក្ខុជាច្រើនបានសម្រេចព្រះអរហត្តផល ព្រះធម៌ទេសនា មានប្រយោជន៍សូម្បីដល់មហាជនហើយ ដូច្នេះឯង ។

ចប់ រឿងភិក្ខុច្រើនរូប

# ៩. រឿងព្រះចេតិយមាស របស់ព្រះកស្សបទសពល

*ព្រះបរមសាស្តា កាលស្តេចយាងទៅកាន់ទីចារិក ទ្រង់ប្រារព្ធព្រះចេតិយមាស របស់ព្រះកស្សបទសពល ទើបត្រាស់ព្រះធម៌ទេសនានេះថា បូជារហេ (បុគ្គលដែលគួរបូជា) ជាដើម ។*

*សេចក្តីពិស្តារថា ព្រះតថាគតមានភិក្ខុសង្ឃពួកធំជាពុទ្ធបរិវារ ស្តេចយាងចាកក្រុងសាវត្ថី ហើយស្តេចយាងទៅកាន់ក្រុងពារាណសីដោយលំដាប់ ស្តេចយាងដល់ទេវស្ថានមួយ ដែលនៅជិតស្រុកតោទេយ្យគ្រាម ក្នុងរវាងផ្លូវ ព្រះសុគតស្តេចប្រថាប់គង់នៅជិតទេវស្ថាននោះ ទ្រង់បញ្ជូនព្រះធម្មភណ្ឌាគារិក (គឺ ព្រះអានន្ទដែលជាឃ្លាំងធម៌) ឲ្យនិមន្តទៅប្រាប់ព្រាហ្មណ៍ ដែលកំពុងធ្វើនូវកសិកម្មត្រង់ទីជិតនោះ ឲ្យចូលមកគាល់ ។ ព្រាហ្មណ៍នោះមកដល់ហើយ មិនថ្វាយបង្គំព្រះតថាគតទេ តែថ្វាយបង្គំទេវស្ថាននោះ ហើយឈរនៅចំណែកម្ខាង ។ ព្រះសុគតក៏ត្រាស់ថា "ព្រាហ្មណ៍ អ្នកសម្គាល់ប្រទេសនេះថាជាទីអ្វី" ព្រាហ្មណក៏ក្រាបទូលថា "ព្រះគោតមដ៏ចម្រើន ខ្ញុំថ្វាយបង្គំទីនេះដោយតាំងចិត្តថា ទីនេះជាចេតិយស្ថានតាមប្រពៃណីរបស់ពួកខ្ញុំ" ។ ព្រះសុគតទើបញ៉ាំងឲ្យព្រាហ្មណ៍នោះរីករាយត្រេកអរដោយព្រះតម្រាស់ថា "ព្រាហ្មណ៍ អ្នកថ្វាយបង្គំស្ថានទីនេះ ឈ្មោះថា បានធ្វើនូវអំពើដ៏ប្រពៃហើយ" ។ ភិក្ខុទាំងឡាយបានស្តាប់*

នូវព្រះពុទ្ធតម្រាស់នោះហើយ ក៏កើតសេចក្ដីសង្ស័យថា “ព្រះមានព្រះភាគទ្រង់ញុំាងព្រាហ្មណ៍នោះ ឲ្យត្រេកអរយ៉ាងនេះ ព្រោះហេតុអ្វីហ្ន៎” ។ គ្រានោះ ព្រះសាស្ដា ដើម្បីទ្រង់ដោះនូវសេចក្ដីសង្ស័យរបស់ភិក្ខុទាំងនោះ ទើបត្រាស់ព្រះទេសនាក្នុងយជិការសូត្រ ក្នុងមជ្ឈិមនិកាយ ហើយទ្រង់និម្មិតព្រះចេតិយមាសរបស់ព្រះកស្សបទសពលកម្ពស់មួយយោជន៍ និងព្រះចេតិយមួយអង្គទៀត ទុកក្នុងអាកាស ទ្រង់សម្ដែងឲ្យមហាជនឃើញ ហើយត្រាស់ថា “ព្រាហ្មណ៍ ការបូជា ដល់បុគ្គលគួរបូជាដូច្នេះ រមែងគួរដោយពិត” ដូច្នេះហើយ ក៏ទ្រង់ប្រកាសនូវបូជារហបុគ្គល ៤ ពួក[១] មានព្រះពុទ្ធជាដើម តាមន័យដូចដែលត្រាស់ទុកក្នុងមហាបរិនិព្វានសូត្រនោះឯង ហើយទ្រង់សម្ដែងដោយពិស្ដារនូវព្រះចេតិយប្រភេទ គឺ សរីរចេតិយ ១ ឧទ្ទិសចេតិយ ១ បរិភោគចេតិយ ១ ។

លុះទ្រង់ត្រាស់ចេតិយ ៣ ប្រភេទចប់ហើយ បានទ្រង់ភាសិតនូវព្រះគាថានេះថា ៖

៩. បូជារហេ បូជយតោ ពុទ្ធេ យទិ ច សាវកេ
បបញ្ចសមតិក្កន្តេ តិណ្ណសោកបរិទ្ទវេ
តេ តាទិសេ បូជយតោ និព្វុតេ អកុតោភយេ
ន សក្កា បុញ្ញំ សង្ខាតុំ ឥមេត្តមបិ កេនចិ ។

កាលបុគ្គលបូជា ដល់បូជារហបុគ្គល គឺ ព្រះពុទ្ធ ឬសាវក

---

(១)- បូជារហបុគ្គល ៤ ពួក គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរហន្ត និងស្ដេចចក្រពត្តិ ។

របស់ព្រះពុទ្ធ ដែលកន្លងផុតបបញ្ចធម៌ ដែលកន្លងផុតសេចក្តី
សោក និងខ្សឹកខ្សួល ឬកាលបូជាដល់ បូជារហបុគ្គលទាំង
នោះ ដែលប្រកបដោយតាទិគុណ លោកមិនមានភ័យអំពី
ទីណា សូម្បីនិព្វានទៅហើយ បុគ្គលណាមួយ មិនអាចរាប់
បុណ្យថា បុណ្យនេះមានប្រមាណប៉ុណ្ណេះ បានឡើយ ។

អធិប្បាយគាថា

បុគ្គលដែលគួរបូជា អធិប្បាយថា អ្នកគួរដើម្បីបូជា ឈ្មោះថា បូជា-រហបុគ្គល ក្នុងព្រះគាថានោះ ។ បទថា **បូជារហេ បូជយតោ** (របស់បុគ្គលអ្នកបូជាហើយ ដល់បុគ្គលដែលគួរបូជា) សេចក្តីថា អ្នកបូជាហើយដោយការឱនលំទោន មានការថ្វាយបង្គំជាដើម និងដោយបច្ច័យ ៤ ។ ព្រះមានព្រះភាគទ្រង់សម្តែងបូជារហបុគ្គលដោយពាក្យថា **ពុទ្ធេ** គឺ ព្រះពុទ្ធទាំងឡាយ ។ បទថា **ពុទ្ធេ** (ព្រះពុទ្ធ) បានដល់ ព្រះសម្មាសម្ពុទ្ធ ។ ស័ព្ទនិបាតថា **យទិ** បានដល់ **យទិវា** អធិប្បាយថា **អថវា** គឺ ក៏ឬថា ។ ពាក្យថា នូវព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ទ្រង់ត្រាស់ទុកហើយក្នុងព្រះគាថានោះ ។ (ឬថា) ព្រះសាវកទាំងឡាយផង ។ បទថា **បបញ្ចសមតិក្កន្តេ** (អ្នកកន្លងផុតបបញ្ចធម៌បានហើយ) សេចក្តីថា បបញ្ចធម៌ គឺ តណ្ហា ទិដ្ឋិ មានះ លោកឈានកន្លងផុតហើយ ។ បទថា **តិណ្ណសោកបរិទ្ទវេ** (អ្នកមានសេចក្តីសោក និងសេចក្តីខ្សឹកខ្សួលកន្លងផុតហើយ) បានដល់ អ្នកមានសេចក្តីសោក និងសេចក្តីខ្សឹកខ្សួលកន្លងផុតទៅ

ហើយ អធិប្បាយថា កន្លងផុតបានទាំងពីរយ៉ាង ។ ភាពជាអ្នកគួរដល់ការបូជា ព្រះមានព្រះភាគត្រាស់ ដោយបទវិសេសនៈ (គុណបទ) ទាំងនោះ ។ បទថា **តេ** (ទាំងនោះ) បានដល់ ព្រះពុទ្ធជាដើម ។ បទថា **តាទិសេ** (បុគ្គលដូច្នោះ) បានដល់ អ្នកប្រកបដោយគុណដូច្នោះ ដោយអំណាចនៃគុណដូចពោលហើយ ។ បទថា **និព្វុតេ** (និព្វានហើយ) បានដល់ និព្វានដោយការរំលត់កិលេស មានរាគៈជាដើម ។ ភ័យអំពីទីណាៗ គឺ អំពីភព ឬអំពីអារម្មណ៍ រមែងមិនមានដល់បុគ្គលដែលគួរបូជាទាំងនោះ ដូច្នោះ បុគ្គលទាំងនោះ ទើបឈ្មោះថា មិនមានភ័យអំពីទីណាៗ ។ ចំពោះបុគ្គលដែលមិនមានភ័យអំពីទីណាៗ ទាំងនោះ ។ បទថា **ន សក្កា បុញ្ញំ សង្ខាតុំ** (ដែលនរណាៗ មិនអាចរាប់បុណ្យបាន) សេចក្តីថា មិនអាចគណនាបុណ្យបាន ។ ប្រសិនបើមានពាក្យសួរមកថា រាប់យ៉ាងណា? គប្បីឆ្លើយថា នរណាៗ ក៏មិនអាចរាប់បុណ្យថា បុណ្យនេះមានប្រមាណប៉ុណ្ណេះ អធិប្បាយថា នរណាៗ ក៏មិនអាចនឹងរាប់ថា បុណ្យនេះមានប្រមាណប៉ុណ្ណេះ បុណ្យនេះមានប្រមាណប៉ុណ្ណេះ ។ **អបិ** ស័ព្ទ គប្បីភ្ជាប់ជាមួយបទថា **កេនចិ** អធិប្បាយថា ដែលបុគ្គលណាៗ ឬពោលដោយការរាប់វិធីណាៗ ក្នុងពាក្យទាំងពីរនោះ ។ បទថា **បុគ្គលេន** (ដែលបុគ្គល) បានដល់ ដែលបុគ្គលនោះ មានព្រះព្រហ្មជាដើម ។ ពាក្យថា **ដោយការរាប់** បានដល់ ដោយការរាប់ ៣ យ៉ាង គឺ ដោយការគណនា ដោយការថ្លឹង និងដោយការវាល់ ។ ការគណនា ដោយន័យថា វត្ថុនេះមានប្រមាណប៉ុណ្ណេះ ឈ្មោះថា គណនា

ការបូជា ដោយគ្រឿងបូជា ឈ្មោះថា បូជា ។ ការធ្វើឲ្យពេញ (វាល់) ដោយកន្ទះទូកដៃ មួយទូកដៃ បំពង់ និងនាឡិជាដើម ឈ្មោះថា វាល់ ។ បុគ្គលណាៗ ក៏មិនអាចរាប់បុណ្យរបស់អ្នកបូជា ចំពោះបុគ្គលដែលគួរបូជា មានព្រះពុទ្ធជាដើម ដោយការរាប់ទាំង ៣ វិធីនេះ ដោយអំណាចនៃវិបាក គឺ ផល ព្រោះវៀរចាកទីបំផុតដូច្នេះ ។

ផលនៃទានរបស់បុគ្គលអ្នកបូជាក្នុងស្ថានទាំងពីរ ដូចម្តេច? បុណ្យរបស់បុគ្គលអ្នកបូជាចំពោះព្រះពុទ្ធជាដើម ដែលទ្រង់នៅមានព្រះជន្ម នរណាៗ ក៏មិនអាចរាប់បាន ។ បុណ្យរបស់បុគ្គលអ្នកបូជាចំពោះព្រះពុទ្ធជាដើម សូម្បីនិព្វានទៅហើយ ដោយខន្ធបរិនិព្វាន ដែលមានកិលេសបរិនិព្វានជានិមិត្ត អ្នកណាៗ ក៏មិនអាចរាប់បានទៀតហ្ន៎ ព្រោះដូច្នោះ គប្បីទីងផ្សេងគ្នាខ្លះ ។ ព្រោះហេតុ (តែមានសេចក្តីសង្ស័យ) នោះឯង ទើបសក្កទេវរាជពោលក្នុងវិមានវត្ថុថា ៖

> “កាលព្រះសម្ពុទ្ធជាដើម ទ្រង់នៅមានព្រះជន្មក្តី និព្វានទៅហើយក្តី
> កាលចិត្តស្មើគ្នា ផលក៏រមែងស្មើគ្នា ព្រោះហេតុ គឺ សេចក្តីជ្រះថ្លា
> នៃចិត្ត សត្វទាំងឡាយ រមែងទៅកាន់សុគតិ” ។

ក្នុងអវសាននៃព្រះធម៌ទេសនា ព្រាហ្មណ៍នោះក៏បានជាសោតាបន្ន ។ ព្រះចេតិយមាសកម្ពស់ទាំងយោជន៍ បានតាំង (លេចឡើង) នៅក្នុងអាកាសអស់ ៧ ថ្ងៃ ។ ក៏សមាគម បានមានហើយដោយជនជាច្រើន ពួកគេបូជាព្រះ

*ចេតិយដោយប្រការផ្សេងៗ អស់ ៧ ថ្ងៃ ។ តអំពីនោះ សេចក្តីផ្សេងគ្នានៃលទ្ធិរបស់អ្នកមានលទ្ធិផ្សេងគ្នា បានកើតមានហើយ ។ ព្រះចេតិយនោះ បានទៅកាន់ទីរបស់ខ្លួនវិញដោយពុទ្ធានុភាព ក្នុងខណៈនោះ ព្រះចេតិយសិលាដ៏ធំបានផុសឡើងហើយក្នុងទីនោះ ។ ប្រជាសត្វ ៨៤.០០០ បានសម្រេចធម្មាភិសម័យ (គឺត្រាស់ដឹងធម៌) ហើយក្នុងសមាគមនោះ ។*

ចប់ រឿងព្រះចេតិយមាសរបស់ព្រះកស្សបទសពល

## ចប់ពុទ្ធវគ្គវណ្ណនា វគ្គទី ១៤

ក្នុងវគ្គនេះរួមមាន ០៩ រឿង


១.រឿងមារធីតា
២. រឿងយមកប្បាដិហារ្យ
៣.រឿងឯរកបត្តនាគរាជ
៤. រឿងបញ្ហាព្រះអានន្ទ
៥.រឿងភិក្ខុអ្នកមិនត្រេកអរ
៦.រឿងអគ្គិទត្តបុរោហិត
៧.រឿងបញ្ហាព្រះអានន្ទ
៨.រឿងសម្ពហុលភិក្ខុ
៩.រឿងព្រះចេតិយមាសរបស់ព្រះកស្សបទសពល

# សុខវគ្គ ទី ១៥

"ពោលអំពីសេចក្ដីសុខពិត"

## ១. រឿងការរំងាប់ជម្លោះរបស់ពួកព្រះញាតិ

**[២៥]** *ព្រះសាស្ដា កាលប្រថាប់គង់នៅក្នុងដែនរបស់អ្នកស្រុកសក្កៈ ទ្រង់ប្រារព្ធពួកព្រះញាតិដើម្បីរម្ងាប់នូវជម្លោះ ទើបត្រាស់ព្រះធម្មទេសនានេះថា* ***សុសុខំ វត (សុខ ហ្ន៎)*** *ជាដើម ។*

ការវិវាទកើតឡើងព្រោះការដណ្ដើមទឹក

*បានឮថា ពួកសាក្យៈ និងពួកកោលិយៈ បញ្ជាឲ្យទប់ស្ទឹងរោហិណី ដោយធ្វើទំនប់តែមួយ ក្នុងរវាងនគរកបិលពស្តុ និងនគរកោលិយៈ ដើម្បីធ្វើស្រែ ។ គ្រានោះ កាលសន្ទូងទាំងឡាយស្វិតក្នុងចំណែកខាងដើមនៃខែជេស្ឋ ពួកកម្មករនៃអ្នកនគរទាំងពីរនោះប្រជុំគ្នា ។ ក្នុងអ្នកនគរទាំងពីរនោះ អ្នកនគរកោលិយៈពោលថា "ទឹកនេះ បើត្រូវពួកយើងនាំទៅ នឹងមិនគ្រប់គ្រាន់ដល់ពួកលោក, កាលបើពួកលោកនាំទៅ ក៏នឹងមិនគ្រប់គ្រាន់ដល់ពួកយើង តែសន្ទូងរបស់ពួកយើងនឹងសម្រេចដោយទឹកតែមួយចំណែកប៉ុណ្ណោះ ពួកលោកចូរឲ្យទឹកនេះដល់ពួកយើងចុះ" ។ ចំណែកពួកអ្នកនគរសក្យៈ ពោលយ៉ាងនេះថា "បើពួកលោកធ្វើជង្រុកឲ្យពេញហើយ ពួកខ្ញុំនឹងមិនអាចកាន់យកមាស កែវ-*

មណីពណ៌ខៀវ កែវពណ៌ខ្មៅ និងកហាបណៈទាំងឡាយ ហើយកាន់កញ្ជើ និងបាវជាដើម ដើរទៅត្រង់ទ្វារផ្ទះរបស់ពួកលោក សទ្ធងរបស់ពួកខ្ញុំ ក៏សម្រេចដោយទឹករួមតែម្យ៉ាងដូចគ្នា ពួកលោកចូរឲ្យទឹកនេះដល់ពួកយើងចុះ” ។

កោលិយៈ. ពួកយើងនឹងមិនឲ្យ ។

សក្យៈ. សូម្បីពួកយើងក៏មិនឲ្យដែរ ។

ពួកអ្នកនគរទាំងពីរនោះ ញុំាងសម្ដីឲ្យចម្រើនឡើងដោយអាការយ៉ាងនេះហើយ ប្រហារនូវគ្នានិងគ្នាយ៉ាងនេះ គឺ ម្នាក់ក្រោកឡើង ហើយប្រហារម្នាក់ទៀត សូម្បីអ្នកដែលត្រូវគេប្រហារនោះ ក៏ប្រហារសូម្បីជនដទៃ ការប៉ះទង្គិចដល់ជាតិ និងរាជត្រកូលទាំងឡាយ ក៏ញុំាងជម្លោះឲ្យចម្រើនឡើង ។ ពួកកម្មករអ្នកដែនកោលិយៈទាំងឡាយពោលថា “ពួកអ្នក ចូរនាំក្មេងអ្នកក្រុងកបិលពស្ដុទៅចុះ ជនពួកណាដែលនៅរួមនឹងបងប្អូនស្រីរបស់ខ្លួនៗ ដូចជាសត្វឆ្កែស្រុក និងឆ្កែព្រៃជាដើម ដំរី សេះ ខែល និងអាវុធទាំងឡាយ របស់ជនទាំងនោះនឹងធ្វើអ្វីពួកយើងបាន” ។

ចំណែកកម្មករអ្នកដែនសក្យៈទាំងឡាយពោលថា “ឥឡូវនេះ ពួកអ្នកចូរនាំយកក្មេងដែលមានរោគឃ្លង់ទៅវិញចុះ ។ ជនពួកណា មិនមានទីពឹងមិនមានគតិ នៅក្រោមដើមក្រថៅ ដូចសត្វតិរច្ឆានទាំងឡាយ ដំរី សេះ ខែល និងអាវុធរបស់ជនទាំងនោះ នឹងធ្វើអ្វីពួកយើងបាន” ។ ជនទាំងនោះ ទៅប្រាប់ពួកអាមាត្យអ្នកត្រួតត្រាក្នុងការងារនោះ ។ ពួកអាមាត្យ ក៏ក្រាបទូលដល់រាជ-

ត្រកូលទាំងឡាយ ។ គ្រានោះ ពួកសក្យៈទាំងឡាយគិតថា “ពួកយើងនឹងសម្តែងនូវកម្លាំងផង នូវឥទ្ធិពលផង របស់អ្នកនៅរួមជាមួយនឹងបងប្អូនស្រីទាំងឡាយ” ហើយត្រៀមកលយុទ្ធចេញទៅ ។ ចំណែកស្តេចកោលិយៈទាំងឡាយទ្រង់គិតថា “ពួកយើងនឹងសម្តែងនូវកម្លាំងផង នូវឥទ្ធិពលផង របស់អ្នកនៅក្រោមដើមក្រថៅ” ដូច្នេះហើយ ក៏ត្រៀមកលយុទ្ធ ចេញទៅ ។

ព្រះសាស្តាស្តេចយាងឃាត់ព្រះញាតិ

ព្រះសាស្តា ទ្រង់ត្រួតមើលនូវសត្វលោកក្នុងវេលាជិតភ្លឺ ទ្រង់ឃើញពួកព្រះញាតិហើយ ទ្រង់ព្រះតម្រិះថា “បើតថាគតមិនទៅ ពួកព្រះញាតិទាំងនោះនឹងវិនាស តថាគតទៅកាន់ទីនោះទើបគួរ លុះទ្រង់ព្រះតម្រិះដូច្នោះហើយស្តេចក៏យាងទៅតាមអាកាសតែមួយព្រះអង្គឯង ទ្រង់ប្រថាប់គង់ដោយព្រះភ្លែនឰដ៏អាកាស ត្រង់កណ្តាលស្ទឹងរោហិណី ។ ព្រះញាតិទាំងឡាយបានឃើញព្រះសាស្តាហើយ ក៏បោះអាវុធចោល មកថ្វាយបង្គំ ។ គ្រានោះ ព្រះសាស្តាត្រាស់សួរព្រះញាតិទាំងនោះថា “មហាបពិត្រ ជម្លោះហ្នឹង ឈ្មោះថា ជាជម្លោះអ្វី?” ។

ពួកព្រះញាតិ. បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនជ្រាបទេ ។

ព្រះសាស្តា. ឥឡូវនេះ នរណាដឹងរឿងនោះ ។

ព្រះញាតិទាំងនោះ សួររហូតដល់ពួកទាសៈ និងកម្មករ ដោយឧបាយនេះថា “ឧបរាជនឹងដឹង សេនាបតីនឹងដឹង” ជាដើម ហើយក្រាបទូលថា “បពិត្រ

ព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គឈ្លោះគ្នា ព្រោះទឹក" ។

ព្រះសាស្តា. មហាបពិត្រ ទឹកមានតម្លៃប៉ុន្មាន ?

ព្រះញាតិ. បពិត្រព្រះអង្គដ៏ចម្រើន មានតម្លៃតិចតួច ។

ព្រះសាស្តា. ក្សត្រទាំងឡាយ មានតម្លៃប៉ុន្មាន ?

ព្រះញាតិ. បពិត្រព្រះអង្គដ៏ចម្រើន ដែលឈ្មោះថា ក្សត្រ មានតម្លៃកាត់ថ្លៃមិនបាន ។

ព្រះសាស្តា. ក៏ការដែលអ្នកទាំងឡាយ ធ្វើពួកក្សត្រដែលកាត់ថ្លៃមិនបានឲ្យវិនាស ព្រោះអាស្រ័យទឹកមានតម្លៃតិចតួច គួរហើយឬ? ។

ព្រះញាតិទាំងនោះ ក៏បាននៅស្ងៀម ។ លំដាប់នោះ ព្រះសាស្តាត្រាស់ហៅព្រះញាតិទាំងនោះមក ហើយទ្រង់ត្រាស់ថា "មហាបពិត្រ ព្រោះហេតុអ្វី មហាបពិត្រទាំងឡាយ ទ្រង់ធ្វើយ៉ាងនេះ កាលបើមិនមានតថាគតទេ ក្នុងថ្ងៃនេះ ស្ទឹង គឺ លោហិតនឹងហូរ ទ្រង់ទាំងឡាយបានធ្វើនូវអំពើដែលមិនសមគួរឡើយ ទ្រង់ទាំងឡាយ ជាអ្នកមានពៀរ ដោយពៀរ ៥ ប្រការ តថាគតមិនមានពៀរ ទ្រង់ទាំងឡាយជាអ្នកក្រហល់ក្រហាយដោយកិលេស តថាគតមិនមានសេចក្តីក្រហល់ក្រហាយ ទ្រង់ទាំងឡាយ ជាអ្នកមានសេចក្តីខ្វល់ខ្វាយក្នុងការស្វែងរកកាមគុណ តថាគតមិនមានសេចក្តីខ្វល់ខ្វាយ" ទើបបានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖

១. សុសុខំ វត ជីវាម     វេរិនេសុ អវេរិនោ

វេរិនេសុ មនុស្សេសុ វិហរាម អវេរិនោ ។
សុសុខំ វត ជីវាម អាតុរេសុ អនាតុរា
អាតុរេសុ មនុស្សេសុ វិហរាម អនាតុរា ។
សុសុខំ វត ជីវាម ឧស្សុកេសុ អនុស្សុកា
ឧស្សុកេសុ មនុស្សេសុ វិហរាម អនុស្សុកា ។

យើងជាអ្នកមិនមានពៀរ រស់នៅជាសុខពិត ក្នុងពួកមនុស្សអ្នកមានពៀរ កាលពួកមនុស្សមានពៀរ យើងជាអ្នកមិនមានពៀរ ។ យើងជាអ្នកមិនមានសេចក្ដីក្ដៅក្រហាយ ដោយកិលេស រស់នៅជាសុខពិត ក្នុងពួកមនុស្សអ្នកមានសេចក្ដីក្ដៅក្រហាយ កាលពួកមនុស្សមានសេចក្ដីក្ដៅក្រហាយ យើងជាអ្នកមិនមានសេចក្ដីក្ដៅក្រហាយ ។ យើងជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយក្នុងការស្វែងរក រស់នៅជាសុខពិត ក្នុងពួកមនុស្សអ្នកមានសេចក្ដីខ្វល់ខ្វាយ កាលពួកមនុស្សមានសេចក្ដីខ្វល់ខ្វាយ យើងជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា សុសុខំ បានដល់ សប្បាយ ។ ព្រះមាន-ព្រះភាគត្រាស់អធិប្បាយពាក្យនេះទុកថា “ក្នុងមនុស្សទាំងឡាយអ្នកមានពៀរនឹងគ្នា ដោយពៀរ ៥ ប្រការ តថាគតមិនមានពៀរ ក្នុងមនុស្សទាំងឡាយអ្នក

មានសេចក្តីក្តៅក្រហាយដោយកិលេស (តថាគត) ឈ្មោះថា មិនមានសេចក្តីក្តៅក្រហាយ ព្រោះជាអ្នកមិនមានកិលេស ក្នុងពួកមនុស្ស អ្នកមានសេចក្តីខ្វល់ខ្វាយក្នុងការស្វែងរកកាមគុណ ៥ (តថាគត) ឈ្មោះថា មិនមានសេចក្តីខ្វល់ខ្វាយ ព្រោះមិនមានការស្វែងរក ទើបរស់នៅជាសុខសប្បាយជាងពួកគ្រហស្ថ អ្នកញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃការកាត់ទី.តជាដើម ឬជាងពួកបព្វជិត អ្នកចិញ្ចឹមជីវិតដោយបាបកម្ម មានវេជ្ជកម្មជាដើម ហើយពោលថា តថាគតរស់នៅសុខ ។ បទដ៏សេសមានន័យងាយទាំងអស់ ។

ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។

ចប់ រឿងការរម្ងាប់ជម្លោះរបស់ពួកព្រះញាតិ

# ២. រឿងមារ

*ព្រះសាស្តា កាលប្រថាប់គង់នៅក្នុងស្រុកព្រាហ្មណ៍ ឈ្មោះបញ្ចសាលា ទ្រង់ប្រារព្ធមារ ត្រាស់ព្រះធម្មទេសនានេះថា **សុសុខំ វត (សុខហ្ន៎)** ជាដើម ។*

ក្មេងស្រី ៥០០ លេងនក្ខត្តប្ញក្ស

*បានឮថា ថ្ងៃមួយព្រះសាស្តា ទ្រង់ឃើញនូវធម៌ដែលជាឧបនិស្ស័យ នៃសោតាបត្តិមគ្គរបស់កុមារិកា ៥០០ រូប ទើបស្តេចយាងចូលទៅអាស្រ័យស្រុកនោះ ។ ក៏កុមារិកាទាំងនោះ ទៅកាន់ស្ទឹងក្នុងថ្ងៃនក្ខត្តប្ញក្ស ងូតទឹក ស្លៀកពាក់រួចស្រេចហើយ ដើរចូលទៅកាន់ស្រុក ។ ចំណែកព្រះសាស្តា ស្តេចក៏យាងចូលទៅកាន់ស្រុកនោះ ដើម្បីបិណ្ឌបាតដែរ ។ មារចូលជ្រែកក្នុងសរីរៈនៃជនអ្នកនៅក្នុងស្រុកទាំងអស់ ធ្វើមិនឲ្យព្រះសាស្តា បាននូវភិក្ខាសូម្បីតែមួយវែក ឈរនៅត្រង់ទ្វារផ្ទះ ទូលសួរព្រះសាស្តានៅពេលដែលស្តេចយាងចេញមក ដោយមានបាត្រដូចជាបុគ្គលលាងទុកហើយថា "សមណៈ លោកបានដុំបាយខ្លះហើយឬ?" ។*

*ព្រះសាស្តា. ម្នាលមារមានចិត្តបាប អ្នកបានធ្វើមិនឲ្យតថាគតបានភិក្ខាឬ? ។*

*មារ. ព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមស្តេចចូលទៅម្តងទៀតចុះ ។*

*បានឮថា មារមានការគិតយ៉ាងនេះថា "ប្រសិនបើព្រះសមណគោតម*

នឹងចូលទៅម្តងទៀត យើងនឹងចូលជ្រែកក្នុងសរីរៈនៃជនទាំងពួង ហើយទះដៃសើចចំអកអំពីខាងមុខព្រះសមណគោតម” ។ ក្នុងខណៈនោះ កុមារិកាទាំងនោះ មកដល់ទ្វារស្រុក ឃើញព្រះសាស្តា ថ្វាយបង្គំហើយ បានឈរនៅក្នុងទីម្ខាង ។ ចំណែកមារទូលព្រះសាស្តាថា “បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គកាលមិនបានដុំបាយ នឹងជាអ្នកត្រូវទុក្ខដែលកើតអំពីសេចក្តីឃ្លាន បៀតបៀនហើយឬ?” ។

អ្នកមិនកង្វល់ សោយបីតិជំនួសអាហារ

ព្រះសាស្តាត្រាស់ថា “ម្នាលមារមានចិត្តបាប ថ្ងៃនេះសូម្បីតថាគតមិនបាននូវអ្វីតិចតួច ក៏នឹងញ៉ាំងកាលឲ្យកន្លងទៅដោយសុខ ដែលកើតអំពីបីតិតែម្យ៉ាង ដូចជាព្រហ្មក្នុងទេវលោកជាន់អាភស្សរៈ” ហើយត្រាស់ព្រះគាថានេះថា ៖

*២. សុសុខំ វត ជីវាម យេសន្នោ នត្ថិ កិញ្ចនំ*
*បីតិភក្ខា ភវិស្សាម ទេវា អាភស្សរា យថា ។*

*យើងមិនមានកង្វល់ តែងរស់នៅជាសុខពិត (ព្រោះ) យើង*
*មានបីតិជាអាហារ ដូចពួកទេវតាជាន់អាភស្សរៈ ។*

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **យេសន្នោ (យើងជាអ្នក)** សេចក្តីថា បណ្តាកិលេសជាតជាគ្រឿងកង្វល់ទាំងឡាយ មានរាគៈជាដើម កិលេសជាតជាគ្រឿង

កន្លស់សូម្បីតែមួយ ដោយអត្ថថា ជាគ្រឿងចង រមែងមិនមានដល់តថាគត ។

បទថា **បីតិភក្ខា (អ្នកមានបីតិជាភក្សា)** ពួកទេវតាជាន់អាភស្សរៈ ជាអ្នកមាន បីតិជាអាហារ ញុំាងកាលឲ្យកន្លងទៅ យ៉ាងណា សូម្បីតថាគត ក៏ដូច្នោះ ។

ក្នុងកាលចប់ទេសនា កុមារិកាទាំង ៥០០ នាក់នោះ ក៏បានតាំងនៅក្នុង សោតាបត្តិផល ។

ចប់ រឿងរបស់មារ

# ៣. រឿងបរាជ័យរបស់ព្រះបាទកោសល

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបរាជ័យរបស់ព្រះបាទកោសល ត្រាស់ព្រះធម្មទេសនានេះថា **ជយំ វេរំ** (អ្នកឈ្នះរមែងបាននូវពៀរ)* ជាដើម ។

អ៊ុំចាញ់ក្មួយ

*បានឮថា ព្រះបាទកោសលនោះ ទ្រង់អាស្រ័យកាសិកគ្រាម ទ្រង់ច្បាំងជាមួយនឹងព្រះបាទអជាតសត្រូវ ដែលជាក្មួយរបស់ព្រះអង្គ កាលព្រះបាទអជាតសត្រូវនោះឲ្យចាញ់ហើយ អស់វារៈ ៣ ដង ក្នុងវារៈទី ៣ ទ្រង់ព្រះតម្រិះថា "យើងមិនអាចនឹងញ៉ាំងក្មេងដែលមានមាត់មិនទាន់អស់ក្លិនទឹកដោះ ឲ្យចាញ់បាន ប្រយោជន៍អ្វីដោយការរស់នៅរបស់យើង" ព្រះរាជា ទ្រង់ផ្តាច់ព្រះក្រយាហារ ស្តេចផ្ទំនៅលើព្រះទែន ។ គ្រានោះ ការប្រព្រឹត្តទៅរបស់ព្រះរាជានោះ ផ្សាយទូទៅក្នុងព្រះនគរ ។ ភិក្ខុទាំងឡាយ ក្រាបទូលព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ព្រះរាជាទ្រង់អាស្រ័យកាសិកគ្រាមត្រូវព្រះបាទអជាតសត្រូវឲ្យទ្រង់បរាជ័យហើយ ៣ ដង ឥឡូវនេះ ព្រះបាទកោសលនោះ ទ្រង់បរាជ័យ (ត្រឡប់) មកហើយ ទ្រង់ផ្តាច់នូវព្រះក្រយាហារហើយទ្រង់ផ្ទំនៅលើព្រះទែន ដោយទ្រង់ត្រិះរិះថា "យើងមិនអាចនឹងញ៉ាំងក្មេងដែលមានមាត់ មិនទាន់អស់ក្លិនទឹកដោះឲ្យចាញ់បាន ប្រយោជន៍អ្វីដោយការ*

រស់នៅរបស់យើង?" ។ ព្រះសាស្តា ទ្រង់ស្តាប់នូវកថារបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកឈ្នះ រមែងបាននូវពៀរ ចំណែកបុគ្គលអ្នកចាញ់ រមែងដេកជាទុក្ខ" ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

*៣. ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ*
*ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។*

*បុគ្គលអ្នកឈ្នះ តែងរងនូវពៀរ បុគ្គលអ្នកចាញ់ តែងដេកជាទុក្ខ ចំណែកបុគ្គលលះបង់ ការឈ្នះ និងការចាញ់ចេញហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ ។*

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ជយំ** (អ្នកឈ្នះ) សេចក្តីថា អ្នកឈ្នះបុគ្គលដទៃ រមែងត្រឡប់បាននូវពៀរ ។ បទថា **បរាជិតោ** (អ្នកចាញ់) សេចក្តីថា អ្នកដែលបុគ្គលដទៃឲ្យចាញ់ហើយ រមែងដេកជាទុក្ខ គឺ រមែងនៅជាទុក្ខក្នុងឥរិយាបថទាំងពួង ព្រោះគិតថា "កាលណាហ្ន៎! ទើបយើងឃើញខ្នងរបស់បច្ចាមិត្ត?" ។ បទថា **ឧបសន្តោ** (អ្នកស្ងប់រម្ងាប់) សេចក្តីថា ព្រះខីណាស្រពអ្នកមានកិលេស មានរាគៈជាដើមក្នុងខាងក្នុងស្ងប់ហើយ លះបង់នូវការឈ្នះនិងការចាញ់ចេញហើយ រមែងនៅជាសុខ គឺ រមែងរស់នៅដោយសុខ ក្នុងឥរិយាបថទាំងពួង ។

ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចប់ រឿងបរាជ័យរបស់ព្រះចានកោសល

# ៤. រឿងក្មេងស្រីរបស់ត្រកូលមួយ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុមារិកាម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា* ***នត្ថិ រាគសមោ អគ្គិ (ភ្លើងស្មើដោយរាគៈមិនមាន)*** *ជាដើម ។*

ព្រះសាស្តាស្តេចប្រថាប់នៅក្នុងរោងអាវាហមង្គល

*បានឮថា មាតារបស់កុមារិកានោះ ធ្វើអាវាហមង្គល និមន្តព្រះសាស្តា ក្នុងថ្ងៃអាវាហមង្គលនោះ ។ ព្រះសាស្តា មានពួកភិក្ខុហែហម ស្តេចយាងទៅកាន់រោងអាវាហមង្គលនោះ ប្រថាប់នៅហើយ ។ នាងកុមារិកានោះ ធ្វើនូវកិច្ចទាំងពួង មានការត្រងទឹកជាដើមដើម្បីពួកភិក្ខុ បានដើរទៅដើរមក ។ ឯស្វាមីរបស់នាងឈរសម្លឹងមើលនាង កាលគេឈរសម្លឹងមើល រាគៈដែលជាកិលេសខាងក្នុង ក៏ផុសផុលឡើង ។ គេត្រូវសេចក្តីមិនដឹងគ្របសង្កត់ហើយ ទើបមិនបម្រើព្រះសម្ពុទ្ធ មិនបម្រើព្រះមហាថេរៈ ៨០ អង្គ បែរជាធ្វើទុកក្នុងចិត្តថា "យើងនឹងលាដៃចាប់ស្ត្រីនោះ" ។ ព្រះសាស្តាទ្រង់ឃើញអធ្យាស្រ័យរបស់បុរសនោះហើយ ទ្រង់បានធ្វើមិនឲ្យគេមើលឃើញស្ត្រីនោះ ។ កាលគេមើលមិនឃើញស្ត្រីនោះ ទើបគេឈរសម្លឹងមើលព្រះសាស្តា ។ ក្នុងកាលដែលគេឈរសម្លឹងមើលនោះ ព្រះសាស្តាត្រាស់ថា "ម្នាលកុមារតូច ដែលឈ្មោះថា ភ្លើងប្រាកដស្មើដោយភ្លើង គឺ រាគៈមិនមាន ឈ្មោះថា ទោសប្រាកដស្មើ*

ដោយទោស គឺ ទោសៈមិនមាន ឈ្មោះថា ទុក្ខប្រាកដស្មើដោយទុក្ខ ព្រោះការរក្សាខន្ធ មិនមាន សូម្បីសុខដូចជានិព្វានសុខ មិនមានដូចគ្នា” ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

៤. នត្ថិ រាគសមោ អគ្គិ    នត្ថិ ទោសសមោ កលិ
នត្ថិ ខន្ធសមា ទុក្ខា    នត្ថិ សន្តិ បរំ សុខំ ។

ភ្លើងស្មើដោយរាគៈ មិនមាន ទោសកំហុសស្មើដោយទោសៈ មិនមាន ទុក្ខទាំងឡាយស្មើដោយខន្ធ មិនមាន សុខក្រៅអំពីសេចក្ដីស្ងប់ មិនមាន ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **នត្ថិ** រាគសមោ (ស្មើដោយរាគៈរមែងមិនមាន) សេចក្ដីថា ឈ្មោះថា ភ្លើងដទៃស្មើដោយរាគៈ ដែលអាចឆេះមិនសម្ដែងនូវផ្សែង អណ្ដាត ឬក៏រងើក ឆេះតែក្នុងខាងក្នុងប៉ុណ្ណោះ ហើយសល់តែគំនរផេះ រមែងមិនមាន ។ បទថា **កលិ** (ទោស) សេចក្ដីថា សូម្បីទោសស្មើដោយទោសៈ រមែងមិនមាន ។ បទថា **ខន្ធសមា**[១] **(ស្មើដោយខន្ធ)** បានដល់ស្មើដោយខន្ធទាំងឡាយ អធិប្បាយថា ឈ្មោះថា ទុក្ខដទៃដូចជាខន្ធទាំងឡាយ ដែលបុគ្គលរក្សាហើយជាទុក្ខ រមែងមិនមាន ។ បទថា **សន្តិ បរំ សុខំ (សុខដទៃក្រៅពីសេចក្ដីស្ងប់)** សេចក្ដីថា សូម្បីសុខដទៃ ក្រៅលែងជាងព្រះនិព្វាន រមែងមិនមាន អធិប្បាយថា ពិតណាស់ សេចក្ដីសុខដទៃ ក៏ជាសុខដែរ តែ

ព្រះនិព្វានជាបរមសុខ ។

ក្នុងកាលចប់ព្រះធម៌ទេសនា កុមារិកា និងកុមារនោះ ក៏បានតាំងនៅក្នុងសោតាបត្តិផល ។ ក្នុងខណៈនោះ ព្រះមានព្រះភាគទ្រង់ធ្វើអាការ គឺ ការឃើញគ្នានិងគ្នាដល់អ្នកទាំងពីរ ដូច្នេះឯង ។

ចប់ រឿងកុមារិកានៃត្រកូលមួយ

---

១ បាលីជា ខន្ធាទិសា ។

# ៥. រឿងឧបាសកមួយរូប

*ព្រះសាស្តា កាលប្រថាប់នៅក្នុងក្រុងអាឡវី ទ្រង់ប្រារព្ធឧបាសកមួយរូប ត្រាស់ព្រះធម្មទេសនាថា **ជិឃច្ឆា** (សេចក្តីឃ្លាន) ជាដើម ។*

ព្រះសាស្តាស្តេចយាងទ្រោសមនុស្សទុគ៌ត

*សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះសាស្តាប្រថាប់នៅក្នុងព្រះគន្ធកុដិ ក្នុងព្រះជេតពន ទ្រង់រមិលមើលនូវសត្វលោកក្នុងវេលាជិតភ្លឺ ទ្រង់ឃើញបុរសទុគ៌តម្នាក់ ដែលមានប្រក្រតីនៅក្នុងក្រុងអាឡវី ទ្រង់ជ្រាបនូវការដល់ព្រមនៃធម៌ដែលជាឧបនិស្ស័យរបស់បុរសទុគ៌តនោះ មានភិក្ខុ ៥០០ រូប ជាបរិវារ ស្តេចបានយាងទៅកាន់ក្រុងអាឡវី ។ អ្នកក្រុងអាឡវីក៏បាននិមន្តព្រះសាស្តា ។ បុរសទុគ៌តនោះបានឮថា "ព្រះសាស្តាស្តេចយាងមក" ដូច្នេះហើយ ក៏បានតាំងចិត្តទុកថា "យើងនឹងស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា" ។ ថ្ងៃនោះឯង គេបានបាត់គោមួយក្បាល គេគិតថា "យើងស្វែងរកគោ ឬក៏ទៅស្តាប់ព្រះធម៌" ក្នុងពេលនោះ គេក៏បានសម្រេចចិត្តថា "យើងស្វែងរកគោ កៀងឲ្យចូលទៅកាន់ហ្វូងហើយ នឹងស្តាប់ព្រះធម៌ជាក្រោយ" ដូច្នេះ ក៏ចេញអំពីផ្ទះតាំងពីព្រលឹម ។ សូម្បីអ្នកក្រុងអាឡវី និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យគង់ ហើយបានអង្គាស ទទួលបាត្រដើម្បីប្រយោជន៍ដល់ការអនុមោទនា ។ ព្រះសាស្តាទ្រង់ប្រថាប់នៅស្ងៀម ដោយធ្វើទុកក្នុងព្រះទ័យថា "តថាគតអាស្រ័យបុគ្គលណា*

មកហើយ អស់ចម្ងាយផ្លូវប្រមាណ ៣០ យោជន៍ បុគ្គលនោះចូលទៅកាន់ព្រៃ ដើម្បីស្វែងរកគោ កាលណាគេមក ទើបតថាគតសម្តែងធម៌” ។ បុរសនោះ ឃើញគោក្នុងវេលាថ្ងៃ កៀងគោចូលហ្វូងហើយ គិតថា “បើទុកជាវត្ថុដទៃមិនមាន យើងនឹងធ្វើនូវកិច្ចត្រឹមតែការថ្វាយបង្គំចំពោះព្រះសាស្តា” សូម្បីត្រូវការឃ្លានបៀតបៀន ក៏មិនទៅផ្ទះ មកកាន់សម្នាក់ព្រះសាស្តាដោយរហ័ស ថ្វាយបង្គំព្រះសាស្តាហើយ ឈរក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តា ទ្រង់ត្រាស់ទៅកាន់អ្នកខ្វល់ខ្វាយក្នុងទាន ក្នុងកាលដែលគេឋិតនៅក្នុងទីដ៏សមគួរនោះថា “វត្ថុអ្វីៗ ដែលជាសំណល់របស់ភិក្ខុសង្ឃ មានដែរឬ?” ។

អ្នកខ្វល់ខ្វាយក្នុងទាន. មានគ្រប់យ៉ាង ព្រះអង្គ ។

ព្រះសាស្តា. បើដូច្នោះ ចូរអ្នកឲ្យបុរសនេះបរិភោគផង ។

ព្រះសាស្តាត្រូវគេនិន្ទា

គេក៏ឲ្យបុរសនោះអង្គុយ ក្នុងទីដែលព្រះសាស្តាត្រាស់ហើយនោះឯង ហើយអង្គាសដោយបបរ និងវត្ថុដែលបុគ្គលគប្បីទំពា និងវត្ថុដែលបុគ្គលគប្បីបរិភោគដោយគោរព ។ បុរសទុគ៌តនោះបរិភោគភត្តស្រេចហើយ ខ្ពុរមាត់ ។ បានឮថា ការចាត់ចែងភត្តរបស់ព្រះតថាគត រមែងមិនមានក្នុងទីដទៃ ក្នុងបិដកទាំង ៣ វៀរទីនេះចេញ ។ ចិត្តរបស់បុរសនោះ មានសេចក្តីក្រវល់ក្រវាយស្ងប់រម្ងាប់ហើយ បានជាចិត្តមានអារម្មណ៍មូលតែមួយ ។ គ្រានោះ ព្រះសាស្តាក៏ត្រាស់អនុបុព្វីកថា ហើយទ្រង់ប្រកាសសច្ចៈទាំងឡាយដល់បុរសនោះ ។ ក្នុង

ទីបំផុតនៃព្រះធម្មទេសនា បុរសនោះក៏តាំងនៅក្នុងសោតាបត្តិផល ។ ចំណែកព្រះសាស្តាទ្រង់ធ្វើអនុមោទនាហើយ ស្តេចក្រោកចាកអាសនៈ ចៀសចេញទៅ ។ មហាជនជូនដំណើរព្រះសាស្តាទៅហើយ ក៏ត្រឡប់មកវិញ ។ ភិក្ខុទាំងឡាយ ដែលទៅជាមួយព្រះសាស្តា លើកទោសថា "អាវុសោទាំងឡាយ អ្នកទាំងឡាយចូរមើលនូវកម្មរបស់ព្រះសាស្តាចុះ កម្មបែបនេះ រមែងមិនមានក្នុងថ្ងៃទាំងឡាយទេ តែថ្ងៃនេះ ព្រះសាស្តាទ្រង់អាស្រ័យមនុស្សម្នាក់ បញ្ជាឲ្យគេចាត់ចែងនូវវត្ថុទាំងឡាយ មានបបរជាដើមឲ្យបុរសនោះ" ។ ព្រះសាស្តាស្តេចយាងត្រឡប់ ប្រថាប់ឈរ ហើយត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយពោលនូវអ្វី?" ។ ទ្រង់ស្តាប់នូវសេចក្តីនោះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះហើយ តថាគតគិតថា តថាគត កាលមកអស់ចម្ងាយផ្លូវកន្តារ ៣០ យោជន៍ ឃើញឧបនិស្ស័យរបស់ឧបាសកនោះហើយ ទើបមកឧបាសកនោះ ឃ្លានក្រៃលែងណាស់ ក្រោកឡើងអំពីព្រលឹមហើយ ដើររកគោក្នុងព្រៃ សូម្បីកាលតថាគតសម្តែងធម៌ ក៏មិនអាចចាក់ធ្លុះនូវធម៌បាន ព្រោះទុក្ខ គឺ សេចក្តីឃ្លាន ទើបតថាគតធ្វើយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា រោគ ប្រាកដស្មើដោយរោគ គឺ សេចក្តីឃ្លាន រមែងមិនមាន" ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

៥. ជិឃច្ឆា បរមា រោគា  សង្ខារា បរមា ទុក្ខា
ឯតំ ញត្វា យថាភូតំ  និព្វានំ បរមំ សុខំ ។

សេចក្តីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង សង្ខារទាំងឡាយ
ជាទុក្ខយ៉ាងក្រៃលែង (អ្នកប្រាជ្ញ) ដឹងច្បាស់សេចក្តីនុ៎ះ តាម
ពិតហើយ (រមែងធ្វើឲ្យច្បាស់) នូវព្រះនិព្វាន ជាសុខយ៉ាង
ក្រៃលែង ។

អធិប្បាយគាថា

បណ្តាបទទាំងឡាយនោះ បទថា **ជិឃច្ឆា បរមា រោគា** (សេចក្តីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង) សេចក្តីថា ព្រោះរោគយ៉ាងដទៃព្យាបាលអស់វារៈមួយគ្រាក៏បាត់ទៅ ឬថា បុគ្គលរមែងលះបង់បាន ដោយអំណាចនៃអង្គនោះៗ ចំណែកសេចក្តីស្រេកឃ្លាន បុគ្គលគប្បីព្យាបាលអស់កាលជានិច្ច ព្រោះហេតុនោះ សេចក្តីស្រេកឃ្លាននេះ ទើបចាត់ជារោគយ៉ាងក្រៃលែងជាងរោគដ៏សេស ។ ខន្ធ ៥ ឈ្មោះថា **សង្ខារទាំងឡាយ** (សង្ខារា) ។ បទថា **ឯតំ ញត្វា** (ដឹងសេចក្តីនុ៎ះ) សេចក្តីថា បណ្ឌិតដឹងច្បាស់តាមការពិតថា "រោគស្មើដោយសេចក្តីស្រេកឃ្លាន រមែងមិនមាន ឈ្មោះថា ទុក្ខ ស្មើដោយការរក្សាខន្ធ រមែងមិនមាន" ហើយធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ បទថា **និព្វានំ បរមំ សុខំ** (ព្រះនិព្វានជាសុខយ៉ាងក្រៃលែង) សេចក្តីថា ព្រោះព្រះនិព្វាននោះជាសុខដ៏កំពូល គឺ យ៉ាងខ្ពង់ខ្ពស់ជាងសុខទាំងអស់ ។

ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ

*មានសោតាបត្តិផលជាដើម ។*

ចប់ រឿងឧបាសកមួយរូប

# ៦. រឿងព្រះបាទបសេនទិកោសល

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទបសេនទិកោសល ត្រាស់ព្រះធម្មទេសនានេះថា **អារោគ្យបរមា លាភា (លាភទាំងឡាយ មានការមិនមានរោគជាយ៉ាងក្រៃលែង)** ជាដើម ។

## ព្រះរាជាសោយព្រះក្រយាហារច្រើន

សេចក្តីពិស្តារថា សម័យមួយ ព្រះរាជាសោយព្រះក្រយាហារទាំងនាឡិនៃអង្ករ ជាមួយសូបៈ និងព្យញ្ជនៈដ៏សមគួរដល់ព្រះក្រយាហារនោះ ។ ថ្ងៃមួយព្រះរាជាទ្រង់សោយព្រះស្ងោយក្នុងវេលាព្រឹកហើយ ទ្រង់មិនទាន់បន្ទោបង់សេចក្តីស្រវឹងក្នុងភត្តនៅឡើយ ស្តេចក៏ទៅកាន់សម្នាក់ព្រះសាស្តា ទ្រង់មានព្រះកាយលំបាក ទ្រង់ប្រែទៅប្រែមក ទាំងការងងុយងោកងក់ក៏គ្របសង្កត់ព្រះអង្គទៀត កាលមិនអាចនឹងទ្រង់ផ្ទំត្រង់បាន ទើបប្រថាប់អង្គុយនៅក្នុងទីមួយ ។ គ្រានោះ ព្រះសាស្តាទ្រង់ត្រាស់ទៅកាន់ព្រះរាជាថា “មហាបពិត្រ ព្រះអង្គមិនទាន់បានសម្រាក ស្តេចក៏មកកាន់ទីនេះឬ?” ។

ព្រះរាជា. ព្រះករុណាព្រះអង្គ ទុក្ខធំបានកើតមានដល់ខ្ញុំព្រះអង្គ ចាប់តាំងពីកាលនៃភត្តដែលខ្ញុំព្រះអង្គបរិភោគហើយ ។ គ្រានោះ ព្រះសាស្តាត្រាស់ទៅកាន់ព្រះរាជាថា “មហាបពិត្រ ការបរិភោគនូវភោជនច្រើនពេក ជាទុក្ខយ៉ាងនេះ” ដូច្នេះហើយ ទ្រង់ទូន្មានដោយព្រះគាថានេះថា ៖

ក្នុងកាលណា បុគ្គលជាអ្នកបរិភោគច្រើន ជាអ្នកងោកងុយ
ជាអ្នកប្រាថ្នានឹងដេក រសាប់រសល់ ដូចជាជ្រូកដ៏ធំដែលគេ
ចិញ្ចឹមដោយអាហារ ក្នុងកាលនោះ គេក៏ជាបុគ្គលល្ងង់ខ្លៅ
រមែងចូលទៅកាន់គភ៌រឿយៗ ។

លុះទ្រង់ត្រាស់ដូច្នោះហើយ ក៏ត្រាស់ថា "មហាបពិត្រ ការបរិភោគនូវភោជនតែល្មមប្រមាណ ទើបគួរ ព្រោះអ្នកបរិភោគល្មមប្រមាណ រមែងបានសេចក្តីសុខ" កាលនឹងទ្រង់ឲ្យឱវាទក្រៃលែងឡើង ទើបត្រាស់ព្រះគាថានេះថា ៖

បុគ្គលអ្នកមានសតិសព្វកាល ដឹងនូវប្រមាណក្នុងភោជន
ដែលខ្លួនបានមកហើយ មានវេទនាតិចតួច (អាហារដែល
បរិភោគហើយ) រមែងរលួយទៅសន្សឹមៗ និងញុំាំងអាយុ
ជីវិតឲ្យប្រព្រឹត្តទៅ ។

ព្រះរាជាមិនអាចនឹងរៀនព្រះគាថាបាន តែត្រាស់ទៅកាន់អាមាត្យឈ្មោះសុទស្សនៈ ជាក្មួយដែលឈរនៅជិតនោះថា "នែបា អ្នកចូររៀនព្រះគាថានេះ" សុទស្សនៈរៀនព្រះគាថានោះហើយ ទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើយ៉ាងណា?" លំដាប់នោះ ព្រះសាស្តាត្រាស់ទៅកាន់អាមាត្យនោះថា "កាលណាព្រះរាជាសោយ អ្នកគប្បីពោលគាថានេះ ក្នុងកាលដែលស្តេចទ្រង់សោយនូវដុំព្រះស្ងោយខាងចុងបំផុត កាលព្រះរាជាទ្រង់កំណត់

សេចក្ដីបានហើយ នឹងទ្រង់លះបង់ដុំបាយនោះ ក្នុងកាលចម្អិនកត្តថ្វាយព្រះរាជាអ្នកគប្បីឲ្យគេបន្ថយអង្ករប្រមាណប៉ុណ្ណោះ តាមការរាប់គ្រាប់បាយ ក្នុងដុំព្រះស្ងោយនោះ" ។ សុទស្សនៈនោះទទួលថា "ព្រះករុណា ព្រះអង្គ" ។ កាលព្រះរាជាសោយព្រះស្ងោយក្នុងវេលាព្រឹកក្ដី ក្នុងវេលាល្ងាចក្ដី ក៏ពោលគាថានោះឡើង ក្នុងកាលដែលព្រះរាជាសោយនូវដុំព្រះស្ងោយចុងក្រោយ ហើយប្រើគេឲ្យបន្ថយអង្ករទាំងឡាយតាមចំនួនគ្រាប់បាយក្នុងដុំព្រះស្ងោយ ដែលព្រះរាជាទ្រង់លះបង់ចោលនោះ ។ ព្រះរាជា ទ្រង់បានស្ដាប់នូវគាថារបស់សុទស្សនៈនោះហើយ ទ្រង់ត្រាស់បង្គាប់ឲ្យព្រះរាជទានទ្រព្យម្ដងមួយពាន់ៗ ។

## ព្រះរាជាទ្រង់បន្ថយព្រះស្ងោយបានហើយ

សម័យខាងក្រោយមក ព្រះរាជាអង្គនោះទ្រង់តាំងនៅក្នុងភាវៈជាអ្នកមានព្រះស្ងោយនៃអង្ករមួយនាឡិជាយ៉ាងក្រៃលែង ទ្រង់ជាអ្នកដល់ហើយនូវសេចក្ដីសុខ ទ្រង់មានព្រះសរីរៈដ៏ស្រោល ។

ក្រោយមកថ្ងៃមួយ ព្រះរាជាស្ដេចទៅកាន់សម្នាក់ព្រះសាស្ដា ថ្វាយបង្គំព្រះសាស្ដាហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះសេចក្ដីសុខកើតដល់ខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គអាចដេញតាមចាប់ម្រឹគក៏បាន សេះក៏បាន កាលមុនខ្ញុំព្រះអង្គមានការច្បាំងជាមួយនឹងក្មួយខ្លួនឯង ឥឡូវនេះ ខ្ញុំព្រះអង្គបានឲ្យធីតា ឈ្មោះវជិរកុមារី ដល់ក្មួយហើយ ឲ្យស្រុកនោះធ្វើឲ្យជាតម្លៃវត្ថុសម្រាប់ងូត ដល់ធីតាឈ្មោះវជិរៈនោះឯង ។ ការប្រកួតប្រកាន់ជាមួយនឹងក្មួយ

នោះស្ងប់ហើយ សេចក្ដីសុខពិត កើតហើយដល់ខ្ញុំព្រះអង្គ ព្រោះហេតុនេះផង សូម្បីកែវមណីរបស់ព្រះបាទកុសរាជ ដែលបាត់ទៅហើយក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃមុន ឥឡូវនេះ កែវមណីនោះ បានមកក្នុងកណ្ដាប់ដៃរបស់ខ្ញុំព្រះអង្គហើយ សេចក្ដីសុខពិត កើតហើយដល់ខ្ញុំព្រះអង្គ ព្រោះហេតុនេះផង ខ្ញុំព្រះអង្គប្រាថ្នា សេចក្ដីស្និទ្ធស្នាលនឹងសាវកទាំងឡាយរបស់ព្រះអង្គ ទើបធ្វើធីតាដែលជាញាតិ របស់ព្រះអង្គទុកក្នុងផ្ទះ សេចក្ដីសុខពិត កើតឡើងហើយដល់ខ្ញុំព្រះអង្គ ព្រោះហេតុនេះផង" ព្រះសាស្ដាត្រាស់ថា "មហាបពិត្រ ការមិនមានរោគ ជាលាភយ៉ាងក្រៃលែង ទ្រព្យប្រាកដស្មើដោយសេចក្ដីសន្ដោសដោយវត្ថុ តាមដែលខ្លួនបាន ហើយ រមែងមិនមាន ឈ្មោះថា ញាតិប្រាកដស្មើដោយការស្និទ្ធស្នាល មិនមាន ឈ្មោះថា ធម្មជាតិជាសុខយ៉ាងក្រៃលែង ប្រាកដស្មើដោយព្រះនិព្វាន មិនមាន" ទើបត្រាស់ព្រះគាថានេះថា ៖

៦. អារោគ្យបរមា លាភា សន្តុដ្ឋិបរមំ ធនំ
វិស្សាសបរមា ញាតី និព្វានំ បរមំ សុខំ ។

លាភមានការមិនមានរោគ ជាយ៉ាងក្រៃលែង ទ្រព្យមានសេចក្ដី សន្ដោស ជាយ៉ាងក្រៃលែង ញាតិ មានសេចក្ដីស្និទ្ធស្នាល ជា យ៉ាងក្រៃលែង ព្រះនិព្វានជាសុខយ៉ាងក្រៃលែង។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា អារោគ្យបរមា (មានការមិនរោគជាយ៉ាង

ក្រៃលែង) សេចក្តីថា ភាពជាអ្នកមិនមានរោគ ជាលាភយ៉ាងក្រៃលែង ពិតណាស់ លាភទាំងឡាយ សូម្បីមានដល់បុគ្គលអ្នកមានរោគ ក៏មិនចាត់ថាជាលាភដែរ ព្រោះដូច្នោះ លាភទាំងពួង ទើបមកដល់អ្នកមិនមានរោគប៉ុណ្ណោះ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អារោគ្យបរមា លាភា** ។ បទថា **សន្តុដ្ឋីបរមំ ធនំ (ទ្រព្យមានសេចក្តីសន្តោសជាយ៉ាងក្រៃលែង)** សេចក្តីថា ភាវៈ គឺ សេចក្តីត្រេកអរនឹងវត្ថុតាមដែលខ្លួនបានហើយ ដែលជារបស់នៃខ្លួន របស់គ្រហស្ថ ឬបព្វជិតនោះឯង ឈ្មោះថា សន្តោស សន្តោសនោះ ជាទ្រព្យយ៉ាងក្រៃលែងជាងទ្រព្យដ៏សេស ។ បទថា **វិស្សាសបរមា ញាតី (ញាតិមានសេចក្តីស្និទ្ធស្នាលជាយ៉ាងក្រៃលែង)** សេចក្តីថា មាតាក្តី បិតាក្តី ចូរលើកទុកចុះ មិនមានសេចក្តីស្និទ្ធស្នាលនឹងបុគ្គលណា បុគ្គលនោះមិនមែនជាញាតិទេ តែបើមានសេចក្តីស្និទ្ធស្នាលនឹងបុគ្គលណា បុគ្គលនោះ សូម្បីមិនជាប់ជាញាតិក៏ដោយ ក៏ឈ្មោះថា ជាញាតិយ៉ាងក្រៃលែង គឺ យ៉ាងខ្ពង់ខ្ពស់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **ញាតិមានសេចក្តីស្និទ្ធស្នាលជាយ៉ាងក្រៃលែង** ។

ម្យ៉ាងទៀត ឈ្មោះថា សេចក្តីសុខដូចព្រះនិព្វាន មិនមាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **និព្វានជាសុខយ៉ាងក្រៃលែង** ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងព្រះបាទបសេនទិកោសល

# ៧. រឿងព្រះតិស្សត្ថេរ

*ព្រះសាស្ដា កាលប្រថាប់គង់នៅក្នុងក្រុងវេសាលី ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា* ***បវិវេករសំ (រសដែលកើតអំពីវិវេក)*** *ដូច្នេះជាដើម ។*

ចានជ្រាបដំណើងបរិនិព្វានហើយ ក៏ព្យាយាមបំពេញសមណធម៌

*សេចក្ដីពិស្ដារថា កាលព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ៤[១] ខែទៀត តថាគតនឹងបរិនិព្វានហើយ" ។ ភិក្ខុ ៧០០ រូប ក្នុងសម្នាក់នៃព្រះសាស្ដា ដល់នូវសេចក្ដីតក់ស្លុតយ៉ាងខ្លាំង ។ ធម្មសង្វេគ ក៏កើតដល់ព្រះខីណាស្រព ទាំងឡាយ ។ ភិក្ខុបុថុជ្ជនទាំងឡាយ មិនអាចនឹងទប់ទឹកភ្នែកបាន ។ ភិក្ខុទាំងឡាយជាពួកៗ ប្រឹក្សាគ្នាថា "ពួកយើងនឹងធ្វើដូចម្ដេចហ្ន៎" គ្រានោះ ភិក្ខុមួយរូបឈ្មោះតិស្សៈគិតថា "បានឮថា ព្រះសាស្ដានឹងបរិនិព្វាន ដោយកាលកន្លងទៅ ៤ ខែទៀត អញសោត ជាអ្នកនៅមានរាគៈមិនទាន់ទៅប្រាស កាលព្រះសាស្ដាទ្រង់នៅព្រះជន្ម អញគួរតែកាន់យកព្រះអរហត្ត (ឲ្យបាន)" លុះគិតដូច្នោះហើយ ក៏ជាបុគ្គលតែម្នាក់ឯងប៉ុណ្ណោះ ក្នុងឥរិយាបថទាំង ៤ ។ ការទៅកាន់សម្នាក់ភិក្ខុទាំងឡាយ ឬការសន្ទនាប្រាស្រ័យជាមួយនឹងភិក្ខុរូបណាមួយ រមែងមិនមាន ។ គ្រានោះ ភិក្ខុទាំងឡាយពោលនឹងភិក្ខុនោះថា "អាវុសោ តិស្សៈ*

---

*១- គួរជា ៣ ខែ តែក្នុងទីនេះលោកប្រែ ៤ ខែ ។*

ព្រោះហេតុអ្វី ទើបអ្នកធ្វើយ៉ាងនេះ" ។ លោកមិនបានស្តាប់សំដីរបស់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះក្រាបទូលរឿងនោះចំពោះព្រះសាស្តា ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះតិស្សៈនោះ មិនមានសេចក្តីស្រឡាញ់ចំពោះព្រះអង្គទេ" ។ ព្រះសាស្តាត្រាស់ឲ្យហៅព្រះតិស្សត្ថេរមក ហើយត្រាស់សួរថា "តិស្សៈ ព្រោះហេតុអ្វី? ទើបអ្នកធ្វើយ៉ាងនេះ" ។ កាលព្រះតិស្សៈក្រាបទូលសេចក្តីប្រាថ្នារបស់ខ្លួនហើយ ទ្រង់ប្រទានសាធុការថា "សាធុ សាធុ តិស្សៈ" ។ ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកដែលស្រឡាញ់តថាគត ចូរជាអ្នកដូចតិស្សៈចុះ" សូម្បីអ្នកធ្វើការបូជាដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម មិនឈ្មោះថាបូជាតថាគតសោះឡើយ លុះតែកណាតែបដិបត្តិធម៌សមគួរដល់ធម៌ ទើបឈ្មោះថា បូជាតថាគត" ហើយត្រាស់ព្រះគាថានេះថា ៖

៧. បវិវេករសំ បិត្វា    រសំ ឧបសមស្ស ច
និទ្ទរោ ហោតិ និប្បាបោ    ធម្មបីតិរសំ បិវំ ។

ភិក្ខុផឹករសវិវេកផង រសព្រះនិព្វាន ជាទីរម្ងាប់កិលេសផង
ផឹករសបីតិដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមានសេចក្តី
ក្រវល់ក្រវាយ មិនមានសេចក្តីសៅហ្មងឡើយ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **បវិវេករសំ** (រសដែលកើតពីវិវេក) សេចក្តីថា រសដែលកើតអំពីវិវេក អធិប្បាយថា សេចក្តីសុខ ដែលកើតអំពីភាពតែ

ម្នាក់ឯង ។ បទថា **បិត្វា (ផឹក)** សេចក្តីថា ផឹកហើយដោយអំណាចនៃអ្នកធ្វើនូវកិច្ច មានការកំណត់ដឹងនូវទុក្ខជាដើម ធ្វើឲ្យជាក់ច្បាស់ដោយភាពជាអារម្មណ៍ ។ បទថា **រសំ ឧបសមស្ស ច (និងរសព្រះនិព្វានដែលចូលទៅស្ងប់)** សេចក្តីថា ផឹកហើយនូវរសនៃព្រះនិព្វាន ដែលជាទីចូលទៅស្ងប់កិលេស ។ បទថា **និទ្ទរោ ហោតិ (រមែងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ)** សេចក្តីថា ភិក្ខុជាខីណាស្រព ឈ្មោះថា ជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ និងមិនមានបាប ព្រោះមិនមានសេចក្តីក្រវល់ក្រវាយ គឺ រាគៈជាដើមក្នុងខាងក្នុង ព្រោះផឹកនូវរសទាំងពីរយ៉ាងនោះ ។ បទថា **រសំ បិវំ (ផឹករស)** សេចក្តីថា សូម្បីកាលផឹករសនៃបីតិ ដែលកើតឡើងហើយ ដោយអំណាចនៃលោកុត្តរធម៌ ៩ រមែងជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ និងមិនមានបាប ។

ក្នុងកាលចប់ព្រះធម៌ទេសនា ព្រះតិស្សៈ ក៏បានសម្រេចព្រះអរហត្ត ។ ទេសនាបានមានប្រយោជន៍ សូម្បីដល់មហាជន ដូច្នេះឯង ។

ចប់ រឿងព្រះតិស្សត្ថេរ

# ៨. រឿងសក្កទេវរាជ

*ព្រះសាស្ដា កាលប្រថាប់គង់នៅក្នុងវេឡុវគ្រាម ទ្រង់ប្រារព្ធសក្កទេ-វរាជ ត្រាស់ព្រះធម្មទេសនានេះថា **សាហុ ទស្សនំ** (ការឃើញ...ជាការល្អ) ជាដើម "សាហុ តាមព្រះអដ្ឋកថា" ។*

*សេចក្ដីពិស្ដារថា សក្កទេវរាជទ្រង់ជ្រាបដល់ព្រះអាពាធ ព្រោះធ្លាក់ព្រះលោហិតជាសមុដ្ឋាន កើតឡើងចំពោះព្រះតថាគត ក្នុងកាលព្រះអង្គដាក់ព្រះជន្មាយុសង្ខារហើយ ទ្រង់បានត្រិះរិះថា "ការដែលយើងទៅកាន់សម្នាក់ព្រះសាស្ដាហើយ ធ្វើជាគិលានុបដ្ឋាក រមែងគួរ" ទ្រង់លះបង់នូវអត្តភាពប្រមាណបីគាវុត ចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយ ទ្រង់ប្របាច់ព្រះបាទដោយព្រះហស្ដទាំងពីរ គ្រានោះ ព្រះសាស្ដាត្រាស់សួរថា "នរណាហ្នឹង" ។*

*សក្កទេវរាជ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាសក្កទេវរាជ ។*

*ព្រះសាស្ដា. មហាបពិត្រយាងមកធ្វើអ្វី ?*

*សក្កទេវរាជ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមកដើម្បីបម្រើព្រះអង្គដែលទ្រង់ប្រឈួន ។*

*ព្រះសាស្ដា. ម្នាលសក្កៈ ក្លិនមនុស្សរមែងប្រាកដដល់ទេវតាទាំងឡាយដូចជាសាកសពដែលចងត្រង់.ក តាំងអំពី ១០០ យោជន៍ អ្នកចូរទៅវិញចុះ អ្នកបម្រើរបស់តថាគត មានហើយ ។*

សក្កទេវរាជក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូម្បីខ្ញុំព្រះអង្គឋិត នៅក្នុងទីបំផុតនៃយោជន៍ ៨៤.០០០ មកកាន់ទីនេះ ដោយអាស្រ័យបានធុំក្លិនសីលរបស់ព្រះអង្គ ខ្ញុំព្រះអង្គនេះឯងនឹងបម្រើព្រះអង្គ" ហើយមិនឲ្យបុគ្គលដទៃពាល់ត្រូវនូវកាជនៈសម្រាប់បន្ទោបង់នូវមន្ទិល ក្នុងសរីរៈរបស់ព្រះសាស្ដាសូម្បីដោយដៃ ទ្រង់តម្កល់នៅលើព្រះសិរសាតែម្យ៉ាង នាំចេញទៅ មិនបានធ្វើសូម្បីនូវអាការត្រឹមតែការជ្រួញព្រះភក្ត្រ ជាអ្នកមានអាការដូចជានាំទៅនូវកាជនៈដែលដាក់គ្រឿងក្រអូប ។ ស្ដេចប្រតិបត្តិក្នុងព្រះសាស្ដា ដោយអាការយ៉ាងនេះ ក្នុងកាលដែលព្រះសាស្ដាព្រះអង្គមានសេចក្ដីសប្បាយនោះឯង ទើបបានស្ដេចទៅវិញ ។

### ភិក្ខុសរសើរសក្កទេវរាជ

ភិក្ខុទាំងនោះប្រជុំគ្នា ពោលឡើងថា "គួរឲ្យសរសើរហ្ន៎ សក្កទេវរាជមានសេចក្ដីស្នេហាក្នុងព្រះសាស្ដា ទ្រង់លះបង់នូវសម្បត្តិដ៏ជាទិព្វបែបនេះ ទ្រង់នាំកាជនៈសម្រាប់បន្ទោបង់នូវមន្ទិលក្នុងសរីរៈរបស់ព្រះសាស្ដាទៅដោយព្រះសិរ មិនបានធ្វើអាការត្រឹមតែការជ្រួញព្រះភក្ត្រ ដូចគេនាំទៅនូវកាជនៈដែលពេញទៅដោយគ្រឿងក្រអូប ដូច្នេះ ទ្រង់បានបម្រើព្រះសាស្ដាហើយ" ព្រះសាស្ដាទ្រង់ស្ដាប់នូវពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ និយាយគ្នាអំពីរឿងអ្វី?" គ្រានោះ ភិក្ខុទាំងនោះក្រាបទូលថា "រឿងឈ្មោះនេះ ព្រះអង្គ" ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សក្កទេវរាជ

ស្រឡាញ់ក្នុងតថាគត មិនជាអស្ចារ្យទេ ព្រោះសក្កទេវរាជនេះ ស្តាប់ធម្មទេសនាហើយ បានជាសោតាបន្ន លះបង់ភាពជាសក្កទេវរាជចាស់ ដល់នូវភាពជាសក្កទេវរាជកំលោះ អាស្រ័យតថាគត ពិតណាស់ កាលសក្កទេវរាជស្តេចគង់នៅកណ្តាលទេវបរិស័ទ ក្នុងឥន្ទសាលគូហា ក្នុងកាលដែលខ្លួនត្រូវមរណភ័យគំរាម ធ្វើទេវបុត្រឈ្មោះ **បញ្ចសិខៈ** អំពីខាងមុខហើយ ស្តេចមករកតថាគត តថាគតបានពោលថា ៖

"ម្នាលវាសវៈ ព្រះអង្គចូរសួរបញ្ហាតថាគតចុះ ព្រះអង្គប្រាថ្នាក្នុងព្រះទ័យនូវបញ្ហាយ៉ាងណាមួយ តថាគតនឹងធ្វើនូវទីបំផុតនៃបញ្ហានោះៗ របស់ព្រះអង្គបានពិត" ។

កាលនឹងបន្ទោបង់នូវសេចក្តីសង្ស័យរបស់សក្កទេវរាជ ទើបទ្រង់បានសម្តែងព្រះធម៌ទេសនា ក្នុងកាលចប់ព្រះធម៌ទេសនា ធម្មាភិសម័យបានមានដល់សត្វទាំងឡាយប្រមាណ ១៤ កោដិ ចំណែកសក្កទេវរាជក៏បានសម្រេចសោតាបត្តិផល ក្នុងខណៈដែលព្រះអង្គគង់នោះឯង ជាសក្កទេវរាជកំលោះ តថាគតមានឧបការៈច្រើនដល់សក្កទេវរាជនោះ ដោយប្រការយ៉ាងនេះ ឈ្មោះថា សេចក្តីស្រឡាញ់ក្នុងតថាគតរបស់សក្កទេវរាជនោះ មិនគួរឲ្យអស្ចារ្យទេ ម្នាលភិក្ខុទាំងឡាយ ក៏ការជួប ការឃើញព្រះអរិយបុគ្គលទាំងឡាយក្តី ការនៅរួមជាមួយនឹងព្រះអរិយបុគ្គលទាំងឡាយក្តី សុទ្ធតែជាហេតុនាំឲ្យកើតសេចក្តីសុខទាំងអស់ តែថា កិច្ចមានការឃើញជាដើមនុ៎ះ ជាមួយពួកបុគ្គលពាល ជា

ហេតុឲ្យកើតទុក្ខ" ហើយទើបទ្រង់ត្រាស់គាថាទាំងនេះថា ៖

៨. សាធុ ទស្សនមរិយានំ សន្និវាសោ សទា សុខោ
អទស្សនេន ពាលានំ និច្ចមេវ សុខី សិយា ។
ពាលសង្គតចារី ហិ ទីឃមទ្ធានំ សោចតិ
ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា ។
ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ
តស្មាហិ

ធីរញ្ច បញ្ញញ្ច ពហុស្សុតញ្ច
ធោរយ្ហសីលំ វតវន្តមរិយំ
តំ តាទិសំ សប្បុរិសំ សុមេធំ
ភជេថ នក្ខត្តបថំវ ចន្ទិមា ។

ការជួបប្រទះព្រះអរិយបុគ្គលទាំងឡាយ ជាការល្អ ការនៅរួមជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឲ្យកើតសេចក្តីសុខសព្វកាល បុគ្គលគប្បីមានសេចក្តីសុខ អស់កាលជានិច្ចបាន ព្រោះមិនជួបប្រទះបុគ្គលពាលទាំងឡាយ ។

បុគ្គល អ្នកប្រព្រឹត្តសេពគប់ដោយជនពាល រមែងសោកស្តាយ អស់កាលយូរអង្វែង ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខសព្វកាល ។ ដូចជាការនៅរួមជាមួយនឹងសត្រូវ

ចំណែកខាងការនៅរួមនឹងធីរជន រមែងជាសុខ ដូចការជួបជុំ
ញាតិទាំងឡាយ ព្រោះហេតុនោះឯង បុគ្គលគួរសេពគប់សប្បុ-
រស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្ដីចេះដឹងច្រើន
ផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវត្ត និង
ធុតង្គវត្តផង ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាល្អផង
ប្រាកដដូច្នោះៗ ឲ្យដូចព្រះចន្ទគប់នូវផ្លូវនក្ខត្តឫក្ស ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា *សាហុ* (ជាការល្អ) បានដល់ ជាការញុំាង ប្រយោជន៍ឲ្យសម្រេច គឺថា ជាការប្រពៃ បានដល់ កម្មដ៏ចម្រើន ។ បទថា **សន្និវាសោ** (ការនៅរួម) សេចក្ដីថា មិនមែនត្រឹមតែការឃើញព្រះអរិយបុគ្គល ទាំងនោះ តែម្យ៉ាងជាការល្អប្រពៃទេ សូម្បីតែការអង្គុយជាដើមក្នុងទីជាមួយនឹង ព្រះអរិយបុគ្គលទាំងឡាយក្ដី ការបានធ្វើនូវវត្តប្រតិបត្តិចំពោះព្រះអរិយបុគ្គល ទាំងនោះក្ដី ជាការប្រពៃដោយពិត ។ បទថា **ពាលសង្គតចារី ហិ** (ព្រោះថា ការត្រាច់សមាគមជាមួយនឹងបុគ្គលពាល) សេចក្ដីថា ព្រោះបុគ្គលណាត្រាច់ រួមជាមួយនឹងបុគ្គលពាល ។ បទថា **ទីឃមទ្ធានំ** (អស់កាលដ៏យូរ) ជាដើម សេចក្ដីថា បុគ្គលនោះត្រូវសំឡាញ់ដែលជាបុគ្គលពាលនិយាយថា "ម្នាលអ្នក ដ៏ចម្រើន ចូរមក ពួកយើងនឹងធ្វើកម្ម មានការកាត់នូវទី.តជាដើម" ជាអ្នកមាន ឆន្ទៈមួយជាមួយនឹងសំឡាញ់ដែលជាបុគ្គលពាលនោះ កាលធ្វើនូវបាបកម្មទាំង

នោះ រមែងដល់នូវទារុណកម្មទាំងឡាយ មានការកាត់ដៃជាដើម ឈ្មោះថា រមែងសោកស្តាយអស់កាលដ៏យូរអង្វែង ។ បទថា **សព្វទា (សព្វកាល)** សេចក្តីថា ឈ្មោះថា ការនៅរួមជាមួយនឹងបុគ្គល ដែលជាសត្រូវមានដាវក្នុងដៃក្តី ឬថា នៅរួមជាមួយនឹងអសិរពិសជាដើមក្តី ជាហេតុឲ្យកើតទុក្ខជានិច្ច យ៉ាងណា ការនៅរួមជាមួយនឹងបុគ្គលពាល (ក៏) ដូច្នោះដូចគ្នា ។ ក្នុងបទថា **ធីរោ ច សុខំ-សំវាសោ (ការនៅរួមជាមួយអ្នកប្រាជ្ញជាសុខ)** នេះ មានវិគ្រោះថា ការនៅរួមជាមួយនឹងអ្នកប្រាជ្ញនោះជាសុខ ព្រោះហេតុនោះ ទើបឈ្មោះថា មានការនៅរួមឲ្យកើតសេចក្តីសុខ អធិប្បាយថា ការនៅក្នុងទីមួយជាមួយនឹងជនជាបណ្ឌិតជាសុខ ។

សួរថា "ការនៅរួមជាមួយនឹងបណ្ឌិត ឲ្យកើតសុខ ដូចម្តេច?" ឆ្លើយថា "ដូចជាសមាគមនៃពួកញាតិដូច្នោះ" អធិប្បាយថា ការសមាគមក្នុងពួកញាតិដែលជាទីស្រឡាញ់ ជាសុខយ៉ាងណា ការនៅរួមជាមួយនឹងអ្នកប្រាជ្ញក៏ជាសុខ ដូច្នោះឯង ។

បទថា **តស្មា (ព្រោះដូច្នោះ)** សេចក្តីថា ព្រោះការនៅរួមជាមួយនឹងបុគ្គលពាលឲ្យកើតទុក្ខ ជាមួយនឹងបណ្ឌិតឲ្យកើតសុខ ដូច្នោះ អ្នកទាំងឡាយចូរគប់រក គឺថា ចូរចូលទៅអង្គុយជិតបណ្ឌិត ដែលជាអ្នកសម្បូរណ៍ទៅដោយបញ្ញា គឺ ជាអ្នកសម្បូរណ៍បញ្ញាដែលជាលោកិយៈ និងលោកុត្តរៈ ដែលឈ្មោះថា អ្នកមានបញ្ញា និងជាអ្នកដល់ព្រមដោយអាគម និងអធិគម ដែលឈ្មោះថា

ពហូស្សុត ដែលឈ្មោះថា ជាអ្នកនាំទៅនូវធុរៈជាប្រក្រតី ព្រោះជាអ្នកមានការនាំទៅនូវធុរៈជាប្រក្រតី គឺ បានដល់ ព្រះអរហត្ត បុគ្គលឈ្មោះថា ជាអ្នកមានវត្ត ព្រោះវត្ត គឺ សីល និងវត្ត គឺ ធុតង្គ បុគ្គលឈ្មោះថា អរិយៈ ព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយ សប្បុរសអ្នកមានបញ្ញាបែបនោះ ដូចជាព្រះចន្ទគោចរផ្លូវអាកាស ដែលគេដឹងថា ជាគន្លងនៃនក្ខត្តឫក្ស ដែលមិនមានមន្ទិល ដូច្នោះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា មនុស្សជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងសក្កទេវរាជ

## ចប់សុខវគ្គវណ្ណនា វគ្គទី ១៥

ក្នុងវគ្គនេះរួមមាន ០៨ រឿង

១. រឿងការរម្ងាប់ជម្លោះនៃពួកព្រះញាតិ

២. រឿងមារ

៣. រឿងបរាជ័យរបស់ព្រះបាទកោសល

៤. រឿងក្មេងស្រីត្រកូលមួយ

៥. រឿងឧបាសកម្នាក់

៦. រឿងព្រះបាទបសេនទិកោសល

៧. រឿងព្រះតិស្សត្ថេរ

៨. រឿងសក្កទេវរាជ

# បិយវគ្គ ទី ១៦

"ពោលអំពីវត្ថុជាទីស្រឡាញ់"

## ១. រឿងបព្វជិត ៣ រូប

[២៦] *ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបព្វជិត ៣ រូប ត្រាស់ព្រះធម្មទេសនានេះថា* ***អយោគេ យុញ្ជមត្តានំ (បុគ្គលប្រកបខ្លួនទុកក្នុងវត្ថុដែលមិនគួរប្រកប)*** *ជាដើម ។*

ត្រកូលដែលមានកូនប្រុសម្នាក់ និងចេញទៅបួស

*បានឮថា មាតាបិតាក្នុងត្រកូលមួយក្នុងក្រុងសាវត្ថី មានបុត្រតូចតែមួយប៉ុណ្ណោះ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ។ ថ្ងៃមួយ បុត្រតូចនោះស្ដាប់ធម្មកថារបស់ពួកភិក្ខុ ដែលមកផ្ទះរបស់ខ្លួន ហើយធ្វើអនុមោទនា មានសេចក្ដីប្រាថ្នាចង់បួស ទើបសូមមាតាបិតាបួស ។ មាតាបិតារបស់គេមិនអនុញ្ញាត ។ គ្រានោះ គេមានគំនិតថា "កាលមាតាបិតាមិនឃើញ យើងនឹង (ចេញ) ទៅខាងក្រៅ ហើយបួស" ។ គ្រានោះ បិតារបស់ក្មេងតូចនោះ កាលនឹងចេញទៅខាងក្រៅ បានប្រគល់បុត្រតូចនោះឲ្យទៅប្រពន្ធ ដោយពាក្យថា "នាងគប្បីរក្សាបុត្រតូចនេះ" មាតារបស់គេ កាលនឹងចេញទៅខាងក្រៅ បានប្រគល់ទៅឲ្យស្វាមី (ដូចគ្នា) ។ ក្រោយមកនៅថ្ងៃមួយ កាលបិតារបស់គេទៅខាងក្រៅ មាតា*

តាំងចិត្តថា "នឹងរក្សាបុត្រ" ក៏ផ្អែកនឹងមាត់ទ្វារម្ខាង ជាក់មាត់ទ្វារម្ខាងទៀតដោយជើងទាំងពីរ អង្គុយលើដីខាងអម្បោះ ។ បុត្រតូចនោះគិតថា "អញនឹងបញ្ឆោតមាតានេះ ហើយនឹងចេញទៅ" លុះគិតដូច្នោះហើយ ក៏ពោលថា "អ្នកម៉ែ ម៉ែ ចូរចៀសចេញ ខ្ញុំនឹងបន្ទោបង់ឧច្ចារៈ" កាលមាតារបស់គេអង្គុញជើងក្ដាម ក៏ចេញទៅកាន់វិហារយ៉ាងប្រញាប់ ចូលទៅរកភិក្ខុទាំងឡាយ ហើយបានអង្វរថា "លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់បំបួសខ្ញុំព្រះករុណាចុះ" ហើយបព្វជ្ជាក្នុងសម្នាក់ភិក្ខុទាំងនោះ ។ គ្រានោះ បិតារបស់គេត្រឡប់មកវិញ ក៏សួរមាតាថា "កូនរបស់យើងទៅណា" មាតាឆ្លើយថា "នាយ អម្បាញ់មិញនៅទីនេះ" បិតារបស់គេក៏រកមើល ដើម្បីឲ្យដឹងថា "បុត្ររបស់យើងនៅទីណាហ្ន៎" មិនឃើញ គិតថា "កូនរបស់យើងនឹងទៅកាន់វិហារ" ទើបទៅកាន់វិហារ ឃើញកូនបួសហើយ ក៏កន្ទក់កន្ទេញយំរៀបរាប់ ហើយពោលថា "នែកូន ហេតុអ្វីទើបកូនធ្វើឲ្យពុកវិនាសយ៉ាងនេះ" ដូច្នេះហើយ គិតថា "កាលបើកូនរបស់យើងបួសហើយ យើងនៅគ្រប់គ្រងផ្ទះធ្វើអ្វីទៀត" លុះគិតដូច្នេះហើយ ក៏បួសក្នុងសម្នាក់ភិក្ខុទាំងឡាយ ។ លំដាប់នោះ មាតារបស់គេគិតថា "មានហេតុអ្វីហ្ន៎ ទើបកូន និងស្វាមីរបស់យើងបាត់យូរម្ល៉េះ ប្រហែលជាទៅកាន់វិហារបួសហើយទេដឹង" រកមើលជនទាំងពីរនោះបណ្ដើរ ដើរទៅកាន់វិហារបណ្ដើរ ឃើញជនទាំងពីរនោះបួសហើយ ក៏គិតថា ប្រយោជន៍អ្វីដោយការនៅគ្របគ្រងផ្ទះរបស់យើងក្នុងកាលដែលជនទាំងពីរនេះបួសហើយ" លុះគិតដូច្នេះហើយ ក៏ទៅកាន់

សម្នាក់ភិក្ខុនី ហើយក៏បួសដែរ ។

ជនទាំងបីនាក់នោះសូម្បីបួសហើយ ក៏នៅតែមិនអាចបែកគ្នាបាន អង្គុយចរចារួមគ្នា ញ៉ាំងថ្ងៃឲ្យកន្លងទៅទាំងក្នុងវិហារ ទាំងក្នុងសម្នាក់ភិក្ខុនី ។ ហេតុនោះ ទាំងពួកភិក្ខុ ទាំងពួកភិក្ខុនីត្រូវរំខាន ។ ក្រោយមកនៅថ្ងៃមួយ ភិក្ខុទាំងឡាយក្រាបទូលនូវអំពើរបស់ជនទាំងបីនាក់នោះចំពោះព្រះសាស្ដា ។

ព្រះសាស្ដាត្រាស់ហៅមកជាស់តឿន

ព្រះសាស្ដា ត្រាស់ឲ្យហៅជនទាំងបីនោះមក ហើយត្រាស់សួរថា "បានឮថា ពួកអ្នកបានធ្វើយ៉ាងនោះពិតមែនឬ" កាលជនទាំងនោះក្រាបទូលថា "ពិតមែនព្រះអង្គ" ក៏ត្រាស់សួរថា "ព្រោះហេតុអ្វី ទើបពួកអ្នកធ្វើយ៉ាងនោះ ដ្បិតថា នោះមិនមែនជាសេចក្ដីព្យាយាមរបស់បព្វជិតទេ" ។ ជនទាំងបីក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនអាចនឹងនៅបែកគ្នាបាន" ។ ព្រះសាស្ដាត្រាស់ថា "ការធ្វើយ៉ាងនោះ ចាប់តាំងអំពីកាលដែលខ្លួនបួសហើយ មិនគួរ ព្រោះថា ការមិនឃើញសត្វ និងសង្ខារដែលជាទីស្រឡាញ់ ការឃើញនូវសត្វ និងសង្ខារដែលមិនជាទីស្រឡាញ់ ជាទុក្ខដោយពិត ហេតុនោះ ការធ្វើសត្វ និងសង្ខារទាំងឡាយណាមួយឲ្យជាទីស្រឡាញ់ក្ដី មិនឲ្យជាទីស្រឡាញ់ក្ដី រមែងមិនសមគួរ" ដូច្នេះហើយ ទើបទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖

១. អយោគេ យុញ្ជមត្តានំ យោគស្មិញ្ច អយោជយំ
អត្ថំ ហិត្វា បិយគ្គាហី បិហេតត្តានុយោគិនំ ។

មា បិយេហិ សមាគញ្ឆិ អប្បិយេហិ កុទាចនំ
បិយានំ អទស្សនំ ទុក្ខំ អប្បិយានញ្ច ទស្សនំ ។
តស្មា បិយំ ន កយិរាថ បិយាបាយោ ហិ បាបកោ
គន្ថា តេសំ ន វិជ្ជន្តិ យេសំ នត្ថិ បិយាប្បិយំ ។

បុគ្គលកាលប្រកបខ្លួនទុក ក្នុងអំពើដែលមិនគួរប្រកប មិនប្រកបខ្លួន ក្នុងអំពើដែលគួរប្រកប លះបង់ប្រយោជន៍ចេញហើយ កាន់យកតាមគាប់ចិត្ត រមែងស្រឡាញ់ បុគ្គលអ្នកប្រកបតាមខ្លួន ។ កុំគប់រកសត្វ និងសង្ខារទាំងឡាយ ដែលជាទីសឡាញ់ និងមិនជាទីស្រឡាញ់ ក្នុងកាលណាៗ ឡើយ ព្រោះថា ការមិនជួបប្រសព្វសត្វ និងសង្ខារជាទីស្រឡាញ់ក្តី ការជួបប្រសព្វសត្វ និងសង្ខារមិនជាទីស្រឡាញ់ក្តី ជាហេតុនាំមកនូវទុក្ខ ។ ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វ និងសង្ខារឲ្យជាទីស្រឡាញ់ ព្រោះការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាសភាពអាក្រក់ ការស្រឡាញ់ និងការស្អប់ មិនមានដល់ពួកជនណា កិលេសគ្រឿងចាក់ស្រែះទាំងឡាយ តែងមិនមានដល់ពួកជននោះ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា អយោគេ (ក្នុងវត្ថុដែលមិនគួរប្រកប) សេចក្តី

ថា ក្នុងអំពើដែលមិនគួរប្រកប គឺ ការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ ។ អធិប្បាយថា ការសេពអគោចរ ៦ យ៉ាង មានអគោចរ គឺ ស្រ្តីពេស្យាជាដើម ឈ្មោះថា ការធ្វើទុកក្នុងចិត្តដោយឧបាយមិនល្អ ក្នុងគាថានេះ បុគ្គលប្រកបខ្លួនទុកក្នុងការធ្វើទុកក្នុងចិត្តដោយឧបាយមិនល្អនោះ ។ បទថា **យោគស្មឹ (ក្នុងវត្ថុដែលគួរប្រកប)** សេចក្តីថា មិនប្រកបខ្លួនទុកក្នុងយោនិសោមនសិការដែលផ្ទុយអំពីអយោនិសោមនសិការនោះ ។ បទថា **អត្ថំ ហិត្វា (លះបង់ចេញហើយនូវប្រយោជន៍)** សេចក្តីថា ពួកបីនៃសិក្ខា មានអធិសីលសិក្ខាជាដើម ឈ្មោះថាជាប្រយោជន៍ លះបង់នូវប្រយោជន៍នោះ ។ បទថា **បិយគ្គាហី (កាន់យកអារម្មណ៍ដែលជាទីស្រឡាញ់)** សេចក្តីថា បានកាន់យកហើយនូវអារម្មណ៍ដែលជាទីស្រឡាញ់ ពោលគឺ កាមគុណ ៥ ប៉ុណ្ណោះ ។ បទថា **បិហេតត្តានុយោគិនំ (ស្រឡាញ់ចំពោះបុគ្គលដែលតាមប្រកបជាមួយខ្លួន)** សេចក្តីថា បុគ្គលឃ្លាតចាកសាសនាដោយការបដិបត្តិនោះ ដល់នូវភាពជាគ្រហស្ថ ក្រោយមករមែងស្រឡាញ់បុគ្គលទាំងឡាយដែលប្រកបតាមខ្លួន ញុំាងគុណទាំងឡាយ មានសីលជាដើមឲ្យដល់ព្រមហើយ បានទទួលសក្ការៈពីសម្នាក់ទេវតា និងមនុស្សទាំងឡាយ គឺ រមែងប្រាថ្នាថា “ធ្វើដូចម្តេចហ្ន៎ យើងគប្បីជាមនុស្ស ដូច្នេះ” ។ បទថា **មា បិយេហិ (កុំសមាគមជាមួយសត្វទាំងឡាយដែលជាទីស្រឡាញ់)** សេចក្តីថា បុគ្គលមិនគប្បីសមាគមជាមួយសត្វ និងសង្ខារដែលជាទីស្រឡាញ់ ក្នុងកាលណាៗ ឡើយ គឺ សូម្បីតែមួយខណៈ សត្វ ឬសង្ខារទាំងឡាយដែល

មិនជាទីស្រឡាញ់ ក៏ដូចគ្នា ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះថា ការមិនឃើញសត្វ និងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ ដោយអំណាចនៃការព្រាត់ប្រាស និងការឃើញសត្វ និងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ ដោយអំណាចការចូលទៅជិត ជាទុក្ខ ។

បទថា **តស្មា (ព្រោះហេតុនោះ)** សេចក្តីថា ព្រោះថា ការជួប និងការមិនជួប ទាំងពីរនេះជាទុក្ខ ។ ព្រោះហេតុនោះ បុគ្គលមិនគប្បីធ្វើសត្វ និងសង្ខារណាៗ ឲ្យជាទីស្រឡាញ់ឡើយ ។ ការប្រាសទៅ គឺ ការព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ ឈ្មោះថា **បិយាបាយោ** ។ បទថា **បាបកោ (ថោកទាប)** បានដល់ លាមក ។

បទថា **គន្ថា តេសំ ន វិជ្ជន្តិ (កិលេសជាគ្រឿងចងទាំងឡាយ រមែងមិនមានដល់បុគ្គលដែលមិនមានអារម្មណ៍ជាទីស្រឡាញ់)** សេចក្តីថា ពួកជនណាមិនមានសេចក្តីស្រឡាញ់ ពួកជននោះរមែងលះបង់នូវកិលេសជាគ្រឿងចាក់ស្រែះផ្លូវកាយ គឺ អភិជ្ឈាចេញបាន ។ ជនទាំងឡាយណា មិនមានការស្អប់ ជនទាំងនោះរមែងលះបង់គ្រឿងជោតក្រង (កាយគន្ថៈ) គឺ ព្យាបាទចេញបាន កាលលះបង់កិលេស ២ យ៉ាងនោះបានហើយ សូម្បីកិលេសជាគ្រឿងចាក់ស្រែះដ៏សេស ក៏ឈ្មោះថា បានលះបង់ហើយដែរ ព្រោះហេតុនោះ បុគ្គលមិនគប្បីធ្វើអារម្មណ៍ឲ្យជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ឡើយ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំង

ឡាយ មានសោតាបត្តិផលជាដើម ។ ចំណែកជនទាំងបីនាក់នោះ គិតថា "ពួកយើងមិនអាចនៅបែកគ្នាបានទេ" ដូច្នេះ ក៏សឹកទៅកាន់ផ្ទះដូចដើមវិញ ។

ចប់ រឿងបព្វជិត ៣ រូប

# ២. រឿងកុដុម្ពិកម្នាក់

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **បិយតោ ជាយតី (រមែងកើតពីសេចក្តីស្រឡាញ់)** ជាដើម ។*

ព្រះសាស្តាស្តេចយាងទៅរម្ងាប់សេចក្តីសោករបស់កុដុម្ពិក

*សេចក្តីពិស្តារថា កុដុម្ពិកនោះ កាលបុត្ររបស់ខ្លួនធ្វើកាលកិរិយាទៅ ត្រូវសេចក្តីសោកចំពោះបុត្តគ្របសង្កត់ ទៅកាន់ប៉ាឆាស្រែកយំ មិនអាចហាមឃាត់សេចក្តីសោកចំពោះបុត្តបាន ។ ព្រះសាស្តាទ្រង់ពិចារណាមើលសត្វលោកក្នុងវេលាជិតភ្លឺ ទ្រង់បានឃើញធម៌ដែលជាឧបនិស្ស័យនៃសោតាបត្តិមគ្គរបស់កុដុម្ពិកនោះ ត្រឡប់មកអំពីបិណ្ឌបាតហើយ ទ្រង់នាំភិក្ខុអ្នកជាបច្ឆាសមណៈមួយរូប ស្តេចយាងទៅកាន់ផ្ទះរបស់កុដុម្ពិកនោះ ។ កុដុម្ពិកនោះ បានឮថា ព្រះសាស្តាស្តេចយាងមកផ្ទះរបស់ខ្លួន ក៏គិតថា "ព្រះសាស្តាទ្រង់នឹងបំណងដើម្បីធ្វើនូវបដិសណ្ឋារៈជាមួយយើង" ទើបអាពធនាព្រះសាស្តាឲ្យស្តេចចូលទៅកាន់ផ្ទះ ក្រាលអាសនៈត្រង់កណ្តាលផ្ទះ កាលព្រះសាស្តាទ្រង់ប្រថាប់គង់ហើយ ក៏មកថ្វាយបង្គំ ហើយអង្គុយក្នុងទីដ៏សមគួរមួយ ។ គ្រានោះ ព្រះសាស្តាត្រាស់សួរកុដុម្ពិកនោះថា "ឧបាសក អ្នកកើតទុក្ខព្រោះហេតុអ្វីហ្ន៎" កាលកុដុម្ពិកនោះក្រាបទូលថា ខ្ញុំព្រះអង្គកើតទុក្ខព្រោះព្រាត់ប្រាសចាកបុត្តដែលជាទីស្រឡាញ់*

ក៏ត្រាស់ថា "កុំគិតឡើយ ឧបាសក ឈ្មោះថា សេចក្ដីស្លាប់នេះ មិនមែនមានតែក្នុងទីមួយទេ ទាំងមិនមែនមានតែចំពោះបុគ្គលម្នាក់ដែរ ការប្រព្រឹត្តទៅនៃភព នៅមានដរាបណា សេចក្ដីស្លាប់ក៏រមែងមានដល់សព្វសត្វដរាបនោះឯង សង្ខារសូម្បីតែមួយ ដែលឈ្មោះថា ទៀង រមែងមិនមាន ព្រោះហេតុនោះ អ្នកគប្បីពិចារណាដោយឧបាយដ៏ប្រពៃថា "ធម្មជាតិដែលមានសេចក្ដីស្លាប់ជាធម្មតា បានស្លាប់ហើយ ធម្មជាតិដែលមានការបែកធ្លាយជាធម្មតា បែកធ្លាយហើយ មិនគួរសោកសៅឡើយ ដ្បិតថា បុរាណបណ្ឌិតទាំងឡាយ ក្នុងកាលបុត្រដែលជាទីស្រឡាញ់ស្លាប់ បានពិចារណាថា "ធម្មជាតិដែលមានសេចក្ដីស្លាប់ជាធម្មតាស្លាប់ហើយ ធម្មជាតិដែលមានការបែកធ្លាយជាធម្មតា បែកធ្លាយហើយ ដូច្នេះហើយ មិនធ្វើនូវសេចក្ដីសោក ចម្រើនមរណស្សតិតែម្យ៉ាង" កុដុម្ពិក៏នោះទូលអារាធនាថា "បពិត្រព្រះអង្គដ៏ចម្រើន បណ្ឌិតពួកណាបានធ្វើហើយយ៉ាងនោះ ហើយបានធ្វើក្នុងកាលណា? សូមព្រះអង្គត្រាស់ប្រាប់ខ្ញុំព្រះអង្គ" កាលនឹងទ្រង់ប្រកាសនូវសេចក្ដីនោះឲ្យជាក់ច្បាស់ ទើបទ្រង់នាំអតីតនិទានមក ញ៉ាំងឧរគជាតកក្នុងបញ្ចកនិបាតឲ្យពិស្ដារថា ៖

កូនរបស់យើង កាលសរីរៈប្រើប្រាស់មិនបាន លះបង់សរីរៈ
ដូចជារបស់ខ្លួនទៅ ដូចពស់លះបង់នូវសំណកចាស់ ដូច្នោះ
កាលបុត្ររបស់យើងស្លាប់ទៅហើយ រាងកាយកាលត្រូវគេដុត
រមែងមិនដឹងនូវបរិទេវនាការនៃញាតិ ព្រោះដូច្នោះ ទើបយើង

មិនសោកសៅចំពោះបុត្តនុ៎ះ គេមានគតិយ៉ាងណា គេក៏ទៅកាន់គតិនោះឯង ។

ដូច្នេះហើយ ក៏ទ្រង់ត្រាស់តទៅទៀតថា “បណ្ឌិតក្នុងកាលមុន កាលកូនដែលជាទីស្រឡាញ់ធ្វើកាលកិរិយាហើយយ៉ាងនោះ មិនប្រព្រឹត្តទៅដូចជាអ្នកដែលបោះបង់នូវការងារទាំងឡាយ ហើយមិនបរិភោគអាហារ ដើរតែយំនោះទេ មិនធ្វើសេចក្តីសោក ដោយអំណាចមរណស្សតិភាវនា ទទួលទានអាហារ ហើយអធិដ្ឋាន (តាំងចិត្តធ្វើ) ការងារទាំងឡាយ ព្រោះដូច្នោះ អ្នកកុំគិតថា “កូនដែលជាទីស្រឡាញ់របស់យើងស្លាប់ហើយ” ពិតណាស់ សេចក្តីសោកក្តី ភ័យក្តី កាលនឹងកើត រមែងអាស្រ័យវត្ថុដែលជាទីស្រឡាញ់នោះឯងកើតឡើង” ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

២. បិយតោ ជាយតី សោកោ   បិយតោ ជាយតី ភយំ
បិយតោ វិប្បមុត្តស្ស   នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា បិយតោ (អំពីរបស់ជាទីស្រឡាញ់) ជាដើម សេចក្តីថា ក៏សេចក្តីសោកក្តី ភ័យក្តី ដែលមានវដ្តៈជាមូល កាលនឹងកើតឡើង

រមែងកើតឡើងអាស្រ័យសត្វ និងសង្ខារដែលជាទីស្រឡាញ់ប៉ុណ្ណោះ តែសេចក្តីសោក និងភ័យសូម្បីទាំងពីរនោះ រមែងមិនមានដល់បុគ្គលអ្នកផុតស្រឡះចាកសត្វ និងសង្ខារដែលជាទីស្រឡាញ់ហើយ ។

ក្នុងកាលចប់ព្រះធម៌ទេសនា កុដុម្ពីក៍នោះ ក៏បានសម្រេចសោតាបត្តិ-ផល ទេសនារមែងបានជាប្រយោជន៍ដល់ជនទាំងឡាយដែលប្រជុំគ្នា ដូច្នេះ ។

ចប់ រឿងកុដុម្ពីក៍ម្នាក់

# ៣. រឿងនាងវិសាខាឧបាសិកា

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងវិសាខាឧបាសិកា ត្រាស់ព្រះធម្មទេសនានេះថា* **បេមតោ ជាយតី** *(រមែងកើតពីសេចក្តីស្រឡាញ់) ជាដើម ។*

ព្រះសាស្តាត្រាស់ឧបាយរំងាប់សេចក្តីសោក

*បានឮថា នាងវិសាខានោះ តាំងទុកនូវកុមារិកាឈ្មោះ សុទត្តី ជាធីតារបស់បុត្រក្នុងតំណែងរបស់ខ្លួន ឲ្យធ្វើជាអ្នកខ្វល់ខ្វាយបម្រើព្រះសង្ឃក្នុងផ្ទះ ។ ក្នុងសម័យដទៃ កុមារិកានោះបានធ្វើកាលកិរិយា នាងវិសាខាប្រើគេឲ្យបញ្ចុះសាកសពនាងសុទត្តីនោះហើយ មិនអាចនឹងអត់សង្កត់នូវសេចក្តីសោកបាន ជាអ្នកមានទុក្ខទោមនស្សទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយនៅក្នុងទីដ៏សមគួរមួយ ។ លំដាប់នោះ ព្រះសាស្តាត្រាស់ទៅកាន់នាងវិសាខាថា "ម្នាលនាងវិសាខា ព្រោះហេតុអ្វី ទើបនាងកើតទុក្ខខូចចិត្ត មានមុខជោកដោយទឹកភ្នែក អង្គុយយំដូច្នេះ" នាងក៏ទូលនូវសេចក្តីនោះ ហើយបានក្រាបទូលថា "ព្រះអង្គដ៏ចម្រើន នាងកុមារីនោះ ជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គ ជាអ្នកដល់ព្រមហើយដោយវត្ត ឥឡូវនេះ ខ្ញុំព្រះអង្គមិនឃើញនូវកុមារីដែលមានសភាពដូច្នោះ" ។*

*ព្រះសាស្តា. វិសាខា ក៏ក្នុងក្រុងសាវត្ថីនេះ មានមនុស្សប្រមាណប៉ុន្មាន?*

វិសាខា. បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គបានត្រាស់ប្រាប់ខ្ញុំព្រះអង្គថា ក្នុងក្រុងសាវត្ថី មានមនុស្ស ៧ កោដិ ។

ព្រះសាស្តា. បើមនុស្សមានប្រមាណប៉ុណ្ណេះ ក៏គប្បីមានដូចជាចៅស្រី របស់នាង នាងគប្បីប្រាថ្នាមនុស្សទាំងនោះឬ ?

នាងវិសាខា. ព្រះករុណា ព្រះអង្គ ។

ព្រះសាស្តា. ក៏មនុស្សដែលនៅក្នុងក្រុងសាវត្ថី ស្លាប់មួយថ្ងៃប៉ុន្មាននាក់?

នាងវិសាខា. បពិត្រព្រះអង្គដ៏ចម្រើន ច្រើន ។

ព្រះសាស្តា. បើដូច្នោះ វេលាដែលមិនសោយសោករបស់នាង មិនគប្បីមានឬ? នាងគប្បីយំអស់ថ្ងៃនិងយប់ មិនមែនឬ ?

នាងវិសាខា. បពិត្រព្រះអង្គដ៏ចម្រើន សូមលើកទុកសិនចុះ ខ្ញុំព្រះអង្គដឹងហើយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់ទៅកាន់នាងថា "បើដូច្នោះ នាងកុំសោកឡើយ សេចក្តីសោកក្តី ភ័យក្តី រមែងកើតពីសេចក្តីស្រឡាញ់" ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

៣. បេមតោ ជាយតី សោកោ  បេមតោ ជាយតី ភយំ
បេមតោ វិប្បមុត្តស្ស  នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោក កើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តី ស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តី

សោកក៏លែងមាន ភ័យនឹងមានមកអំពីណា ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **បេមតោ** (ពីសេចក្ដីស្រឡាញ់) សេចក្ដីថា ព្រោះអាស្រ័យសេចក្ដីស្រឡាញ់ ដែលធ្វើទុកចំពោះបុត្រ និងធីតាជាដើមនោះឯង ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងនាងវិសាខាឧបាសិកា

# ៤. រឿងស្តេចលិច្ឆវី

ព្រះសាស្តា កាលទ្រង់អាស្រ័យក្រុងវេសាលី ទ្រង់ប្រថាប់គង់នៅក្នុងកូដាគារសាលា ទ្រង់ប្រារព្ធពួកស្តេចលិច្ឆវី ត្រាស់ព្រះធម្មទេសនានេះថា ***រតិយា ជាយតី (កើតអំពីតម្រេក)*** ជាដើម ។

## ព្រះសាស្តាត្រាស់ទោសនៃតម្រេកក្នុងកាម

បានឮថា នៅក្នុងថ្ងៃមហោស្រពមួយ ស្តេចលិច្ឆវីទាំងនោះ មួយអង្គៗ តាក់តែងព្រះកាយដោយគ្រឿងអលង្ការទាំងឡាយមិនដូចគ្នា ចេញចាកព្រះនគរទៅកាន់ឧទ្យាន ។ ព្រះសាស្តា ស្តេចយាងចូលទៅបិណ្ឌបាត ទ្រង់ឃើញស្តេចលិច្ឆវីទាំងនោះ ក៏ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមើលស្តេចលិច្ឆវីទាំងនោះ ។ ជនទាំងឡាយដែលមិនធ្លាប់ឃើញទេវតាជាន់តាវត្តិង្ស ចូរមើលស្តេចលិច្ឆវីទាំងនោះចុះ" ដូច្នេះហើយ ស្តេចចូលទៅកាន់ព្រះនគរ ។ សូម្បីស្តេចលិច្ឆវីទាំងនោះ កាលទៅកាន់ឧទ្យាន បាននាំស្ត្រីនគរសោភិនីម្នាក់ទៅជាមួយ អាស្រ័យស្ត្រីនោះ ក៏ត្រូវសេចក្តីប្រណែនគ្របសង្កត់ បានប្រហារនូវគ្នានិងគ្នា ញុំាងឈាមឲ្យហូរដូចជាស្ទឹង ។ គ្រានោះ ពួករាជបុរសលើកស្តេចលិច្ឆវីទាំងនោះដាក់លើគ្រែ ហើយសែងមកវិញ ។ ចំណែកព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ស្តេចក៏ចេញចាកព្រះនគរ ។ ឯពួកភិក្ខុឃើញពួកអ្នកសែង សែងស្តេចលិច្ឆវីទាំងនោះទៅ

ដោយប្រការដូច្នោះ ក៏ក្រាបទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ស្តេចលិច្ឆវីទាំងនោះ កាលពីព្រឹកប្រដាប់តាក់តែងហើយ ចេញចាកព្រះនគរដូចជាពួកទេវតា ឥឡូវនេះអាស្រ័យស្ត្រីម្នាក់ ក៏ដល់នូវសេចក្តីវិនាសយ៉ាងនេះ" ។

ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សេចក្តីសោកក្តី ភ័យក្តី កាលនឹងកើតឡើង រមែងកើតឡើងអាស្រ័យតម្រេក" ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

*៤. រតិយា ជាយតី សោកោ   រតិយា ជាយតី ភយំ*
*រតិយា វិប្បមុត្តស្ស   នត្ថិ សោកោ កុតោ ភយំ ។*

*សេចក្តីសោកកើតអំពីតម្រេក ភ័យកើតអំពីតម្រេក កាលបើរួចស្រឡះចាកតម្រេកហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកអំពីណា ។*

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា *រតិយា (អំពីតម្រេក)* សេចក្តីថា ពីសេចក្តីត្រេកអរក្នុងកាមគុណ ៥ គឺ ព្រោះអាស្រ័យតម្រេកក្នុងកាមគុណ ៥ នោះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងស្តេចលិច្ឆវី

# ៥. រឿងអនិត្ថិគន្ធកុមារ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនិត្ថិគន្ធកុមារ ត្រាស់ព្រះធម្មទេសនានេះថា **កាមតោ ជាយតី (កើតពីកាម)** ជាដើម ។*

*អនិត្ថិគន្ធកុមារឱ្យជាងធ្វើរូបស្រ្តី*

*បានឮថា អនិត្ថិគន្ធកុមារនោះ ជាសត្វដែលចុតិចាកព្រហ្មលោក កើតក្នុងត្រកូលដែលមានភោគៈច្រើន ក្នុងក្រុងសាវត្ថី ។ តាំងពីកើតមក មិនដែលប្រាថ្នានឹងចូលទៅជិតស្រ្តីទេ ត្រូវស្រ្តីចាប់កាន់ក៏ស្រែកយំ មាតា (ត្រូវ) ចាប់កាន់កុមារនោះដោយសំពត់ស្បៃហើយ ទើបឲ្យបៅទឹកដោះ ។ កុមារនោះចម្រើនវ័យហើយ កាលមាតាបិតាពោលថា “នែកូន មាតាបិតានឹងធ្វើនូវអាវាហមង្គលឲ្យដល់កូន” ក៏ហាមឃាត់ថា “ខ្ញុំមិនត្រូវការស្រីទេ” កាលត្រូវមាតាបិតាអង្វររឿយៗ ក៏ឲ្យគេហៅជាងមាស ៥០០ នាក់មក ហើយប្រើគេឲ្យយកមាសដែលមានពណ៌ក្រហម (មាសឆ្អិន) ឲ្យធ្វើជារូបស្រ្តីទាំងដុំ គួរជាទីជ្រះថ្លាយ៉ាងក្រៃលែង កាលមាតាបិតាពោលទៀតថា “នែកូន កាលកូនមិនធ្វើអាវាហមង្គលត្រកូលរបស់យើងនឹងតាំងនៅមិនបាន មាតាបិតានឹងនាំកុមារិកាមកឲ្យកូន” ក៏ពោលថា “បើដូច្នោះ បើលោកទាំងពីរនឹងនាំកុមារិកាដូច្នោះមកឲ្យខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់លោកទាំងពីរ” ដូច្នេះហើយ ក៏សម្តែងនូវរូបមាសនោះ ។ គ្រានោះ មាតាបិតារបស់កុមារនោះ ប្រើគេឲ្យអញ្ជើញពួកព្រាហ្មណ៍ដែលល្បីៗ*

មក ហើយប្រាប់ថា "បុត្ររបស់យើង មានបុណ្យច្រើន គង់នឹងមានកុមារិកាអ្នកធ្វើបុណ្យរួមជាមួយនឹងបុត្ររបស់យើងជាប្រាកដ ពួកលោកចូរទៅ ចូរនាំយករូបមាសនេះទៅ ហើយនាំកុមារិកាដែលមានរូបដូច្នេះមក" លុះពោលដូច្នេះហើយ ក៏បញ្ជូនព្រាហ្មណ៍ទាំងនោះទៅ ។ ព្រាហ្មណ៍ទាំងនោះទទួលថា "ប្រពៃហើយ" ព្រាហ្មណ៍ទាំងនោះ កាលត្រាច់ទៅកាន់ទីចារិក បានទៅដល់សាគលនគរ ក្នុងដែនមទ្ទៈ ។

## ព្រាហ្មណ៍ជួបស្ត្រីដែលមានរូបដូចមាសហើយត្រឡប់មក

ក៏ក្នុងនគរនោះ មានកុមារិកាម្នាក់រូបស្អាត អាយុប្រហែលជា ១៦ ឆ្នាំ ។ មាតាបិតារបស់នាង ឲ្យនាងនៅខាងលើប្រាសាទ ៧ ជាន់ ព្រាហ្មណ៍ទាំងនោះគិតគ្នាថា "ប្រសិនបើក្នុងនគរនេះ មានកុមារិកាបែបនេះ ជនទាំងឡាយឃើញរូបមាសនេះហើយ ក៏នឹងពោលថា រូបចម្លាក់នេះស្រស់ស្អាត ដូចជាធីតានៃត្រកូលឯណោះ" ដូច្នេះហើយ ក៏តាំងទុកនូវរូបនោះក្បែរផ្លូវទៅកាន់កំពង់ទឹក ហើយអង្គុយរង់ចាំមើលក្នុងទីដ៏សមគួរមួយ ។ លំដាប់នោះ ស្ត្រីមេដោះរបស់កុមារិកានោះ ងូតទឹកឲ្យកុមារិកានោះហើយ ប្រាថ្នានឹងងូតទឹកខ្លួនឯង ទើបដើរទៅកាន់កំពង់ទឹក ឃើញរូបនោះក៏សម្គាល់ថាជា "ធីតារបស់ខ្លួន" ក៏ពោលថា "ឱ! នាងជាស្ត្រីប្រដៅក្រ យើងទើបតែងូតទឹកឲ្យនាងហើយក្លាមដើរចេញមក តែនាងគេចមុខអំពីយើង មកកាន់ទីនេះមុនយើងទៀត" ដូច្នេះហើយ ក៏វាយរូបនោះដោយដៃ ដឹងថា រូបនោះរឹង ហើយមិនមានវិការៈ ទើបពោលថា "យើង

បានសម្គាល់ថា នាងនេះជាធីតារបស់យើង នោះជាអ្វីទៅ?” ។ លំដាប់នោះ ព្រាហ្មណ៍ទាំងនោះ ក៏សួរស្ត្រីមេដោះនោះថា “ម្នាលនាង ធីតារបស់នាងមាន រូបដូច្នេះឬ?” ។

មេដោះ. រូបចម្លាក់នេះ នឹងមានតម្លៃអ្វីក្នុងសម្នាក់ធីតារបស់យើង ។

ព្រាហ្មណ. បើដូច្នោះ ចូរនាងសម្តែងធីតារបស់នាងដល់ពួកយើង ។

មេដោះនោះ ទៅកាន់ផ្ទះជាមួយនឹងព្រាហ្មណទាំងនោះហើយ ក៏ជម្រាប ដល់ម្ចាស់ទាំងឡាយ ។ មាតាបិតារបស់កុមារិកានោះ ក៏បានរីករាយជាមួយ នឹងព្រាហ្មណ៍ ហើយក៏ឲ្យធីតារបស់ខ្លួន ចុះមកឈរជិតរូបមាសនៅប្រាសាទ ជាន់ក្រោម ។ រូបមាសនោះ ក៏អស់រស្មី នៅពេលដែលកុមារិកានោះមកឈរ ជិត ។ ព្រាហ្មណ៍ទាំងនោះ ឲ្យរូបមាសនោះទៅមាតាបិតារបស់កុមារិកានោះ ហើយ ញុំាងកុមារិកានោះឲ្យទទួលទុកហើយ ក៏ត្រឡប់ទៅប្រាប់មាតាបិតារបស់ អនិត្ថិគន្ធកុមារ ។

## ក្ដីក្រុងរបស់អនិត្ថិគន្ធកុមារស្លាប់ក្នុងវាងផ្លូវ

មាតាបិតារបស់អនិត្ថិគន្ធកុមារត្រេកអរណាស់ ហើយពោលថា “អ្នក ទាំងឡាយចូរទៅ ចូរនាំកុមារិកានោះមកឲ្យឆាប់” លុះពោលដូច្នេះហើយ ក៏បញ្ជូន គ្រឿងសក្ការៈទៅយ៉ាងច្រើន ។ ចំណែកកុមារ បានឮដំណឹងនោះហើយ ក៏ ញុំាងសេចក្ដីស្រឡាញ់ឲ្យកើតឡើង ដោយអំណាចការបានឮថា “មានក្មេងស្រី មានរូបរាងស្រស់ស្អាតជាងរូបមាសទៀត” ទើបពោលថា “លោកទាំងឡាយ

ចូរនាំនាងមកឲ្យឆាប់” ចំណែកកុមារិកានោះ កាលគេលើកឡើងកាន់យាននាំមក ក៏មានរោគខ្យល់ព្រោះការរលាក់នៃយាន បានធ្វើកាលកិរិយាក្នុងរវាងផ្លូវ ព្រោះនាងជាស្ត្រីប្រកបដោយសុខមាលជាតិ ។

ចំណែកកុមារ តែងតែសួររឿយៗ ថា “មកហើយឬ” ជនទាំងឡាយមិនប្រាប់កុមារនោះ ដែលសួរដោយសេចក្តីស្នេហាក្រៃពេកភ្លាមៗ នោះទេ បង្អែបង្អង់ ២-៣ ថ្ងៃ ទើបប្រាប់រឿងនោះ ។ កុមារនោះ កើតទុក្ខទោមនស្សត្រូវចិត្តថា “យើងមិនបានការរួមរស់នឹងស្ត្រីបែបនោះ” ត្រូវទុក្ខដែលកើតអំពីសេចក្តីសោក ដូចជាភ្នំគ្របសង្កត់ ។

ព្រះសាស្តាទ្រង់សម្តែងឧបាយរម្ងាប់សេចក្តីសោក

ព្រះសាស្តា ទ្រង់ឃើញឧបនិស្ស័យរបស់កុមារនោះ កាលស្តេចយាងទៅបិណ្ឌបាត ស្តេចបានយាងទៅកាន់ទ្វារនៃផ្ទះនោះ ។ លំដាប់នោះ មាតាបិតារបស់កុមារនោះ អារាធនានិមន្តព្រះសាស្តាយាងចូលផ្ទះ ហើយអង្គាសដោយគោរព ។ ក្នុងវេលាស្រេចភត្តកិច្ច ព្រះសាស្តាត្រាស់សួរថា “អនិត្ថិគន្ធកុមារទៅណា?” ។

មាតាបិតា. បពិត្រព្រះអង្គ អនិត្ថិគន្ធកុមារនោះ អត់អាហារដេកនៅក្នុងបន្ទប់ ។

ព្រះសាស្តា. ចូរទៅហៅគេមក ។

អនិត្ថិគន្ធកុមារនោះមក ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយនៅក្នុងទីដ៏

សមគួរមួយ កាលព្រះសាស្ដាត្រាស់សួរថា “ម្នាលកុមារ សេចក្ដីសោកដ៏មានកម្លាំងកើតឡើងដល់អ្នកឬ?” ក៏ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីសោកដ៏មានកម្លាំងកើតឡើងដល់ខ្ញុំព្រះអង្គ ព្រោះបានឮថា ស្ត្រីបែបនោះស្លាប់ក្នុងរវាងផ្លូវហើយ សូម្បីតែកត្ត ក៏ខ្ញុំព្រះអង្គមិនឃ្លាន” ។

លំដាប់នោះ ព្រះសាស្ដាត្រាស់ទៅនឹងកុមារនោះថា “ម្នាលកុមារ អ្នកបានដឹងទេថា សេចក្ដីសោកកើតឡើងដល់អ្នក ព្រោះអាស្រ័យអ្វី?” ។

អនិត្ថិគន្ធកុមារ. ខ្ញុំព្រះអង្គមិនដឹងទេ ព្រះអង្គ ។

ព្រះសាស្ដាត្រាស់ថា “ម្នាលកុមារ សេចក្ដីសោកដ៏មានកម្លាំង ដែលកើតឡើងដល់អ្នកនោះ ព្រោះអាស្រ័យកាម ព្រោះថា សេចក្ដីសោកក្ដី ភ័យក្ដី រមែងកើតឡើងព្រោះអាស្រ័យកាម” ដូច្នេះហើយ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖

**៥. កាមតោ ជាយតី សោកោ   កាមតោ ជាយតី ភយំ**
**កាមតោ វិប្បមុត្តស្ស   នត្ថិ សោកោ កុតោ ភយំ ។**

សេចក្ដីសោកកើតអំពីកាម ភ័យកើតអំពីកាម កាលបើរួចស្រឡះចាកកាមហើយ សេចក្ដីសោកក៏លែងមាន ភ័យនឹងមានមកអំពីណា ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **កាមតោ** (អំពីកាម) សេចក្ដីថា ចាកវត្ថុ

កាម និងកិលេសកាម អធិប្បាយថា សេចក្តីសោកក្តី ភ័យក្តី រមែងកើតឡើង អាស្រ័យកាមសូម្បីទាំងពីរយ៉ាងនោះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា អនិត្ថិគន្ធកុមារ ក៏បានសម្រេចសោតា-បត្តិផល ។

ចប់ រឿងអនិត្ថិគន្ធកុមារ

# ៦. រឿងព្រាហ្មណ៍ម្នាក់

*ព្រះសាស្តា កាលប្រថាប់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **តណ្ហាយ ជាយតី** (រមែងកើតព្រោះតណ្ហា) ជាដើម ។*

ព្រះសាស្តាស្តេចយាងទៅប្រោសព្រាហ្មណ៍មិច្ឆាទិដ្ឋិ

*បានឮថា ព្រាហ្មណ៍នោះជាមិច្ឆាទិដ្ឋិ ថ្ងៃមួយគាត់ទៅកាន់មាត់ស្ទឹង ហើយភ្ជួរស្រែ ។ ព្រះសាស្តាទ្រង់ឃើញការដល់ព្រមនៃឧបនិស្ស័យរបស់គាត់ ទើបស្តេចយាងទៅកាន់សម្នាក់របស់គាត់ ។ ព្រាហ្មណ៍នោះ សូម្បីឃើញព្រះសាស្តា ក៏មិនធ្វើសូម្បីតែសាមីចិកម្ម អង្គុយនៅស្ងៀម ។ គ្រានោះ ព្រះសាស្តាត្រាស់សួរគាត់មុនថា "ព្រាហ្មណ៍ អ្នកកំពុងធ្វើអ្វី?" ។*

*ព្រាហ្មណ៍. បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំកំពុងជម្រះស្រែ ។*

*ព្រះសាស្តាត្រាស់សួរត្រឹមតែប៉ុណ្ណោះហើយ ស្តេចក៏ចៀសចេញទៅ សូម្បីថ្ងៃស្អែក ក៏ព្រះសាស្តាស្តេចយាងទៅកាន់សម្នាក់របស់គាត់ ដែលមកភ្ជួរស្រែ ទ្រង់ត្រាស់សួរថា "ព្រាហ្មណ៍ អ្នកកំពុងធ្វើអ្វី?" ទ្រង់ស្តាប់ថា "ព្រះគោតមដ៏ចម្រើន ខ្ញុំកំពុងភ្ជួរស្រែ" ដូច្នេះហើយ ស្តេចក៏យាងចៀសចេញទៅ ។ សូម្បីក្នុងថ្ងៃតៗ មក ព្រះសាស្តាក៏ស្តេចយាងទៅកាន់សម្នាក់របស់គាត់ ត្រាស់សួរដូច្នោះដដែល ទ្រង់ស្តាប់ថា "ព្រះគោតមដ៏ចម្រើន ខ្ញុំកំពុងព្រោះ កំពុងបាច*

ទឹក កំពុងរក្សាស្រែ" ដូច្នេះហើយ ស្តេចក៏យាងចៀសចេញទៅ ។ គ្រានោះ ព្រាហ្មណ៍ក្រាបទូលព្រះអង្គថា "បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គមកកាន់ទីនេះ ចាប់តាំងពីថ្ងៃដែលខ្ញុំព្រះអង្គជម្រះស្មៅម្ល៉េះ ប្រសិនបើសន្ទូងរបស់ខ្ញុំព្រះអង្គសម្រេចផល ខ្ញុំព្រះអង្គនឹងបែងចែកឲ្យព្រះអង្គខ្លះ បើមិនទាន់ឲ្យព្រះអង្គ ខ្ញុំព្រះអង្គនឹងមិនបរិភោគ ចាប់តាំងពីថ្ងៃនេះទៅ ព្រះអង្គជាសម្លាញ់របស់ខ្ញុំ" ។ លុះក្រោយមក សន្ទូងរបស់ព្រាហ្មណ៍សម្រេចផល ។ កាលព្រាហ្មណ៍ធ្វើកិច្ចគ្រប់យ៉ាងដើម្បីប្រូត ដោយតាំងចិត្តថា "ស្រូវរបស់យើងសម្រេចផលហើយ យើងនឹងឲ្យគេប្រូតក្នុងថ្ងៃស្អែកនេះ" មហាមេឃញាំងភ្លៀងឲ្យបង្អុរចុះមកមួយយប់ទល់ភ្លឺ នាំយកស្រូវរបស់ព្រាហ្មណ៍ទៅអស់ ។ ស្រែប្រាកដស្មើដោយវត្ថុដែលគេជម្រះហើយ ដូច្នេះ ។ ចំណែកព្រះសាស្តា ព្រះអង្គទ្រង់ជ្រាបតាំងអំពីថ្ងៃដំបូងម្ល៉េះថា "ព្រាហ្មណ៍នឹងមិនបានផល" ។ ព្រាហ្មណ៍ទៅស្រែតាំងពីព្រលឹម ដោយតាំងចិត្តថា "យើងនឹងមើលស្រូវ" ក៏ឃើញតែស្រែទទេ បានកើតសេចក្តីសោកយ៉ាងខ្លាំង ទើបគិតថា "ព្រះសមណគោតម មកកាន់ស្រែរបស់យើងតាំងពីថ្ងៃដែលយើងជម្រះស្មៅម្ល៉េះ ចំណែកយើងក៏បានពោលថា "កាលស្រូវរបស់យើងសម្រេចផល យើងនឹងបែងចែកឲ្យព្រះសមណគោតមខ្លះ បើមិនទាន់ឲ្យព្រះសមណគោតម យើងក៏មិនបរិភោគ ចាប់តាំងពីថ្ងៃនេះទៅ ព្រះអង្គជាសម្លាញ់របស់ខ្ញុំ សេចក្តីប្រាថ្នាក្នុងចិត្តរបស់យើងមិនបានសម្រេចឡើយ" ។ ព្រាហ្មណ៍នោះធ្វើការអត់អាហារ ដេកនៅគ្រែតូចមួយ ។ គ្រានោះ ព្រះសាស្តា

ស្តេចយាងទៅកាន់ផ្ទះរបស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍បានដឹងថា ព្រះសាស្តាស្តេចយាងមក ក៏ប្រើ (ជនជាបរិវារ) ថា "ពួកអ្នកចូរទៅនាំសម្ពាញ់របស់យើងមក ហើយឲ្យអង្គុយទីនេះ" ជនជាបរិវារនោះ ក៏បានធ្វើដូច្នេះ ។ ព្រះសាស្តាទ្រង់ប្រថាប់គង់ហើយ ត្រាស់សួរថា "ព្រាហ្មណ៍ទៅណា?" កាលគេក្រាបទូលថា "ដេកនៅក្នុងបន្ទប់" ក៏ទ្រង់ត្រាស់ថា "ពួកអ្នកចូរហៅព្រាហ្មណ៍មក" ហើយត្រាស់សួរព្រាហ្មណ៍ ដែលមកអង្គុយក្នុងទីដ៏សមគួរថា "ព្រាហ្មណ៍ អ្នកកើតអ្វី?" ។

ព្រាហ្មណ. ព្រះគោតមដ៏ចម្រើន ព្រះអង្គបានទៅកាន់ស្រែរបស់ខ្ញុំតាំងពីថ្ងៃដែលខ្ញុំជម្រះស្មៅម៉្លេះ ចំណែកខ្ញុំក៏បានពោលថា កាលស្រូវសម្រេចផលខ្ញុំនឹងបែងចែកឲ្យព្រះអង្គខ្លះ សេចក្តីប្រាថ្នាក្នុងចិត្តរបស់ខ្ញុំមិនសម្រេច ព្រោះហេតុនោះ ទើបសេចក្តីសោកកើតឡើងដល់ខ្ញុំ សូម្បីតែកត្ត ក៏ខ្ញុំមិនឃ្លាន" ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរព្រាហ្មណ៍ថា "ព្រាហ្មណ៍ អ្នកមិនដឹងទេថា សេចក្តីសោកកើតឡើងដល់អ្នក ព្រោះអាស្រ័យអ្វី?" កាលព្រាហ្មណ៍ក្រាបទូលថា "ព្រះគោតម ខ្ញុំមិនដឹងទេ ព្រះអង្គដឹងឬ?" ទើបត្រាស់ថា "យ៉ាងនោះហើយ ព្រាហ្មណ៍ ការពិត សេចក្តីសោកក្តី ភ័យក្តី កាលនឹងកើត រមែងកើតឡើងអាស្រ័យតណ្ហា" ដូច្នេះហើយ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖

៦. តណ្ហាយ ជាយតី សោកោ តណ្ហាយ ជាយតី ភយំ
តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

*សេចក្ដីសោកកើតអំពីតណ្ហា ភ័យកើតអំពីតណ្ហា កាលបើរួចស្រឡះចាកតណ្ហាហើយ សេចក្ដីសោកក៏លែងមាន ភ័យនឹងមានមកអំពីណា ។*

អធិប្បាយគាថា

*បណ្ដាបទទាំងនោះ បទថា **តណ្ហាយ** (ព្រោះតណ្ហា) បានដល់ តណ្ហាដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ អធិប្បាយថា សេចក្ដីសោកជាដើម រមែងកើតឡើងអាស្រ័យតណ្ហានោះ ។*

*ក្នុងកាលចប់ព្រះធម៌ទេសនា ព្រាហ្មណ៍នោះ ក៏បានសម្រេចសោតាបត្តិ-ផល ។*

ចប់ រឿងព្រាហ្មណ៍ម្នាក់

# ៧. រឿងក្មេង ៥០០ នាក់

*ព្រះសាស្តា កាលប្រថាប់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធក្មេង ៥០០ នាក់ ក្នុងរវាងផ្លូវ ត្រាស់ព្រះធម្មទេសនានេះថា **សីលទស្សនសម្បន្នំ** (អ្នកសម្បូរដោយសីល និងទស្សនៈ) ជាដើម ។*

ក្មេង ៥០០ នាក់ ថ្វាយនំដល់ព្រះមហាកស្សបៈ

*សេចក្តីពិស្តារថា ថ្ងៃមួយព្រះសាស្តាមានភិក្ខុ ៥០០ ជាបរិវារ មួយអន្លើដោយព្រះអសីតិមហាថេរៈ ស្តេចយាងចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌ-បាត ទ្រង់ទតឃើញក្មេង ៥០០ នាក់ កាន់កញ្ច្រែងនំចេញពីក្រុងទៅកាន់ឧទ្យានក្នុងថ្ងៃមហោស្រពមួយ ចំណែកក្មេងទាំងនោះថ្វាយបង្គំព្រះសាស្តាហើយ ក៏ចៀសចេញទៅ មិនបានពោលនឹងភិក្ខុសូម្បីតែមួយរូបថា " សូមលោកម្ចាស់ទទួលនំ" ។ ព្រះសាស្តាត្រាស់ទៅកាន់ភិក្ខុទាំងឡាយ ក្នុងកាលដែលក្មេងទាំងនោះដែលទៅហើយថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឆាន់នំឬ?" ។*

*ភិក្ខុ. នំនៅឯណា ព្រះអង្គ ?*

*ព្រះសាស្តា. អ្នកទាំងឡាយមិនឃើញពួកក្មេងកាន់កញ្ច្រែងនំដើរហួសទៅហើយទេឬ ?*

*ភិក្ខុ. ពួកក្មេងទាំងនោះ មិនថ្វាយនំដល់នរណាទេ ព្រះអង្គ ។*

*ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ ក្មេងទាំងនោះមិននិមន្តតថាគត ឬ*

ពួកអ្នកទាំងឡាយដោយទំក៏ពិត តែថា ភិក្ខុដែលជាម្ចាស់ទំកំពុងដើរមកអំពីខាងក្រោយ ឆាន់ទំសិនសឹមទៅ ទើបគួរ ។

តាមធម្មតា ព្រះពុទ្ធទាំងឡាយ រមែងមិនប្រណែន ឬប្រទូស្តចំពោះបុគ្គលណាម្នាក់ឡើយ ព្រោះហេតុនោះ ព្រះសាស្តាត្រាស់ពាក្យនេះហើយ ទើបនាំភិក្ខុសង្ឃទៅគង់នៅក្បែរគល់ឈើមួយ ។ ក្មេងទាំងនោះ ឃើញព្រះមហាកស្សបៈដែលកំពុងនិមន្តមកអំពីខាងក្រោយ កើតសេចក្តីស្រឡាញ់ឡើង មានសរីរៈពេញទៅដោយកម្លាំងនៃបីតិ ដាក់កញ្ច្រែងទំចុះ ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន លើកទំទាំងកញ្ច្រែងឡើង ហើយពោលនឹងព្រះថេរៈថា "បពិត្រលោកម្ចាស់ដ៏ចម្រើន និមន្តទទួលយកចុះ" ។ លំដាប់នោះ ព្រះថេរៈពោលនឹងក្មេងទាំងនោះថា "ទុះ ព្រះសាស្តានឹងភិក្ខុសង្ឃ ប្រថាប់គង់នៅក្បែរគល់ឈើហើយ អ្នកទាំងឡាយចូរកាន់ទេយ្យធម៌ បែងជាចំណែកប្រគេនភិក្ខុចុះ ។ ក្មេងទាំងនោះទទួលព្រមថា "ព្រះករុណា លោកម្ចាស់" ហើយក៏ត្រឡប់ទៅជាមួយព្រះថេរៈ ប្រគេនទំដល់ភិក្ខុទាំងឡាយ ហើយឈរសម្លឹងមើលពួកភិក្ខុនៅក្នុងចំណែកម្ខាង លុះភិក្ខុទាំងឡាយឆាន់ស្រេចហើយ ក៏ប្រគេនទឹក ។

ភិក្ខុទាំងឡាយលើកទោសថា "ពួកក្មេងប្រគេនភិក្ខាព្រោះបុគ្គល មិនទទួលព្រះសម្មាសម្ពុទ្ធ ឬព្រះមហាថេរៈទាំងឡាយដោយទំ ឃើញព្រះមហាកស្សបៈភ្លាម ក៏កាន់យកទំទាំងកញ្ច្រែងមក" ។

ព្រះសាស្តា ទ្រង់ស្តាប់នូវពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា "ម្នាល

ភិក្ខុទាំងឡាយ ភិក្ខុដូចជាមហាកស្សបៈបុត្ររបស់តថាគត រមែងជាទីស្រឡាញ់នៃទេវតា និងមនុស្សទាំងឡាយ ។ ទេវតា និងមនុស្សទាំងឡាយ រមែងបូជាភិក្ខុនោះដោយបច្ច័យ ៤ ដោយពិត" ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

៧. សីលទស្សនសម្បន្នំ ធម្មដ្ឋំ សច្ចវាទិនំ
អត្តនោ កម្មកុព្វានំ តញ្ជនោ កុរុតេ បិយំ ។

ជនតែងធ្វើបុគ្គល ដែលបរិបូណ៌ដោយសីល និងការឃើញត្រូវ
ឋិតនៅក្នុងធម៌ ពោលសច្ចធម៌ជាប្រក្រតី ធ្វើកម្មជារបស់ខ្លួននោះ
ឲ្យជាទីស្រឡាញ់ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **សីលទស្សនសម្បន្នំ** (បុគ្គលបរិបូរដោយ**សីល និងទស្សនៈ**) សេចក្តីថា អ្នកដល់ព្រមដោយចតុប្បារិសុទ្ធិសីល និងការឃើញត្រូវដែលសម្បយុត្តជាមួយមគ្គ និងផល ។ បទថា **ធម្មដ្ឋំ** (អ្នកតាំង**នៅក្នុងធម៌**) សេចក្តីថា អ្នកតាំងនៅក្នុងលោកុត្តរធម៌ ៩ ប្រការ អធិប្បាយថា អ្នកមានលោកុត្តរធម៌ ដែលធ្វើឲ្យជាក់ច្បាស់ហើយ ។ បទថា **សច្ចវាទិនំ** (**អ្នកមានប្រក្រតីពោលតែសច្ចវាចា**) សេចក្តីថា ឈ្មោះថា អ្នកមានប្រក្រតីពោលវាចាសច្ចៈដោយសច្ចញាណ ព្រោះសច្ចៈ ៤ លោកបានធ្វើឲ្យជាក់ច្បាស់ហើយដោយអាការ ១៦ ។ បទថា **អត្តនោ កម្មកុព្វានំ** (**អ្នកធ្វើការងាររបស់ខ្លួន**) សេចក្តីថា សិក្ខា ៣ ឈ្មោះថា ការងាររបស់ខ្លួន ជាអ្នកបំពេញសិក្ខា ៣

នោះ ។

បទថា **តំ ជនោ** (បុគ្គលធ្វើលោក) សេចក្តីថា លោកិយមហាជនរមែងធ្វើបុគ្គលនោះឲ្យជាទីស្រឡាញ់ គឺ ជាអ្នកប្រាថ្នានឹងឃើញ ប្រាថ្នានឹងថ្វាយបង្គំ ប្រាថ្នានឹងបូជាដោយបច្ច័យ ៤ ដោយពិត ។

ក្នុងកាលចប់ព្រះធម៌ទេសនា ក្មេងទាំងអស់នោះក៏បានសម្រេចសោតាបត្តិផល ដូច្នេះឯង ។

ចប់ រឿងក្មេង ៥០០ នាក់

# ៨. រឿងព្រះអនាគាមិត្ថេរ

*ព្រះសាស្តា កាលប្រថាប់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈដែលជាអនាគាមីមួយអង្គ ត្រាស់ព្រះធម្មទេសនានេះថា* ***ឆន្ទជាតោ (អ្នកមានឆន្ទៈកើតឡើងហើយ)*** *ជាដើម ។*

ព្រះថេរៈសម្រេចព្រះអនាគាមិផល

*សេចក្តីពិស្តារថា ថ្ងៃមួយ ពួកសទ្ធិវិហារិកសួរព្រះថេរៈនោះថា "លោកអាចារ្យ ការត្រាស់ដឹងនូវគុណវិសេសរបស់លោក មានឬ?" ព្រះថេរៈអៀនខ្មាសថា "សូម្បីគ្រហស្ថទាំងឡាយ ក៏អាចបានសម្រេចអនាគាមិផលបាន ក្នុងវេលាសម្រេចព្រះអរហត្តនោះឯង សឹមយើងប្រាប់សទ្ធិវិហារិកទាំងនោះ" ដូច្នេះហើយ មិនពោលពាក្យអ្វីៗ ទាំងអស់ ធ្វើកាលកិរិយាហើយ កើតក្នុងទេវលោកជាន់សុទ្ធាវាស ។ គ្រានោះ ពួកសទ្ធិវិហារិករបស់លោកយំខ្សឹកខ្សួលទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយយំក្នុងទីម្ខាង ។ គ្រានោះ ព្រះសាស្តាត្រាស់សួរភិក្ខុទាំងនោះថា "ម្នាលភិក្ខុទាំងឡាយ មានហេតុអ្វីទើបអ្នកទាំងឡាយយំ?" ។*

*ភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ឧបជ្ឈាយ៍របស់ពួកខ្ញុំព្រះអង្គធ្វើកាលកិរិយា ។*

*ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ ហេតុហ្នឹងចូរលើកទុកសិនចុះ អ្នក*

ទាំងឡាយកុំគិតឡើយ មរណធម៌នោះ ជាធម៌ដ៏ទៀតទាត់ ។

ភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន រឿងនោះ ពួកខ្ញុំព្រះអង្គបានដឹងហើយ តែថា ពួកខ្ញុំព្រះអង្គបានសួរព្រះឧបជ្ឈាយ៍របស់ពួកខ្ញុំព្រះអង្គ ពីការត្រាស់ដឹងនូវគុណវិសេស លោកមិនទាន់បានប្រាប់ពួកខ្ញុំព្រះអង្គផង ក៏ធ្វើកាលកិរិយាទៅ ព្រោះហេតុនោះ ទើបពួកខ្ញុំព្រះអង្គដល់នូវសេចក្ដីទុក្ខ ។ ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំគិតឡើយ ឧបជ្ឈាយ៍របស់អ្នកទាំងឡាយ បានសម្រេចអនាគាមិផលហើយ តែលោកខ្មាសអៀនថា "សូម្បីតែពួកគ្រហស្ថ ក៏គេបានសម្រេចអនាគាមិផលដែរ ចាំយើងបានសម្រេចព្រះអរហត្តហើយ សឹមយើងប្រាប់សទ្ធិវិហារិកទាំងនោះ មិនទាន់បានប្រាប់អ្នកទាំងឡាយផង ក៏ធ្វើកាលកិរិយាហើយកើតក្នុងសុទ្ធាវាស ដូច្នេះ អ្នកទាំងឡាយ ចូរធូរចិត្តចុះ ឧបជ្ឈាយ៍របស់ពួកអ្នក ដល់នូវភាវៈជាអ្នកមានចិត្តមិនជាប់ជំពាក់ក្នុងកាមទាំងឡាយ ជាអ្នកមានក្រសែក្នុងខាងលើ" ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

៨. ឆន្ទជាតោ អនក្ខាតេ　　មនសា ច ផុដោ សិយា
កាមេ ច អប្បដិពទ្ធចិត្តោ　　ឧទ្ធំសោតោតិ វុច្ចតិ ។

បុគ្គល អ្នកមានសេចក្ដីប្រាថ្នាចំពោះព្រះនិព្វាន ដែលគេនិយាយប្រាប់គ្នាមិនបានផង ជាអ្នកមានមគ្គចិត្ត និងផលចិត្ត (ខាងក្រោម) ប៉ះពាល់ហើយផង មានចិត្តមិនប្រតិព័ទ្ធក្នុងកាមផង តថាគតហៅ

ថា ជាអ្នកមានខ្សែមគ្គប្រព្រឹត្តទៅ ក្នុងខាងលើ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ឆន្ទជាតោ (អ្នកមានឆន្ទៈកើតឡើងហើយ)** សេចក្ដីថា មានឆន្ទៈកើតឡើងហើយ ដោយអំណាចសេចក្ដីពេញចិត្តក្នុងភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើ គឺ ដល់នូវការឧស្សាហៈហើយ ។ បទថា **អនក្ខាតេ (ក្នុងនិព្វានដែលនរណាៗ ប្រាប់មិនបាន)** គឺ ក្នុងព្រះនិព្វាន ។ ពិតណាស់ព្រះនិព្វាននោះ ឈ្មោះថា **អនក្ខាតៈ** ព្រោះជាធម្មជាតិដែលបុគ្គលប្រាប់គ្នាមិនបានថា "ដែលបច្ច័យឯណោះធ្វើហើយ ឬបណ្ដាពណ៌ផ្សេងៗ មានពណ៌ខៀវជាដើម" ។ បទថា **មនសា ច ផុដោ សិយា (គប្បីជាអ្នកមានចិត្តពាល់ត្រូវហើយក្ដី)** សេចក្ដីថា គប្បីជាអ្នកពាល់ត្រូវនូវចិត្ត ដែលសម្បយុត្តជាមួយនឹងមគ្គ ៣ ចំណែកខាងក្រោម គឺ ឲ្យពេញហើយ ។ បទថា **អប្បដិពទ្ធចិត្តោ (មានចិត្តមិនជាប់ជំពាក់)** សេចក្ដីថា មានចិត្តមិនជាប់ជំពាក់ក្នុងកាមទាំងឡាយដោយអំណាចនៃព្រះអនាគាមិមគ្គក្ដី ។ បទថា **ឧទ្ធំសោតោ (អ្នកមានក្រសែក្នុងខាងលើ)** សេចក្ដីថា ភិក្ខុបែបនោះ កើតហើយក្នុងភពអវិហា បន្ទាប់អំពីនោះទៅ ក៏ទៅកាន់អកនិដ្ឋភព ដោយអំណាចបដិសន្ធិ លោកហៅថា អ្នកមានក្រសែក្នុងខាងលើ ព្រះឧបជ្ឈាយ៍របស់អ្នកទាំងឡាយ ក៏ជាអ្នកដូច្នោះឯង ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ភិក្ខុទាំងនោះ បានសម្រេចអរហត្តផល ។

ទេសនាបានមានប្រយោជន៍ សូម្បីដល់មហាជន ដូច្នេះ ។

ចប់ រឿងព្រះអនាគាមិត្ថេរ:

# ៩. រឿងនាយនន្ទិយៈ

*ព្រះសាស្តា កាលប្រថាប់គង់ក្នុងព្រៃឥសិបតនៈ ទ្រង់ប្រារព្ធនន្ទិយ-កុលបុត្រ ត្រាស់ព្រះធម្មទេសនានេះថា **ចិរប្បវាសឹ (ដែលឃ្លាតឆ្ងាយយូរ)** ជាដើម ។*

នន្ទិយៈជាអនុជាតបុត្រ

*បានឮថា នៅក្នុងក្រុងពារាណសី មានបុត្រនៃត្រកូលដែលដល់ព្រមដោយសទ្ធាម្នាក់ ឈ្មោះនន្ទិយៈ ។ គេជាអ្នកសម្បូរដោយសទ្ធាទំនុកបម្រុងសង្ឃ ជាអ្នកប្រព្រឹត្តតាមនោះឯង ។ ក្នុងកាលចម្រើនវ័យហើយ មាតាបិតាមានបំណងនឹងនាំធីតារបស់អ៊ំ ឈ្មោះនាងរេវតី មកអំពីផ្ទះដែលនៅទល់មុខគ្នា ។ តែនាងរេវតីនោះ ជាស្ត្រីមិនមានសទ្ធា មិនមានការឲ្យទាន ទើបនន្ទិយៈមិនប្រាថ្នានាង ។ លំដាប់នោះ មាតាបិតារបស់នន្ទិយៈពោលទៅកាន់នាងរេវតីថា "នាង គប្បីចូលទៅជូតសម្អាតទីអង្គុយរបស់ភិក្ខុសង្ឃ ហើយចូរក្រាលអាសនៈទាំងឡាយក្នុងផ្ទះនេះ ចូរតាំងជើងបាត្រទុក ។ ក្នុងកាលដែលភិក្ខុទាំងឡាយនិមន្តមក នាងចូរទទួលបាត្រ ហើយនិមន្តឲ្យគង់លើអាសនៈ យកធម្មក្រកត្រងទឹកឆាន់ប្រគេនភិក្ខុទាំងនោះ ចូរលាងបាត្រ ក្នុងកាលភិក្ខុទាំងនោះឆាន់ហើយ កាលនាងធ្វើបានយ៉ាងនេះ នាងក៏ជាស្ត្រីគាប់ចិត្តរបស់បុត្រយើង" ។ នាងក៏បានធ្វើហើយដោយប្រការដូច្នោះ ។ ក្រោយមក មាតាបិតារំឭកដល់ការប្រព្រឹត្ត*

របស់នាងរេវតីប្រាប់បុត្រថា "នាងរេវតីនេះ ជាស្ត្រីគួរដល់ឪវាទ បេះអត់ធន់ចំពោះឪវាទ" កាលនន្ទិយៈយល់ព្រមហើយ ក៏កំណត់ថ្ងៃធ្វើអាវាហមង្គល ។

លំដាប់នោះ នាយនន្ទិយៈពោលទៅកាន់នាងថា "បើនាងបម្រើភិក្ខុសង្ឃ និងមាតាបិតារបស់ខ្ញុំ ដូច្នេះ នាងក៏នឹងបានវត្តក្នុងផ្ទះនេះ នាងចូរជាស្ត្រីមិនប្រមាទចុះ" ។ នាងរេវតីក៏យល់ព្រម ហើយធ្វើនាទីជាអ្នកមានសទ្ធា បម្រើហើយបានពីរបីថ្ងៃ រហូតប្រសូតបុត្រពីរនាក់ ។ ក្រោយមក មាតាបិតារបស់នាយនន្ទិយៈ ក៏បានធ្វើកាលកិរិយា ។ ភាពជាធំលើវត្ថុទាំងពួងក្នុងផ្ទះនោះ បានធ្លាក់មកលើនាងរេវតីនោះតែម្នាក់ឯង ។

តាំងពីមាតាបិតាធ្វើកាលកិរិយាទៅ នន្ទិយៈក៏ជាមហាទានបតី ត្រៀមតាំងពីទានសម្រាប់ភិក្ខុសង្ឃ ហើយផ្តើមតាំងនូវតម្លៃអាហារសម្រាប់មនុស្សកំព្រា និងអ្នកដើរផ្លូវឆ្ងាយជាដើមទុកត្រង់ទ្វារផ្ទះ ។ ក្នុងកាលតមក នន្ទិយៈនោះ បានស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា កំណត់អានិសង្សនៃការថ្វាយអាវាសហើយ ឲ្យគេធ្វើសាលាមានមុខបួន ប្រដាប់ដោយបន្ទប់ ៤ ក្នុងមហាវិហារ ក្នុងព្រៃឥសិបតនៈ ហើយឲ្យក្រាលគ្រែ និងតាំងជាដើម កាលនឹងបង្ហើនថ្វាយអាវាសនោះ បានថ្វាយទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយថ្វាយទឹកទក្ខិណោទកចំពោះព្រះតថាគត ។ ប្រាសាទទិព្វសម្រេចអំពីរតនៈប្រាំពីរប្រការ ដល់ព្រមដោយពួកនារីមានប្រមាណ ១២ យោជន៍ ក្នុងទិសទាំងពួង

កម្ពស់ប្រមាណ ១០០ យោជន៍ ផុសឡើងក្នុងទេវលោកជាន់តាវត្តិង្ស ដំណាល គ្នានឹងការច្រូចទឹកទក្ខិណោទកលើព្រះហស្តរបស់ព្រះតថាគតនោះឯង ។

ព្រះមហាមោគ្គល្លានទៅកាន់ទេវលោក

ក្រោយមកនៅថ្ងៃមួយ ព្រះមហាមោគ្គល្លានទៅកាន់ទីចារិកក្នុងទេវលោក ឈរនៅក្នុងទីមិនឆ្ងាយពីប្រាសាទនោះ សួរទេវបុត្រទាំងឡាយ ដែលមកកាន់សម្នាក់របស់ខ្លួនថា "ប្រាសាទទិព្វ ពេញទៅដោយពួកនាងអប្សរនោះ កើតឡើងហើយដើម្បីអ្នកណា?" ។

លំដាប់នោះ ពួកទេវបុត្រ កាលនឹងប្រាប់ម្ចាស់វិមានដល់ព្រះថេរៈនោះ ទើបពោលថា "លោកម្ចាស់ដ៏ចម្រើន វិមាននេះកើតឡើងដើម្បីបុត្តគហបតីឈ្មោះនន្ទិយៈ ដែលសាងវិហារថ្វាយព្រះសាស្តាក្នុងព្រៃឥសិបតនៈ" ។ ឯពួកស្ត្រីអប្សរ ឃើញព្រះថេរៈនោះហើយ ចុះចាកប្រាសាទ ពោលថា "លោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំកើតក្នុងវិមាននេះ ដោយសេចក្តីប្រាថ្នាថា នឹងជាស្ត្រីបម្រើនន្ទិយៈ ប៉ុន្តែថា កាលពួកខ្ញុំមិនបានឃើញនន្ទិយៈនោះ ពួកខ្ញុំអផ្សុកយ៉ាងក្រៃលែង ព្រោះថា ការលះបង់សម្បត្តិមនុស្សហើយកាន់យកសម្បត្តិដ៏ទិព្វ ដូចជាការទម្លាយឆ្នាំងដីចោល ហើយកាន់យកឆ្នាំងមាស ដូច្នោះ សូមលោកម្ចាស់គប្បីប្រាប់គេ ដើម្បីប្រយោជន៍ដល់ការមកកាន់ទីនេះ" ។

ទិព្វសម្បត្តិកើតឡើងរង់ចាំអ្នកធ្វើបុណ្យ

ព្រះថេរៈត្រឡប់មកអំពីទេវលោកវិញ ក៏ចូលទៅគាល់ព្រះសាស្តា ទូលសួរថា “បពិត្រព្រះអង្គ ទិព្វសម្បត្តិ រមែងកើតដល់បុគ្គលអ្នកមានកល្យាណ-កម្មបានធ្វើហើយ ដែលឋិតនៅក្នុងមនុស្សលោកនៅឡើយដែរឬហ្ន៎?” ។

ព្រះសាស្តា. ម្នាលមោគ្គល្លាន ទិព្វសម្បត្តិដែលកើតដល់នាយនន្ទិយៈក្នុងទេវលោកនោះ អ្នកបានឃើញខ្លួនឯងហើយមិនមែនឬ? ហេតុដូចម្តេច ទើបសួរតថាគតទៀត?

មោគ្គល្លាន. បពិត្រព្រះអង្គដ៏ចម្រើន ទិព្យសម្បត្តិកើតបានយ៉ាងនោះឬ ? ។

គ្រានោះ ព្រះសាស្តាត្រាស់ទៅកាន់ព្រះថេរៈនោះថា ម្នាលមោគ្គល្លាន អ្នកពោលអ្វីហ្នឹង? ឧបមាថា នរណាៗ ឈរនៅត្រង់ទ្វារផ្ទះ ឃើញបុត្រ ឬបងប្អូនប្រុស ដែលបែកគ្នាអស់កាលយូរ (ត្រឡប់) មកអំពីទីដែលនៅបែក មកកាន់ផ្ទះដោយរហ័ស ប្រាប់ថា មនុស្សឈ្មោះឯណោះមកហើយ បើដូច្នោះ ពួកញាតិរបស់បុគ្គលនោះក៏រីករាយក្រៃលែង ហើយចេញមកដោយរហ័ស រមែងត្រេកអរទើងបុគ្គលនោះថា “ពុកមកហើយ ពុកមកហើយ” យ៉ាងណា ពួកទេវតា (មួយអង្គៗ) កាន់យកបណ្ណាការដែលជាទិព្វ ១០ យ៉ាង មកទទួល ដោយគិតថា “យើងមុន យើងមុន” ហើយរមែងត្រេកអរយ៉ាងក្រៃលែងចំពោះស្ត្រី ឬបុរសអ្នកធ្វើនូវអំពើល្អទុកក្នុងលោកនេះ ដែលលះលោកនេះហើយ ទៅកាន់

លោកខាងមុខដូច្នោះដូចគ្នា ដូច្នេះហើយ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖

៩. ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ
ញាតី មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ ។
តថេវ កតបុញ្ញម្បិ អស្មា លោកា បរំ គតំ
បុញ្ញានិ បដិគណ្ហន្តិ បិយំ ញាតីវ អាគតំ ។

ពួកញាតិក្តី មិត្តក្តី សំឡាញ់ក្តី រមែងត្រេកអរនឹងបុរសដែល ឃ្លាតគ្នាអស់កាលយូរ មកអំពីចម្ងាយដោយសួស្តី មកដល់ ហើយ យ៉ាងណាមិញ បុណ្យទាំងឡាយ តែងទទួលបុគ្គល ដែលបានធ្វើបុណ្យ ច្យុតអំពីមនុស្សលោកនេះ ទៅកាន់លោក ខាងមុខ ដូចញាតិទាំងឡាយ ទទួលបុរសជាទីស្រឡាញ់ទើប មកដល់ ដូច្នោះឯង ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា ចិរប្បវាសឹ (អ្នកឃ្លាតទៅអស់កាលយូរ) គឺ ឃ្លាតទៅយូរហើយ ។ បទថា ទូរតោ សោត្ថិមាគតំ (មកហើយអំពីចម្ងាយដោយសួស្តី) សេចក្តីថា អ្នកបានលាភ គឺ បានសម្បត្តិ ដែលសម្រេចអំពីការធ្វើនូវពាណិជ្ជកម្ម ឬដោយការធ្វើនាទីជារាជបុរស មកហើយអំពីទីឆ្ងាយ មិនមានឧបទ្រវៈ ។ បទថា ញាតី មិត្តា សុហជ្ជា ច (ញាតិ មិត្រ និងសំឡាញ់

**ទាំងឡាយ)** សេចក្ដីថា ពួកជនដែលឈ្មោះថា ញាតិ ដោយអំណាចការជាប់ទាក់ទងគ្នាដោយត្រកូល ។ ឈ្មោះថា មិត្ត ព្រោះជាអ្នកធ្លាប់ឃើញគ្នាជាដើម ដែលឈ្មោះថា សំឡាញ់ ព្រោះជាអ្នកមានសន្ដានចិត្តល្អ ។ បទថា **អភិនន្ទន្តិ អាគតំ (រមែងត្រេកអរក្រៃលែងថា មកហើយ)** សេចក្ដីថា ញាតិជាដើម ឃើញគេហើយ រមែងត្រេកអរយ៉ាងក្រៃលែង ដោយអាការត្រឹមតែពាក្យថា "មកល្អហើយ" ឬដោយអាការត្រឹមតែធ្វើនូវអញ្ជលី ម្យ៉ាងទៀត រមែងត្រេកអរនឹងគេដែលជាអ្នកមកដល់ផ្ទះហើយ ដោយអំណាចនាំទៅចំពោះនូវបណ្ណាការ មានប្រការផ្សេងៗ ។

បទថា **តថេវ** ជាដើម សេចក្ដីថា បុណ្យទាំងឡាយតាំងនៅក្នុងឋានៈដូចជាមាតាបិតា នាំបណ្ណាការ ១០ យ៉ាង គឺ "អាយុ វណ្ណៈ សុខ យស ភាពជាអធិបតីដែលជាទិព្វ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈដែលជាទិព្វ" ត្រេកអរយ៉ាងក្រៃលែង ឈ្មោះថា រមែងទទួលបុគ្គលដែលបានធ្វើបុណ្យទុកហើយ ដែលច្យុតចាកលោកនេះ ទៅកាន់លោកខាងមុខ ដោយហេតុដូច្នោះឯង ។

បទថា **បិយំ ញាតីវ (ដូចពួកញាតិ ឃើញញាតិដែលជាទីស្រឡាញ់)** សេចក្ដីថា ដូចពួកញាតិដ៏សេស ឃើញញាតិដែលជាទីស្រឡាញ់មកហើយ ក៏ទទួល នៅក្នុងលោកនេះដូច្នោះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំង

ឡាយ មានសោតាបត្តិជាដើម ដូច្នេះឯង ។

ចប់ រឿងនាយនន្ទិយ:

## ចប់បិយវគ្គវណ្ណនា វគ្គទី ១៦

ក្នុងវគ្គនេះរួមមាន ០៩ រឿង


១. រឿងបុព្វជិត ៣ រូប
២. រឿងកុដុម្ពិកម្នាក់
៣. រឿងឧបាសិកាវិសាខា
៤. រឿងស្តេចលិច្ឆវី
៥. រឿងអនត្ថិគន្ធកុមារ
៦. រឿងព្រាហ្មណ៍ម្នាក់
៧. រឿងក្មេង ៥០០ នាក់
៨. រឿងព្រះអនាគាមិត្ថេរ:
៩. រឿងនាយនន្ទិយ:

# កោធវគ្គ ទី ១៧

"ពោលអំពីសេចក្ដីក្រោធ"

## ១. រឿងខត្តិយកញ្ញាឈ្មោះរោហិណី

**[២៧]** *ព្រះសាស្ដា កាលប្រថាប់គង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធខត្តិយកញ្ញា ឈ្មោះរោហិណី ត្រាស់ព្រះធម្មទេសនានេះថា* ***កោធំ ជហេ*** *(គប្បីលះសេចក្ដីក្រោធ) ជាដើម ។*

សាងសាលាធាន់ជារោគសើស្បែក

*បានឮថា សម័យមួយ ព្រះអនុរុទ្ធដ៏មានអាយុបាននិមន្តទៅកាន់ក្រុងកបិលពស្តុព្រមដោយភិក្ខុ ៥០០ ។ គ្រានោះ ពួកព្រះញាតិទាំងឡាយរបស់លោក ទ្រង់បានស្ដាប់ថាព្រះថេរៈនិមន្តមក ក៏បាននាំគ្នាទៅកាន់សម្នាក់ព្រះថេរៈលើកលែងតែប្អូនស្រីរបស់ព្រះថេរៈ ឈ្មោះរោហិណី ។ ព្រះថេរៈសួរពួកព្រះញាតិថា "ព្រះនាងរោហិណីនៅទីណា?" ។*

*ពួកព្រះញាតិ. នៅក្នុងសម្នាក់ លោកម្ចាស់ ។*

*ព្រះថេរៈ. ហេតុអ្វី ទើបមិនយាងមក ?*

*ពួកព្រះញាតិ. ព្រះនាងមិនយាងមក ព្រោះអៀនខ្មាសចំពោះ "រោគសើ*

ស្បែក កើតឡើងក្នុងសរីរៈរបស់ព្រះនាង” ។

ព្រះថេរៈពោលថា “អ្នកទាំងឡាយ ចូរទៅយាងព្រះនាងមកចុះ” ឲ្យគេទៅយាងព្រះនាងរោហិណី មកហើយ ពោលយ៉ាងនេះទៅកាន់ព្រះនាងដែលជាអ្នកទទូសំពត់ (ស្បៃ) យាងមកហើយថា “រោហិណី ហេតុអ្វីទើបព្រះនាងមិនយាងមក?” ។

ព្រះនាងរោហិណី. លោកម្ចាស់ដ៏ចម្រើន រោគសើស្បែកកើតឡើងក្នុងសរីរៈរបស់ខ្ញុំ ហេតុនោះ ទើបខ្ញុំមិនបានមក ព្រោះខ្មាសគេ ។

ព្រះថេរៈ. ក៏ព្រះនាងធ្វើបុណ្យ មិនគួរឬ ?

ព្រះនាងរោហិណី. នឹងធ្វើដូចម្តេច លោកម្ចាស់ ។

ព្រះថេរៈ. ចូរឲ្យសាងសាលាឆាន់ចុះ ។

ព្រះនាងរោហិណី. ខ្ញុំព្រះករុណាយកអ្វីធ្វើ ?

ព្រះថេរៈ. គ្រឿងប្រដាប់របស់ព្រះនាងមិនមានទេឬ ?

ព្រះនាងរោ. មាន លោកម្ចាស់ ។

ព្រះថេរៈ. មានតម្លៃប៉ុន្មាន ?

ព្រះនាងរោហិណី. មានតម្លៃមួយម៉ឺន ។

ព្រះថេរៈ. បើដូច្នោះ ចូរព្រះនាងលក់គ្រឿងប្រដាប់នោះ ឲ្យគេសាងសាលាឆាន់ចុះ ។

ព្រះនាងរោហិណី. នរណានឹង នឹងធ្វើដើម្បីខ្ញុំ លោកម្ចាស់ ?

ព្រះថេរៈសម្លឹងមើលព្រះញាតិ ដែលឈរនៅក្នុងទីជិតហើយ ពោលថា "សូមចូរជាភារៈរបស់អ្នកទាំងឡាយ" ។

ពួកព្រះញាតិ. តើលោកម្ចាស់នឹងធ្វើអ្វី ?

ព្រះថេរៈ. សូម្បីអាត្មាភាពក៏នៅទីនេះដែរ បើដូច្នោះ អ្នកទាំងឡាយចូរនាំទព្វសម្ភារៈមក ដើម្បីសាលាឆាន់នេះ ។

ពួកព្រះញាតិនោះ ត្រាស់ថា "ប្រពៃហើយ លោកម្ចាស់" លុះពោលដូច្នោះហើយ ក៏នាំទព្វសម្ភារៈមក ។

ព្រះថេរៈ កាលនឹងចាត់ចែងសាលាឆាន់នោះ បានពោលទៅកាន់ព្រះនាងរោហិណីថា "នាងចូរឲ្យគេធ្វើសាលាឆាន់ពីរជាន់ កាលណាជាន់ខាងលើស្រេចហើយ ចូរទ្រង់ធ្វើកិច្ចបោសសំអាតផ្ទៃខាងក្រោមជាដើមរឿយៗ ចុះ" ។ ពួកភិក្ខុក៏គង់រឿយៗ ។ លំដាប់នោះ កាលព្រះនាងបោសសម្អាតសាលាឆាន់ហើយនោះឯង រោគសើស្បែកក៏ជាសះស្បើយទៅ ។ កាលសាលាឆាន់ស្រេចហើយ ព្រះនាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បានថ្វាយខាទនីយៈនិងភោជនីយៈដ៏ប្រណីតចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដែលគង់ពេញសាលាឆាន់នោះ ។

ព្រះសាស្តា ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ត្រាស់សួរថា "នេះជាទានរបស់នរណា?" ។

ព្រះអនុរុទ្ធ. របស់ព្រះនាងរោហិណី ដែលជាប្អូនស្រីរបស់ខ្ញុំព្រះអង្គ

ព្រះអង្គ ។

ព្រះសាស្តា. នាងទៅណា ?

ព្រះអនុរុទ្ធ. នាងនៅក្នុងដំណាក់ ព្រះអង្គ ។

ព្រះសាស្តា. អ្នកទាំងឡាយ ចូរទៅហៅនាងមក ។

ព្រះនាងមិនប្រាថ្នានឹងយាងមក ។ គ្រានោះ ព្រះសាស្តាត្រាស់ឲ្យហៅព្រះនាងដែលមិនប្រាថ្នានឹងយាងមក ឲ្យយាងមក ព្រះសាស្តាត្រាស់ទៅកាន់ព្រះនាង ដែលយាងមកថ្វាយបង្គំហើយ ទ្រង់សួរថា "រោហិណី ហេតុអ្វីទើបនាងមិនមក?" ។

ព្រះនាងរោហិណី. "រោគសើស្បែកកើតឡើងក្នុងសរីរៈរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គខ្មាសព្រោះរោគនោះ ទើបនាងខ្ញុំម្ចាស់មិនមក ព្រះអង្គ" ។

ព្រះសាស្តា. នាងដឹងទេថា រោគនោះអាស្រ័យកម្មអ្វីរបស់នាង ទើបកើតឡើង ?

ព្រះនាងរោហិណី. ខ្ញុំព្រះអង្គមិនជ្រាបទេ ព្រះអង្គ ។

ព្រះសាស្តា. រោគនោះអាស្រ័យសេចក្តីក្រោធរបស់នាង ទើបបានកើតឡើង ។

ព្រះនាងរោហិណី. តើនាងខ្ញុំម្ចាស់ ធ្វើកម្មអ្វីទុក ព្រះអង្គ ?

## បុព្វកម្មរបស់ព្រះនាងរោហិណី

គ្រានោះ ព្រះសាស្តាទ្រង់នាំអតីតនិទានមក (ត្រាស់ដល់ព្រះនាង) ថា ៖

ក្នុងអតីតកាល ព្រះអគ្គមហេសីនៃព្រះរាជាក្រុងពារាណសី បានចងគំនុំនឹងស្ត្រីរបាំរបស់ព្រះរាជាម្នាក់ ទ្រង់ព្រះតម្រិះថា "យើងនឹងញ៉ាំងទុក្ខឲ្យកើតឡើងដល់ស្ត្រីនោះ" លុះគិតដូច្នោះ ហើយក៏បញ្ជាឲ្យគេនាំផ្លែខ្ទេមក រួចបញ្ជាឲ្យហៅស្ត្រីរបាំនោះមកកាន់សម្នាក់របស់ខ្លួន ហើយប្រើគេឲ្យដាក់លំអងខ្ទេទាំងឡាយលើទីដេក លើសំពត់ដណ្តប់ និងក្នុងចន្លោះនៃវត្ថុសម្រាប់ប្រើប្រាស់ទាំងឡាយ មានកម្រាលជាដើមរបស់ស្ត្រីរបាំនោះ ដោយប្រការដែលនាងមិនដឹងខ្លួន ដើរទៅជិតនាង ធ្វើដូចជាប្រលែងលេងជាមួយនឹងនាង ហើយរោយលំអងខ្ទេលើខ្លួនរបស់នាង ភ្លាមៗ នោះឯង សរីរៈរបស់ស្ត្រីរបាំនោះ មានពកតូចនិងពកធំកើតឡើង ។ នាងរមាស់ ក៏ទៅដេកលើទីដេក ។ កាលនាងត្រូវលំអងខ្ទេបៀតបៀនត្រង់ទីដេកនោះ វេទនាដ៏ខ្លាំងក្លាក្រៃលែងបានកើតឡើង ។ ព្រះអគ្គមហេសីក្នុងកាលនោះ បានមកជាព្រះនាងរោហិណី ។

ព្រះសាស្តា លុះទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា "រោហិណីក៏កម្មនោះ នាងបានធ្វើហើយក្នុងកាលនោះ សេចក្តីក្រោធក្តី សេចក្តីប្រណែនក្តី សូម្បីមានប្រមាណតិច មិនគប្បីធ្វើឡើយ" ដូច្នេះហើយ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖

១. កោធំ ជហេ វិប្បជហេយ្យ មានំ

សញ្ញោជនំ សព្វមតិក្កមេយ្យ

តន្នាមរូបស្មឹ អសជ្ជមានំ

*អកិញ្ចនំ នានុបតន្តិ ទុក្ខា ។*

*បុគ្គលគួរលះបង់សេចក្ដីក្រោធចេញ គួរលះបង់មានះចេញ*

*គួរកន្លងសញ្ញោជនធម៌ទាំងអស់ចោលចេញ ទុក្ខទាំងឡាយ*

*តែងមិនជាប់តាមបុគ្គល ដែលមិនជំពាក់ក្នុងនាម និងរូប មិន*

*មានកិលេស គ្រឿងកង្វល់នោះឡើយ ។*

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **កោធំ** (សេចក្ដីក្រោធ) សេចក្ដីថា គប្បីលះបង់នូវសេចក្ដីក្រោធ ដែលមានអាការទាំងពួងផង មានះ ៩ យ៉ាងផង ។ បទថា **សំយោជនំ** (សំយោជនៈ) សេចក្ដីថា គប្បីកន្លងនូវសំយោជនៈទាំង ១០ យ៉ាង មានកាមរាគសំយោជនៈជាដើម ។ បទថា **មសជ្ជមានំ** (ជាអ្នកមិនជាប់) សេចក្ដីថា មិនជាប់ អធិប្បាយថា បុគ្គលប្រកាន់មាំនូវនាម និងរូប ដោយន័យថា "រូបរបស់យើង វេទនារបស់យើងជាដើម កាលនាម និងរូបនោះវិនាសទៅ រមែងសោកសៅក្ដៅក្រហាយ បុគ្គលនេះ ឈ្មោះថា ជាប់ជំពាក់នៅក្នុងនាមរូប ចំណែកបុគ្គលណាមិនប្រកាន់យ៉ាងនោះ ឈ្មោះថា រមែងមិនជាប់ជំពាក់ ទុក្ខទាំងឡាយ រមែងមិនជាប់តាមបុគ្គលនោះ ដែលមិនជាប់ជំពាក់យ៉ាងនោះ បុគ្គលដែលឈ្មោះថា មិនមានកិលេសគ្រឿងកង្វល់ ព្រោះមិនមានរាគៈជាដើម ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំង

ឡាយ មានសោតាបត្តិផលជាដើម ។

សូម្បីព្រះនាងរោហិណី ក៏បានសម្រេចសោតាបត្តិផលដែរ ។ សរីរៈរបស់នាងមានសម្បុរដូចមាសក្នុងខណៈនោះឯង ។ ព្រះនាងចុតិចាកអត្តភាពនោះហើយ បដិសន្ធិក្នុងវវាងព្រំដែនរបស់ទេវបុត្រ ៤ អង្គ ក្នុងភពតាវត្តិង្ស ជាទេពធីតានាំមកនូវសេចក្ដីជ្រះថ្លា ដល់នូវភាពជាអ្នកល្អលើស ដោយលម្អនៃរូប ។ ទេវបុត្រទាំង ៤ អង្គនោះ ឃើញទេវធីតានោះភ្លាម ក៏កើតសេចក្ដីស្នេហាឡើង វិវាទគ្នាថា "នាងកើតក្នុងដែនរបស់យើង នាងកើតក្នុងដែនរបស់យើង" ទៅកាន់សម្នាក់សក្កទេវរាជ ក្រាបទូលថា "បពិត្រទេវរាជ ខ្ញុំព្រះអង្គទាំងបួនកើតក្ដីឡើង ព្រោះអាស្រ័យទេវធីតានេះ សូមព្រះអង្គទ្រង់វិនិច្ឆ័យក្ដីនោះ" ។ សូម្បីសក្កទេវរាជ គ្រាន់តែក្រឡេកឃើញនាងទេពធីតានោះភ្លាម ក៏កើតសេចក្ដីស្នេហាឡើង ត្រាស់សួរទេវបុត្រទាំងបួននោះយ៉ាងនេះថា "ចាប់តាំងពីកាលដែលពួកអ្នកបានឃើញទេពធីតានេះមក ចិត្តរបស់អ្នកទាំងឡាយកើតឡើងយ៉ាងណា?" ។

គ្រានោះ ទេវបុត្រមួយអង្គក្រាបទូលថា "ចិត្តរបស់ខ្ញុំព្រះអង្គកើតឡើងដូចជាសំឡេងស្គរមុនពេលសង្គ្រាម មិនអាចស្ងប់ឡើយ" ។

អង្គទី ២. ចិត្តរបស់ខ្ញុំព្រះអង្គកើតឡើង ដូចជាទឹកធ្លាក់ពីលើភ្នំ រមែងប្រព្រឹត្តទៅយ៉ាងរហ័ស ។

អង្គទី ៣. ចាប់តាំងពីខ្ញុំព្រះអង្គឃើញទេពធីតានេះកាលណា ភ្នែកទាំង

ពីរបស់ខ្ញុំព្រះអង្គលៀនចេញ ដូចជាក្អែកក្តាម ។

អង្គទី ៤. ចិត្តរបស់ខ្ញុំព្រះអង្គ ដូចជាទង់ដែលគេតម្កើងនៅលើចេតិយ ។

គ្រានោះ សក្កទេវរាជត្រាស់ទៅកាន់ទេវបុត្រទាំងបួននោះថា "នែអ្នកទាំងឡាយ ចិត្តរបស់អ្នកទាំងឡាយនៅអាចអត់សង្កត់បាន ចំណែកយើងកាលបានឃើញទេពធីតានេះ ទើបអាចរស់នៅបាន យើងនឹងស្លាប់ ប្រសិនបើមិនបានឃើញទេពធីតានេះ" ។ ពួកទេវបុត្រទាំងបួននោះ ក្រាបទូលថា "បពិត្រមហារាជ ពួកខ្ញុំព្រះអង្គមិនត្រូវការមរណៈរបស់ព្រះអង្គទេ" លុះក្រាបទូលសក្កទេវរាជដូច្នោះហើយ ក៏លះបង់ទេវធីតានោះថ្វាយសក្កទេវរាជ ហើយចៀសចេញទៅ ។ ទេវធីតានោះ បានជាទីស្រឡាញ់របស់សក្កទេវរាជខ្លាំងណាស់ ។ កាលនាងក្រាបទូលថា "មហារាជ នាងខ្ញុំនឹងទៅកាន់ទីលេងឈ្មោះឯណោះ" សក្កទេវរាជក៏មិនអាចហាមឃាត់បានឡើយ ដូច្នេះឯង ។

ចប់ រឿងខត្តិយកញ្ញាឈ្មោះរោហិណី

# ២. រឿងភិក្ខុមួយរូប

ព្រះសាស្តា កាលប្រថាប់នៅក្បែរអគ្គាឡវចេតិយ ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **យោ វេ ឧប្បតិតំ កោធំ (បុគ្គលណាគប្បីឃាត់សេចក្តីក្រោធដែលកើតឡើង)** ជាដើម ។

ភិក្ខុកាប់ដើមឈើដែលទេវតានៅ

សេចក្តីពិស្តារថា កាលព្រះសាស្តាទ្រង់អនុញ្ញាតសេនាសនៈដល់ភិក្ខុសង្ឃហើយ (ទិង) កាលសេនាសនៈទាំងឡាយ ដែលសប្បុរសជនទាំងឡាយមានសេដ្ឋីក្នុងនគររាជគ្រឹះជាដើមកំពុងឲ្យគេកសាង ភិក្ខុអ្នកនៅក្នុងដែនអាឡវីមួយរូប ក៏សង់សេនាសនៈរបស់ខ្លួន ឃើញឈើមួយដើមដែលជាទីពេញចិត្តហើយ ផ្តើមនឹងកាប់ ។ ក៏ទេវតាមានកូនតូចមួយអង្គ ដែលនៅនឹងដើមឈើនោះបីកូនដោយចង្កេះ ឈរអង្វរភិក្ខុនោះថា "លោកម្ចាស់ សូមលោកម្ចាស់កុំធ្វើវិមានរបស់ខ្ញុំឲ្យវិនាសឡើយ ខ្ញុំមិនមានទីនៅទេ មិនអាចបីកូនត្រាច់ទៅនេះទៅនោះបានឡើយ" ។

ភិក្ខុនោះគិតថា "យើងនឹងមិនបានដើមឈើដូច្នេះ ក្នុងទីដទៃទេ" ទើបមិនអើពើនឹងពាក្យរបស់ទេវតានោះ ។

ទេវតានោះគិតថា "ភិក្ខុនេះឃើញទារកនេះហើយ នឹងឈប់ដោយពិត" ទើបដាក់កូនលើមែកឈើ ។ ចំណែកភិក្ខុនោះ មិនអាចទប់ពូថៅដែលខ្លួនលើក

ឡើងហើយបាន ទើបកាប់ ត្រូវដៃទារកនោះដាច់ ទេវតាកើតសេចក្ដីក្រោធយ៉ាងខ្លាំង លើកដៃទាំងពីរឡើងដោយធ្វើទុកក្នុងចិត្តថា "នឹងប្រហារភិក្ខុនេះឲ្យស្លាប់" ប៉ុន្តែភ្លាមៗ នោះ ទេវតានោះគិតឃើញយ៉ាងនេះថា "ភិក្ខុនេះជាអ្នកមានសីល ប្រសិនបើអញសម្លាប់ភិក្ខុនេះឲ្យស្លាប់ អញនឹងទៅកាន់នរក សូម្បីទេវតាដទៃកាលជួបភិក្ខុកាត់ដើមឈើរបស់ខ្លួន នឹងធ្វើអញឲ្យជាប្រមាណថា ទេវតាឯណោះសម្លាប់ភិក្ខុ គេនឹងសម្លាប់ភិក្ខុទាំងឡាយដូចយើងដែរ ភិក្ខុនេះជាអ្នកមានម្ចាស់ យើងទៅប្រាប់ដល់ម្ចាស់របស់ភិក្ខុនេះ" ។ ដាក់ដៃដែលលើកឡើងហើយ យំដើរទៅកាន់សម្នាក់ព្រះសាស្ដា ថ្វាយបង្គំហើយ ឈរនៅក្នុងទីដ៏សមគួរមួយ ។ គ្រានោះ ព្រះសាស្ដាត្រាស់ទៅកាន់ទេវតានោះថា "ទេវតា អ្នកមានរឿងអ្វី?" ទេវតានោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សាវករបស់ព្រះអង្គ ធ្វើកម្មបែបនេះ ចំណែកខ្ញុំព្រះអង្គ ក៏ប្រាថ្នានឹងញុំាងសាវករបស់ព្រះអង្គឲ្យស្លាប់ តែគិតនូវហេតុនេះបាន ទើបមិនសម្លាប់ ហើយប្រញាប់មកកាន់សម្នាក់ព្រះអង្គ" ដូច្នេះហើយ ក៏ក្រាបទូលរឿងនោះទាំងអស់ដោយពិស្ដារ ។ ព្រះសាស្ដាទ្រង់ស្ដាប់នូវរឿងនោះហើយ ត្រាស់ថា "ម្នាលទេវតា ត្រូវហើយៗ ទេវតាឯងគ្រប់សង្កត់សេចក្ដីក្រោធ ដែលកើតឡើងហើយយ៉ាងនោះទុក ដូចជាឃាត់រថដែលលឿនជ្រុលបាន ឈ្មោះថា បានធ្វើកម្មដ៏ប្រពៃហើយ" ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

២. យោ វេ ឧប្បតិតំ កោធំ  រថំ ភន្តំវ ធារយេ

*តមហំ សារថឹ ព្រូមិ   រស្មិគ្គាហោ ឥតរោ ជនោ ។*

*បុគ្គលណាឃាត់សេចក្តីក្រោធ ដែលកើតឡើងហើយ ដូច សារថីទប់រថ ដែលកំពុងលឿនបាន តថាគតហៅបុគ្គលនោះ ថាជាសារថី ជនក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរ (មិន មែនសារថីឡើយ) ។*

អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា **ឧប្បតិតំ** (ដែលផុលឡើង) បានដល់ ដែល កើតឡើងហើយ ។ បទថា **រថំ ភន្តំវ** (រថដែលកំពុងលឿនទៅ) សេចក្តីថា ដូចសារថីដែលឆ្លាត ទប់រថដែលកំពុងលឿនបានតាមត្រូវការ យ៉ាងណាមិញ បុគ្គលណាគ្រប់សង្កត់ គឺ អាចឃាត់សេចក្តីក្រោធដែលកើតឡើងបាន ក៏ដូច្នោះ ដូចគ្នា ។ បទថា **តមហំ** (តថាគត... បុគ្គលនោះ) តថាគតហៅបុគ្គលនោះថា សារថី ។ បទថា **ឥតរោ ជនោ** (ចំណែកជនក្រៅពីនេះ) សេចក្តីថា ចំណែក ជនក្រៅពីនេះ គឺ សារថីរថរបស់ឥស្សរជនទាំងឡាយ មានព្រះរាជា និងឧបរាជ ជាដើម គ្រាន់តែមានឈ្មោះថា ជាអ្នកកាន់ខ្សែបរប៉ុណ្ណោះ មិនមែនជាសារថី ដ៏ប្រសើរឡើយ ។*

*ក្នុងកាលចប់ព្រះធម៌ទេសនា ទេវតានោះ ក៏បានតាំងនៅក្នុងសោតា-បត្តិផល ព្រះធម៌ទេសនាមានប្រយោជន៍ សូម្បីដល់បរិស័ទដែលប្រជុំគ្នាហើយ នោះឯង ។*

ចំណែកទេវតានោះ សូម្បីបានជាព្រះសោតាបន្នហើយ ក៏នៅតែឈរយំ ។ គ្រានោះ ព្រះសាស្ដាត្រាស់សួរទេវតានោះថា "ម្នាលទេវតា អ្នកមានបញ្ហាអ្វី" កាលទេវតាក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន វិមានរបស់ខ្ញុំវិនាសហើយ ឥឡូវនេះ ខ្ញុំព្រះអង្គនឹងធ្វើដូចម្ដេច?" ទើបទ្រង់ត្រាស់ថា "ម្នាលទេវតា អ្នកកុំព្រួយ តថាគតនឹងឲ្យវិមានដល់អ្នក" ហើយទ្រង់បង្ហាញដើមឈើមួយដើមដែលទេវតាចុតិអំពីថ្ងៃមុន ក្នុងទីជិតព្រះគន្ធកុដិ ក្នុងវត្តជេតពន ហើយត្រាស់ថា "ម្នាលទេវតា ដើមឈើក្នុងឱកាសឯណោះទំនេរ អ្នកចូរចូលទៅនៅត្រង់ដើមឈើនោះចុះ" ។ ទេវតានោះ ក៏បានទៅនៅនឹងដើមឈើនោះ តាមព្រះតម្រាស់របស់ព្រះមានព្រះភាគ ។ ចាប់តាំងពីពេលនោះមក ទេវតាដែលមានសក្តិធំៗ ក៏បានជ្រាបថា "វិមានរបស់ទេវតានេះ ព្រះមានព្រះភាគទ្រង់ប្រទានឲ្យ" ក៏មិនអាចមកធ្វើទេវតានោះឲ្យកម្រើកបាន ។

ព្រះសាស្ដា ទ្រង់ធ្វើរឿងនោះឲ្យជាហេតុកើតឡើងហើយ ទ្រង់បញ្ញត្តភូតគាមសិក្ខាបទដល់ភិក្ខុទាំងឡាយ ។

ចប់ រឿងភិក្ខុមួយរូប

# ៣. រឿងឧត្តរាឧបាសិកា

ព្រះសាស្តា កាលប្រថាប់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ធ្វើភត្តកិច្ចក្នុងផ្ទះរបស់នាងឧត្តរាហើយ ទ្រង់ក៏ប្រារព្ធឧបាសិកាឧត្តរា ត្រាស់ធម៌ទេសនានេះថា **អក្កោធេន ជិនេ កោធំ (ឈ្នះសេចក្តីក្រោធដោយការមិនក្រោធ) ជាដើម ។**

នាយបុណ្ណៈក្រលំចាកត្រូវបម្រើសុមនសេដ្ឋី

អនុបុព្វីកថា ក្នុងរឿងឧត្តរាឧបាសិកានោះ មានដូចតទៅនេះ ៖

បានឮថា បុរសកម្សត់ឈ្មោះបុណ្ណៈ អាស្រ័យសុមនសេដ្ឋី ដែលមានប្រក្រតីនៅក្នុងក្រុងរាជគ្រឹះ ធ្វើការបម្រើដើម្បីចិញ្ចឹមជីវិត ។ ក្នុងផ្ទះរបស់គាត់ មានមនុស្សពីរនាក់ប៉ុណ្ណោះ គឺ ភរិយារបស់គាត់ និងធីតាឈ្មោះឧត្តរាម្នាក់ ។ តមកថ្ងៃមួយ ពួករាជបុរសដើរឃោសនាក្នុងក្រុងរាជគ្រឹះថា "អ្នកនគរទាំងអស់ចូរនាំគ្នាលេងនក្ខត្តឫក្ស ៧ ថ្ងៃចុះ" សុមនសេដ្ឋីបានឮការឃោសនានោះហើយ ក៏ហៅនាយបុណ្ណៈមកពីព្រលឹមប្រាប់ថា "នែបា ជនជាបរិវាររបស់ខ្ញុំ គេប្រាថ្នានឹងលេងនក្ខត្តឫក្ស ឯងនឹងលេងនក្ខត្តឫក្សជាមួយនឹងគេឬ ឬ ក៏នៅធ្វើការ?" ។

នាយបុណ្ណៈ. លោកម្ចាស់ ដែលឈ្មោះថា ការលេងនក្ខត្តឫក្សនោះ ជារបស់ពួកអ្នកដែលមានទ្រព្យទេ ក៏ក្នុងផ្ទះរបស់ខ្ញុំ សូម្បីតែអង្ករសម្រាប់បបរទទួលទានក្នុងថ្ងៃស្អែកនេះ មិនទាន់មានផង ។ ប្រយោជន៍អ្វីដោយនក្ខត្តឫក្សដល់ខ្ញុំនោះ? ខ្ញុំបានគោហើយ ក៏នឹងទៅភ្ជួរ ។ សុមនសេដ្ឋី បើដូច្នោះ ឯងចូរ

ទទួលយកគោចុះ ។ គេទទួលយកគោដែលមានកម្លាំង និងនង្គ័លហើយ ក៏និយាយទៅកាន់ភរិយាថា "នែនាង អ្នកនគរគេនាំគ្នាលេងនក្ខត្តឫក្ស ខ្ញុំត្រូវទៅធ្វើការ ព្រោះយើងក្រណាស់ ថ្ងៃនេះនាងគប្បីចំអិនបន្ថែមឲ្យជាទ្វេគុណ ហើយនាំយកទៅឲ្យខ្ញុំ" និយាយជាមួយភរិយាដូច្នេះហើយ ទើបទៅស្រែ ។

## ព្រះសារីបុត្តសង្គ្រោះនាយបុណ្ណៈ

ក្នុងកាលនោះ ព្រះសារីបុត្រចូលនិរោធសមាបត្តិអស់ ៧ ថ្ងៃ ហើយក្នុងថ្ងៃនោះ ចេញអំពីនិរោធសមាបត្តិ ពិចារណាមើលថា "ថ្ងៃនេះ យើងគួរសង្គ្រោះអ្នកណាហ្ន៎" ឃើញនាយបុណ្ណៈចូលទៅក្នុងសំណាញ់ គឺ ញាណរបស់លោកហើយ ក៏ពិចារណាថា "នាយបុណ្ណៈនេះ មានសទ្ធាឬទេ គេអាចសង្គ្រោះយើងឬទេ" ដឹងថា នាយបុណ្ណៈមានសទ្ធា អាចសង្គ្រោះបាន ហើយគេនឹងបានទទួលសម្បត្តិដ៏ធំ ព្រោះបុណ្យនោះជាបច្ច័យ ទើបកាន់បាត្រ និងចីវរទៅកាន់ទីភ្ជួរស្រែរបស់នាយបុណ្ណៈ ឈរសម្លឹងមើលឈើមួយគុម្ពជិតមាត់រណ្ដៅ ។ នាយបុណ្ណៈ ឃើញព្រះថេរៈហើយ បញ្ឈប់ការភ្ជួរ ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន ហើយគិតថា "ព្រះថេរៈគង់នឹងត្រូវការឈើស្ទន់" ទើបធ្វើឈើស្ទន់ឲ្យជាកប្បិយៈ ហើយប្រគេនព្រះថេរៈ ។ គ្រានោះ ព្រះថេរៈបាននាំយកបាត្រ និងសំពត់តម្រងទឹកចេញមកឲ្យនាយបុណ្ណៈ ។ នាយបុណ្ណៈគិតថា "ព្រះថេរៈត្រូវការទឹក" ទើបទទួលយកបាត្រ និងសំពត់តម្រងទឹកនោះមកត្រងទឹកឆាន់ប្រគេនព្រះថេរៈ ។

ព្រះថេរៈគិតថា "នាយបុណ្ណៈនេះ មានលំនៅនៅខាងក្រោយនៃលំនៅជនដទៃ ប្រសិនបើយើងទៅផ្ទះរបស់គេ ភរិយារបស់គេនឹងមិនបានឃើញយើង យើងត្រូវនៅទីនេះ ដរាបដល់ភរិយារបស់គេនាំភត្តមកឲ្យគេ" ព្រះថេរៈបានញ៉ាំងកាលឲ្យកន្លងទៅបន្តិចនៅទីនោះ បានដឹងថា ភរិយារបស់នាយបុណ្ណៈឡើងកាន់ផ្លូវហើយ ក៏និមន្តចូលទៅកាន់ព្រះនគរ ។

ភរិយារបស់នាយបុណ្ណៈថ្វាយភត្តដល់ព្រះថេរៈ

នាងជួបព្រះថេរៈក្នុងវាងផ្លូវហើយ គិតថា "ពេលខ្លះ ទេយ្យធម៌មាន យើងមិនបានជួបព្រះថេរៈ ពេលខ្លះ យើងបានជួបព្រះថេរៈ តែទេយ្យធម៌មិនមាន ក្នុងថ្ងៃនេះ យើងបានជួបព្រះថេរៈហើយ ទាំងទេយ្យធម៌ក៏មាន ព្រះថេរៈនឹងអនុគ្រោះយើងឬទេហ្ន៎?" នាងដាក់ភាជនៈភត្តចុះ ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន ហើយពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំគិតថា ភត្តនេះសៅហ្មង ឬប្រណីតឡើយ សូមធ្វើសេចក្ដីអនុគ្រោះទាសៈរបស់លោកម្ចាស់ចុះ" ។ ព្រះថេរៈបង្អោនបាត្រចូលទៅ នាងយកដៃម្ខាងទ្រភាជនៈ ប្រគេនភត្តព្រះថេរៈដោយដៃម្ខាងទៀត កាលនាងប្រគេនភត្តបានពាក់កណ្ដាល ព្រះថេរៈក៏យកដៃបិទបាត្រ ពោលថា "ល្មមហើយ" នាងពោលថា "លោកម្ចាស់ដ៏ចម្រើន ភត្តមានតែមួយចំណែក ខ្ញុំព្រះករុណាមិនអាចធ្វើឲ្យជាពីរចំណែកបានទេ សូមលោកម្ចាស់ កុំអនុគ្រោះទាសៈរបស់លោកម្ចាស់ក្នុងលោកនេះអី សូមធ្វើនូវសេចក្ដីអនុគ្រោះក្នុងបរលោកចុះ ខ្ញុំព្រះករុណាប្រាថ្នា

ប្រគេនមិនឲ្យសេសសល់" ដូច្នេះហើយ ក៏បានដាក់ភត្តទាំងអស់ទៅក្នុងបាត្រ របស់ព្រះថេរៈ ហើយធ្វើសេចក្ដីប្រាថ្នាថា "សូមឲ្យខ្ញុំព្រះករុណា គប្បីជាអ្នក មានចំណែកនៃធម៌ ដែលលោកម្ចាស់បានឃើញហើយផងចុះ" ។ ព្រះថេរៈពោល ថា "ចូរសម្រេចតាមសេចក្ដីប្រាថ្នាចុះ" ឈរនៅទីនោះឯង ធ្វើអនុមោទនាហើយ បានគង់ធ្វើភត្តកិច្ចនៅក្នុងទីសប្បាយមួយកន្លែង ។ ចំណែកនាងត្រឡប់ទៅរក អន្ករបំអិនភត្តជាថ្មី ។ ចំណែកនាយបុណ្ណៈ ភ្ជួរស្រែបានប្រមាណកន្លះករីសៈ មិនអាចអត់ទ្រាំនឹងសេចក្ដីស្រេកឃ្លានបាន ក៏ដោះគោ ចូលទៅកាន់ម្លប់ឈើ មួយដើម អង្គុយទន្ទឹងមើលផ្លូវភរិយា ។ គ្រានោះ ភរិយារបស់គាត់កាន់ភត្ត ដើរទៅ លុះឃើញ គាត់ក៏គិតថា "ស្វាមីរបស់យើងត្រូវសេចក្ដីស្រេកឃ្លាន បៀតបៀន អង្គុយទន្ទឹងមើលផ្លូវយើង ប្រសិនបើគាត់នឹងគំរាមយើងថា "នាង យូរម្ល៉េះ ហើយយកជន្ទួញប្រហារយើង កម្មដែលយើងធ្វើហើយនឹងជារបស់ ឥតប្រយោជន៍ ដូច្នេះ យើងនឹងប្រាប់ស្វាមីរបស់យើងឲ្យបានមុនតែម្ដង" ដូច្នេះ ហើយ ទើបពោលយ៉ាងនេះថា "នាយ ថ្ងៃនេះ អ្នកចូរធ្វើចិត្តឲ្យជ្រះថ្លាត្រឹមមួយ ថ្ងៃចុះ សូមអ្នកកុំញ៉ាំងកម្មដែលខ្ញុំធ្វើហើយឲ្យឥតប្រយោជន៍ឡើយ តាមពិត នោះ ខ្ញុំបាននាំភត្តមកជូនអ្នកតាំងអំពីព្រលឹមម្ល៉េះ ប៉ុន្តែមកតាមផ្លូវខ្ញុំបានជួប ព្រះធម្មសេនាបតីក្នុងរវាងផ្លូវ ខ្ញុំក៏យកភត្តរបស់អ្នកប្រគេនព្រះថេរៈនោះ ហើយ ត្រឡប់ទៅចំអិនភត្តជាថ្មី សូមអ្នកញ៉ាំងចិត្តឲ្យជ្រះថ្លាចុះ" នាយបុណ្ណៈសួរទៅ ភរិយាថា "នាងដ៏ចម្រើន នាងនិយាយអ្វី?" បានស្ដាប់រឿងនោះម្ដងទៀតហើយ

ក៏ពោលថា "នែនាងដ៏ចម្រើន នាងបានប្រគេនភត្តរបស់យើងដល់លោកម្ចាស់ នាងបានធ្វើកម្មដ៏ប្រពៃហើយ ពីព្រឹកមិញ ខ្ញុំក៏បានប្រគេនឈើជម្រះធ្មេញ និង ទឹកខ្ពុរមាត់ដល់លោកម្ចាស់ដែរ" គេមានចិត្តជ្រះថ្លា ត្រេកអររីករាយនឹងពាក្យ នោះហើយ ជាអ្នកមានកាយនឿយហត់ ព្រោះបានភត្តក្នុងវេលាថ្ងៃពេក យក ក្បាលកើយភ្លៅភរិយា ហើយក៏ដេកលក់ទៅ ។

## ធានរបស់ស្វាមីភរិយាឱ្យផលក្នុងថ្ងៃនោះ

គ្រានោះ ទីដែលនាយបុណ្ណៈភ្ជួរអំពីព្រលឹមនោះ បានក្លាយទៅជាដុំមាស ទាំងអស់ រហូតដល់លំអិតអាចម៍ដី តាំងនៅដូចជាគំនរផ្កាកណិការ ។ នាយ បុណ្ណៈភ្ញាក់ឡើង ក្រឡេកឃើញ ក៏និយាយទៅកាន់ភរិយាថា "ម្នាលនាងដ៏ ចម្រើន ទីដែលខ្ញុំភ្ជួរហើយនោះ ប្រាកដដល់ខ្ញុំជាមាសទាំងអស់ ព្រោះខ្ញុំបាន ភត្តក្នុងវេលាថ្ងៃពេក ភ្នែករបស់ខ្ញុំស្រវាំងទេដឹង?" ។ ចំណែកភរិយារបស់គាត់ ក៏ពោលថា "ទីនោះ ក៏រមែងប្រាកដសូម្បីដល់ខ្ញុំដូច្នោះដែរ" ។ គេក្រោកឡើង ដើរទៅកាន់ទីនោះ ចាប់យកមួយដុំ វាយនឹងជន្ទល់ ហើយដឹងថាជាមាស ទើបគិតថា "ឱ! ទានដែលយើងធ្វើហើយចំពោះព្រះធម្មសេនាបតី ឲ្យផលក្នុង ថ្ងៃនេះឯង យើងមិនអាចបិទបាំងទ្រព្យ មានប្រមាណប៉ុណ្ណេះទុកប្រើប្រាស់បាន ទេ" ទើបយកមាសដាក់ពេញថាសភត្តដែលភរិយានាំមក ហើយទៅកាន់រាជ- ត្រកូល បានឱកាសដែលព្រះរាជាព្រះរាជទានឲ្យហើយ ចូលទៅថ្វាយព្រះរាជា កាលព្រះរាជាត្រាស់សួរថា "នែបា អ្នកមានការអ្វី?" ទើបក្រាបទូលថា "បពិត្រ

ព្រះសម្មតិទេព ទីដែលខ្ញុំព្រះអង្គភ្ជួរហើយក្នុងថ្ងៃនេះទាំងអស់ ជាទីពេញទៅដោយមាសទាំងអស់ ព្រះអង្គគួរបង្គាប់រាជបុរស ឲ្យទៅនាំយកមកទុកចុះ" ។

ព្រះរាជា. អ្នកជានរណា ?

នាយបុណ្ណៈ. ខ្ញុំព្រះអង្គឈ្មោះបុណ្ណៈ ។

ព្រះរាជា. ក៏ថ្ងៃនេះ អ្នកបានធ្វើកម្មអ្វី ?

នាយបុណ្ណៈ. ខ្ញុំព្រះអង្គបានប្រគេនឈើជម្រះធ្មេញ និងទឹកខ្ពុរមាត់ដល់ព្រះធម្មសេនាបតីអំពីព្រលឹម មិនត្រឹមតែប៉ុណ្ណោះទេ ភរិយារបស់ខ្ញុំព្រះអង្គបានប្រគេនភត្តដែលនាងនាំមកដើម្បីខ្ញុំព្រះអង្គចំពោះព្រះធម្មសេនាបតីដែរ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយត្រាស់ថា "នែបា យើងនឹងធ្វើដូចម្ដេច?" ។

នាយបុណ្ណៈ. សូមព្រះអង្គទ្រង់បញ្ជូនរទេះច្រើនពាន់ ទៅនាំយកមាសនោះមកចុះ ។

ព្រះរាជាទ្រង់បានបញ្ជូនរទេះជាច្រើនទៅកាន់ទីនោះ ។ កាលរាជបុរសកាន់យកដោយពាក្យថា "របស់ព្រះរាជា" មាសដែលរាជបុរសកាន់យកហើយនោះៗ ក៏ទៅជាដីដូចដើមវិញ ។ ពួករាជបុរសទៅក្រាបទូលព្រះរាជា ព្រះរាជាត្រាស់សួរថា "ពួកអ្នកពោលពាក្យដូចម្ដេច? ទើបកាន់យក" ក៏ក្រាបទូលថា "ពួកខ្ញុំព្រះអង្គបានពោលពាក្យថា ជាព្រះរាជទ្រព្យរបស់ព្រះអង្គ" ។

ព្រះរាជាត្រាស់ថា នែអ្នកទាំងឡាយ នុ៎ះមិនមែនជាទ្រព្យរបស់យើងទេ

អ្នកទាំងឡាយចូរទៅ ចូរពោលពាក្យថា ជាទ្រព្យរបស់នាយបុណ្ណៈ ហើយកាន់យកចុះ ។ ពួករាជបុរសបានធ្វើហើយ ដោយប្រការដូច្នោះ ។ មាសដែលពួកគេកាន់យកហើយនោះ ក៏បានជាមាសពិតៗ ។ ពួករាជបុរសបានជញ្ជូនមាសទាំងអស់នោះ មកធ្វើជាគំនរត្រង់លាននៃព្រះរាជវាំង (មាសទាំងអស់នោះ) បានជាគំនរ មានកម្ពស់ប្រមាណ ៨០ ហត្ថ ។

## នាយបុណ្ណៈបានទទួលតំណែងជាសេដ្ឋី

ព្រះរាជាទ្រង់ត្រាស់ឲ្យអ្នកនគរប្រជុំគ្នា ហើយត្រាស់ សួរថា "នៅក្នុងនគរនេះ អ្នកដែលមានមាសប្រមាណប៉ុណ្ណេះ មានដែរឬ?" ។

អ្នកនគរ. មហាបពិត្រ មិនមានទេ ។

ព្រះរាជា. ក៏យើងនឹងឲ្យអ្វីដល់នាយបុណ្ណៈ ទើបគួរ?

អ្នកនគរ. ឆត្រជាតំណែងសេដ្ឋី ព្រះអង្គ ។

ព្រះរាជាទ្រង់ត្រាស់ថា "នាយបុណ្ណៈ ចូរជាសេដ្ឋីឈ្មោះពហុធនសេដ្ឋី" ហើយបានព្រះរាជទានឆត្រសម្រាប់សេដ្ឋី និងភោគៈដ៏ច្រើន ។ គ្រានោះ គេបានក្រាបទូលព្រះរាជាថា "បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គទាំងឡាយអាស្រ័យនៅក្នុងត្រកូលដទៃអស់កាលមានប្រមាណប៉ុណ្ណេះ សូមព្រះអង្គព្រះរាជទានទីលំនៅដល់ខ្ញុំព្រះអង្គទាំងឡាយចុះ" ។

ព្រះរាជាត្រាស់ថា "បើដូច្នោះ អ្នកចូរមើលគុម្ពឈើដែលនៅទិសខាងត្បូង ចូរនាំយកគុម្ពឈើនោះចេញហើយ ឲ្យជាងធ្វើទីនៅចុះ" ដូច្នេះហើយ ។

ត្រាស់ប្រាប់នូវទីផ្ទះរបស់សេដ្ឋីជំនាន់បូរាណ ។ គេក៏ឲ្យជាងធ្វើផ្ទះក្នុងទីនោះ ដោយ ២-៣ ថ្ងៃ ប៉ុណ្ណោះ កាលធ្វើគេហប្បវេសនមង្គល (មង្គលជាទីចូលកាន់ផ្ទះ) និងឆត្រមង្គល (មង្គលដែលទទួលឆត្រ) បានថ្វាយទានចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ។ គ្រានោះ ព្រះសាស្តាមុននឹងទ្រង់ធ្វើអនុមោទនាចំពោះទានបុណ្ណសេដ្ឋីនោះ ទើបបានត្រាស់អនុបុព្វីកថា ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនទាំង ៣ នាក់ គឺ បុណ្ណសេដ្ឋី ១ ភរិយារបស់គេ ១ នាងឧត្តរាដែលជាធីតារបស់បុណ្ណសេដ្ឋី ១ បានជាសោតាបន្ន ។

ធីតាបុណ្ណសេដ្ឋីបានជាភរិយាបុត្ររបស់សុមនសេដ្ឋី

ក្រោយមក សេដ្ឋីក្នុងក្រុងរាជគ្រឹះដណ្តឹងធីតារបស់បុណ្ណសេដ្ឋីឲ្យបុត្ររបស់ខ្លួន ។ បុណ្ណសេដ្ឋីពោលថា "ខ្ញុំឲ្យមិនបានទេ" កាលសេដ្ឋីក្នុងក្រុងរាជគ្រឹះពោលថា "លោកកុំធ្វើយ៉ាងនោះឡើយ លោកអាស្រ័យខ្ញុំអស់កាលមានប្រមាណប៉ុណ្ណេះ ទើបបានសម្បត្តិនេះ ចូរឲ្យធីតាដល់បុត្ររបស់ខ្ញុំចុះ" ទើបពោលថា "បុត្ររបស់លោកជាមនុស្សមិច្ឆាទិដ្ឋិ ចំណែកធីតារបស់ខ្ញុំឃ្លាតឆ្ងាយអំពីព្រះរតនៈទាំងបីហើយ រស់នៅមិនបាន ទើបខ្ញុំលើកធីតាឲ្យបុត្ររបស់លោកមិនបាន" ។ គ្រានោះ កុលបុត្រទាំងឡាយ មានសេដ្ឋី និងគហបតីជាដើមអង្វរបុណ្ណសេដ្ឋីថា "នែបុណ្ណៈ សូមលោកកុំទម្លាយនូវសេចក្តីស្និទ្ធស្នាលនឹងសេដ្ឋីក្នុងក្រុងរាជគ្រឹះនោះ ចូរលើកធីតាឲ្យបុត្ររបស់គេចុះ" ។ បុណ្ណសេដ្ឋីក៏ទទួលយល់ព្រមតាមពាក្យរបស់កុលបុត្រទាំងនោះ ហើយបានលើកធីតាឲ្យក្នុងតិថី

ពេញបូរមីខែអាសាឍ ។ តាំងពីវេលាចូលទៅកាន់ត្រកូលស្វាមីហើយ នាងមិនបានចូលទៅរកភិក្ខុ ឬភិក្ខុនី ឬឋ្វាយទាន ឬក៏ស្តាប់ធម៌ឡើយ ។ កាលកន្លងទៅបាន ២ ខែកន្លះ ដោយអាការយ៉ាងនេះ ។ ទើបសួរស្ត្រីបម្រើក្នុងសម្នាក់នោះថា "ពេលនេះខាងក្នុងវស្សានៅសល់ប៉ុន្មានទៀត?" ។

ស្ត្រីបម្រើ. នាងម្ចាស់ នៅសល់កន្លះខែទៀត ។

នាងបញ្ជូនដំណឹងទៅប្រាប់បិតារបស់នាងថា "ហេតុដូចម្តេច ទើបបិតាយកខ្ញុំមកដាក់គុកយ៉ាងនេះ? ការបិតាប្រកាសខ្ញុំថាជាស្ត្រីខាតលក្ខណ៍ ហើយធ្វើឲ្យជាទាសីនៃជនពួកដទៃ ប្រសើរជាង ការដែលបិតាលើកខ្ញុំឲ្យទៅត្រកូលមិច្ឆាទិដ្ឋិបែបនេះ មិនប្រសើរឡើយ តាំងពីខ្ញុំមកកាន់ត្រកូលនេះកាលណា ខ្ញុំមិនដែលបានធ្វើបុណ្យសូម្បីក្នុងបុញ្ញកម្មទាំងឡាយ មានការឃើញ ការជួបភិក្ខុទាំងឡាយឡើយ" ។ លំដាប់នោះ បិតារបស់នាងសម្តែងការមិនសប្បាយចិត្តដោយគិតថា "ធីតារបស់យើងដល់នូវសេចក្តីទុក្ខ" ទើបបញ្ជូនទ្រព្យទៅ ១៥.០០០ កហាបណៈ ដោយផ្តាំថា "ក្នុងនគរនេះ មានស្ត្រីគណិកាឈ្មោះសិរិមា កូនចូរនិយាយនឹងនាងថា នាងចូរទទួលយកទ្រព្យមួយថ្ងៃ ១.០០០ កហាបណៈចុះ នាំនាងមកដោយកហាបណៈទាំងនេះ ឲ្យធ្វើជាស្ត្រីបម្រើស្វាមីរបស់កូន ចំណែកកូន ចូរធ្វើបុណ្យទាំងឡាយចុះ" ។ នាងប្រើគេឲ្យហៅនាងសិរិមាមកហើយពោលថា "នែសម្លាញ់ នាងចូរទទួលយកកហាបណៈទាំងនេះ ហើយចូរបម្រើបុរសជាសម្លាញ់របស់នាងអស់កន្លះខែនេះចុះ " ។

នាងសិរិមានោះយល់ព្រមដោយពាក្យថា "ប្រពៃហើយ" ។ នាងឧត្តរា នាំនាងសិរិមាទៅកាន់សម្នាក់ស្វាមីរបស់ខ្លួន កាលស្វាមីរបស់នាងឃើញនាងសិរិមាមក ក៏សួរថា "នែឧត្តរា តើនាងមានបញ្ហាអ្វី?" នាងក៏ប្រាប់ថា "នាយខ្ញុំសូមឲ្យស្ត្រីដែលជាសម្លាញ់របស់ខ្ញុំ បម្រើអ្នកកន្លះខែនេះ ចំណែកខ្ញុំប្រាថ្នានឹងថ្វាយទាន និងស្តាប់ធម៌អស់កន្លះខែនេះ" ។ សេដ្ឋីបុត្រឃើញនាងសិរិមាមានរូបស្អាត កើតសេចក្តីស្នេហា ក៏យល់ព្រមថា "ល្អហើយ" ។

នាងឧត្តរាបានឱកាសធ្វើបុណ្យ

ចំណែកនាងឧត្តរា និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គស្តេចកុំយាងទៅកាន់ទីដទៃឡើយ សូមព្រះអង្គ ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះអង្គអស់កន្លះខែនេះចុះ" បានទទួលពាក្យប្តេជ្ញាអំពីព្រះសម្មាសម្ពុទ្ធហើយ មានចិត្តត្រេកអរថា "ឥឡូវនេះ អញនឹងបានបម្រើព្រះសាស្តាផង ស្តាប់ធម៌ផង តាំងពីពេលនេះទៅ រហូតដល់ថ្ងៃមហាបវារណា" ចាត់ចែងនូវកិច្ចទាំងពួងក្នុងផ្ទះអ្នកចំអិនភោជនាហារថា "អ្នកទាំងឡាយ ចូរចំអិនបបរយ៉ាងនេះ ចូរចំអិននំយ៉ាងនេះ" ។ គ្រានោះ ស្វាមីរបស់នាងគិតថា "ថ្ងៃនេះជាថ្ងៃមហាបវារណា" បានឈរនៅក្បែរបង្អួច សម្លឹងមើលទៅរោងបាយ ដោយគិតថា "នាងអន្ធពាលនោះ កំពុងធ្វើអ្វីហ្នុ៎?" ឃើញធីតាសេដ្ឋីនោះសៅហ្មងដោយញើស ប្រឡូកប្រឡាក់ដោយផេះ ប្រឡាក់ធ្យូង និងម្រែងភ្លើង កំពុងចាត់ចែងដូច្នោះ ក៏គិតថា "ពុទ្ធោអើយ ស្ត្រីអន្ធពាលនេះ

មិនសោយនូវសិរីសម្បត្តិដូច្នេះ ត្រឡប់ជាមានចិត្តត្រេកអរថា យើងនឹងបម្រើសមណៈត្រងោលទៅវិញ" សើចហើយ ត្រឡប់ទៅវិញ" ។ កាលសេដ្ឋីបុត្រនោះត្រឡប់ទៅវិញ នាងសិរិមាដែលឈរនៅជិតសេដ្ឋីបុត្រនោះគិតថា "សេដ្ឋីបុត្រនេះសម្លឹងមើលអ្វី ហើយសើចហ្ន៎" សម្លឹងមើលទៅតាមបង្អួចនោះ ឃើញនាងឧត្តរាហើយ គិតថា "សេដ្ឋីបុត្រនេះសើច ក៏ព្រោះឃើញនាងនេះ សេចក្តីស្និទ្ធស្នាលជាមួយនឹងនាងឧត្តរានុ៎ះ របស់សេដ្ឋីបុត្រនេះនៅមានដោយពិត" ។

## នាងសិរិមាចាក់នាងឧត្តរាយកទឹកដោះក្តៅស្រោច

បានឮថា នាងសិរិមានោះសូម្បីខ្លួនជាស្ត្រីខាងក្រៅ នៅក្នុងផ្ទះនោះអស់កន្លះខែ ហើយសោយសម្បត្តិនោះ ក៏មិនដឹងថាខ្លួន ជាស្ត្រីខាងក្រៅ បានធ្វើការសម្គាល់ថា "ខ្លួនជាស្ត្រីមេផ្ទះ" ក៏ចងអាឃាតនឹងនាងឧត្តរាថា "យើងនឹងញ៉ាំងសេចក្តីទុក្ខឲ្យកើតដល់វា" ទើបចុះចាកប្រាសាទ ដើរចូលទៅកាន់រោងបាយ យកវែកដួសទឹកដោះថ្លាដែលកំពុងពុះនៅលើទីចំអិននំ ហើយដើរសំដៅទៅរកនាងឧត្តរា ។ នាងឧត្តរាឃើញនាងសិរិមាដើរមក ក៏ផ្សាយមេត្តាទៅរកនាងថា "ស្ត្រីជាសម្លាញ់របស់អញមានឧបការៈចំពោះអញច្រើនណាស់ ចក្រវាឡនៅចង្អៀតពេកណាស់ ព្រហ្មលោក ក៏នៅទាបពេកណាស់ដែរ ចំណែកគុណរបស់ស្ត្រីជាសម្លាញ់យើងធំពេកណាស់ យើងអាស្រ័យនាង ទើបបានឱកាសថ្វាយទាន និងស្តាប់ធម៌ ប្រសិនបើអញមានសេចក្តីក្រោធចំពោះនាងសិរិមានោះ ទឹកដោះថ្លានេះ ចូរលោកយើងចុះ បើយើងមិនមានទេ ចូរកុំលោកឡើយ" ទឹក

ដោះថ្លាកំពុងពុះ ដែលនាងសិរិមាស្រោចលើសីសៈនាងឧត្តរានោះ បានក្លាយទៅជាវត្ថុដូចជាទឹកត្រជាក់ ។ លំដាប់នោះ ពួកទាសីរបស់នាងឧត្តរា ឃើញនាងសិរិមាញ៉ាំងវែកឲ្យពេញដោយទឹកដោះថ្លា កាន់យកមកទៀត ដោយគិតថា "ទឹកដោះថ្លានេះត្រជាក់" ក៏គំរាមថា "នែស្រីកំណាច (ស្រីប្រដៅក្រ) នាងចូរចៀសចេញ នាងមិនគួរយកទឹកដោះថ្លាដែលកំពុងពុះស្រោចលើនាងម្ចាស់របស់យើងទាំងឡាយឡើយ ក្រោកឡើងអំពីខាងនេះផង ខាងនោះផង ប្រើដៃផង ជើងផង វាយឲ្យដួលដេកលើផែនដី ។ នាងឧត្តរា មិនអាចនឹងហាមឃាត់នាងទាសីទាំងនោះបាន ។ គ្រានោះ នាងហាមឃាត់ទាសីទាំងឡាយដែលឈរនៅខាងលើនាងសិរិមានោះ ហើយសួរសិរិមាថា "នែនាងដ៏ចម្រើន នាងធ្វើកម្មធ្ងន់បែបនេះ ដើម្បីអ្វី?" ដូច្នេះហើយ បានឲ្យឱវាទនាងសិរិមា ឲ្យងូតដោយទឹកដែលលាយដោយទឹកក្តៅ បានលាបដោយប្រេង ដែលគេចំអិនអស់មួយរយដង ។

## នាងសិរិមាដឹងខ្លួនសូមទោសនាងឧត្តរា

ខណៈនោះ នាងសិរិមាដឹងខ្លួនថា ខ្លួនជាស្ត្រីខាងក្រៅ ហើយគិតថា "យើងយកទឹកដោះដែលកំពុងពុះ ទៅស្រោចលើនាងឧត្តរា ព្រោះហេតុត្រឹមតែការសើចរបស់ស្វាមី យើងធ្វើកម្មធ្ងន់ណាស់ នាងឧត្តរានេះមិនបញ្ជាពួកទាសីថា ពួកនាងចូរចាប់ស្ត្រីនេះ ត្រឡប់ជាហាមឃាត់ពួកទាសីទាំងអស់នោះក្នុងកាលដែលបៀតបៀនយើង បានធ្វើនូវកិច្ច ដែលបុគ្គលគប្បីធ្វើដល់យើង

ប្រសិនបើយើងមិនសូមឲ្យនាងអត់ទោសឲ្យទេ ក្បាលរបស់អញនឹងបែកជា ៧ ចំរៀក" ដូច្នេះហើយ ទើបក្រាបចុះទៀបជើងនាងឧត្តរា ហើយពោលថា "នាងម្ចាស់ សូមនាងម្ចាស់អត់នូវទោសនោះឲ្យខ្ញុំផងចុះ" ។

នាងឧត្តរា. ខ្ញុំជាធីតាដែលមានបិតា កាលបើបិតារបស់ខ្ញុំអត់ទោសឲ្យនាង ខ្ញុំក៏អត់ទោសឲ្យនាងដែរ ។

នាងសិរិមា. នាងម្ចាស់ សេចក្ដីនោះលើកទុកសិនចុះ ខ្ញុំនឹងឲ្យបុណ្ណ-សេដ្ឋីដែលជាបិតារបស់នាងអត់ឲ្យដែរ ។

នាងឧត្តរា. បុណ្ណសេដ្ឋីនោះ ជាបិតាបង្កើតរបស់យើងក្នុងវដ្ដៈ ប៉ុន្តែកាលបិតាបង្កើតរបស់យើងក្នុងវិវដ្ដៈអត់ទោសឲ្យ ខ្ញុំក៏អត់ទោសឲ្យដែរ ។

សិរិមា. អ្នកណាជាបិតាបង្កើតរបស់នាងក្នុងវិវដ្ដៈ ។

នាងឧត្តរា. ព្រះសម្មាសម្ពុទ្ធ ។

នាងសិរិមា. ខ្ញុំមិនមានសេចក្ដីស្និទ្ធស្នាលជាមួយនឹងព្រះសម្មាសម្ពុទ្ធទេ ។

នាងឧត្តរា. ខ្ញុំជានា ថ្ងៃស្អែកនេះ ព្រះសាស្ដាទ្រង់នាំភិក្ខុសង្ឃមកកាន់ទីនេះ នាងចូរកាន់យកគ្រឿងសក្ការៈតាមមានតាមបានមកកាន់ទីនេះ ហើយសូមឲ្យព្រះអង្គអត់ទោសឲ្យចុះ ។

## នាងសិរិមាសូមឱ្យព្រះសាស្ដាអត់ទោសឱ្យ

នាងសិរិមាយល់ព្រមដោយពាក្យថា "ប្រពៃហើយ នាងម្ចាស់" ក្រោក

ឡើងដើរទៅកាន់ផ្ទះរបស់ខ្លួន ហើយប្រើស្ត្រីដែលជាបរិវារ ៥០០ នាក់ ឲ្យត្រៀមខាទនីយៈ និងភោជនីយាហារមានប្រការផ្សេងៗ ស្អែកឡើងក៏កាន់សក្ការៈនោះមកផ្ទះនាងឧត្តរា មិនហ៊ានដាក់បាត្រភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានទេ ទើបឈរនៅក្នុងទីមួយ នាងឧត្តរាឃើញដូច្នោះ ក៏ទៅយកវត្ថុទាំងអស់នោះមកចាត់ចែងហើយ ។ ក្នុងវេលាស្រេចភត្តកិច្ច នាងសិរិមា ព្រមទាំងបរិវារក្រាបចុះទៀបព្រះបាទរបស់ព្រះសាស្តា ។

គ្រានោះ ព្រះសាស្តាត្រាស់សួរនាងសិរិមាថា "នាងមានកំហុសអ្វី?" ។

នាងសិរិមា. បពិត្រព្រះអង្គដ៏ចម្រើន កាលពីថ្ងៃម្សិល នាងខ្ញុំបានធ្វើកម្មឈ្មោះនេះ កាលនោះ ស្ត្រីដែលជាសម្លាញ់របស់នាងខ្ញុំព្រះអង្គ បានហាមឃាត់ទាសីដែលបៀតបៀននាងខ្ញុំព្រះអង្គ បានធ្វើឧបការៈដល់នាងខ្ញុំព្រះអង្គដោយពិត នាងខ្ញុំព្រះអង្គដឹងនូវគុណនៃស្ត្រីដែលជាសម្លាញ់ ទើបសូមឲ្យនាងអត់ទោសឲ្យ កាលនោះ នាងពោលនឹងនាងខ្ញុំព្រះអង្គថា កាលបើព្រះអង្គទ្រង់អត់ទោសឲ្យនាងខ្ញុំព្រះអង្គ ទើបនាងអត់ទោសឲ្យដែរ ។

ព្រះសាស្តា. ឧត្តរា បានឮថា យ៉ាងនោះឬ ?

នាងឧត្តរា. ព្រះករុណា ព្រះអង្គ កាលពីថ្ងៃម្សិលស្ត្រីជាសម្លាញ់របស់នាងខ្ញុំព្រះអង្គ បានយកទឹកដោះដែលកំពុង ពុះមកស្រោចលើក្បាលរបស់នាងខ្ញុំព្រះអង្គពិតមែន ។

ព្រះសាស្តាត្រាស់សួរថា "ឧត្តរា កាលនោះ នាងគិតយ៉ាងណា ?

នាងឧត្តរា. បពិត្រព្រះអង្គដ៏ចម្រើន នាងខ្ញុំព្រះអង្គ គិតយ៉ាងនេះថា "ចក្រវាឡនេះចង្អៀតពេកណាស់ ព្រហ្មលោកក៏ទាបពេកដែរ គុណរបស់ស្ត្រីជាសម្លាញ់របស់នាងខ្ញុំព្រះអង្គប៉ុណ្ណោះ ទើបធំ ព្រោះនាងខ្ញុំព្រះអង្គអាស្រ័យនាង ទើបបានឱកាសធ្វើទាន និងស្តាប់ធម៌ ប្រសិនបើនាងខ្ញុំព្រះអង្គ មានសេចក្តីក្រោធលើនាង ទឹកដោះដ៏ក្តៅនេះ ចូរលោកខ្ញុំព្រះអង្គចុះ បើនាងខ្ញុំព្រះអង្គមិនមានសេចក្តីក្រោធទេ កុំរលាកឡើយ" ហើយបានផ្សាយមេត្តាទៅកាន់នាង ។

ព្រះសាស្តាត្រាស់ថា "ប្រពៃហើយ ឧត្តរា ការឈ្នះសេចក្តីក្រោធយ៉ាងនោះ ទើបគួរ ក៏ធម្មតាបុគ្គលអ្នកក្រោធ គប្បីឈ្នះដោយការមិនក្រោធ បុគ្គលដែលជេរគេ ផ្តាសាគេ គប្បីឈ្នះដោយការមិនជេរ (តប) មិនផ្តាសា (តប) បុគ្គលដែលកំណាញ់ស្វិតស្វាញ គប្បីឈ្នះដោយការឲ្យទាន បុគ្គលដែលនិយាយកុហក គប្បីឈ្នះដោយការពោលពាក្យពិត" ដូច្នេះហើយ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖-

៣. អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។

បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ ដោយការឲ្យ គប្បីផ្ចាញ់មនុស្សនិយាយពាក្យមិនពិត

ដោយពាក្យពិត ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា អក្កោធេន (ដោយសេចក្ដីមិនក្រោធ) សេចក្ដីថា បុគ្គលដែលក្រោធ គប្បីឈ្នះដោយមិនក្រោធ ។ បុគ្គលដែលមិនល្អ គឺអ្នកមិនចម្រើន គប្បីឈ្នះដោយអំពើល្អ បុគ្គលកំណាញ់ គឺ អ្នកស្វិតស្វាញគប្បីឈ្នះដោយចិត្តដែលគិតលះវត្ថុជារបស់ខ្លួន បុគ្គលនិយាយពាក្យឡេះឡោះគប្បីឈ្នះដោយពាក្យពិត ព្រោះហេតុនោះ ទើបព្រះសាស្ដាត្រាស់យ៉ាងនេះថា អក្កោធេន ជិនេ កោធំ ។បេ។ សច្ចេនាលិកវាទិនំ (គប្បីឈ្នះសេចក្ដីក្រោធដោយការមិនក្រោធ ។ល។ គប្បីឈ្នះបុគ្គលនិយាយពាក្យមិនពិត ដោយពាក្យពិត ។

ក្នុងកាលចប់ព្រះធម៌ទេសនា នាងសិរិមាព្រមដោយបរិវារទាំង ៥០០ នាក់ ក៏បានតាំងនៅក្នុងសោតាបត្តិផល ដូច្នេះឯង ។

ចប់ រឿងឧត្តរាឧបាសិកា

# ៤. រឿងបញ្ហារបស់ព្រះមហាមោគ្គល្លាន

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់ព្រះមហាមោគ្គល្លានត្ថេរ ត្រាស់ព្រះធម្មទេសនា នេះថា សច្ចំ ភណេ (បុគ្គលគប្បីពោលពាក្យសច្ចៈ) ជាដើម ។*

ព្រះមហាមោគ្គល្លាននៅទេវលោក

*សេចក្តីពិស្តារថា សម័យមួយ ព្រះថេរៈនិមន្តទៅកាន់ទេវលោក ឈរនៅទៀបទ្វារវិមាននៃទេពធីតាអ្នកមានសក្តិធំ ហើយសួរទេពធីតានោះ ដែលមកកាន់សម្នាក់របស់ខ្លួន ថ្វាយបង្គំហើយឈរនៅ ថា "នែទេពធីតា សម្បត្តិរបស់នាងច្រើនណាស់ នាងបានធ្វើកម្មអ្វី?" ។*

*ទេពធីតា. សូមលោកម្ចាស់ កុំសួរខ្ញុំព្រះករុណាធ្វើអ្វី ។*

*បានឮថា ទេពធីតានោះខ្មាសចំពោះព្រះថេរៈ ព្រោះកម្មតិចតួចរបស់ខ្លួន ទើបបានពោលយ៉ាងនេះ ។ ទេពធីតានោះ កាលព្រះថេរៈពោលថា "ចូរប្រាប់មកចុះ" ទើបប្រាប់ព្រះថេរថា "លោកម្ចាស់ដ៏ចម្រើន ទានក៏ខ្ញុំព្រះករុណាមិនបានថ្វាយ ការបូជាក៏ខ្ញុំព្រះករុណាមិនបានធ្វើ ព្រះធម៌ក៏មិនបានស្តាប់ ខ្ញុំព្រះករុណារក្សាត្រឹមតែពាក្យសច្ចៈប៉ុណ្ណោះ" ។*

*ព្រះថេរៈទៅកាន់ទ្វារវិមាននៃទេពធីតាដទៃៗ ហើយសួរទេពធីតាដទៃៗ ដែលមកហើយ ៗ កាលទេពធីតាទាំងនោះ មិនអាចទឹងលាក់លៀមព្រះថេរៈ*

បាន ទើបទេពធីតាមួយអង្គនិយាយមុនថា “លោកម្ចាស់ បណ្តាបុញ្ញកម្ម ក្នុងបុញ្ញកិរិយាវត្ថុទាំងឡាយ មានទានជាដើម ជាបុញ្ញកម្មដែលខ្ញុំព្រះករុណាបានធ្វើហើយ មិនមាន តែក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ ខ្ញុំព្រះករុណាជាទាសីនៃអ្នកដទៃ ចៅហ្វាយរបស់ខ្ញុំនោះកាចអាក្រក់ក្រៃលែងណាស់ តែងតែបំបែកក្បាលខ្ញុំដោយកំណាត់ឈើខ្លះ ដោយអង្កត់ឧសខ្លះ ដែលខ្លួនកាន់យកហើយៗ ខ្ញុំនោះកាលសេចក្តីក្រោធកើតឡើង ក៏ទូន្មានខ្លួនឯងប៉ុណ្ណោះថា ចៅ-ហ្វាយរបស់នាងជាធំ នឹងធ្វើនាងឲ្យមានលក្ខណៈខ្វាត់ខ្វាយក៏បាន នឹងកាត់នូវអវយវៈទាំងឡាយ មានច្រមុះជាដើមរបស់នាងក៏បាន ដូច្នេះហើយ ទើបមិនធ្វើសេចក្តីក្រោធឲ្យកើតឡើង ព្រោះហេតុនោះ ទើបខ្ញុំព្រះករុណាបាននូវសម្បត្តិនេះ” ។ អង្គដទៃៗ ក៏ប្រាប់ទានបន្តិចបន្តួចដែលខ្លួនធ្វើហើយ ដោយន័យជាដើមថា “លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណារក្សាចម្ការអំពៅ បានប្រគេនអំពៅមួយដើមដល់ភិក្ខុមួយរូប” ។ អង្គដទៃប្រាប់ថា “ខ្ញុំបានប្រគេនផ្លែទន្លាប់មួយផ្លែ” ។ អង្គដទៃប្រាប់ថា “ខ្ញុំបានប្រគេនផ្លែល្ពៅមួយផ្លែ” ។ អង្គដទៃប្រាប់ថា “ខ្ញុំបានប្រគេនផ្លែដំបូមួយផ្លែ” ។ អង្គដទៃប្រាប់ថា “ខ្ញុំបានប្រគេនដំឡូងមួយមើម” ។ អង្គដទៃប្រាប់ថា “ខ្ញុំបានប្រគេនស្ពៅមួយក្តាប់” ដូច្នេះហើយ ក៏ប្រាប់ថា ព្រោះហេតុនោះ ទើបពួកខ្ញុំបានសម្បត្តិនេះ” ។

ពោលពាក្យសច្ចៈប៉ុណ្ណោះ ក៏ទៅឋានសួគ៌បាន

ព្រះថេរៈបានស្តាប់បុញ្ញកម្ម ដែលទេពធីតាទាំងនោះធ្វើហើយ ទើបចុះ

ចាកស្ថានសួគ៌ ចូលទៅគាល់ព្រះសាស្តា ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលអាចដែរឬ ដើម្បីបាននូវទិព្វសម្បត្តិដោយហេតុត្រឹមតែពោលពាក្យពិត ត្រឹមតែរំលត់សេចក្តីក្រោធ ត្រឹមតែថ្វាយទាន មានផ្លែទន្ទាប់ជាដើមដ៏តិចតួចក្រៃពេក" ។

ព្រះសាស្តា. មោគ្គល្លាន ហេតុអ្វីទើបអ្នកសួរតថាគត ពួកទេពធីតាប្រាប់សេចក្តីនោះដល់អ្នកហើយ មិនមែនឬ?

មោគ្គល្លាន. ព្រះករុណា ព្រះអង្គ ។ បុគ្គលប្រហែលជាបានទិព្វសម្បត្តិដោយបុញ្ញកម្មត្រឹមតែប៉ុណ្ណោះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់ទៅកាន់ព្រះមោគ្គល្លានថា "មោគ្គល្លាន បុគ្គលពោលត្រឹមតែពាក្យពិតក្តី លះបង់សេចក្តីក្រោធក្តី ថ្វាយទានតែបន្តិចបន្តួចក្តី រមែងទៅកាន់ទេវលោកបានដោយពិត" ដូច្នេះហើយ ទើបបានត្រាស់ព្រះគាថានេះថា ៖-

៤. សច្ចំ ភណេ ន កុជ្ឈេយ្យ ទជ្ជា អប្បស្មិ យាចិតោ
ឯតេហិ តីហិ ឋានេហិ គច្ឆេ ទេវាន សន្តិកេ ។

បុគ្គលគួរពោលពាក្យពិត ១ មិនគួរក្រោធ ១ កាលគេសូមវត្ថុ
សូម្បីមានតិច ក៏គួរឲ្យ (តាមតិច) ១ បុគ្គលគប្បីទៅកើតក្នុង
សម្នាក់ទេវតាទាំងឡាយបាន ដោយហេតុទាំង ៣ នេះឯង ។

អធិប្បាយគាថា

*បណ្ដាបទទាំងនោះ បទថា **សច្ចំ ភណេ** (គួរពោលពាក្យសច្ចៈ) សេចក្ដីថា គប្បីសម្ដែង គឺ គប្បីពោលពាក្យពិត អធិប្បាយថា គប្បីតាំងមាំនៅក្នុងពាក្យពិត ។*

*បទថា **ន កុជ្ឈេយ្យ** (មិនគួរក្រោធ) បានដល់ មិនគួរក្រោធចំពោះបុគ្គលដទៃ ។ បទថា **យាចិតោ** (ត្រូវគេសូម) សេចក្ដីថា បព្វជិតអ្នកមានសីល ឈ្មោះថា អ្នកសូម ។ ពិតណាស់ បព្វជិតទាំងនោះ មិនសូមឡើយថា "អ្នកទាំងឡាយចូរឲ្យ" រមែងឈរនៅត្រង់ទ្វារផ្ទះ ក៏ពិតមែន ប៉ុន្តែដោយអត្ថ ឈ្មោះថា សូមដែរ បុគ្គលអ្នកមានសីល សូមហើយយ៉ាងនោះ កាលមានទេយ្យធម៌តិចតួច ក៏គប្បីឲ្យតិចតួច ។ បទថា **ឯតេហិ តីហិ** (ដោយឋានៈ ៣ នោះ) សេចក្ដីថា បណ្ដាហេតុទាំងនោះ សូម្បីហេតុត្រឹមតែមួយ បុគ្គលក៏អាចទៅកាន់ទេវលោកបាន ។*

*ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។*

ចប់ រឿងបញ្ហារបស់ព្រះមហាមោគ្គល្លាន

# ៥. រឿងបញ្ហាដែលភិក្ខុទូលសួរ

ព្រះសាស្តា កាលទ្រង់ប្រថាប់អាស្រ័យក្រុងសាកេត ទ្រង់គង់នៅក្នុងអញ្ជនវ័ន ប្រារព្ធបញ្ហាដែលភិក្ខុទាំងឡាយទូលសួរ បានត្រាស់ព្រះធម្មទេសនានេះថា **អហឹសកា យេ (មុនីពួកណាជាអ្នកមិនបៀតបៀន)** ជាដើម ។

ពីរនាក់ប្តីប្រពន្ធសម្តែងខ្លួនថាជាពុទ្ធបិតា និងពុទ្ធមាតា

ដូចបានស្តាប់មក ក្នុងកាលដែលព្រះមានព្រះភាគមានភិក្ខុសង្ឃចោមរោម ស្តេចយាងទៅកាន់ក្រុងសាកេតដើម្បីបិណ្ឌបាត ព្រាហ្មណ៍ចាស់ដែលមានប្រក្រតីនៅក្នុងក្រុងសាកេតម្នាក់ ដើរចេញចាកព្រះនគរ ជួបព្រះទសពលត្រង់ចន្លោះទ្វារ ក៏ក្រាបចុះទៀបព្រះបាទទាំងពីរ ហើយចាប់ព្ធដ៏កព្រះបាទយ៉ាងមាំពោលថា "នែបា ធម្មតាមាតា និងបិតាទាំងឡាយ បុត្រទាំងឡាយ គប្បីប្រតិបត្តិក្នុងកាលដែលលោកចាស់ជរាហើយ មិនមែនឬ? ហេតុអ្វី ទើបកូនមិនសម្តែងខ្លួនឲ្យប្រាកដដល់យើងទាំងឡាយ អស់កាលមានប្រមាណប៉ុណ្ណេះ? បិតាបានឃើញកូនហើយ ចំណែកមាតារបស់កូន មិនទាន់បានជួបកូននៅឡើយ ដូច្នេះកូនចូរទៅសួរសុខទុក្ខមាតារបស់កូនបន្តិចទៅ" លុះពោលដូច្នេះហើយ ក៏បាននាំព្រះសាស្តាទៅកាន់ផ្ទះរបស់ខ្លួន ។ ព្រះសាស្តាស្តេចយាងទៅកាន់ផ្ទះនោះហើយទ្រង់ប្រថាប់នៅលើអាសនៈដែលគេក្រាលទុក ជាមួយនឹងភិក្ខុសង្ឃ ។ ចំណែកព្រាហ្មណី ក្រាបទៀបព្រះបាទទាំងពីររបស់ ព្រះសាស្តាហើយទូលថា

"កូនសម្លាញ់ កូនទៅទីណាអស់កាលប្រមាណប៉ុណ្ណេះ? ធម្មតាមាតា និងបិតាទាំងឡាយ បុត្រធីតាទាំងឡាយ គប្បីបម្រើក្នុងកាលដែលខ្លួនចាស់ជរាហើយ មិនមែនឬ? ហើយញ៉ាំងបុត្រ និងធីតា ឲ្យថ្វាយបង្គំព្រះសាស្តាដោយពាក្យថា "អ្នកទាំងឡាយចូរមក ចូរថ្វាយបង្គំបងប្រុស" ។ ចំណែកពីរនាក់ប្តីប្រពន្ធនោះ មានចិត្តត្រេកអរ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ទទួលភិក្ខាក្នុងផ្ទះនេះអស់កាលជានិច្ចចុះ" កាលព្រះសាស្តាត្រាស់ថា "ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់រមែងមិនទទួលភិក្ខាតែក្នុងកន្លែងមួយ អស់កាលជានិច្ចទេ" ។ ទើបក្រាបទូលថា "បើដូច្នោះ សូមព្រះអង្គទ្រង់បញ្ជូនពួកមនុស្សដែលមកនិមន្តព្រះអង្គ ឲ្យមកសម្នាក់ខ្ញុំព្រះអង្គ" ។ ចាប់ពីពេលនោះមក ព្រះសាស្តាទ្រង់បញ្ជូនពួកជនដែលមកនិមន្តព្រះអង្គ ឲ្យទៅកាន់សម្នាក់ព្រាហ្មណ៍ ដោយព្រះតម្រាស់ថា "ពួកអ្នកចូរទៅប្រាប់ព្រាហ្មណ៍ចុះ" អ្នកដែលមកនិមន្តព្រះអង្គទាំងនោះ តែងតែទៅប្រាប់ព្រាហ្មណ៍ថា "យើងទាំងឡាយនិមន្តព្រះសាស្តាដើម្បីទទួលភត្តក្នុងថ្ងៃស្អែក" ។ ឲ្យតែថ្ងៃស្អែកឡើង ព្រាហ្មណ៍តែងតែកាន់ភាជនៈភត្ត និងភាជនៈសម្លអំពីផ្ទះរបស់ខ្លួនទៅកាន់ទីប្រថាប់នៃព្រះសាស្តា ។ ក្នុងកាលការនិមន្តទៅក្នុងទីដទៃមិនមានព្រះសាស្តាតែងតែទ្រង់ធ្វើភត្តកិច្ចក្នុងផ្ទះរបស់ព្រាហ្មណ៍នោះឯង ។ ចំណែកព្រាហ្មណ៍ និងព្រាហ្មណី ថ្វាយទេយ្យធម៌ចំពោះព្រះតថាគត ស្តាប់ធម្មកថាជានិច្ច ហើយក៏បានសម្រេចនូវអនាគាមិផល ។

## ព្រះសាស្ដាត្រាស់បុព្វប្រវត្តិរបស់ព្រាហ្មណ៍

ភិក្ខុទាំងឡាយបានសន្ទនាគ្នាក្នុងធម្មសភាថា "អ្នកមានអាយុទាំងឡាយ ព្រាហ្មណ៍ និងព្រាហ្មណីឈ្មោះឯណោះ ដឹងថា ព្រះបាទសុទ្ធោទនៈជាព្រះបិតារបស់ព្រះតថាគត ព្រះនាងមហាមាយាជាព្រះមាតាហើយ ប៉ុន្តែនៅតែហៅព្រះអង្គថា ជាបុត្ររបស់យើង ចំណែកព្រះសាស្ដាក៏ទ្រង់ទទួលដោយប្រការដូច្នោះដែរ តើមានហេតុដូចម្ដេចហ្ន៎ ព្រះសាស្ដាទ្រង់ព្រះសណ្ដាប់នូវកថារបស់ភិក្ខុទាំងនោះហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ទាំង ២ នាក់ ប្ដីប្រពន្ធនោះ រមែងហៅបុត្ររបស់ខ្លួនប៉ុណ្ណោះថា "បុត្រ" ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមក ទ្រង់សម្ដែងនូវការៈនៃព្រះអង្គ ជាបុត្ររបស់ព្រាហ្មណ៍ពីរនាក់ប្ដី-ប្រពន្ធនោះអស់ ៣.០០០ ជាតិថា "ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ព្រាហ្មណ៍នេះ ជាបិតារបស់តថាគត ៥០០ ជាតិ ជាប់ៗ គ្នា ជាឪពុកមា ៥០០ ជាតិ ជាឪពុកធំ ៥០០ ជាតិ ចំណែកព្រាហ្មណីនោះ ក៏បានជាមាតារបស់តថាគត ៥០០ ជាតិជាប់ៗ គ្នា ជាម្ដាយមីង ៥០០ ជាតិ ជាម្ដាយធំ ៥០០ ជាតិ តថា-គតចម្រើនវ័យក្នុងដៃរបស់ព្រាហ្មណ៍នោះ ១.៥០០ ជាតិ ចម្រើនវ័យក្នុងដៃរបស់ព្រាហ្មណី ១.៥០០ ជាតិយ៉ាងនេះ" ។ ហើយទ្រង់បានភាសិតព្រះគាថាទាំងនេះថា ៖-

ការបង្អោនចិត្ត សូម្បីចិត្តក៏ជ្រះថ្លាក្នុងបុគ្គលណា គេរមែង
ស្រឡាញ់ក្នុងបុគ្គលសូម្បីនោះ ដែលខ្លួនមិនធ្លាប់បានឃើញ

ដោយពិត សេចក្តីស្រឡាញ់នោះរមែងកើត ព្រោះអាស្រ័យ
ហេតុពីរប្រការយ៉ាងនេះ គឺ ព្រោះការនៅរួមគ្នាក្នុងកាលមុន
១ ព្រោះការទំនុកបម្រុងគ្នាក្នុងបច្ចុប្បន្ននេះ ១ ប្រៀបដូចជា
ផ្កាឈូកដុះក្នុងទឹកបាន (ព្រោះអាស្រ័យទឹកនិងភក់) ដូច្នោះ ។

ព្រះសាស្តាស្តេចយាងទៅកាន់ទីបូជាសពព្រាហ្មណ៍

ព្រះសាស្តា ទ្រង់អាស្រ័យត្រកូលនោះ អស់មួយត្រៃមាស ។ ចំណែកព្រាហ្មណ៍ និងព្រាហ្មណីនោះ ធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តផលហើយក៏បានបរិនិព្វាន ។ គ្រានោះ ជនទាំងឡាយធ្វើសក្ការៈដ៏ធំដល់ព្រាហ្មណ៍ និងព្រាហ្មណីនោះ លើកឡើងកាន់ផ្ទះកំពូលជាមួយគ្នា ហើយនាំទៅ ។ សូម្បីព្រះសាស្តាមានភិក្ខុ ៥០០ ជាបរិវារ ស្តេចក៏យាងទៅកាន់ទីប៉ាឆាជាមួយនឹងជនទាំងនោះដែរ ។ មហាជនចេញទៅដោយគិតថា "បានឮថា ព្រះមាតា និងព្រះបិតារបស់ព្រះពុទ្ធ ធ្វើមរណកាលហើយ ។ ព្រះសាស្តា ស្តេចចូលទៅប្រថាប់ឈរនៅក្នុងសាលាមួយខ្នង នៅជិតទីប៉ាឆានោះ ។ មហាជនមកថ្វាយបង្គំព្រះសាស្តាហើយ ឈរនៅក្នុងទីដ៏សមគួរមួយ ធ្វើបដិសណ្ឋារៈនឹងព្រះសាស្តា ហើយទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គកុំទ្រង់មានព្រះចិន្តាថា "ព្រះមាតា និងព្រះបិតារបស់ព្រះអង្គ ធ្វើមរណកាលហើយ" ។

ព្រះសាស្តាទ្រង់ត្រាស់ជរាសូត្រ

ព្រះសាស្តា ទ្រង់មិនហាមឃាត់មនុស្សទាំងនោះឡើយថា "អ្នកទាំងឡាយ

កុំពោលយ៉ាងនោះ” ទ្រង់រមិលមើលនូវអធ្យាស្រ័យរបស់បរិស័ទហើយ កាលនឹងទ្រង់សម្តែងធម៌ឲ្យសមគួរដល់ខណៈនោះ ទើបទ្រង់បានត្រាស់ជរាសូត្រនេះដោយន័យជាដើមថា ៖-

ជីវិតនេះមានប្រមាណតិចហ្ន៎ សត្វតែងស្លាប់សូម្បីតិចជាង
១០០ ឆ្នាំ ប្រសិនបើរស់ហួសពី ១០០ ឆ្នាំ សត្វនោះក៏តែង
ស្លាប់ព្រោះជរាដោយពិត” ។

ក្នុងកាលចប់ព្រះធម៌ទេសនា ធម្មាភិសម័យបានមានដល់សត្វ ៨ ម៉ឺន ៤ ពាន់ ។

ភិក្ខុទាំងឡាយ កាលមិនដឹងថាព្រាហ្មណ៍ និងព្រាហ្មណី បរិនិព្វានហើយ ក៏ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ភពខាងមុខរបស់ព្រាហ្មណ៍ និងព្រាហ្មណីយ៉ាងណាដែរ?” ។

## ព្រះអសេក្ខមុនីទៅកាន់ទីដែលមិនច្យុតិ

ព្រះសាស្តាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា អភិសម្បរាយ-ភព របស់ព្រះអសេក្ខមុនីទាំងឡាយបែបនោះ រមែងមិនមាន ព្រោះថា ព្រះអ-សេក្ខមុនីបែបនោះ រមែងដល់មហានិព្វានដែលមិនចេះច្យុតិ ដែលមិនចេះស្លាប់” ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖-

៥. អហឹសកា យេ មុនយោ និច្ចំ កាយេន សំវុតា
តេ យន្តិ អច្ចុតំ ឋានំ យត្ថ គន្ត្វា ន សោចរេ ។

ជនទាំងឡាយណា ជាអ្នកប្រាជ្ញ មិនបៀតបៀនសត្វដទៃ សង្រួម ហើយដោយកាយទ្វារ (ជាដើម) ជានិច្ច ជនទាំងឡាយនោះ រមែង ទៅកាន់ស្ថានដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែង មិនសោកស្តាយ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **មុនយោ** (មុនី) គឺ ព្រះអសេក្ខមុនីទាំង ឡាយសម្រេចមគ្គ និងផល ដោយមោនេយ្យបដិបទា ។

បទថា **កាយេន** (ដោយកាយ) ពាក្យនោះ ត្រឹមតែជាពាក្យប្រធាននៃ ធម្មទេសនាប៉ុណ្ណោះ អធិប្បាយថា សង្រួមហើយដោយទ្វារទាំង ៣ ។ បទថា **អច្ចុតំ** (មិនចុតិ) បានដល់ ទៀង ។ បទថា **ឋានំ** (ឋានៈ) បានដល់ ឋានៈ ដែលមិនកម្រើក គឺ ឋានៈដែលទៀងទាត់ឋិតថេរ ។ បទថា **យត្ថ** (ក្នុងឋានៈ ណា) ជាដើម សេចក្តីថា មុនីទាំងឡាយរមែងទៅកាន់ឋានៈ គឺ ព្រះនិព្វានជា ទីដែលបុគ្គលទាំងឡាយទៅហើយមិនសោកសៅ គឺ មិនក្តៅក្រហាយ ។

ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំង ឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងបញ្ហាដែលពួកភិក្ខុទូលសួរ

# ៦. រឿងនាងបុណ្ណាទាសី

*ព្រះសាស្តា កាលប្រថាប់នៅលើភ្នំគិជ្ឈកូដ ទ្រង់ប្រារព្ធទាសីរបស់សេដ្ឋីក្នុងក្រុងរាជគ្រឹះឈ្មោះបុណ្ណា ត្រាស់ធម្មទេសនានេះថា* ***សទា ជាគរមានានំ*** *(របស់បុគ្គលដែលភ្ញាក់គ្រប់កាល) ជាដើម ។*

នាងបុណ្ណាថ្វាយនំកន្ទក់ចំពោះព្រះពុទ្ធ

*បានស្តាប់មកថា ថ្ងៃមួយ សេដ្ឋីក្នុងនគររាជគ្រឹះបានឲ្យស្រូវជាច្រើនដល់នាងបុណ្ណាដើម្បីឲ្យនាងបុក ។ នាងអុជប្រទីបក្នុងពេលរាត្រីដើម្បីបុកស្រូវ មានខ្លួនជោកទៅដោយញើស ទើបចេញទៅឈរហាលខ្យល់នៅខាងក្រៅ ដើម្បីត្រូវការសម្រាក ។ ក្នុងសម័យនោះ ព្រះទព្វមល្លបុត្តជាអ្នកចាត់ចែងសេនាសនៈដើម្បីភិក្ខុទាំងឡាយ ។ ព្រះថេរៈញ៉ាំងម្រាមដៃឲ្យភ្លឺដើម្បីភិក្ខុទាំងឡាយដែលស្តាប់ធម៌ហើយ ទៅកាន់សេនាសនៈរៀងៗ ខ្លួន និម្មិតភិក្ខុទាំងឡាយដែលទៅខាងមុខៗ ដើម្បីប្រយោជន៍ដល់ការសម្តែងផ្លូវ ។ នាងបុណ្ណាឃើញភិក្ខុទាំងឡាយដែលត្រាច់ទៅលើភ្នំ ដោយពន្លឺនោះ ទើបគិតថា "យើងត្រូវទុក្ខបៀតបៀន ទើបមិនបានដេកសូម្បីនៅពេលនេះ ។ ចុះហេតុអ្វី លោកម្ចាស់ទាំងឡាយ លោកមិនសិងដែរ ដូច្នេះហើយ ក៏សម្គាល់ថា ការមិនសប្បាយនឹងមានដល់ភិក្ខុរូបខ្លះ ឬឧបទ្រវហេតុដោយសារពស់ នឹងមានក្នុងទីនោះហ្ន៎" កាន់យកកន្ទក់អំពីព្រលឹម ផ្សើមឲ្យទទឹកដោយទឹកហើយ ធ្វើនំលើបាតដៃ អាំង*

លើរងើកភ្លើង ខ្ចប់ដាក់ក្នុងថ្នក់ គិតថា "នឹងស៊ីនំទៅតាមផ្លូវទៅកាន់កំពង់ទឹក" ទើបកាន់ក្អមទឹក ដើរសំដៅទៅកាន់កំពង់ទឹក ។ ចំណែកព្រះសាស្តា ក៏ស្តេចយាងទៅកាន់ផ្លូវនោះដែរ ដើម្បីចូលកាន់ស្រុកបិណ្ឌបាត ។ នាងបុណ្ណាឃើញព្រះសាស្តាហើយ គិតថា "ក្នុងថ្ងៃដទៃៗ កាលយើងជួបព្រះសាស្តា ទេយ្យធម៌របស់យើងមិនមាន កាលទេយ្យធម៌មាន យើងមិនបានជួបព្រះសាស្តា ឥឡូវនេះ ទេយ្យធម៌ក៏មាន ទាំងព្រះសាស្តាក៏ប្រាកដនៅចំពោះមុខ ប្រសិនបើព្រះអង្គទ្រង់មិនគិតថា ទានរបស់យើងសៅហ្មង ឬក៏ប្រណីត ទ្រង់នឹងគប្បីទទួល យើងនឹងថ្វាយនំនេះចំពោះព្រះអង្គ" ដូច្នេះហើយ ក៏ដាក់ក្អមទឹកក្នុងចំណែកម្ខាង ថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ទទួលទានដ៏សៅហ្មងនេះដោយអនុគ្រោះចុះ" ។ ព្រះសាស្តាទ្រង់ទតមើលព្រះអានន្ទហើយទ្រង់បង្អោនបាត្រដែលមហារាជថ្វាយ ដែលព្រះអានន្ទនាំចេញមកថ្វាយទទួលនំ ។ ចំណែកនាងបុណ្ណា ដាក់នំនោះទៅក្នុងបាត្ររបស់ព្រះសម្មាសម្ពុទ្ធហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើនធម៌ដែលព្រះអង្គទ្រង់ឃើញហើយនោះ សូមសម្រេចដល់ខ្ញុំព្រះអង្គផង" ។ ព្រះសាស្តា ទាំងដែលទ្រង់ប្រថាប់ឈរនោះឯង បានធ្វើអនុមោទនាថា "ចូរសម្រេចយ៉ាងនោះចុះ" ។

## ព្រះសាស្តាទ្រង់សោយនំរបស់នាងបុណ្ណា

នាងបុណ្ណាគិតថា "ព្រះសាស្តាទ្រង់ធ្វើការសង្គ្រោះយើងក៏ពិត ប៉ុន្តែព្រះ

អង្គទ្រង់នឹងមិនសោយនំនោះទេ គង់នឹងឲ្យនំនោះដល់ក្អែក ឬក៏ឆ្កែខាងមុខមិនខាន ហើយស្តេចយាងទៅកាន់ដំណាក់របស់ព្រះរាជា ឬក៏ទៅកាន់ផ្ទះរបស់មហាមាត្យ នឹងសោយនូវភោជនដ៏ប្រណីតដោយពិត" ។ ព្រះសាស្តា ទ្រង់ជ្រាបវារៈចិត្តរបស់នាងហើយ ទើបទ្រង់ទតទៅកាន់ព្រះអានន្ទ ហើយទ្រង់សម្តែងអាការដើម្បីនឹងប្រថាប់គង់ ។ ព្រះថេរៈបានក្រាលចីវរថ្វាយ ។ ព្រះសាស្តាទ្រង់បានប្រថាប់គង់ធ្វើភត្តកិច្ចនៅខាងក្រៅព្រះនគរនោះឯង ។ ទេវតាក្នុងផែ្ទចក្រវាឡទាំងមូល បាននាំនូវឱជារស ដែលសមគួរដល់ទេវតា និងមនុស្សទាំងឡាយឲ្យដូចជាផ្លិតនៃឃ្មុំ ហើយដាក់ចូលទៅក្នុងនំនោះ ។ ចំណែកនាងបុណ្ណាក៏បានឈរមើលព្រះមានព្រះភាគទ្រង់ធ្វើភត្តកិច្ចនោះដែរ ។ ក្នុងវេលាស្រេចភត្តកិច្ចព្រះអានន្ទបានថ្វាយទឹក ។ ព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ត្រាស់ហៅនាងបុណ្ណាមក សួរថា "ម្នាលនាងបុណ្ណា ព្រោះហេតុអ្វី ទើបនាងរិះគន់សាវករបស់តថាគត?" ។

នាងបុណ្ណា. ខ្ញុំព្រះអង្គ មិនបានរិះគន់សាវករបស់ព្រះអង្គទេ ។

ព្រះសាស្តា. បើដូច្នោះ នាងសម្លឹងមើលសាវកទាំងឡាយរបស់តថាគតហើយ គិតយ៉ាងណា ?

នាងបុណ្ណា. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគិតយ៉ាងនេះថា យើងមិនបានដេក ព្រោះឧបទ្រព គឺ សេចក្តីទុក្ខ ចំណែកលោកម្ចាស់ទាំងឡាយមិនបានសិង ព្រោះមានហេតុអ្វី? ការមិនសប្បាយ ឬឧបទ្រពដោយសារសត្វ

សាហាវ មានពស់ជាដើម មានដល់ភិក្ខុរូបណាមួយឬ ។

សាវករបស់ព្រះពុទ្ធភ្ញាក់ជានិច្ច

ព្រះសាស្ដាទ្រង់ស្ដាប់នូវពាក្យរបស់នាងបុណ្ណានោះហើយ ក៏ត្រាស់ថា "បុណ្ណា នាងមិនបានដេក ព្រោះអន្តរាយ គឺ សេចក្ដីទុក្ខរបស់ខ្លួន ចំណែកសាវករបស់តថាគត មិនដេក ព្រោះជាអ្នកប្រកបរឿយៗ នូវធម៌ជាគ្រឿងភ្ញាក់រឭកគ្រប់កាល" ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៈ-

៦. សទា ជាគរមានានំ អហោរត្តានុសិក្ខិនំ
និព្វានំ អធិមុត្តានំ អត្ថំ គច្ឆន្តិ អាសវា ។

អាសវៈទាំងឡាយរបស់បុគ្គល អ្នកភ្ញាក់រឭកសព្វកាល
ជាអ្នកសិក្សាត្រៃសិក្ខា ទាំងថ្ងៃទាំងយប់ មានចិត្តចុះស៊ប់
កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អហោរត្តានុសិក្ខិនំ** (មានប្រក្រតីសិក្សាទាំងថ្ងៃទាំងយប់) បានដល់ សិក្សាត្រៃសិក្ខាទាំងថ្ងៃទាំងយប់ ។ បទថា **និព្វានំ អធិមុត្តានំ** (បង្អោនទៅកាន់ព្រះនិព្វាន) បានដល់ អ្នកមានអធ្យាស្រ័យក្នុងព្រះនិព្វាន ។ បទថា **អត្ថំ គច្ឆន្តិ** (រមែងដល់នូវការតាំងនៅមិនបាន) សេចក្ដីថា អាសវៈទាំងឡាយសូម្បីទាំងអស់របស់បុគ្គលបែបនោះ រមែងដល់ការតាំងនៅមិនបាន គឺ រមែងវិនាស បានដល់ មិនមាន ។

ក្នុងកាលចប់ព្រះធម៌ទេសនា នាងបុណ្ណាដែលឈរនៅក្នុងទីនោះឯង ក៏បានសម្រេចសោតាបត្តិផល ។ ទេសនាមានប្រយោជន៍ សូម្បីដល់បរិស័ទ ដែលមកប្រជុំគ្នាក្នុងទីនោះឯង ។

## ពួកភិក្ខុនាំគ្នាសរសើរព្រះសាស្ដា

ព្រះសាស្ដា លុះទ្រង់ធ្វើភត្តកិច្ចដោយនំកន្ទក់ ដែលចំអិនដោយរងើកភ្លើងហើយ ស្ដេចក៏យាងទៅកាន់វិហារវិញ ។ ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងធម្មសភាថា "អ្នកមានអាយុទាំងឡាយ អំពើដ៏កម្រដែលព្រះសម្មាសម្ពុទ្ធទ្រង់ធ្វើភត្តកិច្ចដោយនំកន្ទក់ចំអិនដោយរងើកភ្លើង ដែលនាងបុណ្ណាថ្វាយ ទ្រង់បានធ្វើហើយ" ។ ព្រះសាស្ដាស្ដេចមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វី?" កាលភិក្ខុទាំងឡាយ ក្រាបទូលថា "ដោយកថាឈ្មោះនេះ ព្រះអង្គ" ដូច្នេះហើយ ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលពីមុន តថាគតក៏បរិភោគនំកន្ទក់ ដែលនាងបុណ្ណានេះឲ្យហើយដែរ ហើយទ្រង់នាំអតីតនិទានមក ទ្រង់ត្រាស់ កុណ្ឌកសិន្ធវបោតកជាតក នេះ ឲ្យពិស្ដារថា ៖-

ព្រះពោធិសត្វ កាលនឹងសាកល្បង (សួរ) សេះសិន្ធវនោះ ទើបពោលគាថាទី ១ ថា "អ្នកធ្លាប់បរិភោគស្មៅដែលសល់ ដែលធ្លាប់បរិភោគបាយក្ដាំង និងកន្ទក់ហើយ នេះជាភោជនរបស់អ្នក ឥឡូវនេះ ហេតុអ្វីក៏អ្នកមិនបរិភោគ ។

សេះសិន្ធពស្តាប់ឮដូច្នោះហើយ ក៏បានពោល ២ គាថា ថា ៖-

បពិត្រមហាព្រហ្ម ជនទាំងឡាយមិនស្គាល់សត្វដែលគួរចិញ្ចឹមដោយជាតិ ឬដោយមារយាទដែលគួរទូន្មាន ក្នុងទីណា ក្នុងទីនោះ ប្ដីក៏ខ្ញុំមិនបរិភោគបាយក្តាំងនឹងកន្ទក់ច្រើន ។

ចំណែកខាងលោកស្គាល់ខ្ញុំច្បាស់ថា សេះនេះឧត្តមយ៉ាងណាៗ ខ្ញុំកាលដឹង ព្រោះអាស្រ័យអ្នកជាអ្នកដឹង ទើបមិនបរិភោគនូវកន្ទក់របស់អ្នក ។

ចប់ រឿងនាងបុណ្ណាទាសី

# ៧. រឿងអតុលឧបាសក

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធដល់ឧបាសកឈ្មោះ **អតុលៈ** ត្រាស់ព្រះធម្មទេសនានេះថា **បោរាណមេតំ** (ការនិន្ទា និងការសរសើរនោះ ជារបស់បូរាណ) ជាដើម ។*

អតុលៈក្រោធនឹងព្រះរេវតៈព្រោះលោកមិននិយាយជាមួយ

*សេចក្តីពិស្តារថា អតុលៈនោះជាឧបាសកអ្នកក្រុងសាវត្ថី មានឧបាសកជាបរិវារ ៥០០ នាក់ ថ្ងៃមួយ នាំពួកឧបាសកទាំងនោះទៅកាន់វិហារដើម្បីប្រាថ្នានឹងស្តាប់ក្នុងសម្នាក់ព្រះរេវតៈ ថ្វាយបង្គំព្រះរេវតៈហើយ អង្គុយក្នុងទីសមគួរមួយ ។ លោកដ៏មានអាយុអង្គនោះ ជាអ្នកត្រេកអរក្នុងសេចក្តីស្ងាត់ត្រាច់ទៅតែម្នាក់ឯង ដូចរាជសីហ៍ ព្រោះដូច្នោះ ទើបលោកមិនពោលពាក្យអ្វីៗ ជាមួយនឹងឧបាសកនោះ គេនោះក្រោធថា "ព្រះថេរៈរូបនេះមិនពោលពាក្យអ្វីៗ ជាមួយនឹងខ្លួន" ក្រោកឡើង ដើរទៅកាន់សម្នាក់ព្រះសារីបុត្តត្ថេរ ឈរក្នុងទីដ៏សមគួរមួយ កាលព្រះថេរៈពោលថា "ឧបាសកទាំងឡាយ អ្នកទាំងឡាយមកមានការអ្វី?" ពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណានាំឧបាសកទាំងនេះចូលទៅរកព្រះរេវតៈ ដើម្បីស្តាប់ព្រះធម៌ តែព្រះថេរៈមិនបានពោលពាក្យអ្វីៗ ជាមួយនឹងពួកខ្ញុំព្រះករុណាឡើយ ខ្ញុំខឹងលោកទើបមកកាន់ទីនេះ សូមលោកម្ចាស់សម្តែងធម៌ដល់ពួកខ្ញុំព្រះករុណាចុះ" ។ គ្រានោះ*

ព្រះថេរៈពោលថា “ឧបាសក បើដូច្នោះ អ្នកទាំងឡាយចូរអង្គុយចុះ” ហើយបានសម្ដែងអភិធម្មកថាយ៉ាងច្រើន ។

អតុលៈខឹងអ្នកនិយាយច្រើន

ឧបាសកនោះក្រោធថា “ដែលឈ្មោះថា អភិធម្មកថា ជាធម៌ល្អិតក្រៃពេក សុខុមក្រៃពេក ព្រះថេរៈសម្ដែងអភិធម្មតែម្យ៉ាងយ៉ាងច្រើន ពួកយើងមិនត្រូវការអភិធម្មទេ” ដូច្នោះហើយ បាននាំបរិស័ទទៅកាន់សម្នាក់ព្រះអានន្ទត្ថេរ កាលព្រះថេរៈសួរថា “មានការអ្វី ឧបាសក?” ពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំព្រះករុណាចូលទៅរកព្រះរេវតៈដើម្បីស្ដាប់ព្រះធម៌ មិនបានសូម្បីតែការរាក់ទាក់ និងការសំណេះសំណាលបន្តិចបន្តួច ក្នុងសម្នាក់របស់លោក ក៏ក្រោធខឹងហើយ ទើបទៅកាន់សម្នាក់ព្រះសារីបុត្រ សូម្បីព្រះថេរៈរូបនោះ ក៏បានសម្ដែងអភិធម្មតែម្យ៉ាង ល្អិតក្រៃពេក យ៉ាងច្រើនដល់ពួកខ្ញុំព្រះករុណា ពួកខ្ញុំព្រះករុណាខឹងព្រះថេរៈរូបនោះថា ពួកយើងមិនត្រូវការអភិធម្មទេ ទើបមកទីនេះ សូមលោកម្ចាស់សម្ដែងធម្មកថាដល់ពួកខ្ញុំព្រះករុណាចុះ” ។

ព្រះថេរៈ. បើដូច្នោះ ពួកអ្នកចូរអង្គុយស្ដាប់ចុះ ។

ព្រះថេរៈសម្ដែងព្រះធម៌តែបន្តិចបន្តួចដល់ពួកឧបាសកទាំងនោះ ធ្វើឲ្យយល់បានងាយ ។

អតុលៈខឹងអ្នកនិយាយតិច

ឧបាសកទាំងនោះខឹងព្រះថេរៈហើយ ទៅកាន់សម្នាក់ព្រះសាស្ដា ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះសាស្ដាត្រាស់សួរឧបាសកទាំងនោះថា “ឧបាសកទាំងឡាយ ពួកអ្នកមកធ្វើអ្វី?” ។

ពួកឧបាសក. បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គមកដើម្បីស្ដាប់ធម៌ ។

ព្រះសាស្ដា. ក៏ពួកអ្នក បានស្ដាប់ធម៌ហើយឬ ?

ពួកឧបាសក. បពិត្រព្រះអង្គដ៏ចម្រើន ដំបូង ពួកខ្ញុំព្រះអង្គចូលទៅរកព្រះរេវតៈ លោកមិនបានពោលពាក្យអ្វីៗ ជាមួយនឹងពួកខ្ញុំព្រះអង្គឡើយ ពួកខ្ញុំព្រះអង្គខឹងនឹងលោក ហើយក៏ទៅរកព្រះសារីបុត្រ ព្រះថេរៈនោះសម្ដែងអភិធម្មដល់ពួកខ្ញុំព្រះអង្គយ៉ាងច្រើន ពួកខ្ញុំព្រះអង្គកំណត់អភិធម្មនោះមិនបាន ក៏ក្រោធខឹង ហើយចូលទៅរកព្រះអានន្ទ ព្រះថេរៈនោះ សម្ដែងធម៌ដល់ពួកខ្ញុំព្រះអង្គតិចពេក ពួកខ្ញុំព្រះអង្គខឹងនឹងលោក ទើបមកកាន់ទីនេះ ។

ការនិន្ទា និងការសរសើរជារបស់បូរាណ

ព្រះសាស្ដាទ្រង់ស្ដាប់នូវពាក្យរបស់ឧបាសកទាំងនោះហើយ ក៏ត្រាស់ថា “អតុលៈ ប្រការនោះ គេធ្លាប់ប្រព្រឹត្តមកតាំងពីបូរាណនោះឯង ជនទាំងឡាយតែងនិន្ទា ទាំងបុគ្គលអ្នកអង្គុយស្ងៀម ទាំងបុគ្គលអ្នកនិយាយច្រើន ទាំងបុគ្គលអ្នកនិយាយតិច ព្រោះថា អ្នកដែលគេគប្បីនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាង រមែងមិនមាន សូម្បីព្រះរាជាទាំងឡាយ ជនពួកខ្លះក៏និន្ទា ពួក

ខ្លះក៏សរសើរ ផែនដីដ៏ធំក្តី ព្រះចន្ទ និងព្រះអាទិត្យក្តី ជាតុ មានអាកាសជាដើមក្តី បុគ្គលខ្លះនិន្ទា បុគ្គលខ្លះសរសើរ សូម្បីព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ប្រថាប់គង់សម្តែងធម៌កណ្តាលបរិស័ទទាំង ៤ ក៏ពួកខ្លះនិន្ទា ពួកខ្លះសរសើរ ការនិន្ទា និងសរសើររបស់បុគ្គលពាល មិនជាប្រមាណទេ ប៉ុន្តែបុគ្គលដែលត្រូវបណ្ឌិតអ្នកមានបញ្ញានិន្ទាហើយ ទើបឈ្មោះថា ជាការនិន្ទាពិតៗ បុគ្គលដែលបណ្ឌិតសរសើរហើយ ឈ្មោះថា ជាការសរសើរពិតៗ" ដូច្នេះហើយ ទ្រង់ទើបបានកាសិតព្រះគាថាទាំងនេះថា ៖-

៧. បោរាណមេតំ អតុល នេតំ អជ្ជតនាមិវ
និន្ទន្តិ តុណ្ហិមាសីនំ និន្ទន្តិ ពហុភាណិនំ
មិតភាណិម្បិ និន្ទន្តិ នត្ថិ លោកេ អនិន្ទិតោ ។
ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ
ឯកន្តំ និន្ទិតោ បោសោ ឯកន្តំ វា បសំសិតោ ។
យញ្ចេ វិញ្ញូ បសំសន្តិ អនុវិច្ច សុវេ សុវេ
អច្ឆិទ្ទវុត្តឹ មេធាវឹ បញ្ញាសីលសមាហិតំ
នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោ ។

ម្នាលអតុលៈ ការតិះដៀល និងការសរសើរនេះ ជារបស់បូរាណ ការតិះដៀល និងការសរសើរនេះ មិនមែនទើបនឹង

កើតឡើងក្នុងថ្ងៃនេះទេ (ព្រោះថា) ជនទាំងឡាយតែងនិន្ទាបុគ្គលអ្នកអង្គុយស្ងៀម ក៏មាន និន្ទាបុគ្គលអ្នកនិយាយច្រើន ក៏មាន និន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណ ក៏មាន (អ្នកណាៗ ក៏ដោយ) ក្នុងលោក ដែលមិនត្រូវគេនិន្ទា គ្មានឡើយ បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាង មិនមែនមានមកហើយតែក្នុងអតីតក៏ទេ នឹងមានទៅក្នុងអនាគតក៏ទេ មានតែក្នុងបច្ចុប្បន្ននេះក៏ទេ ។ បើអ្នកប្រាជ្ញទាំងឡាយសង្កេតមើលរាល់ៗ ថ្ងៃ ហើយសរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្តមិនដាច់ មានប្រាជ្ញា មានចិត្តតម្កល់ខ្ជាប់ក្នុងបញ្ញា និងសីល អ្នកណាគួរនឹងនិន្ទាបុគ្គល ដែលដូចជាគ្រឿងរបស់មាសជម្ពូនទនោះបាន សូម្បីទេវតា និងមនុស្សទាំងឡាយ ក៏សរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរ (ដូចគ្នា) ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា បោរាណមេតំ (នោះជារបស់បូរាណ) គឺការនិន្ទា និងការសរសើរនុ៎ះឯង ជារបស់បូរាណ ។ ព្រះមានព្រះភាគ ត្រាស់ហៅឧបាសកនោះថា "អតុល:" ។ បទថា នេតំ អជ្ជតនាមិវ (នោះមិនមែនមានដូចក្នុងថ្ងៃនេះ) សេចក្តីថា ការនិន្ទា ឬការសរសើរនេះ មិនមែនទើបនឹងកើតឡើងក្នុងថ្ងៃនេះ ក៏ទេ អធិប្បាយថា ពិតណាស់ ជនទាំងឡាយតែងនិន្ទា

បុគ្គលអ្នកអង្គុយស្ងៀមថា "ហេតុដូចម្តេច បុគ្គលនេះអង្គុយស្ងៀមដូចជាមនុស្សគ ដូចជាមនុស្សថ្លង់ ដូចជាមនុស្សមិនដឹងអ្វី" ដូច្នេះក៏មាន តែងនិន្ទាបុគ្គលអ្នកនិយាយច្រើនថា "ហេតុដូចម្តេច បុគ្គលនេះក៏ចចាកអារាកដូចជាស្លឹកត្នោតដែលត្រូវខ្យល់បក់ ពាក្យសម្តីរបស់បុគ្គលនេះ មិនមានទីបំផុត" ដូច្នេះក៏មាន តែងនិន្ទាដល់បុគ្គលអ្នកនិយាយល្មមប្រមាណថា "ហេតុដូចម្តេច បុគ្គលនេះសម្គាល់ពាក្យសម្តីដូចជាមាសប្រាក់ និយាយពីរបីមាត់ហើយអង្គុយស្ងៀម" ក៏មាន បុគ្គលដែលមិនត្រូវគេនិន្ទា រមែងមិនមានក្នុងលោកនេះ ដោយប្រការទាំងពួង ដោយប្រការយ៉ាងនោះ ។ បទថា **ន ចាហុ (មិនមែនមានហើយ)** ជាដើម បានដល់ មិនមែនមានមកហើយតែក្នុងអតីតក៏ទេ នឹងមានទៅក្នុងអនាគតក៏ទេ ។ ពីរបទថា **យញ្ចេ វិញ្ញូ (ប្រសិនបើវិញ្ញូជន...ណា)** សេចក្តីថា ការនិន្ទា ឬការសរសើររបស់ជនពាល មិនជាប្រមាណ តែបណ្ឌិតទាំងឡាយសង្កេតមើលហើយ គឺ ជ្រាបហេតុនៃការនិន្ទា ឬហេតុនៃការសរសើរហើយរាល់ៗ ថ្ងៃ រមែងសរសើរបុគ្គលណា អ្នកដែលមានឈ្មោះថា ប្រព្រឹត្តមិនដាច់ ព្រោះជាអ្នកប្រកបព្រមដោយសិក្ខាទាំងបីមិនដាច់ ឬការប្រព្រឹត្តទៅនៃជីវិតមិនដាច់ អ្នកដែលមានឈ្មោះថា មានបញ្ញា ព្រោះជាអ្នកប្រកបព្រមដោយលោកិយប្បញ្ញា និងលោកុត្តរប្បញ្ញា និងដល់ព្រមដោយចតុប្បារិសុទ្ធិសីល អ្នកណាគួរនឹងនិន្ទាបុគ្គលដែលដូចជាគ្រឿងអលង្ការនៃមាសជម្ពូនទ ដែលប្រាសចាកទោសនៃមាស ទាំងគួរដល់ការជំ និងការខាត់ ។ បទថា *ទេវាបិ (សូម្បីទេវតា និង*

**មនុស្សទាំងឡាយ)** ជាដើម បានដល់ ទេវតាក្តី មនុស្សជាបណ្ឌិតក្តី ក្រោកឡើងហើយ រមែងស្ញើចសរសើរនូវភិក្ខុនោះ ។ បទថា **ព្រហ្មុនាបិ (សូម្បីព្រហ្ម)** សេចក្តីថា មិនមែនត្រឹមតែទេវតា និងមនុស្សប៉ុណ្ណោះទេ ដែលសរសើរនោះ សូម្បីមហាព្រហ្មក្នុងម៉ឺនចក្រវាឡ ក៏សរសើរបុគ្គលនោះដែរ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ឧបាសកទាំង ៥០០ នោះ ក៏បានសម្រេចសោតាបត្តិផល ដូច្នេះឯង ។

ចប់ រឿងអតុលឧបាសក

# ៨. រឿងឆព្វគ្គិយភិក្ខុ

*ព្រះសាស្តា កាលប្រថាប់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា* ***កាយប្បកោបំ*** *(ការកម្រើកផ្លូវកាយ) ជាដើម ។*

*មូលបញ្ញត្តិការពាក់ទ្រនាប់ជើងឈើ*

*សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះសាស្តាទ្រង់ឮនូវសំឡេង* ***"ខដ: ខដ:"*** *នៃភិក្ខុទាំងនោះ ដែលជាអ្នកកាន់ឈើច្រត់ដោយដៃទាំងពីរ ពាក់ទ្រនាប់ជើងចង្រ្កមលើថ្មដា ទ្រង់ត្រាស់សួរថា "អានន្ទ នុ៎ះជាសំឡេងអ្វី?" ទ្រង់ជ្រាបថា "ជាសំឡេង ខដ: ខដ: នៃពួកឆព្វគ្គិយភិក្ខុដែលពាក់ទ្រនាប់ជើងឈើចង្រ្កម" ក៏ទ្រង់បញ្ញត្តិសិក្ខាបទ ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគួររក្សាទ្វារ មានកាយទ្វារជាដើម" ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ ទើបទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-*

*៨. កាយប្បកោបំ រក្ខេយ្យ　កាយេន សំវុតោ សិយា*
*កាយទុច្ចរិតំ ហិត្វា　កាយេន សុចរិតំ ចរេ*
*វចីបកោបំ រក្ខេយ្យ　វាចាយ សំវុតោ សិយា*
*វចីទុច្ចរិតំ ហិត្វា　វាចាយ សុចរិតំ ចរេ*
*មនោបកោបំ រក្ខេយ្យ　មនសា សំវុតោ សិយា*
*មនោទុច្ចរិតំ ហិត្វា　មនសា សុចរិតំ ចរេ*

កាយេន សំវុតា ធីរា  អថោ វាចាយ សំវុតា
មនសា សំវុតា ធីរា  តេ វេ សុបរិសំវុតា ។

បុគ្គលគប្បីរក្សានូវការកម្រើកកាយ គប្បីសង្រួមកាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្តកាយសុចរិត គប្បីរក្សានូវការកម្រើកវាចា គប្បីសង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្តវចីសុចរិត គប្បីរក្សានូវការកម្រើកចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោសុចរិត អ្នកប្រាជ្ញទាំងឡាយបានសង្រួមកាយ សង្រួមវាចា អ្នកប្រាជ្ញទាំងឡាយ បានសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថាសង្រួមហើយដោយប្រពៃ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា កាយប្បកោបំ (ការកម្រើកកាយ) បានដល់ គប្បីរក្សាកាយសុចរិតបីយ៉ាង ។ បទថា កាយេន សំវុតោ (សង្រួមកាយ) សេចក្តីថា គប្បីហាមឃាត់ការចូលទៅនៃទុច្ចរិតក្នុងកាយទ្វារ សង្រួមហើយ គឺ មានទ្វារបិទហើយ ក៏ព្រោះបុគ្គលលះបង់កាយទុច្ចរិតហើយ ប្រព្រឹត្តកាយសុចរិត ឈ្មោះថា រមែងធ្វើកម្មនោះ សូម្បីទាំងពីរយ៉ាង ព្រោះដូច្នោះ ទើបព្រះអង្គត្រាស់ថា កាយទុច្ចរិតំ ហិត្វា កាយេន សុចរិតំ ចរេ (គប្បីលះកាយទុច្ចរិតហើយ ប្រព្រឹត្តសុចរិតតាមផ្លូវកាយ) ។ សូម្បីក្នុងគាថាជាលំដាប់

តទៅ ក៏ន័យនេះដូចគ្នា ។ បទថា ***កាយេន សំវុតា ធីរា (ធីរជនទាំងឡាយសង្រួមផ្លូវកាយ)*** សេចក្តីថា បណ្ឌិតទាំងឡាយណា កាលមិនធ្វើកាយទុច្ចរិតមានបាណាតិបាតជាដើម ឈ្មោះថា បានសង្រួមកាយហើយ កាលមិនធ្វើវចីទុច្ចរិត មានមុសាវាទជាដើម ឈ្មោះថា បានសង្រួមវាចាហើយ កាលមិនធ្វើមនោទុច្ចរិត មានអភិជ្ឈាជាដើមឲ្យកើតឡើង ឈ្មោះថា បានសង្រួមចិត្តហើយ បណ្ឌិតទាំងនោះ ឈ្មោះថា សង្រួមហើយដោយប្រពៃ ដោយសព្វគ្រប់ គឺ រក្សាល្អហើយ គ្រប់គ្រងល្អហើយ មានទ្វារបិទល្អហើយក្នុងលោកនេះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះ ។

ចប់ រឿងឆព្វគ្គិយភិក្ខុ

## ចប់កោធវគ្គវណ្ណនា វគ្គទី ១៧

ក្នុងវគ្គនេះរួមមាន ០៨ រឿង


១. រឿងព្រះនាងរោហិណី
២. រឿងភិក្ខុមួយរូប
៣. រឿងឧត្តរាឧបាសិកា
៤. រឿងបញ្ហាព្រះមហាមោគ្គល្លាន
៥. រឿងបញ្ហាភិក្ខុទូលសួរ
៦. រឿងនាងបុណ្ណាទាសី
៧. រឿងអតុលឧបាសក
៨. រឿងឆព្វគ្គិយភិក្ខុ


## ចប់អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ តតិយភាគ

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

-លោកគ្រូអគ្គបណ្ឌិត .................................. $ 2.000 USA

-ឧបាសក តាំង សុផល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ $ 200 USA

-ឧបាសិកា តាំង ស៊ីថា ព្រមទាំងស្វាមី និងបុត្ត ......... $ 100 USA

-ឧបាសិកា តាំង ដល្លា ព្រមទាំងស្វាមី និងបុត្ត ......... $ 100 USA

-កុមារី តាំង សុមារតី .................................. $ 100 USA

-ឧបាសិកា រួច លាង ព្រមទាំងបុត្ត .................................. $ 100 AUS


នត្ថិ សន្តិ បរំ សុខំ
ព្រះរាជាណាចក្រកម្ពុជា